ព្រឹត្តិប័ត្ររបស់សមាគមដើម្បីច្បាប់ខ្មែរ

រួមសហការជាមួយវិទ្យាស្ថានវិជ្ជាជីវៈតុលាការនៃសាកលវិទ្យាល័យម្សៅម៉ូឡាំង លីយ៉ុង ៣

ក្រោមការដឹកនាំរបស់ :

M. W. DROSS, Professeur à l'Université lumière Lyon 2
M. le Doyen H. FULCHIRON, Professeur à l'Université Jean Moulin Lyon 3
M. M. GAILLARD, Professeur à l'Université lumière Lyon 2
M. F. MARMOZ, Maître de Conférences à l'Université Jean Moulin Lyon 3

វិធីសាស្ត្រគតិយុត្ត

- នីតិកម្ពុជា -

(១៩ លំហាត់ និង កំណែ នៃមុខវិជ្ជាចម្បងទាំង ៥ របស់នីតិ ដើម្បីហ្វឹកហ្វឺន
និងសិក្សាឱ្យកាន់តែស៊ីជំរៅ លើវិធីសាស្ត្រនៃការបំពេញការងាររបស់និស្សិតច្បាប់)

អ្នកសំរបសំរួល : លោក កាន ច័ន្ទមេត្តា, កញ្ញា ការីន កូចុំង, កញ្ញា បេអាទ្រីស ចាលីវ៉ែ

ក្រុមអ្នកនិពន្ធ :

លោក កាន ច័ន្ទមេត្តា, លោក កើត រិទ្ធ, កញ្ញា ការីន កូចុំង, អ្នកស្រី ចាំង ស៊ីណាត, អ្នកស្រី អូដ្រេ ឆាអ៊ីន, លោក ឈន សុភាព, លោក ថេង ច័ន្ទសង្ហារ, កញ្ញា អាន-ធីតា នរោត្តម, លោក នួន ផារ៉ែត្ត, កញ្ញា អេម៉ាណុយអែល ប៊ូរហ្គ័រ, អ្នកស្រី ផ្លូរ៉ង ដឺប៊ែរ, អ្នកស្រី ណន ប៊ុនណា, កញ្ញា បេអាទ្រីស ចាលីវ៉ែ, កញ្ញា ប៉ែន រ៉ានី, លោក លីម ស៊ុយហុង, លោក ស៊ូ សុជាតិ, លោក ស៊ុម សុខម្ហូ, លោក ស្សៀង ធីរិទ្ធ និង លោក នីកូឡា រីយ៉ាស ។

ក្រុមអ្នកបកប្រែ :

លោក កាន ច័ន្ទមេត្តា, លោក កើត រិទ្ធ, អ្នកស្រី ចាំង សីណាត, លោក ថេង ច័ន្ទសង្ហារ, កញ្ញា ប៉ែន រ៉ានី, លោក សន សោភ័ណ្ឌ, លោក ស៊ូ សុជាតិ, លោក ស៊ុម សុខម្ហូ លោក ស្សៀង ធីរិទ្ធ និងលោក ហ៊ែល ចំរើន ។

ចោះពុម្ពផ្សាយ ដោយ
សមាគមដើម្បីច្បាប់ខ្មែរ
២០០៦

Scanned with CamScanner

មាត្រា ៦៨ នៃច្បាប់ចុះថ្ងៃទី ០៥.០៣.២០០៣ ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធប្រហាក់ប្រហែល ចែងថា ការរំលោភបំពានលើសិទ្ធិអ្នកនិពន្ធដូចមានចែងក្នុងច្បាប់នេះ តាមរយៈការផលិត ការផលិតឡើងវិញ ឬការសម្តែង ឬការផ្សព្វផ្សាយនូវស្នាដៃដោយប្រើមធ្យោបាយបែបណាក៏ដោយ គឺជាបទល្មើសដែលត្រូវទទួលទោសតាមច្បាប់ ។ បទល្មើសនៃការផលិត ឬការបផលិតឡើងវិញ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០ "ប្រាំលាន"រៀល ទៅ ២៥.០០០.០០០ "ម្ភៃប្រាំលាន"រៀល ឬ/និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី ៦ "ប្រាំមួយ"ខែ ដល់ ១២ "ដប់ពីរ" ខែ ។ ករណីមិនរៀងចាល ត្រូវផ្តន្ទាទោសទ្វេដង ។

Scanned with CamScanner

ក្រុមអ្នកនិពន្ធ និងអ្នកបកប្រែ

លោក កាន ច័ន្ទមេត្តា : និស្សិតត្រៀមបណ្ឌិតនៅមហាវិទ្យាល័យនីតិសាស្ត្រនៃសាកលវិទ្យាល័យហ្សង់មូឡាំង លីយ៉ុង ៣

លោក កើត រិទ្ធ : និស្សិតត្រៀមបណ្ឌិតនៅមហាវិទ្យាល័យនីតិសាស្ត្រនៃសាកលវិទ្យាល័យហ្សង់មូឡាំង លីយ៉ុង ៣

កញ្ញា ការីន កូចុាំង : A.T.E.R នៅមហាវិទ្យាល័យនីតិសាស្ត្រនៃសាកលវិទ្យាល័យហ្សង់មូឡាំង លីយ៉ុង ៣

អ្នកស្រី ចាំង ស៊ីណាត : ចៅក្រម

អ្នកស្រី អូដ្រេ ឆាអ៊ីន : អធិការកិច្ចការងារ

លោក ឈន សុភាព : បណ្ឌិតនីតិសាធារណៈ នៅមហាវិទ្យាល័យនីតិសាស្ត្រនៃសាកលវិទ្យាល័យលុយមីញ្ហ៊ែរ លីយ៉ុង ២

លោក ថេង ច័ន្ទសង្ហារ : និស្សិតត្រៀមបណ្ឌិតនៅមហាវិទ្យាល័យនីតិសាស្ត្រនៃសាកលវិទ្យាល័យលុយមីញ្ហ៊ែរ លីយ៉ុង ២

កញ្ញា អាន-ធីតា នរោត្តម : និស្សិតត្រៀមបណ្ឌិតនៅមហាវិទ្យាល័យនីតិសាស្ត្រនៃសាកលវិទ្យាល័យប៉ារីស ១

លោក នួន ជាវ័ត្ត : និស្សិតត្រៀមបណ្ឌិតនៅមហាវិទ្យាល័យនីតិសាស្ត្រនៃសាកលវិទ្យាល័យ ហ្សង់មូឡាំង លីយ៉ុង ៣

កញ្ញា អេម៉ាណុយអែល ប៊ូរប៉្លែ : អ្នកច្បាប់, ការិយាល័យច្បាប់នៃអង្គការស្បៀងអាហារពិភពលោក, រ៉ូម, អ៊ីតាលី

អ្នកស្រី ផ្លឺរ៉ង ដឺប៊ែ : Maître de conférences នៅសាកលវិទ្យាល័យលុយមីញ្ហ៊ែរ លីយ៉ុង ២

អ្នកស្រី ណន ប៊ុនណា : និស្សិតត្រៀមបណ្ឌិតនៅមហាវិទ្យាល័យនីតិសាស្ត្រនៃសាកលវិទ្យាល័យហ្សង់មូឡាំង លីយ៉ុង ៣

កញ្ញា បេអាទ្រីស ប៉ាលីវ៉ែ : Maître de conférences ផ្នែកនីតិឯកជននៅសាកលវិទ្យាល័យហ្សង់មូឡាំង លីយ៉ុង ៣

កញ្ញា ប៉ែន រ៉ានី : គ្រូឧត្តមសិក្សាវេលាកាលនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រ សេដ្ឋកិច្ច

លោក លឹម ស៊ុយហុង : និស្សិតត្រៀមបណ្ឌិតនៅមហាវិទ្យាល័យនីតិសាស្ត្រនៃសាកលវិទ្យាល័យលុយមីញ្ហ៊ែរ លីយ៉ុង ២

លោក សន សោភណ្ឌ : គ្រូឧត្តមសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រ សេដ្ឋកិច្ច

លោក ស៊ូ សុជាតិ : និស្សិតត្រៀមបណ្ឌិតនៅមហាវិទ្យាល័យនីតិសាស្ត្រនៃសាកលវិទ្យាល័យលុយមីញ្ហ៊ែរ លីយ៉ុង ២

លោក ស៊ុម សុខម្ហូ : និស្សិតត្រៀមបណ្ឌិតនៅមហាវិទ្យាល័យនីតិសាស្ត្រនៃសាកលវិទ្យាល័យហ្សង់មូឡាំង លីយ៉ុង ៣

លោក សៀង ធិរិទ្ធ : គ្រូឧត្តមសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រ សេដ្ឋកិច្ច

លោក ទីកូឡា រីយ៉ាស : និស្សិតត្រៀមបណ្ឌិតនៅមហាវិទ្យាល័យនីតិសាស្ត្រនៃសាកលវិទ្យាល័យហ្សង់មូឡាំង លីយ៉ុង ៣

លោក ហ៊ែល ចំរើន : និស្សិតត្រៀមបណ្ឌិតនៅមហាវិទ្យាល័យនីតិសាស្ត្រនៃសាកលវិទ្យាល័យប៉ារីស ១ ។

Scanned with CamScanner

សេចក្តីថ្លែងអំណរគុណ

សមាគមដើម្បីច្បាប់ខ្មែរ ដែលមានសមាសភាពចូលរួមដោយអ្នកជំនាញវិជ្ជាជីវៈច្បាប់, សាស្ត្រាចារ្យ និងនិស្សិតត្រៀមបណ្ឌិត ជនជាតិចារាំង និងខ្មែរ សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ សំរាប់ការជួយគាំទ្រ និងលើកទឹកចិត្តក្នុងការតាក់តែង និងការបោះពុម្ពផ្សាយស្នៀវភៅនេះ ដល់ :

- សាស្ត្រាចារ្យណែនាំ
- វិទ្យាស្ថានវិជ្ជាជីវៈតុលាការនៃសាកលវិទ្យាល័យហ្សង់មូឡាំង លីយ៉ុង ៣ ។

យើងទាំងអស់គ្នាក៏សូមអរគុណផងដែរ ដល់និស្សិតថ្នាក់ពិសេសចារាំងឆ្នាំទី ១ ជំនាន់ ២០០៧ សំរាប់ការជួយផ្ទៀងផ្ទាត់អក្ខរាវិរុទ្ធ ។

Scanned with CamScanner

មាតិការឿង

សេចក្តីផ្តើម.....១

ភាគទី ១ : សលាកប័ត្រសេចក្តីសម្រេចតុលាការ..... ៥

ផ្នែកទី ១ : ធាតុផ្សំចាំបាច់ដើម្បីយល់ឱ្យបានល្អអំពីសេចក្តីសម្រេចតុលាការ..... ៦

កថាខណ្ឌទី ១ : ចំណេះដឹងអំពីការរៀបចំប្រព័ន្ធយុត្តាធិការ..... ៦

កថាខណ្ឌទី ២ : ចំណេះដឹងអំពីនីតិវិធី..... ៨

កថាខណ្ឌទី ៣ : ការយល់ដឹងពីវាក្យស័ព្ទគតិយុត្តរបស់សេចក្តីសម្រេចតុលាការ..... ២៤

កថាខណ្ឌទី ៤ : ការសិក្សាអំពីរចនាសម្ព័ន្ធនៃសេចក្តីសម្រេចតុលាការ.....៣២

ផ្នែកទី ២ : វិធីសាស្ត្ររៀបចំសលាកប័ត្រសេចក្តីសម្រេចតុលាការ..... ៥៨

កថាខណ្ឌទី ១ : ការបង្ហាញអំពីវិធីសាស្ត្ររៀបចំសលាកប័ត្រសេចក្តីសម្រេចតុលាការ..... ៥៨

កថាខណ្ឌទី ២ : លំហាត់អនុវត្តវិធីសាស្ត្រ.....៦៩

ផ្នែកទី ៣ : សលាកប័ត្រសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ..... ៥៨

កថាខណ្ឌទី ១ : មុខងាររបស់ក្រុមប្រឹក្សាធម្មនុញ្ញ ៥៨

កថាខណ្ឌទី ២ : រចនាសម្ព័ន្ធនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ..... ៥៨

កថាខណ្ឌទី ៣ : វិធីសាស្ត្រសាលកប័ត្រសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ១០៨

កថាខណ្ឌទី ៤ : លំហាត់អនុវត្តវិធីសាស្ត្រ.....១១០

ភាគទី ២ : អត្ថាធិប្បាយអត្ថបទ តាមន័យទូលាយ..... ១១៦

ផ្នែកទី ១ : បរិមាធិប្បាយអត្ថបទ និង អត្ថបទរបស់អ្នកនិពន្ធ..... ១១៦

កថាខណ្ឌទី ១ : ការបង្ហាញវិធីសាស្ត្រអត្ថាធិប្បាយអត្ថបទ និងអត្ថបទរបស់អ្នកនិពន្ធ..... ១១៦

កថាខណ្ឌទី ២ : លំហាត់អនុវត្តវិធីសាស្ត្រ ដើម្បីស្រង់យកគំនិតចម្បងនៃអត្ថបទ និងរៀបចំគំនិតទាំងនោះ..... ១២០

កថាខណ្ឌទី ៣ : លំហាត់អនុវត្តវិធីសាស្ត្រតាមដំណាក់កាលនីមួយៗ ១២៥

កថាខណ្ឌទី ៤ : លំហាត់អនុវត្តវិធីសាស្ត្រ..... ១២៩

ផ្នែកទី ២ : វិធីសាស្ត្រអត្ថាធិប្បាយសេចក្តីសម្រេចតុលាការ.....**១៤៨**

កថាខណ្ឌទី ១ : ការបង្ហាញវិធីសាស្ត្រ ១៤៨

កថាខណ្ឌទី ២ : លំហាត់អនុវត្តទាក់ទងនឹងមុខវិជ្ជានីតិរដ្ឋប្បវេណី..... ១៥២

Scanned with CamScanner

ភាគីទី ៣ : លំហាត់អនុវត្ត..... ១៦១
ផ្នែកទី ១ : ធាតុផ្សំនៃចំណេះដឹងចាំបាច់ ដើម្បីយល់អំពីវិធីសាស្ត្រលំហាត់អនុវត្ត..... ១៦១
កថាខណ្ឌទី ១ : ការផ្តួចផ្តើមការទាញរកហេតុផលគតិយុត្ត..... ១៦១
កថាខណ្ឌទី ២ : ការកំណត់ចរិតលក្ខណៈគតិយុត្ត..... ១៦៤

ផ្នែកទី ២ : វិធីសាស្ត្រលំហាត់អនុវត្ត..... ១៦៧
កថាខណ្ឌទី ១ : ការបង្ហាញអំពីវិធីសាស្ត្រ..... ១៦៧
កថាខណ្ឌទី ២ : លំហាត់អនុវត្តវិធីសាស្ត្រ..... ១៧៨

ភាគទី ៤ : បរិមាធិប្បាយគតិយុត្ត..... ២០៥
ផ្នែកទី ១ : វិធីសាស្ត្របរិមាធិប្បាយ.....២០៥
កថាខណ្ឌទី ១ : ការបង្ហាញវិធីសាស្ត្រ.....២០៥
កថាខណ្ឌទី ២ : លំហាត់ទាក់ទងនឹងការរៀបចំបង្កើតបន្លង់.....២១០
កថាខណ្ឌទី ៣ : ការអនុវត្តវិធីសាស្ត្រតាមដំណាក់កាលនីមួយៗរហូតដល់ដំណាក់កាលរៀបចំបន្លង់.....២១២

ផ្នែកទី ២ : លំហាត់អនុវត្តវិធីសាស្ត្រ.....២១៩
កថាខណ្ឌទី ១ : មុខវិជ្ជានីតិរដ្ឋប្បវេណី..... ២១៩
កថាខណ្ឌទី ២ : មុខវិជ្ជានីតិព្រហ្មទណ្ឌ.....២២៤
កថាខណ្ឌទី ៣ : មុខវិជ្ជានីតិពាណិជ្ជកម្ម..... ២៣០
កថាខណ្ឌទី ១ : មុខវិជ្ជានីតិការងារ.....២៣៨
កថាខណ្ឌទី ៥ : មុខវិជ្ជានីតិសាធារណៈ..... ២៤៦

អារម្ភកថា

ការបោះពុម្ពផ្សាយស្បៀវភៅ **វិធីសាស្ត្រគតិយុត្ត** គឺជាលទ្ធផលនៃការងាររបស់អ្នកផ្តើមគំនិត តាំងពីច្រើនឆ្នាំណាស់មកហើយ ។ យើងត្រូវកោតសរសើរពួកគេដែលពុំបានបោះបង់ចោលការងារនេះ ទោះមានការលំបាកយ៉ាងណាក៏ដោយ ។ វិទ្យាស្ថានសិក្សាផ្នែកតុលាការនៃទីក្រុងលីយ៉ុង មានសេចក្តីសោមនស្សរីករាយឥតឧបមាដែលបានលើកទឹកចិត្ត និងគាំទ្រសមិទ្ធិកម្មដ៏ប្រពៃមួយនេះ ។

វណ្ណកម្មមួយនេះឆ្លើយតបទៅនឹងតម្រូវការពីរយ៉ាងរបស់និស្សិតកម្ពុជា ដែលចាប់ផ្តើមសិក្សាផ្នែកច្បាប់ ហើយមានគោលដៅបំពេញវិជ្ជាជីវៈផ្នែកច្បាប់ និងតុលាការ ។

នីតិសាស្ត្រ គឺជាបច្ចេកទេសមួយដែលធ្វើអោយរដ្ឋអាចរៀបចំ និងចាត់ចែងរចនាសម្ព័ន្ធរបស់សង្គមមួយបាន ។ ក៏ដូចជាបច្ចេកទេសផ្សេងទៀតដែរ បច្ចេកទេសផ្នែកនីតិសាស្ត្រ តម្រូវអោយមានចំណេះធ្វើជាចាំបាច់ ។ វិចារណកិច្ចគតិ-យុត្ត និងគំនិតគតិយុត្ត មានវិធានរបស់ខ្លួនដាច់ដោយឡែកខុសពីវិធីសាស្ត្របែបប្រវត្តិសាស្ត្រ ឬបែបទស្សនវិជ្ជា ។ ការទទួលបាននូវចំណេះធ្វើបែបនេះ គឺជាគោលដៅជាអាទិភាពមួយនៃការសិក្សាច្បាប់ ។ ក្នុងន័យនេះ ស្បៀវភៅវិធីសាស្ត្រគតិយុត្ត នឹងក្លាយជាឧបករណ៍មួយដ៏មានតម្លៃ ។ លំហាត់ផ្សេងៗគ្នាដែលលើកឡើង និងគន្លឹះសល្យដ៏ល្អរបស់អ្នកនិពន្ធស្បៀវភៅ អាចអោយនិស្សិតទទួលបាននូវគំនិតប្រតិកម្មភ្លាមៗ ដែលជាប្រយោជន៍សម្រាប់ជោគជ័យក្នុងការប្រឡងនៅតាមសាកលវិទ្យាល័យ និងការប្រឡង ព្រមទាំងការប្រឡងប្រជែងចូលក្នុងជីវិតវិជ្ជាជីវៈ ។

វណ្ណកម្មនេះបង្ហាញនូវសគុណទីពីរទៀត ។ អ្នកនិពន្ធស្បៀវភៅមានបំណងចង់អោយលំហាត់ទាំងអស់សរសេរជាភាសាខ្មែរផង និងជាភាសាបារាំងផង ។ អ្នកវិជ្ជាជីវៈទៅថ្ងៃអនាគតដែលពេលនេះកំពុងតែអានអារម្ភកថា គឺជានិស្សិតដែលត្រូវតែមានជំនឿជឿជាក់ពីសារសំខាន់ចម្បងនៃការចេះដឹងយ៉ាងហោចណាស់ក៏ភាសាបរទេសចំនួនមួយដែរ ។ ការបើកចំហរទៅកាន់ពិភពលោកដែលគេហៅថា សកលភាវូបនីយកម្ម គឺជាប្រភពនៃធនធាន ហើយក៏ជាឱកាសមួយសម្រាប់យល់ពីគំនិត និងប្រពៃណីផ្នែកគតិយុត្តរបស់គ្នាទៅវិញទៅមកដែរ ។ ហេតុនេះ គេត្រូវកត់សម្គាល់ពីអត្ថប្រយោជន៍ដែលនិស្សិតអាចទាញយកបានពីទិដ្ឋភាពដ៏សែនវិជ្ជមានពីស្បៀវភៅទីមួយស្តីអំពីវិធីសាស្ត្រគតិយុត្ត បោះពុម្ពផ្សាយជាពីរភាសា នៅព្រះរាជាណាចក្រកម្ពុជា ។

ជាទីបញ្ចប់ យើងសូមជូនពរដល់និស្សិតទាំងអស់អោយប្រើប្រាស់ស្បៀវភៅនេះអោយបានល្អ ហើយជូនប្រទះតែជោគជ័យក្នុងអំឡុងពេលសិក្សានៅសាកលវិទ្យាល័យរបស់ខ្លួន ។

លោក អែវ ក្រុស
នាយកវិទ្យាស្ថានសិក្សាផ្នែកតុលាការនៃទីក្រុងលីយ៉ុង

លោក ហ្សង់ ម៉ាកម៉ូស
នាយករងវិទ្យាស្ថានសិក្សាផ្នែកតុលាការនៃទីក្រុងលីយ៉ុង

Scanned with CamScanner

សេចក្តីផ្តើម

Scanned with CamScanner

សេចក្តីផ្តើម

ដើម្បីក្លាយជាអ្នកច្បាប់ និស្សិតច្បាប់ត្រូវមានចំណេះដឹងរឹងមាំ ។ មូលដ្ឋាននៃចំណេះដឹងមួយនឹងត្រូវផ្តល់អោយនិស្សិតច្បាប់ ក្នុងអំឡុងពេលសិក្សានៅសាកលវិទ្យាល័យដែលបន្ទាប់មកទៀតនិស្សិត អាចបង្កើនចំណេះដឹងរបស់ខ្លួនតាមរយៈបទពិសោធជាក់ស្តែង និងការស្រាវជ្រាវបន្ថែមទៀត ក្នុងអំឡុងពេលប្រកបវិជ្ជាជីវៈរបស់ខ្លួន ។

ប្រភពនៃចំណេះដឹងទីមួយរបស់និស្សិត គឺមេរៀនដែលសាស្ត្រាចារ្យបានផ្តល់អោយក្នុងពេលសិក្សា ទោះជាការសិក្សាក្នុងថ្នាក់រូមក្តី ឬថ្នាក់ការងារប្រតិបត្តិក្តី ។ ដើម្បីអោយការបង្រៀនមានប្រសិទ្ធិភាព បានន័យថាសាស្ត្រាចារ្យអាចផ្ទេរចំណេះដឹងរបស់ខ្លួនបានយ៉ាងពិតប្រាកដ និស្សិតត្រូវមានអាកប្បកិរិយាសកម្មនៅក្នុងពេលរៀន ដោយនិស្សិតត្រូវយកចិត្តទុកដាក់ចំពោះពាក្យសំដីទាំងប៉ុន្មានរបស់សាស្ត្រាចារ្យ ពោលគឺទាមទារអោយមានវិន័យមួយយ៉ាងប្រាកដក្នុងការតាមដានមេរៀនក្នុងថ្នាក់រូម និងថ្នាក់ការងារប្រតិបត្តិ ។ ប៉ុន្តែ ការស្តាប់តែម្យ៉ាងពុំគ្រប់គ្រាន់ទេ និស្សិតដែលគ្រាន់តែស្តាប់គ្រូពន្យល់ នឹងមានអារម្មណ៍ថា ចងចាំខ្លឹមសារសំខាន់ៗនៃមេរៀន ពេលចេញពីថ្នាក់រៀនទៅ តែនិស្សិតនោះនឹងដឹងថាប៉ុន្មានថ្ងៃ ឬសប្តាហ៍ក្រោយមក ឬក៏ប៉ុន្មានខែ ឬឆ្នាំក្រោយមកទៀត នៅពេលដែលខ្លួនត្រូវចូលរួមក្នុងការប្រឡងប្រជែងអ្វីមួយ ខ្លួនហាក់ដូចជាចាំមិនច្បាស់ទាល់តែសោះ ។ ដើម្បីចៀសវាងនូវផលវិបាកបែបនេះ គេត្រូវផ្សារភ្ជាប់ការស្តាប់យ៉ាងយកចិត្តទុកដាក់ក្នុងពេលរៀន ជាមួយនឹងការកត់ត្រាយ៉ាងមានប្រសិទ្ធិភាព ។ ដូច្នេះ និស្សិតអាចចងចាំមេរៀនឡើងវិញបាន ដោយសារខ្លឹមសារនៃកំណត់ត្រារបស់ខ្លួននេះ ។ និស្សិតពុំអាចកត់ត្រារាល់ពាក្យសំដីទាំងអស់របស់សាស្ត្រាចារ្យបានទេ ព្រោះសាស្ត្រាចារ្យម្នាក់ៗតែងនិយាយញាប់ ។ ហេតុនេះ និស្សិតត្រូវត្រងត្រាប់កត់ត្រាតែអ្វីដែលជាខ្លឹមសារបានហើយ ដោយជ្រើសរើសយកតែពត៌មានណាដែលចាំបាច់ប៉ុណ្ណោះ ។ អាចធ្វើយ៉ាងនេះបាន គឺទាមទារឱ្យនិស្សិតមានសមត្ថភាពបែងចែកធាតុសំខាន់ចម្បង និងធាតុបន្ទាប់បន្សំ ។ តាមរយៈការសិក្សាបន្តិចម្តងៗ ប្រតិបត្តិការខាងលើនឹងអាចធ្វើទៅបានយ៉ាងងាយស្រួល ។ និស្សិតត្រូវរក្សាទុកកំណត់ត្រារបស់ខ្លួន ព្រោះនឹងមានប្រយោជន៍ នៅពេលដែលខ្លួនដាក់ពាក្យធ្វើការ ឬចូលរួមក្នុងការប្រឡងប្រជែងផ្នែករដ្ឋបាល ឬផ្នែកតុលាការ ។ និស្សិត ឬបេក្ខជនប្រឡង អាចធ្វើការរំលឹកមេរៀនរបស់ខ្លួនឡើងវិញ តាមរយៈកំណត់ត្រានោះ ។ ប៉ុន្តែ យើងសូមផ្តល់អនុសាសន៍ថា និស្សិតមិនត្រូវរង់ចាំដល់ពេលចុងក្រោយទើបចាប់ផ្តើមអាន ឬរំលឹកមេរៀនរបស់ខ្លួននោះ ។ និស្សិតល្អម្នាក់ គឺជានិស្សិតដែលនឹងអានឡើងវិញនូវមេរៀនរបស់ខ្លួន យ៉ាងរ៉ាប់រហ័សក្រោយពីរៀននៅក្នុងថ្នាក់រួចហើយ ដើម្បីផ្ទៀងផ្ទាត់មើលថា ខ្លួនបានយល់មេរៀនឬទេ និងដើម្បីសិក្សាមេរៀននោះតែម្តង ។ ក្នុងអំឡុងពេលឆ្នាំសិក្សា និស្សិតត្រូវតែអានឡើងវិញ ។ ធ្វើដូច្នេះ ចំណេះដឹងរបស់ខ្លួននឹងមិនបាត់បង់ទៅទេ បន្ទាប់ពីពេលប្រឡង ឬប្រឡងប្រជែង តែចំណេះដឹងទាំងនោះ នឹងស្ថិតនៅក្នុងការចងចាំរបស់ខ្លួនជារៀងរហូត ។

ប្រភពទីមួយនៃចំណេះដឹងនេះ គឺជាមូលដ្ឋានមួយដែលនិស្សិតត្រូវពង្រីកឡើងដោយការងារផ្ទាល់របស់ខ្លួន ។ មេរៀនក្នុងថ្នាក់រូម និងការងារប្រតិបត្តិត្រូវបំពេញបន្ថែមដោយអំណានស្បៃវែកៅ អត្ថបទ សេចក្តីសម្រេចរបស់តុលាការ

Scanned with CamScanner

និងអត្ថបទច្បាប់ក្នុងន័យសំភារៈ ទាំងអស់នេះបង្កើតជាប្រភពចំណេះដឹង ។ ដើម្បីអាចទាញយកប្រយោជន៍ពីប្រភពទាំងនេះបានភ្លាមៗ បន្ទាប់ពីខ្លួនចូលមកក្នុងសាកលវិទ្យាល័យ និស្សិតត្រូវរកមើលកន្លែងណាដែលខ្លួនអាចរកព័ត៌មានទាំងនោះបាន ។ កន្លែងទាំងនោះស្ថិតនៅក្នុងមហាវិទ្យាល័យនីតិសាស្ត្រ ដូចជានៅបណ្ណាល័យ និងកន្លែងសហប្រតិបត្តិការបារាំង សម្រាប់និស្សិតនៃសាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលនៅទីនោះនិស្សិតអាចរកឃើញនូវកម្រងច្បាប់ កម្រងវិស្វកប្រវត្តិដែលមានអត្ថបទផ្សេងៗរបស់អ្នកច្បាប់កម្ពុជាឬបារាំង ទាក់ទងនឹងនីតិកម្ពុជា។ កន្លែងស្រាវជ្រាវក៏មានដែរនៅក្រៅមហាវិទ្យាល័យនីតិសាស្ត្រ ដូចជាបណ្ណសារដ្ឋានជាតិ ឬបណ្ណាល័យជាតិ ។ គេក៏អាចរកព័ត៌មានទាំងនេះតាមរយៈអ៊ីនធើណែតបានដែរ ដោយធ្វើការស្រាវជ្រាវលើគេហទំព័រជាផ្លូវការ ឬមានលទ្ធភាពបញ្ចាទិញសៀវភៅ ឬថតចម្លងសៀវភៅដែលស្ថិតនៅបរទេស[1] ។ យើងសូមជូនដំបូន្មានដល់និស្សិត ឬបេក្ខជនប្រឡងឱ្យកត់ត្រាទុកនូវអ្វីដែលខ្លួនបានអាននៅលើក្រដាសមួយសន្លឹក ដោយកត់ទុកអំពីប្រភពនៃអត្ថបទ កាលបរិច្ឆេទរបស់ច្បាប់ក្នុងន័យសំភារៈ ឈ្មោះអ្នកនិពន្ធអត្ថបទ ឬសៀវភៅណាមួយ ចំណងជើងអត្ថបទ ឬកាលបរិច្ឆេទនៃសេចក្តីសម្រេចរបស់តុលាការ បន្ទាប់មកសង្ខេបពីគំនិតសំខាន់ៗនៃអត្ថបទនោះនៅលើក្រដាស ។

តាមរយៈការងារនេះ និស្សិត ឬបេក្ខជនប្រឡង នឹងបង្កើតទុកនូវវប្បធម៌គតិយុត្តមួយ ។ ប៉ុន្តែ ចំណេះដឹងតែម្យ៉ាងក៏ពុំគ្រប់គ្រាន់ដែរ ។ អ្នកច្បាប់ដ៏ឆ្នើមម្នាក់ គឺជាអ្នកច្បាប់ដែលចេះប្រើប្រាស់ចំណេះដឹងរបស់ខ្លួន ពោលគឺចេះយកចំណេះដឹងនោះទៅធ្វើជាវិចារណកិច្ច ។ និស្សិត ឬបេក្ខជនប្រឡងមិនពូកែ គឺអ្នកដែលគិតថា នីតិសាស្ត្រគ្រាន់តែការបង្ហាញពីវិធានច្បាប់ដែលខ្លួនបានរៀនប៉ុណ្ណោះ ។ អ្នកច្បាប់ គឺជាអ្នកវិជ្ជាជីវៈម្នាក់ដែលមានវិធីសាស្ត្រធ្វើការងារពិសេសជាបន្ថែមទៅលើចំណេះដឹងរបស់ខ្លួនទៀត ។ និស្សិតដ៏ល្អម្នាក់ គឺជានិស្សិតដែលមានមិនត្រឹមតែចំណេះដឹងដែលខ្លួនបានទទួលប៉ុណ្ណោះទេ ថែមទាំងចេះប្រើប្រាស់វិធីសាស្ត្រធ្វើការងារទៀតផង ។

ជាដំបូង អ្នកច្បាប់គឺជាអ្នកវិជ្ជាជីវៈម្នាក់ដែលបំពេញការងារនៅក្នុងវិស័យច្បាស់លាស់មួយ ។ ហេតុដូចនេះហើយទើបដូចជាអ្នកវិជ្ជាជីវៈទាំងអស់ អ្នកច្បាប់ប្រើប្រាស់វាក្យស័ព្ទដោយឡែករបស់ខ្លួន ។ និស្សិត ឬបេក្ខជនប្រឡងត្រូវយកចិត្តទុកដាក់ ជាពិសេសនៅក្នុងការប្រើវាក្យស័ព្ទរបស់ខ្លួន ។ នៅក្នុងក្របខ័ណ្ឌនៃការសិក្សា និងក្រោយមកទៀតនៅក្នុងក្របខ័ណ្ឌនៃការងាររបស់ខ្លួន និស្សិតត្រូវច្បៀសវាងនូវវាក្យស័ព្ទទូទៅ ដោយយកចិត្តទុកដាក់តែវាក្យស័ព្ទច្បាប់ជាការគ្រប់គ្រាន់ ។ ការប្រើប្រាស់បច្ចេកពាក្យច្បាប់ជាការសំខាន់ ពុំអាចច្បៀសវាងបាន តែនេះពុំមែនតែជាការស្រើបស្រាលតាមសម័យក្នុងគោលដៅបែងចែកអ្នកច្បាប់ពីជនដែលពុំមែនជាអ្នកច្បាប់នោះទេ ។ ផលប្រយោជន៍នៃការប្រើប្រាស់បច្ចេកពាក្យច្បាប់គឺមានលក្ខណៈជ្រៅជ្រះខ្លាំងណាស់ ។ ពាក្យមួយក្នុងវិស័យច្បាប់មានអត្ថន័យជាក់លាក់ដែលជាគោលការណ៍ពុំមានពាក្យមានន័យដូចទេ ដោយហេតុថាពាក្យទាំងនេះនាំអោយមានការអនុវត្តវិធានពិសេស។ នីតិសាស្ត្រហាក់បីដូចជាទូដ៏ធំទូលាយមួយដែលមានថតជាច្រើន ហើយក្នុងថតនីមួយៗពោរពេញទៅដោយវិធានច្បាប់ពិសេស និងមានឈ្មោះមួយ ។ ប្រសិនបើយើងទាញថតទូមួយចេញមក គឺយើងទាញយកវិធានគតិយុត្តចេញមកដែរ ។ ដូច្នេះ គេមិន

[1] ដើម្បីទទួលបានព័ត៌មានច្រើនជាងនេះ សូមទាក់ទងមជ្ឈមណ្ឌលវប្បធម៌បារាំង។

Scanned with CamScanner

ត្រូវច្រឡំថតទូនោះទេ ។ ពាក្យច្បាប់មួយទាក់ទងនឹងរបបមួយ បានសេចក្តីថា ទាក់ទងនឹងអង្គនៃវិធានគតិយុត្តមួយ ។ គេពុំអាចប្រើប្រាស់ពាក្យមួយជំនួសពាក្យមួយទៀតបានទេ ។

ម្យ៉ាងវិញទៀត វាក្យស័ព្ទគតិយុត្តធ្វើអោយអ្នកច្បាប់យល់បានប្រសើរជាង ព្រោះវាក្យស័ព្ទនេះពុំធ្វើឱ្យមានភាពមិនច្បាស់លាស់ទេ ។ ឧទាហរណ៍ថា ប្រសិនបើពាក្យមោយភាពត្រូវបានប្រើប្រាស់ នេះជាបញ្ហាទាក់ទិននឹងការបង្កើតកិច្ចសន្យាណាមួយ ។ ផ្ទុយមកវិញ ប្រសិនបើយើងនិយាយពីរំលាយ គឺសំដៅដល់ការលំបាកពាក់ព័ន្ធនឹងការអនុវត្តកិច្ចសន្យា ។

នៅប្រទេសកម្ពុជា គេឃើញថា នៅមានភាពមិនច្បាស់លាស់នៅឡើយក្នុងការប្រើប្រាស់វាក្យស័ព្ទគតិយុត្ត ។ ពាក្យខ្លះអាចមានន័យច្រើន ដែលអាចនាំអោយមានការច្របូកច្របល់ចូលគ្នា។ សព្វថ្ងៃនេះគេឃើញមានឆន្ទៈនយោបាយដ៏ប្រាកដមួយ ដើម្បីបំពេញកង្វះខាតនេះ ក្នុងគោលដៅកំណត់អោយជាក់លាក់នូវវាក្យស័ព្ទគតិយុត្ត ។ ទាំងនេះគឺជាការងារដ៏យូរអង្វែងមួយដែលម្នាក់ៗត្រូវតែចូលរួមរួម ទាំងនិស្សិត និងបេក្ខជនប្រឡងផង ដោយព្យាយាមសាកល្បងប្រើប្រាស់ពាក្យច្បាប់ទាក់ទងនឹងស្ថានភាពមួយដែលខ្លួនត្រូវប្រឈមមុខ ។

លក្ខណៈសំខាន់ជាងនេះទៀតនោះ អ្នកច្បាប់ដ៏ល្អ គឺជាបុគ្គលដែលចេះដេញរកហេតុផល មានន័យថា ជាបុគ្គលដែលអាចប្រកាន់យកជំហរណាមួយ ប្រឈមមុខនឹងការលំបាក ដោយលើកឡើងពីអំណះអំណាងរបស់ខ្លួន ។ ហេតុនេះ បេក្ខជន ឬនិស្សិត មិនពូកែ គឺជនដែលពោលស្របជនដែលឆ្លើយតែបាទ ឬចាស ឬទេ តបទៅនឹងសំណួរដែលចោទសួរ ។ ផ្ទុយមកវិញ អ្នកច្បាប់ល្អអាចឆ្លើយបានតែទៅតាមវិចារណកិច្ចប្រកបដោយអំណះអំណាង ទៅតាមការគិតពិចារណាប៉ុណ្ណោះ ។ និស្សិតត្រូវតែរៀនសូត្រពីវិចារណកិច្ច ហើយលុះត្រាតែនិស្សិតនោះអាចគ្រប់គ្រងពីរបៀបធ្វើវិចារណកិច្ចបានទើបគេក្លាយជាអ្នកច្បាប់ ។ ទាំងនេះជាកម្មវត្ថុចំបងនៃស្បៀវភៅនេះដែលពុំមែនជាស្បៀវភៅក្បួនផ្សំទេ តែជាស្បៀវភៅដែលមានគោលដៅជួយនិស្សិត និងបេក្ខជនប្រឡងប្រជែង ដើម្បីបង្ហាត់បង្រៀនពួកគេឱ្យចេះពីវិចារណកិច្ចគតិយុត្ត ឬក៏ដើម្បីលំអិតវិចារណកិច្ចរបស់អ្នកដែលមានបទពិសោធច្រើនជាងនិស្សិត និងបេក្ខជនប្រឡងប្រជែង ។ ដោយហេតុថាបទពិសោធបានមកពីការអនុវត្តលំហាត់អនុវត្តជាច្រើននឹងលើកយកមកបង្ហាញ នៅក្នុងមុខវិជ្ជាសំខាន់ៗដែលបង្រៀននៅមហាវិទ្យាល័យនីតិសាស្ត្រ ព្រមទាំងមុខវិជ្ជាផ្សេងទៀត ដែលបេក្ខជនប្រឡងប្រជែងជួបប្រទះជាទូទៅ : នីតិរដ្ឋប្បវេណី នីតិព្រហ្មទណ្ឌ នីតិពាណិជ្ជកម្ម នីតិការងារ និងនីតិសាធារណៈ ។ ក្នុងន័យនេះ ស្បៀវភៅនេះជាឧបករណ៍សារសំខាន់ណាស់ទាំងសម្រាប់និស្សិតច្បាប់ពីឆ្នាំទីមួយ ដល់ឆ្នាំទីបួន ទាំងសម្រាប់បេក្ខជនប្រឡងប្រជែងផ្នែករដ្ឋបាល ឬតុលាការ ។ ជាការពិតណាស់ថា យើងសូមជូនអនុសាសន៍ដល់និស្សិត និងបេក្ខជនប្រឡងប្រជែង ឱ្យធ្វើលំហាត់ដោយខ្លួនឯង មុននឹងពិនិត្យមើលសំណើកំណែធ្វើឡើងដោយអ្នកច្បាប់កម្ពុជា ឬបារាំង នៅក្នុងវិស័យឯកទេសរបស់ពួកគេ ។

និស្សិត ឬបេក្ខជនប្រឡងប្រជែងផ្នែករដ្ឋបាល និងតុលាការ អាចជួបប្រទះលំហាត់ជាច្រើនប្រភេទ ។ ដូច្នេះ ស្បៀវភៅនេះ នឹងរៀបចំដោយយោងទៅតាមលំហាត់ផ្សេងៗទាំងនោះ :

- សលាកប័ត្រសេចក្តីសម្រេចរបស់តុលាការ (ភាគទី ១)

Scanned with CamScanner

- អត្ថាធិប្បាយអត្ថបទក្នុងន័យទូលាយ ដែលរួមមានអត្ថាធិប្បាយអត្ថបទរបស់អ្នកនិពន្ធណាម្នាក់ អត្ថាធិ-ប្បាយអត្ថបទច្បាប់ក្នុងន័យសំភារៈ ឬអត្ថាធិប្បាយសេចក្តីសម្រេចរបស់តុលាការ (ភាគទី ២)
- ករណីអនុវត្ត (ភាគទី ៣)
- បរមាធិប្បាយ (ភាគទី ៤)

Scanned with CamScanner

ភាគទី ១

សលាកប័ត្រសេចក្តីសម្រេច

របស់តុលាការ

Scanned with CamScanner

ភាគទី ១
សលាកប័ត្រសេចក្តីសម្រេចរបស់តុលាការ

លំហាត់ធ្វើសលាកប័ត្រសេចក្តីសម្រេចរបស់តុលាការអាចឱ្យនិស្សិត ឬបេក្ខជនប្រឡងក្នុងវិស័យតុលាការ ឬវិស័យរដ្ឋបាលហ្វឹកហាត់អំពីវិចារណកិច្ច (ការដេញរកហេតុផល) បែបគតិយុត្ត និយាយឱ្យកាន់តែច្បាស់តាមបែបតុលាការ ។ លំហាត់នេះ គឺជាលំហាត់ដំបូង ចាំបាច់សម្រាប់យល់ពីការធ្វើអត្ថាធិប្បាយវែកញែកទៅលើសេចក្តីសម្រេចរបស់តុលាការ ដែលជាការពន្យល់ និងការវាយតម្លៃទៅលើដំណោះស្រាយរបស់តុលាការ ក្នុងការយល់ឃើញលើបញ្ហាត្រូវវិនិច្ឆ័យ[2] ។ គោលដៅនៃការធ្វើសលាកប័ត្រសេចក្តីសម្រេចរបស់តុលាការ គឺដើម្បីផ្សែងផ្ចាត់លើការយល់ពីសេចក្តីសម្រេចនោះ ។ ដើម្បីធ្វើយ៉ាងនេះបាន និស្សិត ឬបេក្ខជនប្រឡងត្រូវធ្វើសេចក្តីសង្ខេបមួយ ដែលសរសេរឡើងវិញនូវវិចារណកិច្ចដែលសាលាជម្រះក្តីចេញសេចក្តីសម្រេច បានអនុវត្តតាម ដោយគោរពដំណាក់កាលនៃនីតិវិធីឱ្យបានត្រឹមត្រូវ ។ គុណភាពនៃសលាកប័ត្រសេចក្តីសម្រេចរបស់តុលាការ គឺអាស្រ័យលើចំណេះដឹងយ៉ាងច្បាស់លាស់អំពីដំណើរការប្រព្រឹត្តទៅរបស់តុលាការ និងវិធីសាស្ត្របំពេញការងាររបស់ចៅក្រម ។ ហេតុនេះ ការយល់ជ្រួតជ្រាបអំពីវិធីសាស្ត្រធ្វើសលាកប័ត្រសេចក្តីសម្រេចរបស់តុលាការ (ផ្នែកទី ២) ទាមទារឱ្យមានចំណេះដឹងមួយចំនួនជាមុនសិន (ផ្នែកទី១) ។

ផ្នែកទី ១ : ចំណេះដឹងផ្សេងៗចាំបាច់ត្រូវមានដើម្បីឱ្យយល់បានល្អពីសេចក្តីសម្រេចរបស់តុលាការ

ការសិក្សាពីសេចក្តីសម្រេចរបស់តុលាការទាមទារឱ្យយល់ដឹងពី :

- *ការរៀបចំជាទូទៅនៃប្រព័ន្ធតុលាការ* ព្រោះថា និស្សិត ឬបេក្ខជនប្រឡងត្រូវមានសមត្ថភាពកំណត់ពីទីតាំង ឬតួនាទីរបស់សាលាជម្រះក្តីចេញសេចក្តីសម្រេច ប្រៀបទៅនឹងការរៀបចំតុលាការទាំងមូល និងមានសមត្ថភាពបង្ហាញពីសមត្ថកិច្ចតាមសាច់រឿង និងសមត្ថកិច្ចតាមដែនដីរបស់សាលាជម្រះក្តីនោះ (កថាខណ្ឌ ទី១)
- *នីតិវិធី* ដើម្បីអាចយល់ និងតាមដានការវិវត្តតាមពេលវេលានៃការដោះស្រាយបញ្ហាគតិយុត្តចោទឡើងចំពោះចៅក្រម ដោយយល់បានច្បាស់ពីប្រភេទបណ្តឹងដែលគូភាគីប្រើប្រាស់ (កថាខណ្ឌទី២) ។

ម្យ៉ាងវិញទៀត និស្សិត ឬបេក្ខជនប្រឡង ពុំអាចទទួលបានជោគជ័យក្នុងការធ្វើសលាកប័ត្រសេចក្តីសម្រេចរបស់តុលាការបានទេ ប្រសិនបើមិនអាចយល់ច្បាស់ពី :

- វាក្យស័ព្ទគតិយុត្តដែលចៅក្រមជាអ្នកវិជ្ជាជីវៈខាងច្បាប់យកមកប្រើប្រាស់ (កថាខណ្ឌទី៣)

[2] សូមមើលភាគទី ២ ។

Scanned with CamScanner

- វិចារណកិច្ចជាក់លាក់របស់ចៅក្រមដែលសម្តែងឱ្យឃើញ តាមរយៈរចនាសម្ព័ន្ធពិសេសនៃសេចក្តីសម្រេចរបស់តុលាការ (កថាខ័ណ្ឌទី៤) ។

កថាខណ្ឌទី១ : ចំណេះដឹងពីការរៀបចំផ្នែកយុត្តាធិការ (បេអាទ្រីស ចាលីវ)

សាលាជំម្រះក្តីទាំងឡាយត្រូវបានរៀបចំតាមរបៀបសាជីជ្រុង (ខ) ហើយស្ថិតក្នុងលំដាប់គតិយុត្តតែមួយប៉ុណ្ណោះ (ក) ។

ក. គណយុត្តាធិការឯកនិយម

ប្រព័ន្ធតុលាការនៅកម្ពុជាផ្អែកលើគោលការណ៍នៃគណយុត្តាធិការឯកនិយម ។ តាមការពិត គឺមាត្រា ១២៨ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ដែលកំណត់ឱ្យអំណាចតុលាការ មានសមត្ថកិច្ចជំនុំជម្រះលើរាល់វិវាទទាំងអស់ រួមទាំងវិវាទរដ្ឋបាលផងដែរ ។ ប៉ុន្តែ នៅក្នុងអតីតកាល គណយុត្តាធិការពុំមានលក្ខណៈឯកនិយមបែបនេះទេ[3] ។ នៅឆ្នាំ ១៩២៤ មាត្រា ២៤៧ នៃក្រមព្រហ្មទណ្ឌចាស់ បានកំណត់ពីការបែងចែកអំណាចយ៉ាងតឹងរឹង ដោយហាមឃាត់ "អ្នករាជការខាងតុលាការជ្រៀតជ្រែកទៅក្នុងកិច្ចការដែលជាមុខការរបស់អាជ្ញាធរខាងរដ្ឋបាល" ។ ដូច្នេះ គេសង្កេតឃើញមានការបែងចែករវាងគណយុត្តាធិការទាំងពីរលំដាប់ដែលត្រូវបានបង្កើតឡើងដោយព្រះរាជប្រកាសចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៣៣ ហើយត្រូវបានកែប្រែដោយព្រះរាជក្រមចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៥៧ :

- សាលាជំម្រះក្តីនៃគណយុត្តាធិការខាងតុលាការយុត្តិធម៌ ដែលមានសាលាវិនិច្ឆ័យជាតុលាការជាន់ខ្ពស់បំផុត
- សាលាជំម្រះក្តីនៃគណយុត្តាធិការខាងរដ្ឋបាល ដែលសេចក្តីសម្រេចចេញដោយ**ក្រុមវិវាទ**នៅថ្នាក់ទីមួយ ហើយអាចឱ្យគេប្តឹងឧទ្ធរណ៍ទៅ**សភាមួយនៃក្រុមប្រឹក្សារដ្ឋ**[4]បាន ។

ចរិតទ្វិកនិយមខាងលើបានបាត់បង់ទៅនៅសម័យខ្មែរក្រហម ហើយពុំត្រូវបានបង្កើតឡើងវិញម្តងទៀតនោះទេ ទោះបីជាមានឆន្ទៈរបស់អ្នកច្បាប់ខ្លះក៏ដោយ ។

ខ. ការរៀបចំជារាងសាជីជ្រុងនៃសាលាជំម្រះក្តី

ចាប់ពីផ្នែកខាងក្រោមរហូតដល់កំពូលនៃសាជីជ្រុង គេឃើញមានសាលាជំម្រះក្តីថ្នាក់ទីមួយ បន្ទាប់មកសាលាជំម្រះក្តីថ្នាក់ទីពីរ និងចុងក្រោយបំផុតគឺ តុលាការកំពូល ។

---

[3] សូមមើលស្នាដៃរបស់ ចាំង ស៊ីណាត-កាន ច័ន្ទមេត្តា-កើត រិទ្ធ-ថេង ច័ន្ទសង្វារ-ឡូអ៊ិក អាវីឡាណីង-បេអាទ្រីស ចាលីវ អំពី *សេចក្តីផ្តើមនៃនីតិកម្មកម្ពុជា* បោះពុម្ព និងផ្សព្វផ្សាយដោយផ្នែកសហប្រតិបត្តិការ និងសកម្មភាពវប្បធម៌នៃស្ថានទូតបារាំង ឆ្នាំ២០០៥ ទំព័រទី ៨៤ និងទំព័របន្តបន្ទាប់ ។

[4] សាលាជំម្រះក្តីនេះត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៥៧ តែពុំមានអត្ថិភាពពិតប្រាកដទេ ។

Scanned with CamScanner

១. សាលាដំបូងក្នុងឋានៈជាសាលាដំបូង

តាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាដម្រះក្តីនៃរដ្ឋកម្ពុជាចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ តុលាការខេត្ត ក្រុង ជាតុលាការនីតិរូមថ្នាក់ទីមួយ បានសេចក្តីថាតុលាការខេត្ត ក្រុង មានសមត្ថកិច្ចជំនុំជម្រះរាល់រឿងក្តីទាំងអស់ដែលច្បាប់ពុំបានផ្តល់សមត្ថកិច្ចជាពិសេសទៅតុលាការណាមួយជាកំណត់ទេ ។ តុលាការខេត្ត ក្រុង ជំនុំជម្រះទាំងលើអង្គហេតុ និងអង្គច្បាប់ លើរាល់វិវាទទាំងអស់ ក្នុងវិស័យរដ្ឋប្បវេណី ព្រហ្មទណ្ឌ ពាណិជ្ជកម្ម ការងារ និងរដ្ឋបាលផងដែរ ។ តាមទ្រឹស្តី គេមានបំណងចង់ឱ្យមានសាលាដំបូង (តុលាការខេត្ត ក្រុង) មួយយ៉ាងតិច នៅក្នុងតំបន់ ឬខេត្តទីមួយ[5] ។ សេចក្តីសម្រេចរបស់តុលាការខេត្ត ក្រុង អាចឱ្យគេប្តឹងឧទ្ធរណ៍បាន ក្នុងរយៈពេលពីរខែ គិតចាប់ពីពេលចេញសាលក្រម ។

នាពេលសព្វថ្ងៃ ប្រទេសកម្ពុជាមានតែសាលាដម្រះក្តីពិសេសមួយប៉ុណ្ណោះគឺ តុលាការយោធា ។ តុលាការយោធាស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងការពារជាតិ ដោយតុលាការត្រូវជូនដំណឹងពីរាល់វិវាទទាំងអស់ដែលខ្លួនត្រូវដោះស្រាយទៅក្រសួងការពារជាតិ ។ តុលាការយោធាមានទីតាំងនៅរាជធានីភ្នំពេញ និងមានសមត្ថកិច្ចជំនុំជម្រះលើរាល់បទល្មើសយោធានៅលើទឹកដីនៃរដ្ឋកម្ពុជា ។ បទល្មើសមួយត្រូវចាត់ទុកជាបទល្មើសយោធា ប្រសិនបើ បទល្មើសនោះ ប្រព្រឹត្តដោយយោធិននៅក្នុងជួរកងទ័ព ហើយដែលពាក់ព័ន្ធនឹងវិន័យកងទ័ព ឬប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់កងកម្លាំងប្រដាប់អាវុធ ។ ផ្ទុយមកវិញ ចំពោះបទល្មើសព្រហ្មទណ្ឌនៃនីតិរូមប្រព្រឹត្តដោយយោធិន គឺសាលាដម្រះក្តីនៃនីតិរូមជាអ្នកមានសមត្ថកិច្ច ។ ប៉ុន្តែក្រោមឥទ្ធិពលរបស់ប្រទេសជាវាំង ប្រទេសកម្ពុជាក្នុងអតីតកាល ក៏ធ្លាប់មានតុលាការពិសេសជាច្រើនដែរ ទាំងតុលាការពិសេសផ្នែកព្រហ្មទណ្ឌ និងទាំងតុលាការពិសេសផ្នែករដ្ឋប្បវេណី ។ សេចក្តីព្រាងច្បាប់ស្តីពីការចាត់តាំងតុលាការ បានចែងឱ្យបង្កើតតុលាការពាណិជ្ជកម្មចំនួន ២១ ដែលមានសមត្ថកិច្ចដោះស្រាយវិវាទមានតម្លៃដើមលើសពី ១០ លានរៀល កើតឡើងរវាងពាណិជ្ជករស្តីពីកិច្ចសន្យា និងកិច្ចសម្រុះសម្រួល ដែលមានលក្ខណៈពាណិជ្ជកម្ម ឬស្តីពីពាណិជ្ជកិច្ច ឬក៏ជាវិវាទរវាងសមាជិកក្រុមហ៊ុន ឬម្ចាស់ហ៊ុននៃក្រុមហ៊ុនពាណិជ្ជកម្ម ដែលទាក់ទងដល់ក្រុមហ៊ុន ។ ដូចគ្នាដែរ ច្បាប់ការងាររបស់ព្រះរាជាណាចក្រកម្ពុជាគ្រោងបង្កើតតុលាការការងារចំនួន ៨ ដើម្បីដោះស្រាយវិវាទបុគ្គលរវាងកម្មករនិយោជិត និងនិយោជក ដោយមកពីការអនុវត្តកិច្ចសន្យាការងារ ឬកិច្ចសន្យាហ្វឹកហ្វឺនកូនជាង[6] ។

២. សាលាដម្រះក្តីថ្នាក់ទីពីរ

សាលាឧទ្ធរណ៍ មានសមត្ថកិច្ចជំនុំជម្រះខាងអង្គហេតុ និងអង្គច្បាប់ លើរាល់បណ្តឹងឧទ្ធរណ៍ពីសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោម[7] ។ សាលាឧទ្ធរណ៍មានតែមួយគត់ និងមានទីតាំងនៅរាជធានីភ្នំពេញ ។ សេចក្តីព្រាងច្បាប់

[5] មាត្រា ៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។ សូមមើលគំនូរបំព្រួញ ។

[6] មាត្រា ៣៨៧ នៃច្បាប់ការងារចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៧ ។

[7] ការរៀបចំបង្កើតសាលាឧទ្ធរណ៍មានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ និងបំពេញបន្ថែមដោយច្បាប់ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ១៩៩៣ ។ សាលាឧទ្ធរណ៍ចាប់ផ្តើមមានរូបរាងពិតប្រាកដនៅឆ្នាំ ១៩៩៤ ។


Scanned with CamScanner

ស្តីពីការចាត់តាំងតុលាការ គ្រោងនឹងបង្កើតសាលាឧទ្ធរណ៍ពីរទៀត មួយនៅខេត្តបាត់ដំបង និងមួយទៀតនៅខេត្តកំពង់ចាម ។

៣. សាលាជម្រះក្តីកំពូល

តុលាការកំពូល មានទីតាំងនៅរាជធានីភ្នំពេញ និងមានសមត្ថកិច្ចជំនុំជម្រះ លើរាល់បណ្តឹងសាទុក្ខពីសាលដីការបស់សាលាឧទ្ធរណ៍ ។ តុលាការកំពូលមិនមែនជាសាលាជម្រះក្តីថ្នាក់ទីបីទេ ព្រោះតុលាការកំពូលជំនុំជម្រះតែលើអង្គច្បាប់ប៉ុណ្ណោះ លើកលែងតែក្នុងករណីមានបណ្តឹងសាទុក្ខលើកទីពីរ ដែលតុលាការកំពូលជម្រះទាំងអង្គហេតុ និងអង្គច្បាប់ ។

គំនូរបំព្រួញពីការរៀបចំជាឯកតៃនៃតុលាការនៅកម្ពុជា



ឥទ្ធាខណ្ឌទី ២ : ការយល់ដឹងអំពីនីតិវិធី

ក្រោយពីការរំដោះនៅឆ្នាំ ១៩៧៩ កម្ពុជាបានចាប់ផ្តើមស្តារ និងកសាងឡើងវិញនូវភាពខ្ចៃខ្ចាំ តាមរយៈប្រភពធនធានផ្ទាល់ខ្លួន និងជំនួយអន្តរជាតិផ្សេងទៀត ទោះបីជាប្រទេសនៅតែស្ថិតនៅក្នុងស្ថានភាពអស្ថេរភាពដែលបណ្តាលមកពីនិរន្តភាពនៃសង្គ្រាមស៊ីវិលក៏ដោយ។ ស្របតាមកិច្ចព្រមព្រៀងទីក្រុងប៉ារីស ថ្នាក់ដឹកនាំក្នុងប្រទេសសម្រេចរៀបចំការបោះឆ្នោតថ្មីមួយ ដែលប្រព្រឹត្តនៅឆ្នាំ ១៩៩៣ ។ នៅក្នុងឆ្នាំដដែលនោះ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រទី ២ ត្រូវបានអនុម័តដោយសភាធម្មនុញ្ញ ។ ដើម្បីបំពេញនូវកង្វះខាតផ្នែកច្បាប់ សភាធម្មនុញ្ញបានបញ្ជូលនូវបទប្បញ្ញត្តិមួយ

Scanned with CamScanner

គឺមាត្រា ១៣៩ ដែលក្លាយជាមាត្រា ១៥៨ ថ្មី បន្ទាប់ពីមានការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៥ ។ មាត្រានេះចែងថា "ច្បាប់ និងលិខិតបទដ្ឋានទាំងអស់នៅកម្ពុជា ដែលធានា ការពារបាននូវទ្រព្យសម្បត្តិរដ្ឋ សិទ្ធិ សេរីភាព និងទ្រព្យសម្បត្តិត្រឹមត្រូវតាមច្បាប់របស់បុគ្គល និងដែលសមស្របនឹងប្រយោជន៍ជាតិ ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀត រហូតដល់មានអត្ថបទថ្មីមកកែប្រែ ឬលុបចោល លើកលែងតែបទប្បញ្ញត្តិណា ដែលផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញនេះ។" បទប្បញ្ញត្តិនេះត្រូវបានចាត់ទុកជាការបំពេញបន្ថែមមួយចំពោះកង្វះខាតខាងផ្នែកនីតិវិធីរដ្ឋប្បវេណី ដែលមិនទាន់មានច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីច្បាស់លាស់ជាធរមាន "ក" នៅឡើយ ។ ផ្ទុយមកវិញ ចំពោះនីតិវិធីព្រហ្មទណ្ឌ យើងមានច្បាប់ជាធរមានមួយចំនួនផងដែរ "ខ" ដែលឆ្លុះបញ្ចាំងអំពីដំណើរការនៃនីតិវិធីនេះ ។

គ. និតិវិធីរដ្ឋប្បវេណី : (កាន ច័ន្ទមេត្តា)

ក្នុងរយៈពេលរង់ចាំការអនុម័តនូវសេចក្តីព្រាងក្រមស្តីពីនីតិវិធីរដ្ឋប្បវេណីថ្មីដែលត្រូវបានរៀបចំ ដោយអ្នកជំនាញការជប៉ុន, វិធាននៃនីតិវិធីរដ្ឋប្បវេណីនៅតែស្ថិតនៅជាប្រធានបទមួយមានភាពខ្វះខាត បើទោះបីជាមានវត្តមាននូវបទដ្ឋានមួយចំនួនចាប់ពីឆ្នាំ ១៩៨១[៥] មកក៏ដោយ ជាអាទិ៍ : សារាចរណែ ចុះថ្ងៃទី ០៨-០៩-១៩៨៤ របស់ក្រសួងយុត្តិធម៌ដែលជូនដំណឹងដល់សមមិត្តប្រធានតុលាការប្រជាជនខេត្ត ក្រុង និងសារាចរណែពីរទៀត ចុះថ្ងៃទី ១៨-០២-១៩៨៥ ទាក់ទងនឹងការកំណត់នូវការណែនាំអំពីនីតិវិធីរដ្ឋប្បវេណី បែបបទក្នុងការតាក់តែងសាលក្រម ទាក់ទងការសម្រេចក្នុងករណីលែងលះតាមការព្រមព្រៀងរវាងសហព័ទ្ធទាំងពីរ និងបែបបទអនុវត្តនីតិវិធីដែលត្រូវបានអនុវត្តសម្រាប់ព្រះរាជអាជ្ញា និងតុលាការប្រជាជនខេត្ត ក្រុង ។ មានបទប្បញ្ញត្តិខ្លះទៀតត្រូវបានបង្កើតឡើង ដើម្បីបំពេញនូវចំណុចខ្លះដូចជា ក្រឹត្យ-ច្បាប់ចុះថ្ងៃទី ២៦-០៨-១៩៨៧ ទាក់ទងនឹងការរៀបចំ និងសកម្មភាពតុលាការប្រជាជនកំពូល និងអគ្គព្រះរាជអាជ្ញាអមតុលាការប្រជាជនកំពូល, ច្បាប់ចុះថ្ងៃទី ២៦-០៧-១៩៨៩ ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, ច្បាប់ចុះថ្ងៃទី ០២-០៥-១៩៩២ ស្តីពីបែបបទនៃការអនុវត្តសាលក្រមរដ្ឋប្បវេណី, ច្បាប់ចុះថ្ងៃទី ១០-០៩-១៩៩២ ស្តីពីប្រព័ន្ធតុលាការ នីតិព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ ដែលអនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល, ច្បាប់ចុះថ្ងៃទី ០៨-០២-១៩៩៣ ស្តីពីការចាត់តាំង និងសកម្មភាពសាលាដំរះក្តីនៃរដ្ឋកម្ពុជា និងច្បាប់ចុះថ្ងៃទី ០៨-០៣-១៩៩៣ ស្តីពីនីតិវិធីព្រហ្មទណ្ឌ និងប្រកាស ចុះថ្ងៃទី ២៥-០៣-១៩៩៤ ស្តីពីនីតិវិធីដោះស្រាយជំលោះឯកជន ។ ដោយយោងតាមមាត្រា ១៥៨ ថ្មីនៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ដើម្បីបំពេញកង្វះខាតក្នុងមុខវិជ្ជានេះ មានបទប្បញ្ញត្តិផ្នែកខ្លះនៃក្រមនីតិវិធីរដ្ឋប្បវេណីសង្គមចាស់ក៏ត្រូវបានអនុវត្តផងដែរ ។

តើយើងអាចលើកឡើងនូវវិធាននៃនីតិវិធីរដ្ឋប្បវេណីណាខ្លះ ដែលកំពុងត្រូវបានអនុវត្តនាពេលបច្ចុប្បន្ននេះ ?

មុនដាក់ពាក្យបណ្តឹងទៅតុលាការ និងមុនពេលចាប់ផ្តើមនីតិវិធី ដោយយោងតាមទំនៀមទំលាប់ និងការអនុវត្តជាក់ស្តែងជាបន្តបន្ទាប់ ភាគីវិវាទតែងតែមានបំណងចង់សម្របសម្រួលគ្នា នៅចំពោះមុខអាជ្ញាធរសាធារណៈមាន

[៥] ការអនុម័តរដ្ឋធម្មនុញ្ញនៃសាធារណៈរដ្ឋប្រជាមានិតកម្ពុជា ឆ្នាំ ១៩៨១ ។

Scanned with CamScanner

សមត្ថកិច្ចក្នុងដែនដី ដែលពួកគេស្នាក់នៅ ដូចជាមេឃុំ ឬចៅសង្កាត់ជាដើម ។ ការអនុវត្តនេះ[៩] ក៏ត្រូវបានទទួលស្គាល់ផងដែរ តាមរយៈការអនុម័តនូវច្បាប់មួយចំនួន ជាអាទិ៍ ច្បាប់អាពាហ៍ពិពាហ៍[១០] និងត្រួសារ ច្បាប់ការងារ[១១] .... ។

នៅពេលដែលពាក្យបណ្តឹងមួយត្រូវបានធ្វើឡើង ភាគីដើមបណ្តឹង ឬដើមចោទត្រូវបំពេញនូវលក្ខខណ្ឌបីយ៉ាង :

- *ផលប្រយោជន៍ស្របច្បាប់* : មានតែបុគ្គល ដែលទទួលរងនូវការខូចខាតផលប្រយោជន៍ស្របច្បាប់តែប៉ុណ្ណោះ អាចធ្វើពាក្យបណ្តឹងបាន ហើយផលប្រយោជន៍នោះអាចមានត្រឹមតែផ្លូវចិត្ត ឬអនាគត[១២] ។
- *សមត្ថភាព* : សមត្ថភាព គឺជាអំណាចនីត្យានុកូល ដើម្បីធ្វើពាក្យបណ្តឹងមួយ[១៣] ។ ហេតុដូច្នេះ អនីតិជនអាចធ្វើពាក្យបណ្តឹងបាន ដោយអ្នកតំណាងអាណាព្យាបាលស្របច្បាប់តែប៉ុណ្ណោះ ។
- *គុណភាពស្របច្បាប់*[១៤] : គុណភាពសំដៅទៅលើលទ្ធភាពក្នុងការធ្វើពាក្យបណ្តឹងដែលត្រូវបានទទួលស្គាល់ចំពោះជនរងគ្រោះ ឬម្ចាស់សិទ្ធិនៃវិវាទ សន្តតិជន ឬសិទ្ធិវិន្ត ឬអ្នកតំណាងស្របច្បាប់ ឬតាមកិច្ចសន្យាអណត្តិ[១៥] ។

លើសពីនេះទៀត នៅក្នុងពាក្យបណ្តឹងត្រូវតែចែងឱ្យបានច្បាស់នូវកម្មវត្ថុ និងមូលហេតុ ហើយត្រូវតែដាក់ជូនតុលាការមានសមត្ថកិច្ច ។ សមត្ថកិច្ចរបស់តុលាការត្រូវបានបែងចែកជាពីរយ៉ាង ។

សមត្ថកិច្ចតាមសាច់រឿង មានចែងក្នុងរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ និងមាត្រា ៦ នៃច្បាប់ស្តីការចាត់តាំង និងសកម្មភាពសាលាដម្រះក្តីនៃរដ្ឋកម្ពុជា ។ តុលាការប្រជាជនខេត្ត ក្រុង មានសមត្ថកិច្ចទទួលស្គាល់ជាលើកទី ១ នូវរឿងវិវាទទាំងឡាយ ដែលទាក់ទងនឹងរឿងពាណិជ្ជកម្ម[១៦], រឿងរដ្ឋប្បវេណី, រឿងព្រហ្មទណ្ឌ, រឿងរដ្ឋបាល និងវិវាទការងារ[១៧] ។ ក្នុងករណីដែលគ្មានអត្ថបទផ្សេងពីនេះបានកំណត់អំពីសមត្ថកិច្ចពិសេសចំពោះយុត្តាធិការណាមួយទេ វិវាទត្រូវស្ថិតនៅក្នុងសមត្ថកិច្ចរបស់យុត្តាធិការនៃនីតិរូម[១៨] ។ ដូចជាករណីតុលាការយោធា គឺជាតុលាការពិសេសដែលទទួលស្គាល់នូវ

---

[៩] ដោយយោងតាមការអនុវត្តជាក់ស្តែង ប្រជាពលរដ្ឋខ្មែរក្នុងរឿងវិវាទទាក់ទងនឹងអចលនវត្ថុ តែងតែអនុវត្តនីតិវិធីផ្សះផ្សានៅចំពោះមេឃុំ ឬចៅសង្កាត់ ។

[១០] ក្នុងករណីលែងលះ សហព័ន្ធទាំងពីរត្រូវតែគោរពនូវនីតិវិធីដែលមានចែងក្នុងផ្នែកទី ៣ នៃជំពូកទី ៣ នៃច្បាប់អាពាហ៍ពិពាហ៍ និង ត្រួសារឆ្នាំ ១៩៨៩ ជាពិសេសក្នុងមាត្រា ៤២ ។ នៅក្នុងបុព្វកថានៃសារាចរណែនាំចុះថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ១៩៨៤ "ក្នុងរឿងរដ្ឋប្បវេណី ជាពិសេសរឿងអាពាហ៍ពិពាហ៍ និង ត្រួសារ តុលាការប្រជាជនខេត្ត ក្រុងត្រូវតែអនុវត្តនូវការផ្សះផ្សារវាងភាគីជាមុនសិន ដើម្បីបង្កើតនូវចំណងសារជាថ្មីឡើងវិញរវាងពួកគេ និងអនុញ្ញាតឱ្យប្រជាជនមានសាមគ្គីភាព.....

[១១] ក្នុងករណីវិវាទការងារបុគ្គល ភាគីត្រូវប្រគល់រឿងវិវាទស្ថិតនៅក្នុងនីតិវិធីផ្សះផ្សានៅចំពោះមុខមន្ត្រីអធិការកិច្ចខេត្ត យោងតាមមាត្រា ៣០០ នៃច្បាប់ការងារ ។ នីតិវិធីដូចគ្នានោះក៏ត្រូវបានអនុវត្តផងដែរក្នុងករណីវិវាទសមូហភាពការងារ អនុលោមតាមមាត្រា ៣០៣ នៃច្បាប់ការងារ ។

[១២] មាត្រា ១២ នៃក្រមនីតិវិធីរដ្ឋប្បវេណីសង្គមចាស់ ។

[១៣] មាត្រា ១៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីសង្គមចាស់ ។

[១៤] មាត្រា ១១ នៃក្រមនីតិវិធីរដ្ឋប្បវេណីសង្គមចាស់ ។

[១៥] មាត្រា ១៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីសង្គមចាស់ ។

[១៦] មាត្រា ៥៥ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងការចុះបញ្ជីពាណិជ្ជកម្មចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥ ។

[១៧] មាត្រា ៣៨៩ នៃច្បាប់ការងារ ។

[១៨] ក្នុងរឿងពាណិជ្ជកម្ម វិវាទការងារ និងវិវាទកិច្ចសន្យា ។

Scanned with CamScanner

រឿងវិវាទទាំងឡាយដែលទាក់ទងនឹងបទល្មើសយោធា ចំណែកបទល្មើសព្រហ្មទណ្ឌផ្សេងទៀត មានចែង និងជាសមត្ថកិច្ចរបស់យុត្តាធិការនៃនីតិរួម[១៩] ។

ចំណែកសមត្ថកិច្ចតាមដែនដី តុលាការប្រជាជនខេត្ត ក្រុង មានសមត្ថកិច្ចជាកំណត់នៅក្នុងដែនដីនៃខេត្ត ឬក្រុងនៃរឿងវិវាទ ។ តុលាការយោធា[២០] , សាលាឧទ្ធរណ៍[២១] និងតុលាការកំពូល[២២] ដែលមានទីតាំងនៅទីក្រុងភ្នំពេញ មានសមត្ថកិច្ចលាតសន្ធឹងនៅទូទាំងប្រទេស ។ ជាគោលការណ៍ តុលាការមានសមត្ថកិច្ច គឺតុលាការនៃទីលំនៅរបស់ចុង-ចម្លើយ ។ បើសិនជាបណ្តឹងបាតិបុគ្គល, បណ្តឹងប្រត្យក្ស ឬបណ្តឹងទាក់ទងនឹងស្ថានភាពបុគ្គល[២៣] ដើមបណ្តឹងមានជម្រើសផ្សេងទៀត ។ ទាក់ទងនឹងពាក្យបណ្តឹងប្រត្យក្ស ចំពោះអចលនវត្ថុ តុលាការមានសមត្ថកិច្ច គឺតុលាការដែលអចលនវត្ថុតាំងនៅ[២៤] ។ ចំណែកឯរឿងលែងលះ តុលាការមានសមត្ថកិច្ចគឺតុលាការនៃទីលំនៅរបស់ចុងចម្លើយ[២៥] ។ ចំពោះករណីវិវាទទាក់ទងនឹងការប្រកាសមិនទទួលស្គាស់កូនឥតខាន់ស្លាដោយឪពុកតុលាការមានសំមត្ថកិច្ច គឺតុលាការនៃទីលំនៅខាងម្តាយនៃកូន[២៦] ។ ចំណែកបណ្តឹងទាំងឡាយ ដែលទាក់ទងនឹងការចុះបញ្ជីអត្រានុកូលដ្ឋាន តុលាការមានសមត្ថកិច្ច គឺតុលាការនៃទីន្លែងតាក់តែងលិខិតនោះ[២៧] ។

យុត្តាធិការថ្នាក់ទី ១ តុលាការខេត្ត ក្រុង មានសមាសភាពជំនុំជម្រះដោយចៅក្រមមួយរូប ព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារងម្នាក់ និងក្រឡាបញ្ជីម្នាក់[២៨] ។ ក្នុងរឿងព្រហ្មទណ្ឌ និងរឿងទាក់ទងនឹងសណ្តាប់ធ្នាប់សាធារណៈ ព្រះរាជអាជ្ញាដើរតួនាទីជាគូក្តីដើម[២៩] ដែលក្នុងរឿងវិវាទផ្សេងទៀត[៣០] គាត់ដើរតួត្រឹមតែជាគូក្តីរណបតែប៉ុណ្ណោះ ។

---

[១៩] មាត្រា ៩ វាក្យខណ្ឌ ២ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពសាលាដំរះក្តីនៃរដ្ឋកម្ពុជា ។

[២០] មាត្រា ២ នៃ ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពសាលាដំរះក្តីនៃរដ្ឋកម្ពុជា ។

[២១] មាត្រា ១៥៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី ៨ មិនា ឆ្នាំ ១៩៩៣ ។

[២២] មាត្រា ៣ នៃ ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពសាលាដំរះក្តីនៃរដ្ឋកម្ពុជា និង មាត្រា ២០៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

[២៣] មាត្រា ៨៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីសង្គមចាស់ ។ ក្នុងរឿងនេះទោះបីជាមានចុងចម្លើយច្រើនក៏ដោយ ពាក្យបណ្តឹងត្រូវធ្វើឡើងនៅចំពោះមុខតុលាការនៃទីកន្លែងដែលអចលនវត្ថុតាំងនៅ ។ ក៏ប៉ុន្តែ បើសិនជាវិវាទទាក់ទងនឹងអចលនវត្ថុច្រើន ដើមចោទអាចជ្រើសរើសតុលាការមានសមត្ថកិច្ច ដោយយោងទៅលើទីកន្លែងដែលអចលនវត្ថុតាំងនៅ ស្របតាមមាត្រា ៥២ នៃក្រមខាងលើ ។

[២៤] មាត្រា ៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីសង្គមចាស់ ។

[២៥] មាត្រា ៤១ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ។

[២៦] មាត្រា ៨៥ នៃច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ។

[២៧] មាត្រា ៥៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីសង្គមចាស់ ។

[២៨] មាត្រា ៦ វាក្យខណ្ឌ ២ នៃ ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពសាលាដំរះក្តីនៃរដ្ឋកម្ពុជា ។ មាត្រា ៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និង មាត្រា ៥៦ វាក្យខណ្ឌ ៣ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

[២៩] មាត្រា ៥ វាក្យខណ្ឌ ២ និង ៥ នៃ ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពសាលាដំរះក្តីនៃរដ្ឋកម្ពុជា និង មាត្រា ៥២ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ។ មាត្រា ៥៤ នៃច្បាប់ចុងក្រោយនេះបានបន្ថែមថា ក្នុងរឿងវិវាទទាក់ទងនឹងផលប្រយោជន៍អនីតិជន ឬ អសមត្ថជន ព្រះរាជអាជ្ញាត្រូវចោទដោយខ្លួន ឯងក្នុងនាមជាដើមបណ្តឹង។

[៣០] មាត្រា ៥ វាក្យខណ្ឌទី ៤ នៃ ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពសាលាដំរះក្តីនៃរដ្ឋកម្ពុជា និង មាត្រា ៥៣ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

Scanned with CamScanner

ការបើកសវនាការត្រូវធ្វើឡើងជាសាធារណៈ លើកលែងតែករណីមួយចំនួន ដែលជនរងគ្រោះ ឬអ្នកតំណាងរបស់ជនរងគ្រោះ លើកសំណូមពរឱ្យតុលាការបើកសវនាការជាសំងាត់[៣១] ។

នៅពេលចប់សវនាការ តុលាការអាចប្រកាសសាលក្រមនៅចំពោះមុខគូភាគីដែលសាលក្រមនោះមានឈ្មោះថា សាលក្រមចំពោះមុខ ឬនៅចំពោះមុខតែដើមចោទ ដែលសាលក្រមនេះជាសាលក្រមកំចាំងមុខ ។ ក្នុងករណី សាលក្រមចំពោះមុខ ភាគីមិនយល់ស្របមានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេល ២ ខែ គិតចាប់ពីថ្ងៃប្រកាសសាលក្រម ។ ប៉ុន្តែក្នុងករណីសាលក្រមកំចាំងមុខវិញ ភាគីអវត្តមានមានសិទ្ធិប្តឹងជំទាស់ក្នុងរយៈពេល ១៥ ថ្ងៃ បន្ទាប់ពីបានទទួលដំណឹងពីសាលក្រម។ បើសិន ជារយៈពេលនេះត្រូវបានផុតរលត់ គាត់មានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេល ២ ខែ គិតចាប់ពីថ្ងៃផុតរយៈពេលប្តឹងទាស់[៣២] ។

បុគ្គលដែលអាចប្តឹងឧទ្ធរណ៍បាន មានព្រះរាជអាជ្ញា ឬបុគ្គលដែលមានផលប្រយោជន៍ក្នុងរឿងវិវាទ ដូចជាជនរងគ្រោះ ជនជាប់ចោទក្នុងរឿងព្រហ្មទណ្ឌ មេធាវី ឬអ្នកតំណាងការពារក្តី[៣៣] ។ បើសិនជាមានម្នាក់ក្នុងចំណោមពួកគេខាងលើនេះបានប្តឹងឧទ្ធរណ៍ សំណួរត្រូវបានចោទឡើងថា តើឧទ្ធរណ៍មានអានុភាពផ្អាកជាបណ្តោះអាសន្នការអនុវត្តសាលក្រមដែរឬទេ ? បណ្តឹងឧទ្ធរណ៍ដែលទាក់ទងដល់សេចក្តីសំរេចរបស់តុលាការ របស់ចៅក្រម ឬរបស់រដ្ឋអាជ្ញា) ពុំមានអានុភាពផ្អាកសេចក្តីសំរេចទាំងនោះទេ លើកលែងតែបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយរដ្ឋអាជ្ញា ក្នុងរឿងឃុំខ្លួន ឬដោះលែងឱ្យនៅក្រៅឃុំជាបណ្តោះអាសន្ន[៣៤] ។

សាលាឧទ្ធរណ៍មានសមត្ថកិច្ចជំនុំជម្រះនូវសេចក្តីសម្រេច ដែលចេញដោយតុលាការខេត្ត ក្រុង និងតុលាការយោធា ។ នៅពេលសវនាការ សាលាឧទ្ធរណ៍មានសមាសភាពជំនុំជំរះដោយចៅក្រមបីរូប ដែលមានម្នាក់ជាប្រធាន អមដោយអគ្គព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញារងមួយរូប និងក្រឡាបញ្ជីម្នាក់[៣៥] ។ ដូចគ្នាទៅនឹងតុលាការខេត្ត ក្រុងដែរ សាលាឧទ្ធរណ៍ជំនុំជម្រះទាំងអង្គហេតុ និងអង្គច្បាប់[៣៦] ។ នៅពេលចប់សវនាការ សាលាឧទ្ធរណ៍ចេញសាលដីកាមួយ ។ គូភាគីដែលជំទាស់ប្រឆាំងនឹងសាលដីកានេះ មានសិទ្ធិធ្វើបណ្តឹងសាទុក្ខក្នុងរយៈពេល ២ ខែ គិតចាប់ពីថ្ងៃប្រកាសសាលដីកានោះមក ។ ប៉ុន្តែ ប្រសិនជាសាលដីកាកំចាំងមុខចុងចម្លើយ គូភាគីអវត្តមានអាចប្តឹងជំទាស់នឹងសាលដីកាក្នុងរយៈពេល ១៥ ថ្ងៃ គិតពីថ្ងៃបានទទួលដំណឹង និងមានសិទ្ធិប្តឹងសាទុក្ខក្នុងរយៈពេល ២ ខែ គិតចាប់ពីថ្ងៃ

---

[៣១] មាត្រា ២៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ឆ្នាំ ១៩៩២ ។

[៣២] មាត្រា ៧ នៃ ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពសាលាជំរះក្តីនៃរដ្ឋកម្ពុជា និងមាត្រា ៤ ចំនុចទី ៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

[៣៣] មាត្រា ៨ វាក្យខណ្ឌទី ១ និង ២ នៃ ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពសាលាជំរះក្តីនៃរដ្ឋកម្ពុជា ។

[៣៤] មាត្រា ៨ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពសាលាជំរះក្តីនៃរដ្ឋកម្ពុជា និងមាត្រា ៤ ចំនុចទី ២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

[៣៥] មាត្រា ៤ ចំនុចទី ៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

[៣៦] មាត្រា ១២ នៃ ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពសាលាជំរះក្តីនៃរដ្ឋកម្ពុជា និង មាត្រា ៥ ចំនុចទី ២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

Scanned with CamScanner

ផុតរយៈពេលប្តឹងជំទាស់[៣៧] ។ បុគ្គលដែលមានសិទ្ធិធ្វើពាក្យបណ្តឹងសាទុក្ខមានអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍, ជនរង គ្រោះ, មេធាវី ឬអ្នកតំណាង ឬជនជាប់ចោទ[៣៨] ។

បណ្តឹងសាទុក្ខមានអានុភាពផ្អាកការអនុវត្តជាបណ្តោះអាសន្ននូវការអនុវត្តសាលាដីការបស់សាលាឧទ្ធរណ៍លើកលែងតែបណ្តឹងទាក់ទងនឹងការជាប់ឃុំឃាំង ឬការដាក់ឱ្យនៅក្រៅឃុំជាបណ្តោះអាសន្ន ការតម្កល់រឿងមិនចាត់ការ និងការលើកលែងការចោទប្រកាន់ ។ ភាគីប្តឹងសាទុក្ខត្រូវដាក់ពាក្យបណ្តឹងនៅចំពោះយុត្តាធិការដែលចេញសេចក្តីសម្រេចនោះ[៣៩] មានន័យថាយុត្តាធិការនៅទីក្រុងភ្នំពេញ ដោយហេតុថានាពេលបច្ចុប្បន្នកាលនេះ យើងមានតែសាលាឧទ្ធរណ៍តែមួយគត់ មានទីតាំងនៅទីក្រុងភ្នំពេញ ។

តុលាការកំពូលគឺជាយុត្តាធិការជាន់ខ្ពស់ដែលមានសមត្ថកិច្ចជំនុំជម្រះតែលើអង្គច្បាប់ប៉ុណ្ណោះ មិនមែនលើអង្គហេតុនៃសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍នោះទេ ។ ប៉ុន្តែ ក្នុងករណីបណ្តឹងសាទុក្ខលើកទី ២ តុលាការកំពូលជំនុំជម្រះជាសភាពេញអង្គ ហើយជំនុំជម្រះទាំងអង្គហេតុ និងអង្គច្បាប់[៤០] ។ ក្នុងដំណាក់កាលនៃបណ្តឹងសាទុក្ខលើកទី ១ តុលាការកំពូលជំនុំជម្រះ ដោយមានសមាសភាពចៅក្រម ៥ រូប ដែលមានម្នាក់ជាប្រធាន, អគ្គព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាម្នាក់ និងក្រឡាបញ្ជីម្នាក់ ។ នៅពេលចប់សវនាការ តុលាការកំពូលអាចចេញសាលដីកាមួយ ដោយបដិសេធបណ្តឹងសាទុក្ខ ប្រសិនបើសាលដីការបស់សាលាឧទ្ធរណ៍មានមូលដ្ឋានច្បាប់ត្រឹមត្រូវ ឬបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ ដោយបញ្ជូនសំណុំរឿងទៅសាលាឧទ្ធរណ៍ជំនុំជម្រះសាជាថ្មី ដោយមានសមាសភាពថ្មី បើសិនសាលដីការបស់សាលាឧទ្ធរណ៍គ្មានមូលដ្ឋានច្បាប់គ្រប់គ្រាន់ ឬក៏ផ្ទុយនឹងបទបញ្ញត្តិច្បាប់ណាមួយ ។ ក្នុងករណីនេះចៅក្រមដែលមានសមាសភាពថ្មីនេះគ្មានកាតព្វកិច្ចកាត់ក្តីស្របតាមតុលាការកំពូលនោះទេ ។ នៅពេលដែលសាលាឧទ្ធរណ៍បានចេញសាលដីកា ហើយមានភាគីណាម្នាក់មិនយល់ស្របនឹងសេចក្តីសម្រេចនោះ គាត់អាចធ្វើពាក្យបណ្តឹងសាទុក្ខជាលើកទី២ ដោយគោរពតាមនីតិវិធីដដែល ដែលបានកំណត់ក្នុងនីតិវិធីនៃពាក្យបណ្តឹងសាទុក្ខលើកទី ១ ។ តុលាការកំពូលជំនុំជម្រះជាសភាពេញអង្គ ដោយមានសមាសភាពចៅក្រម ៩ រូប ដែលមានម្នាក់ជាប្រធាន, អគ្គព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញារងម្នាក់ ឬព្រះរាជអាជ្ញាម្នាក់ និងក្រឡាបញ្ជីមួយរូប[៤១] ។ សេចក្តីសម្រេចចេញជាលើកចុងក្រោយ និងក្លាយជាស្ថាពរ[៤២] ។

---

[៣៧] មាត្រា ១៣ វាក្យខណ្ឌចុងក្រោយ នៃ ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពសាលាជំរះក្តីនៃរដ្ឋកម្ពុជា និងមាត្រា ៥ ចំនុចទី ២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

[៣៨] មាត្រា ១៣ វាក្យខណ្ឌទី ១ ២ និង ៣ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពសាលាជំរះក្តីនៃរដ្ឋកម្ពុជា ។

[៣៩] មាត្រា ១៤ នៃ ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពសាលាជំរះក្តីនៃរដ្ឋកម្ពុជា មាត្រា ៥ ចំនុចទី ១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និង មាត្រា ២០៧ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ។

[៤០] មាត្រា ១៦ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពសាលាជំរះក្តីនៃរដ្ឋកម្ពុជារ ។

[៤១] មាត្រា ១៦ នៃ ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពសាលាជំរះក្តីនៃរដ្ឋកម្ពុជា ។

[៤២] មាត្រា ៥ ចំនុចទី ៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

Scanned with CamScanner

ខ- នីតិវិធីព្រហ្មទណ្ឌ : (កើត វិទ្ធ)

នៅពេលដែលមានបទល្មើសមួយកើតឡើង គេសង្កេតឃើញមានកិច្ចនីតិវិធីជាច្រើនត្រូវបានអនុវត្ត ដោយអាជ្ញាធរមានសមត្ថកិច្ច ស្របតាមវិធាននៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដើម្បីធ្វើការកំណត់អំពីអត្ថភាពតាមផ្លូវច្បាប់នៃបទល្មើសនោះ មុនពេលដែលជនល្មើសត្រូវបានផ្តន្ទាទោសដោយតុលាការព្រហ្មទណ្ឌ ។ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌចែងអំពីដំណាក់កាលផ្សេងៗនៃដំណើរការនីតិវិធី ដើម្បីកំណត់អំពីអត្ថភាពនៃបទល្មើសនេះ ដែលយើងអាចធ្វើការបែងចែកជា ៣ ដំណាក់កាលធំៗ សម្រាប់ការសិក្សាជាបន្តបន្ទាប់ដូចតទៅ :

១- ដំណាក់កាលនៃការស្វែងរកបទល្មើស និងការធ្វើបណ្តឹងអាជ្ញា

ជាទូទៅ ការស្វែងរកបទល្មើសឧក្រិដ្ឋ មជ្ឈិម និងលហុ គឺជាតួនាទី និងសមត្ថកិច្ចរបស់នគរបាលយុត្តិធម៌[៤៣] ។ ប្រតិបត្តិការស្វែងរកបទល្មើសរបស់នគរបាលយុត្តិធម៌ត្រូវស្ថិតនៅក្រោមការដឹកនាំ និងសម្របសម្រួលរបស់ព្រះរាជ-អាជ្ញា និងក្រោមការត្រួតពិនិត្យរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍[៤៤] ។ ចំណែកឯព្រះរាជអាជ្ញាវិញ ក្រៅពីតួនាទីស្វែងរកបទល្មើសក្នុងនាមជាមន្ត្រីនគរបាលយុត្តិធម៌មួយរូបនៅពេលបំពេញភារកិច្ច[៤៥] និងក្រៅពីតួនាទីធ្វើការដឹកនាំ និងសម្របសម្រួលការងាររបស់នគរបាលយុត្តិធម៌ ព្រះរាជអាជ្ញាមានអំណាចមួយទៀតដែលកំណត់ដោយច្បាប់ គឺអំណាចក្នុងការធ្វើបណ្តឹងអាជ្ញា ។

១.១- នគរបាលយុត្តិធម៌

នៅក្នុងការអនុវត្តសមត្ថកិច្ចរបស់ខ្លួនដើម្បីស្វែងរក និងពិនិត្យបទល្មើសព្រហ្មទណ្ឌ មន្ត្រីនគរបាលយុត្តិធម៌ទទួលពាក្យបណ្តឹងទាមទារ ឬបណ្តឹងបរិហារនានា ព្រមទាំងរបាយការណ៍របស់នគរបាលយុត្តិធម៌ទាំងឡាយទាក់ទងនឹងបទឧក្រិដ្ឋ មជ្ឈិម និងលហុ ។ មន្ត្រីនគរបាលយុត្តិធម៌ចាត់វិធានការប្រមូលភស្តុតាងផ្សេងៗនៃបទល្មើស ហើយអាចទទួលដីកាចាត់ឱ្យសួរជំនួសចំពោះករណីណាមួយ ។ មន្ត្រីនគរបាលយុត្តិធម៌ដែលមានសមត្ថកិច្ចដើម្បីធ្វើកិច្ចការខាងលើ គឺជាមន្ត្រីនគរបាលយុត្តិធម៌នៅទីកន្លែងប្រព្រឹត្តបទល្មើស, ខាងលំនៅដ្ឋានរបស់ជនល្មើស ឬមន្ត្រីនគរបាលយុត្តិធម៌នៅទីកន្លែងដែលជនល្មើសត្រូវបានរកឃើញ[៤៦] ។

នៅក្នុងករណីបទល្មើសជាក់ស្តែង[៤៧] មន្ត្រីនគរបាលយុត្តិធម៌អាចយកចម្លើយពីសាក្សីនានា ធ្វើការឆែកឆេរ និងរឹបអូសនូវវត្ថុតាងផ្សេងៗ និងអាចចាត់តាំងអ្នកជំនាញក្នុងករណីចាំបាច់ ។ មន្ត្រីនគរបាលយុត្តិធម៌អាចចាប់ខ្លួន និង

---

[៤៣] មាត្រា ៣៥ ថ្មី នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ។

[៤៤] មាត្រា ៣៦ ថ្មី នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ។ មុនពេលមានវិសោធនកម្ម មាត្រា ៣៦ ចាស់ បានចែងថា ប្រតិបត្តិការនៃ នគរបាលយុត្តិធម៌ស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់ព្រះរាជអាជ្ញា និងក្រោមការត្រួតពិនិត្យរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

[៤៥] មាត្រា ៣៦ ថ្មី នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ។

[៤៦] មាត្រា ៣៧ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ។

[៤៧] សូមមើលមាត្រា ១៨ និង មាត្រា ១៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ទាក់ទងនឹង និយមន័យនៃបទល្មើសជាក់ស្តែង និងលក្ខខណ្ឌនៃការប្រើអំណាចបង្ខំរបស់មន្ត្រីនគរបាលយុត្តិធម៌ ដូចជា អំណាចក្នុងការចាប់ខ្លួន និងឃាត់ខ្លួន ជាដើម ។

Scanned with CamScanner

សម្រេចឃាត់ខ្លួនជនល្មើសនៅក្នុងបទល្មើសជាក់ស្តែង និងគ្រប់ជនទាំងអស់ដែលប្រឆាំងនឹងជននោះ មន្ត្រីនគរបាលយុត្តិ-ធម៌មានភស្តុតាងច្បាស់ច្បាស់ និងស៊ីចង្វាក់ដែលបញ្ជាក់ថា ជននោះបានចូលរួមក្នុងការប្រព្រឹត្តបទល្មើស ។ ការសម្រេចឃាត់ខ្លួនអាចធ្វើបានដោយមន្ត្រីនគរបាលយុត្តិធម៌ សម្រាប់រយៈពេលមិនលើសពី ៤៨ ម៉ោង ។ ក្នុងករណីបទល្មើសឧក្រិដ្ឋ និងតាមការស្នើសុំជាលាយលក្ខណ៍អក្សរពីមន្ត្រីនគរបាលយុត្តិធម៌ ព្រះរាជអាជ្ញាអាចសម្រេចអនុញ្ញាតឱ្យឃាត់ខ្លួនរយៈពេល ២៤ ម៉ោង បន្ថែមទៀត ប្រសិនបើមានតម្រុយចង្អុលបង្ហាញច្បាស់ថា ជននោះបានចូលរួមនៅក្នុងការប្រព្រឹត្តបទល្មើស ហើយដែលរយៈពេលបន្ថែម ២៤ ម៉ោងនេះចាំបាច់ ដើម្បីបម្រើឱ្យការស៊ើបអង្កេតប្រព្រឹត្តទៅបានល្អ[៤៨] ។ ក្នុងករណីផ្សេងពីនេះ មន្ត្រីនគរបាលយុត្តិធម៌មិនអាចចាប់ខ្លួន ឬឃាត់ខ្លួនជនជាប់សង្ស័យបានឡើយ ប្រសិនបើពុំមានដីកាពីតុលា-ការ ដូចជាដីកានាំខ្លួន ឬដីកាចាប់ខ្លួន ជាដើម[៤៩] ។

នគរបាលយុត្តិធម៌ត្រូវកត់ត្រាក្នុងកំណត់ហេតុរបស់ខ្លួន នូវរាល់ប្រតិបត្តិការស្វែងរក និងពិនិត្យបទល្មើស និងរាល់លទ្ធផលនៃប្រតិបត្តិការនៃការស៊ើបអង្កេតផ្សេងៗ ។ កំណត់ហេតុទាំងនេះមានតម្លៃគ្រាន់តែជាព័ត៌មានប៉ុណ្ណោះ ។ និយាយម្យ៉ាងទៀត កំណត់ហេតុទាំងនេះមានតម្លៃគ្រាន់តែជារបាយការណ៍ធម្មតាដែលពុំមានកំលាំងជាភស្តុតាងអ្វីជាពិសេសឡើយ ។ ប៉ុន្តែ ប្រសិនបើកំណត់ហេតុទាំងនោះ ធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ កំណត់ហេតុទាំងនោះ ត្រូវចាត់ទុកជាបន្ទាល់ ដែលចៅក្រមត្រូវតែជឿរហូតដល់មានភស្តុតាងផ្ទុយ ហើយដែលភស្តុតាងផ្ទុយនេះ អាចត្រូវបានគេជូនមកចៅក្រម តាមគ្រប់មធ្យោបាយស្របច្បាប់ទាំងអស់ ។ ក្នុងករណីដែលពុំមានភស្តុតាងផ្ទុយ ចៅក្រមត្រូវចាត់ទុកព័ត៌មាន ឬខ្លឹមសារនៅក្នុងកំណត់ហេតុនោះថា ពិតប្រាកដ ។

ប្រសិនបើជនជាប់សង្ស័យត្រូវបានចាប់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនជននោះទៅព្រះរាជអាជ្ញាក្នុងរយៈពេលមិនលើសពី ៤៨ ម៉ោង (ឬ ៧២ ម៉ោង ក្នុងករណីដែលមានការពន្យាពេលនៃការឃាត់ខ្លួន) ។ រយៈពេល ៤៨ ម៉ោង ឬ ៧២ ម៉ោងនេះ មិនត្រូវរាប់បញ្ចូលរយៈពេលចាំបាច់សម្រាប់ការដឹកជញ្ជូនជនជាប់សង្ស័យឡើយ ។ នៅក្នុងគ្រប់ករណីទាំងអស់ មន្ត្រីនគរបាលយុត្តិធម៌មិនអាចសម្រេចតម្កល់រឿងព្រហ្មទណ្ឌទុកមិនចាត់ការបានទេ ទោះបីជាភាគីទាំងអស់សុខចិត្តធ្វើការសម្រុះសម្រួលគ្នាក៏ដោយ ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែបញ្ជូនរឿងក្តី ដែលខ្លួនបានរកឃើញ ឬបានទទួលទៅព្រះរាជអាជ្ញាចាត់ការតាមនីតិវិធីបន្តជាងរាប[៥០] ។

---

[៤៨] មាត្រា ៣៨ ថ្មី នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ។

[៤៩] មាត្រា ៣៥ និង មាត្រា ៣៨ ថ្មី នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ។

[៥០] មាត្រា ៤៧ និង មាត្រា ៤៨ ថ្មី នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ។ មន្ត្រីនគរបាលយុត្តិធម៌ ដែលមិនគោរពបទប្បញ្ញត្តិដែលមានចែងក្នុងមាត្រា ៤៧ និងមាត្រា ៤៨ ខាងលើនេះ អាចត្រូវផ្តន្ទាទោសដាក់ពន្ធនាគារដោយយោងតាមមាត្រា ២២ និង មាត្រា ៥៧ នៃ ច្បាប់ព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ១៩៩២ ។

Scanned with CamScanner

២.២. ព្រះរាជអាជ្ញា

ខុសពីរឿងរដ្ឋប្បវេណី ដែលព្រះរាជអាជ្ញាមានតួនាទីបន្ទាប់បន្សំ នៅក្នុងរឿងព្រហ្មទណ្ឌ ព្រះរាជអាជ្ញាត្រូវបានច្បាប់ផ្តល់អំណាចឱ្យធំធេងណាស់[៥១] ។ ក្នុងនាមជាម្ចាស់បណ្តឹងអាជ្ញា[៥២] ព្រះរាជអាជ្ញាទទួលកំណត់ហេតុ និងរបាយការណ៍ពីនគរបាលយុត្តិធម៌ទាក់ទងបទល្មើសព្រហ្មទណ្ឌ បណ្តឹងទាមទារ និងបណ្តឹងបរិហារនានាពីប្រជាពលរដ្ឋ ឬពីមន្ត្រីពាក់ព័ន្ធផ្សេងទៀត ។ ក្រោយពេលទទួលដំណឹងអំពីបទល្មើសព្រហ្មទណ្ឌ ព្រះរាជអាជ្ញាត្រូវចាត់វិធានការ ធ្វើការអង្កេតចាំបាច់ស្របតាមនីតិវិធីនៃច្បាប់ ដើម្បីពិនិត្យអំពីពិរុទ្ធភាពរបស់ជនជាប់សង្ស័យ ។ នៅក្នុងករណីបទល្មើសជាក់ស្តែង ព្រះរាជ-អាជ្ញាអាចចាត់វិធានការធ្វើការស៊ើបអង្កេតបឋមដោយខ្លួនឯង ។ យោងតាមមាត្រា ៦២ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ១៩៩៣ នៅក្នុងករណីបទល្មើសឧក្រិដ្ឋជាក់ស្តែង និងមុនពេលដែលចៅក្រមស៊ើបអង្កេតបានទទួលសំណុំរឿង ព្រះរាជអាជ្ញាអាចចេញដីកានាំខ្លួន សូរចម្លើយជនពាក់ព័ន្ធផ្សេង។ ចាត់នីតិវិធីឆែកឆេរលំនៅដ្ឋានរបស់ជនជាប់សង្ស័យ និងរឹបអូសវត្ថុតាងចាំបាច់នានា ដើម្បីបង្ហាញការពិត ហើយក្នុងករណីចាំបាច់ អាចចាត់តាំងអ្នកជំនាញបាន ។ ក្រោយពេលបានចុះប្រតិបត្តិការលើកន្លែងកើតហេតុរួចមក សំណុំរឿង ព្រមទាំងភស្តុតាងនានាដែលប្រមូលបាន ត្រូវបញ្ជូនទៅចៅក្រមដោយភ្ជាប់ដីកាសន្និដ្ឋានបញ្ជូនរឿងស៊ើបសួរ ដើម្បីបន្តការស៊ើបអង្កេត ។

នៅពេលបានទទួលពាក្យបណ្តឹងទាមទារ បណ្តឹងបរិហារ ឬកំណត់ហេតុបទល្មើស ឬបន្ទាប់ពីមានការស៊ើបអង្កេត ព្រះរាជអាជ្ញាត្រូវធ្វើការពិនិត្យលើអង្គហេតុ និងសម្រេចលើបណ្តឹងអាជ្ញា ។ យោងតាមអង្គហេតុនៃរឿង ព្រះរាជអាជ្ញាសម្រេច :

- តម្កល់រឿងទុកមិនចាត់ការ ប្រសិនបើអំពើដែលគេប្តឹងមកខ្លួន ឬដែលខ្លួនបានទទួលនោះ មិនចូលជាបទល្មើសព្រហ្មទណ្ឌទេនោះ ។ នៅក្នុងករណីនេះ ព្រះរាជអាជ្ញាត្រូវជូនដំណឹងទៅភាគីអំពីការសម្រេចតម្កល់រឿងទុកមិនចាត់ការនោះ ក្នុងរយៈពេល ២ ខែ គិតចាប់ពីថ្ងៃទទួលពាក្យប្តឹង ។ ភាគីដែលបានដាក់ពាក្យប្តឹងហើយ នៅតែយល់ថា អំពើដែលខ្លួនបានប្តឹងនោះ ជាបទល្មើសព្រហ្មទណ្ឌ អាចប្តឹងតវ៉ាអំពីការសម្រេចតម្កល់រឿងទុកមិនចាត់ការរបស់ព្រះរាជអាជ្ញា ទៅសាលាឧទ្ធរណ៍បាន ។ សេចក្តីសម្រេចតម្កល់រឿងទុកមិនចាត់ការរបស់ព្រះរាជអាជ្ញា ពុំមានអាជ្ញាអស់ជំនុំ ដូចសាលក្រម ឬសាលដីកាស្ថាពរឡើយ ពោលគឺព្រះរាជអាជ្ញាអាចលើកយករឿងនោះមកចោទប្រកាន់វិញពេលណាក៏បាន កុំឱ្យតែបណ្តឹងអាជ្ញា ត្រូវបានរលត់ដោយផុតអាជ្ញាយុកាល ឬដោយករណីផ្សេង ទៀតដែលមានចែងក្នុងច្បាប់[៥៣] ។

---

[៥១] គួរកត់សំគាល់ថា នៅក្នុងរឿងព្រហ្មទណ្ឌ អយ្យការត្រូវតាំងខ្លួនជាតូក្តីដើមរហូត រីឯនៅក្នុងរឿងរដ្ឋប្បវេណី ជាគោលការណ៍ អយ្យការគ្រាន់តែមានតួនាទីជាភាគី "រណប" ប៉ុណ្ណោះ ។

[៥២] មាត្រា ១៣១ ថ្មី (មាត្រា ១១២ ចាស់) នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣, មាត្រា ៥ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពនៃសាលាជំរះក្តីនៃរដ្ឋកម្ពុជា ចុះថ្ងៃទី ០៨-០២-១៩៩៣, មាត្រា ៤ និង មាត្រា ៨ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ និង មាត្រា ២ នៃច្បាប់ ព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី ១០-០៩-១៩៩២ ។

[៥៣] មាត្រា ៥៩ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ។

Scanned with CamScanner

- ចោទប្រកាន់តាមរយៈបណ្តឹងអាជ្ញា[៥៤] ប្រសិនបើអំពើដែលគេប្តឹងមកខ្លួន ឬដែលខ្លួនបានទទួលនោះ គឺជាបទល្មើសព្រហ្មទណ្ឌ ។ ការចោទប្រកាន់តាមរយៈបណ្តឹងអាជ្ញានេះ អាចធ្វើឡើងតាមនីតិវិធី ២ តទៅទៀតដូចខាងក្រោម :

ក-ប្រសិនបើអំពើនោះចូលជាបទល្មើសឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវតែធ្វើការចោទប្រកាន់ ដោយស្នើសុំឱ្យមានការស៊ើបអង្កេតមួយដោយចៅក្រមស៊ើបអង្កេត ។ នៅក្នុងករណីនេះ ព្រះរាជអាជ្ញាធ្វើដីកាមួយ គឺ "ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ" ដោយធ្វើការវាយតម្លៃកំណត់បទល្មើស បញ្ជាក់អំពីអត្ថបទច្បាប់ និងចង្អុលឱ្យចំបុគ្គលដែលពាក់ព័ន្ធនឹងបទល្មើសនោះ ហើយបញ្ជូនដីកានោះ ទៅប្រធានតុលាការដើម្បីស្នើសុំឱ្យមានការស៊ើបអង្កេតដោយចៅក្រម ។

ខ-ប្រសិនបើអំពើនោះ ជាបទល្មើសមជ្ឈិមវិញ ព្រះរាជអាជ្ញាអាច ឬមួយស្នើសុំឱ្យមានការស៊ើបអង្កេត ដូចករណីខាងលើ ក្នុងករណីដែលអំពើនោះជាបទល្មើសមជ្ឈិមធ្ងន់ធ្ងរ និងស្មុគស្មាញ ឬមួយសម្រេចធ្វើការចោទប្រកាន់ដោយប្តឹងទៅតុលាការជំនុំជម្រះដោយផ្ទាល់តែម្តង តាមនីតិវិធីនៃការចោទប្រកាន់ដោយផ្ទាល់ ក្នុងករណីបទល្មើសមជ្ឈិមដែលអាចត្រូវផ្តន្ទាទោសជាក់ពន្ធនាគារជាអតិបរមាមិនលើសពី ១ ឆ្នាំ ឬតាមនីតិវិធីនៃការនាំខ្លួនជនជាប់ចោទជាបន្ទាន់ទៅទីសវនាការក្នុងករណីបទល្មើសជាក់ស្តែង[៥៥] ។

២_ ដំណាក់កាលស៊ើបអង្កេត

ការស៊ើបអង្កេតក្នុងរឿងព្រហ្មទណ្ឌត្រូវដឹកនាំដោយចៅក្រមម្នាក់ដែលគេឱ្យឈ្មោះថា "ចៅក្រមស៊ើបអង្កេត" ។ ក្នុងហ៊ានៈជាចៅក្រមអាសនៈនៃតុលាការខេត្ត ក្រុង ចៅក្រមរូបនេះអាចបំពេញតួនាទីរបស់ខ្លួននៅក្នុងសំណុំរឿងផ្សេងគ្នាជាចៅក្រមស៊ើបអង្កេតក៏បាន ជាចៅក្រមជំនុំជម្រះក៏បាន ។ យោងតាមគោលការណ៍នៃការបែងចែកមុខងាររវាងការធ្វើបណ្តឹងអាជ្ញា (ឬការចោទប្រកាន់) និងការស៊ើបអង្កេត ចៅក្រមស៊ើបអង្កេតមិនអាចធ្វើការស៊ើបអង្កេតរឿងក្តីណាមួយដោយខ្លួនឯងបានឡើយ ប្រសិនបើព្រះរាជអាជ្ញាមិនបានស្នើសុំឱ្យមានការស៊ើបអង្កេត តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[៥៦] ហើយប្រសិនបើគាត់ពុំត្រូវបានតែងតាំងដោយប្រធានតុលាការ បន្ទាប់ពីពិនិត្យសំណុំរឿង ។

---

[៥៤] ក្រោយពេលមានការចោទប្រកាន់ដោយព្រះរាជអាជ្ញា "ជនជាប់សង្ស័យ" ត្រូវបានគេឱ្យឈ្មោះថា "ជនជាប់ចោទ" ។

[៥៥] មាត្រា ៦១, មាត្រា ៦៤ ដល់ មាត្រា ៦៧ និងមាត្រា ១០២ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ។ ដោយយោងតាមបទប្បញ្ញត្តិនៃមាត្រា ១០២ ដែលគេអាចធ្វើការបែងចែកនីតិវិធីនៃការនាំខ្លួនជនជាប់ជាបន្ទាន់ទៅទីសវនាការ (មាត្រា ៦៤ ដល់មាត្រា ៦៦ និងមាត្រា ១០២) ពីនីតិវិធីនៃការចោទប្រកាន់ដោយផ្ទាល់ទៅតុលាការ (មាត្រា ៦១, មាត្រា ៦៧ និងមាត្រា ១០២) ។

[៥៦] មាត្រា ៦៩ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ចែងថា "ចៅក្រមស៊ើបអង្កេតធ្វើលិខិតស៊ើបអង្កេតអ្វីមិនបានទេ ប្រសិនបើគ្មានបានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់តំណាងអយ្យការទេ ។

ក្នុងករណីដែលចៅក្រមស៊ើបអង្កេតបានទទួលផ្ទាល់នូវបណ្តឹងទាមទារណាមួយនោះ ចៅក្រមស៊ើបអង្កេតត្រូវបញ្ជូនពាក្យប្តឹងនោះ ព្រមទាំងលិខិតនានាដែលមានភ្ជាប់មកជាមួយនោះ ដោយខ្លួនមិនត្រូវចាត់ការស៊ើបអង្កេតអ្វីបន្តិចបន្តួចមុនឡើយ ទៅជូនព្រះរាជអាជ្ញា ដែលនឹងត្រូវចាត់ការដូចបញ្ញត្តិដែលមានចែងក្នុងជំពូកមុន" ។

Scanned with CamScanner

ក្រោយពេលទទួលបានការចោទប្រកាន់ និងសំណុំរឿង ចៅក្រមស៊ើបអង្កេតអាចចាត់គ្រប់វិធានការទាំងអស់ដែលខ្លួនយល់ថា ចាំបាច់ដើម្បីបំភ្លឺការពិត[៥៧] ។ ចៅក្រមស៊ើបអង្កេតអាចចាត់នីតិវិធីសួរចម្លើយជនជាប់ចោទ និងយកចម្លើយពីជនពាក់ព័ន្ធ ឬសាក្សីផ្សេងៗ ចៅក្រមស៊ើបអង្កេតអាចចុះទៅដល់ទីកន្លែងកើតហេតុ ធ្វើការឆែកឆេរ និងរឹបអូសវត្ថុតាងនានា ឬអាចចាត់ឱ្យមានការធ្វើកោសលវិច័យ ប្រសិនបើចៅក្រមស៊ើបអង្កេតយល់ថា ចាំបាច់ដើម្បីបំភ្លឺការពិត ។ ប្រសិនបើចៅក្រមស៊ើបអង្កេតស្ថិតក្នុងស្ថានភាពមិនអាចធ្វើកិច្ចស៊ើបសួរបាន ចៅក្រមស៊ើបអង្កេតអាចស្នើសុំឱ្យមន្ត្រីនគរបាលយុត្តិធម៌ ឬចៅក្រមស៊ើបអង្កេតនៃតុលាការថ្នាក់ទី ១ ផ្សេងទៀតដែលមានសមត្ថកិច្ចតាមដែនដី ធ្វើកិច្ចនោះជំនួសបានតាមរយៈដីកាមួយគឺ ដីកាចាត់ឱ្យសួរជំនួស ។ នៅក្នុងគ្រប់កិច្ចនីតិវិធីនៃការស៊ើបអង្កេតរបស់ខ្លួន ចៅក្រមស៊ើបអង្កេតត្រូវធ្វើកំណត់ហេតុ ដោយមានការចុះហត្ថលេខាពីចៅក្រមស៊ើបអង្កេត និងក្រឡាបញ្ជីព្រមទាំងបុគ្គលពាក់ព័ន្ធផ្សេងទៀត ។

នៅក្នុងដំណាក់កាលនៃនីតិវិធីនេះ សិទ្ធិនៃការការពារខ្លួនត្រូវបានផ្តល់ឱ្យជនជាប់ចោទចាប់តាំងពីពេលដែលជននោះចូលខ្លួនជាលើកទី ១ នៅចំពោះមុខចៅក្រមស៊ើបអង្កេត ។ ក្រោយពេលធ្វើការផ្ទៀងផ្ទាត់លើអត្តសញ្ញាណនៃជនជាប់ចោទ និងប្រាប់ជនជាប់ចោទអំពីបទចោទប្រកាន់ដោយព្រះរាជអាជ្ញារួចមក ចៅក្រមស៊ើបអង្កេត ត្រូវតែបញ្ជាក់ប្រាប់ជនជាប់ចោទអំពីសិទ្ធិក្នុងការឆ្លើយ ឬមិនឆ្លើយដោយគ្មានមេធាវីការពារខ្លួន ។ ប្រសិនបើ ជនជាប់ចោទស្នើសុំរកមេធាវីការពារខ្លួន នៅក្នុងករណីនេះ ចៅក្រមស៊ើបអង្កេតត្រូវផ្អាកការសួរចម្លើយ ហើយត្រូវកោះហៅមេធាវីដែលនឹងត្រូវជ្រើសរើសដោយជនជាប់ចោទខ្លួនឯង ឬដែលត្រូវចាត់តាំងដោយប្រធានតុលាការមកស្តាប់ការសួរចម្លើយជនជាប់ចោទ ដែលនឹងធ្វើនៅចំពោះមុខមេធាវីនោះ ។ ប្រធានតុលាការត្រូវធ្វើការចាត់តាំងដោយឯកឯង នូវមេធាវីក្នុងករណីដូចខាងក្រោម[៥៨] :

- ជនជាប់ចោទជាអនីតិជនគ្មានទីពឹង
- ជនជាប់ចោទជាមនុស្ស ឥ ថ្លង់ មនុស្សខ្វាក់ ឬជនមានវិបត្តិស្មារតី
- ជនជាប់ចោទត្រូវជាប់ចោទពីបទឧក្រិដ្ឋណាមួយ ហើយខ្លួនគ្មានលទ្ធភាពអាចពឹងអ្នកជួយការពារខ្លួនបាន

នៅក្នុងករណីផ្សេងពីករណីខាងលើនេះ ចៅក្រមស៊ើបអង្កេតអាចសួរយកចម្លើយជនជាប់ចោទបាន កាលណាជនជាប់ចោទ សុខចិត្តការពារខ្លួនដោយខ្លួនឯង ។

ប្រសិនបើជនជាប់ចោទ ស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្ន មេធាវី ឬអ្នកការពារសិទ្ធិអាចប្រាស្រ័យទាក់ទងជននេះបានដោយសេរី ។ ការសន្ទនា ឬការនិយាយទាក់ទងគ្នារវាងមេធាវី ឬអ្នកការពារសិទ្ធិ ជាមួយកូនក្តីខ្លួន ដែលជាប់ឃុំខ្លួនបណ្តោះអាសន្ន មិនត្រូវគេលួចស្តាប់ ឬកត់ត្រាឡើយ ។ មេធាវី ឬអ្នកការពារសិទ្ធិអាចឱ្យកូនក្តីខ្លួនស្តាប់នូវអ្វីដែលខ្លួនបានឃើញ ឬបានកត់ត្រាចេញពីសំណុំរឿង ហើយដែលខ្លួនយល់ថា មានប្រយោជន៍ក្នុងកិច្ចការពារកូនក្តីខ្លួន ។

---

[៥៧] ដោយហេតុនេះហើយ បានជាគេឱ្យឈ្មោះចៅក្រមស៊ើបអង្កេតថា ជា "ចៅក្រមដាក់បន្ទុក និងដោះបន្ទុក" ។ សូមមើលមាត្រា ៨៧ និងមាត្រា ១២៥ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ។ សូមមើលផងដែរ មាត្រា ២៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី ១០-០៩-៩២ ស្តីពីមធ្យោបាយនៃកស្តុតាង ។

[៥៨] សូមមើល មាត្រា ៧៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ។

Scanned with CamScanner

ប៉ុន្តែ មេធាវី ឬអ្នកការពារសិទ្ធិមិនត្រូវប្រគល់ឯកសារ ឬវត្ថុអ្វីឱ្យដល់កូនក្តីខ្លួនឡើយ កាលបើគ្មានការអនុញ្ញាតពិសេសពីចៅក្រមស៊ើបអង្កេត[៥៩] ។

ក្រោយពេលចូលខ្លួនជាលើកទី ១ នៅចំពោះមុខខ្លួន ចៅក្រមស៊ើបអង្កេតអាចសម្រេចភ្លាមអំពីការដាក់ឱ្យជនជាប់ចោទនៅក្នុងឃុំបណ្តោះអាសន្ន ឬឱ្យនៅក្រៅឃុំ ។ គួរកត់សំគាល់ផងដែរថា នៅក្នុងដំណាក់កាលនេះ មានតែចៅក្រមស៊ើបអង្កេតទេ ដែលមានអំណាចក្នុងការសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ន ។ ជាគោលការណ៍ ដើម្បីសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចៅក្រមស៊ើបអង្កេតត្រូវមានបទុកច្បាស់លាស់ ធ្ងន់ធ្ងរ និងស្ថិតង្វាក់គ្នាដែលបញ្ជាក់ថា ជនជាប់ចោទបានចូលរួមក្នុងការប្រព្រឹត្តបទល្មើស ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារក្នុងនាមជាជនសមគំនិត ឬជនដៃដល់ ។ សេចក្តីសម្រេចឃុំខ្លួនបណ្តោះអាសន្ន ត្រូវចែងឱ្យបានច្បាស់អំពីមូលហេតុនៃការសម្រេចរបស់ខ្លួន ។ យោងតាមមាត្រា ១៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ មានមូលហេតុចំបងពីរដែលនាំឱ្យចៅក្រមស៊ើបអង្កេតសម្រេចឃុំខ្លួនបណ្តោះអាសន្ន[៦០] គឺ :

ទី១-ការសម្រេចឃុំខ្លួនបណ្តោះអាសន្នធ្វើឡើងដោយខ្លាចជនជាប់ចោទមិនចូលខ្លួនមកតុលាការ ដោយហេតុជនជាប់ចោទគ្មានអ្វីអាចធានាថា ខ្លួននឹងបង្ហាញខ្លួននៅចំពោះតុលាការ ។

ទី២-ដើម្បីធានាដំណើរការស៊ើបអង្កេតឱ្យបានល្អ ជាពិសេសដើម្បីកុំឱ្យជនជាប់ចោទប្រើឥទ្ធិពលលើសាក្សី ឬជនរងគ្រោះ ឬបំផ្លាញភស្តុតាងនានាជាដើម ។

វិធានការបង្ខំដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេរីភាពបុគ្គលនេះ អាចត្រូវបានចៅក្រមស៊ើបអង្កេតសម្រេចដោយឯកឯង ឬដោយមានការស្នើសុំពីព្រះរាជអាជ្ញា ឬពីជនរងគ្រោះ ។ ប្រសិនបើវិធានការនេះត្រូវបានស្នើសុំ ដោយព្រះរាជអាជ្ញា ឬជនរងគ្រោះ ចៅក្រមស៊ើបអង្កេតត្រូវសំរេចក្នុងរយៈពេល ៥ ថ្ងៃ ដោយដីកាមួយដែលមាន ចែងហេតុផលត្រឹមត្រូវ[៦១] ។ ភាគីទាំងអស់មានសិទ្ធិប្តឹងតវ៉ាទៅសាលាឧទ្ធរណ៍ប្រឆាំងនឹងការសម្រេចរបស់ចៅក្រមស៊ើបអង្កេតក្នុងរយៈពេល ១៥ ថ្ងៃ គិតពីថ្ងៃបានទទួលដំណឹង[៦២] ហើយសាលាឧទ្ធរណ៍ត្រូវសម្រេចអំពីបណ្តឹងឧទ្ធរណ៍នេះ ក្នុងរយៈពេល ១៥ ថ្ងៃ យ៉ាងយូរគិតពីថ្ងៃទទួលពាក្យបណ្តឹងឧទ្ធរណ៍[៦៣] ។ ការសម្រេចឃុំខ្លួនបណ្តោះអាសន្ន ឬនៅក្រៅឃុំនេះ មាន

---

[៥៩] មាត្រា ៨០ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ។

[៦០] បើយោងតាមការអនុវត្តជាក់ស្តែង ជាទូទៅ ចៅក្រមស៊ើបអង្កេត តែងបញ្ជាក់មូលហេតុនៅក្នុងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ខ្លួនថា " ដើម្បីធានាការស៊ើបអង្កេតឱ្យបានល្អ" ។

[៦១] មាត្រា ៩៥ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ។

[៦២] មាត្រា ៧៩ វិក្យខណ្ឌ ២ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ។ ប៉ុន្តែ បើយោងតាមមាត្រា ១៤ ចំណុចទី ៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ រយៈពេលនៃការប្តឹងឧទ្ធរណ៍ខាងលើ ត្រូវបានកំណត់ត្រឹម ៥ ថ្ងៃវិញ ក្រោយពីថ្ងៃចេញដីកាសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ន ។

[៦៣] ដូចកំណត់យោងខាងលើ ។

Scanned with CamScanner

អានុភាពអនុវត្តភ្លាម ទោះជាមានបណ្តឹងតវ៉ាទៅសាលាឧទ្ធរណ៍ក៏ដោយ លើលែងតែមានបណ្តឹងឧទ្ធរណ៍របស់តំណាងអយ្យការប៉ុណ្ណោះ[៦៤] ។

ក្រៅពីអំណាចក្នុងការសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចៅក្រមស៊ើបអង្កេតមានអំណាចក្នុងការចាត់គ្រប់វិធានការទាំងអស់ដែលចៅក្រមស៊ើបអង្កេតយល់ថាចាំបាច់ ដើម្បីបំភ្លឺការពិត ប៉ុន្តែ អំណាចនេះពុំមែនជាអំណាចដែលគ្មានព្រំដែនកំណត់ឡើយ ។ ដូចនេះ ចៅក្រមស៊ើបអង្កេតអាចស៊ើបអង្កេតបានតែក្នុងអង្គហេតុ ឬអំពើដែលមានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាតែប៉ុណ្ណោះ ។ យន្តការនេះ គេឱ្យឈ្មោះថា "ការប្តឹងទៅចៅក្រមស៊ើបអង្កេតចំពោះអំពើ" ។ ប្រសិនបើក្នុងពេលស៊ើបអង្កេត ចៅក្រមស៊ើបអង្កេតរកឃើញមានអង្គហេតុថ្មីផ្សេងទៀតដែលបង្កើតឱ្យមានបទល្មើសថ្មីផ្សេងពីបទល្មើសដែលមានកំណត់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ចៅក្រមស៊ើបអង្កេត មិនអាចធ្វើការស៊ើបអង្កេតទៅលើអំពើថ្មីនោះទេ ។ ដោយយោងតាមគោលការណ៍នៃការបែងចែកមុខងារធ្វើបណ្តឹងអាជ្ញា និងមុខងារស៊ើបអង្កេត ចៅក្រមស៊ើបអង្កេតត្រូវស្នើសុំដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពីព្រះរាជអាជ្ញាទើបអាចធ្វើការស៊ើបអង្កេតលើបទល្មើសថ្មីបាន ។ ប៉ុន្តែ ប្រសិនបើអង្គហេតុថ្មីនេះគ្រាន់តែបង្កើតបានជាស្ថានទម្ងន់ទោសនៃបទល្មើស ដែលមានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ចៅក្រមអាចបន្តការស៊ើបអង្កេតរបស់ខ្លួនចំពោះអង្គហេតុថ្មីនោះបាន[៦៥] ។ ជាគោលការណ៍ ចៅក្រមស៊ើបអង្កេតក៏មិនចាំបាច់ស្នើសុំដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពីព្រះរាជអាជ្ញាដែរ កាលបើក្នុងពេលស៊ើបអង្កេត ចៅក្រមស៊ើបអង្កេតរកឃើញមានបុគ្គលផ្សេងទៀតដែល ពុំមានកំណត់ឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ប៉ុន្តែ បុគ្គលទាំងនោះគឺជាជនសមគំនិត ឬសហការីនៅក្នុងបទល្មើសដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ។ ប៉ុន្តែ នៅក្នុងការអនុវត្ត ចៅក្រមស៊ើបអង្កេតក៏ត្រូវស្នើសុំដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមផងដែរ នៅពេលដែលចៅក្រមស៊ើបអង្កេតរកឃើញមានបុគ្គលថ្មីជាជនល្មើសដែលពុំមានកំណត់ ឬចង្អុលបង្ហាញក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[៦៦] ។

យោងតាមការបកស្រាយខាងលើ ចៅក្រមស៊ើបអង្កេតអាចធ្វើការស៊ើបអង្កេតបានតែទៅអ្វីដែលមានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងរបស់ព្រះរាជអាជ្ញាតែប៉ុណ្ណោះ ។ ប៉ុន្តែ នៅក្នុងករណីខ្លះ ចៅក្រមស៊ើបអង្កេតអាចយល់ឃើញខុសពីព្រះរាជអាជ្ញាទាក់ទងទៅនឹងការវាយតម្លៃកំណត់បទល្មើស ។ នៅក្នុងករណីនេះ ចៅក្រមស៊ើបអង្កេតអាចធ្វើការកែប្រែបទចោទប្រកាន់ ខុសពីបទចោទប្រកាន់របស់ព្រះរាជអាជ្ញានៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ។ នៅក្នុងករណីដែលមានការកែប្រែបទចោទប្រកាន់ ចៅក្រមស៊ើបអង្កេតត្រូវជូនដំណឹងទៅព្រះរាជអាជ្ញា ដើម្បីអាចឱ្យ

[៦៤] មាត្រា ៧៩ វគ្គខណ្ឌ ១ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ។
[៦៥] មាត្រា ៨១ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ។
[៦៦] តុលាការក្រុងភ្នំពេញ. សំណុំរឿងព្រហ្មទណ្ឌលេខ ១៨០ ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០២ ។

Scanned with CamScanner

ព្រះរាជអាជ្ញាធ្វើការប្តឹងតវ៉ាទៅសាលាឧទ្ធរណ៍បាន ក្នុងរយៈពេល ២៤ ម៉ោង[៦៧] ។ ប៉ុន្តែ ប្រសិនបើចៅក្រមស៊ើបអង្កេត ធ្វើការកែប្រែបទចោទប្រកាន់ពីបទមជ្ឈឹមទៅបទឧក្រិដ្ឋ ចៅក្រមស៊ើបអង្កេត ត្រូវស្នើសុំឱ្យមានការចោទប្រកាន់ជាថ្មីពីអយ្យការ និងធ្វើការសួរចម្លើយសាជាថ្មីទៅលើអង្គហេតុនោះ[៦៨] ។

នៅពេលដែលចៅក្រមស៊ើបអង្កេតយល់ឃើញថា ការស៊ើបអង្កេតមូលសព្វគ្រប់ហើយ ចៅក្រមស៊ើបអង្កេត ត្រូវទុកសំណុំរឿងឱ្យមេធាវីជនជាប់ចោទធ្វើការពិនិត្យក្នុងរយៈពេល ២៤ ម៉ោង ។ បន្ទាប់មកចៅក្រមស៊ើបត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាតាមរយៈដីកាមួយ ដែលគេឱ្យឈ្មោះថា "ដីកាជូនរឿងទៅពិនិត្យមូល" ។ ក្នុងរយៈពេល ៣ ថ្ងៃបន្ទាប់ពីថ្ងៃទទួលបានសំណុំរឿង ព្រះរាជអាជ្ញាត្រូវធ្វើសេចក្តីសន្និដ្ឋានស្ថាពររបស់ខ្លួន ហើយបញ្ជូនសំណុំរឿងទៅចៅ-ក្រមស៊ើបអង្កេតវិញ តាមដីកាមួយគេឱ្យឈ្មោះថា "ដីកាសន្និដ្ឋានស្ថាពរ" ។ ក្រោយពេលទទួលបាននូវសេចក្តីសន្និដ្ឋានស្ថាពរពីអយ្យការហើយ ចៅក្រមអាចធ្វើការសម្រេចដូចខាងក្រោម :

- ប្រសិនបើចៅក្រមស៊ើបអង្កេតយល់ឃើញថា អង្គហេតុដែលមានក្នុងសំណុំរឿងមិនចូលជាបទល្មើសឧក្រិដ្ឋ បទល្មើសមជ្ឈឹម ឬបទល្មើសលហុទេនោះ ឬប្រសិនបើពុំមានបន្ទុកគ្រប់គ្រាន់ ដែលបញ្ជាក់ថា ជនជាប់ចោទមានពិរុទ្ធទេនោះ ចៅក្រមស៊ើបអង្កេតសម្រេចធ្វើការលើកលែងការចោទប្រកាន់[៦៩] ។ ការសម្រេចលើកលែងការចោទប្រកាន់នេះ ត្រូវមានចែងមូលហេតុឱ្យបានច្បាស់លាស់ និងត្រូវជូនដំណឹងទៅភាគីទាំងអស់ ដើម្បីអាចឱ្យភាគីដែលមិនសុខចិត្តនឹងការសម្រេចនោះ ធ្វើការប្តឹងតវ៉ាទៅសាលាឧទ្ធរណ៍ ។ ជាគោលការណ៍ បណ្តឹងឧទ្ធរណ៍ពុំមានអានុភាពផ្អាកការអនុវត្តដីកាសម្រេចលើកលែងការចោទប្រកាន់របស់ចៅក្រមស៊ើបអង្កេតបានឡើយ លើកលែងតែបណ្តឹងឧទ្ធរណ៍ក្នុងរយៈពេល ២៤ ម៉ោង របស់ព្រះរាជអាជ្ញាតែប៉ុណ្ណោះ[៧០] ។ បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាត្រូវធ្វើក្នុងរយៈពេល ២៤ ម៉ោង ចំណែកឯភាគីផ្សេងទៀតអាចធ្វើបណ្តឹងឧទ្ធរណ៍បានក្នុងរយៈពេល ៦០ ថ្ងៃគិតពីថ្ងៃទទួលដំណឹង[៧១] ។ ប្រសិនបើ សាលាឧទ្ធរណ៍បដិសេធដីកាលើកលែងចោទប្រកាន់របស់ចៅក្រមស៊ើបអង្កេត ប្រធានសាលាឧទ្ធរណ៍អាចចេញដីកាចាប់ខ្លួនជនជាប់ចោទជាថ្មី ហើយយកមកឃុំខ្លួនបណ្តោះអាសន្ន កាលណាជនជាប់ចោទនៅក្រៅឃុំ ។

- ផ្ទុយមកវិញ ប្រសិនបើចៅក្រមស៊ើបអង្កេតយល់ឃើញថា មានបន្ទុកគ្រប់គ្រាន់ដើម្បីធ្វើការចោទប្រកាន់ជនជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ ចៅក្រមស៊ើបអង្កេតត្រូវបញ្ជូនសំណុំរឿង និងជនជាប់ចោទទៅជំនុំជម្រះ តាមរយៈដីកាមួយដែលគេហៅថា "ដីកាបញ្ជូនរឿងទៅជំនុំជម្រះ" ។ នៅក្នុងនីតិវិធីជាក់ស្តែង ចៅក្រមស៊ើបអង្កេតបញ្ជូនសំណុំរឿងទៅប្រធានតុលាការ ។ ក្រោយពេលទទួលបានសំណុំរឿង ប្រធានតុលាការនឹងធ្វើការចាត់តាំងចៅក្រមអាសនៈណាម្នាក់ ដើម្បីធ្វើការជំនុំជម្រះសំណុំរឿងនោះ ។ ចៅក្រមដែលអាចទទួលការតែងតាំងជាចៅក្រមជំនុំជម្រះ អាចជា

---

[៦៧] មាត្រា ៤២ វិក្យខណ្ឌ ៣ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ។

[៦៨] មាត្រា ៤៣ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ។

[៦៩] មាត្រា ៤០ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ។

[៧០] មាត្រា ៤០ ថ្មី នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ។

[៧១] មាត្រា ៤១ ថ្មី នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ។

Scanned with CamScanner

ប្រធានតុលាការខ្លួនឯង ឬចៅក្រមអាសនៈផ្សេងទៀតដែលមាននៅក្នុងយុត្តាធិការរបស់ខ្លួន ប៉ុន្តែ ចៅក្រមដែលបានទទួលការស៊ើបអង្កេតសំណុំរឿងនោះ មិនអាចត្រូវបានតែងតាំងជាចៅក្រមជំនុំជម្រះទៀតបានឡើយ ។

៣- ជំណាក់កាលជំនុំជម្រះ

ជាទូទៅ ខេត្ត ក្រុងនីមួយ១ មានតុលាការមួយ ដែលមានសមត្ថិចួលាតសន្ធឹងនៅក្នុងដែនដីនៃខេត្ត ក្រុងនោះ ។ នៅក្នុងរឿងព្រហ្មទណ្ឌ តុលាការខេត្ត ក្រុង មានសមត្ថកិច្ចជំនុំជម្រះគ្រប់បទល្មើសទាំងអស់ ទាំងបទល្មើសឧក្រិដ្ឋ មជ្ឈិម និងលហុ លើកលែងតែបទល្មើសយោធា ដែលជាសមត្ថកិច្ចរបស់តុលាការពិសេស គឺតុលាការយោធា ។ តុលាការជាន់ទីមួយនេះ ធ្វើការជំនុំជម្រះ ដោយមានចៅក្រមមួយរូប តំណាងអយ្យការម្នាក់ និងមានក្រឡាបញ្ជីមួយរូប ។

នៅពេលដែលប្រធានតុលាការបានទទួលសំណុំរឿងព្រហ្មទណ្ឌពីតំណាងអយ្យការតាមនីតិវិធីនៃការបញ្ជូនរឿងទៅជំនុំជម្រះដោយផ្ទាល់ ឬពីចៅក្រមស៊ើបអង្កេតតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះ ប្រធានតុលាការត្រូវចាត់តាំងចៅ-ក្រមអាសនៈណាម្នាក់ ដើម្បីទទួលបន្ទុកធ្វើការជំនុំជម្រះ ដែលចៅក្រមអាសនៈនេះ អាចជាប្រធានតុលាការខ្លួនឯងផ្ទាល់ ឬចៅក្រមអាសនៈម្នាក់ផ្សេងទៀត ក្រៅពីចៅក្រមដែលបានធ្វើការស៊ើបអង្កេត ។ ក្រោយពេលទទួលបានការចាត់តាំងចៅក្រមដែលទទួលបន្ទុកជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌនោះ ត្រូវជូនដំណឹងទៅមេធាវី និងភាគីទាំងអស់អំពីកាលបរិច្ឆេទនៃសវនាការ ។ ប្រសិនបើជនជាប់ចោទកំពុងជាប់ឃុំខ្លួនបណ្តោះអាសន្ន ចៅក្រមជំនុំជម្រះបញ្ជាឱ្យនាំខ្លួនជនជាប់ចោទចេញពីមន្ទីរឃុំឃាំង ហើយប្រសិនបើជនជាប់ចោទមិនស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្នទេនោះ ចៅក្រមចេញដីកាបង្គាប់ឱ្យជនជាប់ចោទចូលខ្លួន តាមកាលកំណត់នៃសវនាការ ។ នៅក្នុងករណីបទឧក្រិដ្ឋ វត្តមានមេធាវីការពារជនជាប់ចោទត្រូវមានជាដាច់ខាត ផ្ទុយទៅវិញ នៅក្នុងរឿងមជ្ឈិម វត្តមានមេធាវីការពារជនជាប់ចោទមិនចាំបាច់មានក៏បានដែរ ។ ប៉ុន្តែ ប្រសិនបើមានមេធាវីការពារក្តី ចៅក្រមជំនុំជម្រះត្រូវជូនដំណឹងទៅមេធាវីទាំងអស់ក្នុងរយៈពេល ១៥ ថ្ងៃ មុនពេលសវនាការ ដើម្បីអាចឱ្យមេធាវីពិនិត្យ និងសិក្សាសំណុំរឿង ។

ជាគោលការណ៍ សវនាការត្រូវធ្វើជាសាធារណៈ ។ សាលក្រមដែលត្រូវបានប្រកាសដោយរំលោភលើគោល-ការណ៍ជាសាធារណៈនេះ ត្រូវទុកជាមោឃៈ[៧២] ។ ប៉ុន្តែ សវនាការអាចធ្វើជាសម្ងាត់ ឬជាអសាធារណៈបាន ប្រសិនបើភាពជាសាធារណៈនៃសវនាការអាចធ្វើឱ្យមានគ្រោះថ្នាក់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬដល់ប្រពៃណីល្អ[៧៣] ។ សវនាការជាសម្ងាត់នេះអាចធ្វើបានតែទៅលើភាគមួយនៃការសួរដេញដោលតែប៉ុណ្ណោះ ពោលគឺការស៊ើបអង្កេត (ការសួរដេញដោល) នាពេលសវនាការ រីឯការប្រកាសសាលក្រម ជាចំខាតត្រូវធ្វើជាសាធារណៈ បើពុំនោះទេ ត្រូវទុកជាមោឃៈ ។

សវនាការព្រហ្មទណ្ឌត្រូវបានបែងចែកជាច្រើនដំណាក់កាល ដែលនៅទីនេះ យើងធ្វើការបែងចែកការសិក្សាទៅលើពីរដំណាក់កាលធំៗគឺ : ការស៊ើបអង្កេតនាពេលសវនាការ ឬការសួរដេញដោល និង ការប្រកាសសាលក្រម[៧៤] ។

---

[៧២] មាត្រា ១២៨ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ។

[៧៣] មាត្រា ១២៩ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ។

[៧៤] មាត្រា ១២៨ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ។

Scanned with CamScanner

នៅក្នុងពេលសវនាការ ចៅក្រមអាចធ្វើការសួរចម្លើយជនជាប់ចោទ សាកសួរសាក្សី និងជនពាក់ព័ន្ធដទៃផ្សេងទៀត ជាដើម ។ គ្រប់សំណួរទាំងអស់អាចត្រូវបានចោទសួរនាពេលសនាការតាមរយៈចៅក្រម លើកលែងតែសំណួររបស់តំណាងអយ្យការ របស់មេធាវី ឬអ្នកការពារសិទ្ធិ ដែលចៅក្រមអាចអនុញ្ញាតឱ្យសួរសំណួរដោយផ្ទាល់តែម្ដងបាន ។ នៅពេលចប់ការសួរដេញដោល ចៅក្រមអនុញ្ញាតឱ្យភាគី និងអ្នកពាក់ព័ន្ធផ្សេងៗ ទៀតនៅក្នុងនីតិវិធី និយាយជាចុងក្រោយ ឬធ្វើសេចក្ដីសន្និដ្ឋានជាបន្តបន្ទាប់ តាមលំដាប់ដូចតទៅ : ភាគីដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវខាងរដ្ឋប្បវេណី ជនជាប់ចោទ មេធាវី ឬអ្នកការពារសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី តំណាងអយ្យការ មេធាវី ឬអ្នកការពារសិទ្ធិរបស់អ្នកទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណី និងចុងក្រោយបង្អស់ មេធាវី ឬអ្នកការពារសិទ្ធិរបស់ជនជាប់ចោទ[៧៥] ។

កាលណាការសួរដេញដោល ការសន្និដ្ឋានទោសរបស់តំណាងអយ្យការ និងការសន្និដ្ឋានការពារបានធ្វើចប់សព្វគ្រប់ហើយ ចៅក្រមប្រកាសថយខ្លួនទៅបន្ទប់សម្ងាត់ដើម្បីពិចារណា ។ ចាប់ពីដំណាក់កាលនេះទៅ ការជូនសំអាង ឬសំណូមពរផ្សេងៗ មិនអាចធ្វើបានទៀតឡើយ[៧៦] ។ នៅពេលត្រលប់ចូលសវនាការពីបន្ទប់សម្ងាត់វិញ ចៅក្រមជំនុំជម្រះប្រកាសសាលក្រមរបស់ខ្លួនជាសាធារណៈ[៧៧] ។

សាលក្រមរបស់តុលាការខេត្ត ក្រុង អាចជាសាលក្រមចំពោះមុខ ឬកំបាំងមុខ ។ សាលក្រមចំពោះមុខ គឺ ជាសាលក្រមដែលត្រូវបានប្រកាសនៅចំពោះមុខជនជាប់ចោទ ប៉ុន្តែត្រូវចាត់ទុកជាសាលក្រមកំបាំងមុខវិញ ប្រសិនបើជនជាប់ចោទមិនបានចូលខ្លួននៅក្នុងសវនាការតាមការបង្គាប់ឱ្យចូលខ្លួនត្រឹមត្រូវតាមច្បាប់ដោយចៅក្រម មានន័យថា សាលក្រមត្រូវបានប្រកាសដោយអវត្តមានជនជាប់ចោទ ។ សាលក្រមចំពោះមុខបើកសិទ្ធិឱ្យភាគីធ្វើការប្ដឹងតវ៉ាទៅសាលាឧទ្ធរណ៍បានក្នុងរយៈពេល ២ ខែ គិតចាប់ពីថ្ងៃប្រកាសសាលក្រម ។ ជាទូទៅ បណ្ដឹងឧទ្ធរណ៍ត្រូវធ្វើទៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានចេញសាលក្រមនោះ[៧៨] ។ ចំពោះសាលក្រមកំបាំងមុខវិញ ជនជាប់ចោទអាចធ្វើបណ្ដឹងទាស់បាន ក្នុងរយៈពេល ១៥ ថ្ងៃ គិតពីថ្ងៃបានទទួលដំណឹងអំពីសាលក្រម[៧៩] និងធ្វើបណ្ដឹងឧទ្ធរណ៍បានក្នុងរយៈពេល ២ ខែ គិតពីថ្ងៃផុតកំណត់ប្ដឹងទាស់[៨០] ។ ប្រសិនបើ ជនជាប់ចោទបានធ្វើបណ្ដឹងទាស់ត្រឹមត្រូវតាមការកំណត់របស់ច្បាប់ សាលក្រមផ្ដន្ទាទោសកំបាំងមុខត្រូវចាត់ទុកជាអសារឥតការ ។ ប៉ុន្តែ ប្រសិនបើជនជាប់ចោទដែលបានប្ដឹងទាស់នឹងសាលក្រមកំបាំង មិនបានចូលខ្លួនជាលើកទី ២ នៅក្នុងសវនាការ តាមការបង្គាប់ឱ្យចូលខ្លួនត្រឹមត្រូវតាមច្បាប់

---

[៧៥] មាត្រា ១៣៧ នៃច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ។

[៧៦] មាត្រា ១៤១ នៃច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ។

[៧៧] មាត្រា ១៤២ នៃច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ។

[៧៨] មាត្រា ១៥៥ និង មាត្រា ១៧៨ នៃច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ។ មាត្រា ៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ និង មាត្រា ៧ នៃច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពសាលាជំរះក្ដីនៃរដ្ឋកម្ពុជា ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

[៧៩] មាត្រា ១១៦ នៃច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ។ មាត្រា ៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ និង មាត្រា ៧ នៃច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពសាលាជំរះក្ដីនៃរដ្ឋកម្ពុជា ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

[៨០] មាត្រា ១៧៨ នៃច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ។

Scanned with CamScanner

ទេនោះ ចៅក្រមចេញសាលក្រមកំប៉ាំងមុខលើកទី ២ ដែលត្រូវចាត់ទុកដូចជាសាលក្រមចំពោះមុខដែរ[៨១] ។ សាលក្រមដែលសម្រេចលើបណ្តឹងទាស់របស់ជនជាប់ចោទ បើកសិទ្ធិឱ្យធ្វើការប្តឹងតវ៉ាទៅសាលាឧទ្ធរណ៍ក្នុងរយៈពេល ពីរ ខែ គិតពីថ្ងៃប្រកាសសាល ក្រម[៨២] ។

ឥថាខណ្ឌទី៣. ការយល់ដឹងពីភាក្យស័ព្ទគតិយុត្តរបស់សេចក្តីសម្រេចតុលាការ

ក៏ដូចជាមុខវិជ្ជាដទៃទៀតដែរ នីតិសាស្ត្រទាមទារឱ្យមានការយល់ដឹងយ៉ាងច្បាស់លាស់ពីវាក្យស័ព្ទពិសេសមួយចំនួន ។ ប៉ុន្តែ ប្រទេសកម្ពុជាជួបប្រទះនូវការលំបាកយ៉ាងច្រើន ក្នុងការកំណត់វាក្យស័ព្ទច្បាប់ ។ ជួនកាល ពាក្យតែមួយអាចត្រូវបានគេប្រើប្រាស់នៅក្នុងន័យផ្សេងៗគ្នា ឬក៏វាក្យស័ព្ទច្រើនអាចមានអត្ថន័យដូចគ្នា។ ប្រទេសកម្ពុជាត្រូវខិតខំប្រឹងប្រែងយ៉ាងខ្លាំងថែមទៀតសម្រាប់កំណត់ស័ព្ទវិទ្យារបស់ខ្លួន ក្នុងន័យច្បៀសវាងនូវការប្រើប្រាស់វាក្យស័ព្ទខុស ។ ការខិតខំប្រឹងប្រែងនេះ ត្រូវបានផ្តួចផ្តើមឡើងដោយរាជរដ្ឋាភិបាល នាពេលថ្មីៗនេះ ។ គណកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់មួយត្រូវបានបង្កើតឡើង តាមអនុក្រឹត្យលេខ ៣៦ ចុះថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០០៣ ដោយមានសមាជិកចំនួន ១៩ រូប ក្នុងនោះមានអ្នកជំនាញខាងផ្នែកភាសា និងអ្នកច្បាប់ ដូចជាសាស្ត្រាចារ្យច្បាប់ មេធាវី និងចៅក្រម ។ គណកម្មការបណ្ឌិតសភារួមប្រជុំពីរដងក្នុងមួយសប្តាហ៍ ។

ជារឿងមានសារសំខាន់ណាស់ដែលនិស្សិត ឬបេក្ខជនប្រឡងត្រូវចេះយ៉ាងស្ទាត់ជំនាញនូវពាក្យច្បាប់ ប្រើប្រាស់នៅក្នុងសលាកប័ត្រសេចក្តីសម្រេចរបស់តុលាការ (ក) ។ ការធ្វើលំហាត់អនុវត្តខ្លះអាចធ្វើឱ្យអ្នកអានផ្សែងផ្សាត់ពីកម្រិតចំណេះដឹងរបស់ខ្លួនក្នុងវិស័យនេះបាន (ខ) ។

ក. សទ្ធានុក្រមពាក្យច្បាប់ : (បេអាទ្រីស បាលីវ៉ែ, ចាំង ស៊ីណាត, កាន ច័ន្ទមេត្តា, កើត រិទ្ធ និង ស៊ូ សុជាតិ)

ការវាយតម្លៃដោយឆន្ទានុសិទ្ធិ (Appréciation souveraine) : ការបកស្រាយដែលពុំអាចឱ្យមានការត្រួតពិនិត្យបាន ។ ចៅក្រមនៃសាលាជម្រះក្តីខាងអង្គហេតុមានអំណាចក្នុងការវាយតម្លៃលើអង្គហេតុនានា ប្រកបដោយឆន្ទានុសិទ្ធិ បានសេចក្តីថា ជាគោលការណ៍ តុលាការកំពូលពុំអាចពិនិត្យឡើងវិញលើការបកស្រាយអង្គហេតុរបស់ចៅក្រមថ្នាក់ក្រោម' ទេ ។

ការតូលតវ៉ា[៨៣] (Tierce opposition) : "ឬប្តឹងជំទាស់របស់តតិយជន" បណ្តឹងវិសាមញ្ញនៃ ការប្រកែក ឬការកែប្រែដែលអនុញ្ញាតឱ្យបុគ្គលម្នាក់មិនមែនជាភាគី ហើយក៏មិនមែនជាអ្នកតំណាងក្នុងដំណើរក្តី ដើម្បីជំទាស់នឹងសេចក្តីសម្រេចដែលធ្វើឱ្យគាត់ទទួលរងនូវការបាត់បង់ផលប្រយោជន៍ ។

---

[៨១] មាត្រា ១២៣ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ។

[៨២] មាត្រា ១២៤ និង មាត្រា ១៧៨ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ។

[៨៣] មាត្រា ៤៧១ នៃក្រមនីតិវិធីរដ្ឋប្បវេណីចាស់ ។

Scanned with CamScanner

ការយល់ឃើញ (Attendu) : ពាក្យប្រើប្រាស់ដើម្បីបង្ហាញពីកថាខណ្ឌនីមួយៗរបស់សេចក្តីសម្រេចតុលាការ ហើយក្នុងនោះចៅក្រមបង្ហាញពីសំអាងហេតុរបស់ខ្លួន ។

ការបន្ទោស (Grief) : មូលហេតុរិះគន់ ។

ការទុកជាមោឃៈ (Annulation) : អភិសួន្យនៃសេចក្តីសម្រេចរបស់តុលាការ ដោយមូលហេតុមានភាពមិនប្រក្រតីខាងទម្រង់ ឬគតិច្បាប់ បន្ទាប់ពីមានបណ្តឹងឧទ្ធរណ៍នៅចំពោះមុខសាលាឧទ្ធរណ៍ ឬបណ្តឹងសាទុក្ខនៅចំពោះមុខតុលាការកំពូល ។

បណ្តឹងជំទាស់ (Opposition) : មធ្យោបាយនៃការធ្វើពាក្យបណ្តឹងសាមញ្ញនៃនីតិរូម និងមធ្យោបាយនៃការជំទាស់ប្រកែកដែលអាចត្រូវបានធ្វើឡើងដោយភាគីវិវាទម្ខាង ដើម្បីជំទាស់ប្រឆាំងទៅនឹងសេចក្តីសម្រេចកំបាំងមុខមួយ[៨៤] ។ ក្រោយការចូលជាធរមាននៃក្រមនីតិវិធីរដ្ឋប្បវេណីថ្មី យើងត្រូវមានការប្រុងប្រយ័ត្នចំពោះការប្រើប្រាស់ពាក្យនេះ ដោយហេតុថា ក្នុងអត្ថបទនោះ *ពាក្យបណ្តឹងជំទាស់* សំដៅទៅលើបណ្តឹងឧទ្ធរណ៍ជំទាស់នីងដីកា ចំណែក*បណ្តឹងទាស់* បញ្ជាក់អំពីការប្តឹងជំទាស់ក្នុងន័យនៃនីតវិជ្ជមាន[៨៥] ។

ភ្នក្តី (Plaideur) :ភាគីនៃរឿងវិវាទ ។

ចុងចោទ (Défendeur) : បុគ្គលម្នាក់ ដែលត្រូវបានជំទាស់ដោយពាក្យបណ្តឹងមួយនៅតុលាការ ។

ចុងបណ្តឹងឧទ្ធរណ៍ (Intimé) : ឈ្មោះចុងចម្លើយនៃបណ្តឹងឧទ្ធរណ៍ ។

ឆ្លើយសំអាងលើ (Exciper) : ជូនសំអាងលើករណីលើកលែង លើមធ្យោបាយការពារក្តី ។ ឧទាហរណ៍ : ឆ្លើយសំអាងលើភាពសុចរិតរបស់ខ្លួនឯង ។

ជនជាប់សង្ស័យ (Suspect) : ជនដែលត្រូវបានគេសង្ស័យថា បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ នៅក្នុងដំណាក់កាលនៃនីតិវិធីតុលាការមុនពេលមានការសម្រេចចោទប្រកាន់ដោយអយ្យការ[៨៦] ។

ជនជាប់ចោទ (Accusé) : ជនដែលត្រូវបានព្រះរាជអាជ្ញាសម្រេចធ្វើការចោទប្រកាន់ បញ្ជូនទៅចៅក្រមស៊ើបអង្កេត ឬទៅតុលាការដើម្បីជំនុំជម្រះ ។ charged

ត្រឹមត្រូវតាមគតិច្បាប់ ឬមូលហេតុ (Bien-fondé) : ភាពត្រឹមត្រូវនៃពាក្យបណ្តឹងមួយ ទៅនឹងវិធាននៃនីតិដែលត្រូវបានអនុវត្ត ។ សំណូនវោហាស័ព្ទនេះមានសទិសន័យដូចជា "ការទទួលយកពាក្យបណ្តឹង" សម្រាប់ឃុត្តាធិការអង្គហេតុ និង "បដិសេធសេចក្តីសម្រេចរបស់ចៅក្រមអង្គហេតុ" សម្រាប់តុលាការកំពូល ។ នៅក្នុងសេចក្តីសម្រេចនាពេលថ្មីៗនេះ ចៅក្រមប្រើនូវពាក្យគតិច្បាប់ ដោយផ្ទុយនឹងពាក្យទម្រង់ច្បាប់ ដើម្បីកំណត់នូវភាពត្រឹមត្រូវតាមគតិច្បាប់ ឬមូលកភាព ។

---

[៨៤] មាត្រា ៧ វាក្យខណ្ឌទី ២ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពសាលាដម្រះក្តីនៃរដ្ឋកម្ពុជា ។

[៨៥] មើលមាត្រា ៣០២ នៃសេចក្តីព្រាងនីតិវិធីរដ្ឋប្បវេណី ។

[៨៦] ពាក្យនេះ មានប្រើនៅក្នុង មាត្រា ៦២ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ និងមាត្រា ១៣ និងមាត្រា ២៥ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

Scanned with CamScanner

ទិដ្ឋាការ (Visa) : ការចង្អុលបង្ហាញនៅក្នុងសេចក្តីសម្រេចរបស់តុលាការអំពីវិធានច្បាប់យោង ។

ទម្រង់ច្បាប់ (Forme) : សំដៅទៅលើរាល់លិខិតនីតិវិធី និងលិខិតរបស់ចៅក្រម ដែលត្រូវតែគោរពនូវលក្ខណៈរបស់វា។ យើងត្រូវកំណត់ចំណាំថា ពាក្យ"ទម្រង់ច្បាប់" ត្រូវបានប្រើប្រាស់ក្នុងសេចក្តីសម្រេចរបស់តុលាការនាពេលថ្មីៗនេះដែលមានន័យដូចគ្នានឹងពាក្យ "ភាពអាចទទួលបាន" ។

ធម្មនុញ្ញភាព (Constitutionnalité) : ភាពដែលបញ្ជាក់ថាស្របទៅតាមបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ។ គេប្រើពាក្យនេះក្នុងវិស័យនៃការត្រួតពិនិត្យភាពស្របនៃអត្ថបទច្បាប់ផ្សេងៗ ទៅនឹងរដ្ឋធម្មនុញ្ញ ។

នីតិវិធី (Procédure) : ទម្រង់បែបបទ ដែលត្រូវបានគេគោរព ដើម្បីលើកឡើងនូវអំណះអំណាងតាមផ្លូវតុលាការ ។

នីត្យានុកូលភាព (Légalité) : ភាពស្របទៅតាមបញ្ញត្តិនៃច្បាប់ ។ ពាក្យនេះគេប្រើដើម្បីសំគាល់លក្ខណៈនៃបទដ្ឋានគតិយុត្តអ្វីមួយ ដែលត្រូវតែស្របទៅតាមបញ្ញត្តិច្បាប់ ឬបញ្ញត្តិនៃបទដ្ឋានដែលខ្ពស់ជាង ។

ដីកា (Ordonnance) : សេចក្តីសម្រេចចេញដោយចៅក្រមទទួលបន្ទុកស៊ើបអង្កេត ដូចជាករណីចៅក្រមស៊ើបអង្កេត ។ ឧទាហរណ៍ ដីកាលើកលែងការចោទប្រកាន់[៨៧] ។

ដើមចោទ (Demandeur/demandresse) : បុគ្គលម្នាក់ដែលដាក់ពាក្យបណ្តឹងមួយទៅតុលាការ ។

ដើមបណ្តឹងឧទ្ធរណ៍ (Appelant) : ឈ្មោះនៃម្ចាស់ពាក្យបណ្តឹងឧទ្ធរណ៍ ។

ដោយពិចារណាឃើញ (Considérant) : មានន័យដូចគ្នាទៅនឹងពាក្យ "យល់ឃើញ"(Attendu) ។ ជាពាក្យដែលប្រើនៅក្នុងការតាក់តែងសេចក្តីសំរេចរបស់សាលាឧទ្ធរណ៍ និងតុលាការឧទ្ធរណ៍រដ្ឋបាល មុនឆ្នាំ ១៩៧៥ ហើយនៅក្នុងពេលបច្ចុប្បន្ននេះ មានប្រើនៅក្នុងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

បដិសេធ (Débouter) : មិនទទួលស្គាល់ពាក្យបណ្តឹងទៅតុលាការរបស់ភាគីម្ខាង ដើមចោទ ឬដើមបណ្តឹងឧទ្ធរណ៍ ។ បដិសេធពាក្យបណ្តឹង ។

ប្តឹងទៅតុលាការ (Agir en justice) "សិទ្ធិ" : សិទ្ធិដែលបុគ្គលគ្រប់រូបក្នុងការប្តឹងទៅតុលាការ ដើម្បីធានាការគោរពសិទ្ធិរបស់ពួកគេ ឬផលប្រយោជន៍ស្របច្បាប់ ។

សំណូនវោហាស័ព្ទនេះមានសទិសន័យដូចគ្នានឹងពាក្យ : ដាក់ពាក្យបណ្តឹងមួយទៅតុលាការ, ប្តឹងទៅតុលាការ, កោះហៅនណាម្នាក់ទៅតុលាការ ឬនៅចំពោះមុខយុត្តាធិការមួយ ។

បណ្តឹងឧទ្ធរណ៍ (Appel) "ប្តឹងឧទ្ធរណ៍" : បណ្តឹងនៃនីតិរូមក្នុងការកែប្រែ ឬលប់ចោល ដែលតាមរយៈនោះ ភាគីម្ខាក់ដាក់វិវាទនៅចំពោះមុខយុត្តាធិការមួយ ដែលមានឋានានុក្រមខ្ពស់ជាង ដែលជំនុំជម្រះសាជាថ្មីទាំងអង្គហេតុ និងអង្គច្បាប់[៨៨] ។

---

[៨៧] នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីចាស់ យោងតាមមាត្រា ២៩១ ដីកាបញ្ជាក់ពីសេចក្តីសម្រេច ដែលក្នុងនោះ ប្រធាននៃយុត្តាធិការខុសៗគ្នា ចូលរួមចេញសេចក្តីសម្រេចខ្លះតែម្នាក់ឯង ។ ក្នុងអត្ថបទថ្មីៗនេះ ពាក្យនេះត្រូវបានលើយកមកប្រើសាជាថ្មីឡើងវិញក្នុងមាត្រា ១០២, ១០៤ ជាពិសេស ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

[៨៨] យើងអាចប្រើប្រាស់និយមន័យ ដែលមានចែងក្នុងមាត្រា ៣៧១ នៃក្រមនីតិវិធីរដ្ឋប្បចាស់ : បណ្តឹងឧទ្ធរណ៍ ជាពាក្យរបស់គូភាគីណាមួយ ប្តឹងសុំឱ្យកែប្រែសាលក្រមសាលាដំបូង ដែលគូភាគីនោះពុំសុខចិត្ត ដោយគិតស្មានថា សាលក្រមនោះនាំឱ្យខូចខាតប្រយោជន៍របស់ខ្លួន ។ តាមពិត មាត្រា ១៥៨ នៃរដ្ឋធម្ម-

Scanned with CamScanner

បណ្តឹងសាទុក្ខ (Pourvoi en cassation) : ពាក្យបណ្តឹងជំទាស់ប្រឆាំងនឹងសេចក្តីសម្រេចមួយដែលចេញជាលើកចុងក្រោយដោយចៅក្រមខាងអង្គហេតុ ហើយដែលធ្វើឡើងនៅចំពោះមុខតុលាការកំពូល ។

ផ្នែកខាងសេចក្តីសម្រេច (Dispositif) : សេចក្តីថ្លែងពីដំណោះស្រាយចំពោះវិវាទណាមួយ ។

ភាពត្រឹមត្រូវតាមទម្រង់ច្បាប់ (Recevabilité) : លក្ខណៈនៃពាក្យបណ្តឹងមួយ ដែលការពិនិត្យទៅលើមូលដ្ឋានគតិច្បាប់ត្រូវបានធ្វើឡើងដោយយុត្តាធិការទទួលពាក្យបណ្តឹង ។

ពាក្យប្តឹង (Plainte): លិខិត ដែលជនរងគ្រោះនៃបទល្មើស ប្តឹងទៅមន្ត្រីនគរបាលយុត្តិធម៌[៥៩] ឬព្រះរាជអាជ្ញា[៥០] ។

ពិរុទ្ធជន (Inculpé): វាក្យស័ព្ទនេះ ត្រូវបានប្រើនៅក្នុងការអនុវត្តរបស់តុលាការ នៅពេលដែលចៅក្រមស៊ើបអង្កេតមានបន្ទុកគ្រប់គ្រាន់ ដែលបញ្ជាក់ថា ជនជាប់ចោទមានពិរុទ្ធ ។ ដោយយោងទៅលើពិរុទ្ធភាពនេះ ជនជាប់ចោទត្រូវបានគេហៅថា "ពិរុទ្ធជន" ។ ពាក្យថា "ពិរុទ្ធជន"នេះ មានបង្គប់នូវអត្ថន័យថា ជនជាប់ចោទមានពិរុទ្ធ ដែលនេះផ្ទុយទៅនឹងគោលការណ៍សច្ចធារណ៍នៃនិរទោស (គោលការណ៍សន្មតទុកជាមុនថាគ្មានទោស ដរាបណាគ្មានសាលក្រមផ្តន្ទាទោសស្ថាពរ) ដែលគោលការណ៍ត្រូវបានទទួលស្គាល់នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា[៥១] ។

មធ្យោបាយ (Moyens) (នៃបណ្តឹងសាទុក្ខ) : មូលហេតុលើកឡើង ដើម្បីគាំទ្របណ្តឹងសាទុក្ខ ដើម្បីគាំទ្រគោលបំណងរបស់ខ្លួន ។

ឋានាធិការ (Instance) : ថ្នាក់នៃការចាប់ផ្តើមរឿងវិវាទ ។ ប៉ុន្តែ ក្នុងសេចក្តីសម្រេចខ្លះ បន្ទាប់ពីបានទទួលឯករាជ្យភាពរបស់ខ្មែរ ពាក្យនេះត្រូវបានប្រើប្រាស់ដូចនឹងពាក្យ "ថ្នាក់ទី ១" មានន័យថា ថ្នាក់ដែលត្រូវបានដំណើរការនៅចំពោះមុខចៅក្រមថ្នាក់ទី ១ ។

សភា (Chambre) : ឈ្មោះរបស់ផ្នែកមួយនៃតុលាការកំពូល ។

សម្រេចឱ្យរួចខ្លួន (Acquiter) : សេចក្តីសម្រេចដែលចេញដោយតុលាការជំនុំជម្រះព្រហ្មទណ្ឌ ដែលសម្រេចឱ្យជនជាប់ចោទរួចខ្លួន ឬប្រកាសថា ជនជាប់ចោទគ្មានទោស (ប្រើក្នុងរឿងឧក្រិដ្ឋ) ។

សាលាជម្រះក្តី (Juridiction) : ពាក្យទូទៅសំដៅលើតុលាការទាំងអស់ ។

សាលាជម្រះក្តីនៃនីតិសាមញ្ញ ឬនីតិវិធី (Juridiction de droit commun) : សាលាជម្រះក្តីមានសមត្ថកិច្ចជំនុំជម្រះរាល់វិវាទទាំងអស់ លើកលែងតែមានច្បាប់ពិសេសផ្តល់សមត្ថកិច្ចឱ្យសាលាជម្រះក្តីផ្សេងទៀត ។

ទុញ្ញចែងថា " ច្បាប់ និង លិខិតបទដ្ឋានទាំងអស់នៅកម្ពុជា ដែលចានា ការពារបានទូវទ្រព្យសម្បត្តិរដ្ឋ សិទ្ធិ សេរីភាព និង ទ្រព្យសម្បត្តិត្រឹមត្រូវតាមច្បាប់របស់បុគ្គល និងដែលសមស្របនឹងប្រយោជន៍ជាតិត្រូវមានអានុភាពអនុវត្តបន្តទៅមុខ ទៀតរហូតដល់មានអត្ថបទថ្មីមកកែប្រែ ឬលុបចោល លើកលែងតែបទប្បញ្ញត្តិណា ដែលផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញនេះ។ ម៉ាត្រានេះមិនកំណត់អំពីព្រំដែននៃពេលវេលានោះទេ អ្នកជំនាញការច្បាប់មួយចំនួនអះអាងថា នីតិមុនរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ រួមទាំងនីតិនាសម័យសង្គមរាស្ត្រនិយមអាចត្រូវបានអនុវត្តក្នុងការរង់ចាំនូវអត្ថបទថ្មី ជាពិសេសក្រមនីតិវិធីរដ្ឋប្បវេណីថ្មី ។

[៥៩] មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ។

[៥០] មាត្រា ៥៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ។

[៥១] មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ។

Scanned with CamScanner

សាលាជម្រះក្តីពិសេស (Juridiction d'exception ou d'attribution) : សាលាជម្រះក្តីដែលមានសមត្ថកិច្ចតាមសាច់រឿងកំណត់ដោយច្បាប់ពិសេសណាមួយ ។

សាលាជម្រះក្តីខាងអង្គហេតុ (Juridiction du fond) : សាលាជម្រះក្តីដែលសម្រេចទាំងលើអង្គច្បាប់ និងអង្គហេតុ ផ្ទុយពីតុលាការកំពូលដែលជាគោលការណ៍គឺជាចៅក្រមផ្នែកខាងច្បាប់ លើកលែងតែមានបណ្តឹងសាទុក្ខលើកទីពីរ ។

សាលាជម្រះក្តីថ្នាក់ទីមួយ (Juridiction du prepmier degré ou ressort) : សាលាជម្រះក្តីដែលសម្រេចពិវាទជាលើកទីមួយលើអង្គហេតុ និងលើអង្គច្បាប់ ។

សាលាជម្រះក្តីថ្នាក់ទីពីរ (Juridiction du second degré ou ressort) : សាលាជម្រះក្តីដែលសម្រេចពិវាទជា លើកទីពីរលើអង្គហេតុ និងលើអង្គច្បាប់ ។

សំអាងហេតុ (Motifs) : វិចារណកិច្ចរៀបរាប់ដោយចៅក្រមនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន[៩២] ។

សាលដីកា (Arrêt) : ឈ្មោះដើម្បីកំណត់ជាសេចក្តីសម្រេចចេញដោយយុត្តាធិការជាន់ខ្ពស់[៩៣] ។ ប្រៀបធៀបជាមួយ "សាលក្រម" និង "ដីកា" ។

សាលដីកាបដិសេធ (Arrêt de cassation) : សេចក្តីសម្រេចរបស់តុលាការកំពូល ដែលក្នុងនោះគ្រប់ផ្នែក ឬផ្នែកខ្លះនៃសេចក្តីសម្រេចដែលចេញដោយយុត្តាធិការខាងអង្គហេតុ ត្រូវបានបដិសេធចោល[៩៤] ។

សាលដីកាតម្កល់ (Arrêt confirmatif) : សេចក្តីសម្រេចរបស់តុលាការ ដែលសាលាឧទ្ធរណ៍តម្កល់សេចក្តីសម្រេចរបស់យុត្តាធិការថ្នាក់ទី ១[៩៥] ទុកជាបានការ ។

សាលដីកាតម្កល់ (Arrêt de rejet) : សេចក្តីសម្រេចរបស់តុលាការកំពូល ដែលបដិសេធចោលនូវអំណះអំណាងរបស់ម្ចាស់បណ្តឹងសាទុក្ខ ហើយតម្កល់សេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ទុកជាបានការដដែល ។ ប្រៀបធៀបជាមួយ "សាលដីកាបដិសេធ"[៩៦] ។

សាលដីកាបដិសេធ (Arrêt infirmatif) : សេចក្តីសម្រេច ដែលសាលាឧទ្ធរណ៍លុបចោលសេចក្តីសម្រេចចេញដោយចៅក្រមថ្នាក់ទី ១[៩៧] ។

---

[៩២] សូមមើលមាត្រា ១៤៣ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ១៩៩៣ ។

[៩៣] ក្រមនីតិវិធីរដ្ឋប្បវេណីចាស់បានចែងរួចហើយ ក្នុងមាត្រា ២៩១ នូវប្រភេទផ្សេងៗនៃសេចក្តីសម្រេចរបស់តុលាការ ។ បទបញ្ញត្តិនេះចែងថា សេចក្តីសម្រេចចេញដោយតុលាការថ្នាក់ក្រោម គឺជាសាលក្រម ចំណែកឯសេចក្តីសម្រេចចេញដោយសាលាឧទ្ធរណ៍ សាលាវិនិច្ឆ័យ សាលាក្រមចោទ និងសាលាឧក្រិដ្ឋគឺជាសាលដីកា ។ ការកំណត់លក្ខណៈនៃសាលដីកា សម្រាប់សេចក្តីសម្រេចចេញដោយតុលាការជាន់ខ្ពស់ត្រូវបានចែងសាជាថ្មីឡើងវិញដោយអត្ថបទថ្មីៗនេះ ។ មើលមាត្រា ២២០ និង ២២១ នៃច្បាប់ចុះថ្ងៃទី ០៨-០៣-១៩៩៣ ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

[៩៤] យើងត្រូវកំណត់ចំណាំថា ការបកប្រែជាភាសាបារាំង ប្រើប្រាស់ជូនកាលពាក្យបដិសេធ "មាត្រា ១២, ១៣ និង ១៤ នៃច្បាប់ចុះថ្ងៃទី ០៨-០២-១៩៩៣ ស្តីអំពីការចាត់តាំង និងសកម្មភាពសាលាជម្រះក្តី" ជូនកាលំពាក្យលុបចោល "មាត្រា ៥៣, ២០៥, ២២០, ២២១, ២២៤ និង ២២៥ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ០៨-០៣-១៩៩៣ ។

[៩៥] ឧទាហរណ៍ មាត្រា ១៩៤ នៃច្បាប់ចុះថ្ងៃទី ០៨-០៣-១៩៩៣ ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

[៩៦] ជាភាសាខ្មែរ ពាក្យដូចគ្នានេះត្រូវបានប្រើប្រាស់ ដើម្បីសំដៅលើពាក្យសាលដីកាតម្កល់ និងសាលដីកាបដិសេធ ។ មើលមាត្រា ២២០ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី ០៨-០៣-១៩៩៣ ។

Scanned with CamScanner

សេចក្តីសន្និដ្ឋាន (Conclusion) :

ន័យទី ១ : លិខិតនៃនីតិវិធី ដែលក្នុងនោះ ភាគីវិវាទលើកឡើងនូវអំណះអំណាងរបស់ខ្លួន ឬមធ្យោបាយការពារ ឬការជូនសំអាងនៅតុលាការ (សេចក្តីសន្និដ្ឋានការពារ) ។

ន័យទី ២ : ពាក្យ ដែលកំណត់ពីបណ្តឹងរបស់ព្រះរាជអាជ្ញា ដែលក្នុងនោះនៅក្នុងរឿងរដ្ឋប្បវេណី តាមន័យទូលាយ ជាយោបល់ "មាត្រា ៥៣ នៃច្បាប់ឆ្នាំ ១៩៩៣ ស្តីអំពីនីតិវិធីព្រហ្មទណ្ឌ" ឬនៅក្នុងរឿងព្រហ្មទណ្ឌ ជាពាក្យបណ្តឹងជំទាស់ប្រឆាំងជនជាប់ចោទ "មាត្រា ៥២ នៃច្បាប់ដដែល" (សេចក្តីសន្និដ្ឋានចោទប្រកាន់) ។

សេចក្តីសម្រេចឱ្យរួចខ្លួន (Relaxe): ជាសេចក្តីសម្រេចក្នុងរឿងព្រហ្មទណ្ឌ ដែលតាមរយៈសេចក្តីសម្រេចនោះ ជនជាប់ចោទត្រូវបានប្រកាសថា គ្មានពិរុទ្ធភាព (ប្រើក្នុងរឿងមជ្ឈិម) ។

សេចក្តីសម្រេចរបស់តុលាការ (Décision de justice): ពាក្យសាមញ្ញទូទៅ ដែលក្រសោបនូវពាក្យដីកា សាលក្រម និងសាលដីកា ។

ស្នាក្តី ឬអ្នកការពារក្តី (Défenseur) :បុគ្គលដែលទទួលបាននូវតួនាទី ដើម្បីជាតំណាង និងជួយភាគីម្ខាងនៅតុលាការ ។

សាលក្រម (Jugement) : ឈ្មោះត្រូវបានកំណត់ចំពោះសេចក្តីសម្រេចចេញដោយតុលាការថ្នាក់ទី ១ ។ ប្រៀបធៀបជាមួយ "សាលដីកា" ។

សាលក្រមរៀបចំ (Jugement avant dire droit) : សេចក្តីសម្រេចចេញក្នុងពេលដំណើរការនីតិវិធី ដើម្បីរៀបចំការស៊ើបអង្កេត ឬរកដំណោះស្រាយជាបណ្តោះអាសន្ននូវស្ថានភាពណាមួយ ។

សម្រេចសេចក្តី (Statuer) : ជំនុំជម្រះ ។

អង្គច្បាប់ (Droit) : ជាពាក្យផ្ទុយទៅនឹងអង្គហេតុ ។ អង្គច្បាប់សំដៅលើបណ្តាវិធានច្បាប់ទាំងអស់ដែលគ្រប់គ្រងជីវភាពក្នុងសង្គម ហើយដាក់ទណ្ឌកម្មដោយអាជ្ញាធរសាធារណៈ ។

អង្គហេតុ (Faits) : ក្នុងន័យចង្អៀត អង្គហេតុសំដៅលើកាលៈទេសៈជាកម្មវត្ថុនៃវិវាទ ។ ក្នុងន័យទូលាយ ប្រើប្រាស់នៅក្នុងសេចក្តីសម្រេចជាច្រើនមុនឆ្នាំ ១៩៧៥ អង្គហេតុសំដៅលើផ្នែកមួយនៃសេចក្តីសម្រេចរបស់តុលាការ ដែលថ្លែងឡើងវិញនូវហេតុការណ៍ ដែលជាដើមកំណើតនាំឱ្យមានវិវាទ រហូតដល់ដំណោះស្រាយពីហេតុការណ៍នោះ ដោយសាលាជម្រះក្តីមុន ។

អង្គសេចក្តី (Fond) : អង្គសេចក្តី សំដៅទៅលើផ្នែកមួយ ខ្លឹមសារ ឬធាតុសំខាន់នៃរឿងក្តី ។ សូមមើលពាក្យ "ត្រឹមត្រូវតាមច្បាប់ ឬមូលភាព" ។

អំណះអំណាង (Argumentation) : វិចារណកិច្ច (ការដេញរកហេតុផល) ធ្វើដោយភាគី ។

---

[៥៧] មើលមាត្រា ១៩៨ និង ២០១ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី ០៨-០៣-១៩៩៣ ។

Scanned with CamScanner

ខ. ការផ្សៀងផ្ទាត់លើការយល់ដឹងពីខាគ្យស័ព្ទគតិយុត្ត

ដើម្បីផ្សៀងផ្ទាត់ថា អ្នកពិតជាបានយល់ដឹងច្បាស់លាស់ពីការប្រើប្រាស់វាក្យស័ព្ទខាងលើ ចូរអ្នកធ្វើលំហាត់ដូចខាងក្រោម (១) ដោយពុំមើលឯកសារ និងមើលកំណែឡើយ (២)។

១_លំហាត់

<u>លំហាត់ទី១</u>

ចូរបំពេញអត្ថបទដូចតទៅ :

នៅពេលលោក រិទ្ធី កំពុងដើរនៅតាមដងវិថីព្រះនរោត្តម មានអ្នកបើកបរម្នាក់មកប៉ះលោកធ្វើឱ្យលោកដួល។ លោក រិទ្ធី ត្រូវគេបញ្ជូនទៅមន្ទីរពេទ្យ កាល់ម៉ែត្រ។ នៅពេលនេះ គ្រូពេទ្យសន្និដ្ឋានថា ស្ថានភាពរបស់លោក រិទ្ធី ពិតជាមានគ្រោះថ្នាក់ តែពីរបីថ្ងៃក្រោយមក លោក រិទ្ធី ក៏ដឹងខ្លួនឡើងវិញ ហើយស្ថានភាពរបស់លោកក៏ប្រសើរឡើងបន្តិចម្តងៗ។ ទោះជាយ៉ាងនេះក្តី ស្ថានភាពរបស់លោកទាមទារឱ្យមានការបង្ហាត់បង្រៀនឡើងវិញ ក្នុងរយៈពេលយូរ ហើយលោកពុំអាចទៅធ្វើការបានទេ ក្នុងរវាងពី ១២ខែ ទៅ ១៨ខែ។ លោក រិទ្ធី សម្រេចចិត្តរកមេធាវីម្នាក់ឈ្មោះ លោក ជុំ។

លោក រិទ្ធី .....អ្នកបើកបរឡានទៅ.....ដើម្បីទាមទារឱ្យសងការខូចខាតកើតឡើងដល់លោក។ លោក រិទ្ធីជា.....នៅក្នុងបណ្តឹងនេះ ហើយលោក ជុំ គឺជា.....របស់លោក ចំណែកឯអ្នកបើកបរឡានគឺជា .....។ តាមរយៈ..... ចុះថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ២០០១ ចៅក្រម..... បានសម្រេចតាមពាក្យបណ្តឹងរបស់លោក .....ថា កំហុសរបស់អ្នកបើកបរបានបណ្តាលឱ្យកើតព្យសនកម្មដល់លោក រិទ្ធី ហើយអ្នកបើកបរត្រូវតែជូសជុលព្យសនកម្មនោះ។ អ្នកបើកបរ.....។ សាលាឧទ្ធរណ៍ចេញ.....មួយសម្រេច .....ខ្លះ ដោយ ..... ថា លោក រិទ្ធីក៏មានអាកប្បកិរិយាខុសដែរ ពីព្រោះតាមចំលើយរបស់អ្នកបើកបរថា លោក រិទ្ធី ដើរនៅពេលយប់ដោយស្រវឹងជាខ្លាំង នៅកណ្តាលថ្នល់ ហើយលោក រិទ្ធី ពុំបានបង្ហាញភស្តុតាងផ្ទុយពីចំលើយរបស់អ្នកបើកបរទេ។ ចៅក្រម..... សន្និដ្ឋានឱ្យអ្នកបើកបររួចផុតពីការទទួលខុសត្រូវពាក់កណ្តាល។ លោក រិទ្ធី .... ដោយសំអាងលើមាត្រា ៥៣៧ចាស់ នៃក្រមរដ្ឋប្បវេណីចាស់។ ដើម្បីគាំទ្រគោលបំណងរបស់លោក លោក រិទ្ធី បានលើក ..... សំអាងតែមួយគត់ : សាលាឧទ្ធរណ៍បានផ្លាស់ប្តូរវិធានទាក់ទងនឹងបន្ទុកភស្តុតាង។ តុលាការកំពូល ..... របស់ ..... ហើយបញ្ជូនសំណុំរឿងឱ្យ ..... ដែលមានសមាសភាពខុសប្លែកពីមុន ជំនុំជម្រះសាជាថ្មី ដោយ .....ថា ភស្តុតាងអំពីអាកប្បកិរិយាខុសឆ្គងរបស់ជនរងគ្រោះក្នុងគ្រោះថ្នាក់មួយ ជាបន្ទុករបស់អ្នកបើកបរ។

Scanned with CamScanner

លំហាត់ទី២

ចូរឱ្យនិយមន័យពាក្យដូចខាងក្រោម :

១-សាលាជម្រះក្តីពិសេស

២-មធ្យោបាយ

៣-ទិដ្ឋាការ

៤-បណ្តឹងឧទ្ធរណ៍

៥-ភាពត្រឹមត្រូវតាមទម្រង់ច្បាប់

ចូរពន្យល់ពីភាពខុសប្លែកគ្នារវាង :

១-ជនជាប់ចោទ-ពិរុទ្ធជន-ជនជាប់សង្ស័យ

២-ដើមចោទ-ចុងចម្លើយ-អ្នកការពារ

៣-សេចក្តីសម្រេចរបស់តុលាការ-ដីកា-សាលក្រម-សាលដីកា

៤-សាលាជម្រះក្តី-តុលាការ

៥-មធ្យោបាយ-សំអាងហេតុ

២_កំណែ

លំហាត់ទី១

លោក រិទ្ធី **ប្តឹង**ពីអ្នកបើកបរឡានទៅ**តុលាការក្រុងភ្នំពេញ** ដើម្បីទាមទារឱ្យសងការខូចខាតកើតឡើងដល់លោក ។ លោក រិទ្ធី ជា**ដើមចោទ**នៅក្នុងបណ្តឹងនេះ ហើយលោក ជុំ គីជា**អ្នកការពារ (មេធាវី)** របស់លោក ចំណែកឯអ្នកបើកបរឡានគឺជា**ចុងចម្លើយ** ។ តាមរយៈ**សាលក្រម** ចុះថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ២០០១ ចៅក្រម**ថ្នាក់ទីមួយ**បានសម្រេចតាមពាក្យបណ្តឹងរបស់លោក ដោយ**សំអាងហេតុ**ថា កំហុសរបស់អ្នកបើកបរបានបណ្តាលឱ្យកើតព្យសនកម្មដល់លោក រិទ្ធី ហើយអ្នកបើកបរត្រូវតែជួសជុលព្យសនកម្មនោះ ។ អ្នកបើកបរ**ប្តឹងឧទ្ធរណ៍** ។ សាលាឧទ្ធរណ៍ចេញ**សាលដីកា**មួយ សម្រេច**កែប្រែសាលក្រមខ្លះ** ដោយ**សំអាងហេតុថា** លោក រិទ្ធី ក៏មានអាកប្បកិរិយាខុសដែរ ពីព្រោះតាមចំលើយរបស់អ្នកបើកបរថា លោក រិទ្ធី ដើរនៅពេលយប់ ដោយស្រវឹងជាខ្លាំង នៅកណ្តាលថ្នល់ ហើយលោក រិទ្ធី ពុំបានបង្ហាញភស្តុតាងផ្ទុយពីចំលើយរបស់អ្នកបើកបរទេ ។ ចៅក្រម**ខាងអង្គហេតុ** សន្និដ្ឋានឱ្យអ្នកបើកបររួចផុតពីការទទួលខុសត្រូវពាក់កណ្តាល ។ លោក រិទ្ធី **ប្តឹងសាទុក្ខ** ដោយសំអាងលើមាត្រា ៤៣៧ ចាស់ នៃក្រមវិធីព្រហ្មទណ្ឌ ។ ដើម្បីគាំទ្រគោលបំណងរបស់លោក លោក រិទ្ធី បានលើក**មធ្យោបាយ**សំអាងតែមួយគត់ : សាលាឧទ្ធរណ៍បានផ្លាស់ប្តូរវិធានទាក់ទងនឹងបន្ទុកភស្តុតាង ។ តុលាការកំពូល**ទុកសាលដីការ**របស់**សាលាឧទ្ធរណ៍ជាមោឃៈ** ហើយបញ្ជូនសំណុំរឿងឱ្យ**សាលាឧទ្ធរណ៍** ដែលមានសមាសភាពខុសប្លែកពីមុនជំនុំជម្រះសាជាថ្មី ដោយ**សំអាងហេតុ**ថា ភស្តុតាងអំពីអាកប្បកិរិយាខុសឆ្គងរបស់ជនរងគ្រោះក្នុងគ្រោះថ្នាក់មួយ ជាបន្ទុករបស់អ្នកបើកបរ ។

Scanned with CamScanner

លំហាត់ទី២

ចូរផ្សឹងផ្ទាត់ចំលើយនៅក្នុងសន្ទានុក្រមវាក្យស័ព្ទច្បាប់[៩៨] ។

កថាខណ្ឌទី ៤ : ការសិក្សាពីរចនាសម្ព័ន្ធនៃសេចក្តីសម្រេចរបស់តុលាការ : (បេអាទ្រីស បាលីវ៉ែ, ចាំង ស៊ីណាត និង កាន ច័ន្ទមេត្តា)

យើងសង្កេតឃើញថា សេចក្តីសម្រេចរបស់តុលាការកម្ពុជាក្រោយពេលទទួលបានឯករាជ្យភាព ជាសេចក្តីសម្រេចប្រកបដោយវិចារណកិច្ចយ៉ាងតឹងរឹង ព្រោះចៅក្រមកម្ពុជា ចេះទាញយកប្រយោជន៍ពីឥទ្ធិពលបរទេសនាពេលនោះ ដោយរក្សាទុកនូវលក្ខណៈពិសេសប្លែករបស់ខ្លួន (ក) ។ ផ្ទុយទៅវិញ សេចក្តីសម្រេចក្រោយៗមកទៀត ហាក់ដូចជាមានរចនាសម្ព័ន្ធពុំសូវតឹងរឹងដូចកាលពីមុនទេ បានសេចក្តីថា សេចក្តីសម្រេចទាំងនេះគ្រាន់តែដើរតាមកាលបរិច្ឆេទផ្នែកនីតិវិធី ហើយធ្វើការអធិប្បាយលើអង្គសេចក្តីនៃរឿងក្តីតិចតួចប៉ុណ្ណោះ ក្នុងករណីខ្លះស្ទើតែគ្មាន (ខ) ។

ក. នៅក្នុងនីតិកម្មជាចាប់ពីពេលទទួលបានឯករាជ្យភាព

ការសិក្សានេះត្រូវបានធ្វើឡើង ចាប់ពីសេចក្តីសម្រេចរបស់តុលាការចេញក្រោយពេលប្រទេសកម្ពុជាទទួលបានឯករាជ្យភាពនៅឆ្នាំ ១៩៥៣ លើតែសេចក្តីសម្រេចដែលអាចពិគ្រោះបានប៉ុណ្ណោះ[៩៩] ពោលគឺមានសាលដីកាសាលាវិនិច្ឆ័យប្រហែលជា ៣០ ជាង និងសាលដីកាសាលាឧទ្ធរណ៍ប្រហែលជា ១០ ជាង ។ ទោះជាមានការខ្វះខាតបែបនេះក្តី ការសិក្សាពីរចនាសម្ព័ន្ធសេចក្តីសម្រេចរបស់តុលាការធ្វើឱ្យយើងមានការចាប់អារម្មណ៍ជាខ្លាំង ព្រោះយើងសង្កេតឃើញថា រចនាសម្ព័ន្ធមានសភាពដូចៗគ្នាទាំងក្នុងសេចក្តីសម្រេចរបស់សាលាវិនិច្ឆ័យ ទាំងក្នុងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ ផងដែរ ។

១-សាលដីកាសាលាវិនិច្ឆ័យ

បើពិនិត្យទៅលើផ្នែកវេយ្យាករណ៍ ទាក់ទងនឹងការប្រើប្រាស់វណ្ណយុត្ត សាលដីកាសាលាវិនិច្ឆ័យមានចាប់ពីរ បីទៅបួនឃ្លា អាស្រ័យទៅតាមថា តើបណ្តឹងត្រឹមត្រូវតាមទម្រង់ច្បាប់ ឬទេ ហើយឃ្លានីមួយៗរួមមានវាក្យសម្ព័ន្ធចម្បង និងវាក្យសម្ព័ន្ធចំណុះជាច្រើនទៀត ។ អ្នកសរសេរសេចក្តីសម្រេចប្រើប្រាស់ ខំណ្ឌ នៅពេលពិនិត្យពីទម្រង់ច្បាប់ និងគតិច្បាប់របស់បណ្តឹង នៅពេលបញ្ចប់សំអាងហេតុ និងបញ្ចប់ផ្នែកខាងសេចក្តីសម្រេចរបស់សាលដីកា[១០០] ។ ការប្រើប្រាស់ឃ្លាច្រើនយ៉ាងនេះ ធ្វើឱ្យអ្នកអានងាយស្រួលអានសេចក្តីសម្រេច ។ ប៉ុន្តែការប្រើប្រាស់វណ្ណយុត្តនេះអាចឱ្យគេរិះគន់បានព្រោះគេឃើញមានប្រធានតែមួយគត់គឺ "សាលា" ដែលស្ថិតនៅក្បាលសេចក្តីសម្រេច ហើយផ្នែកនីមួយៗនៃសេចក្តីសម្រេចពុំមានប្រធានណាផ្សេងទៀតទេ ។ ដូច្នេះតាមពិត សេចក្តីសម្រេចរបស់សាលាវិនិច្ឆ័យរួម មានឃ្លាតែមួយគត់ ។

---

[៩៨] សូមមើលផ្នែកទី ១ កថាខណ្ឌទី ៣ ត្រង់ចំណុច ក ។

[៩៩] កម្រងសេចក្តីសម្រេចតុលាការ ឆ្នាំ ១៩៥៤ ឆមាសទីមួយ កម្រងសេចក្តីសម្រេចតុលាការឆ្នាំ ១៩៥៥ និងឆ្នាំ ១៩៥៦ ឆមាសទីមួយ ។

[១០០] សូមមើលការប្រើប្រាស់សញ្ញាវណ្ណយុត្តទាំងនេះ នៅក្នុងសេចក្តីសម្រេចរបស់តុលាការ ។

Scanned with CamScanner

ក្នុងបំណងធ្វើឱ្យសាលដីការបស់ខ្លួនកាន់តែងាយស្រួលយល់ ចៅក្រមកម្ពុជាចែកសេចក្តីសម្រេចរបស់ខ្លួនជាពីរផ្នែក ដែលជួនកាលសម្តែងឱ្យឃើញតាមរយៈចំណងជើងសរសេរយ៉ាងច្បាស់លាស់ ។

ផ្នែកទីមួយនៃសេចក្តីសម្រេចពាក់ព័ន្ធនឹងការពិនិត្យលើទម្រង់ច្បាប់របស់បណ្តឹង ដែលសាលាវិនិច្ឆ័យទទួលយកមកដោះស្រាយ ។ ផ្នែកនេះចែកចេញជាពីរផ្នែកតូចៗទៀត : សំអាងហេតុដែលនាំមុខដោយពាក្យ "យល់ឃើញ" និងផ្នែកខាងសេចក្តីសម្រេច ។ នៅពេលដែលបណ្តឹងខុសនីងទម្រង់ច្បាប់ សេចក្តីសម្រេចត្រូវបញ្ចប់ត្រឹមនេះ ។

សាលដីកាសាលាវិនិច្ឆ័យ-សភាឧក្រិដ្ឋ ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ១៩៩៥

សាលា :

សំអាងហេតុ

សម្រេចលើទម្រង់ច្បាប់របស់បណ្តឹងសាទុក្ខ,

- យល់ឃើញថា N.S. ដើមបណ្តឹងរដ្ឋប្បវេណី បានប្តឹងសាទុក្ខនៅថ្ងៃទី ៤ ខែមីនា ឆ្នាំ១៩៩៥ ពីសាលដីការបស់សាលាក្រុមចោទ ចុះថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ១៩៩៥ ដែលរក្សាទុកដីកាលើកលែងការចោទប្រកាន់របស់សុភាចារបុរសនៃសាលាដំបូងខេត្តពោធិ៍សាត់ ជាប្រយោជន៍ដល់ឈ្មោះ T និងឈ្មោះ H ដែលជាជនជាប់ចោទពីបទលួចត្រីក្នុងឡូតិ៍នេសាទរបស់អ្នកប្តឹង ;
- យល់ឃើញថា មាត្រា ៦៩៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានរៀបរាប់ពីករណី ដែលអាចឱ្យប្តឹងសាទុក្ខបាន ; យល់ឃើញថា នៅក្នុងការរៀបរាប់នោះ ពុំឃើញមានករណីពីសាលដីការបស់សាលាក្រុមចោទដែលសម្រេចពីការជំទាស់នឹងដីកាចេញដោយសុភាចារបុរសឡើយ ;
- យល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីអាចសំអាងពីសិទ្ធិក្នុងការធ្វើបណ្តឹងសាទុក្ខទទួលស្គាល់ដោយមាត្រា ៦៤៤ តែក្នុងករណីដែលមានរៀបរាប់ក្នុងមាត្រា ៦៤៥ ប៉ុណ្ណោះ ;
- យល់ឃើញថា តាមមាត្រា ៦៤៣ (ទី៣) នៃក្រមខាងលើ មានតែរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ប៉ុណ្ណោះ អាចប្តឹងសាទុក្ខនឹងសាលដីការបស់សាលាក្រុមចោទបាន ; យល់ឃើញថាដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិដូចនេះតែក្នុងករណីចែងដោយមាត្រា ៥០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌប៉ុណ្ណោះ ;
- យល់ឃើញថា N. S. ពុំបានបំពេញលក្ខខណ្ឌទាមទារដើម្បីអាចប្តឹងសាទុក្ខបានទេ ; ដូច្នេះបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែប្រកាសថា ខុសនីងទម្រង់ច្បាប់ ។

ផ្នែកខាងសេចក្តីសម្រេច

ហេតុដូចនេះសម្រេច :

ប្រកាសថា បណ្តឹងសាទុក្ខខុសនីងទម្រង់ច្បាប់ ។

ផ្នែកទីពីរនៃសេចក្តីសម្រេចរបស់សាលាវិនិច្ឆ័យទាក់ទងនឹងការពិនិត្យលើគតិច្បាប់ ប្រសិនបើ បណ្តឹងសាទុក្ខត្រឹមត្រូវតាមទម្រង់ច្បាប់ហើយ ។ ផ្នែកនេះរួមមាន :

Scanned with CamScanner

- សំអាងហេតុដែលរៀបចំជាការ "យល់ឃើញ" ច្រើនឃ្លា ដោយធ្វើការបែងចែករវាងអង្គហេតុ និងអង្គច្បាប់ ។ រចនាសម្ព័ន្ធបែបនេះត្រូវបានប្រើប្រាស់នៅគ្រប់សាលដីកាទាំងអស់ ។ ពាក្យថា "អង្គហេតុ" សំដៅទៅលើការពិតជាក់ស្តែងដែលខុស១គ្នា ទៅតាមសេចក្តីសម្រេចនីមួយ១ ។ ពេលខ្លះ អង្គហេតុសំដៅទៅលើអង្គហេតុនៃរឿងក្តីតែម្តង បានសេចក្តីថា ជាការផ្ទែងពីកម្មវត្ថុនៃដំលោះ[១០១] ប៉ុន្តែជាញឹកញាប់ គេសង្កេតឃើញថា អង្គហេតុនេះក៏រួមបញ្ចូលទាំងការបង្ហាញពីនីតិវិធីនៅសាលាជម្រះក្តីថ្នាក់ទីមួយ និងថ្នាក់ទីពីរ[១០២] ឬរហូតដល់សេចក្តីសម្រេចរបស់សាលាជម្រះក្តីនោះទៀតផង[១០៣] ហើយក្នុងនោះក៏អាចមានការចង្អុលបង្ហាញពីបណ្តឹងសាទុក្ខដែរ[១០៤] ។ នៅពេលដែលក្នុងផ្នែកខាងអង្គហេតុ គេពុំអាចបង្ហាញពីសេចក្តីសម្រេចរបស់សាលាជម្រះក្តីថ្នាក់ក្រោម និងបណ្តឹងសាទុក្ខទេ ចំណុចទាំងពីរនឹងត្រូវលើកយកមកបង្ហាញនៅក្នុងកថាខណ្ឌ ដែលមានចំណងជើងថា "អង្គច្បាប់" បន្ទាប់មកបង្ហាញពីវិចារណកិច្ចរបស់សាលាវិនិច្ឆ័យ ។ រាល់សេចក្តីសម្រេចទាំងអស់សុទ្ធតែមានវិចារណកិច្ចជាបីវាក្យសម្ព័ន្ធតាមបែបតុលាការ ។ បន្ទាប់ពីវាយតម្លៃលើស្ថានភាពគតិយុត្តរួចមក សាលដីការបស់សាលាវិនិច្ឆ័យនឹងបង្ហាញពីវិធានច្បាប់ ។ វិធានច្បាប់នេះនឹងត្រូវយកមកអនុវត្តលើអង្គហេតុនៃរឿងក្តី[១០៥] ។ សេចក្តីសន្និដ្ឋានសំដៅលើផ្នែកខាងសេចក្តីសម្រេច ។ នៅក្នុងសាលដីកាមួយចំនួនរាល់ដំណាក់កាលនីមួយ១នៃវិចារណកិច្ចខាងលើ អាចរកឃើញយ៉ាងងាយស្រួល ហើយតាមលំដាប់លំដោយទៀតផង (លំដាប់ទីមួយ : វិធានច្បាប់-លំដាប់ទីពីរ : ការអនុវត្តវិធានច្បាប់លើអង្គហេតុ-លំដាប់ទីបី : សេចក្តីសន្និដ្ឋាន) ។ ក្នុងសេចក្តីសម្រេចខ្លះ លំដាប់ទីពីរបែរជាស្ថិតនៅមុនលំដាប់ទីមួយវិញ ក៏មានដែរ ។ ដូច្នេះ វិចារណកិច្ចត្រូវបានបញ្ច្រាស់គ្នាទៅវិញ ។
- ផ្នែកខាងសេចក្តីសម្រេច : រួមមានពីផ្នែកជានិច្ច ព្រោះក្នុងផ្នែកនេះ អ្នកតាក់តែងសេចក្តីសម្រេចបង្ហាញពីការសម្រេចរបស់តុលាការ ទាក់ទងនឹងទម្រង់ច្បាប់ និងគតិច្បាប់របស់បណ្តឹងសាទុក្ខ ។

[១០១] ១៣% នៃសេចក្តីសម្រេចដែលយកមកសិក្សា ។
[១០២] ២៦% នៃសេចក្តីសម្រេចដែលយកមកសិក្សា ។
[១០៣] ៤៥% នៃសេចក្តីសម្រេចដែលយកមកសិក្សា ។
[១០៤] ២៦% នៃសេចក្តីសម្រេចដែលយកមកសិក្សា ។
[១០៥] សូមមើលការបង្ហាញជាលក្ខណៈពេញលេញអំពីបញ្ហានេះនៅក្នុងផ្នែកទី ៣ ស្តីពីករណីអនុវត្ត ។

Scanned with CamScanner

សាលាវិនិច្ឆ័យ សភារដ្ឋប្បវេណី ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ១៩៥៣

ឧម្ភច់ច្បាប់

សំអាងហេតុ

សាលា :

សម្រេចពីទម្រង់ច្បាប់របស់បណ្តឹងសាទុក្ខ,

យល់ឃើញថា តាមលិខិតចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៥៣ S បានប្តឹងសាទុក្ខពីសាលដីកាសាលាឧទ្ធរណ៍ចុះថ្ងៃខែឆ្នាំដូចខាងលើ ដែលបានកែប្រែសាលក្រមរបស់សាលាលហុនៃស្រុកបារាយ ហើយសម្រេចប្រគល់ឱ្យកាតិវាទរបស់ខ្លួនឈ្មោះ R នូវដីទំនាស់ស្ថិតក្នុងឃុំ K ហើយសម្រេចបង្គាប់ឱ្យ S សងដីទៅ R វិញ :

យល់ឃើញថា បណ្តឹងសាទុក្ខនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ច្បាប់ ហើយបានធ្វើឡើងក្នុងកំណត់ពេលច្បាប់,

ផ្នែកខាងសេចក្តីសម្រេច

ដូច្នេះត្រូវប្រកាសថាបណ្តឹងសាទុក្ខនេះស្របតាមទម្រង់ច្បាប់ ។

តាមអង្គហេតុ :

អំណះអំណាងរបស់ដើមចោទ និង ម្ចាស់បណ្តឹងឧទ្ធរណ៍

យល់ឃើញថា R បានអះអាងនៅតុលាការថ្នាក់ទីមួយ ក៏ដូចជានៅសាលាឧទ្ធរណ៍ដែរថា ដីទំនាស់ជាកម្មសិទ្ធិរបស់ខ្លួន ហើយម្តាយខ្លួនឈ្មោះ នាង O គ្រាន់តែបញ្ចាំដីឱ្យឈ្មោះ S ក្នុងតម្លៃ ២៣០ $ ប៉ុណ្ណោះ;

អំណះអំណាងរបស់ចុងចម្លើយ និង ចុងបណ្តឹងឧទ្ធរណ៍

យល់ឃើញថា នៅតុលាការថ្នាក់ទីមួយ ក៏ដូចជានៅសាលាឧទ្ធរណ៍ ដែរ S បានជំទាស់ទៅនឹងសំអាងខាងលើ ដោយបញ្ជាក់ថាកិច្ចសន្យារវាងខ្លួននិងនាង O នៅ ឆ្នាំ១៩៤៦ គឺជាកិច្ចសន្យាលក់ ប៉ុន្តែប្រធានការិយាល័យភូមិបាលបានបដិសេធចុះបញ្ជីកិច្ចសន្យាលក់ ដោយសំអាងថាដីនេះពុំទាន់ប្រកាសចុះបញ្ជីនៅឡើយ ;

សំអាងហេតុ

យល់ឃើញថា ពេលដេញដោលនៅតុលាការថ្នាក់ទីមួយ ក៏ដូចជានៅសាលាឧទ្ធរណ៍ដែរ គូភាគីទាំងសងខាងបានបង្ហាញសាក្សីរបស់ខ្លួនរៀងៗខ្លួន ;

សេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍

ប៉ុន្តែយល់ឃើញថា ការឱ្យតម្លៃទៅលើសក្តីភាពទាំងនោះជាការវាយតម្លៃដោយឆន្ទានុសិទ្ធិរបស់ចៅក្រមខាងអង្គហេតុ ; យល់ឃើញថា ប័ណ្ណតែមួយគត់ដែលផ្តល់ជាភស្តុតាងមកក្នុងសំណុំរឿងនេះ គឺការប្រកាសភោគៈនៅភូមិបាល ដោយឈ្មោះ R ក្រោយពេលចាប់ផ្តើមរឿងក្តីនេះ

គតិច្បាប់

Scanned with CamScanner

ទៅហើយ ;

យល់ឃើញថា ដោយសំអាងលើប័ណ្ណប្រកាសដីធ្លីមួយនេះសាលាឧទ្ធរណ៍សម្រេចប្រគល់ដីទំនាស់ទៅឱ្យ R ។

តាមអង្គច្បាប់ :

យល់ឃើញថា ដីទំនាស់ជាដីដែលពុំទាន់ចុះបញ្ជីសុរិយោដីនៅឡើយ ; **ការវាយតម្លៃលើ**

យល់ឃើញថា ហេតុដូច្នេះ កម្មសិទ្ធិដីធ្លីត្រូវបង្កើតឡើងស្របតាម **ស្ថានភាព**
មាត្រា ៧២៣ នៃ ក្រមរដ្ឋប្បវេណី តាមរយៈភោគៈប្រាំឆ្នាំ ដែលច្បាប់
ទាមទារជាពិសេសឱ្យភោគៈនោះ ត្រូវបានមកដោយសន្តិភាព និងច្បាស់ **វិធានច្បាប់**
លាស់ ; យល់ឃើញថា ការប្រកាសដីធ្លីពុំមែនជាភស្តុតាងនៃភោគៈទេ
គ្រាន់តែជាធាតុមួយនៃភោគៈសាធារណៈប៉ុណ្ណោះ បើយោងតាមអត្ថ-
ន័យយ៉ាងច្បាស់លាស់នៃមាត្រា ៧១៣ នៃក្រមរដ្ឋប្បវេណីធាតុមួយ
ផ្សេងទៀតនៃភោគៈ គឺការបង់ពន្ធដីជាឡើងទាត់;

យល់ឃើញថា ក្នុងរឿងក្តីនេះ ការប្រៀបធៀបកាលបរិច្ឆេទចាប់ផ្តើម **ការអនុវត្តទៅលើ**
រឿងក្តី និងកាលបរិច្ឆេទប្រកាសដីធ្លី មានលក្ខណៈគ្រប់គ្រាន់ បង្ហាញឱ្យ **អង្គហេតុនៃរឿងក្តី**
ឃើញថា ភោគៈរបស់ R ពុំមានលក្ខណៈសន្តិភាព ហើយក៏នៅព្រលាំ
ដែរ ;

យល់ឃើញថា ម្យ៉ាងវិញទៀត តាមមាត្រា ១៣៤៦ នៃក្រមរដ្ឋប្ប **វិធានច្បាប់**
វេណី ការបញ្ចាំអចលនវត្ថុត្រូវទាញចេញពីកិច្ចសន្យាបង្កើតឡើង តាម
សំបុត្របញ្ជាក់ ទោះជារវាងគូភាគីក៏ដោយ; យល់ឃើញថា ក្នុង
លក្ខខណ្ឌទាំងនេះ តុលាការពុំចាំបាច់យកអំណះអំណាងរបស់ R ទាក់ទង **ការអនុវត្តទៅលើ**
នឹងអត្ថិភាពនៃកិច្ចសន្យាបញ្ចាំមកពិចារណាឡើយ ព្រោះ R ទំនងជាពុំ **អង្គហេតុនៃរឿងក្តី**
មានសមត្ថភាពនឹងបង្ហាញសំបុត្របញ្ជាក់លើបញ្ហានេះទេ;

យល់ឃើញថា ផ្ទុយមកវិញ ទោះជាក្នុងវិស័យអចលនវត្ថុក៏ដោយ រវាង
គូភាគី ការលក់ជាកិច្ចសន្យាព្រមព្រៀង មានអានុភាពចាប់តាំង ពីពេល **វិធានច្បាប់**
ផ្ទាស់ប្តូរការព្រមព្រៀង ហើយរវាងគូភាគី បើមានមន្ទិលសង្ស័យ
អត្ថិភាពនៃកិច្ចសន្យាលក់អាចបង្ហាញតាមគ្រប់មធ្យោបាយទាំងអស់ ;

យល់ឃើញថា យោងតាមនីតិវិធីបង្ហាញឱ្យឃើញថា ចៅក្រមខាងអង្គ
ហេតុបានផ្តល់ដីទំនាស់ឱ្យទៅ R ដោយពុំបានពិចារណាថាតើមានកិច្ច **ការអនុវត្តទៅលើ**
សន្យាលក់ឬទេ, យល់ឃើញថា ដោយពុំមានការជំទាស់ថា R ឬគ្រួសារ **អង្គហេតុនៃរឿងក្តី**

Scanned with CamScanner

របស់ R ពិតជាអ្នកកាន់កាប់ដីទំនាស់មុនឆ្នាំ ១៩៤៦ មែន ចៅក្រមខាងអង្គហេតុក៏ទទួលស្គាល់អំណះអំណាងរបស់ R ទាក់ទងនឹងអត្ថិភាពនៃកិច្ចសន្យាបញ្ចាំ ព្រោះមានការលំបាកយល់ថា ហេតុអ្វីបាន R ត្រូវបង្ខំឱ្យចាកចេញពីដីរបស់ខ្លួន តែចៅក្រមខាងអង្គហេតុពុំបានសម្រេច ពីបញ្ហាអត្ថិភាពនៃកិច្ចសន្យាលក់ឡើយ;

យល់ឃើញថា ហេតុដូច្នេះ គេត្រូវបង្ហាញភស្តុតាងតាមគ្រប់មធ្យោបាយថា តើមានការលក់ឬទេ គេត្រូវរកភស្តុតាងពីភោគៈពិតប្រាកដលើដីទំនាស់ នៅពេលចាប់ផ្តើមរឿងក្តី ពីព្រោះការប្រកាសដីធ្លី ដោយ R ពុំទុកជាបានផលអ្វីទាំងអស់ ដោយសារមូលហេតុដូចខាង លើ ;

យល់ឃើញថា នៅក្នុងគ្រប់ករណីទាំងអស់ ដោយចាត់ទុកជាភស្តុតាងផ្តាច់មុខនៃភោគៈនូវការប្រកាសដីធ្លីធ្វើនៅពេលភោគៈនោះ ត្រូវគេជំទាស់ទៅតុលាការ សាលដីកាសាលាឧទ្ធរណ៍បានប្រព្រឹត្តអំពើរំលោភច្បាប់ ។

ហេតុដូច្នេះ :

សេចក្តីសន្និដ្ឋាន :

ដំណោះស្រាយរបស់សាលាវិនិច្ឆ័យ

តាមទម្រង់ច្បាប់ : ទទួលបណ្តឹងសាទុក្ខ ។

ផ្នែកខាងសេចក្តីសម្រេច

តាមគតិច្បាប់ : បដិសេធ និងទុកជាមោឃៈសាលដីកាសាលាឧទ្ធរណ៍ដោយសារបានរំលោភច្បាប់ តាមការអនុវត្តមាត្រា ៤៣៧ វាក្យខណ្ឌទី ១ នៃ*ក្រមនីតិវិធីព្រហ្មទណ្ឌ* ហើយបង្វិលទៅសាលាឧទ្ធរណ៍វិញប្រកបដោយសមាសភាពថ្មី ដើម្បីឱ្យសាលាឧទ្ធរណ៍សម្រេចឱ្យស្របទៅតាមការចង្អុលបង្ហាញដូចខាងលើ ។

២-សាលដីកាសាលាឧទ្ធរណ៍

សាលដីកាសាលាឧទ្ធរណ៍ ត្រូវបានរៀបចំជារចនាសម្ព័ន្ធតាមរបៀបដូចគ្នានឹងសាលដីការបស់សាលាវិនិច្ឆ័យដែរ លើកលែងតែសំអាងហេតុរបស់សាលដីកាសាលាឧទ្ធរណ៍ចែកចេញជា"ដោយពិចារណាឃើញ Considérant" ពុំមែន"ការយល់ឃើញ Attendu"ទេ ។ ម្យ៉ាងវិញទៀត តាមសេចក្តីសម្រេចដែលយើងអាចយកមកសិក្សាបាន ក្នុងសេចក្តីអត្ថាធិប្បាយអំពី "តាមអង្គហេតុ" ជានិច្ចជាកាលសំដៅទៅលើអង្គហេតុនៃរឿងក្តី។ ហេតុដូច្នេះហើយ កថាខណ្ឌអំពី "តាមអង្គច្បាប់" ចាប់ផ្តើមដោយយោងទៅលើសេចក្តីសម្រេចរបស់ចៅក្រមថ្នាក់ទីមួយ ។

រចនាសម្ព័ន្ធគំរូរបស់សេចក្តីសម្រេចសាលាឧទ្ធរណ៍គឺ :

Scanned with CamScanner

សាលា

សម្រេចលើទម្រង់ច្បាប់នៃបណ្តឹងឧទ្ធរណ៍

យល់ឃើញថា...

តាមអង្គហេតុ : ដោយពិចារណាឃើញថា...

តាមអង្គច្បាប់ : ដោយពិចារណាឃើញថា...

ហេតុដូច្នេះ :

តាមទម្រង់ច្បាប់ :...

តាមគតិច្បាប់ :...

ប៉ុន្តែគួរកត់សំគាល់ពីការបែងចែករវាង**សាលដីកាតម្កល់** និង**សាលដីកាបដិសេធ**។ នៅក្នុងសាលដីកាបដិសេធ វិចារណកិច្ចរបស់ចៅក្រមសាលាឧទ្ធរណ៍ត្រូវបានអត្ថាធិប្បាយ ដោយគោរពតាមគោលការណ៍វិចារណកិច្ចជាបីវាក្យ-សម្ព័ន្ធ ផ្ទុយទៅវិញនៅក្នុងសាលដីកាតម្កល់ សាលាឧទ្ធរណ៍ប្រើប្រាស់រូបមន្តខ្លីៗ ដោយប្រកាសតែផ្នែកខាងសេចក្តីសម្រេចប៉ុណ្ណោះ ។ ដើម្បីផ្តល់ជាសំអាងដល់ដំណោះស្រាយអង្គសេចក្តីរបស់ខ្លួន សាលាឧទ្ធរណ៍សរសេរសាលក្រមឡើងវិញ ។

សាលដីកាសាលាឧទ្ធរណ៍ ចុះថ្ងៃទី ៣ ខែកក្កដា ឆ្នាំ១៩៩៤ (សាលដីកាតម្កល់)

សាលា :

ទម្រង់ច្បាប់ សំអាងហេតុ : យល់ឃើញថា តាមសាលក្រមចុះថ្ងៃទី ២១ ខែមេសា ឆ្នាំ១៩៩៣ សាលាដំបូងបានច្រានចោលបណ្តឹងរបស់ H ហើយឱ្យ H ទទួលបន្ទុកលើចំណាយប្រាក់ប្រដាប់ក្តីនៃរឿងក្តីដែលខ្លួនបានប្តឹងពីក្រុមហ៊ុន I ;

ផ្នែកខាងសេចក្តីសម្រេច : យល់ឃើញថា បណ្តឹងឧទ្ធរណ៍ដោយ H ពីសេចក្តីសម្រេចខាងលើមានលក្ខណៈត្រឹម ត្រូវតាមទម្រង់ច្បាប់ ហើយប្តឹងក្នុងអំឡុងពេលកំណត់ដោយច្បាប់ ;

ដូច្នេះ បណ្តឹងឧទ្ធរណ៍មានលក្ខណៈត្រឹមត្រូវតាមទម្រង់ច្បាប់ ;

គតិច្បាប់ សំអាងហេតុ : ប៉ុន្តែយល់ឃើញថា ម្ចាស់បណ្តឹងឧទ្ធរណ៍ពុំបានផ្តល់មធ្យោបាយថ្មីទេ ; យល់ឃើញថា សេចក្តីសម្រេចរបស់ចៅក្រមថ្នាក់ទីមួយមានលក្ខណៈត្រឹមត្រូវហើយ ។

ផ្នែកខាងសេចក្តីសម្រេច : ហេតុដូច្នេះ :

តាមទម្រង់ច្បាប់ : ទទួលបណ្តឹងឧទ្ធរណ៍។

តាមគតិច្បាប់ : តម្កល់ទាំងស្រុងសាលក្រមរបស់សាលាដំបូង ដោយអនុម័តយកសំអាងហេតុរបស់សាលក្រមសាលាដំបូងសម្រេចច្រានចោលបណ្តឹងទាំងអស់របស់

Scanned with CamScanner

H ហើយតម្រូវឱ្យបង់ចំណាយប្រាក់ប្រដាប់ក្តីនៅសាលាដំបូង និងសាលាឧទ្ធរណ៍ ។

តុលាការ :

(សរសេរឡើងវិញនូវសាលក្រមរបស់សាលាដំបូង)

សាលដីកាសាលាឧទ្ធរណ៍ ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ១៩៥៤ (សាលដីកាបដិសេធ)

ឧម្ភទ់ច្បាប់

សាលា :

សំអាងហេតុ

សម្រេចពីទម្រង់ច្បាប់របស់បណ្តឹងឧទ្ធរណ៍,

យល់ឃើញថា តាមលិខិតត្រឹមត្រូវតាមទម្រង់ និងធ្វើឡើងក្នុងអំឡុងពេលកំណត់ដោយច្បាប់ P បានប្តឹងឧទ្ធរណ៍ពីសាលក្រមរបស់សាលាដំបូងបារាំងនៅរាជធានីភ្នំពេញ ដែលបានចេញចំពោះមុខគូក្តីនៅថ្ងៃទី ២៤ ខែមីនា ឆ្នាំ១៩៥៣ ហើយសម្រេចច្រានចោលបណ្តឹងរបស់ P ស្នើសុំឱ្យបំផ្លាញសំណង់ធ្វើនៅលើដីរបស់ខ្លួនដោយលោក M តែបានសម្រេចឱ្យ M ប្រគល់ទៅ P ចំនួន ៣៥00$ សម្រាប់ជាសំណងនៃដីធ្លីដែលបានបំពាន ;

ផ្នែកខាងសេចក្តីសម្រេច

ដូច្នេះយល់ឃើញថា ត្រូវប្រកាសទទួលបណ្តឹងឧទ្ធរណ៍ត្រឹមត្រូវតាមទម្រង់ច្បាប់ ។

តាមអង្គហេតុ :

យល់ឃើញថា ស្តែងចេញពីនីតិវិធី និងការសួរដេញដោលសឱ្យឃើញ ថា P និង M មានដីជាប់ព្រំគ្នានៅ V ; យល់ឃើញថា M បានសាងសង់ផ្ទះមួយលើដីរបស់ខ្លួន ; យល់ឃើញថា គេពុំអាចជំទាស់បានទេ ថាសំណង់នេះបំពានលើដីរបស់ P ; យល់ឃើញថា ទោះជា P បានប្រាប់ក៏ដោយ ក៏ M នៅតែបន្តសាងសង់ផ្ទះរបស់ខ្លួន រហូតដល់ផ្ទះនេះបានបំពានលើដីរបស់ P ខ្លះ;

អង្គហេតុនៃរឿងក្តី

តាមអង្គច្បាប់ :

យល់ឃើញថា យោងតាមអង្គហេតុដូចបានកំណត់ខាងលើ សេចក្តីសម្រេចរបស់តុលាការថ្នាក់ទីមួយដែលសម្រេចច្រានចោលបណ្តឹងរបស់ P ទាមទារឱ្យរុះរើសំណង់ចេញពីដីរបស់ខ្លួន ហើយសម្រេចប្រគល់តែសំណងប៉ុណ្ណោះ ពុំមានលក្ខណៈត្រឹមត្រូវទេ ;

ការអនុវត្តទៅលើអង្គហេតុតែក្នុងលក្ខណៈ

Scanned with CamScanner

ពុំច្បាស់លាស់

យល់ឃើញថា តាមការពិតទៅបញ្ហាដែលសាលាឧទ្ធរណ៍លើកយកមកវាយតម្លៃនេះត្រូវស្ថិតក្រោមអំណាចច្បាប់បារាំង ដោយសារតែកាលបរិច្ឆេទនៃពេលកើតហេតុនោះ ពោលគឺមាត្រា ៥៥៥ នៃក្រមរដ្ឋប្បវេណីបារាំង ; យល់ឃើញថា អត្ថបទច្បាប់នេះប្រើប្រាស់ពាក្យដូចគ្នាបេះបិតទៅនឹងមាត្រា ៦៥៣ នៃក្រមរដ្ឋប្បវេណីកម្ពុជា ; យល់ឃើញថា អត្ថបទច្បាប់ទាំងពីរនេះចែងថា ;

ការពិចារណាច្បាប់

គតិច្បាប់ សំអាងហេតុ

"នាកាលដំណាំ សំណង់ និងការងទាំងពួង គឺតតិយជនបានសង់ បានធ្វើដោយសម្ភារៈរបស់ខ្លួន ហើយកម្មសិទ្ធិករត្រូវមានសិទ្ធិនឹងទុករបស់ទាំងនោះ ឬនឹងឱ្យអ្នកដទៃនោះរុះរើនាំយកចេញបាន ។

បើកម្មសិទ្ធិករឱ្យយកដំណាំ និងសំណង់ទាំងនោះចេញ អ្នកដែលបានដាំបានសាងសង់នោះត្រូវនាំយកចេញដោយបង់ខាតសោហ៊ុយលើខ្លួន និងទារសំណូកចិត្តអ្វីមិនបានឡើយ តតិយជននោះអាចនឹងត្រូវទណ្ឌកម្មឱ្យចេញសោហ៊ុយជម្ងឺចិត្តឱ្យកម្មសិទ្ធិករទៀតផងក៏បាន ប្រសិនបើកិច្ចការនោះបានបណ្តាលឱ្យមានព្យសនកម្មដល់កម្មសិទ្ធិករនៃ ដី..." ;

ការអនុវត្តទៅលើអង្គហេតុនៃរឿងក្តី និងការផ្ទែងពីវិធានច្បាប់

ម្យ៉ាងវិញទៀត យល់ឃើញថា M តែងតែដឹងថាដីនោះជាកម្មសិទ្ធិ របស់ P ហើយដឹងថា ទោះជាយ៉ាងណាក៏ដោយ ខ្លួនមិនអាចទាញយកប្រយោជន៍ពីបទបញ្ញត្តិសន្តោសប្រណី សម្រាប់តតិយជនសុចរិត ចែងដោយវាក្យខ័ណ្ឌទី ៣ នៃអត្ថបទច្បាប់ខាងលើបានឡើយ ; យល់ឃើញថា ទោះជាយ៉ាងណាក្តី M ពុំជំទាស់ថា ខ្លួនបានទទួលការដាក់កំហិតពី P ឱ្យបញ្ឈប់សំណង់របស់ខ្លួនឡើយ ;

ជាចុងក្រោយ យល់ឃើញថា សេចក្តីសម្រេចរបស់ចៅក្រមថ្នាក់ទីមួយឈានរហូតដល់ទទួលស្គាល់នូវសិទ្ធិដកហូតកម្មសិទ្ធិតាមបែបឯកជន តែតាមការពិតទៅ ឯកសិទ្ធិក្នុងការដកហូតកម្មសិទ្ធិ មានន័យថា ឯកសិទ្ធិ

ការអនុវត្តទៅលើអង្គ

Scanned with CamScanner

ហេតុនៃរឿងក្តី និងការផ្ទែងពីវិធានច្បាប់

ក្នុងការបង្ខំឱ្យបុគ្គលម្នាក់ផ្ទេរកម្មសិទ្ធិមកឱ្យខ្លួន គឺជាសិទ្ធិរបស់រាជការ និងដើម្បីផលប្រយោជន៍សាធារណៈយ៉ាងត្រឹមត្រូវប៉ុណ្ណោះ នៅក្នុងច្បាប់បារាំង ក៏ដូចជានៅក្នុងច្បាប់កម្ពុជាដែរ ។

ហេតុដូច្នេះ :

ផ្នែកខាងសេចក្តីសម្រេច

- តាមទម្រង់ច្បាប់ : ទទួលបណ្តឹងឧទ្ធរណ៍ ។
- តាមគតិច្បាប់ : បដិសេធសាលក្រមដែលគេប្តឹងឧទ្ធរណ៍ ហើយសម្រេចធ្វើអ្វីដែលចៅក្រមថ្នាក់ទីមួយគួរគប្បីធ្វើ, បង្គាប់ឱ្យ M រុះរើសំណង់ដែលបំពានលើដីរបស់ P ចេញ ដោយប្រើប្រាស់សោហ៊ុយផ្ទាល់ខ្លួន ។

ខ. នៅក្នុងនីតិវិធីមានរបស់តម្កូជាបច្ចុប្បន្ន

ការសិក្សានេះផ្តែកលើការវិភាគសាលដីការបស់តុលាការកំពូលប្រហែលជា ៣០០ សម្រេចចាប់ពីឆ្នាំ ១៩៩៥ ដល់ឆ្នាំ ២០០២ និងសាលដីកាសាលាឧទ្ធរណ៍ប្រមាណជា ៥០ សាលដីកា ។ តាមរយៈការសិក្សាខាងលើបង្ហាញពីលទ្ធភាពក្នុងការទាញចេញនូវចនាសម្ព័ន្ធគំរូមួយទាំងសម្រាប់សាលដីកាតុលាការកំពូល (១) ទាំងសម្រាប់សាលដីកា សាលាឧទ្ធរណ៍ (២) ។

១-សាលដីកាតុលាការកំពូល

នៅពេលសព្វថ្ងៃ គេឃើញមានបទបញ្ញត្តិតែមួយគត់ដែលបកស្រាយពីរចនាសម្ព័ន្ធរបស់សេចក្តីសម្រេចតុលាការ គឺមាត្រា ១៤៣ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី ០៨-០៣-១៩៩៣ ។ បទបញ្ញត្តិនេះបញ្ជាក់ថា សាលក្រមក្នុងរឿងព្រហ្មទណ្ឌត្រូវមានពីរផ្នែកគឺ :

- ផ្នែកទីមួយជាផ្នែកខាងលក្ខណៈសម្បត្តិ ត្រូវមាន :
  - អត្តសញ្ញាណរបស់តូភាគី : ឈ្មោះ ទីជ្ជាជីវៈ និងតូនាទី
  - អត្តសញ្ញាណរបស់មេធាវី
  - ការចោទប្រកាន់ជាក់លាក់
  - សំណូមពររបស់តូក្តី ប្រសិនបើមាន

Scanned with CamScanner

- ✎ សេចក្តីរំលឹកពីនីតិវិធីដែលបានប្រព្រឹត្ត ដោយមានចុះនិទ្ទេសនូវអំពើ និងកិច្ចធំៗ ព្រមទាំងឧប្បត្តិហេតុនានា ។
- ✎ សំណូរ និងចម្លើយធ្វើនៅពេលសវនាការ ។

- ផ្នែកទីពីរមានឈ្មោះថា ផ្នែកខាងសាលក្រមសុទ្ធសាធ ។ ផ្នែកនេះត្រូវចែកចេញជាពីរផ្នែកតូចៗទៀតគឺ :
  - ✎ សំអាងហេតុ គឺយោបល់ទាំងឡាយដែលនាំឱ្យកំណត់ចេញសេចក្តីសម្រេចរបស់តុលាការ ។
  - ✎ សេចក្តីសម្រេចបញ្ជាក់ពីវិធានការទាំងឡាយដែលបានចាត់ឬការផ្តន្ទាទោសដែលតុលាការបានសម្រេច ។

ទោះជាបទប្បញ្ញត្តិនេះពាក់ព័ន្ធតែនឹងសាលក្រមព្រហ្មទណ្ឌក្តី ក៏ក្នុងការអនុវត្តជាក់ស្តែង អត្ថន័យនៃបទប្បញ្ញត្តិខាងលើត្រូវបានយកមកអនុវត្តចំពោះសាលក្រមរដ្ឋប្បវេណីក្នុងន័យទូលាយដែរ និងរហូតដល់សាលដីកាសាលាឧទ្ធរណ៍ ព្រមទាំងសាលដីកាតុលាការកំពូលផងដែរ ។ ដោយពិនិត្យលើសាលដីការបស់តុលាការកំពូលបច្ចុប្បន្ន គេសង្កេតឃើញថា សាលដីកាទាំងនោះត្រូវបានរៀបចំ ដោយចែកចេញជាពីរផ្នែកដូចបានបញ្ជាក់ក្នុងមាត្រា ១៤៣ ដែរ ។ និយាយឱ្យច្បាស់ជាងនេះទៅទៀត សាលដីការបស់តុលាការកំពូលមានរចនាសម្ព័ន្ធដូចតទៅ :

១) <u>ផ្នែកទី១</u> រួមមាន :

- កាលបរិច្ឆេទសវនាការ (មានការបញ្ជាក់ថា តើសវនាការប្រព្រឹត្តទៅជាសាធារណៈ ឬជាសម្ងាត់)
- សមាសភាពរបស់តុលាការ
- អត្តសញ្ញាណរបស់គូភាគី : ម្ចាស់បណ្តឹងសាទុក្ខ និងចុងបណ្តឹងសាទុក្ខ
- ការចាប់ផ្តើមបណ្តឹងទៅតុលាការ
- អង្គហេតុ : អង្គហេតុត្រង់ចំណុចនេះពុំមែនជាអង្គហេតុដែលចៅក្រមថ្នាក់ក្រោមសម្រេចយកទេ តែជាអង្គហេតុលើកសំអាងដោយភាគីដើមចោទនៅតុលាការថ្នាក់ទីមួយប៉ុណ្ណោះ ។
- សេចក្តីរំលឹកពីនីតិវិធី :
  - ✎ សេចក្តីសម្រេចរបស់តុលាការថ្នាក់ទីមួយ (មានតែផ្នែកខាងសេចក្តីសម្រេចប៉ុណ្ណោះដែលត្រូវយកមករៀបរាប់ ចំណែកឯសំអាងហេតុវិញពុំឃើញមានចែងទេ)
  - ✎ ម្ចាស់ ឬដើមបណ្តឹងឧទ្ធរណ៍ (អំណះអំណាងរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ពុំត្រូវបានរំលឹកឡើងវិញទេ សាលដីកាតុលាការកំពូលគ្រាន់តែបញ្ជាក់ថា ម្ចាស់បណ្តឹងឧទ្ធរណ៍បានបណ្តឹងឧទ្ធរណ៍ប៉ុណ្ណោះ)
  - ✎ សេចក្តីសម្រេចរបស់ចៅក្រមថ្នាក់ទីពីរ (មានតែផ្នែកខាងសេចក្តីសម្រេចប៉ុណ្ណោះដែលត្រូវបានចង្អុលបង្ហាញ)
  - ✎ អត្តសញ្ញាណរបស់ម្ចាស់បណ្តឹងសាទុក្ខ ។

Scanned with CamScanner

- សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ[១០៦]
- អំណះអំណាងរបស់គូភាគីពេលសវនាការនៅចំពោះមុខតុលាការកំពូល[១០៧] ។

២) ផ្នែកទីពីរ

ផ្នែកនេះជាផ្នែកសំខាន់ជាងគេនៅក្នុងសាលដីកា ។ ដូយពីសាលដីកាក្នុងសម័យក្រោយបានឯករាជ្យ សាលដីការបស់តុលាការកំពូលបច្ចុប្បន្ន ប្រើប្រាស់វណ្ណយុត្ត ខ័ណ្ឌ ក្រោយឃ្លានីមួយ១ ។ ប្រធាននៃឃ្លាមានតែមួយគត់គឺ តុលាការកំពូល ប៉ុន្តែ ដើម្បីឱ្យមានភាពច្បាស់លាស់ ចៅក្រមសុខចិត្តប្រើប្រាស់សញ្ញា ខ័ណ្ឌ នៅរាល់ការបញ្ចប់ឃ្លា ហើយឃ្លានីមួយ១ ត្រូវគ្នានឹងការអធិប្បាយគំនិតមួយ។ ជួនកាល នៅក្នុងការយល់ឃើញតែមួយ គេប្រើរហូតដល់ទៅសញ្ញា ខ័ណ្ឌ ពីរ ឬបីឯណោះ។ ផ្នែកនេះចែកចេញជាពីរផ្នែកតូច១ទៀតគឺ :

- **<u>សំអាងហេតុ</u>**

សំអាងហេតុចែកចេញជាការយល់ឃើញច្រើន ហើយចំនួននៃការយល់ឃើញនេះ ប្រែប្រួលពីសេចក្តីសម្រេចមួយទៅសេចក្តីសម្រេចមួយទៀត ជាទូទៅចាប់ពីការយល់ឃើញចំនួនមួយ ទៅចំនួនប្រាំពីរ ។ សំអាងហេតុមានកម្មវត្ថុស្តីពីទម្រង់ច្បាប់ផង និងគតិច្បាប់ផង ។

ប្រសិនបើបញ្ហាគតិយុត្តទាក់ទងនឹងទម្រង់ច្បាប់ សំអាងហេតុបកស្រាយតែពីរឿងនេះទេ ។ ការពិនិត្យលើទម្រង់ច្បាប់ទាក់ទងនឹងបញ្ហាបីយ៉ាង[១០៨]

- រយៈពេលប្តឹងសាទុក្ខ
- គុណសម្បត្តិ និងផលប្រយោជន៍ក្នុងការប្តឹងសាទុក្ខ
- ទម្រង់បែបបទនៃបណ្តឹងសាទុក្ខ។

---

[១០៦] វត្តមានរបស់អយ្យការត្រូវតែមានជាដាច់ខាត ទោះជានៅក្នុងរឿងក្តីរដ្ឋប្បវេណីក៏ដោយ (មាត្រា ៥៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ)។ បទប្បញ្ញត្តិនេះចែងថា ដើម្បីមានតម្លៃត្រឹមត្រូវតាមច្បាប់ តុលាការព្រហ្មទណ្ឌ ក៏ដូចជាតុលាការរដ្ឋប្បវេណី ទាមទារឱ្យមានចៅក្រមមួយរូប រដ្ឋអាជ្ញា ឬរដ្ឋអាជ្ញារងមួយរូប និងក្រឡាបញ្ជីមួយរូបជាជំនួយការ ។ ទាក់ទងនឹងសវនាការនៅតុលាការកំពូល មាត្រា ២០៨ វាក្យខណ្ឌទី ១ បញ្ជាក្តថា តុលាការកំពូល ក្នុងពេលជំនុំជម្រះរឿងព្រហ្មទណ្ឌ ក៏ដូចជារឿងរដ្ឋប្បវេណី ត្រូវមានប្រធាននៃសាលាជំរះក្តីជាន់ខ្ពស់នេះអមដោយចៅក្រម ៤ រូប មានតំណាងមហាអយ្យការមួយរូប និងក្រឡាបញ្ជីមួយរូប ។ ក្នុងករណីដែលប្រធានអវត្តមាន ឬមានចុះ: អនុប្រធានមួយរូបត្រូវទទួលការជំនួស ។ ក្នុងន័យដូចគ្នាដែរ សូមមើលមាត្រា ១៦ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជា ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។ សម្រាប់សាលាឧទ្ធរណ៍ បទប្បញ្ញត្តិដដែលជាក់លាក់បែបនេះពុំឃើញមាននៅក្នុងច្បាប់ទេ តែមាត្រា ១៦០ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌបញ្ជាក់ថា "មុខងារសំខាន់របស់អគ្គរដ្ឋអាជ្ញាអមសាលាឧទ្ធរណ៍ គឺធ្វើសេចក្តីសន្និដ្ឋាននៅពេលសវនាការ និងប្តឹងសាទុក្ខទៅ តុលាការកំពូលចំពោះសាលដីកាសាលាឧទ្ធរណ៍ ...។

[១០៧] ប្រសិនបើភាគីមានវត្តមាននៅពេលសវនាការ ភាគីនោះនឹងលើកសំអាងរបស់ខ្លួននៅក្នុងសារណាមកអត្ថាធិប្បាយម្តងទៀត ។ ផ្ទុយទៅវិញ ប្រសិនបើភាគីណាម្នាក់អវត្តមាន ក្រឡាបញ្ជីសវនាការនឹងអានសារណារបស់ភាគីនោះ ហើយសេចក្តីសម្រេចរបស់តុលាការគ្រាន់តែបញ្ជាក់ថា សារណាត្រូវបានអានប៉ុណ្ណោះ ។

[១០៨] មាត្រា ២១១ និងមាត្រា ២១២ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

Scanned with CamScanner

ប្រសិនបើបញ្ហាគតិយុត្តទាក់ទិននឹងគតិច្បាប់ ចៅក្រមរមែងពន្យល់ពីបញ្ហាទម្រង់ច្បាប់នៅក្នុងឃ្លានៃការយល់ឃើញមួយ, ឬច្រើន ។ ជាញឹកញាប់ ឃ្លានេះច្រើនតែជាឃ្លាគំរូដើម្បីបញ្ជាក់ថា បណ្តឹងសាទុក្ខត្រឹមត្រូវតាមទម្រង់ច្បាប់ ។ សំអាងហេតុអំពីគតិច្បាប់ត្រូវបានចៅក្រមយកមកបកស្រាយជាលក្ខណៈវែង ឬខ្លី នៅក្នុងការយល់ឃើញផ្សេងទៀត ។ ចំពោះរឿងនេះ គេសង្កេតឃើញថា ហាក់ដូចជាពុំមានឯកភាពគ្នាពីសាលដីកាមួយ ទៅសាលដីកាមួយទៀតទេ ។ រាល់សេចក្តីសម្រេចទាំងអស់សុទ្ធតែមានសេចក្តីថ្លែងពីអង្គហេតុមិនប្រែប្រួល បានសេចក្តីថា អង្គហេតុលើកសំអាងដោយគូភាគី ហើយចៅក្រមថ្នាក់ក្រោមចាត់ទុកថាត្រឹមត្រូវពិតប្រាកដ ។ សេចក្តីថ្លែងនេះខុសគ្នាពីសាលដីកាមួយទៅសាលដីកាមួយទៀត ។ អង្គហេតុអាចរួមបញ្ចូលគ្នានៅក្នុងការយល់ឃើញតែមួយ ឬអធិប្បាយជាខ្លឹៗនៅក្នុងការយល់ឃើញជាច្រើន ។ នៅក្នុងសេចក្តីសម្រេចបច្ចុប្បន្ន ចៅក្រមរមែងភ្ជាប់អង្គហេតុពន្យល់ជាមួយនឹងមូលដ្ឋានច្បាប់តែម្តង ពោលគឺ : បទប្បញ្ញត្តិច្បាប់ ឬជាបទបញ្ជា ទំនៀមទម្លាប់ ឬគោលការណ៍ទូទៅណាមួយ ។

ឧទាហរណ៍ : យល់ឃើញថា ដើមដងរបស់លោក X ពិតជាបានរលំលើផ្ទះរបស់លោក Y បណ្តាលឱ្យមានការខូចខាតផ្ទះរបស់លោក Y ប្រាកដមែន ។ ដូច្នេះ លោក X ត្រូវទទួលខុសត្រូវដូចដែលមានចែងក្នុងមាត្រា ១២១ នៃក្រឹត្យ-ច្បាប់លេខ ៣៨ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៨៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ។

ផ្ទុយពីសាលដីការបស់សាលាវិនិច្ឆ័យក្នុងនីតិកម្មជាសម័យមុនដែលធ្វើការបកស្រាយវិធានច្បាប់ មុននឹងយកវិធានច្បាប់នោះទៅអនុវត្តលើអង្គហេតុនៃរឿងក្តី សេចក្តីសម្រេចរបស់តុលាការកំពូលបច្ចុប្បន្ន ទោះជាសេចក្តីសម្រេចថ្មីៗខ្លះក៏ដោយ ក៏ពុំស្ទើរមានសំអាងហេតុផ្នែកច្បាប់ដែរ មានច្រើនតែសំអាងហេតុផ្នែកអង្គហេតុប៉ុណ្ណោះ ។

- <u>**សេចក្តីសម្រេច**</u>

ផ្នែកខាងសេចក្តីសម្រេចតែងចាប់ផ្តើមដោយឃ្លាគំរូដូចតទៅ :

- **លើកបណ្តឹងចោលជាអសារបង់** បានសេចក្តីថា បណ្តឹងសាទុក្ខត្រូវបានច្រានចោលដោយខុសនឹងទម្រង់ច្បាប់ ។
- **ទទួលបណ្តឹងសាទុក្ខទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ និងគតិច្បាប់** មានន័យថា បណ្តឹងសាទុក្ខមានលក្ខណៈត្រឹមត្រូវលើគ្រប់ផ្នែកទាំងអស់ ។ សាលដីកានេះគេហៅថា <u>**សាលដីកាបដិសេធ**</u>[105] ។
- **ទទួលបណ្តឹងសាទុក្ខទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខុសនឹងគតិច្បាប់** ឃ្លានេះមានអត្ថន័យថា បណ្តឹងសាទុក្ខអាចទទួលយកមកពិនិត្យបាន ព្រោះត្រឹមត្រូវតាមទម្រង់ហើយ ប៉ុន្តែ បណ្តឹងនេះពុំមានលក្ខណៈត្រឹមត្រូវទេ បើគេពិនិត្យទៅលើគតិច្បាប់នោះ ។ សាលដីកានេះមានឈ្មោះថា <u>**សាលដីកាតម្កល់**</u> ។

បន្ទាប់ពីឃ្លានេះរួចហើយ ជាញឹកញាប់ ចៅក្រមតែងសរសេរឃ្លាដែលមើលទៅមានលក្ខណៈច្រំដែល ដោយរំលឹកឡើងវិញថា សាលដីការបស់សាលាឧទ្ធរណ៍ត្រូវទុកជាមោឃៈ[110] ឬក៏បណ្តឹងសាទុក្ខត្រូវបដិសេធចោលខ្លះ ឬទាំងស្រុងតាមទម្រង់ និងគតិច្បាប់ ។

---

[105] ការពន្យល់បកស្រាយ សូមមើលផ្នែកដែលជាភាសាចាវ៉ង ។

[110] ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌពុំប្រើពាក្យ ***ទុកជាមោឃៈ*** ដោយស្ងួយប្រវត្តិទេ (មាត្រា ២២១ វាក្យខណ្ឌចុងក្រោយ មាត្រា ១៦៥ វាក្យខណ្ឌចុងក្រោយ និងមាត្រា ២០៩) ប៉ុន្តែ ពេលខ្លះច្បាប់ប្រើពាក្យ ***បដិសេធ*** ជាជំនួសវិញ : សូមមើលមាត្រា ២២០ និងមាត្រា ២២១ ។ ទាក់ទងនឹងបណ្តឹងសាទុក្ខ

Scanned with CamScanner

សាលដីកាតុលាការកំពូល ចុះថ្ងៃទី ៤ ខែ មីនា ឆ្នាំ ១៩៩៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

តុលាការកំពូល
សំណុំរឿងរដ្ឋប្បវេណី
លេខ ១០៦
ចុះថ្ងៃទី ១៧.០៤.៩៨
សាលដីកា
លេខ ៣៩
ចុះថ្ងៃទី០៤.០៣.៩៩

ផ្នែកទី មួយ

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី ០៤ ខែមីនា ឆ្នាំ១៩៩៩ ដោយមានសមាសភាពដូចតទៅ... ។

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ១០ ចុះថ្ងៃទី ១២.០១.៩៨ នៃសំណុំរឿងលេខ ៧៦៤ ចុះថ្ងៃទី ២៦.១២.៩៦ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ M... និងចុងបណ្តឹងសាទុក្ខឈ្មោះ K ... ។

អត្តសញ្ញាណរបស់គូភាគីការចាប់ផ្តើមបណ្តឹងនៅតុលាការ

កម្មវត្ថុនៃបណ្តឹង : ប្តឹងទាមទារសំណងអន្តរាយ

បានឃើញបណ្តឹងសាទុក្ខលេខ ៥០ ចុះថ្ងៃទី ០៣.០៣.៩៨ របស់ឈ្មោះ M1 ប្តឹងមិនសុខចិត្ត នឹងសេចក្តីសំរេចរបស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១០៦ ចុះថ្ងៃទី ២៧.០៤.៩៨ របស់តុលាការកំពូល ។

ច្បាប់កំប្រើប្រាស់ពាក្យ បដិសេច ដែរ : មាត្រា ២២០ វាក្យខ័ណ្ឌទី ២។ ក្នុងការអនុវត្តជាក់ស្តែង ពាក្យ បដិសេច ត្រូវប្រើប្រាស់បញ្ចូលគ្នាជាមួយពាក្យ *តាមទម្រង់ច្បាប់ ឬតាមច្បាប់* ។

Scanned with CamScanner

តាមពាក្យបណ្តឹងចុះថ្ងៃទី ១២.០៥.៩២ របស់ឈ្មោះ K ប្តឹងទាមទារសំណងជួសជុលការខូចខាតផ្ទះចំនួន ២០០ ០០០ រៀល ពីឈ្មោះ M ដោយអាងហេតុថា ដើមដូងមួយដើមរបស់ M បានបាក់រលំសង្កត់លើផ្ទះរបស់ខ្លួនបណ្តាលឱ្យបាក់ផ្ទោងផ្ទាន និងសង្កសីមួយចំនួនទៀត។

អង្គហេតុលើកសំអាងដោយដើមចោទ

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១៨៤ ចុះថ្ងៃទី ១៩.០៨.៩៥ របស់តុលាការខេត្តបាត់ដំបងដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

សាលក្រម (សេចក្តីសំរេច)

១-ក.ទទួលពាក្យបណ្តឹងចុះថ្ងៃទី១២.០៥.៩២ របស់ឈ្មោះ K ជាដើមចោទប្តឹងទាមទារសំណងអន្តរាយបណ្តាលពីដើមដូងបាក់លើផ្ទះ ពីឈ្មោះ M ជាចុងចម្លើយ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

ខ.ទទួលយកសំណូមពរនាពេលសវនាការរបស់ដើមចោទសុំទាមទារសំណងអន្តរាយ និង ជំងឺចិត្តទុកជាត្រឹមត្រូវតាមគតិច្បាប់

គ.លិខិតផ្ទេរសិទ្ធិចុះថ្ងៃទី ២១.០២.៩៥ របស់ឈ្មោះ M ជាចុងចម្លើយធ្វើការផ្ទេរសិទ្ធិឱ្យឈ្មោះ N ត្រូវជាប្រពន្ធ មកជាតំណាងស្របច្បាប់ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់។

២-ឱ្យឈ្មោះ M ជាចុងចម្លើយចេញសំណងអន្តរាយ និងជំងឺចិត្តជាប្រាក់រៀលស្មើនឹងប្រាក់បាតចំនួន ៥000 បាត ឱ្យឈ្មោះ K ជាដើមចោទ។ ដើមចោទទាមទារលើសពីនេះបដិសេធចោល ។ គិតចាប់ពីថ្ងៃដែលសាលក្រមនេះចូលជាស្ថាពរ។ តាមមាត្រា ១២១ និងមាត្រា ១២៨ នៃក្រឹត្យច្បាប់លេខ ៣៨ ក្រ.ច. ចុះថ្ងៃទី ២៨.១០.៨៨។

៣-បង្គាប់ឱ្យឈ្មោះ M ជាចុងចម្លើយបង់ប្រាក់ប្រដាប់ក្តី...

៤-សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី។ បើកផ្លូវឧទ្ធរណ៍ ២ ខែ គិតពីថ្ងៃកាត់ក្តីតទៅ។

បណ្តឹងឧទ្ធរណ៍

បានឃើញ សេចក្តីសុំប្តឹងតវ៉ាលេខ ១១១ ចុះថ្ងៃទី ១៦.១០.៩៥ របស់ឈ្មោះ M ប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចរបស់តុលាការខេត្តបាត់ដំបងទាំងមូល។

សាលដីកាសាលាឧទ្ធរ

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១០ ចុះថ្ងៃទី ១២.០១.៩៨ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៦.១០.៩៥ របស់ឈ្មោះ M ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយខុសនឹងគតិច្បាប់។

Scanned with CamScanner

ណ៍ (សេចក្តីសំរេច)

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ១៨៤ ចុះថ្ងៃទី ១៩.០៨.៩៥ របស់តុលាការខេត្ត បាត់ដំបងទុកជាបានការពេញទាំងមូល ។

៣-រីបអូសប្រាក់ប្រដាប់ក្តី... ។

៤-សាលដីកានេះប្រកាសជាសាធារណៈចំពោះមុខភូតិ្ត បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញ បណ្តឹងសាទុក្ខលេខ ៥០ ចុះថ្ងៃទី០៣.០៣.៩៨ របស់ឈ្មោះ M1 ប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចរបស់សាលាឧទ្ធរណ៍ទាំងមូល ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា :

ក្រោយពីបានពិនិត្យត្រប់ឯកសារពាក់ព័ន្ធរឿងក្តីនេះមក

តំណាងមហាអយ្យការយល់ឃើញថា សាលាឧទ្ធរណ៍សំរេចត្រឹមត្រូវតាមគតិច្បាប់ហើយ ។ សូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាម ច្បាប់ ។

អំណះអំណាងរបស់ម្ចាស់បណ្តឹងសាទុក្ខ

បានស្តាប់ចម្លើយដោះសាររបស់ឈ្មោះ M1 នៅពេលជំនុំជំរះថា ក្នុងពាក្យបណ្តឹងដើមចោទ សុំសងតែ ២០ ម៉ឺនរៀលទេ តែតុលាការឱ្យសង ៥000 បាតទៅវិញ ខ្លួនឆ្ងល់ថា គេគ្រប់គ្នា ពេលខ្យល់ព្យុះ មានរដ្ឋអំណាចជួយដោះស្រាយយកចិត្តទុកដាក់ ចំណែកខ្លួនទៅជាសងគេវិញ ។ ខ្លួនចង់ដឹងថា មានច្បាប់ណាដែលកំណត់ឱ្យខ្លួនសង ។

បានស្តាប់សារណារបស់ឈ្មោះ K

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់លោក M1 និងសារណារបស់លោក K

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

Scanned with CamScanner

ភាពអាចទទួលបាននៃបណ្តឹងតាមទំរង់ច្បាប់

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៥០ ចុះថ្ងៃទី ០៣.០៣.៩៨ របស់លោក M1 តំណាងឱ្យ លោក M ប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចនៃសាលដីការដ្ឋប្បវេណីលេខ ១០ ចុះថ្ងៃទី ១២. ១០.៩៨ របស់សាលាឧទ្ធរណ៍ទាំងមូល ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី។

សំអាងហេតុ

ការបង្ហាញអង្គហេតុ និងការភ្ជាប់អង្គហេតុទៅនឹងមូលដ្ឋានច្បាប់

-យល់ឃើញថា ដើមដូងរបស់លោក M ពិតជាបានរលំលើផ្ទះរបស់លោក K បណ្តាលឱ្យ មានការខូចខាតផ្ទះរបស់លោក K ប្រាកដមែន។ ដូច្នេះ លោក M ត្រូវទទួលខុសត្រូវដូច ដែលមានចែងក្នុងមាត្រា ១២១ នៃក្រឹត្យ ច្បាប់លេខ ៣៨ ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ១៩៨៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា។

ផ្នែកទី ៣:

-យល់ឃើញថា ការដែលលោក M1 លើកឡើងថា ការបាក់ដើមដូងរបស់លោកគឺបណ្តាលមកពីបាតុភូតធម្មជាតិនោះ ពុំមានភស្តុតាងបញ្ជាក់ឱ្យបានថាជាករណីប្រធានសក្តិឡើយ ហើយការកំណត់សំណងរបស់តុលាការ គឺធ្វើឡើងតាមការអង្កេត និងតាមសំណូមពររបស់ ជនរងគ្រោះ។

-យល់ឃើញថា លោក K បានធ្វើសារណាការពារក្តីរបស់លោកជូនតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខលោក ប៉ុន្តែចាត់ទុកជាចំពោះមុខ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ១០ ចុះថ្ងៃទី ១២.០១.៩៨ របស់សាលាឧទ្ធរណ៍សំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវទាំងទំរង់ ទាំងគតិច្បាប់ហើយ។

ហេតុដូច្នេះ

សំរេចសេចក្តីចំពោះមុខលោក M1 កំបាំងមុខលោក K ប៉ុន្តែចាត់ទុកជាចំពោះមុខ

Scanned with CamScanner

សេចក្តីសំរេច

១-ទទួលបណ្តឹងសាទុក្ខលេខ ៥០ ចុះថ្ងៃទី ០៣.០៣.៩៨ របស់លោក M1 ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនីតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ ១០ ចុះថ្ងៃទី ១២.០១.៩៨ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីដែលលោក M1 បានបង់រួចហើយនៅតុលាការកំពូលចំនួន ១៩ 000 រៀល ... ។

៤-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី ០៤ ខែមីនា ឆ្នាំ១៩៩៩ ។

២_សាលដីកាសាលាឧទ្ធរណ៍

រចនាសម្ព័ន្ធទូទៅនៃសាលដីការបស់សាលាឧទ្ធរណ៍ក៏ឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យកំណត់ ដោយមាត្រា ១៨៣ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ដែរ ។ ដូច្នេះ រចនាសម្ព័ន្ធរបស់សាលដីកាសាលាឧទ្ធរណ៍មានលក្ខណៈប្រហាក់ប្រហែលនឹងសាលដីការបស់តុលាការកំពូលដែរ ។

ជារួមមក រចនាសម្ព័ន្ធទូទៅរបស់សាលដីកាសាលាឧទ្ធរណ៍អាចបង្ហាញតាមរបៀបដូចតទៅ[111] :

១) ផ្នែកទីមួយ

- កាលបរិច្ឆេទនៃសវនាការ (លក្ខណៈជាសាធារណៈ ឬជាសម្ងាត់) ។ ភាពខុសគ្នាបន្តិចរវាងសាលដីការបស់សាលាឧទ្ធរណ៍ និងសាលដីការបស់តុលាការកំពូលគឺ : ក្នុងសាលដីកាសាលាឧទ្ធរណ៍ ការចង្អុលបង្ហាញពីកាលបរិច្ឆេទតែងនាំមុខដោយឃ្លាគំរូមួយឃ្លាគឺ : (សាលាឧទ្ធរណ៍) បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់ សាលាជំរះក្តីដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ ៦៦ ក្រ ចុះថ្ងៃទី ០៨-០២-១៩៩៣ ។
- សមាសភាពរបស់សាលាឧទ្ធរណ៍
- អត្តសញ្ញាណរបស់គូភាគី : ម្ចាស់ ឬដើមបណ្តឹងឧទ្ធរណ៍ និងចុងបណ្តឹងឧទ្ធរណ៍
- ការចាប់ផ្តើមបណ្តឹងនៅតុលាការ
- អង្គហេតុលើកឡើងដោយដើមចោទនៅតុលាការថ្នាក់ទីមួយ
- សេចក្តីរំលឹកពីនីតិវិធី :
  - សេចក្តីរំលឹកពីភស្តុតាងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរដែលគូភាគីនៅតុលាការថ្នាក់ទីមួយលើកសំអាង
  - សេចក្តីសម្រេចរបស់ចៅក្រមថ្នាក់ទីមួយ (មានតែផ្នែកខាងសេចក្តីសម្រេចប៉ុណ្ណោះ)
  - អត្តសញ្ញាណរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍

[111] សាលដីកាចំទួន ៥០ ត្រូវបានយកមកសិក្សា ។

Scanned with CamScanner

- សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- អំណះអំណាងរបស់គូភាគី ពេលសវនាការនៅសាលាឧទ្ធរណ៍ ។

២) ផ្នែកទីពីរ

ផ្នែកនេះរួមមានពីរផ្នែកតូច១គឺ :

- **<u>សំអាងហេតុ</u>**

ដូចគ្នានឹងសាលដីកាតុលាការកំពូលដែរ ចៅក្រមសាលាឧទ្ធរណ៍សម្រេចលើទម្រង់ច្បាប់នៃបណ្តឹងឧទ្ធរណ៍ជាមុនសិន ។ ប្រសិនបើបណ្តឹងឧទ្ធរណ៍មានលក្ខណៈត្រឹមត្រូវតាមទម្រង់ច្បាប់ហើយ ចៅក្រមនឹងពិនិត្យពីគតិច្បាប់នៃរឿងក្តី ។ ក្នុងករណីនេះ ចៅក្រមរៀបរាប់ពីបញ្ហាទម្រង់ច្បាប់នៅក្នុងការយល់ឃើញមួយឃ្លា ។ ចំពោះការពិនិត្យលើគតិច្បាប់វិញ រចនាសម្ព័ន្ធរបស់សាលដីកាសាលាឧទ្ធរណ៍ ពុំខុសប្លែកពីសាលដីការបស់តុលាការកំពូលទេ ។ ចៅក្រមសម្រេចលើបញ្ហានេះ ដោយសរសេរសំអាងហេតុចាប់ពី ១ ទៅ ១០ ឃ្លា ចាប់ផ្តើមដោយការយល់ឃើញ ក្នុងគោលដៅបញ្ជាក់ពីភាពពិតប្រាកដនៃអង្គហេតុ និងពន្យល់ពីអង្គហេតុទាំងនោះ ។

- **<u>សេចក្តីសម្រេច</u>**

ផ្នែកខាងសេចក្តីសម្រេចតែងចាប់ផ្តើមដោយឃ្លាគំរូមួយ :

- ***បដិសេធបណ្តឹងឧទ្ធរណ៍ចោលដោយខុសនឹងទម្រង់ច្បាប់*** បានសេចក្តីថា បណ្តឹងឧទ្ធរណ៍ពុំអាចទទួលយកបានទេ តាមទម្រង់ច្បាប់ ។
- ***ទទួលបណ្តឹងឧទ្ធរណ៍ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់*** មានន័យថា បណ្តឹងឧទ្ធរណ៍អាចទទួលយកបានខាងទម្រង់ច្បាប់ ហើយការប្តឹងមកនេះក៏ត្រឹមត្រូវតាមគតិច្បាប់ដែរ ។ សាលដីកាប្រភេទនេះ ហៅថា **<u>សាលដីកាបដិសេធ</u>** ។
- ***ទទួលបណ្តឹងឧទ្ធរណ៍ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខុសនឹងគតិច្បាប់*** ឃ្លានេះមានអត្ថន័យថា បណ្តឹងឧទ្ធរណ៍អាចទទួលយកបានតាមទម្រង់ច្បាប់ តែបណ្តឹងនេះពុំអាចទទួលបានជោគជ័យ ដោយខុសនឹងគតិច្បាប់ ។ សាលដីកាប្រភេទនេះ ហៅថា **<u>សាលដីកាតម្កល់</u>** ។

បន្ទាប់មកទៀត ចៅក្រមតែងសរសេរឃ្លាប្រយោគដែលមើលទៅមានលក្ខណៈច្រំដែល ដោយរំលឹកឡើងវិញថា សាលដីកានេះកែប្រែ ឬតម្កល់សាលក្រមខ្លះ ឬទាំងស្រុង ។

Scanned with CamScanner

សាលដីកាសាលាឧទ្ធរណ៍ ចុះថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០០២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តាមនាមប្រជារាស្ត្រខ្មែរ
សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ ៦៦ ក្រ ចុះថ្ងៃទី ០៨.០២.២០០២
បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍នាថ្ងៃទី ០៣.១០. ២០០២
ដោយមាន សមាសភាពដូចតទៅ...
ដើម្បីជំនុំជំរះលើបណ្តឹងឧទ្ធរណ៍នៃរឿងរដ្ឋប្បវេណីលេខ ៥៦៣ ចុះថ្ងៃទី ១៣-០៨-២០០២

- ដើមចោទឈ្មោះ A ... ជាដើមបណ្តឹងឧទ្ធរណ៍ ។
- ចុងចម្លើយឈ្មោះB ... ជាដើមបណ្តឹងឧទ្ធរណ៍ ។
- តតិយជនឈ្មោះ S និង D ... ជាដើមបណ្តឹងឧទ្ធរណ៍ ។

<u>កម្មវត្ថុបណ្តឹង</u> : ប្តឹងទាមទារប្រាក់ជំពាក់ចំនួន ៥000 USD និងជម្ងឺចិត្ត ២000 USD

អត្ថសញ្ញាណរបស់តួភាពីការចាប់ផ្តើមបណ្តឹងនៅតុលាការ

ផ្នែកទី មួយ

តាមបណ្តឹងឧទ្ធរណ៍លេខ ១៧ ចុះថ្ងៃទី ១២-០៦-២០០២ របស់ឈ្មោះ X (តំណាងដើមចោទ) មិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីចុះថ្ងៃទី ០៩-០៥-២០០២ របស់តុលាការក្រុង ភ្នំពេញទាំងមូល បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៤-០៦-២០០២ របស់ឈ្មោះ D មិនសុខចិត្តអំពី សំណងជម្ងឺចិត្ត និងសំណងបំណុលជំពាក់- បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៧-០៦-២០០២ របស់ឈ្មោះ B មិនសុខចិត្តត្រង់ចំណុចទី ២ និងចំណុច ខ នៃសាលក្រម ។
រីឯដំណើរឿងហេតុមានដូចតទៅ :

អង្គ

Scanned with CamScanner

ហេតុលើកសំអាងដោយដើមចោទនៅតុលាការថ្នាក់ទីមួយ

តាមពាក្យបណ្ដឹងចុះថ្ងៃទី ១១-០២-២០០២ របស់ដើមចោទឈ្មោះ A បានប្ដឹងទាមទារប្រាក់ជំពាក់ចំនួន ៥000 USD និងជម្ងឺចិត្តចំនួន ៣000 USD ពីចុងចម្លើយឈ្មោះ B ដោយលើកសំអាងហេតុថា ឈ្មោះនេះបានខ្ចីលុយពីខ្លួន តាំងពីថ្ងៃទី ២៣-០៨-២000 ដោយដាក់បញ្ចាំបួងផ្ទះ តែពុំព្រមសងវិញតាមសន្យា។

បណ្ដឹងតប របស់ចុងចម្លើយ

បានឃើញពាក្យបណ្ដឹងតបចុះថ្ងៃទី ០៣.០៤.២00២ របស់ឈ្មោះ B ថាខ្លួនសុំបដិសេធពាក្យបណ្ដឹងរបស់ A និងសុំបដិសេធកិច្ចសន្យាលក់ជូនម្ចាស់ដើមចុះថ្ងៃទី ២៣-០៨-២000 ដោយសំអាងហេតុថា ការដែលឈ្មោះ A បានប្ដឹងពីខ្លួននោះ គឺមិនត្រឹមត្រូវទេ ព្រោះថា ឈ្មោះ S និងប្រពន្ធឈ្មោះ D ពីរនាក់ប្ដីប្រពន្ធជាអ្នកខ្ចីប្រាក់ទេ ដោយគ្រាន់តែឱ្យខ្លួនធ្វើជាសាក្សីដឹងឮក្នុងរឿងនេះ។ អ្នកទាំងពីរក៏បានទទួលស្គាល់ផងដែរ នាពេលផ្សះផ្សានៅចំពោះមុខតុលាការក្រុងភ្នំពេញថ្ងៃទី ០៥-០៣-២00២ ថាពួកខ្លួនទាំងពីរនាក់ ជាអ្នកខ្ចីប្រាក់ និងជាអ្នកទទួលប្រាក់ទាំងអស់នោះដែរ។ ដូច្នេះ ខ្លួន B សុំឱ្យឈ្មោះ A ប្ដឹង ទារពីឈ្មោះ S និងប្រពន្ធឈ្មោះ D វិញចុះ។

សេចក្ដីរំលឹកពីភស្ដុតាងលើកសំអាងនៅតុលាការថ្នាក់ទីមួយ ឬអំណះ

បានឃើញចម្លើយរបស់តំណាងដើមចោទឈ្មោះ A ឆ្លើយនាពេលផ្សះផ្សា ក៏ដូចជាពេលស៊ើបសួរនៅតុលាការថ្នាក់ក្រោមថា ខ្លួននៅតែរក្សាការប្ដឹងទាមទារប្រាក់ពីចុងចម្លើយឈ្មោះ B ដូចក្នុងពាក្យបណ្ដឹងដដែល ដោយសំអាងថា ចុងចម្លើយ B បានខ្ចីលុយចំនួន ៥000USD ហើយបានយកបួងផ្ទះមកដាក់បញ្ចាំនិងបានដាក់ឈ្មោះផ្ទេរកម្មសិទ្ធិឱ្យហើយ បានសុំជូលផ្ទះនោះពីខ្លួនដើម្បីស្នាក់នៅជាបណ្ដោះអាសន្នវិញ ដោយឱ្យឈ្នួលផ្ទះតម្លៃ ១៧៥ USD ក្នុងមួយខែ តែក្រោយមកចុងចម្លើយគេចវេះមិនព្រមបង់ឈ្នួលផ្ទះ និងបានបដិសេធមិនទទួលស្គាល់ការជំពាក់នេះ។ ហើយឈ្មោះ B បានធ្វើកិច្ចសន្យាថា ក្នុងរយៈពេល ១ ឆ្នាំ បើគ្មានលុយលោះយកផ្ទះនោះវិញទេ សុខចិត្តប្រគល់ផ្ទះនោះឱ្យខាងដើមចោទ។ ក្នុងរឿងនេះ ខ្លួនសំណូមពរថា ប្រសិនបើឈ្មោះ B ជាចុងចម្លើយមិនព្រមសងប្រាក់ សុំឱ្យតុលាការរឹបអូសទ្រព្យសម្បត្តិដែលមានលក់ឡាយឡុង សងបំណុល បើរឹងរូស សុំឱ្យចាប់ដាក់គុកបង្ខំ រូបកាយតាមច្បាប់។

Scanned with CamScanner

អំណាងរបស់គូភាគីនៅតុលាការថ្នាក់ទីមួយ

បានឃើញចម្លើយរបស់ចុងចម្លើយឈ្មោះ B ឆ្លើយថា ខ្លួនមិនបានខ្ចីលុយពីដើមចោទទេ គឺ គ្រាន់តែបានប្រគល់ប្លង់ផ្ទះរបស់ខ្លួនទៅនាង D និងប្តីឈ្មោះ S យកទៅដាក់បញ្ចាំដើម្បីខ្ចីប្រាក់ចំនួន ៥000 USD យកទៅធ្វើដើមទុនរកស៊ី ហើយខ្លួនធ្លាប់បានប្រាប់ដើមចោទ តាំងពីដំបូងថា ខ្លួនព្រមឱ្យឈ្មោះ S និងនាង D យកប្លង់ផ្ទះខ្លួនដាក់បញ្ចាំដើម្បីខ្ចីប្រាក់។

បានឃើញចម្លើយរបស់ឈ្មោះ S និងប្រពន្ធឈ្មោះ D ជាតតិយជនខាងភាគីចុងចម្លើយ បានឆ្លើយនាពេលផ្សះផ្សាថា ចំពោះលុយដែលចុងចម្លើយឈ្មោះB បានខ្ចីពីដើមចោទនោះ ខ្លួនជាអ្នកទទួលយកទាំងអស់ទៅធ្វើដើមទុនរកស៊ី គឺយកផ្ទាល់នៅការិយាល័យមេធាវីរបស់ដើមចោទ មិនបានយកបន្តពីឈ្មោះ B ទេ។ ហេតុនេះ ពួកខ្លួនទាំងពីរនាក់ប្តីប្រពន្ធសុំធានាចេញលុយសងទៅដើមចោទវិញ ជាបណ្តើរៗ បើសងទាំងអស់តែម្តង ខ្លួនមិនមាន លទ្ធភាពទេ។

បានឃើញចម្លើយរបស់ឈ្មោះ S (តតិយជន) បានឆ្លើយក្នុងកំណត់ហេតុចុះថ្ងៃទី ០៥-០៣-២00២ នៅតុលាការក្រុងភ្នំពេញថា ខ្លួនពិតជាបានទៅទាក់ទងខ្ចីលុយពីឈ្មោះ A ពិតប្រាកដមែន ដោយយកប្លង់ផ្ទះរបស់អ្នកស្រី B ទៅដាក់ ហើយភាគីខាងដើមបណ្តឹងបានទៅមើលផ្ទះ ហើយយល់ព្រមឱ្យខ្ចីលុយចំនួន ៥000 USD។ ខ្លួនធ្លាប់បានប្រាប់ទៅដើមចោទ តាំងពីទំនាក់ទំនងដំបូងថា ខ្លួនជាអ្នកខ្ចីលុយ យកទៅទិញឡានរកស៊ី ហើយខាងដើមបណ្តឹងបានទារយកប្លង់ផ្ទះរបស់ខ្លួន យកទៅដាក់ទើបគេព្រមឱ្យលុយខ្ចី តែផ្ទះខ្លួនឥតមានប្លង់ ទើបប្រពន្ធរបស់ខ្លួនបានទៅខ្ចីប្លង់របស់អ្នកស្រី B យកទៅដាក់ ហើយដើមចោទក៏បានយល់ព្រមឱ្យខ្លួនខ្ចីលុយ ដោយដើមចោទជាអ្នករត់ការធ្វើកិច្ចសន្យាទាំងអស់។ ក្នុងរឿងនេះ ខ្លួនយល់ព្រមសងលុយទៅដើមចោទវិញ ប៉ុន្តែតាមលទ្ធភាពបន្តិចម្តងៗ បើសងទាំងអស់តែម្តង ខ្លួនពុំមានលទ្ធភាពទេ។

Scanned with CamScanner

បានឃើញចម្លើយរបស់ឈ្មោះ D (ប្រពន្ធរបស់ឈ្មោះ S) បានឆ្លើយថា ប្តីរបស់ខ្លួនបានទៅទាក់ទងនៅការិយាល័យមេធាវី ដើម្បីខ្ចីលុយ ហើយខ្លួនបានទៅខ្ចីបួងផ្ទះពីឈ្មោះ B ដើម្បីយកទៅបញ្ចាំយកលុយ ដើមចោទក៏បានទៅមើលផ្ទះ និងជាអ្នករត់ការធ្វើកិច្ចសន្យាផ្សេងៗទាំងអស់ ។ ហើយថាខ្លួនមិនបានទៅទាក់ទងខ្ចីលុយទេ គឺបានទៅចូលរួមប៉ុណ្ណោះ ហើយក៏មិនបានផ្តិតមេដៃលើកិច្ចសន្យាណាមួយនោះដែរ ។ ប៉ុន្តែខ្លួនទទួលស្គាល់ថា ប្តីរបស់ខ្លួនពិតជាបានទៅខ្ចីលុយពីដើមចោទដោយផ្ទាល់ ។

បានឃើញចម្លើយសាក្សីឈ្មោះ L ឆ្លើយថា ឈ្មោះ B បានមកទាក់ទងសុំខ្ចីលុយពីឈ្មោះ A ហើយ A បានឱ្យខ្លួនទៅមើលផ្ទះរបស់អ្នកស្រី B ហើយក៏សម្រេចឱ្យខ្ចី លុយ ។ នៅពេលនោះ ឈ្មោះ A បានរៀបចំសំណុំឯកសារ ហើយឱ្យអ្នកស្រី B ផ្តិត មេដៃ ពេលអ្នកស្រី B មកទទួលប្រាក់ បានយកបួងផ្ទះមួយ និងអត្តសញ្ញាណប័ណ្ណមួយមកដាក់ ដោយមានពីរនាក់ប្តីប្រពន្ធឈ្មោះ S និងឈ្មោះ D ផ្តិតមេដៃធ្វើជាសាក្សី ។ ខ្លួនមិនបានផ្តិតមេដៃលើលិខិតស្នាម ធ្វើជាសាក្សីក្នុងកិច្ចសន្យាផ្សេងៗនោះទេ ខ្លួនគ្រាន់តែបានដឹងឮ ព្រោះខ្លួនធ្វើការនៅការិយាល័យមេធាវីនោះដែរ ។

បានឃើញសាលក្រមលេខ ១១ ចុះថ្ងៃទី ០៥-០៥-០២ របស់តុលាការក្រុងភ្នំពេញ ដែលបានសម្រេច :

សាលក្រម (ផ្នែកខាងសេចក្តីសម្រេចប៉ុណ្ណោះ)

១-ទទួលពាក្យបណ្តឹងដើមចោទឈ្មោះ A ចុះថ្ងៃទី ១១.០២.០២ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ និងគតិច្បាប់ ។

- ទទួលស្គាល់លោក X ជាតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។

២- បង្គាប់ឱ្យឈ្មោះ B ឈ្មោះ S និងឈ្មោះ D រួមគ្នាសងប្រាក់ចំនួន ៥000 USD (ប្រាំពាន់ដុល្លាអាមេរិក) ការប្រាក់ ៥% ក្នុងមួយឆ្នាំ គិតចាប់ពីថ្ងៃប្រកាសសាលក្រម និងជម្ងឺ ចិត្តចំនួន ១ លានរៀល ។

ក) បើគ្មានប្រាក់បង់តាមការកំណត់ខាងលើទេ ត្រូវរឹបអូសទ្រព្យសម្បត្តិរបស់ឈ្មោះ S និងឈ្មោះ D លក់ឡាយឡុង ។

ខ) បើលក់ទ្រព្យសម្បត្តិរបស់ឈ្មោះ S និងប្រពន្ធឈ្មោះ D មិនគ្រប់ទេ ត្រូវលក់ឡាយឡុងផ្ទះរបស់ចុងចម្លើយ B សងបង្គ្រប់ ។

គ) បើគ្មានទ្រព្យសម្បត្តិ ត្រូវដាក់គុកបង្ខំរូបរាងកាយលើឈ្មោះ S និងប្រពន្ធឈ្មោះ D តាមមាត្រា ១៣៣ នៃច្បាប់ស្តីពីនីតិវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ ៥១ ក្រ ចុះថ្ងៃទី ២០-០៥-៩២ ។

៣-បង្គាប់ឱ្យឈ្មោះ B S និង D បង់ប្រាក់ប្រដាប់ក្តី...

Scanned with CamScanner

៤-សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខភាគី។ បើគូភាគីណា
មួយមិនសុខចិត្តនឹងសាលក្រមនេះ សម្រេចបើកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍ក្នុងរយៈពេលពីរខែ
គិតពីថ្ងៃប្រកាសសាលក្រម ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ១៧ ចុះថ្ងៃទី ១០-០៦-០២ របស់ឈ្មោះ X (តំណាង
ឱ្យដើមចោទ) មិនសុខចិត្តត្រង់ចំណុចនៃសាលក្រមទាំងមូល។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ១៩ ចុះថ្ងៃទី ២៤-០៦-០២ របស់ឈ្មោះ D មិនសុខ
ចិត្តអំពីសំណងជម្ងឺចិត្ត និងសំណងចំណុលជំពាក់។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ២០ ចុះថ្ងៃទី ២៧-០៦-០២ របស់ឈ្មោះ B មិនសុខ
ចិត្តត្រង់ចំណុចទី ២ និងចំណុច ខ នៃសាលក្រម។

បានឃើញរបាយការណ៍រឿងចុះថ្ងៃទី ២៧-០៩-០២ របស់ចៅក្រមរបាយការណ៍សា-
លាឧទ្ធរណ៍។

នាពេលសវនាការ

-លោកមេធាវី Y តំណាងឱ្យឈ្មោះ A ជាដើមចោទបានឆ្លើយថាការប្តឹងតវ៉ាមកនេះ
ដោយសារចៅក្រមថ្នាក់ក្រោមសម្រេចខុសនឹងគតិច្បាប់។ ការមិនសុខចិត្តនេះ គឺដោយ
សារឈ្មោះ B ជាអ្នកខ្ចី បែរជាសម្រេចឱ្យឈ្មោះ S ជាអ្នកសងទៅវិញ។ ហើយថា
ក្នុងរឿងនេះ គឺជាការខ្ចីចងការប្រាក់។ កូនក្តីខ្លួនពិតជាបានទទួលការប្រាក់ចំនួន ១៤
ខែ ហើយមែន ។ លោកសំណូមពរសុំបដិសេធសាលក្រមតុលាការថ្នាក់ក្រោមទាំងមូល
ព្រោះថាឈ្មោះ B ជា កូនបំណុល រីឯឈ្មោះ S គ្រាន់តែជាសាក្សីប៉ុណ្ណោះ ។ ហើយ
សុំទាមទារជម្ងឺចិត្តចំនួន ៣000 ដុល្លាអាមេរិក និងការប្រាក់តាមច្បាប់កំណត់ ។

-ចុងចម្លើយឈ្មោះ B និងតតិយជនឈ្មោះ S អវត្តមាន។

តំណាងមហាអយ្យការសន្និដ្ឋាន : សូមតុលាការសម្រេចតាមច្បាប់ចុះ។

ក្រោយពីបានស្តាប់ចម្លើយមេធាវីតំណាងដើមចោទ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានពិនិត្យ និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

សាលាឧទ្ធរណ៍

-យល់ឃើញថា ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១២-០៦-០២ របស់ឈ្មោះ X ធ្វើឡើង
តាមកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជំរះបាន យោងតាមបញ្ញត្តិមាត្រា ៧ នៃ
ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី។

-យល់ឃើញថា ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៤-០៦-០២ របស់ឈ្មោះ D ធ្វើឡើង

Scanned with CamScanner

ផ្នែក ទី ៣

តាមកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន យោងតាមបញ្ញត្តិមាត្រា ៧ នៃ ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ។ — ឧទ្ធរណ៍

-យល់ឃើញថា ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៧-០៦-០២ របស់ឈ្មោះ B ធ្វើឡើងតាមកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន យោងតាមបញ្ញត្តិមាត្រា ៧ នៃ ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ។

យល់ឃើញថា ពាក្យសុំទទួលស្គាល់មេធាវីចុះថ្ងៃទី ២៣-០៨-០២ សុំទទួលស្គាល់លោក មេធាវី Y ជាមេធាវីរបស់ឈ្មោះ A ធ្វើឡើងមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

យល់ឃើញថា តាមលិខិតផ្ទេរសិទ្ធិដី និងផ្ទះចុះថ្ងៃទី ២១-០៨-២០០០ បានបញ្ជាក់ឱ្យ ឃើញថាឈ្មោះ B បានផ្ទេរកម្មសិទ្ធិដី និងផ្ទះទៅឱ្យដើមចោទហើយ ខ្លួនបានជួលផ្ទះនេះពីដើមចោទវិញក្នុងតម្លៃ ១៧៥ ដុល្លាអាមេរិក ក្នុងមួយខែ ។ ប៉ុន្តែតាមការអះអាង និងការប្តឹងទាមទារ ៥000 ដុល្លាអាមេរិក ដោយមានអត្រាការប្រាក់ ១៧៥ ដុល្លាអាមេរិកក្នុងមួយខែ ។ ដូចនេះ ឃើញថា កិច្ចសន្យាខាងលើពុំមែនជាកិច្ចសន្យាលក់ផ្ទេរកម្មសិទ្ធិ និងជួលផ្ទះ ទេ គឺជាកិច្ចសន្យាខ្ចីចង្ការប្រាក់ ។ — ការបង្ហាញពីអង្គហេតុ

សំអាងហេតុ

យល់ឃើញថា តាមការអះអាងរបស់ចុងចម្លើយឈ្មោះ B និងតតិយជនឈ្មោះ S ប្រពន្ធ ឈ្មោះ D បានបញ្ជាក់ថា ឈ្មោះ B ពុំមែនជាអ្នកខ្ចីប្រាក់ពីដើមចោទទេ គឺឈ្មោះ S និង ប្រពន្ធឈ្មោះ D ជាអ្នកខ្ចី ហើយបានយកបួងផ្ទះរបស់ឈ្មោះ B ទៅដាក់បញ្ចាំឱ្យដើមចោទ តែប៉ុណ្ណោះ ប៉ុន្តែការអះអាងនេះពុំមានលក្ខណៈត្រឹមត្រូវឡើយ ព្រោះថា តាមលិខិតផ្ទេរសិទ្ធិ ដី និងផ្ទះចុះថ្ងៃទី ២១.០៨.២000 កិច្ចសន្យាលក់ជូនម្ចាស់ដើមវិញ និងលិខិតជួលផ្ទះចុះថ្ងៃទី ២១-០៨-២000 និងតាមបង្កាន់ដៃទទួលប្រាក់ថ្លៃឈ្នួលផ្ទះ (ឬការប្រាក់) គឺមានតែឈ្មោះ B តែប៉ុណ្ណោះ ជាគូភាគី រីឯឈ្មោះ S គ្រាន់តែជាសាក្សីប៉ុណ្ណោះ ។ ដូចនេះឈ្មោះ B ត្រូវមានកាតព្វកិច្ចសងបំណុលនេះទៅឱ្យដើមចោទវិញ។

យល់ឃើញថា ចុងចម្លើយ និងតតិយជនបានអះអាងថា ខ្លួនបានបង់ការប្រាក់ឱ្យទៅដើមចោទបានចំនួន ១៤ ខែ ហើយនាពេលសវនាការ ដើមចោទបានឆ្លើយទទួលស្គាល់ថា បានទទួលការប្រាក់ពីចុងចម្លើយចំនួន ១៤ ខែ ពិតមែន ដែលស្មើនឹង ២៤៥0 ដុល្លាអាមេរិក។

យល់ឃើញថា កិច្ចសន្យាខ្ចីប្រាក់នេះ មានការប្រាក់លើសច្បាប់កំណត់ ដូចមានចែងក្នុងមាត្រា ៥៩ នៃក្រឹត្យច្បាប់លេខ ៣៨ ក្រច ចុះថ្ងៃទី ២៨-១0-៨៨ ដូចនេះចំនួនការប្រាក់លើសនេះគប្បីគិតជាប្រាក់ដើមតាមបញ្ញត្តិមាត្រា ៦0 នៃក្រឹត្យច្បាប់ខាងលើនេះ — ការបង្ហាញពីអង្គ

Scanned with CamScanner

ហេតុនិងការភ្ជាប់អង្គហេតុទៅនឹងមូលដ្ឋានច្បាប់

វិញ ។ ប៉ុន្តែ តុលាការគប្បីគិតការប្រាក់តាមច្បាប់ និងការខាតបង់របស់ដើមបំណុលវិញ។

យល់ឃើញថា តាមការយល់ឃើញខាងលើ សាលក្រមលេខ ១១ ចុះថ្ងៃទី ០៩-០៥-០២ សំរេចមានលក្ខណៈខុសឆ្គងពីគតិច្បាប់ គប្បីបដិសេធចោល ។

ហេតុដូច្នេះទិនិច្ឆ័យសេចក្តី

ផ្នែកខាងសេចក្តីសំរេច

១-ទទួលបណ្តឹងឧទ្ធរណ៍របស់ឈ្មោះ X ចុះថ្ងៃទី ១២-០៦-០២ បណ្តឹងឧទ្ធរណ៍របស់ឈ្មោះ D ចុះថ្ងៃទី ២៤-០៦-០២ និងបណ្តឹងឧទ្ធរណ៍របស់ឈ្មោះ B ចុះថ្ងៃទី ២៧-០៦-០២ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-បដិសេធសាលក្រមរដ្ឋប្បវេណីលេខ ១១ ចុះថ្ងៃទី ០៩-០៥-០២ របស់តុលាការក្រុងភ្នំពេញចោលជាអសារបង់ ។

៣-ទុកជាមោឃៈកិច្ចសន្យាចុះថ្ងៃទី ២៣-០៨-២០០០ និងកិច្ចសន្យាលក់ និងលោះវិញ ចុះថ្ងៃទី ២៣-០៨-២០០០ និងលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី ២១-០៨-២០០០ រវាងឈ្មោះ A និង B ចាប់ពីពេលនេះតទៅ ។

៤-បង្គាប់ឱ្យឈ្មោះ B សងប្រាក់ចំនួន ២៥៥០ ដុល្លាអាមេរិកទៅឱ្យឈ្មោះ A ព្រមទាំងការប្រាក់ ៥% ក្នុងមួយឆ្នាំ លើទឹកប្រាក់ ៥០០០ ដុល្លាអាមេរិក គិតពីថ្ងៃទី ២៣-០៨-២០០០ រហូតដល់ថ្ងៃទី ២៣-១០-០១ និងការប្រាក់ ៥%ក្នុងមួយឆ្នាំលើប្រាក់ដើម ២៥៥២ ដុល្លាអាមេរិកគិតចាប់ពីថ្ងៃទី ២៣-១០-០១ រហូតដល់ថ្ងៃសងគ្រប់ចំនួន ។

-បង្គាប់ឱ្យឈ្មោះ B សងការខាតបង់ និងជម្ងឺចិត្តចំនួន ១៥០០ ដុល្លាអាមេរិកទៅឱ្យឈ្មោះ A ។

-បើឈ្មោះ B គ្មានប្រាក់សង និងរឹងរូសមិនព្រមសង បង្គាប់ឱ្យរឹបអូសផ្ទះ លក់ឡាយឡុង ដើម្បីធានាសំណង និងដាក់គុកបង្ខំរូបកាយ តាមមាត្រា ១៣៥ នៃច្បាប់ស្តីពីវិធី អនុវត្តសាលក្រមរដ្ឋប្បវេណី ។

៥-កាត់យកប្រាក់ប្រដាប់ក្តី...

Scanned with CamScanner

៦-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខដើមចោទ កំពាំងមុខចុងចម្លើយ និងតតិយជន បើកផ្លូវតវ៉ាក្នុងកំណត់ច្បាប់ ។

ផ្នែកទី ២ : ទិធីសាស្ត្រនៃការធ្វើសណាកប័ត្រសេចក្តីសម្រេចរបស់តុលាការ : (បេអាទ្រីស ចាលីវេ និង កាន ច័ន្ទមេត្តា)

វិធីសាស្ត្រដែលត្រូវបង្ហាញ (កថាខណ្ឌទី ១) ព្រមទាំងមានលំហាត់នឹងត្រូវបានលើកឡើងផងដែរនោះ គឺដើម្បីអនុញ្ញាតឱ្យនិស្សិត និងបេក្ខជនប្រឡងអាចហ្វឹកហាត់ នៅក្នុងមុខវិជ្ជាប្រឡងនីមួយៗ (កថាខណ្ឌទី ២) ។

កថាខណ្ឌទី ១ : ទិធីសាស្ត្រនៃការគាត់តែងសណាកប័ត្រសេចក្តីសម្រេចរបស់តុលាការ :

មុននឹងតាក់តែងសណាកប័ត្រសេចក្តីសម្រេចរបស់តុលាការ (ក) យើងត្រូវត្រៀមរៀបចំនូវកិច្ចការជាបឋមមួយចំនួន (ខ) ។

ក. ការរៀបចំកិច្ចការជាបឋម

ក្រដាសព្រាងដ៏ល្អគឺជាគន្លឹះនៃការធ្វើសណាកប័ត្រសេចក្តីសម្រេចរបស់តុលាការ ប្រកបដោយគុណភាព ។ ការអានតែមួយលើក ទោះបីជាការអាននោះមានលក្ខណៈម៉ត់ចត់យ៉ាងណាក៏ដោយ ក៏គ្មានលក្ខណៈគ្រប់គ្រាន់ដែរ គឺត្រូវគោរពនូវដំណាក់ជាច្រើនទៀត :

១. មុននឹងចាប់ផ្តើមអាននូវសេចក្តីសម្រេចរបស់តុលាការ ត្រូវស្វែងរកជាមុនសិននូវប្រភេទនៃសេចក្តីសំរេចនោះ "ដីកា, សាលក្រម ឬសាលដីកា....", យុត្តាធិការទទួលពាក្យបណ្តឹង និងកាលបរិច្ឆេទនៃសេចក្តីសម្រេចនោះ ។

២. ត្រូវអានសេចក្តីសម្រេចរបស់តុលាការលើកទីមួយ ដើម្បីទាញយកប្រធានបទដែលទាក់ទង ។

៣. ចុងបញ្ចប់ ការអានលើកទី ២ និងលើកទី ៣ "ឬច្រើនជាងនេះ"ជាការចាំបាច់ដើម្បីទទួលបាននូវការយល់ដឹងដោយលំអិតទៅលើសេចក្តីសម្រេចនោះ ។ តាមរយៈការអាននេះ អ្នកត្រូវមានសមត្ថភាពលើកឡើងនូវអង្គហេតុនៃវិវាទ, ចំណោទបញ្ហាគតិយុត្តចំពោះចៅក្រម, អំណះអំណាងរបស់គូភាគី, សេចក្តីសម្រេចចេញដោយចៅក្រមទៅលើចំណោទបញ្ហាខាងលើ ។ ដើម្បីធ្វើកិច្ចការនេះបាន កិច្ចការនៅលើក្រដាសព្រាងមានសារៈសំខាន់ជាចំបង ។ អ្នកត្រូវយល់អំពីរចនាសម្ព័ន្ធនៃសេចក្តីសម្រេចរបស់តុលាការ ដោយបែងចែកនូវអង្គហេតុជាមួយការចាប់ផ្តើមដាក់ពាក្យបណ្តឹង, សេចក្តីសម្រេចរបស់តុលាការថ្នាក់ទី ១ "ផ្នែកសេចក្តីសម្រេច និងសំអាងហេតុ", អំណះអំណាងរបស់គូភាគីនៅសាលាឧទ្ធរណ៍, សេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ "ផ្នែកសេចក្តីសម្រេច និងសំអាងហេតុ",អំណះអំណាងរបស់គូភាគីនៅតុលាការ-កំពូល, សេចក្តីសម្រេចរបស់តុលាការកំពូល "ផ្នែកសេចក្តីសម្រេច និងសំអាងហេតុ" ។ បើសិនជាអ្នកជួបនូវផលលំបាកក្នុងការកំណត់នូវអត្តសញ្ញាណនៃផ្នែកនីមួយៗ អ្នកអាចយកពាក្យ "យល់ឃើញថា ឬប៉ុន្តែ យល់ឃើញថា" ជាជំនួយបាន ។

ឧទាហរណ៍ : ដោយមិនពិនិត្យមើលប្រអប់ខាងស្តាំ អ្នកត្រូវព្យាយាមកំណត់អត្តសញ្ញាណនូវផ្នែកនីមួយៗ នៃសេចក្តីសម្រេចលេខ ២៧ ចុះថ្ងៃទី ១៩-០៩-១៩៩៧ របស់តុលាការកំពូល :

Scanned with CamScanner

- អង្គហេតុ
- ការចាប់ផ្តើមពាក្យបណ្តឹងទៅតុលាការ
- សេចក្តីសំរេចរបស់តុលាការថ្នាក់ទី ១
- បណ្តឹងឧទ្ធរណ៍
- សេចក្តីសំរេចរបស់សាលាឧទ្ធរណ៍
- បណ្តឹងសាទុក្ខ
- សេចក្តីសំរេចរបស់តុលាការកំពូល

តុលាការកំពូលបានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី ១២-០៩-១៩៩៧... ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌខេ ៤៩ ចុះថ្ងៃទី ០៣-០៣-១៩៩៧ របស់សាលាឧទ្ធរណ៍ "លើកទី ២" និងសំណុំរឿងព្រហ្មទណ្ឌលេខ ៣០ ចុះថ្ងៃទី ២៣-០៥-១៩៩៧ របស់តុលាការកំពូល ពីបទធ្វើមនុស្សឃាដដោយអចេតនា និងបង្ករបួសស្នាមដោយអចេតនា ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ០២-០៩-១៩៩៥ តាមបញ្ញត្តិមាត្រា ៥៦ និង៦០ ច្បាប់ចរាចរជើងគោក និងមាត្រា ៦៨-៧០ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

ម្ចាស់បណ្តឹងសាទុក្ខ : លោក ឡៅ ប៊ុនខេង "អ្នកទទួលខុសត្រូវសំណងរដ្ឋប្បវេណី" ភេទ ប្រុស អាយុ ៣៩ ឆ្នាំ សញ្ជាតិខ្មែរ កើតនៅឃុំស្វាយចៅ ស្រុកសង្កែ ខេត្តបាត់ដំបង ការិតវប្បធម៌ថ្នាក់ទី ២ ចាស់ សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃ ផ្ទះលេខ ៣៥១ ផ្លូវលេខ ១៦៣ សង្កាត់ទួលទំពូងទី ២ ខណ្ឌចំការមន រាជធានីភ្នំពេញ របររកស៊ីធ្វើសិប្បកម្មឡអិដ្ឋ ប្រពន្ធឈ្មោះ សុង រ៉ូចនី មានកូនចំនួន ០៣ នាក់ ឪពុកឈ្មោះ ឡៅ សិរិទ្ធ "រ" ម្តាយឈ្មោះ អ៊ឹង សៀនអេង "ស" ។ មេធាវី ឬអ្នកការពារក្តី "គ្មាន"

ឈ្មោះ ឡៀន ប៉ាវ "**ជនជាប់ចោទ**" ភេទប្រុស អាយុ ៤២ ឆ្នាំ សញ្ជាតិខ្មែរ កើតនៅឃុំទីកវិល ស្រុកស្អាង ខេត្តកណ្តាល ការិតវប្បធម៌ថ្នាក់ទី ១១ ចាស់ សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិព្រែកថ្មី ឃុំទីកវិល ស្រុកស្អាង ខេត្តកណ្តាល របររកស៊ី កម្មករបើករថយន្ត ប្រពន្ធឈ្មោះ ម៉ៅ សៀងហៃ មានកូនចំនួន ០៧ នាក់ ឪពុកឈ្មោះ ឡៀន "ស" ម្តាយឈ្មោះ ឡាំង អ៊ "រ" ទោសពីមុនគ្មាន ។ ក្រៅឃុំ ។

ចុងបណ្តឹងសាទុក្ខ : ១. លោក ហ៊ុយ វ៉ា "ដើមបណ្តឹងរដ្ឋប្បវេណី" ភេទប្រុស អាយុ ៥៤ ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃផ្ទះលេខ ៩៦ អឺ0 ផ្លូវលេខ ១៤៨ ក្រុមទី ៣៥ សង្កាត់ផ្សារកណ្តាលទី ២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ របររកស៊ីលក់ដូរ ។

២. លោក សេង រចនា "ដើមបណ្តឹងរដ្ឋប្បវេណី" ភេទប្រុស អាយុ ៤៣ ឆ្នាំ

Scanned with CamScanner

សញ្ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃផ្ទះលេខ ១០៤ អឺ0 ផ្លូវលេខ ៥៣ ក្រុមទី ៥ សង្កាត់ផ្សារ ថ្មីទី ៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ របររកស៊ី លក់ដូរ ។

ជនរងគ្រោះ : ១. ឈ្មោះ វ៉ា លី "ស្លាប់ ត្រូវជាកូនរបស់លោក ហ៊ុយ វ៉ា "ភេទស្រី អាយុ ២១ ឆ្នាំ សញ្ជាតិខ្មែរ របររកស៊ី សិស្ស ។

២. ឈ្មោះ អ៊ុ សោភ័ណ "របួសស្នាម ត្រូវជាកូនរបស់លោក សេង រចនា " ភេទស្រី អាយុ ១៨ ឆ្នាំ សញ្ជាតិខ្មែរ រប់ររកស៊ី សិស្ស ។ មេធាវី ឬអ្នកការពារ "គ្មាន" ។

តាមបណ្តឹងសាទុក្ខ"លើកទី ២" លេខ ១៣៤ ចុះថ្ងៃទី ២៤-០៤-១៩៩៧ របស់លោក ឡៅ ប៊ុនខេង ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌ "លើកទី ២" លេខ ៤៩ ចុះថ្ងៃទី ០៣-០៣-១៩៩៧ របស់សាលាឧទ្ធរណ៍ លើសេចក្តីសម្រេចទាំងមូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ១៣-០៩-១៩៩៥ របស់លោក ហ៊ុ វ៉ា និងលោក សេង រចនា ត្រូវជាឪពុករបស់ជនរងគ្រោះទាំងពីរ បានអះអាងថា : នៅថ្ងៃទី ០២-០៩-១៩៩៥ វេលាម៉ោង ០៩ ព្រឹក កូនស្រីខ្លួនទាំងពីរនាក់បានធ្វើដំណើរមួមគ្នាជិះម៉ូតូឆាលីមួយគ្រឿងតាមបណ្តោយផ្លូវពីខេត្តកណ្តាល មកក្រុងភ្នំពេញ ហើយត្រូវរងគ្រោះថ្នាក់ចរាចរ នៅម្តុំសង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ ដោយឡានដឹកដីធុនធ្ងន់មួយគ្រឿង បានមកបុកពីក្រោយ មានម៉ាកហ្គុយសូ ផ្លាក លេខ ក.0៣៣៨ បើកបរដោយឈ្មោះ គ្បៀន ប៉ាវ ភេទប្រុស អាយុ ៤២ ឆ្នាំ សញ្ជាតិខ្មែរ ឈ្មោះនេះស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រុមហ៊ុនដឹកដី-សុង វុចលី តំណាងក្រុមហ៊ុននេះ ដោយ ឈ្មោះ ឡៅ ប៊ុនខេង បណ្តាលឱ្យកូនរបស់ពួកគេ នាង វ៉ា លី ត្រូវស្លាប់ និងនាង អ៊ុ សោភ័ណ ត្រូវរងរបួស និងម៉ូតូឆាលីមួយគ្រឿងត្រូវខ្ទេចខ្ទីអស់ប្រើមិនកើត ។ ពួកគេធ្វើសំណូមពរ ដល់ស្ថាប័នមានសមត្ថកិច្ច ឱ្យផ្តន្ទាទោសជនល្មើសទៅតាមច្បាប់ និងសុំឱ្យក្រុមហ៊ុនដឹកដី-សុង វុចលី តំណាងដោយឈ្មោះ ឡៅ ប៊ុនខេង សងសំណងជាម៉ូចិត្ត និងថ្លៃធ្វើបុណ្យសព ចំនួន ៦ ម៉ឺនដុល្លាអាមេរិក និងកូនខ្លួនរងរបួសស្នាមថ្លៃថ្នាំព្យាបាលជាម៉ូចិត្ត និងថ្លៃម៉ូតូខូច សរុបចំនួន ១០ ម៉ឺន ដុល្លាអាមេរិក ។

អង្គហេតុ

ការដាក់ពាក្យបណ្តឹងទៅ តុលាការ

បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមតុលាការក្រុងភ្នំពេញថា : ក្នុងរឿងនេះការស្លាប់ និងរបួសរបស់ជនរងគ្រោះ ពិតជារងដោយការបើកបរ រថយន្តរបស់ជនល្មើស ដោយផ្អែកលើចម្លើយសាក្សី ជនរងគ្រោះ និងរបាយការណ៍របស់សមត្ថកិច្ច ជាកំហុសរបស់ជនល្មើស ក្នុងនាមតំណាងអយ្យការ សូមតម្កល់ការចោទប្រកាន់ទុកដដែល និងប្រគល់សិទ្ធិជូនតុលាការវិនិច្ឆ័យតាមច្បាប់ ។

យោងតាមសាលក្រមលេខ ១៣៧ ចុះថ្ងៃទី ២៧-១១-១៩៩៥ តុលាការក្រុងភ្នំពេញបានសម្រេចថា :

Scanned with CamScanner

សេចក្តីសម្រេចរបស់តុលាការថ្នាក់ទី ១

១. ផ្តន្ទាទោសឈ្មោះ គ្បែន ប៉ាវ ភេទប្រុស អាយុ ៤២ ឆ្នាំ ជាតិខ្មែរ ដោយដាក់ពន្ធនាគារចំនួន ០១ ឆ្នាំ តែទោសនេះព្យួរទាំងអស់ ដោយទុករយៈពេលសាកល្បងចំនួន ០៥ ឆ្នាំ គិតពីថ្ងៃឃុំខ្លួន ថ្ងៃទី ០៦-០៩-១៩៩៥ តទៅ តាមមាត្រា ៤០.៧០ និង ៥៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលនៅកម្ពុជា និងច្បាប់ចរាចរជើងគោក ពីបទសម្លាប់មនុស្សដោយអចេតនា និងបង្ករបួសស្នាមដោយអចេតនា ប្រព្រឹត្តនៅទីក្រុងភ្នំពេញ កាលពីថ្ងៃទី ០២-០៩-១៩៩៥ ។

២.បង្គាប់ឱ្យឈ្មោះ ឡៅ ប៊ុនខេង ភេទប្រុស អាយុ ៣៩ ឆ្នាំ ជាតិ ខ្មែរ ជាអ្នកទទួលខុសត្រូវខាងរដ្ឋប្បវេណី សងជូន គ្បែន ប៉ាវ នូវសោហ៊ុយបង់ខាត និងជម្ងឺចិត្តចំនួន ២៥ ០០០ ដុល្លាអាមេរិក ឱ្យទៅឈ្មោះ ហ៊ុន វ៉ា ប្រពន្ធឈ្មោះ យឹម នាង ដែលជាដើមបណ្តឹងរដ្ឋប្បវេណី ជាឪពុកម្តាយជនរងគ្រោះឈ្មោះ វ៉ា លី និងឱ្យសងចំនួនទឹកប្រាក់ ៣០០០ ដុល្លាអាមេរិក និងថ្លៃម៉ូតូចំនួន ១ ៣០០ ដុល្លាអាមេរិក ឱ្យទៅឈ្មោះ សេង រចនា ប្រពន្ធឈ្មោះ អ៊ឹម ហ៊ាង ដែលជាឪពុកម្តាយ របស់នាង អ៊ុ សោភ័ណ ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

៣. សម្រេចរឹបអូសរថយន្តម៉ាកហ្សុយសូ មីស៊ុបីស៊ី ពាក់ផ្លាកលេខ ក. ០៣៣៨ ភ.ព.៣ លេខតួ អា.២២០២០២៥ លេខម៉ាស៊ីន ៦០៣៨៦៦ ដើម្បីទុកលក់ធានាសំណង ក្នុងករណីមិនព្រមសង ។

៤.ម៉ូតូឆាលីរបស់ជនរងគ្រោះ ពាក់ផ្លាកលេខ ឆ.៦១៣៧ ភ.ព.១ ប្រគល់ឱ្យជនរងគ្រោះឈ្មោះ អ៊ុ សោភ័ណ វិញ ។

៥.សាលក្រមនេះជំនុំជម្រះជាសាធារណៈ ចំពោះមុខជនជាប់ចោទ សម្រេចបើកផ្លូវឧទ្ធរណ៍តាមការកំណត់ច្បាប់ ។

សារណានៅសាលាឧទ្ធរណ៍

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ១២៦ ចុះថ្ងៃទី ២៨-១១-១៩៩៥ របស់ឈ្មោះ ចុង អ៊ៀវហេង "ជាមេធាវីការពារជនជាប់ចោទ" ដែលប្តឹងតវ៉ាពីសាលក្រមព្រហ្មទណ្ឌលេខ ១៣៧ "ក" ចុះថ្ងៃទី ២៧-១១-១៩៩៥ ត្រង់ចំណុចទី ២-៣ នៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា :ចំពោះសំណងរដ្ឋប្បវេណី និងចំពោះបញ្ហាធានាយកឡានចេញ គឺស្រេចលើក្រុមប្រឹក្សាជំនុំជម្រះពិចារណាចុះ។

សេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍

បានឃើញសាលដីកាព្រហ្មទណ្ឌ "លើកទី ១" លេខ ២៣ ចុះថ្ងៃទី ២៩-១១-១៩៩៦ របស់សាលាឧទ្ធរណ៍ដែលបានសម្រេច :

១.ទទួលបណ្តឹងឧទ្ធរណ៍របស់លោក ចុង អ៊ៀវហេង មេធាវីជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៣៧ ចុះថ្ងៃទី ២៧-១១-១៩៩៥ របស់តុលាការក្រុងភ្នំពេញទុកជាបានការ លើកលែងតែចំណុចទី ៤ ត្រូវបដិសេធចោល ហើយចំណុចទី ២ ត្រង់សំណងថ្លៃម៉ូតូ ត្រូវសម្រេចកែប្រែថា : ប្រគល់ម៉ូតូឆាលីពាក់ផ្លាកលេខ ឆ. ៦១៣៧ ភ.ព.១

Scanned with CamScanner

ឱ្យទៅឈ្មោះ ឡេវ៉ែ ប៊ុនខេង ដែលជាអ្នកទទួលខុសត្រូវសំណងរដ្ឋប្បវេណី ជាកម្មសិទ្ធិតទៅ និង បង្គាប់ឱ្យឈ្មោះ ឡេវ៉ែ ប៊ុនខេង សងប្រាក់ចំនួន ១000 ដុល្លាអាមេរិក ជាថ្លៃម៉ូតូ ទៅឱ្យឪពុក ម្តាយជនរងគ្រោះឈ្មោះ អ៊ុ សោភ័ណ ឈ្មោះ សេង រចនា និងឈ្មោះ អ៊ុម ហ៊ាង ។ ក្រៅពីនេះ តម្កល់ទុកជាបានការដដែល ។

៣. សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នាពេលសវនាការ ចំពោះដើមបណ្តឹងរដ្ឋ ប្បវេណី អ្នកទទួលខុសត្រូវសំណងរដ្ឋប្បវេណី ជនជាប់ចោទ និងមេធាវីរបស់អ្នកទទួលខុសត្រូវ សំណងរដ្ឋប្បវេណី ។ បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

បណ្តឹងសាទុក្ខ លើកទី ១

បានឃើញបណ្តឹងសាទុក្ខ "លើកទី ១" លេខ ៨៧ ចុះថ្ងៃទី ២២-០៤-១៩៩៦ របស់លោក ចុង អ៊ឹវហេង "មេធាវីការពារជនជាប់ចោទ" ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ២៣ ចុះថ្ងៃទី ២៩-0៣-១៩៩៦ របស់សាលាឧទ្ធរណ៍លើសេចក្តីសម្រេចទាំងមូល ។

សេចក្តីសន្និដ្ឋានរបស់អគ្គ-ព្រះរាជអាជ្ញា

បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមតុលាការកំពូលថា :តាមការស៊ើបអង្កេតរបស់តុលាការទាំងពីរថ្នាក់រួចមក ហើយពុំមានភស្តុតាងមកផ្ទុយកំណត់ហេតុនេះទេ ហើយដូចនេះ កំណត់ហេតុគួរតែជឿទុកជាភស្តុតាង ហើយវ៉ាស៊ីសង្វាក់គ្នានឹងចម្លើយសាក្សីឈ្មោះ វ៉ា ដែលបានឆ្លើយចំពោះមុខនគរបាល កាលពីថ្ងៃទី ០2-0៩-១៩៩៥ ។ នៅក្នុងកំណត់ហេតុនេះ មានបញ្ជាក់ពីមូលហេតុដែលនាំឱ្យមានការស្លាប់ និងរបួសនោះច្បាស់លាស់ណាស់ គឺថាមូលហេតុ ដែលបណ្តាលឱ្យមានគ្រោះថ្នាក់ គឺរថយន្តប្រជែងម៉ូតូខាងស្តាំខ្វះការប្រុងប្រយ័ត្ន ឯម៉ូតូមិនប្រកាន់ចំណីផ្លូវរបស់ខ្លួន ។ ម៉្យាងវិញទៀត ក្នុងកំណត់ហេតុចុះថ្ងៃទី 0២-0៩-១៩៩៥ បញ្ជាក់ថា ម៉ូតូជិះពីមុខរថយន្តផ្នែកខាងស្តាំ នេះបញ្ជាក់ឱ្យឃើញថា អ្នកបើកបរនៅពីក្រោយម៉ូតូ បានឃើញម៉ូតូពិតប្រាកដ ហើយបានប្រជែងស្តាំ ខ្វះការប្រុងប្រយ័ត្នយ៉ាងពិតប្រាកដ ។ គប្បីអ្នកបើកបរបង្អង់ល្បឿន ហើយស៊ីផ្លៃសុំផ្លូវទៅ តែបែជាបង្ខំវ៉ាស្តាំ ដែលជាកំហុសមួយធ្ងន់ធ្ងរណាស់ ។ ចំណែកម៉ូតូពិតមែនមិនប្រកាន់ចំណីផ្លូវ តែម៉ូតូនៅពីមុខឡាន ហើយជាសត្វានុម័តសភាពផ្លូវសព្វថ្ងៃនៅម្តុំចាក់អង្រែ ក្រោមមានគ្រលុកចំ១ ពិបាកបើកបរ ហើយម្នាក់ៗជិះតែលើចំណីផ្លូវដែលល្អ តែវាក៏ជាកំហុសខ្លះដែរ ។ បញ្ហាដែលជាកំហុសធ្ងន់ធ្ងរគឺប្រជែងម៉ូតូខាងស្តាំ បណ្តាលឱ្យស្លាប់ និងរបួសនារីជិះម៉ូតូ ។ ចំណុចមួយដែលតុលាការថ្នាក់ក្រោមយកមាត្រា ៤0 អំពើមនុស្សឃាដដោយអចេតនាមកប្រើនោះ ព្រោះថា ច្បាប់ចរាចរជើងគោកមាត្រា ៦0 មានន័យច្បាស់លាស់ថា "ចេតនា" តែដោយចៅ ក្រមតុលាការថ្នាក់ក្រោមយល់ឃើញថា "ធ្វេសប្រហែសនោះ"ហើយតាមគោលការណ៍ជានីត្យានុកូលភាព ចៅក្រមត្រូវតែអនុវត្តតាមន័យនៅក្នុងច្បាប់ជាធរមាន មកផ្តន្ទាទោសជនល្មើសនោះ ទើបតម្រូវឱ្យចៅក្រមយកមាត្រា ៤0 នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលមកអនុវត្តវិញ ហើយម៉្យាងវិញទៀត ការបង្កើត

Scanned with CamScanner

យុត្តិសាស្ត្រជាអំណាចរបស់តុលាការកំពូល ចៅក្រមថ្នាក់ក្រោមគ្រាន់តែមានសិទ្ធិបកស្រាយរកន័យពិតនៃមាត្រាច្បាប់ ដែលមិនច្បាស់លាស់តែប៉ុណ្ណោះ តែមាត្រា ៦០ នៃ ច្បាប់ចរាចរជើងគោកមានន័យច្បាស់លាស់ហើយ "ដោយចេតនា" គឺមិនអាចអនុវត្តបានក្នុងរឿងនេះទេ ។ ចំណុចមួយទៀតគ្មានច្បាប់ណា កំណត់ពីតម្លៃនៃជីវិតមនុស្សទេ បើរបួសស្នាម ឬការអន្តរាយនានាទើបវាយតម្លៃបាន ។ ដូចនេះការសម្រេចថា : សងប៉ុន្មាននោះ ជាសិទ្ធិអំណាចសម្រេចដោយអធិបតេយ្យរបស់ចៅក្រម ហើយថាសងច្រើន ឬតិចនោះ គិតពុំបានឡើយ ព្រោះជីវិតមនុស្សមិនមែនជាវត្ថុពាណិជ្ជកម្មគតិយុត្តទេ ។ អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិចារណាតាមច្បាប់ ។

សេចក្តីសម្រេចរបស់តុលាការកំពូលលើកទី ១

បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ១៨ ចុះថ្ងៃទី ០៤-១០-១៩៩៦ របស់តុលាការកំពូល ដែលបានសម្រេច :

វិនិច្ឆ័យសេចក្តីចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី

១. ទទួលបណ្តឹងសាទុក្ខលេខ ១៨៧ ចុះថ្ងៃទី ២២-០៤-១៩៩៦ របស់លោក ចុង អ៊ឹវហេង មេធាវីឱ្យជនជាប់ចោទទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២. ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ ២៣ ចុះថ្ងៃទី២៩-០៣-១៩៩៦ របស់សាលាឧទ្ធរណ៍ ទាំងមូល ។

៣. បង្ហិលសំណុំរឿងព្រហ្មទណ្ឌលេខ ១២ ចុះថ្ងៃទី ២៧-០៦-១៩៩៦ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជម្រះជាថ្មីឡើងវិញ ។

៤. សាលដីកានេះប្រកាសសវនាការជាសាធារណៈ នៅថ្ងៃទី ០៤-១០-១៩៩៦ ។

សេចក្តីសន្និដ្ឋានរបស់អគ្គព្រះរាជអាជ្ញា

បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ "លើកទី ២"ថា : រឿងនេះតុលាការកំពូលបានលើកមាត្រា ៦០ ច្បាប់ចរាចរផ្លូវគោក មកកំណត់ទោសលើឈ្មោះ គ្បៀន ប៉ាវ តែខ្ញុំមហាអយ្យការថា បើយកមាត្រា ៦០ នេះមកកំណត់ទោស គឺមិនត្រឹមត្រូវទេ ព្រោះ ច្បាប់ចរាចរចេញមុន ច្បាប់ព្រហ្មទណ្ឌអន្តរកាលចេញក្រោយ ។ បើនិយាយពីកំហុសគឺអ្នកជិះម៉ូតូមានកំហុសដែរ ឯថាអ្នកណាជែងអ្នកណា គឺគ្មានលក្ខណៈច្បាស់លាស់ ដូច្នេះអំពីសំណងគួរលៃ យ៉ាងណា ដោយពិចារណាអំពីកំហុសរបស់ជនរងគ្រោះផងដែរ ។

សេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍លើកទី ២

បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ៤៩ ចុះថ្ងៃទី ០៣-០៣-១៩៩៧ របស់សាលាឧទ្ធរណ៍ "លើក ទី ២" ដែលបានសម្រេច :

១. ទទួលជំនុំជម្រះរឿងនេះឡើងវិញ ដោយអំណាចសាលដីកាតុលាកាកំពូលលេខ ១៨ ចុះថ្ងៃ ទី ០៤-១០-១៩៩៦ ។

២. បដិសេធសាលក្រព្រហ្មទណ្ឌលេខ ១៣៧ "ក" ចុះថ្ងៃទី ២៧-១១-១៩៩៥ របស់តុលាការ

Scanned with CamScanner

ក្រុងភ្នំពេញចោល ហើយសម្រេចជាថ្មីថា :

ក.សម្រេចផ្តន្ទាទៅដាក់ពន្ធនាគារឈ្មោះ គ្បៀន ប៉ាវ កំណត់ ០៦ ខែ តែទោសនេះត្រូវព្យួរដោយដាក់ឱ្យសាកល្បងកំណត ០៥ ឆ្នាំ គិតពីថ្ងៃកាត់សេចក្តី ពីបទធ្វើមនុស្សឃាដដោយចេតនា និងបង្ក របួសស្នាមដោយអចេតនា ប្រព្រឹត្តនៅទីក្រុងភ្នំពេញ កាលពីថ្ងៃទី ០២-០៩-១៩៩៥ តាមបញ្ញត្តិមាត្រា ៥៦ និង៦០ ច្បាប់ចរាចរជើងគោក និងមាត្រា ៦៨ និង ៧០ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

ខ. ឱ្យឈ្មោះ ឡៅវ ប៊ុនខេង ជាអ្នកទទួលខុសត្រូវខាងបទរដ្ឋប្បវេណីសងជូសឈ្មោះ គ្បៀន ប៉ាវ នូវ សោហ៊ុយបង់ខាងជម្ងឺចិត្តចំនួន ២ ម៉ឺន ដុល្លាអាមេរិក ឱ្យទៅឈ្មោះ ហ៊ុយ វ៉ា ប្រពន្ធឈ្មោះ យីម នាង ដែលជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវជាឪពុកម្តាយជនរងគ្រោះឈ្មោះ វ៉ា លី ។

គ. ឱ្យឈ្មោះ ឡៅវ ប៊ុនខេង សងសោហ៊ុយបង់ខាងជម្ងឺចិត្តចំនួន ១000 ដុល្លាអាមេរិក និងសំណង ជូសជុលម៉ូតូឆាលីចំនួន ៣00 ដុល្លាអាមេរិក ឱ្យទៅឈ្មោះ សេង រចនា ប្រពន្ធឈ្មោះ អ៊ឹម ហៀង ដែលជាឪពុកម្តាយនាង អ៊ី សោភ័ណ ដោយប្រគល់ម៉ូតូឆាលីឱ្យនាង អ៊ី សោភ័ណ វិញ។

ក្នុងករណីរឹងរូសពុំព្រមសង ត្រូវរឹបអូសទ្រព្យសម្បត្តិរបស់ឈ្មោះ ឡៅវ ប៊ុនខេង លក់ឡាយឡុងដើម្បីធានាសំណង ។

៣. សាលដីកានេះជំនុំជម្រះនាសវនាការថ្ងៃទី ២៨-០២-១៩៩៧ និងប្រកាសនៅថ្ងៃទី ០៣-០៣-១៩៩៧ ចំពោះមុខជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវបទរដ្ឋប្បវេណី ។ បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញ បណ្តឹងសាទុក្ខ "លើកទី ២" លេខ ១៣៤ ចុះថ្ងៃទី ២៤-០៤-១៩៩៧ របស់ឈ្មោះ ឡៅវ ប៊ុនខេង ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌ "លើកទី ២" លេខ ៤៩ ចុះថ្ងៃទី ០៣-០៣-១៩៩៧ របស់សាលាឧទ្ធរណ៍ លើសេចក្តីសម្រេចទាំងមូល ។

សារណា "បណ្តឹងសាទុក្ខ លើកទី ២"

បានឃើញសារណាចុះថ្ងៃទី ១៣-០៨-១៩៩៧ របស់ឈ្មោះ ឡៅវ ប៊ុនខេង ជាម្ចាស់បណ្តឹងសាទុក្ខ ធ្វើឡើងហួសកំណត់ច្បាប់ ។

បានស្តាប់វេបាយការណ៍របស់ចៅក្រមវេបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា :

-មានពិរុទ្ធគ្រប់គ្រាន់លើឈ្មោះ គ្បៀន ប៉ាវ ពីបទមនុស្សឃាដ និងបង្កវបួសស្នាមដោយអចេត នាបណ្តាលមកពីគ្រោះថ្នាក់ចរាចរ ប្រព្រឹត្តនៅលើផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែ ខណ្ឌ មានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០២-០៩-១៩៩៥ ពិតប្រាកដមែន ។

- តាងនាមអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល សូមធ្វើសេចក្តីសន្និដ្ឋានជូនក្រុមប្រឹក្សា

Scanned with CamScanner

១.បណ្តឹងសាទុក្ខរបស់ឈ្មោះ ឡៅវ ប៊ុនខេង ស្ថិតនៅក្នុងកំណត់ច្បាប់ គប្បីលើកយករឿងនេះមកពិនិត្យពិចារណា ។

២. តម្កល់សាលដីព្រហ្មទណ្ឌលេខ ៤៩ ចុះថ្ងៃទី ០៣-០៣-១៩៩៧ របស់សាលាឧទ្ធរណ៍លើកទី ២ ទុកជាបានការពេញទាំងមូល ។

បានស្តាប់ចម្លើយដោះសាររបស់លោក ហ៊ុយ វ៉ា ជា "ចុងបណ្តឹងសាទុក្ខ" នៅពេលជំនុំជម្រះ ថាៈបើតាមសំណង សាលាឧទ្ធរណ៍សម្រេចមកនេះវាមិនស្មើនឹងជីវិតទេ សំណងប៉ុន្មានវាក៏មិនស្មើជីវិតកូនស្រីខ្ញុំបាទដែរ ។

បានស្តាប់ចម្លើយដោះសាររបស់លោក សេង រចនា ជា "ចុងបណ្តឹងសាទុក្ខ" នៅពេលជំនុំជម្រះ ថា : ខ្ញុំបាទគ្មានមតិអ្វីបន្ថែមទេ ។

ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់ចម្លើយដោះសារ របស់លោក ឡៅវ ប៊ុនខេង អ្នកទទួលខុសត្រូវសំណងរដ្ឋប្បវេណី លោក ហ៊ុយ វ៉ា "ដើមបណ្តឹងរដ្ឋប្បវេណី និងលោក សេង រចនា ដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

សេចក្តីសម្រេចរបស់តុលាការកំពូលលើកទី២

យល់ឃើញថា បណ្តឹងសាទុក្ខជាលើកទី ២ លេខ ១៣៤ ចុះថ្ងៃទី ២៤-០៤-១៩៩៧ របស់អ្នកទទួលខុសត្រូវសំណងរដ្ឋប្បវេណី ឈ្មោះ ឡៅវ ប៊ុនខេង ដែលប្តឹងអំពីសេចក្តីសម្រេចទាំងមូលនៃសាលដីកាព្រហ្មទណ្ឌលេខ ៤៩ ចុះថ្ងៃទី ០៣-០៣-១៩៩៧ របស់សាលាឧទ្ធរណ៍ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចទទួលរឿងនេះមកជំនុំជម្រះរួមក្រុមដល់អង្គសេចក្តីបាន តាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី និងតាមមាត្រា ២២៦ នៃ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

យល់ឃើញថា មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ឡៀន ប៉ាវ ពីបទបើកបរបណ្តាលឱ្យមានគ្រោះថ្នាក់ដល់ស្លាប់អ្នកដទៃ ដោយអចេតនា និងធ្វើឱ្យអ្នកដទៃមានរបួសស្នាម ដោយខ្វះការប្រុងប្រយ័ត្ន ប្រព្រឹត្តនៅទីក្រុងភ្នំពេញ កាលពីថ្ងៃទី ០២-០៩-១៩៩៥ ។ បទល្មើសដែលមានចែង និងដាក់ទោសតាមបញ្ញត្តិមាត្រា ៦០ និង ៥៦ នៃច្បាប់ចរាចរជើងគោក ។

យល់ឃើញថា សាលាឧទ្ធរណ៍បានកំណត់បទល្មើសត្រឹមត្រូវហើយ ដោយលើកយកមាត្រា ៥៦ និង ៦០ នៃច្បាប់ចរាចរជើងគោកមកអនុវត្ត ។ ក៏ប៉ុន្តែមាត្រា ៦០ នៃច្បាប់នេះមានការភ័ន្តច្រឡំ ក្នុងការប្រើពាក្យ "ចេតនា" ដែលជាសត្យានុម័តគ្រោះថ្នាក់ចរាចរបណ្តាលឱ្យអ្នកដទៃស្លាប់ គឺជាមនុស្សឃាដដោយ "អចេតនា" ពុំមែនជាបទមនុស្សឃាដដោយ "ចេតនា" ឡើយ ។

Scanned with CamScanner

ដូច្នេះ តុលាការកំពូលគប្បីកំណត់ពាក្យ "ចេតនា" ក្នុងមាត្រា ៦០ នៃច្បាប់ចរាចរជើងគោកថា ជា"អចេតនា"វិញ ហើយលើកយកបញ្ហានេះដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីពិនិត្យ និងសម្រេច ក្នុងពេលអនាគតតាមមាត្រា ១២២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

យល់ឃើញថាគ្រោះថ្នាក់ចរាចរនេះពិតជាកើតមានឡើងដោយការបំពានទៅលើបទបញ្ជាចរាចរ របស់ជនជាប់ ចោទ ឈ្មោះ គ្បៀន ប៉ាវ ដែលមានអ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណីឈ្មោះ ឡៅ វ ប៊ុនខេង និងរបស់ជនរងគ្រោះ ។

យល់ឃើញថា

សាលាឧទ្ធរណ៍បានសម្រេចអំពីសំណងរដ្ឋប្បវេណីដោយពំបានពិចារណាអំពីកំហុសឆ្គងរបស់ជនរង គ្រោះ ដែលបានបំពានផងដែរ ទៅលើបទបញ្ជាចរាចរ ក៏ប៉ុន្តែក្នុងសាលដីកាព្រហ្ម ទណ្ឌលេខ ៤៩ ចុះថ្ងៃទី ០៣-០៣-១៩៩៧ សាលាឧទ្ធរណ៍បានយល់ឃើញថា អំពីការរួបរួមគ្នាទទួលខុសត្រូវ អំពីគ្រោះថ្នាក់នេះ ហើយបានបន្ថយសំណងរដ្ឋប្បវេណី ស្របតាមការយល់ឃើញរបស់តុលាការ កំពូលរួចហើយដែរ ប៉ុន្តែការបន្ថយនេះ នៅមានចំនួនតិចនៅឡើយ ។

យល់ឃើញថា ម្ចាស់បណ្តឹងសាទុក្ខបានធ្វើសារណាការពារក្តីរបស់ខ្លួនជូនមកតុលាការកំពូល ហួសរយៈពេលកំណត់តាមផ្លូវច្បាប់ ។

យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៤៩ ចុះថ្ងៃទី ០៣-០៣-១៩៩ របស់សាលាឧទ្ធរណ៍ ដែលសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវហើយ លើកលែងចំណុច "ក" និង"ខ" នៃ ចំណុចទី ២ ដែលគប្បីធ្វើការសម្រេចជាថ្មី ។

សេចក្តីសម្រេច លើកទី២របស់ តុលាការកំពូល

<u>ហេតុដូច្នេះ</u>

<u>វិនិច្ឆ័យសេចក្តីចំពោះមុខតួក្តី</u>

១.ទទួលបណ្តឹងសាទុក្ខលេខ ១៣៤ ចុះថ្ងៃទី ២៤-០៤-១៩៩៧ របស់អ្នកទទួលខុសត្រូវរដ្ឋប្បវេ ណីឈ្មោះ ឡៅ វ ប៊ុនខេង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិ ច្បាប់ខ្លះ ។

២. តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៤៩ ចុះថ្ងៃទី ០៣-០៣-១៩៩៧ របស់សាលាឧទ្ធរណ៍ទុកជា បានការដោយកែតម្រូវចំណុច "ក" និង"ខ" នៃចំណុចទី ២ ទៅជា :

"ក.សម្រេចផ្តន្ទាទោសដាក់ពន្ធនាគារឈ្មោះ គ្បៀន ប៉ាវ កំណត់មួយឆ្នាំ ប៉ុន្តែទោសនេះត្រូវព្យួរ ដោយមានរយៈពេលសាកល្បងកំណត់ ០៥ ឆ្នាំ គិតពីថ្ងៃប្រកាសសាលដីកានេះពីបទធ្វើមនុស្ស ឃាដដោយអចេតនា និងបង្ករបួសស្នាមដោយអចេតនា ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ០២-០៩-១៩៩៥ តាមបញ្ញត្តិមាត្រា ៥៦ និង ៦០ ច្បាប់ចរាចរជើងគោក និងមាត្រា ៦៨-៧០ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

Scanned with CamScanner

"ខ. ឱ្យឈ្មោះ ឡៅវ ប៊ុនខេង ជាអ្នកទទួលខុសត្រូវសងជូនឈ្មោះ គ្បែន ប៉ាវ នូវសោហ៊ុយបង់ខាតជម្ងឺចិត្តចំនួន ១៥ ០០០ ដុល្លាអាមេរិក ឱ្យទៅឈ្មោះ ហ៊ុ វ៉ា ប្រពន្ធឈ្មោះ យឹម នាង ដែលជើមបណ្តឹងរដ្ឋប្បវេណី ត្រូវជាឪពុកម្តាយជនរងគ្រោះឈ្មោះ វ៉ា លី ។ ចំណុចក្រៅពីនេះរក្សាទុកនៅដដែល ។

៣. សាលដីកានេះប្រកាសសវនាការជាសាធារណៈ នៅថ្ងៃទី ១៩-០៩-១៩៩៧ ។

១. ការគាំទ្រនូវសលាកប័ត្រនៃសេចក្តីសម្រេចរបស់តុលាការ

សលាកប័ត្រសាលដីកា គឺជាការសង្ខេបសេចក្តីសំរេចរបស់ឃុត្តាធិការមួយ ។ កិច្ចការនេះត្រូវរក្សាទុកនូវចនាសម្ព័ន្ធទូទៅ មានន័យថា កិច្ចការនេះត្រូវគោរពនូវតាមលំដាប់នៃនីតិវិធី ។

១. អង្គហេតុ

ដំណាក់កាលទីមួយត្រូវសង្ខេបនូវអង្គហេតុ ដោយមិនត្រូវចម្លងឃ្លានៅក្នុងសេចក្តីសម្រេចនោះ ដើម្បីឱ្យអ្នកអានងាយយល់អំពីកម្មវត្ថុនៃវិវាទ ។ អ្នកត្រូវមានការប្រុងប្រយ័ត្ន ព្រោះមានសេចក្តីសម្រេចភាគច្រើន អង្គហេតុទាំងអស់ដែលលើកឡើងដោយភាគី ត្រូវបានលើកឡើងជាច្រំដែលជាថ្មីម្តងទៀត ។ អ្នកយកតែអង្គហេតុទាំងឡាយណាដែលត្រូវបានចាត់ទុកជាអង្គហេតុត្រឹមត្រូវ ដោយចៅក្រមខាងអង្គហេតុតែប៉ុណ្ណោះ ។ ចំណែកអង្គហេតុសំខាន់ អ្នកត្រូវលើកឡើងតាមលំដាប់លំដោយ ។ អ្នកក៏ត្រូវកំណត់ចរិតលក្ខណៈគតិយុត្តនៃអង្គហេតុទាំងនោះផងដែរ ។ ឧទាហរណ៍ : សាលដីកាបញ្ជាក់ថា លោក តាន់ បានលក់ទូរស័ព្ទចល័តមួយគ្រឿងជាមួយអ្នកស្រី តូ ។ ឈ្មោះ របស់តូភាគីមានសារសំខាន់តិចតួច ដោយហេតុថា វាគ្មានអ្វីបំភ្លឺបន្ថែមនោះទេ ។ វាជាការគួរក្នុងការកំណត់ចរិតលក្ខណៈរបស់លោក តាន់ គឺជាអ្នកលក់ ចំណែកអ្នកស្រី តូ គឺជាអ្នកទិញ ។

២. នីតិវិធី

ក្នុងដំណាក់កាលទី ២ នេះ យើងត្រូវលើកឡើងនូវាល់ចាតុផ្សំនៃនីតិវិធី និងត្រូវប្រើប្រាស់វា ដោយគោរពតាមលំដាប់នីមួយៗ ។ ដំណាក់នេះចាប់ផ្តើមដោយការដាក់ពាក្យបណ្តឹង និងបញ្ចប់នីតិវិធីមុនពេលចេញសេចក្តីសម្រេចដែលជាកម្មវត្ថុនៃការវិភាគ ។ ដូច្នេះ ប្រសិនបើអ្នកទាំងអស់គ្នាធ្វើសលាកប័ត្រសាលដីការបស់សាលាឧទ្ធរណ៍ ការបកស្រាយរបស់អ្នកត្រូវបញ្ចប់ បន្ទាប់ពីបានបង្ហាញនូវអំណះអំណាង ដែលត្រូវបានលើកឡើងដោយដើមបណ្តឹងឧទ្ធរណ៍ និងការការពារដោយចុងបណ្តឹងឧទ្ធរណ៍ ។ បើសិនជាសាលដីការបស់តុលាការកំពូល នីតិវិធីនឹងត្រូវបញ្ចប់ បន្ទាប់ពីមានការលើកឡើងនូវអំណះអំណាងរបស់ភាគីនៅតុលាការកំពូល ។

- យើងត្រូវចាប់ផ្តើម ដោយការបង្ហាញអំពីការដាក់ពាក្យណ្តឹង ។ អ្នកទាំងអស់គ្នាត្រូវព្យាយាមឆ្លើយនូវ ៥ សំណួរ " បើសិនជាចម្លើយស្ថិតនៅក្នុងសេចក្តីសម្រេចរបស់តុលាការដែលជាកម្មវត្ថុនៃការវិភាគ " : អ្នកណាជាដើមចោទ ?អ្នកណាជាចុងចម្លើយ ? យុត្តាធិការណាទទួលពាក្យបណ្តឹង ? ប្រភេទនៃពាក្យបណ្តឹង ? មូលដ្ឋានគតិយុត្តនៃពាក្យបណ្តឹង ?

Scanned with CamScanner

ដើម្បីឆ្លើយតបនឹងសំណួរទាំងនោះ ដោយច្បាស់រាងនូវការតាក់តែងឃ្លាវែងអន្លាយ អ្នកទាំងអស់គ្នាអាចជ្រើសរើសនូវឃ្លាគំរូមួយ ដូចជា : "ក" ដើមចោទប្តឹងលោក "ខ" ចុងចម្លើយ នៅចំពោះមុខតុលាការក្រុងភ្នំពេញ ដើម្បីប្រកាសមោយភាពកិច្ចសន្យាលក់ ដោយមូលហេតុភ័ន្តច្រឡំ ឈរលើមូលដ្ឋាននៃមាត្រា ៨ នៃក្រឹត្យ-ច្បាប់លេខ ៣៨ ចុះថ្ងៃទី ២៨-១០-១៩៨៨ ។

- សេចក្តីសម្រេចរបស់តុលាការថ្នាក់ទី ១ ត្រូវបានលើកឡើង ដោយបង្ហាញជាដំបូងអំពីផ្នែកសេចក្តីសម្រេច មានន័យថា តើតុលាការថ្នាក់ទី ១ ទទួលពាក្យបណ្តឹងចាត់ទុកថាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ឬក៏មិនត្រឹមត្រូវ បន្ទាប់មកគឺសំអាងហេតុ ។ ឃ្លាគំរូ : តុលាការថ្នាក់ទី ១ បានបដិសេធពាក្យបណ្តឹង ដោយសំអាងហេតុថា...ឬ ផ្ទុយមកវិញ តុលាការទទួលពាក្យបណ្តឹងចាត់ទុក ថាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ដោយសំអាងហេតុថា ..... ។

- បន្ទាប់មក ត្រូវលើកឡើងអំពីបណ្តឹងឧទ្ធរណ៍ ដែលត្រូវបានធ្វើឡើងដោយដើមបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងចុងបណ្តឹងឧទ្ធរណ៍ ។ អំណះអំណាងរបស់គូភាគីត្រូវលើកឡើងផងដែរ បើសិនជាយើងស្គាល់ ។

- សេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ ត្រូវបានលើកឡើងនៅក្នុងផ្នែកសេចក្តីសម្រេច : សាលាឧទ្ធរណ៍ បានបដិសេធឬតម្កល់សាលក្រមរបស់តុលាការថ្នាក់ក្រោម និងសំអាងហេតុ: ប្រសិនបើសាលាឧទ្ធរណ៍ ថែរក្សានូវសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោម ដោយសំអាងហេតុថាសាលាឧទ្ធរណ៍តម្កល់សាលក្រម ប៉ុន្តែ បើមិនដូច្នោះទេ សាលាឧទ្ធរណ៍បដិសេធសាលក្រម ដោយសំអាងហេតុថា..... ។

- ចុងបញ្ចប់ ប្រសិនបើមានបណ្តឹងសាទុក្ខ យើងត្រូវបញ្ជាក់អំណះអំណាងនៃបណ្តឹងសាទុក្ខ ។ លោក ឬអ្នកស្រី "ក" បានប្តឹងសាទុក្ខប្រឆាំងនឹងលោក ឬ អ្នកស្រី "ខ" ។ គាត់ត្រូវបង្ហាញនូវអំណះអំណាង "ចំនួន" របស់ខ្លួន និងត្រូវបកស្រាយផងដែរ ។

៣. បញ្ហាគតិយុត្ត "អាចមានមួយ ឬច្រើន"

ដំណាក់កាលនេះមានភាពលំបាកច្រើនជាងដំណាក់កាលមុនៗក្នុងការតាក់តែងសលាកប័ត្រសេចក្តីសម្រេចរបស់តុលាការ តែដំណាក់កាលនេះជាចំណុចកណ្តាលមួយ ។ ចំណោទបញ្ហាត្រូវតាក់តែងក្រោមទម្រង់ជាសំណួរ ដែលយើងអាចឆ្លើយបានតាមចម្លើយស្រប ឬចម្លើយផ្ទុយ ។ ប្រសិនបើសំណួរនេះត្រូវបានលើកឡើងនៅតុលាការកំពូល វាត្រូវបានបង្កើតឡើងរវាងសំអាងហេតុនៃសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ និងអំណះអំណាងរបស់គូភាគីបណ្តឹងសាទុក្ខ ។ បើសិនជាសេចក្តីសម្រេចត្រូវបានចេញដោយសាលាឧទ្ធរណ៍ សំណួរអាចត្រូវបានបង្កើតឡើងរវាងមូលហេតុនៃសេចក្តីសម្រេចរបស់តុលាការថ្នាក់ទី ១ និងអំណះអំណាងរបស់គូភាគីបណ្តឹងឧទ្ធរណ៍ ។ សំណួរពុំត្រូវមានលក្ខណៈទូទៅពេកនោះទេ ប៉ុន្តែ ត្រូវតម្រង់ឱ្យបានច្បាស់លាស់អំពីបញ្ហាគតិយុត្ត ។ យើងត្រូវមានសមត្ថភាពយល់ដឹងសំណួរ ដោយមិនចាំបាច់ស្គាល់អំពីសាលដីកា និងអង្គហេតុនោះទេ ។ ដើម្បីផ្ទៀងផ្ទាត់ថាតើសំណួរគតិយុត្តដែលត្រូវបានចោទឡើងត្រឹមត្រូវដែរឬទេ អ្នកអាចពិនិត្យមើលទៅលើសេចក្តីសម្រេចរបស់តុលាការដែលជាកម្មវត្ថុនៃការវិភាគនេះ វាឆ្លើយតបនឹងចំណោទបញ្ហានោះ ។ ក្នុងករណីគ្មានភាពរលូន យើងត្រូវចាប់ផ្តើមពិចារណាសាជាថ្មីអំពីចំណោទបញ្ហារបស់យើង ។ ចំណោទបញ្ហា

Scanned with CamScanner

ត្រូវបង្កើតឡើងដោយមានលក្ខណៈអរូបី "ឈ្មោះរបស់គូភាគី និងធាតុផ្សំក្រៅពីអង្គហេតុផ្សេងទៀត មិនត្រូវលេចឡើងនោះទេ" ប៉ុន្តែ ពុំត្រូវមានលក្ខណៈទូទៅពេកនោះទេ "ត្រូវចង្អុលបង្ហាញឱ្យបានច្បាស់អំពីសំណួរគតិយុត្ត" ។

៤. សេចក្តីសម្រេចរបស់ឃុត្តាធិការដែលឧទ្ធរណាក្បែបណ្តឹង

សេចក្តីសម្រេចនេះត្រូវតែបង្ហាញឡើងក្នុងផ្នែកសេចក្តីសម្រេច និងសំអាងហេតុរបស់វា ។ យើងមិនត្រឹមតែឆ្លើយមែន ឬមិនមែន ទៅនឹងសំណួរដែលចោទសួរនោះទេ ។ បើសិនជាសាលដីកាចេញដោយតុលាការកំពូល យើងត្រូវតែនិយាយថា តើតុលាការកំពូលបដិសេធសាលដីកាសាលាឧទ្ធរណ៍"ក្នុងសម្មតិកម្មនេះ យើងនិយាយថាជាសាលដីកាបដិសេធ" ឬបដិសេធបណ្តឹងសាទុក្ខ "យើងនិយាយថា ជាសាលដីកាតម្កល់" និងសំអាងហេតុរបស់វា ។

បន្ទាប់ពីបានបង្ហាញអំពីទ្រឹស្តីនៃវិធីសាស្ត្រ យើងអាចយល់ច្បាស់អំពីវិធីសាស្ត្រនេះ ក្រោយពីបានអនុវត្តនូវលំហាត់ជាច្រើនដូចខាងក្រោមនេះ ។

កថាខណ្ឌទី ២ : លំហាត់អនុវត្តធ្វើសលាកប័ត្រ

គោលបំណងនៃលំហាត់អនុវត្តធ្វើសលាកប័ត្រ គឺអនុញ្ញាតឱ្យនិស្សិត ឬបេក្ខជនប្រឡងអាចហ្វឹកហាត់ដោយខ្លួនឯង ។ យើងផ្តល់យោបល់ចំពោះអ្នកថា ត្រូវព្យាយាមតាក់តែងដោយខ្លួនឯងនូវសលាកប័ត្រនៃសាលដីកានីមួយៗជាបន្តបន្ទាប់ រួចហើយយើងគ្រាន់តែពិនិត្យមើលលើកំណែដែលត្រូវបានលើកឡើងប៉ុណ្ណោះ ។ អ្នកកុំរារែកក្នុងការធ្វើសាជាថ្មីឡើងវិញជាច្រើនដងនូវលំហាត់ទាំងនេះ រហូតដល់ពេលដែលអ្នកទាំងអស់គ្នាអាចធ្វើសលាកប័ត្រទាំងមូលដោយខ្លួនឯងបាន ។

ក. និតិវិធីបឋមតេណី

រៀបចំសលាកប័ត្រសាលដីកា ដែលចេញដោយតុលាការកំពូល ចុះថ្ងៃទី ២៥-០៩-១៩៩៧ ។

១. សាលដីកា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី

លេខ ២៤៩

ចុះថ្ងៃទី ២០-០៨-១៩៩៧

សាលដីកា

លេខ ១៧៤ ចុះថ្ងៃទី ២៥-០៩-១៩៩៧

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី ២៥-០៩-១៩៩៧ ដោយមាន សមាសភាពដូចតទៅ :

Scanned with CamScanner

១. ឯកឧត្តម ចាន់ សុក	ប្រធាន
២. លោក ប៉ែន ស៊ុន	ចៅក្រម
៣. លោក វៀល មូន	ចៅក្រម
៤. លោក ស៊ុន ឌីម	ចៅក្រម
៥. លោក ជីវ កេង	ចៅក្រម

ក្រឡាបញ្ជី

លោក ឡេង វុធ

តំណាងមហាអយ្យការ

លោក ជួន ស៊ុនឡេង ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ ៤១៣ ចុះថ្ងៃទី ០៥-០៨-១៩៩៧ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៣៤៥ ចុះថ្ងៃទី ០៣-០៦-១៩៩៧ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ កង ហាក់ ភេទ ប្រុស អាយុ ៦៤ ឆ្នាំ សញ្ជាតិ កម្ពុជា របររកស៊ី ជវា ទីលំនៅសព្វថ្ងៃ ផ្ទះលេខ ៦៣ អឺ០ហ្សេត ផ្លូវលេខ ១៣៦ សង្កាត់ផ្សារថ្មី ២ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ឪពុកឈ្មោះ កង លី "ស" ម្តាយឈ្មោះ លាក ជន "ស" ។

និង ចុងចម្លើយបណ្តឹងសាទុក្ខឈ្មោះ កង ហ៊ុន ភេទ ស្រី អាយុ ៣៣ ឆ្នាំ សញ្ជាតិ កម្ពុជា របររកស៊ី នៅផ្ទះ ទីលំនៅសព្វថ្ងៃ ភូមិត្រីរលេខ ១៨៨ ក្រុម ៦៣ ផ្លូវលេខ ៥១ សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន ក្រុងភ្នំពេញ ឪពុក ឈ្មោះ កង ហាក់ "រ" ម្តាយឈ្មោះ ម៉ែង សាមួយ "ស" ប្តី ឈ្មោះ ឈូរ ហាងថែង ។

តាមបណ្តឹងសាទុក្ខលេខ ២៨០ ចុះថ្ងៃទី ០៧-០៨-១៩៩៧ របស់លោក កង ហាក់ បានប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២៤៩ ចុះថ្ងៃទី ២០-០៨-១៩៩៧ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ០៩-១២-១៩៩៦ របស់លោក កង ហាក់ ជាដើមចោទថា : នៅឆ្នាំ ១៩៨៩ ខ្លួនបានទិញដីឡូត៍ និងសាងសង់ផ្ទះលេខ ១៨៨ ឱ្យប្រពន្ធខ្លួនស្នាក់នៅ ។ ដល់ឆ្នាំ ១៩៩២ ខ្លួនបានទៅរកស៊ីនៅវៀតណាម ឈ្មោះ កង ហ៊ុន ត្រូវជាកូនចិញ្ចឹមខ្លួនបានបញ្ជាឱ្យប្រពន្ធខ្លួនផ្តិតមេដៃលើកិច្ចសន្យាមួយដោយឈ្មោះនេះប្រាប់ថាជាកិច្ចសន្យាជួល តែការពិតជាកិច្ចសន្យាប្រគល់សិទ្ធិ ហើយបានផ្ទេរកម្មសិទ្ធិទៀត ។ ម៉្យាងទៀត ឈ្មោះ កង ហ៊ុន បានគ្រប់គ្រងត្បូងពេជ្រមួយចំនួនធំ ដែលប្រពន្ធខ្លួនផ្ញើទុក ខ្លួនទាមទារយកវិញទុកចែកកូនៗ ។

បានឃើញសាលក្រមលេខ ២៨"ក" ចុះថ្ងៃទី ២៦-០៣-១៩៩៧ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១. ទទួលពាក្យបណ្តឹងចុះថ្ងៃទី ០៩-១២-១៩៩៦ របស់ដើមចោទឈ្មោះ កង ហាក់ ទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ ។

Scanned with CamScanner

២. ទទួលស្គាល់ថា កង ហាក់ និងនារី ម៉ែង សាមួយ ជាប្តីប្រពន្ធគ្នា មិនបានលែងលះតាមផ្លូវតុលាការឡើយ ហើយជាម្ចាស់កម្មសិទ្ធិករលើភូមិគ្រឹះលេខ ១៨៨ ផ្លូវលេខ ៥១ ក្រុម ៦៣ សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន ក្រុងភ្នំពេញ ។

៣. បដិសេធវិញ្ញាបនប័ត្រសំគាល់អចលនវត្ថុលេខ ៥.៨៨៧ ចុះថ្ងៃទី ២៩-១១-១៩៩១ ចោលជាអសារបង់ គិតចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរ ។

៤. បង្គាប់ឱ្យនារី កង ហ៊ុន និង ឈួរ ហាងថេង ចុះចេញពីភូមិគ្រឹះលេខ ១៨៨ ផ្លូលេខ ៥១ ក្រុម ៦៣ សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន ក្រុងភ្នំពេញ គិតចាប់តាំងពីសាលក្រមចូលស្ថាពរ ។

៥. ប្រគល់ភូមិគ្រឹះលេខ ១៨៨ ផ្លូវលេខ ៥១ ក្រុម ៦៣ សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន ក្រុងភ្នំពេញ ឱ្យទៅឈ្មោះ កង ហាក់ ថែរក្សា គ្រប់គ្រង និងកាន់កាប់ ចាប់តាំងពីសាលក្រមស្ថាពរ តាមមាត្រា ៣៧ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ។

៦. បង្គាប់ឱ្យនារី កង ហ៊ុន ប្រគល់គ្រឿងអលង្កានូវ : បង្គោងខ្សែកពីមានដាំត្បូងពេជ្រ, ខ្សែដៃពីរខ្សែ "មួយខ្សែដាំពេជ្រ មួយខ្សែទៀតដាំត្បូងខ្សែវ និង ចិញ្ចៀនត្បូងក្រហមមួយវង់ "ឱ្យទៅឈ្មោះ កង ហាក់ ។

៧. បង្គាប់ឱ្យនារី កង ហ៊ុន និងឈួរ ហាងថេង រួមគ្នាបង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង ១ ៨០០ រៀល, រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០ រៀល, រង្វាន់សាក្សី ២០០០ រៀល និងរង្វាន់អ្នកប្រគល់ដីការកោះ ៣០០០ រៀល បូករួម ៧ ០០០រៀល ប្រាក់នេះបានកាត់យកពីប្រាក់ ៧ ០០០ រៀល ដែលដើមចោទបានបង់ទុកជាស្រេច ។ កាលបើហួសកំណត់ប្តឹងឧទ្ធរណ៍ បង្គាប់ឱ្យនារី កង ហ៊ុន និងឈួ, ហាងថេង សងប្រាក់ ៧ ០០០ រៀល ឱ្យទៅដើមចោទវិញ និងបង្គាប់ឱ្យបង់ពន្ធសមាមាត្រចំនួន មួយភាគរយ លើតម្លៃភូមិគ្រឹះខាងលើ និងត្បូងពេជ្រខាងលើ ប្រាក់នេះត្រូវបង់ចូលថវិការដ្ឋចំនួន ៨០ ភាគរយ និងបានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេសចំនួន ២០ ភាគរយ ។

៨. សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខដើមចោទ កំពាំងមុខចុងចម្លើយ សម្រេចបើកផ្លូវឧទ្ធរណ៍ ក្នុងរយៈពេល ២ ខែ គិតចាប់ពីថ្ងៃផុតបណ្តឹងទាស់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ២៦ "ក" ចុះថ្ងៃទី ០២-០៥-១៩៩៧ របស់លោក កង ហាក់ ប្តឹងមិនសុខចិត្តត្រង់ចំណុចទី ៦ នៃសាលក្រម និងពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៧-០៤-១៩៩៧ របស់លោក ឈួរ ហាងថេង និងអ្នកស្រី កង ហ៊ុន ប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចនៃសាលក្រមទាំងមូលធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញ សាលដីការដ្ឋប្បវេណីលេខ ៤១៣ ចុះថ្ងៃទី ០៥-០៨-១៩៩៧ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១. "ក" ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៧-០៤-១៩៩៧ របស់ឈ្មោះ កង ហ៊ុន និងឈ្មោះ ឈួរ ហាងថេង ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

Scanned with CamScanner

"ខ" ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០២-០៥-១៩៩៧ របស់ឈ្មោះ កង ហាក់ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់តែលើកចោលដោយទាស់ខុសនឹងគតិច្បាប់ ។

២. បដិសេធសាលក្រមរដ្ឋប្បវេណីលេខ ២៨"ក" ចុះថ្ងៃទី ២៦-០៣-១៩៩៧ របស់តុលាការក្រុងភ្នំពេញ ចោលជាអសារបង់ ។

៣. ប្រគល់ផ្ទះទំនាស់លេខ ១៨៨ ផ្លូវលេខ ៥១ ក្រុម ៦៣ សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ៥ ៨៨៧ ចុះថ្ងៃទី ២៩-១១-១៩៩១ ឱ្យទៅឈ្មោះ កង ហ៊ុន និងឈ្មោះ ឈួរ ហាង ថេង កាន់កាប់ និងគ្រប់គ្រងជាកម្មសិទ្ធិនៅពេលដែលសាលដីកានេះចូលជាស្ថាពរ ។

៤. សម្រេចកាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣ 000 រៀល គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្លឹង ២ ៥៥0 រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥0 រៀល, រង្វាន់អ្នកប្រគល់ដីកាកោះ និងអាជ្ញាធរតុលាការ ១0 000 រៀល សរុប ១៣ 000 រៀល កាលបើហួសកំណត់ប្តឹងសាទុក្ខ បង្គាប់ឱ្យឈ្មោះ កង ហាក់ បង់ប្រាក់ប្រដាប់ក្តីចំនួន ១៣ 000 រៀល ឱ្យទៅឈ្មោះ កង ហ៊ុន និងឈ្មោះ ឈួរ ហាងថេង វិញ និងបង់ពន្ធសមាមាត្រមួយភាគរយ លើតម្លៃផ្ទះទំនាស់ ។

៥. សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី ។ សំរេចបើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ២៨0ចុះថ្ងៃទី ០៧-0៨-១៩៩៧ របស់លោក កង ហាក់ ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសារណា ចុះថ្ងៃទី ២៧-0៨-១៩៩៧ របស់លោក កង ហាក់

បានឃើញសារណាឆ្លើយតប ចុះថ្ងៃទី 0២-0៥-១៩៩៧ របស់លោក ឈួរ ហាងថេង

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការថា :

យល់ឃើញបណ្តឹងសាទុក្ខរបស់ដើមចោទស្ថិតនៅក្នុងកំណត់ច្បាប់ គប្បីលើកយករឿងនេះមកពិនិត្យពិចារណា។

យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៤១៣ ចុះថ្ងៃទី 0៥-0៨-១៩៩៧ របស់សាលាឧទ្ធរណ៍បានសម្រេចត្រឹមត្រូវតាមគតិច្បាប់ហើយ សូមក្រុមប្រឹក្សាជំនុំជំរះសម្រេចតាមច្បាប់ ។

លោក កង ហាក់ បានឆ្លើយថា ខ្លួនជាប្តីរបស់នាង ម៉ែង សាមួយ បានរស់នៅជាមួយគ្នារហូតមិនដែលថាលែងលះគ្នាទេ ខ្លួនបានឱ្យប្រពន្ធខ្លួនទិញផ្ទះនៅឆ្នាំ ១៩៨៩ ហើយជួសជុសនៅឆ្នាំ ១៩៩១ គឺទិញពីឈ្មោះ លិញ ព្រមទាំងបានជួសជុលអស់ប្រាក់ជាច្រើន ខ្លួនពុំដែលឃើញកូនមកមើល ឬជួយធ្វើអ្វីឡើយ កង ហ៊ុន ត្រូវជាកូនចិញ្ចឹមខ្លួនបានបញ្ឆោតឱ្យប្រពន្ធខ្លួន ឈ្មោះ ម៉ែង សាមួយ ផ្តិតមេដៃលើកិច្ចសន្យា ដោយឈ្មោះនេះប្រាប់ថាជាកិច្ចសន្យាជួល តែការពិតជាកិច្ចសន្យាប្រគល់សិទ្ធិសោះ នៅពេលដែលប្រពន្ធខ្លួនរៀបស្លាប់ ក៏គេមិនដែលមកមើល ឬជួយថែរក្សាម្តាយរបស់គេដែរ ខ្លួនទេដែលជាអ្នកចេញមុខមកមើល និងបានខ្ចីលុយគេធ្វើបុណ្យឱ្យប្រពន្ធខ្លួន ក៏ពួកគេមិនដែលជួយចេញអ្វីដល់ខ្លួនដែរ ខ្លួនសូមបញ្ជាក់ថា ការពិត ឬមិនពិតមាននៅក្នុងលិខិតទាំងនោះស្រាប់ ហើយសូមលោកប្រធានតុលាការជ្រាប ខ្លួនបាន

Scanned with CamScanner

ទិញផ្ទះដល់ស្រុកយួន ក៏គេតាមទៅលក់ទៀត ផ្ទះនៅផ្សារដេប៉ូ ក៏គេលក់ដែរ កូនខ្លួនចិញ្ចឹមរហូតមក ខ្លួនស្រលាញ់គេណាស់ ខ្លួនមិននឹកស្មានថា គេមានគំនិតដល់នេះ គេបានជេរខ្លួននៅតាមជញ្ជាំងផ្ទះច្រើនណាស់ ខ្លួនមានទាំងរូបថតជូនសំអាងទៀត សូមលោកប្រធានតុលាការមេត្តាជួយរកយុត្តិធម៌ឱ្យខ្លួនផង ។

អ្នកស្រី កង ហ៊ុន បានឆ្លើយថា ពាក្យដែលគាត់បាននិយាយនេះ គឺជាពាក្យមិនពិតទាំងអស់ គឺគ្មានអ្វីជាសំអាងច្បាស់លាស់នោះទេ សូមលោកមេត្តាជួយពិចារណារកយុត្តិធម៌ឱ្យខ្លួនផង ។

លោក ឈួរ ហាងថេង បានឆ្លើយថា នៅក្នុងប័ណ្ណគ្រួសារ របស់ឈ្មោះ កង ហាក់ ដែលបានបញ្ជាក់ថា គាត់បានរស់នៅផ្ទះលេខ ១៨៨ នេះជាប័ណ្ណក្លែងក្លាយទេ តាមពិតក្នុងប័ណ្ណនោះគ្មានឈ្មោះគាត់ទេ នៅក្នុងប័ណ្ណសុំកម្មសិទ្ធិ ក៏គ្មានឈ្មោះ កង ហាក់ ដែរ ហើយក៏គាត់មិនបានមកតវ៉ាអ្វីដែរ អំពីគ្រឿងអលង្កា ដែលគាត់បាននិយាយថា ថាមានតម្លៃនោះតាមពិតជាគ្រឿងក្រឡៃទេ មិនដូចពាក្យដែលគាត់បានចោទប្រកាន់មកទេ សូមលោកប្រធានមេត្តាពិចារណា ។

ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

ក្រោយពីស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់

តុលាការកំពូល

យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២៨០ ចុះថ្ងៃទី ០៧-០៨-១៩៩៧ របស់លោក កង ហាក់ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះ បានតាមមាត្រា ១៨ នៃច្បាប់ស្តីការចាត់តាំង និងសកម្មភាពសាលាជំរះក្តី ។

យល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់ និងច្បាស់លាស់បញ្ជាក់លោក កង ហាក់ បានបែកលំនៅសង្វាសពីអ្នកស្រី ម៉ែង សាមួយ ទៅរួមរស់នៅជាមួយអ្នកស្រី ចាន់ សុខខេង តាំងពីឆ្នាំ ១៩៨៤ មកម្លេះ ហើយគ្មានភស្តុតាងណាបញ្ជាក់ថា លោក កង ហាក់ បានបន្តរកស៊ីរួមគ្នាជាមួយអ្នកស្រី ម៉ែង សាមួយ ឬ មានទ្រព្យសម្បត្តិរួមក្រៅពីផ្ទះលេខ ១១៨ សង្កាត់ទឹកល្អក់ទី ៣ ក្រោយឆ្នាំ ១៩៨៤ ទេ ។

យល់ឃើញថា ការលើកឡើងរបស់លោក កង ហាក់ ក្នុងសារណាចុះថ្ងៃទី ២៧-០៨-១៩៩៧ ដែលថា លោកទិញផ្ទះទំនាស់នេះនៅឆ្នាំ ១៩៨៩ ឱ្យអ្នកស្រី ម៉ែង សាមួយ ធ្វើអាជីវកម្ម និងកាន់កាប់នោះ ជាការបំភ័ន្តអង្គហេតុទាំងស្រុង ពីព្រោះមានមូលដ្ឋានច្បាស់លាស់បញ្ជាក់ថា អ្នកស្រី ម៉ែង សាមួយ ទិញផ្ទះនេះតែម្នាក់ឯង នៅឆ្នាំ ១៩៩០ ដូចមានកិច្ចសន្យាលក់ទិញផ្ទះ ចុះថ្ងៃទី ០៤-១០-១៩៩០ ជាភស្តុតាងស្រាប់ ។

យល់ឃើញថា ការលើកឡើងនៅក្នុងសារណារបស់លោក កង ហាក់ ដែលថាលិខិតធ្វើអំណោយផ្ទះ និងប័ណ្ណកម្មសិទ្ធិដែលស្ថាប័នមានសមត្ថកិច្ចចេញឱ្យលោក ឈួរ ហាងថេង និងអ្នកស្រី កង ហ៊ុន លោក មិនទទួលស្គាល់ទេ ដោយសារ លោកពុំបានយល់ព្រមតាមមាត្រា ៣៧ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ទេនោះ ជាការពុំត្រឹមត្រូវឡើយ ពីព្រោះប័ណ្ណកម្មសិទ្ធិលេខ ៥.៨៨៧ ចុះថ្ងៃទី ២៩-១១-១៩៩១ ដែលការិយាល័យសុរិយោដីក្រុងភ្នំពេញ ចេញ

Scanned with CamScanner

ឱ្យអ្នកស្រី ម៉ែង សាមួយ ពុំមានឈ្មោះ លោក កង ហាក់ ទេ ។ ហើយការដែលលោក កង ហាក់ បានឆ្លើយនៅពេលសវនាការ សាលាឧទ្ធរណ៍ថា លោកជាអ្នករត់ការធ្វើប័ណ្ណនេះ ប៉ុន្តែលោកពុំបានដាក់ឈ្មោះលោកទេនោះ ដូច្នេះ ផ្ទះនោះត្រូវបានទៅជាកម្មសិទ្ធិផ្តាច់មុខរបស់អ្នកស្រី ម៉ែង សាមួយ តែម្នាក់ឯង ដែលតាមមាត្រា ៤១ នៃក្រឹត្យ-ច្បាប់លេខ ៣៨ ចុះថ្ងៃទី ២៨-១០-១៩៨៨ លោក កង ហាក់ ពុំមានសិទ្ធិមកតវ៉ាពីរឿងផ្ទះនេះទៀតឡើយ ។ ម៉្យាងទៀតអ្នកស្រី ម៉ែង សាមួយ ក៏មានសិទ្ធិផ្តាច់មុខក្នុងការសម្រេចធ្វើអំណោយផ្តាច់នេះឱ្យលោក ឈូរ ហាងថេង និងអ្នកស្រី កង ហ៊ុន ដោយពុំចាំបាច់មានការយល់ព្រមពីលោក កង ហាក់ តាមមាត្រា ៣៨ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារដែរ ។ ដោយលិខិតធ្វើអំណោយផ្តាច់នេះបានចុះបញ្ជី និងប្រថាប់ត្រារួចហើយនោះ តាមមាត្រា ១៩៤ នៃច្បាប់ភូមិបាល លោក កង ហាក់ ក៏តែគ្មានសិទ្ធិតវ៉ាទៅទៀត ។

យល់ឃើញថា ការលើកឡើងរបស់លោក កង ហាក់ ដែលថាមានគ្រឿងអលង្ការដូចខាងក្រោម :

- ខ្សែដៃពេជ្រ ១ ខ្សែ	តម្លៃ	៨ ៥០០ ដុល្លាអមេរិក
- ខ្សែដៃពេជ្រ ១ ខ្សែ	តម្លៃ	៣ ៥០០ ដុល្លាអាមេរិក
- បណ្តោងពេជ្រ ១	តម្លៃ	៦ ០០០ ដុល្លាអាមេរិក
- ចិញ្ចៀនវែន ១ វង់	តម្លៃ	៥ ០០០ ដុល្លាអាមេរិក
- ក្រវិលពេជ្រ ១ គូ	តម្លៃ	២ ៥០០ ដុល្លាអាមេរិក
- ចិញ្ចៀនត្បូង ១ គូ	តម្លៃ	៣០០ ដុល្លាអមេរិក
- ចិញ្ចៀនត្រមាស ២ វង់	តម្លៃ	១៥០ ដុល្លាអាមេរិក

គ្រឿងអលង្ការទាំងនេះ ឈ្មោះ ង៉ សេង បានប្រគល់ឱ្យលោក លោកបានវេចខ្ចប់ប្រគល់ឱ្យ កង ហ៊ុន ទុករហូតដល់សព្វថ្ងៃ ។

ការលើកឡើងបែបនេះរបស់លោក កង ហាក់ ជាការពុំត្រឹមត្រូវទេ ពីព្រោះគ្មានភស្តុតាងណា ដែលបញ្ជាក់ថាអ្នកស្រី កង ហ៊ុន បានរក្សាទុកនូវគ្រឿងអលង្ការតាមចំនួន និងតម្លៃដូចការលើកឡើងរបស់លោក កង ហាក់ ទេ ហើយក៏ពុំមានភស្តុតាងណាបញ្ជាក់ថា គ្រឿងអលង្ការទាំងនេះជាទ្រព្យសម្បត្តិរបស់លោក និងអ្នកស្រី ម៉ែង សាមួយ ដែរ ពីព្រោះ លោក និងអ្នកស្រី បានបែកលំនៅដ្ឋានគ្នា តាំងពីឆ្នាំ ១៩៨៤ មកម្ល៉េះ ។ ម៉្យាងទៀត គ្រឿងអលង្ការមួយចំនួនដែលឈ្មោះ ង៉ សេង បានប្រគល់ឱ្យអ្នកស្រី កង ហ៊ុន ជាអលង្ការ ដែលមានតម្លៃតិចតួច ហើយក៏ដោយសារអ្នកស្រី កង ហ៊ុន បានយកប្រាក់ទៅលោះពីឈ្មោះ ង៉ សេង និងម្ចាស់បំណុលផ្សេងទៀតដែរ ដូច្នេះ លោក កង ហាក់ គ្មានសិទ្ធិទាមទារគ្រឿងអលង្ការទាំងនេះទេ ។

យល់ឃើញថា ការលើកឡើងក្នុងសារណារបស់លោក កង ហាក់ ដែលថា លោកជាអ្នកជួសជុលផ្ទះចំនាស់នេះបញ្ជាក់ថា លោកជាម្ចាស់នៃផ្ទះចំនាស់នេះ នោះក៏ជាការពុំត្រឹមត្រូវដែរ ពីព្រោះគ្មានភស្តុតាងបញ្ជាក់ថា ក្រោយពេលដែលអ្នកស្រី ម៉ែង សាមួយ ទិញផ្ទះរួច លោក កង ហាក់ បានទៅសុំម៉ៅការជួសជុលផ្ទះដោយយកកំរែតែប៉ុណ្ណោះ ។

Scanned with CamScanner

យល់ឃើញថា ឯកសារមួយចំនួនដែល លោក កង ហាក់ ទើបតែបានដាក់ជូនមកតុលាការកំពូល តុលាការកំពូលពុំមានសមត្ថកិច្ចលើកមកពិចារណាបានឡើយ ពីព្រោះ ឯកសាទាំងនេះជាភស្តុតាងថ្មី ដែលតុលាការថ្នាក់ក្រោមពុំទាន់បានពិចារណានៅឡើយ ហើយតុលាការកំពូលជំនុំជម្រះលើកទី ១ នេះ ជំនុំជម្រះតែលើអង្គច្បាប់ប៉ុណ្ណោះ ពុំពិចារណាដល់អង្គហេតុទេ ។

យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៤១៣ ចុះថ្ងៃទី ០៥-០៨-១៩៩៧ របស់សាលាឧទ្ធរណ៍ ដែលសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

<u>ហេតុដូច្នេះ</u>

<u>វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី</u>

១. ទទួលបណ្តឹងសាទុក្ខលេខ ២៨០ ចុះថ្ងៃទី ០៧-០៨-១៩៩៧ របស់លោក កង ហាក់ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនីតិច្បាប់ ។

២. តម្កល់សាលដីការដ្ឋប្បវេណីលេខ ៤១៣ ចុះថ្ងៃទី ០៥-០៨-១៩៩៧ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣. · រឹមអូសប្រាក់ប្រដាប់ក្តីចំនួន ១៩ 000 រៀល ដែលលោក កង ហាក់ បានបង់រួចហើយ គឺ :

- ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន ៤ 000 រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨00 រៀល សម្រាប់ជាវង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់
- ចំណាយលើកិច្ចប្រគល់ដីការកោះចំនួន ១៥ 000 រៀល សរុប ១៩ 000 រៀល ។

បង្គាប់ឱ្យលោក កង ហាក់ បង់ពន្ធសមាមាត្រចំនួនមួយភាគរយ លើតម្លៃផ្ទះទំនាស់ ។

៤. សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី ២៥-០៩-១៩៩៧ ។

២. កំណែ : (កាន ច័ន្ទមេត្តា)

១. អង្គហេតុ :

លោក កង ហាក់ បានចាកចោលលំនៅសង្វាសពីសហព័ទ្ធជាប្រពន្ធរបស់ខ្លួន ហើយចាកចេញទៅកាន់ប្រទេសវៀតណាមជាមួយនារីថ្មីម្នាក់ទៀត ប៉ុន្តែគ្មានសាលក្រមស្តីការលែងលះត្រូវបានធ្វើឡើងនោះទេ ។ ក្នុងរយៈពេលអវត្តមានរបស់គាត់រវាងឆ្នាំ ១៩៨៩-១៩៩0 សហព័ទ្ធប្រពន្ធបានទិញផ្ទះមួយនៅទីក្រុងភ្នំពេញ ដែលគាត់បានធ្វើប្រទានកម្មផ្ទះនេះឱ្យទៅកូនស្រីចិញ្ចឹមរបស់គាត់ ហើយប្រទានកម្មនេះក៏ត្រូវបានចុះបញ្ជីនៅស៊ុរិយោដីផងដែរ ។ ម៉្យាងវិញទៀត កូនស្រីចិញ្ចឹមរបស់គាត់ ក៏បានកាន់កាប់នៅត្បូងមានតម្លៃមួយចំនួនទៀត ។

Scanned with CamScanner

២. នីតិវិធី :

- ការដាក់ពាក្យបណ្តឹងទៅតុលាការ :

ក្រោយពីការស្លាប់ប្រពន្ធរបស់គាត់ លោក កង ហាក់ បានប្តឹងទៅតុលាការក្រុងភ្នំពេញ ដើម្បីទាមទារនូវអចលនវត្ថុ និងត្បូងពេជ្រពីកូនចិញ្ចឹមរបស់គាត់ ។ លោក កង ហាក់ បានសំអាងថា តាមពិត គាត់ជាអ្នកទិញអចលនវត្ថុវិវាទនោះ។ គាត់បានចាត់ទុកថា ប្រទានកម្មដែលធ្វើឡើងដោយប្រពន្ធរបស់គាត់ឱ្យទៅកូនស្រីចិញ្ចឹមនោះ កើតឡើងដោយចេតនាទុច្ចរិតក្នុងការបន្លំបោកប្រាស់របស់កូនស្រីចិញ្ចឹមនោះតែប៉ុណ្ណោះ ។ កូនស្រីនេះបានធ្វើឱ្យប្រពន្ធរបស់គាត់ជឿជាក់ថា វាគ្រាន់តែជាកិច្ចសន្យាជួលទេវិញ ។

- សេចក្តីសម្រេចរបស់តុលាការក្រុងភ្នំពេញ :

តុលាការក្រុងភ្នំពេញបានសម្រេចឱ្យកូនចិញ្ចឹមប្រគល់ផ្ទះលេខ ១៨៨ ទៅឱ្យដើមចោទរក្សាទុក និងគ្រប់គ្រងដោយយោងទៅលើមាត្រា ៣៧ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ហើយក៏បានបដិសេធនូវវិញ្ញាបនប័ត្រសំគាល់អចលនវត្ថុចោល និងត្រូវប្រគល់នូវត្បូងត្រលប់មកវិញផងដែរ ។

- បណ្តឹងឧទ្ធរណ៍ និងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ :

លោក កង ហាក់ និងកូនស្រីចិញ្ចឹមរបស់គាត់បានប្តឹងឧទ្ធរណ៍ ។ សាលាឧទ្ធរណ៍បានបដិសេធសាលក្រមរបស់តុលាការក្រុងភ្នំពេញ ដោយសម្រេចប្រគល់អចលនវត្ថុនោះឱ្យទៅកូនស្រីចិញ្ចឹមរបស់គាតវិញ ។

- មធ្យោបាយសំអាងនៃបណ្តឹងសាទុក្ខ :

លោក កង ហាក់ បានប្តឹងសាទុក្ខទៅតុលាការកំពូល ដោយលើកឡើងនូវអំណះអំណាងថា កូនស្រីចិញ្ចឹមនេះ មិនដែលមកជួយមកធ្វើអ្វីនោះទេ នៅពេលមានការសាងសង់ផ្ទះវិវាទនៅឆ្នាំ ១៩៩១ ។ ម៉្យាងវិញទៀត កូនស្រីចិញ្ចឹម បានបោកបញ្ឆោតសហព័ទ្ធប្រពន្ធដែលជាម្តាយឱ្យចុះកិច្ចសន្យាប្រទានកម្មផ្ទះនោះមកឱ្យខ្លួន ។ នៅពេលដែលសហព័ទ្ធប្រពន្ធរៀបនឹងស្លាប់ កូនស្រីចិញ្ចឹមនេះពុំដែលមកជួយថែទាំនោះទេ គឺមានតែលោក កង ហាក់ តែប៉ុណ្ណោះ ។

៣. ចំណោទបញ្ហាគតិយុត្ត :

ក្នុងករណីដែលអចលនវត្ថុមួយត្រូវបានទិញដោយសហព័ទ្ធម្តាង ក្នុងរយៈពេលមានចំណងអាពាហ៍ពិពាហ៍ ហើយក្នុងវិញ្ញាបនប័ត្រសំគាល់អចលនវត្ថុមានតែឈ្មោះសហព័ទ្ធម្តាងជាអ្នកទិញតែប៉ុណ្ណោះ តើអចលនវត្ថុនេះអាចត្រូវបានចាត់ទុកជាទ្រព្យផ្ទាល់ខ្លួន ឬទ្រព្យរួម ? តើសហព័ទ្ធជាអ្នកទិញមានសិទ្ធិចាត់ចែងតែម្នាក់ឯងលើទ្រព្យនេះដែរ ឬទេ ?

៤. សេចក្តីសម្រេចរបស់តុលាការកំពូល

តុលាការកំពូលបានសម្រេចតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទាំងមូល ដោយហេតុថាមានភស្តុតាង លើកឡើង ដោយកូនស្រីចិញ្ចឹមដែលបញ្ជាក់ថាអង្គហេតុដែលអះអាងដោយដើមបណ្តឹងសាទុក្ខមានការភ័ន្តច្រឡំ ដោយសំអាងហេតុថា មានភស្តុតាងផ្សេងទៀតបញ្ជាក់ថា មានតែសហព័ទ្ធប្រពន្ធតែម្នាក់គត់ ដែលបានទិញផ្ទះវិវាទនោះ តាមរយៈកិច្ចសន្យាលក់ទិញផ្ទះនៅឆ្នាំ ១៩៩០ ។ ជាពិសេសទៀត មានតែឈ្មោះសហព័ទ្ធប្រពន្ធប៉ុណ្ណោះ នៅក្នុងវិញ្ញាបនប័ត្រសំគាល់អចលនវត្ថុឆ្នាំ ១៩៩១ ។ យោងតាមមាត្រា ៤១ និងមាត្រា ៣៧ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ គាត់ជាកម្មសិទ្ធិករ

Scanned with CamScanner

និងមានសិទ្ធិផ្តាច់មុខក្នុងការសម្រេចធ្វើប្រទានកម្មឱ្យទៅកូនចិញ្ចឹម ដោយមិនចាំបាច់មានការយល់ព្រមពីសហព័ន្ធប្តីនោះទេ ។ ម៉្យាងវិញទៀត កិច្ចសន្យាប្រទានកម្មនេះ ត្រូវបានចុះបញ្ជី និងប្រថាប់ត្រា ។ ផ្អែកលើមាត្រា ១៩៤ នៃច្បាប់ភូមិបាល ដូច្នេះ កិច្ចសន្យានេះអាចប្រឆាំងបានគ្រប់បុគ្គលទាំងអស់ ។ ចំណែកគ្រឿងក្សួងពេជ្រក៏គ្មានភស្តុតាងបញ្ជាក់ថាទ្រព្យទាំងនោះជាទ្រព្យរួមផងដែរ ។

ខ. នីតិព្រហ្មទណ្ឌ

រៀបចំសលាកប័ត្រសាលដីការលេខ ២៧ ចុះថ្ងៃទី ១៩-០៩-១៩៩៧ របស់តុលាការកំពូល ។

១. សាលដីកា

សូមមើលសាលដីខាងលើនៅទំព័រទី ៦១

២. កិច្ចណា : (ប៉ែន រ៉ានី និង ការិន ភូថុំង)

១. អង្គហេតុ :

នៅថ្ងៃទី០២ ខែ កញ្ញា ឆ្នាំ ១៩៩៥ មានគ្រោះថ្នាក់ចរាចរមួយកើតឡើងរវាងរថយន្តធុនធ្ងន់ ដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុនមួយ និងទោចក្រយាន្តមួយបើកបរដោយនារីពីរនាក់ ដែលក្នុងនោះមាននារីម្នាក់បានស្លាប់ និងម្នាក់ទៀតរងរបួស ។

២. នីតិវិធី :

- ការដាក់ពាក្យបណ្តឹងទៅតុលាការ :

ឪពុកម្តាយរបស់ជនរងគ្រោះទាំងពីរនាក់បានដាក់ពាក្យបណ្តឹង ដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខតុលាការក្រុងភ្នំពេញ ។ ពួកគាត់បានចោទប្រកាន់អ្នកបើកបររថយន្តធុនធ្ងន់ ពីបទមនុស្សឃាដ និងបង្ករបួសស្នាមដោយចេតនា យោងតាមមាត្រា ៥៦ និង ៦០ នៃច្បាប់ស្តីពីចរាចរជើងគោក និងប្តឹងសុំទាមទារសំណងខូចខាតពីក្រុមហ៊ុន ជានិយោជករបស់អ្នកបើកបរ និងជាកម្មសិទ្ធិកររថយន្ត ។

-សេចក្តីសំរេចរបស់តុលាការដំបូងចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ :

តុលាការបានផ្តន្ទាទោសដាក់ពន្ធនាគារអ្នកបើកបររថយន្តចំនួន ១ឆ្នាំ ដោយព្យួរការអនុវត្តទោសសាកល្បងរយៈពេល ៥ ឆ្នាំ ពីបទមនុស្សឃាដ និងបង្ករបួសស្នាមដោយអចេតនា ដែលមានចែងក្នុងមាត្រា ៤០ (ស្តីពីមនុស្សឃាដដោយអចេតនា) និងមាត្រា ៧០ (ស្តីពីការព្យួរទោសសាកល្បង) នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងមាត្រា ៥៦ នៃច្បាប់ស្តីពីចរាចរជើងគោក ។ លើសពីនេះ តុលាការបានផ្តន្ទាទោសក្រុមហ៊ុនឱ្យជួសជុលសំណងខូចខាតចំពោះគ្រោះថ្នាក់ខាងលើនេះ ។

-បណ្តឹងឧទ្ធរណ៍ និងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ១៩៩៦ :

អ្នកបើកបររថយន្តបានធ្វើបណ្តឹងឧទ្ធរណ៍ ប៉ុន្តែ សាលាឧទ្ធរណ៍បានតម្កល់សាលក្រមទុកជាបានការ ។

Scanned with CamScanner

-បណ្តឹងសាទុក្ខលើកទីមួយ :

អ្នកបើកបររថយន្តបានធ្វើបណ្តឹងសាទុក្ខលើសេចក្តីសំរេចរបស់សាលាឧទ្ធរណ៍ទាំងមូល(អំណះអំណាងនៃបណ្តឹងសាទុក្ខមិនត្រូវបានសរសេរនៅក្នុងសេចក្តីសំរេចនេះទេ) ។

អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល បានលើកឡើងថា អ្នកបើកបររថយន្តមានកំហុស ប៉ុន្តែ នារីរងគ្រោះទាំងពីរក៏មានកំហុសដែរ ផ្អែកទៅលើស្ថានភាពផ្លូវដែលមានគ្រោះថ្នាក់កើតឡើង ។ លើសពីនេះ អគ្គព្រះរាជអាជ្ញា បានរំលឹកថា តុលាការក្រុងភ្នំពេញបានអនុវត្តមាត្រា ៤០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល មិនមែនមាត្រា ៦០ នៃច្បាប់ស្តីពីចរាចរជើងគោកទេ ព្រោះមាត្រានេះប្រើពាក្យ "ចេតនា" ក៏ប៉ុន្តែ បើតាមចៅក្រមថ្នាក់ដំបូង ក្នុងករណីនេះ ការស្លាប់និងការរងរបួស មិនមែនដោយចេតនាទេ ប៉ុន្តែ ដោយសារការធ្វេសប្រហែស ។ គោលការណ៍នីត្យានុកូលភាពកំណត់ឱ្យចៅក្រមអនុវត្តច្បាប់ដែលមានជាធរមាននៅពេលកើតហេតុ ហើយចៅក្រមថ្នាក់ដំបូងមានទាទ្រឹមតែបកស្រាយច្បាប់ដែលមិនច្បាស់លាស់ប៉ុណ្ណោះ ការបង្កើតយុត្តិសាស្ត្រថ្មីៗជាសមត្ថកិច្ចរបស់តុលាការកំពូល ។ ដូច្នេះ មានតែមាត្រា ៤០ ប៉ុណ្ណោះ ដែលអាចយកមកអនុវត្តបានក្នុងករណីខាងលើនេះ ។ ជាចុងក្រោយ អគ្គព្រះរាជអាជ្ញាយល់ថា ការកំណត់ពីតម្លៃនៃសំណងការខូចខាតខាងរូបរាងកាយ និងសំការៈ ជាអំណាចឆន្ទានុសិទ្ធិរបស់ចៅក្រមថ្នាក់ដំបូង ហើយការស្លាប់របស់បុគ្គលណាម្នាក់ ពុំអាចជាកម្មវត្ថុនៃការសងបានទេ ព្រោះថា "ពុំមានច្បាប់ណាអាចកំណត់ពីតំលៃជីវិតមនុស្ស" ។

នៅថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៦ តុលាការកំពូលបានបដិសេធសាលដីកាសាលាឧទ្ធរណ៍ និងបង្វែរសំណុំរឿងទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជម្រះសាជាថ្មី ។

- សេចក្តីសម្រេច ឬសាលដីកា លើកទី២ របស់សាលាឧទ្ធរណ៍ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៧ :

អគ្គព្រះរាជអាជ្ញាតុលាការកំពូលបានសន្និដ្ឋានថា ចៅក្រមតុលាការកំពូលបានយោងមាត្រា ៦០ នៃច្បាប់ស្តីពីចរាចរជើងគោក ដែលចូលជាធរមានមុនច្បាប់ព្រហ្មទណ្ឌអន្តរកាល ដូច្នេះ សេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ពុំមានមូលដ្ឋានច្បាស់លាស់នោះទេ ។ លើសពីនេះ កំហុសរបស់ជនរងគ្រោះក៏ត្រូវតែគិតរាប់បញ្ចូល ដើម្បីវាយតំលៃសោហ៊ុយជម្ងឺចិត្តផងដែរ ។

ក្នុងករណីនេះសាលាឧទ្ធរណ៍បានផ្តន្ទាទោសដាក់ពន្ធនាគារអ្នកបើកបររថយន្តចុងចន្ទន់ចំនួន ៦ខែ ដោយព្យួរទោសសាកល្បងរយៈពេល ៥ ឆ្នាំ ពីបទមនុស្សឃាតដោយចេតនា និងបង្ករបួសស្នាមដោយអចេតនា តាមមាត្រា ៥៦ និង៦០ នៃច្បាប់ស្តីពីចរាចរជើងគោក និងមាត្រា ៦៨ ដល់ ៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។ សាលាឧទ្ធរណ៍ក៏បានផ្តន្ទាទោសក្រុមហ៊ុនឱ្យសងសោហ៊ុយជម្ងឺចិត្តទៅភាគីរដ្ឋប្បវេណី ។

ក្រុមហ៊ុនបានធ្វើបណ្តឹងសាទុក្ខលើកទីពីរ ទៅតុលាការកំពូល ។

- មធ្យោបាយសំអាងក្នុងបណ្តឹងសាទុក្ខលើកទីពីរ :

ក្រុមហ៊ុនបានបដិសេធសាលដីកាសាលាឧទ្ធរណ៍ទាំងមូល ។ ក្រុមហ៊ុនបានអះអាងថាចំនួនទឹកលុយ ដែលត្រូវបង់ទៅជនរងគ្រោះពុំមានសមាមាត្រនោះទេ ។ ដូច្នេះ ក្រុមហ៊ុនបានសុំឱ្យមានការបន្ថយចំនួនទឹកប្រាក់នៃសោហ៊ុយជម្ងឺចិត្ត ។

Scanned with CamScanner

- សេចក្តីសន្និដ្ឋានរបស់អគ្គព្រះរាជអាជ្ញា :

អគ្គព្រះរាជអាជ្ញាប្រកាន់យកនូវបទល្មើសមនុស្សឃាដ និងបង្ករបួសស្នាមដោយអចេតនា និងសំណូមពរឱ្យរក្សាសាលដីកាសាលាឧទ្ធរណ៍ទាំងមូល ។

៣. បញ្ហាគតិយុត្ត :

បញ្ហាគតិយុត្តពីរបានចោទឡើងក្នុងសាលដីកានេះ :

១-តើគ្រោះថ្នាក់ចរាចរដែលបានបណ្តាលឱ្យមានការស្លាប់ និងបង្ករបួសស្នាមដល់អ្នកដទៃ ត្រូវបានចាត់ទុកជាបទល្មើសមនុស្សឃាដ និងបង្ករបួសស្នាមដោយអចេតនា ឬចេតនា ?

២-តើជនរងគ្រោះដែលបានស្លាប់ ឬរងរបួសស្នាមបណ្តាលមកពីកំហុសផ្ទាល់ខ្លួនមួយផ្នែក ត្រូវតែទទួលខុសត្រូវរួមគ្នាជាមួយអ្នកប្រព្រឹត្តដែរឬទេ ?

៤. សេចក្តីសម្រេចរបស់តុលាការកំពូល :

ក្នុងសាលដីកាចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៩៧ តុលាការកំពូលបានតម្កល់សាលដីកាសាលាឧទ្ធរណ៍មួយផ្នែក ។ តុលាការកំពូលបានសម្រេចថា អ្នកបើកបររថយន្តមានពិរុទ្ធពីបទមនុស្សឃាដនិងបង្ករបួសស្នាមដោយអចេតនា ផ្អែកតាមមាត្រា ៥៦ និង៦០ នៃច្បាប់ស្តីពីចរាចរជើងគោក មិនមែនដោយចេតនា ដូចដែលសាលាឧទ្ធរណ៍បានសម្រេចនោះទេ ។ សញ្ញាណនៃពាក្យ"ដោយចេតនា" ដែលមាននៅក្នុងមាត្រាខាងលើនេះ មានការភ័ន្តច្រឡំ ។ តុលាការកំពូលសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារជនជាប់ចោទចំនួន ១ឆ្នាំ ដោយព្យួរការអនុវត្តទោសរយៈពេល ៥ ឆ្នាំ ផ្អែកតាមមាត្រា ៦៨-៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

លើសពីនេះ យោងតាមកំហុសរបស់ជនរងគ្រោះទាំងពីរ ដែលបានបំពានច្បាប់ចរាចរ តុលាការកំពូលសម្រេចថា ជនរងគ្រោះត្រូវទទួលខុសត្រូវទៅលើកំហុសរបស់ខ្លួន ។ ដូច្នេះ តុលាការសម្រេចបន្ថយចំនួនទឹកប្រាក់នៃការជួសជុសសំណងដែលក្រុមហ៊ុនត្រូវផ្តល់ទៅជនរងគ្រោះ ។

គ. នីតិកាណិជ្ជកម្ម

រៀបចំសលាកប័ត្រសាដីកាខាងក្រោមនេះ :

១. សាលដីកា :

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី

លេខ : ២៤២

ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០២

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

Scanned with CamScanner

<u>សាលដីកា</u>

លេខ : ៧៣
ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៣

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០៣ ដោយមានសមាសភាពដូចតទៅ :

១- ឯកឧត្តម ឱិត មុន្នី	ប្រធាន
២- លោក ស៊ុន ឌីម	ចៅក្រម
៣- លោក ប្រាក់ គីមសាន	ចៅក្រមរបាយការណ៍
៤- លោក សោម សេរីរឌ្ឍ	ចៅក្រម
៥- លោក ប៉ែន សារឿន	ចៅក្រម

<u>ក្រឡាបញ្ជី</u>

កញ្ញា សេន សុខា

<u>តំណាងមហាអយ្យការ</u>

ឯកឧត្តម ជួន ស៊ុនឡេង ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខ ពីសាលដីកាលេខ០៩ "ឈ" ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០២ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៧៤៧ ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០១ របស់សាលាឧទ្ធរណ៍ ។

រវាងដើមចោទ អ្នកស្រី ពៅ គីមលី ជាម្ចាស់បណ្តឹងសារទុក្ខ ប្រធានក្រុមហ៊ុន SAN I.P.R & Trading Co.L.T.D ទីលំនៅផ្ទះលេខ ០៩ ផ្លូវ អង្គឌួង សង្កាត់ វត្តភ្នំ ខណ្ឌ ដូនពេញ ក្រុងភ្នំពេញ ។

លោក ជូ ចាន់ធីរ៉ា ជាមេធាវី និងជាតំណាងឱ្យដើមចោទ

និង ចុងចម្លើយក្រុមហ៊ុន Crocodile International Pte. LTD ជាចុងបណ្តឹងសាទុក្ខ

លោក អ៊ឹង វណ្ណៈ ជាមេធាវី និងជាតំណាងឱ្យចុងចម្លើយ ។

<u>កម្មវត្ថុបណ្តឹង</u> : ប្តឹងសុំលប់សេចក្តីសម្រេចចុះបញ្ជីសញ្ញាពាណិជ្ជកម្ម Crocodile & Device ។

បានឃើញបណ្តឹងសាទុក្ខលេខ៥៣ ចុះថ្ងៃទី ០៧-០២-២០០២ របស់មេធាវី ជូ ចាន់ធីរ៉ា ប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ០៩ "ឈ" ចុះថ្ងៃទី ១០-០១-២០០២ របស់សាលាឧទ្ធរណ៍លើសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២៤២ ចុះថ្ងៃទី ២៩-០៧-២០០២ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ២៨-១២-១៩៩៩ របស់ឈ្មោះ ពៅ គីមលី ជាប្រធានក្រុមហ៊ុន SAN.I.P.R តំណាងឱ្យក្រុមហ៊ុន Lachemise Lacoste ប្តឹងសុំលប់សេចក្តីសម្រេចចុះបញ្ជីសញ្ញាពាណិជ្ជកម្ម Crocodile International Pte. LTD ដោយសំអាងហេតុថា ក្រុមហ៊ុន Lachemise Lacoste បានចុះបញ្ជីការពារផ្លាកសញ្ញារូបក្រពើនៅប្រទេសកម្ពុជា មានវិញ្ញាបនប័ត្រចុះបញ្ជីលេខ ៧១៣៥ ចុះថ្ងៃទី ១០-០៥-១៩៩៦ និងបានប្រើប្រាស់លើកដំបូងពីឆ្នាំ ១៩២៧ មក ប៉ុន្តែ

Scanned with CamScanner

ក្រុមហ៊ុន Crocodile International Pte. LTD បានលួចចុះផ្លាកសញ្ញាពាណិជ្ជកម្ម រូបក្រពើនេះនៅប្រទេសកម្ពុជា និងបានប្រើប្រាស់រហូតដល់សព្វថ្ងៃ ជាហេតុធ្វើឱ្យប៉ះពាល់ផលប្រយោជន៍នៃផលិតផលចំនិញ Lacoste យ៉ាងធ្ងន់ធ្ងរ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៤៩ "ឆ" ចុះថ្ងៃទី ២០-១១-២០០០ របស់តុលាការក្រុងភ្នំពេញដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១- ទទួលស្គាល់លិខិតប្រគល់សិទ្ធិជូនមេធាវី ជូ ចាន់ធីរ៉ា ចុះថ្ងៃទី ២៦-១០-១៩៩៩ របស់ក្រុមហ៊ុន សានអាយភីអ័រ តំណាងឱ្យក្រុមហ៊ុន Lachemise Lacoste Company (LLC) ប្រទេសបារាំង ទុកជាត្រឹមត្រូវតាមច្បាប់ ។

២- ទទួលស្គាល់លិខិតប្រគល់សិទ្ធិជូនមេធាវី អ៊ឹង វណ្ណៈ ចុះថ្ងៃទី ១៤-០២-២០០០ របស់ក្រុមហ៊ុន Dominern Somgiat & Boonma LTD តំណាងឱ្យក្រុមហ៊ុន Crocodile International Pte. LTD (CI) ប្រទេសសឹង្ហបួរី ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣- ទទួលពាក្យបណ្តឹងចុះថ្ងៃទី ២៨-១២-១៩៩៩ របស់ក្រុមហ៊ុន សានអាយភីអ័រ តំណាងឱ្យក្រុមហ៊ុន Lachemise Lacoste Company (LLC) ប្រទេសបារាំង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្តុយនឹងគតិច្បាប់ ។

៤- រឹបអូសប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្លឹងចំនួន ១៨០០ រៀល រង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់ ២០០ រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ៥០០០ រៀល សរុប ៧០០០ រៀល ប្រាក់នេះបានកាត់យកពីប្រាក់ ៧០០០ រៀល ដែលតំណាងដើមចោទបានបង់ទុកស្រេច ។

៥- ទទួលពាក្យបណ្តឹងតបចុះថ្ងៃទី ២៧-០៦-២០០០ របស់មេធាវី អ៊ឹង វណ្ណៈ តំណាងឱ្យក្រុមហ៊ុន Crocodile International Pte. LTD (CI) ប្រទេសសឹង្ហបួរី ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

៦- តម្កល់សេចក្តីសម្រេចចុះថ្ងៃទី ១៤-០៣-១៩៩៩ របស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា ស្តីពីការបដិសេធការសុំលប់ផ្លាកសញ្ញាម៉ាក Crocodile & Design ទុកជាបានការដែល ។

៧- អោយឈ្មោះ ជូ ចាន់ធីរ៉ា បង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្លឹងចំនួន ១៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់ ២០០ រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ៥០០០រៀល សរុប ៧០០០ រៀល ប្រាក់នេះបានកាត់យកពីប្រាក់ ៧០០០ រៀល ដែលឈ្មោះ អ៊ឹង វណ្ណៈបានបង់ទុកស្រេច ។

កាលបើហួសឧទ្ធរណ៍ បង្គាប់ឱ្យឈ្មោះ ជូ ចាន់ធីរ៉ា សងប្រាក់ ៧០០០ រៀលនេះ ឱ្យទៅឈ្មោះ អ៊ឹង វណ្ណៈវិញ ។

៨- សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខតំណាងគូក្តី បើកផ្លូវឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ០២"ឆ" ចុះថ្ងៃទី ១៧-០១-២០០១ របស់មេធាវី ជូ ចាន់ធីរ៉ា ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ៤៩ "ឆ" ចុះថ្ងៃទី ២០-១១-២០០០ របស់តុលាការក្រុងភ្នំពេញ លើសេចក្តីសម្រេចទាំងមូល ។

Scanned with CamScanner

បានឃើញសាលដីការដ្ឋប្បវេណីលេខ ០៩ "ឈ" ចុះថ្ងៃទី ១០-០១-២០០២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៧-០១-២០០១ របស់លោកមេធាវី ជូ ចាន់ធីរ៉ា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ៤៩"ឆ" ចុះថ្ងៃទី ២០-១១-២០០០ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០ រៀល ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់រួចហើយ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្មឹង ២.៥៥០ រៀល រង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់ ៤៥០ រៀល រង្វាន់អ្នកប្រគល់ដីការកោះ ៥០០០ រៀល និងចំណាយលើអាជ្ញាធរតុលាការ ៥.០០០ រៀល សរុប ១៣.០០០ រៀល ។

៤- សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខមេធាវីតំណាងគូក្តី ។ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៥៣ ចុះថ្ងៃទី ៧-០២-២០០២ របស់ ជូ ចាន់ធីរ៉ា ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៩ "ឈ" ចុះថ្ងៃទី ១០-០១-២០០២ របស់សាលាឧទ្ធរណ៍លើសេចក្តីសម្រេចទាំងមូល ។

បានឃើញសារណា ចុះថ្ងៃទី ០៩-០៩-២០០២ របស់លោក ជូ ចាន់ធីរ៉ា ។

បានឃើញសារណាតប ចុះថ្ងៃទី ២២-១១-២០០២ របស់លោក អៀង វណ្ណៈ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថាសាលដីការដ្ឋប្បវេណីលេខ០៩"ឈ"ចុះថ្ងៃទី ១០-០១-២០០២ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

សូមក្រុមប្រឹក្សាជំនុំជម្រះសម្រេចតាមច្បាប់ ។

លោក ជូ ចាន់ធីរ៉ា ជាមេធាវី និងជាតំណាងការពារឱ្យដើមចោទ ធ្វើសេចក្តីសន្និដ្ឋាននៅពេលសវនាការថា : ខ្លួនពុំសុខចិត្តនឹងសេចក្តីសម្រេចរបស់តុលាការក្រុងភ្នំពេញ និងសាលាឧទ្ធរណ៍ រូបភាពក្រពើនេះបានមកពីអ្នកតូកែវាយសីម្នាក់ ពេលនេះក្រុមហ៊ុននេះបានយកមកផ្សាយពាណិជ្ជកម្ម ដែលធ្វើឱ្យមានការល្បីល្បាញ ហើយក្រុមហ៊ុន LLC បានចុះបញ្ជីពាណិជ្ជសញ្ញារូបក្រពើ Lacoste ចំនួន ១៨៦ ប្រទេស លើពិភពលោក រួមទាំងប្រទេសកម្ពុជាផង ដែលបានចុះបញ្ជីតាំងពីថ្ងៃទី ១៥-០៦-១៩៩២ ។ ឯការប្រើពាណិជ្ជសញ្ញារបស់ក្រុមហ៊ុនចុងចមួយ ពុំមានកើតឡើងពីប្រវត្តិដើមពិតនៃឈ្មោះភូមិសាស្ត្រ ឬឈ្មោះនៃអ្នកបង្កើតក្រុមហ៊ុនមុនគេនៃក្រុមហ៊ុនចុងចមួយទេ ។ នេះបង្ហាញឱ្យឃើញថា ក្រុមហ៊ុន Crocodile International ជ្រើសរើសពាណិជ្ជសញ្ញារូបក្រពើ Crocodile លើផលិតផលរបស់ខ្លួនត្រាប់តាមក្រុមហ៊ុន LLC ដែលប្រើប្រាស់ពាណិជ្ជសញ្ញារូបក្រពើដែលសាធារណៈជនបាននិយមប្រើប្រាស់រួចមក ហើយធ្វើឱ្យសាធារណៈជនភ័ន្តច្រឡំថា ផលិតផលរបស់ក្រុមហ៊ុនចុងចំលើយក៏ជាផលិតផលរបស់ក្រុមហ៊ុន LLC ដែរ លុះដល់អតិថិជនយកទៅប្រើប្រាស់ទៅមានគុណភាពអន់ ក៏យល់ថាផលិតផលរបស់ក្រុមហ៊ុន LLC ធ្លាក់គុណភាពមិនល្អដូចដែលគេប្រើប្រាស់ពី

Scanned with CamScanner

មុនមក ។ ហើយក្រុមហ៊ុន LLC បានចុះបញ្ជីនៅថ្ងៃទី ១៥-០៦-១៩៩២ មុនការចុះបញ្ជីពាណិជ្ជសញ្ញារបស់ក្រុមហ៊ុន Crocodile International គឺនៅថ្ងៃទី ២២-០២-១៩៩៣ ។ ហើយផលិតផល Crocodile របស់ក្រុមហ៊ុន CI ទើបតែមានប្រើប្រាស់លក់ដូរនៅប្រទេសកម្ពុជាយើងសម័យនេះទេ ពីមុនមក ប្រជាពលរដ្ឋមិនដែរស្គាល់ឡើយ ។ ដូចនេះ យើងឃើញថាផលិតផលទាំងពីរក្រុមហ៊ុននេះពិតជាមានលក្ខណៈដូចគ្នា ឬស្រដៀងគ្នាបេះបិទ ព្រោះផ្លាកសញ្ញាទាំងពីរ គឺសត្វក្រពើដូចគ្នា ។

ដូចនេះ ខ្លួនសុំប្តឹងពីការភ័ន្តច្រឡំផ្លាកសញ្ញារូបក្រពើរបស់ Lacoste និង Crocodile ហើយ Crocodile មានដាក់សញ្ញារូបក្រពារ ហើយមិនបានសរសេរអក្សរនៅខាងក្រោមទេ ហើយអក្សរខ្លះតូច១មើលមិនចង់ឃើញ ដោយសារការភ័ន្តច្រឡំនេះហើយទើបខ្លួនប្តឹងទៅតុលាការ ។ ខ្លួនបានចុះបញ្ជីនៅប្រទេសឥណ្ឌូនេស៊ី ម៉ាឡេស៊ី ថៃឡង់ និងនៅសាំងហ្គាពួរ ហើយចំពោះការប្តឹងផ្តល់នៅប្រទេសទាំងនេះខ្លួនមិនបានដឹងទេ គ្រាន់តែបានចុះបញ្ជី Lachemise Lacoste មានពណ៌បៃតង ហើយពណ៌វាប្រែប្រួលទៅតាមផលិតផល ។ ចំពោះផលិតផលមួយចំនួនដាក់តែរូបក្រពើទេ តែខ្លះទៀតដាក់រូបក្រពើ ហើយដាក់អក្សរតូចថា Lacoste ។ អតិថិជនមួយចំនួនច្រើននិយាយថា រូបក្រពើមិនល្អធ្វើឱ្យមានការភ័ន្តច្រឡំដល់អតិថិជន និងប៉ះពាល់ដល់ផលប្រយោជន៍ក្រុមហ៊ុន Lacoste ។ ខ្លួនសុំបដិសេធសាលដីកាសាលាឧទ្ធរណ៍ និងសុំបង្វិលសំណុំរឿងទៅសាលាឧទ្ធរណ៍វិញ ។

លោក អៀង វណ្ណៈ ជាមេធាវី និងជាតំណាងការពារឱ្យចុងចម្លើយធ្វើសេចក្តីសន្និដ្ឋាននៅពេលសាវនាការថា : សត្វក្រពើ និងក្រពា តំណាងដូចគ្នាគ្រាន់តែរស់នៅប្រទេសផ្សេងគ្នាដែលជាហេតុធ្វើឱ្យរូបរាងមានលក្ខណៈខុសគ្នា ដូចនេះវាមិនមានលក្ខណៈដូចគ្នាទេ ។ ក្រុមហ៊ុននេះបានបោះរូបក្រពើ "ក្រពា" ហើយបានដាក់អក្សរតូច១នៅខាងក្រោម Crocodile បើមានការភ័ន្តច្រឡំ គេមិនឱ្យធ្វើចរាចរនៅក្នុងប្រទេសគេទេ សូម្បីប័ណ្ណលិខិតបញ្ជាក់ពលកម្មក៏គាត់ចុះបញ្ជីឱ្យដែរ នេះបញ្ជាក់ថាគ្មានការភ័ន្តច្រឡំទេ ។ ចំពោះសត្វក្រពើ និងសត្វក្រពា ខ្លួនបានមើលស្បែវកៅបារាំង ចំពោះរូបសញ្ញាក្រពើ វាមានពណ៌មិនឡើងទេ ដូចលោកមេធាវីខាងលើនេះបានជំរាបហើយសំខាន់គឺ ការសរសេរអក្សរទេ គេដាក់រូបក្រពើ ហើយសរសេរអក្សរតែម្តង ។

ខ្លួនសុំឱ្យឯកឧត្តមប្រធានក្រុមប្រឹក្សាជំនុំជំរះ មេត្តាតម្កល់សាលដីកាទាំងពីរថ្នាក់ទុកជាបានការពេញទាំងមូល ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីគូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

<u>តុលាការកំពូល</u>

- បានឃើញបណ្តឹងសាទុក្ខលេខ ៥៣ ចុះថ្ងៃទី ៧-០២-២០០២ របស់លោក ជូ ចាន់ធីរ៉ា ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកឡើងនេះមកជំនុំជម្រះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ។

Scanned with CamScanner

- យល់ឃើញថា ការលើកឡើងរបស់លោក ជូ ចាន់ធីរ៉ា មេធាវីការពារឱ្យក្រុមហ៊ុន Lachemise Lacoste Company (LLC) ក្នុងសារណាចុះថ្ងៃទី ០៩-០៩-២០០២ ថា តាមអនុសញ្ញាទីក្រុងប៉ារីសឆ្នាំ ១៩៦៧ កិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជា និងសហរដ្ឋអាមេរិក ចុះថ្ងៃទី ០៤-១០-១៩៩៦ ស្តីពីទំនាក់ទំនងពាណិជ្ជកម្ម និងសិទ្ធិការពារកម្មសិទ្ធិបញ្ញា និងប្រកាសលេខ ៣៦៨ ព.ណ.ព.ក.ប.ប្រ របស់ក្រសួងពាណិជ្ជកម្ម បណ្តឹងរបស់ក្រុមហ៊ុន LLC សុំឱ្យក្រុមហ៊ុន CI លុបម៉ាកសញ្ញារូបក្រពើ ចៀសវាងការភ័ន្តច្រឡំដល់សាធារណៈជន វាជាការត្រឹមត្រូវនេះ គឺជាការភ័ន្តច្រឡំ ពីព្រោះថា :

  - ឈ្មោះម៉ាករបស់ក្រុមហ៊ុន CI សឹង្គបូរី គឺ CROCODILE ឯឈ្មោះម៉ាករបស់ក្រុមហ៊ុន LLC បារាំង គឺ LACOSTE ។
  - រូបភាពម៉ាករបស់ក្រុមហ៊ុន CI សឹង្គបូរី គឺ រូបសត្វក្រពើ ឯរូបភាពម៉ាករបស់ក្រុមហ៊ុន LLC បារាំងគឺ សត្វក្រពា ។

- បានឃើញថា ក្រុមហ៊ុន LACOSTE បានប្តឹងសុំលុបម៉ាកនេះនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ដោយបានបញ្ជូនឯកសារភ្ជាប់ជាមួយជាច្រើន នាយកដ្ឋានកម្មសិទ្ធិបញ្ញាបានធ្វើការសិក្សា និងស្រាវជ្រាវ ព្រមទាំងបានសន្និដ្ឋានថា ម៉ាកទាំងពីរនេះមិនអាចមានការភ័ន្តច្រឡំឡើយ ។

- បានឃើញថា ដើមចោទ និងចុងចម្លើយពុំបានចូលរួមសវនាការនេះទេ ប៉ុន្តែមេធាវីរបស់គូភាគីបានចូលរួម ដូចនេះតុលាការកំពូលជំនុំជម្រះរឿងនេះកំចាំងមុខគូភាគី ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- បានឃើញថា សាលដីការដ្ឋប្បវេណីលេខ ០៩ ឈ ចុះថ្ងៃទី១០-០១-២០០២ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

<u>ហេតុដូចនេះ</u>

<u>វិនិច្ឆ័យសេចក្តីចំពោះមុខមេធាវីគូភាគី កំចាំងមុខគូភាគី</u>

<u>ប៉ុន្តែ ចាត់ទុកជាចំពោះមុខ</u>

១- ទទួលបណ្តឹងសាទុក្ខលេខ ៥៣ ចុះថ្ងៃទី ០៧-០២-២០០២ របស់លោក ជូ ចាន់ធីរ៉ា ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ ០៩ ឈ ចុះថ្ងៃទី ១០-០១-២០០២ របស់សាលាឧទ្ធរណ៍ ទុកជាបានការទាំងមូល ។

៣- រឹបអូសប្រាក់ប្រដាប់ក្តី ចំនួន ១៩.០០០ រៀល ដែលអ្នកស្រី ពៅ គីមលី បានបង់រួចហើយគឺ :

  - ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង ៤.០០០ រៀល ប៉ុន្តែ ប្រាក់នេះត្រូវកាត់ចំនួន ៨០០ រៀល សម្រាប់រង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់ ។
  - ចំណាយលើការប្រគល់ដីកាកោះ ចំនួន ១៥.០០០ រៀល សរុប ១៩.០០០ រៀល ។

៤-សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៣-០៤-២០០៣ និងប្រកាសនៅថ្ងៃទី ០៨-០៤-២០០៣។

Scanned with CamScanner

២. កំរិណ : (សៀង ធិរិទ្ធ)

១- អង្គហេតុ

ក្រុមហ៊ុន La chemise Lacoste Company (LLC) ដែលជានីតិបុគ្គលនៃនីតិបារាំង បានប្រើប្រាស់ផ្លាកសញ្ញារបស់ខ្លួនរូបក្រពើ ក្នុងឆ្នាំ ១៩២៧ និងបានចុះបញ្ជីការពារផ្លាកសញ្ញាពាណិជ្ជកម្មរូបក្រពើនេះនៅប្រទេសកម្ពុជា តាំងពីឆ្នាំ ១៩៩២ ។ ក្រុមហ៊ុន Crocodile International Pte Ltd (CI) ប្រទេសសឹង្ហបូរី បានប្រើប្រាស់ផ្លាកសញ្ញាពាណិជ្ជកម្មដូចគ្នានេះមកចុះបញ្ជីការពារនៅប្រទេសកម្ពុជា ក្នុងឆ្នាំ ១៩៩៣ ដែលជាហេតុធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍នៃក្រុមហ៊ុន Lacoste ។ ដូចនេះ អ្នកប្រើប្រាស់អាចមានការភ័ន្តច្រឡំរវាងផលិតផលនៃក្រុមហ៊ុនទាំងពីរនេះ ។ ប៉ុន្តែនាយកដ្ឋានកម្មសិទ្ធិបញ្ញាបានបដិសេធលប់ចោលការចុះបញ្ជីការពារផ្លាក Crocodile & Design ។

២- នីតិវិធី

- ការផ្តើមបណ្តឹងទៅកាន់តុលាការ

អ្នកស្រី ពៅ គីមលី ដែលជាប្រធានក្រុមហ៊ុន SAN.I.P.R តំណាងឱ្យក្រុមហ៊ុន Lacoste (LLC) បានដាក់ពាក្យបណ្តឹងនៅថ្ងៃទី ២៨-១២-១៩៩៩ ទៅតុលាការក្រុងភ្នំពេញ ដើម្បីសុំលុបសេចក្តីសម្រេចចុះបញ្ជីសញ្ញាពាណិជ្ជកម្ម Crocodile & Design របស់ក្រុមហ៊ុន Crocodile (CI) ដែលត្រូវបានតំណាង ដោយមេធាវី អៀង វណ្ណៈ ហើយបានដាក់ពាក្យបណ្តឹងតបវិញចុះថ្ងៃទី ២៧-០៦-២០០០ ។

- សេចក្តីសម្រេចតុលាការថ្នាក់ដំបូង

តុលាការក្រុងភ្នំពេញបានចេញសាលក្រមចុះថ្ងៃទី ២០-១១-២០០០ ប្រកាសទទួលពាក្យបណ្តឹងរបស់ក្រុមហ៊ុន SAN.I.P.R តំណាងឱ្យក្រុមហ៊ុន Lacoste (LLC) ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោល ដោយផ្ទុយនឹងគតិច្បាប់ ។ ដូចនេះ តុលាការទទួលពាក្យបណ្តឹងតបរបស់មេធាវី អៀង វណ្ណៈ ដោយសំអាងថា សេចក្តីសម្រេចបដិសេធនូវការលប់ផ្លាកសញ្ញា Crocodile & Design ចុះថ្ងៃទី ១៨-០៦-១៩៩៩ របស់នាយកដ្ឋានកម្មសិទ្ធបញ្ញា ទុកជាបានការដដែល ។

- បណ្តឹងឧទ្ធរណ៍ និងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍

បណ្តឹងឧទ្ធរណ៍ត្រូវបានធ្វើឡើងនៅថ្ងៃទី ១៧-០១-២០០១ ប៉ុន្តែ សាលាឧទ្ធរណ៍បានសម្រេចនៅថ្ងៃទី ១០-០១-២០០២ តម្កល់សាលក្រមទុកជាបានការ ។

- បណ្តឹងសាទុក្ខ

ក្រុមហ៊ុន Lacoste (LLC) បានធ្វើបណ្តឹងសាទុក្ខ ។ ក្រុមហ៊ុននេះបានលើកសំអាងនៅក្នុងបណ្តឹងសាទុក្ខរបស់ខ្លួនថា តាមទស្សនៈជាប្រវត្តិសាស្ត្រ ក្រុមហ៊ុន Lacoste (LLC) បានជ្រើសរើសយកពាណិជ្ជសញ្ញារូបក្រពើ និងត្រូវបានចុះបញ្ជីនៅ ១៨៦ ប្រទេស រួមទាំងប្រទេសកម្ពុជាផងដែរ ។ ផ្ទុយទៅវិញ ពាណិជ្ជសញ្ញារបស់ក្រុមហ៊ុន Crocodile (CI) ពុំមានកើតឡើងពីប្រវត្តិណាមួយច្បាស់លាស់នោះទេ ។ ម្យ៉ាងទៀត ក្រុមហ៊ុន Lacoste (LLC) បានចុះបញ្ជីការពារនូវ

Scanned with CamScanner

ពាណិជ្ជសញ្ញារបស់ខ្លួននៅប្រទេសកម្ពុជាតាំងពីថ្ងៃទី ១៥-០៦-១៩៩២ ចំណែកឯ ក្រុមហ៊ុន Crocodile (CI) ទើបតែចុះបញ្ជីការពារនៅថ្ងៃទី ២២-០២-១៩៩៣ តែប៉ុណ្ណោះ ។

ម្យ៉ាងទៀត លក្ខណៈដែលនាំឱ្យមានការភ័ន្តច្រឡំដែរនោះ គឺ Crocodile & Device ប្រើប្រាស់នូវផ្លាកសញ្ញា Crocodile ដែលផ្លាកសញ្ញានេះ ជួនកាលមានសរសេរអក្សរនៅខាងក្រោម ប៉ុន្តែ អក្សរតូចៗមើលមិនចង់ឃើញ ។

អាស្រ័យដូចនេះ ដើមបណ្តឹងសាទុក្ខ សុំប្តឹងបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ ពីព្រោះថា ការប្រើប្រាស់ផ្លាកសញ្ញាពាណិជ្ជកម្មដូចគ្នា ឬប្រហាក់ប្រហែលគ្នាអាចនាំឱ្យសាធារណៈជនមានការភ័ន្តច្រឡំលើទំនិញនៃក្រុមហ៊ុនទាំងពីរនេះ ។

ឯភាគីចុងចម្លើយវិញ បានការពារដោយសំអាងថា សត្វទាំងពីរនេះមិនមានលក្ខណៈដូចគ្នាទេ ពីព្រោះមួយជាសត្វក្រពើពិតប្រាកដ ឯមួយទៀតជាសត្វក្រពា ។

ដូច្នេះភាគីចុងចម្លើយបានសុំឱ្យតម្កល់សេចក្តីសម្រេចរបស់តុលាការទាំងពីរថ្នាក់ទុកជាបានការដដែល ។

៣- បញ្ហាគតិយុត្ត

តើទង្វើរបស់ក្រុមហ៊ុនមួយដែលប្រើប្រាស់នូវផ្លាកសញ្ញាពាណិជ្ជកម្មស្រដៀងគ្នា នឹងផ្លាកសញ្ញាពាណិជ្ជកម្មរបស់ក្រុមហ៊ុនដ៏ល្បីល្បាញមួយ មានលក្ខណៈគ្រប់គ្រាន់ អាចចាត់ទុកជាការប៉ះពាល់ដល់ផលប្រយោជន៍របស់ក្រុមហ៊ុន ចុងក្រោយនេះដែរឬទេ ?

៤- សេចក្តីសម្រេចតុលាការកំពូល

តុលាការកំពូលបានបដិសេធបណ្តឹងសាទុក្ខ ដោយសំអាងថា ផ្លាកសញ្ញាពាណិជ្ជកម្មរបស់ក្រុមហ៊ុន Crocodile (CI) សឹង្ហបូរី គឺ CROCODILE ឯផ្លាកសញ្ញាពាណិជ្ជកម្មរបស់ក្រុមហ៊ុន Lacoste (LLC) បារាំង គឺ LACOSTE ។ លើសពីនេះទៀត រូបភាពផ្លាកសញ្ញារបស់ក្រុមហ៊ុន Crocodile (CI) សឹង្ហបូរី គឺ សត្វក្រពា ឯរូបភាពម៉ាករបស់ក្រុមហ៊ុន Lacoste (LLC) បារាំង គឺ សត្វក្រពើ ។

ឃ. និតិការខារ

រៀបចំសលាកប័ត្រសាលដីការបស់សាលាឧទ្ធរណ៍ ចុះថ្ងៃទី ២៦-០៩-២០០២

១. សាលដីកា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងរដ្ឋប្បវេណី

លេខ ៤៨៦/១៨-០៧-២០០២

Scanned with CamScanner

សាលដីកា **តាងនាមប្រជារាស្ត្រខ្មែរ**

លេខ:១៧៣ "ឈ"/២៦-០៥-២០០២ **សាលាឧទ្ធរណ៍ភ្នំពេញ**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសឱ្យប្រើតាមក្រិត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨-០២-១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ កាលពីថ្ងៃទី ២៦-០៥-២០០២ ដែលមានសមាសភាពដូចខាងក្រោមនេះ :

ក្រុមប្រឹក្សាជំនុំជំរះ

លោក សាលី ធារ៉ា ជាប្រធាន

លោក ធូ មណី ជាចៅក្រមប្រឹក្សា

លោក ងួន អ៊ីម ជាចៅក្រមប្រឹក្សា

តំណាងមហាអយ្យការ

លោក សរ យសថាវរៈ

ក្រមធ្វើបញ្ជីសវនាការ

លោក ប៉ុន សាវ៉ាត់

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងរដ្ឋប្បវេណីលេខ ៤៨៦ ចុះថ្ងៃទី ១៨-០៧-២០០១ រវាង

- ដើមចោទ និងជាចុងបណ្តឹងឧទ្ធរណ៍ :

១. ឈ្មោះ លឹម ធីតា ភេទ ស្រី អាយុ ២៥ ឆ្នាំ ជាតិ ខ្មែរ

២. ឈ្មោះ អ៊ុំ វិសាល ភេទ ប្រុស អាយុ ២៧ ឆ្នាំ ជាតិ ខ្មែរ

៣. ឈ្មោះ លៀង សុភា ភេទ ប្រុស អាយុ ២៥ ឆ្នាំ ជាតិ ខ្មែរ

អ្នកទាំងបីនាក់ មានទីលំនៅសព្វថ្ងៃភូមិចំបក់ ឃុំវល្លស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ តំណាងឱ្យកម្មកររោងចក្រកាត់ដេរ ។

មានឈ្មោះ លៀន ចិន្តា ជាមេធាវីការពារក្តី ។

- ចុងចម្លើយ និងជាដើមបណ្តឹងឧទ្ធរណ៍ឈ្មោះ ជា កី ភេទ ប្រុស អាយុ ៥០ ឆ្នាំ ជាតិ ខ្មែរ ទីលំនៅសព្វថ្ងៃ ផ្ទះលេខ ៥៦បេ ក្រុមទី ២២ ផ្លូវលេខ ៣២៨ សង្កាត់ទួលស្វាយព្រៃទី ២ ខណ្ឌចំការមន ក្រុងភ្នំពេញ តំណាងឱ្យក្រុមហ៊ុនកាត់ដេរ ។

អំពីវិវាទ : ប្តឹងសុំឱ្យកម្មករកាត់ដេរទាំង ០៧ នាក់ ចូលបំរើការងារក្នុងរោងចក្រវិញ និងទាមទារជម្ងឺចិត្តចំនួន ៥.០០០ ដុល្លារអាមេរិកក្នុងម្នាក់ ។ ។

តាមពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២២-០៤-២០០២ របស់ឈ្មោះ កៅ ជីងស៊ីង ប្តឹងឧទ្ធរណ៍ និងសាលក្រមរដ្ឋប្បវេណីលេខ ១២ ចុះថ្ងៃទី ១២-០៣-២០០២ របស់តុលាការខេត្តកំពង់ស្ពឺ លើចំណុចនៃសាលក្រមទាំងមូល ។

Scanned with CamScanner

ឯរឿងហេតុមានដូចតទៅ :

បានឃើញពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ លីម ធីតា, អ៊ី វិសាល និងឈ្មោះ ល្បែង សុភា តំណាងឱ្យកម្មករ រោងចក្រកាត់ដេរនៅវត្តចំបក់ (Cambodia Apparel industry Co.,Ltd) ប្តឹងសុំឱ្យកម្មករទាំង ០៧ នាក់ បានចូលបំរើការងារក្នុងរោងចក្រមវិញ និងសុំទាមទារជម្ងឺចិត្តចំនួន ៥.០០០ ដុល្លារអាមេរិក ក្នុងម្នាក់ៗ ដោយសំអាងហេតុថា រោងចក្របានបញ្ឈប់ការងារកម្មករ ដោយគ្មានមូលហេតុឡើយ ឯកម្មករទាំងនោះ ត្រូវខាងរោងចក្របញ្ឈប់ពីការងារ តាំងពីថ្ងៃ ០៥-០១-២០០០ មកម្ល៉ះ ។

បានឃើញចម្លើយដើមចោទឈ្មោះ លីម ធីតា "តំណាងកម្មករ" ឆ្លើយថា ខ្លួនសុំប្តឹងពីឈ្មោះ រ៉ូ ហ៊ីតហ្គ ជាអ្នកគ្រប់គ្រងកម្មករកាត់ដេរបានបញ្ឈប់ការងារខ្លួន ដោយពុំមានមូលហេតុ កាលពីថ្ងៃទី ០៤-០១-២០០០ ។ នៅថ្ងៃទី ០៣-០១-២០០០ ម៉ោង ៣ និង ៣០នាទី ក្នុងរោងចក្រមានប៉ូលីសហៅកម្មកឈ្មោះ ល្បែង សុភា, ហ៊ុន សុភាព, ភួង ទូច ទៅដោះស្រាយ ហើយខ្លួនក៏ទៅជាមួយដែរ ដោយគ្មានឈ្មោះ ថង ប៊ុនធីម និងនឿក ណែម ទៅផងដែរ ។ ពេលទៅដល់ស្នងការនគរបាលនោះ លោក ជា វុធ បានឃុំខ្លួនឈ្មោះ ល្បែង សុភា, ហ៊ុន សុភាព, ភួង ទូច ។ លុះដល់ថ្ងៃទី ០៤-០១-២០០០ ខ្លួនទៅធ្វើការនៅរោងចក្រ តែត្រូវសន្តិសុខប្រាប់ថា ឈ្មោះ រ៉ូ ប៊ីតហ្គ មិនឱ្យចូលទៅទេ ។ លុះស្អែកឡើងខ្លួនមករោងចក្រទៀត ហើយសន្តិសុខមិនឱ្យចូលដដែល ខ្លួនក៏មកប្តឹងមន្ទីរសង្គមកិច្ច ហើយខាងសង្គមកិច្ចបានចេញលិខិតលេខ ០២ សក.ចយខ ចុះថ្ងៃទី ១៤-០២-២០០០ ឱ្យកម្មករចូលធ្វើការវិញ ខ្លួនក៏យកលិខិតនេះទៅឱ្យរោងចក្រ តែគេនៅតែមិនឱ្យចូលធ្វើការដដែល ។

សំណូមពរសុំរោងរោងចក្រអនុវត្តតាមលិខិតរបស់មន្ទីរសង្គមកិច្ច និងទាមទារជម្ងឺចិត្តចំនួន ៥.០០០ ដុល្លារ-អាមេរិក ។

បានឃើញចម្លើយដើមចោទឈ្មោះ ល្បែង សុភា ឆ្លើយថា : ប្រធានក្រុមហ៊ុន Cambodia Apparel industry Co.,Ltd នេះ បានបញ្ឈប់ខ្លួនមិនឱ្យធ្វើការនៅក្នុងរោងចក្រ ដោយចោទប្រកាន់ខ្លួនថា បំផុសកម្មកររធ្វើកូដកម្ម នៅថ្ងៃទី ០៤-០៥-០៦ និងថ្ងៃទី ១៤-១៥-១៦ ខែ ធ្នូ ឆ្នាំ ១៩៩៩ ។ ម៉្យាងទៀតនៅថ្ងៃទី ១៦-១២-១៩៩៩ កម្មកររោងចក្របានចលនាឱ្យឈ្មោះ អ៊ុំ វិសាល ចូលធ្វើការវិញ ចំណែកខ្លួនធ្វើការធម្មតា ដោយកម្មករចលនាខ្លួនឯងនោះ ខ្លួនមិនដឹងឡើយ ហើយប្រធានក្រុមហ៊ុនបានបញ្ឈប់ខ្លួនមិនឱ្យធ្វើការ នៅថ្ងៃទី ០៥-០១-២០០២ សំណូមពរសុំឱ្យក្រុមហ៊ុនទទួលខ្លួនចូលធ្វើការវិញ និងសុំបើកប្រាក់ខែ ចាប់ពីថ្ងៃទីបញ្ឈប់ការងារ រហូតដល់ថ្ងៃចូលបំរើការងារវិញ និងទាមទារជម្ងឺចិត្តចំនួន ១.៥០០ ដុល្លារអាមេរិក ។ បានឃើញចម្លើយដើមចោទឈ្មោះ អ៊ុំ វិសាល ឆ្លើយថា : នាយកក្រុមហ៊ុន Cambodia Apparel industry Co.,Ltd បានបញ្ឈប់ការងារខ្លួន កាលពីថ្ងៃទី ០៣-០៣-២០០០ ដោយចោទខ្លួនថា : ឈប់ឥតច្បាប់ កាលពីថ្ងៃនោះ នៅក្នុងរោងចក្រ កម្មករទាំងអស់រួមទាំងខ្លួនផងបានធ្វើបាតុកម្ម ហើយនាយកក្រុមហ៊ុននោះ បញ្ឈប់ខ្លួនពីការងារដោយគ្មានមូលហេតុ រហូតដល់សព្វថ្ងៃនេះ ហេតុនេះ ខ្លួនសុំឱ្យក្រុមហ៊ុនទទួលខ្លួនធ្វើការវិញ និងសុំបើកប្រាក់ខែចាប់ពីថ្ងៃទីបញ្ឈប់ការងាររហូតដល់ថ្ងៃចូលបំរើការងារ និងទាមទារជម្ងឺចិត្តចំនួន ៣.០០០ ដុល្លារអាមេរិក ហើយសុំឱ្យក្រុមហ៊ុនអនុវត្តតាមលិខិតណែនាំរបស់ក្រសួងសង្គមកិច្ចលេខ ១០៦៥ សក. បយ ចុះថ្ងៃទី ២០-០៤-២០០០ ។

Scanned with CamScanner

បានឃើញចម្លើយរបស់ចុងចម្លើយឈ្មោះ កៅ ជីងស៊ីង "តំណាងក្រុមហ៊ុន" ឆ្លើយថា : កម្មកររោងចក្រត្រូវតែគោរពតាមបទបញ្ជាផ្ទៃក្នុងរបស់រោងចក្រ ហើយកម្មករធ្វើខុសនៅពេលធ្វើការងារ ដូចជាកម្មករបានប្រមូលផ្តុំគ្នាធ្វើកូដកម្ម នៅថ្ងៃទី ០៤-១២-១៩៩៩ ធ្វើកូដកម្មក្នុងរោងចក្រ នៅថ្ងៃទី ១៤,១៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ ធ្វើកូដកម្មម្តងទៀត និងនៅថ្ងៃទី ០៣-០១-២០០០ គឺធ្វើដោយគ្មានមូលហេតុឡើយ ។ បញ្ហាទាំងអស់នោះ ហើយដែលធ្វើឱ្យខ្លួនមិនអាចទទួលយកម្មករទាំងនោះ ចូលធ្វើការនៅក្នុងរោងចក្រខ្លួនបានឡើយ ។ .

បានឃើញចម្លើយសាក្សីដើមចោទឈ្មោះ ឱន ស្រីមុំ ឆ្លើយថា : នៅថ្ងៃទី-ខែ-ឆ្នាំ មិនចាំ ខាងក្រុមហ៊ុនកាត់ដេរនៅវត្តចំបក់បានបញ្ឈប់ខ្លួនដោយផ្ទេរការងារទៅកន្លែងផ្សេង ដែលខ្លួនពុំមានកំហុសឡើយ ទើបកូនក្រុមខ្លួនធ្វើកូដកម្មតវ៉ា ដើម្បីខ្លួនបានចូលធ្វើការកន្លែងដដែលវិញ តែខាងក្រុមហ៊ុនមិនឱ្យខ្លួនធ្វើទេ ហើយឱ្យខ្លួនធ្វើពាក្យសុំឈប់ខ្លួនឯង ។ គ្មានការពាក់ព័ន្ធជាមួយឈ្មោះ លឹម ធីតា នោះទេ ។

បានឃើញចម្លើយសាក្សីដើមចោទ ឈ្មោះ នៅ ច័ន្ទតារ៉ា បានឆ្លើយថា : នៅថ្ងៃ-ខែ-ឆ្នាំ មិនចាំ ថៅកែរោងចក្រវត្តចំបក់បានដកបុងបើកលុយ ហើយកម្មករតវ៉ាយកបុងបើកលុយវិញ ក៏កើតមានរឿងកើតឡើង ហើយថៅកែរោងចក្របានឱ្យឈ្មោះទៅប៉ូលីស ឱ្យប៉ូលីសហៅឈ្មោះ ហ៊ុន សុភាព, ភួង តូច ដោយមានការហៅប៉ូលីសដូច្នេះ ឈ្មោះ ភួង តូច ក៏ហៅ លឹម ធីតា ទៅជាមួយជួយដោះស្រាយ ។ លុះដល់ថ្ងៃចូលធ្វើការវិញ ខាងរោងចក្របានបញ្ឈប់ឈ្មោះ លឹម ធីតា មិនឱ្យធ្វើការម្តងទៀត ។

បានឃើញចម្លើយសាក្សីដើមចោទឈ្មោះ ឃុត ច័ន្ទតារា ឆ្លើយថា : រោងចក្រកាត់ដេរនៅវត្តចំបក់បានបញ្ឈប់ការងារឈ្មោះ អ៊ុំ វិសាល ដោយសារឈ្មោះនេះធ្វើកូដកម្មចំនួន ០៦ ថ្ងៃ ហើយក្រុមហ៊ុនចោទថា ឈប់ឥតច្បាប់ ហើយកម្មករក៏នាំគ្នាធ្វើកូដកម្មតវ៉ាទាំងអស់គ្នាទៅពីបញ្ហាចោទនេះ ។

បានឃើញចម្លើយដើមចោទឈ្មោះ ជុស សុខុម ឆ្លើយថា : នៅរោងចក្រកាត់ដេរមានធ្វើកូដកម្ម ដោយសាររោងចក្រកាត់ដេរបញ្ឈប់ការងារឈ្មោះ លឹម ធីតា, ភួ តូច, ល្បែង សុភា, ថង ប៊ុន, ឡឿក ណែម ទើបកម្មករធ្វើកូដកម្មដើម្បីទាមទារឱ្យឈ្មោះទាំងនោះបានចូលធ្វើការវិញ ។ កូដកម្មនេះ អ៊ុំ វិសាល ក៏ចូលរួមធ្វើដែរ គឺធ្វើចំនួន ០៦ ថ្ងៃ ហើយខាងរោងចក្រចោទ អ៊ុំ វិសាល ថា ឈប់ឥតច្បាប់ ហើយក៏បញ្ឈប់ការងារឈ្មោះនេះតែម្តង ។

បានឃើញលិខិតលេខ ០២ សកប.យខ ចុះថ្ងៃទី ១៤-០២-២០០០ របស់ក្រសួងសង្គមកិច្ច ស្តីពីការបញ្ឈប់កម្មករចំនួន ០៦ នាក់ របស់រោងចក្រកាត់ដេរ ។

បានឃើញលិខិតលេខ ១០៦៥ សក.បយ ចុះថ្ងៃទី ២០-០៤-២០០០ របស់ក្រសួងសង្គមកិច្ច ស្តីពីការអនុវត្តសេរីភាពសហជីព ។

បានឃើញរបាយការណ៍លេខ ៩០ សក.ប.អក ចុះថ្ងៃទី ០២-០៥-២០០០ និងរបាយការណ៍លេខ .៣៥ សកប.យខ ចុះថ្ងៃទី ០៩-០២-២០០០ របស់ក្រសួងសង្គមកិច្ច ស្តីអំពីដំណោះស្រាយវិវាទ រវាងឈ្មោះ លឹម ធីតា ជាមួយ និងក្រុមហ៊ុនកាត់ដេរ ។

Scanned with CamScanner

បានឃើញលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី ១៨-០៧-២០០២ របស់ឈ្មោះ កៅ ជីងស៊ីង មុខរបរគណនេយ្យករោងចក្រកាត់ដេរ សូមប្រគល់សិទ្ធិជូនទៅលោក ជា កី ភេទ ប្រុស អាយុ ៥០ ឆ្នាំ ដើម្បីដោះស្រាយរឿងក្តីនេះជំនួសខ្លួន ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១២ ចុះថ្ងៃទី ១២-០៣-២០០២ របស់តុលាការខេត្តកំពង់ស្ពឺ ដែលសម្រេចសេចក្តីដូចតទៅ :

១. ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ លីម ធីតា. ភួង តូច. អ៊ុំ វិសាល. ល្បែង សុភា តំណាងឱ្យកម្មករចំនួន ០៧ នាក់ ចុះថ្ងៃទី ២២-០៦-២០០០ ទុកជាត្រឹមត្រូវតាមទម្រង់ និងតតិច្បាប់ ។

២. បង្គាប់ឱ្យក្រុមហ៊ុនរោងចក្រកាត់ដេរ Cambodia Apparel industry Co.,Ltd នៅវត្តចំបក់ ឃុំវល្ល័ស ឱ្យទទួលយកកម្មករចំនួន ០៧ នាក់ ចូលបំរើការងារ ដោយរក្សាហានៈដើមវិញនូវកម្មករនិយោជិត ដែលនិយោជកបានលប់ឈ្មោះ មានរាយនាមដូចខាងក្រោម :

- ឈ្មោះ អ៊ុំ វិសាល
- ឈ្មោះ លីម ធីតា
- ឈ្មោះ ភួង តូច
- ឈ្មោះ ឡើក ណែម
- ឈ្មោះ ថង ប៊ុនធីម និង ឈ្មោះ ហ៊ុន សុភាព

ដោយមានការរំលឹកប្រាក់ឈ្នួលផង ចាប់ពីថ្ងៃបញ្ឈប់ការងាររហូតដល់ថ្ងៃប្រកាសសាលក្រមស្ថាពរ និងបង្គាប់ឱ្យបង់ប្រាក់ជម្ងឺចិត្តចំនួនស្មើនឹង ១.000 ដុល្លារអាមេរិក ។ សំណើលើសពីនេះ ត្រូវបដិសេធចោល តាមមាត្រា ៣៨៥ ស្តីពីច្បាប់ការងារនៃព្រះរាជក្រមលេខ ជសរ.កប ០៣៩៧/០១ ចុះថ្ងៃទី ១៣-០៣-១៩៩៧ ។

៣. បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ប្រដាប់ក្តីចំនួន ៧.000 រៀល ក្នុងនោះមានពន្ធចុះបញ្ជីក្តី និងពន្ធប្តឹងចំនួន ១៨00 រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន ២00 រៀល និងចំណាយលើអាជ្ញាធរកណ្តាលចំនួន ៥000 រៀល សរុបទាំង អស់ចំនួន ៧ 000 រៀល ។

៤. សាលក្រមនេះជំនុំជម្រះជាសាធារណៈចំពោះមុខគូក្តី និងបើកផ្លូវឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២២-០៤-២00២ របស់ឈ្មោះ កៅ ជីងស៊ីង ប្តឹងឧទ្ធរណ៍នឹងសាលក្រមរដ្ឋប្បវេណីលេខ ១២ ចុះថ្ងៃទី ១២-០៣-២00២ របស់តុលាការខេត្តកំពង់ស្ពឺ លើចំណុចនៃសាលក្រមទាំងមូល ។

បានឃើញរបាយការណ៍រឿងរបស់ចៅក្រមរបាយការណ៍នៃសាលាឧទ្ធរណ៍ ចុះថ្ងៃទី ៣0-0៨-២00២ ។

នាពេលសវនាការ

ដើមចោទឈ្មោះ លីម ធីតា ឆ្លើយថា : កំហុសដែលគាត់លើកឡើងថា ខ្លួនឥតបានបំពេញការងារ និងជេរប្រមាថនោះ ពុំសមហេតុសមផលទេ ។ មូលហេតុដែលកើតឡើងនោះ គឺដោយសារតែប្រធានរោងចក្រដកយកបុងកម្មករ ។ ក្នុងការតវ៉ានេះ ក៏មានប៉ូលីសមកអញ្ជើញកម្មករ ហើយក៏ឃុំខ្លួនកម្មករទាំងបីនាក់ ហើយប៉ូលីសបញ្ជូនខ្លួនមកវិញ

Scanned with CamScanner

ហើយគេមិនឱ្យចូលធ្វើការ ។ ការមិនឱ្យចូលធ្វើការ និងមិនឱ្យបុងកម្មករវិញ គឺនៅថ្ងៃទី ០៣ ។ ខ្លួនជាអនុប្រធានសហជីព គឺបានបោះឆ្នោតថ្ងៃទី ៣០-១០-១៩៩៩ ហើយគេចេញទិដ្ឋាការ ថ្ងៃទី ២១-០១-២០០០ ។ នៅពេលបង្កើសហជីព សហជីពមានសេរីភាពគ្រប់គ្រាន់ កាលណាបោះឆ្នោតរួចរាល់អស់ហើយនោះ គប្បីនិយោជិតទទួលស្គាល់ ។ ខ្លួនឥតបានញុះញង់ឱ្យកម្មករធ្វើកូដកម្មឡើយ ។ ការងារសហជីពមិនអាចយកម៉ោងក្នុងរោងចក្រមកបំពេញបានឡើយ កន្លងមក បើរោងចក្រឥតការងារធ្វើ គេមិនឱ្យជាលិខិត ជាលាយលក្ខណ៍អក្សរទេ គឺគេនិយាយប្រាប់ដោយផ្ទាល់មាត់ នេះមិនមែនជាកំហុសរបស់កម្មករទេ គឺកំហុសរបស់រោងចក្រ ។ ចំពោះការបើប្រាក់ខែ យើងមានបើកមែន តែមិនចាំថា បានយ៉ាងណានោះទេ ។ ឈ្មោះ ហ៊ុន សុភាព មានអត្តលេខ ២០០១ ប្រាក់ប្បៅវត្ស ៤០ ដុល្លារអាមេរិក ចូលធ្វើការនៅថ្ងៃទី ២០-០២-១៩៩៩ ហើយបញ្ឈប់ការងារនៅថ្ងៃទី ០៤-០១-២០០០ ។

ចំពោះការចោទប្រកាន់លើឈ្មោះ ហ៊ុន សុភាព របស់រោងចក្រ មិនត្រឹមត្រូវទេ ព្រោះប្រពន្ធគាត់មានជម្ងឺជាញឹកញាប់ ហើយអាចសុំច្បាប់ ។ តាមខ្លួនដឹង ការគម្រាមកំហែងសន្តិសុខនោះ គឺអ្នកផ្សេងឡើតមានបញ្ហាជាមួយសង្សារ ហើយអ្នកនោះ គេជាអ្នកប្រមាថ ហើយកាលនោះ កម្មករបានបោះឆ្នោតឱ្យលោក អ៊ុំ វិសាល ជាប់ជាតំណាងសហជីព ហើយផ្ទាល់ឱ្យមកធ្វើការនៅកន្លែងអ៊ុត ឱ្យទៅធ្វើជាសន្តិសុខវិញ ទើបបណ្តាលឱ្យកម្មករមានការរំជើបរំជួលប្រហែលតែពីរម៉ោងប៉ុណ្ណោះ ពុំមែនធ្វើកូដកម្មពីរ-បីថ្ងៃនោះទេ ។

សំណូមពរសុំឱ្យតម្កល់សាលក្រមរបស់តុលាការខេត្តកំពង់ស្ពឺទុកជាបានការដដែល ។

ដើមចោទឈ្មោះ អ៊ុំ វិសាល ឆ្លើយថា : ចំពោះការធ្វើកូដកម្មនៅថ្ងៃទី ២១ ដល់ថ្ងៃទី ២៦-០២-២០០០ បានធ្វើបាតុកម្មដែរ ។ ការបើកប្រាក់ខែ ខ្លួនឥតបានចាំទេ ។ ខ្លួនឈប់ពីថ្ងៃទី ២១,២២,២៣,២៤,២៥,២៦ គឺដោយសារខ្លួនសុំច្បាប់ ដើម្បីសុំធ្វើបាតុកម្ម ។ ការធ្វើកូដកម្មនេះ គឺដើម្បីធ្វើបានខ្លួនគ្រាន់តែជូនដំណឹងទៅរោងចក្រប៉ុណ្ណោះ ឯសហព័ន្ធសហជីពបានបំផុសកម្មករឱ្យធ្វើកូដកម្ម និងបាតុកម្មនៅភ្នំពេញ និងនៅរោងចក្រ ។

ដើមចោទឈ្មោះ អៀង សុភា ឆ្លើយថា ខ្លួនសូមបដិសេធការចោទប្រកាន់របស់លោកដំណាងរោងចក្រ ព្រោះថា នៅខែ សីហា នៅរោងចក្រឥតមានការងារធ្វើ ហើយរោងចក្របានឱ្យខ្លួនសំរាកពីការងារ តែខណៈនោះ ខែ ១២ ខ្លួនក៏ឥតបានឈប់ដែរ ។ ចំពោះថ្ងៃទី ២៤ ខ្លួនបានសុំប្រធានក្រុម ។ ខ្លួនទៅធ្វើការរហូតដល់ថ្ងៃទី ០៣-០១-២០០០ ជាថ្ងៃមានបញ្ហា ទើបខ្លួនឈប់ ។ នៅថ្ងៃទី ០៣-០១-២០០០ ខ្លួនឥតបានទទួលប្រាក់នៅឡើយទេ ។ ចំពោះការគំរាមកំហែងកាន់កាំបិត គឺគេចោទប្រកាន់ខ្លួនទាំងស្រុង ។ ឈ្មោះ អ៊ុំ វិសាល ចូលធ្វើការនៅថ្ងៃទី ០៣-០៣-១៩៩៩ មានប្រាក់ប្បៅវត្ស ៤០ ដុល្លារអាមេរិក ហើយបញ្ឈប់ការងារ លោក អ៊ុំ វិសាល នៅថ្ងៃទី ០១-០៣-២០០០ ។

ចុងចម្លើយឈ្មោះ ជា កី "តំណាងរោងចក្រកាត់ដេរ" ឆ្លើយថា មូលហេតុដែលរោងចក្រខ្លួនមិនទទួលកម្មករទាំង ០៣ នាក់នោះ ឱ្យចូលធ្វើការវិញ ពីព្រោះថា ឈ្មោះ លឹម ធីតា នេះ បានចូលបំរើការងារថ្ងៃទី ១៨-០២-១៩៩៩ នៅផ្នែកសាប់ ហើយត្រូវរោងចក្របញ្ឈប់នៅថ្ងៃទី ០៤-០១-២០០០ ។ កំហុសរបស់គាត់ "លឹម ធីតា" គឺពុំគោរពតាមវិន័យរបស់រោងចក្រតេ គឺនៅក្នុងមាត្រា ៨៣ នៃច្បាប់ការងារ ដោយបានញុះញង់កម្មករឱ្យចូលរួមធ្វើកូដកម្ម និងឧស្សាហ៍ចោលការងារ ដើម្បីបង្កាក់ការផលិតកម្ម និងបានបំផុសកម្មករមិនឱ្យចូលរួមផលិតកម្ម ។

Scanned with CamScanner

ឧទាហរណ៍ : បានបញ្ជូនទៅក្រុមសាច់របស់គាត់ "លីម ធីតា" មិនឱ្យដំណើរការការងារ ។ ឥទ្ធិពលរបស់គាត់ រូបភាពក្រុមរបស់គាត់ គឺគាត់តាំងខ្លួនរបស់គាត់ជាតំណាងកម្មករ ។ ឈ្មោះ លីម ធីតា ពុំមែនជាតំណាងសហជីពរបស់រោងចក្រខ្លួន "ជា កី" នោះទេ ។ កន្លងមកសមត្ថកិច្ចបានកោះហៅជាញឹកញាប់ ។ កំហុសទីពីរ គឺ គាត់បានជេរបញ្ឆោរទៅលើប្រធានក្រុម ។ រោងចក្រឥតបានដឹងថា អ្នកស្រី លីម ធីតា ទៅជាមួយអាជ្ញាធរទេ ។ កំហុសរបស់គាត់នៅថ្ងៃទី ០៣-០១-២០០០ មកធ្វើការតែមួយព្រឹក ។ ចំពោះកម្មករ ០៣ នាក់ ដែលអាជ្ញាធរហៅទៅ គឺកម្មករមានសកម្មភាពខ្លាំងក្លា ហើយកម្មករត្រូវគេអញ្ជើញដោយផ្ទាល់ ខ្លួនឥតបានដឹងទេ ។ ចំពោះ ហ៊ុន សុភាព មានកំហុសទីមួយ ឈប់ឥតច្បាប់ ទីពីរគំរាមកំហែង និងបំផុសកម្មករ ដើម្បីផ្អាកសកម្មភាពការងារ ដូចជាការគម្រាមកំហែងមកលើសន្តិសុខនៅថ្ងៃទី ២៦-១២-១៩៩៩ មានសន្តិសុខឈ្មោះ ឥត ស៊ីណាត ជាអ្នកដឹងឮ ដូចជាថ្ងៃទី ១៦-១២-១៩៩៩ វេលាម៉ោង ៧ ព្រឹក ។ ការឈប់ឥតច្បាប់នៅថ្ងៃទី ១០,១៥,២១,២២,២៣-១១-១៩៩៩ ។ ខែ ធ្នូ ថ្ងៃទី ១១, ១៧ ពេលល្ងាចថ្ងៃទី ២៥,២៩,៣០ ។ ខ្លួនសូមបញ្ជាក់ថា បុងនោះបានបញ្ជាក់ច្បាស់ថ្ងៃចូលធ្វើការ អត្តលេខ ពុំអាចកែប្រែបានឡើយ ។ ឈ្មោះ ល្បៀង សុភា មានកំហុសឈប់ឥតច្បាប់ និងគំរាមប្រធានរោងចក្រនៅថ្ងៃទី ២៧-១២-១៩៩៩ គឺគំរាមលោក ភូ ពេញ ដោយយកកាំបិតមកកំឡាចដល់រោងចក្រ ហើយកាំបិតនេះ ត្រូវបានស្នងការនគរបាលដកយកទៅរក្សាទុក ។ ការឈប់ឥតច្បាប់ខែ សីហា ឆ្នាំ ១៩៩៩ គឺឈប់នៅថ្ងៃទី ១៣,១៤,១៦,១៧,១៨,២៥,៣០ និងឈប់ឥតច្បាប់នៅខែ ធ្នូ ថ្ងៃទី ២៤,៣១ ។ ថ្ងៃទី ១៥ ពេលល្ងាចគាត់ "ល្បៀង សុភា" ឥតមកធ្វើការរហូតដល់ថ្ងៃនេះ ។ ចំពោះប្រាក់ខែ យើងបានបើកដល់ខែ មីនា ឆ្នាំ ២០០០ ។

លោក អ៊ុំ វិសាល បានឈប់ឥតច្បាប់ និងបានទទួលកំហុសពីរដង ហើយក្រុមហ៊ុនបានប្តូរការងារគាត់ពីផ្នែកមួយ ហើយក៏បានបង្កការអុកឡុកនាំឱ្យខកខានការធ្វើអាជីវកម្ម ។ ក្រោយពីបានធ្វើកិច្ចសន្យា ថ្ងៃទី ២៦-០១-២០០០ រួចមក នៅថ្ងៃទី ២១,២២,២៣,២៤,២៥,២៦,២៩ ខែ កុម្ភៈ គាត់ "អ៊ុំ វិសាល" ឈប់ឥតច្បាប់ទៀត ។ គ្រប់បញ្ហាទាំងអស់ បានប្តឹងទៅក្រសួងសង្គមកិច្ចដូចគ្នា គឺប្តឹងនៅថ្ងៃទី ០៤-០៣-២០០០ ។

ខ្លួនសូមជម្រាបជូនតុលាការថា ករណីឱ្យរោងចក្រទទួលយកកម្មករទាំង ០៧ នាក់នេះ ចូលបំរើការងារវិញនោះ គឺ មិនអាចទទួលបានទេ ហើយខ្លួនសំណូមពរ គឺ :

១. ខ្លួនសូមបដិសេធនូវសាលក្រមលេខ ១២ ចុះថ្ងៃទី ១២-០៣-២០០២ របស់តុលាការខេត្តកំពង់ស្ពឺចោល ។
២. សុំឱ្យកម្មករម្នាក់សងប្រាក់ដល់រោងចក្រក្នុងម្នាក់ៗ ចំនួន ២០០០ ដុល្លាអាមេរិក ដែលធ្វើឱ្យរាំងស្ទះដល់ផលិតកម្ម ។
៣. សុំឱ្យតុលាការពិចារណាលើកំហុសកម្មករទាំងនោះតាមច្បាប់ ។

មេធាវី ល្បៀន ចិន្តា សន្និដ្ឋានថា : បើផ្អែកតាមច្បាប់ការងារ ការឈប់នេះ បើឈប់ភ្លាមគប្បីដាក់ពិន័យ ។ ហេតុផលនៃការបញ្ឈប់ការងារនេះ គឺជាលេសដើម្បីបញ្ឈប់តំណាងសហជីព ពីព្រោះថា ការបង្ហាញហេតុផលរបស់គាត់ "ជា កី" ខុសគ្នារហូត ។

Scanned with CamScanner

យោងតាមប្រកាសរបស់ក្រសួងសង្គមកិច្ច បើភាគីណាមួយមិនអនុវត្តទេ ភាគីនោះជាអ្នកមានកំហុស ហើយក្រសួងសង្គមកិច្ច បានដាក់កំហិតឱ្យអ្នកទាំងអស់ចូលធ្វើការងារវិញ ។ ម៉្យាងវិញទៀត ក្រោយពីក្រសួងសង្គមកិច្ចដោះស្រាយរួចហើយ អស់រយៈពេលពីរខែ ក្រុមហ៊ុនមិនបានដោះស្រាយ និងមិនប្តឹងមកតុលាការទេ គឺ ក្រុមហ៊ុនផ្តល់សិទ្ធិក្នុងការតវ៉ាតាមផ្លូវតុលាការហើយ ។ សូមតុលាការតម្កល់សាលក្រមរបស់តុលាការខេត្តកំពង់ស្ពឺ ទុកជាបានការ ។

<u>តំណាងមហាអយ្យការសន្និដ្ឋាន :</u>

សុំឱ្យតុលាការសម្រេចសេចក្តីតាមច្បាប់ចុះ ។

- ក្រោយពីបានស្តាប់ចម្លើយគូភាគីឆ្លើយការណ៍ និងប្តឹងសុំ
- ក្រោយពីបានពិនិត្យលើកសុតាងដែលពាក់ព័ន្ធ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានតំណាងមហាអយ្យការ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

<u>សាលាឧទ្ធរណ៍</u>

យល់ឃើញថា បណ្តឹងឧទ្ធរណ៍របស់លោក កៅ ជីងស៊ីង តំណាងឱ្យរោងចក្រកាត់ដេរ Cambodia Apparel industry Co.,Ltd ចុះថ្ងៃទី ២២-០៤-២០០២ ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន យោងតាមបញ្ញត្តិមាត្រា ៧ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ។

យល់ឃើញថា វិវាទការងាររវាងរោងចក្រកាត់ដេរ Cambodia Apparel industry Co.,Ltd ជាមួយនិងកម្មករ ០៧ នាក់ ត្រូវបានអធិការកិច្ចការងារថ្នាក់ខេត្ត និងថ្នាក់ក្រសួងបានសម្របសម្រួលជាច្រើនលើកហើយ តែមិនបានសម្រេច ដោយហេតុថា ភាគីរោងចក្រពុំព្រមចូលដោះស្រាយ ។

យល់ឃើញថា ការមិនព្រមចូលខ្លួនដោះស្រាយរបស់និយោជក ទើបអធិការកិច្ចការងារបង្គាប់ឱ្យនិយោជកទទួលកម្មករទាំងអស់នោះចូលធ្វើការវិញ ហើយបើមិនព្រមចូលធ្វើការវិញទេនោះ ភាគីនិយោជកត្រូវដោះស្រាយប្រាក់បញ្ឈប់ការងារ និងប្រាក់រង្វាន់ផ្សេងៗដែលជាផលប្រយោជន៍របស់កម្មករ ដែលត្រូវបានទទួល ។

យល់ឃើញថា តាមការពិនិត្យក្នុងសំណុំរឿង និងឯកសារពាក់ព័ន្ធ ដែលភាគីនិយោជកដាក់ជាសំអាង បានបង្ហាញឱ្យឃើញថា កម្មករទាំងនោះអនុវត្តមិនបានត្រឹមត្រូវតាមបទបញ្ជារោងចក្រ គឺមានអ្នកខ្លះមានកំហុសច្រើនលើកមានចុះកិច្ចសន្យាទទួលកំហុស ខ្លះទៀតទទួលស្គាល់ថា មានការឈប់ច្រើនថ្ងៃ ដោយឥតច្បាប់ ដែលជាមូលហេតុនាំឱ្យភាគីនិយោជកមិនអាចទទួលឱ្យចូលធ្វើការវិញបាន ។

យល់ឃើញថា និយោជកនៅតែមិនព្រមទទួលឱ្យកម្មករទាំងនោះចូលធ្វើការវិញដែល ដោយហេតុថា ខ្លាចអ្នកទាំងនោះ អាចបង្កការអុកឡុកដល់ដំណើរការអាជីវកម្ម ធ្វើឱ្យបាត់បង់ផលប្រយោជន៍រួម រវាងកម្មករទូទៅ និងនិយោជក ហើយប្រតិភូបុគ្គលិកប្រចាំរោងចក្រក៏បានបដិសេធមិនឱ្យកម្មករទាំង ០៧ នាក់នេះ ចូលធ្វើការវិញដែរ ដែលជាមូលហេតុ គប្បីតុលាការពិចារណា ។

Scanned with CamScanner

យល់ឃើញថា ដើម្បីជាផលប្រយោជន៍សង្គម ប្រយោជន៍រួមរវាងកម្មករ និងនិយោជក ព្រមទាំងនិយោជកផងដែរ តុលាការគប្បីពិចារណាទៅលើការបញ្ឈប់ការងាររបស់និយោជកទៅលើកម្មករទាំងនោះ ដោយយោងតាមបញ្ញត្តិមាត្រា ៧៤,៧៥ និងមាត្រា ៧៩ នៃច្បាប់ការងារ ។

យល់ឃើញថាកម្មករដែលត្រូវនិយោជកបញ្ឈប់ការងារត្រូវបានទទួលផលប្រយោជន៍ពីនិយោជកដូចខាងក្រោម :

- ឈ្មោះ លឹម ធីតា ចូលធ្វើការនៅថ្ងៃទី ១៨-០២-១៩៩៩ ហើយត្រូវបញ្ឈប់ការងារនៅថ្ងៃទី ០៤-០១-២០០០ ដែលមានប្រៀវត្សមូលដ្ឋាន ៥០ ដុល្លារអាមេរិក ហើយត្រូវបានកំរៃនៃការជូនដំណឹងមុន ០៧ ថ្ងៃ ស្មើនឹង ២១ ថ្ងៃ គុណនឹង ៥០ ដុល្លារអាមេរិក ចែកនឹង ២៦ ស្មើនឹង ៤០.៣២ ដុល្លារអាមេរិក "(២១ថ្ងៃ x ៥០ ដុល្លា)/២៦ ថ្ងៃ = ៤០.៣២ ដុល្លារអាមេរិក" ។
- ឈ្មោះ ភូ តូច ចូលធ្វើការនៅថ្ងៃទី ០៤-០៦-១៩៩៩ ហើយត្រូវបញ្ឈប់ការងារនៅថ្ងៃទី ០៤-០១-២០០០ ដែលមានប្រាក់ប្រៀវត្សមូលដ្ឋាន ៤០ ដុល្លារអាមេរិក ហើយត្រូវបានកំរៃនៃការជូនដំណឹង ០៧ ថ្ងៃ, សោហ៊ុយបណ្តេញចេញ ០៧ ថ្ងៃ, សោហ៊ុយជម្ងឺចិត្ត ០៧ ថ្ងៃ ស្មើនឹង ៣២.១៣ ដុល្លារអាមេរិក "(២១ថ្ងៃ x 40 ដុល្លា)/២៦ ថ្ងៃ = ៣២.១៣ ដុល្លារអាមេរិក" ។
- ឈ្មោះ អ៊ុំ វិសាល ចូលធ្វើការនៅថ្ងៃទី ០៣-០៣-១៩៩៩ ហើយបញ្ឈប់ការងារនៅថ្ងៃទី ០៣-០៣-២០០០ មានប្រាក់ប្រៀវត្សមូលដ្ឋាន ៤០ ដុល្លារអាមេរិក ហើយត្រូវបានកំរៃនៃការជូនដំណឹងមុន ០៧ ថ្ងៃ, សោហ៊ុយបណ្តេញចេញ ០៧ ថ្ងៃ, សោហ៊ុយជម្ងឺចិត្ត ០៧ ថ្ងៃ ស្មើនឹង ២១ ថ្ងៃគុណនិង ៤០ ដុល្លារអាមេរិក ចែកនឹង ២៦ ថ្ងៃ ស្មើនឹង ៣២.១៣ ដុល្លា "(២១ថ្ងៃ x៤០ ដុល្លា)/២៦ ថ្ងៃ = ៣២.១៣ ដុល្លារអាមេរិក" ។
- ឈ្មោះ ល្បែង សុភា ចូលធ្វើការនៅថ្ងៃទី ០២-០៧-១៩៩៩ ហើយបញ្ឈប់ការងារនៅថ្ងៃទី ០៤-០១-២០០០ មានប្រាក់ប្រៀវត្សមូលដ្ឋាន ៤០ ដុល្លារអាមេរិក ហើយត្រូវបានប្រាក់កំរៃនៃការជូនដំណឹងមុន ០៧ ថ្ងៃ, សោហ៊ុយបណ្តេញចេញ ០៧ ថ្ងៃ, សោហ៊ុយជម្ងឺចិត្ត ០៧ ថ្ងៃ ស្មើនឹង ២១ ថ្ងៃ គុណនឹង ៤០ ដុល្លារអាមេរិក ចែកនឹង ២៦ ថ្ងៃ ស្មើនឹង ៣២.១៣ ដុល្លារអាមេរិក "(២១ថ្ងៃ x៤០ ដុល្លា)/២៦ ថ្ងៃ = ៣២.១៣ ដុល្លារអាមេរិក" ។
- ឈ្មោះ ឡឿក ណែម ចូលធ្វើការនៅថ្ងៃទី ០២-០៧-១៩៩៩ ហើយបញ្ឈប់ពីការងារនៅថ្ងៃទី ០៤-០១-២០០០ ដែលមានប្រាក់ប្រៀវត្សមូលដ្ឋាន ៤០ ដុល្លារអាមេរិក ហើយត្រូវបានកំរៃនៃការជូនដំណឹងមុន ០៧ ថ្ងៃ, សោហ៊ុយបណ្តេញចេញ ០៧ ថ្ងៃ, ហើយសោហ៊ុយជម្ងឺចិត្ត ០៧ ថ្ងៃ ស្មើនឹង ២១ ថ្ងៃ គុណនឹង ៤០ ដុល្លារអាមេរិក ចែកនឹង ២៦ ថ្ងៃ ស្មើនឹង ៣២.១៣ ដុល្លារអាមេរិក "(២១ថ្ងៃ x ៤០ ដុល្លា)/២៦ ថ្ងៃ = ៣២.១៣ ដុល្លារអាមេរិក" ។
- ឈ្មោះ ថង ប៊ុនធឹម ចូលធ្វើការនៅថ្ងៃទី ១៩-០៦-១៩៩៩ ហើយបញ្ឈប់ពីការងារនៅថ្ងៃទី ០៤-០១-២០០០ ដែលមានប្រាក់ប្រៀវត្សមូលដ្ឋាន ៤០ ដុល្លាអាមេរិក ហើយត្រូវបានកំរៃនៃការជូនដំណឹងមុន ០៧ ថ្ងៃ, សោហ៊ុយបណ្តេញចេញ ០៧ ថ្ងៃ, ហើយសោហ៊ុយជម្ងឺចិត្ត ០៧ ថ្ងៃ ស្មើនឹង ២១ ថ្ងៃ គុណនឹង ៤០ ដុល្លារអាមេ-

Scanned with CamScanner

រិក ចែកនឹង ២៦ ថ្ងៃ ស្មើនឹង ៣២.១៣ ដុល្លាអាមេរិក "(២១ថ្ងៃ x ៤០ ដុល្លា)/២៦ ថ្ងៃ = ៣២.១៣ ដុល្លារអាមេរិក" ។

- ឈ្មោះ ហ៊ុន សុភាព ចូលធ្វើការនៅថ្ងៃទី ២០-០១-១៩៩៩ ហើយបញ្ឈប់ពីការងារនៅថ្ងៃទី ០៤-០១-២០០០ ដែលមានប្រាក់ប្រៀវត្សមូលដ្ឋាន ៥០ ដុល្លារអាមេរិក ហើយត្រូវបានកំរៃនៃការជូនដំណឹងមុន ០៧ ថ្ងៃ, សោហ៊ុយបណ្តេញចេញ ០៧ ថ្ងៃ, ហើយសោហ៊ុយជម្ងឺចិត្ត ០៧ ថ្ងៃ ស្មើនឹង ២១ ថ្ងៃ គុណនឹង ៤០ ដុល្លារអាមេរិក ចែកនឹង ២៦ ថ្ងៃ ស្មើនឹង ៣២.១៣ ដុល្លារអាមេរិក "(២១ថ្ងៃ x ៥០ ដុល្លា)/២៦ ថ្ងៃ = ៤០.៣២ ដុល្លារអាមេរិក" ។

យល់ឃើញថា សាលក្រមតុលាការខេត្តកំពង់ស្ពឺលេខ ១២ ចុះថ្ងៃទី ១២-០៣-២០០២ ដែលបានសម្រេចឱ្យកម្មករទាំង ០៧ នាក់ចូលធ្វើការវិញ និងឱ្យនិយោជកសងសំណងជម្ងឺចិត្តទៅកម្មករទាំង ០៧ នាក់ចំនួន ១.០០០ ដុល្លារអាមេរិក ដោយយោងតាមបញ្ញត្តិមាត្រា ៣៨៥ នៃច្បាប់ការងារនោះ ពុំសមហេតុសមផលទេ ព្រោះថានៅក្នុងជំពូក ៤ ផ្នែកទី ៣ មាត្រា ៧៤ នៃច្បាប់នេះ បានទុកសិទ្ធិឱ្យនិយោជករំលាយកិច្ចសន្យាការងារតាមឆន្ទៈរបស់ខ្លួនបាន ហើយរឿងនេះ ដោយសារកម្មករមានកំហុស និយោជកបានជូនដំណឹង ០៧ ថ្ងៃមុន ស្របតាមមាត្រា ៧៥ ដែលតម្រូវឱ្យនិយោជកចេញប្រាក់សងទៅឱ្យកម្មករ ដោយផ្អែកតាមមាត្រា ៧៩ ដូចការយល់ឃើញខាងលើ ។

ដូច្នេះសាលក្រមរបស់តុលាការខេត្តកំពង់ស្ពឺខាងលើសម្រេចឡើងពុំបានត្រឹមត្រូវទេ គប្បីបដិសេធចោល ។

យល់ឃើញថា សំណូមពររបស់តំណាងរោងចក្រសុំទាមទារជម្ងឺចិត្តពីកម្មករក្នុងម្នាក់ៗចំនួន ២.០០០ ដុល្លារអាមេរិក ដោយសំអាងហេតុថា កម្មករទាំងអស់នេះ ធ្វើឱ្យខូចប្រយោជន៍នោះ សាលាឧទ្ធរណ៍មិនលើកយកមកពិចារណាទេ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តី

១. ទទួលបណ្តឹងឧទ្ធរណ៍របស់លោក កៅ ជីងស៊ុ តំណាងឱ្យរោងចក្រកាត់ដេរ Cambodia Apparel industry Co.,Ltd ចុះថ្ងៃទី ២២-០៤-២០០២ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២. បដិសេធសាលក្រមរដ្ឋប្បវេណីលេខ ១២ ចុះថ្ងៃទី ១២-០៣-២០០២ របស់តុលាការខេត្តកំពង់ស្ពឺ ចោលជាអសារបង់ ។

៣. ទទួលស្គាល់ការបញ្ឈប់ការងាររបស់និយោជកនៅលើកម្មករ ០៧ នាក់ ហើយបង្គាប់ឱ្យនិយោជកនៃរោងចក្រកាត់ដេរ Cambodia Apparel industry Co.,Ltd សងសោហ៊ុយបណ្តេញចេញ, សោហ៊ុយការជូនដំណឹងមុន និងសោហ៊ុយជម្ងឺចិត្ត ទៅកម្មករទាំង ០៧ នាក់ ដូចខាងក្រោម :

- សងទៅឈ្មោះ លឹម ធីតា អត្តលេខ ១១៤៤ ចំនួន ៤០.៣២ ដុល្លារអាមេរិក
- សងទៅឈ្មោះ ភូង តូច អត្តលេខ ២០១០ ចំនួន ៣២.១៣ ដុល្លារអាមេរិក
- សងទៅឈ្មោះ អ៊ុំ វិសាល អត្តលេខ ១២៣១ ចំនួន ៣២.១៣ ដុល្លារអាមេរិក
- សងទៅឈ្មោះ ល្បៀង សុភា អត្តលេខ ២៣៥០ ចំនួន ៣២.១៣ ដុល្លារអាមេរិក

Scanned with CamScanner

- សងទៅឈ្មោះ ឡឿក ណែម អត្តលេខ ២០១៣ ចំនួន ៣២.១៣ ដុល្លារអាមេរិក
- សងទៅឈ្មោះ ថង ប៊ុនធីម អត្តលេខ ២៣៦៤ ចំនួន ៣២.១៣ ដុល្លារអាមេរិក
- សងទៅឈ្មោះ ហ៊ុន សុភាព អត្តលេខ ២០០១ ចំនួន ៤០.៣២ ដុល្លារអាមេរិក

ការប្តឹងលើសពីនេះ បដិសេធចោល ។ តាមបញ្ញត្តិមាត្រា ៧៤, ៧៥ និង ៧៩ នៃច្បាប់ការងារ ចុះថ្ងៃទី ១០-០១-១៩៩៧ ។

៤. រឹមអូសប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣ ០០០ រៀល គឺពន្ធចុះបញ្ជីក្តី ពន្ធប្តឹង ២៥៥០ រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០ រៀល ចំណាយលើអ្នកប្រគល់ដីកាកោះ ៥០០០ រៀល និងលើអាជ្ញាធរតុលាការ ៥ ០០០ រៀល សរុប ១៣ ០០០ រៀល ។

៥. សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខតំណាងឱ្យដើមចោទឈ្មោះ លីម ធីតា, ល្បែង សុភា, អ៊ុំ វិសាល តំណាងក្រុមហ៊ុនកាត់ដេរជាចុងចម្លើយ លោក ជា កី កំប៉ាំងមុខឈ្មោះ ភូង តូច និងចំពោះមុខ មេធាវីការងារឱ្យដើមចោទ ។ បើផ្លូវប្តឹងឥវ៉ាក្នុងកំណត់ច្បាប់ ។

២. អំណែ : (អូដ្រេ ឆាអ៊ីន)

១. អង្គហេតុ

នៅថ្ងៃទី ០៥-០១-២០០០ និយោជិតចំនួន ០៧ នាក់ ត្រូវបានបណ្តេញចេញដោយក្រុមហ៊ុន Cambodia Apparel industry Co.,Ltd ។ និយោជិតទាំងអស់នេះអះអាងថា ការលុបចោលកិច្ចសន្យាការងាររបស់ពួកគាត់ ត្រូវបានធ្វើឡើងដោយគ្មានមូលហេតុត្រឹមត្រូវ វិវាទនេះធ្វើឱ្យពួកគាត់ជំទាស់ជាមួយក្រុមហ៊ុន។ អធិការកិច្ចការងារបានព្យាយាមក្នុងការសម្របសម្រួលជាច្រើនលើក តែគ្មានការឯកភាពគ្នានោះទេ ដោយហេតុថា ភាគីខាងនិយោជកអវត្តមាន ។ អធិការកិច្ចការងារបានចេញលិខិតចុះថ្ងៃទី ១៤-០២-២០០០ ដោយឱ្យនិយោជិតទាំងអស់នោះចូលបំពេញការងារក្នុងក្រុមហ៊ុនវិញ ឬបើមិនដូច្នេះទេ និយោជកត្រូវបង់នូវសោហ៊ុយជម្ងឺចិត្ត និងផលប្រយោជន៍ផ្សេងទៀត ។ លិខិតនេះពុំត្រូវបានអនុវត្តដោយនិយោជកនោះទេ ។

២. នីតិវិធី

- ការដាក់ពាក្យបណ្តឹងទៅតុលាការ និងអំណះអំណាងរបស់គូក្តី :

និយោជិតទាំងនោះ បានដាក់ពាក្យបណ្តឹងទៅតុលាការខេត្តកំពង់ស្ពឺ ដើម្បីទាមទារឱ្យពួកគេបានចូលបំពេញការងារក្នុងក្រុមហ៊ុនវិញ និងសោហ៊ុយជម្ងឺចិត្ត ។ និយោជិតម្នាក់ឈ្មោះ លីម ធីតា លើកឡើងនូវការលុបចោលកិច្ចសន្យាដោយគ្មានមូលហេតុត្រឹមត្រូវ ដោយហេតុថា នាងពុំត្រូវបានអនុញ្ញាតឱ្យចូលបំពេញការងារនោះទេ បន្ទាប់ពីនាងបានទៅជាមួយនិយោជិតបីនាក់ផ្សេងទៀត ដែលត្រូវបានកោះហៅនៅប៉ុស្តិ៍នគរបាល ។ និយោជិតចំនួន ០២ នាក់ផ្សេងទៀត ក៏បានលើកឡើងនូវអំណះអំណាងស្រដៀងគ្នាផងដែរ ដោយចាត់ទុកថា ពួកគាត់បានបំពេញការងារដូចធម្មតា ហើយពួក

Scanned with CamScanner

គាត់មិនដែលចូលរួមក្នុងការធ្វើកូដកម្មនោះទេ ។ ផ្ទុយមកវិញ ចុងចម្លើយ បានលើកឡើងថា ការលុបចោលកិច្ចសន្យាការងារត្រូវបានធ្វើឡើង ដោយមូលហេតុថា ពួកគាត់បានចូលរួមធ្វើកូដកម្ម ដោយគ្មានមូលហេតុ ប្រើអំពើហិង្សាផ្ទុយនឹងបទបញ្ជាផ្ទៃក្នុង ។

- សេចក្តីសម្រេចរបស់តុលាការថ្នាក់ទី ១ :

នៅថ្ងៃទី ១២-០៣-២០០២ តុលាការខេត្តកំពង់ស្ពឺ ទទួលពាក្យបណ្តឹងរបស់និយោជិតទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ដោយសម្រេចបញ្ជូលពួកគេទៅបំពេញការងារក្នុងក្រុមហ៊ុនវិញ ដោយសងប្រាក់ប្រៃវត្ស គិតចាប់តាំងពីថ្ងៃលុបចោលកិច្ចសន្យា រហូតដល់ថ្ងៃសាលក្រមចូលស្ថាពរ ហើយបង្គាប់ឱ្យនិយោជកបង់ប្រាក់ចំនួន ១.០០០ ដុល្លារអាមេរិក ជាសោហ៊ុយជម្ងឺចិត្ត ។

- បណ្តឹងឧទ្ធរណ៍

តំណាងរបស់ក្រុមហ៊ុនបានប្តឹងឧទ្ធរណ៍ ហើយលើកឡើងនូវកំហុសរបស់និយោជិត ដើម្បីអាចចាត់ទុកជាមូលហេតុនៃការបណ្តេញចេញ ជាពិសេសយោងតាមមាត្រា ៨៣ នៃច្បាប់ការងារឆ្នាំ ១៩៩៧ ដោយញុះញង់និយោជិតផ្សេងទៀតចូលរួមធ្វើកូដកម្ម និងបោះបង់ចោលចង្វាក់ផលិតកម្ម. ដោយមូលហេតុអវត្តមានគ្មានសុំលិខិតអនុញ្ញាត និងមាននិយោជិតម្នាក់ ក្នុងចំណោមពួកគេ ដោយមូលហេតុនៃការគម្រាមកំហែងនៅចំពោះមុខនិយោជិតផ្សេងទៀត ។

ចុងបណ្តឹងឧទ្ធរណ៍បានបដិសេធនូវកំហុស ដែលបានលើកឡើងខាងលើ ហើយស្នើសុំទៅតុលាការតម្កល់សាលក្រមរបស់តុលាការខេត្តកំពង់ស្ពឺ ។

៣. ចំណោទបញ្ហាគតិយុត្ត

តើកំហុសដែលលើកឡើងដោយនិយោជក ចំពោះនិយោជិត អាចជាមូលហេតុនាំឱ្យមានការលុបចោលកិច្ចសន្យាការងារមានរយៈពេលមិនកំណត់ដែរឬទេ ប្រសិនបើការលុបចោលនេះធ្វើឡើង ដោយគ្មានការជូនដំណឹងទុកជាមុនផងដែរ ?

៤. សេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍

សាលាឧទ្ធរណ៍ បានបដិសេធសាលក្រម ដោយសំអាងហេតុថា វាជាវិវាទមួយយ៉ាងខ្លាំងក្លាវាងនិយោជក និងនិយោជិតទាំង ០៧ នាក់ ដែលបានប្រព្រឹត្តនូវកំហុស ។ ហេតុដូច្នេះ ដើម្បីធានាផលប្រយោជន៍សង្គម ផលប្រយោជន៍របស់ក្រុមហ៊ុន និងរបស់និយោជិត សាលាឧទ្ធរណ៍បដិសេធការបញ្ជូលនិយោជិតទាំងនោះទៅធ្វើការនៅក្រុមហ៊ុនវិញ តែយោងតាមមាត្រា ៧៥. ៧៥ និង ៧៩ នៃច្បាប់ការងារឆ្នាំ ១៩៩៧ និយោជកត្រូវសងសោហ៊ុយបណ្តេញចេញ. សោហ៊ុយការជូនដំណឹងមុន និងសោហ៊ុយជម្ងឺចិត្ត ទៅនិយោជិត ។ ប៉ុន្តែ មាត្រា ៧៤. ពុំមែនមាត្រា ៣៨៥ នៃច្បាប់ការងារទេ ត្រូវអនុវត្ត ដែលមាត្រានេះចែងថា និយោជកអាចរំលាយកិច្ចសន្យាការងារជាឯកតោភាគីបាន ។ ការលុបចោលនេះ មានលក្ខណៈស្របច្បាប់ ដោយហេតុថា វាកើតចេញមកពីកំហុសរបស់និយោជិត ។ ក្នុងករណីនេះ និយោជិតក៏អាចលើកឡើងដើម្បីទទួលបាននូវសំណងការខូចខាត ។

Scanned with CamScanner

ផ្នែកទី ៣ : សលាកប័ត្រសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

តថាខណ្ឌទី ១: មុខងារនៃក្រុមប្រឹក្សាធម្មនុញ្ញ

យោងតាមរដ្ឋធម្មនុញ្ញ ២៤-០៩-១៩៩៣ ក្រុមប្រឹក្សាធម្មនុញ្ញមានមុខងារសំខាន់ពីរយ៉ាង :

- ***ការត្រួតពិនិត្យធម្មនុញ្ញភាព*** : ដែលជាមុខងារតម្រូវឱ្យមានការត្រួតពិនិត្យ ទៅលើលក្ខណៈស្រប ឬភាពស្របនៃអត្ថបទច្បាប់ទៅនឹងរដ្ឋធម្មនុញ្ញ ។ ការត្រួតពិនិត្យអាចធ្វើជាបច្ឆាកាល (មុនការចូលជាធរមាននៃច្បាប់) ឬជាអនាគតកាល (ក្រោយការចូលជាធរមាននៃច្បាប់) តាមការស្នើសុំឡើងដោយព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា សមាជិករដ្ឋសភាមួយភាគដប់ សមាជិកព្រឹទ្ធសភាមួយភាគដប់ និងតាមរយៈស្ថាប័នតុលាការ (ចំពោះតែករណីនៃការត្រួតពិនិត្យជាអនាគតកាល) ។ ការប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ មានលក្ខណៈចាំបាច់ និងបង្ខំ ចំពោះសេចក្តីព្រាងច្បាប់អង្គការ និងបទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងព្រឹទ្ធសភា ។ ក្រុមប្រឹក្សាធម្មនុញ្ញ មានរយៈពេល ៣០ ថ្ងៃ ចាប់គិតពីថ្ងៃដាក់ពាក្យបណ្តឹង ដើម្បីចេញសេចក្តីសម្រេចអំពីភាពស្របនៃអត្ថបទច្បាប់ និងបទបញ្ជាទាំងនេះ ជាមួយនឹងរដ្ឋធម្មនុញ្ញ ។

- ***ការត្រួតពិនិត្យភាពត្រឹមត្រូវនៃការបោះឆ្នោតសភាបញ្ជូតិ*** : ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ច ដោះស្រាយរាល់វិវាទដែលទាក់ទិនទៅនឹងការបោះឆ្នោត ដូចជាការរៀបចំបញ្ជីបោះឆ្នោត លិខិតរៀបចំបម្រុងការផ្សេងៗដែលនាំអោយការបោះឆ្នោតអាចធ្វើទៅបាន និងកិច្ចបោះឆ្នោតជាលំដាប់តែម្តង ។ ក្នុងចំនាស់អំពីការបោះឆ្នោតនេះ ក្រុមប្រឹក្សាធម្មនុញ្ញមានលក្ខណៈជាស្ថាប័នតុលាការដ៏ពិតប្រាកដ ។

តថាខណ្ឌទី ២ : រចនាសម្ព័ន្ធនៃសេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ មានទម្រង់បីបែប : សេចក្តីសម្រេចអំពីធម្មនុញ្ញភាព សេចក្តីសម្រេចអំពីការបកស្រាយច្បាប់ និងសេចក្តីសម្រេចអំពីវិវាទបោះឆ្នោត ។

១. សេចក្តីសម្រេចអំពីធម្មនុញ្ញភាព

សេចក្តីសម្រេចនេះរៀបចំឡើងជាពីរផ្នែកសំខាន់ : ផ្នែកដំបូងបង្ហាញអំពី "ទិដ្ឋាការ" ដែលជាសំណុំអត្ថបទច្បាប់ដែលទាក់ទង ដូចជារដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣. ព្រះរាជក្រមចុះថ្ងៃទី ៨-០៤-១៩៩៨ ប្រកាសអោយប្រើច្បាប់ស្តីអំពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ និងអត្ថបទច្បាប់ដទៃទៀត ព្រមទាំងបង្ហាញផងដែរអំពីបណ្តឹងសុំអោយមានការត្រួតពិនិត្យធម្មនុញ្ញភាព ។ ផ្នែកទីពីរនៃសេចក្តីសម្រេច គឺជាតួនៃសេចក្តីសម្រេចតែម្តងដែលត្រូវបានតាក់តែងឡើងជាពីរលំដាប់ : ដំបូងគឺ ដំណើរអង្គហេតុ ដែលរៀបចំឡើងដោយពាក្យចាប់ផ្តើមថា "ដោយយល់ឃើញថា" និងផ្នែកសេចក្តីសម្រេច ដែលបង្ហាញអំពីសេចក្តីសន្និដ្ឋានរបស់ក្រុមប្រឹក្សាទាំងមូល ។ ផ្នែកទីពីរនេះ គឺតែងចាប់ផ្តើមឡើងដោយពាក្យពីរឃ្លាថា :

Scanned with CamScanner

" បន្ទាប់ពីបានស្តាប់វាចយការណ៍នៃសមាជិកផ្ទៀវចាយការណ៍ បន្ទាប់ពីបានពិភាក្សាសំរេចទៅតាមច្បាប់ "

នៅក្នុងលំដាប់ដំបូង ដែលបង្ហាញអំពីដំណើរអង្គហេតុ គឺមានរៀបរាប់អំពីអង្គហេតុ ព្រមទាំងការពន្យល់ ឬការបញ្ជាក់អំណះអំណាងផ្សេងៗ ដែលជាសំអាងហេតុបង្ហាញឡើងដោយក្រុមប្រឹក្សាធម្មនុញ្ញ ។ ចំពោះអង្គហេតុ គឺសេចក្តីទាំងស្រុងនៃអត្ថបទច្បាប់ ដែលជាកម្មវត្ថុនៃពាក្យបណ្តឹងនេះ ។ មាត្រាដែលសង្ស័យថា មានលក្ខណៈផ្ទុយពីរដ្ឋធម្មនុញ្ញ ហើយតម្រូវអោយមានការត្រួតពិនិត្យនោះ នឹងត្រូវរៀបរាប់យ៉ាងពេញលេញ នៅក្នុងសេចក្តីសម្រេច មានន័យថា ក្រុមប្រឹក្សាធម្មនុញ្ញមិនធ្វើការរៀបរាប់នូវមាត្រាដទៃទៀត ដែលមានលក្ខណៈច្បាស់លាស់ថា មិនផ្ទុយទៅនឹងរដ្ឋធម្មនុញ្ញ ឬមាត្រាដែលមិនមែនជាកម្មវត្ថុនៃបណ្តឹងនោះឡើយ ។ មុននឹងផ្តល់ដំណោះស្រាយទៅលើធម្មនុញ្ញភាពនៃច្បាប់ ក្រុមប្រឹក្សាធម្មនុញ្ញតែងពិនិត្យជាមុននូវភាពត្រឹមត្រូវនៃនីតិវិធីដាក់ពាក្យបណ្តឹង ។

ចំពោះលំដាប់ទីពីរ ដែលបង្ហាញអំពីផ្នែកសេចក្តីសម្រេច យើងនឹងលើកមកនិយាយរួម នៅក្នុងចំនុចទី ២ បន្ទាប់នេះ ។

២. សេចក្តីសម្រេចអំពីការបកស្រាយអត្ថបទច្បាប់

ផ្នែកដំបូងគឺ ដូចគ្នាទៅនឹងសេចក្តីសម្រេចខាងលើដែរ ។ ចំពោះផ្នែកទី ២ សំអាងហេតុបង្ហាញអំពីដំណើរអង្គហេតុ មានន័យថា ជាការបង្ហាញអត្ថបទដែលចោទជាផលលំបាក និងបកស្រាយរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។ ផ្នែកសេចក្តីសម្រេច ត្រូវបានបែងចែកជាពីរប្រការ ។ ប្រការទី១ គឺជាដំណោះស្រាយស្តីពីការបកស្រាយអត្ថបទដែលស្នើសុំ ។ ប្រការនេះ គ្រាន់តែជាការសង្ខេបឡើងវិញនូវការវិភាគ ដែលត្រូវបានបង្ហាញក្នុងសំអាងហេតុ ។ ចំណែកប្រការទី ២ គឺបញ្ជាក់អំពីអំណាចនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ក្រោមទម្រង់ :

" សេចក្តីសម្រេចនេះ ធ្វើឡើងនៅរាជធានីភ្នំពេញ នៅថ្ងៃទី (កាលបរិច្ឆេទនៃសេចក្តីសម្រេច) ដោយក្រុមប្រឹក្សាធម្មនុញ្ញ នៅក្នុងសម័យប្រជុំពេញអង្គ ។ សេចក្តីសំរេចនេះ ចូលជាស្ថាពរ បិទផ្លូវតវ៉ា និងមានអានុភាពអនុវត្តទៅលើអំណាចសាធារណៈទាំងអស់ ហើយត្រូវចុះផ្សាយក្នុងរាជកិច្ច " ។

ឧទាហរណ៍ : សេចក្តីសម្រេចអំពីធម្មនុញ្ញភាព. ក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០០

ក្រុមប្រឹក្សាធម្មនុញ្ញ

អត្ថបទយោង {
- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ប្រកាសឱ្យប្រើច្បាប់ ស្តីអំពីការរៀប ចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៩៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីអំពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាធម្មនុញ្ញ
}

Scanned with CamScanner

សំអាងហេតុ

ពាក្យបណ្តឹង

- បានឃើញលិខិតរបស់ប្រធានរដ្ឋសភា លេខ ៨៥ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០ ស្នើសុំឱ្យមានការត្រួតពិនិត្យ ធម្មនុញ្ញភាពនៃច្បាប់ស្តីអំពីសវនកម្មនៃព្រះ រាជាណាចក្រកម្ពុជា ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួល នៅថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០ ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិកវាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

ផ្នែកសេចក្តីសម្រេច

និយ័តភាពនៃការប្តឹង

- យល់ឃើញថា រដ្ឋសភា និងព្រឹទ្ធសភា បានអនុវត្តត្រឹមត្រូវទៅតាមបែបបទដែលមានកំណត់នៅក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យអនុម័តច្បាប់ស្តីអំពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- យល់ឃើញថា រដ្ឋសភា បានអនុវត្តត្រឹមត្រូវទៅតាមបែបបទកំណត់ក្នុងវាក្យខណ្ឌទី ២ នៃមាត្រា ១៤០ នៃរដ្ឋធម្មនុញ្ញ ក្នុងការបញ្ជូនមកក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីត្រួតពិនិត្យធម្មនុញ្ញភាព មុនការឡាយព្រះហស្តលេខាប្រកាសឱ្យប្រើច្បាប់រៀបចំអង្គការនេះ
- យល់ឃើញថាទម្រង់នៃការតាក់តែង និងការអនុម័តច្បាប់នេះ គឺមិនមានលក្ខណៈផ្ទុយទៅនឹងរដ្ឋធម្មនុញ្ញនោះទេ

អង្គហេតុ (ខ្លឹមសារនៃមាត្រា)

-យល់ឃើញថា មាត្រា ៤០ នៃច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជាដែលចែងថា " គណៈកម្មាធិការអចិន្ត្រៃយ៍ នៃរដ្ឋសភា មានសិទ្ធិជ្រើសរើសសវនករពិសេសមួយ ដើម្បីត្រួតពិនិត្យឡើងវិញលើសកម្មភាព និងប្រតិបត្តិការរបស់អាជ្ញាធរសវនកម្ម" គឺមិនស្របទៅនឹងរដ្ឋធម្មនុញ្ញ ដោយហេតុថា ផ្ទុយទៅនឹងគោលការណ៍ដែលកំណត់ឡើងថា គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា មិនអាចតំណាងឱ្យរដ្ឋសភានៅគ្រប់កាលទេសៈឡើយ ។ គណៈកម្មាធិការអចិន្ត្រៃយ៍ មិនអាចតំណាងឱ្យរដ្ឋសភានៅក្នុងសម័យប្រជុំសភាឡើយ ជាពិសេសចំពោះករណីនៃកិច្ចការដ៏សំខាន់ ដូចជាការជ្រើសរើសសវនករពិសេសនេះ ។ ម៉្យាងទៀត មាត្រា ៨៤ នៃរដ្ឋធម្មនុញ្ញ កំណត់ថា នៅចន្លោះសម័យប្រជុំសភា គណៈកម្មាធិការអចិន្ត្រៃយ៍ ទទួលបន្ទុកលើការងារប្រចាំថ្ងៃប៉ុណ្ណោះ ។

អំណះអំណាងរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

សម្រេច :

ប្រការ ១ : ច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តរួចដោយរដ្ឋសភា នាថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០ និងដោយព្រឹទ្ធសភា នាថ្ងៃទី ២១ ខែ

Scanned with CamScanner

មករា ឆ្នាំ ២000 គឺស្របទៅនឹងរដ្ឋធម្មនុញ្ញ លើកលែងតែមាត្រា ៤០ ។

សេចក្តីសម្រេចស្តីពីធម្មនុញ្ញភាព

ប្រការ ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២000 ដោយក្រុមប្រឹក្សាធម្មនុញ្ញ ក្នុង សម័យប្រជុំពេញអង្គ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា និងមានអានុភាពអនុវត្តទៅលើអំណាចសាធារណៈទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។

៣. សេចក្តីសម្រេចអំពីវិវាទឆោះឆ្លោត

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញក្នុងករណីនេះ មានលក្ខណៈស្រដៀងគ្នានឹងសេចក្តីសម្រេចរបស់ស្ថាប័នតុលាការនីតិរូមដែរ ព្រោះថា ក្រុមប្រឹក្សាធម្មនុញ្ញដើរតួនាទីជាស្ថាប័នតុលាការពេញលក្ខណៈ ។ តួនាទីរបស់ស្ថាប័ននេះគឺស្វែងរកនូវដំណោះស្រាយចំពោះជំលោះដែលកើតឡើងរវាងដើមបណ្តឹង និងភាគីម្ខាងទៀតជាចុងចម្លើយ ទាក់ទិនទៅនឹងភាពត្រឹមត្រូវនៃការបោះឆ្នោត ។ សេចក្តីសម្រេចធ្វើឡើងជាពីរផ្នែក ដូចជាសេចក្តីសម្រេចត្រួតពិនិត្យធម្មនុញ្ញភាពដែរ ។

ផ្នែកទី ១ គឺចង្អុលបញ្ជាក់អំពីសំណុំអត្ថបទច្បាប់ដែលទាក់ទិន ដូចជា រដ្ឋធម្មនុញ្ញ ច្បាប់ស្តីអំពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ច្បាប់បោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ច្បាប់ស្តីអំពីវិសោធនកម្មច្បាប់បោះ-ឆ្នោត ព្រមទាំងមានរៀបរាប់អំពីពាក្យបណ្តឹង (សំបុត្រ និង របាយការណ៍ផ្សេងៗ) ។ ផ្នែកទី២ ដែលចាប់ផ្តើមជានិច្ចជាកាល ដោយឃ្លាដូចខាងក្រោម :

" បន្ទាប់ពីបានស្តាប់របាយការណ៍នៃសមាជិកវាយការណ៍

បន្ទាប់ពីបានស្តាប់ចម្លើយនៃភាគីទាំងអស់

បន្ទាប់ពីបានពិភាក្សាសម្រេចទៅតាមច្បាប់ " ស្ថិតនៅជាគោលការណ៍ដែលបែងចែកជាពីរវគ្គ ។ វគ្គដំបូង សំដៅទៅលើការពិនិត្យទៅលើភាពអាចទទួលបាននៃពាក្យបណ្តឹង ហើយនៅក្នុងវគ្គទី២ គឺ ផ្នែកសេចក្តីសម្រេច និងសំអាងហេតុ ។

- សំអាងហេតុតែងតែភ្ជាប់មកជាមួយនូវពាក្យ " ដោយយល់ឃើញថា " ។ ក្នុងមូលហេតុនេះ យើងឃើញមានការរៀបរាប់អំពីអង្គហេតុ និងវិចារណកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។ អង្គហេតុ បង្ហាញនូវកម្មវត្ថុនៃចំនាស់ ដែលអាចជាភាពមិនច្បាស់លាស់នៃការបោះឆ្នោត ការបដិសេធមិនអោយចុះឈ្មោះក្នុងបញ្ជីបោះឆ្នោត សុក្រឹតភាពនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬការជំទាស់ទៅនឹងលទ្ធផលនៃការបោះឆ្នោត ។ ដើមបណ្តឹង អាចជាបុគ្គលសាមញ្ញ ឬជាតំណាងអោយគណបក្សនយោបាយ ដែលបានចូលរួមការបោះឆ្នោត ។ ចំណែកចុងចម្លើយ ជានិច្ចជាកាលគឺជាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ វិចារណកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ គឺវិភាគទៅលើចារិកលក្ខណៈនៃអង្គហេតុ ការលើកឡើងនូវវិធានដែលត្រូវអនុវត្ត និងការអនុវត្តវិធានទៅក្នុងអង្គហេតុ ។ នីតិវិធីនេះ ជានិច្ចជាកាលមិនសូវត្រូវបានអនុវត្តតាមលំដាប់ដូច្នេះនោះទេ ។

Scanned with CamScanner

- ផ្នែកសេចក្តីសម្រេច ធ្វើឡើងក្រោមទម្រង់ជាប្រការផ្សេងៗ ដែលបង្ហាញអំពីដំណោះស្រាយវិវាទ ។ ដំណោះស្រាយនេះអាចជាការបដិសេធពាក្យបណ្តឹង ឬជាការតម្កល់បណ្តឹងទុកជាបានការ ដោយហេតុថាមានភាពត្រឹមត្រូវតាមច្បាប់ ។ ប្រការចុងក្រោយ គឺរៀបរាប់អំពីអំណាចនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ក្រោមទម្រង់ដូចគ្នានឹងទម្រង់ដែលយើងឃើញនៅក្នុងសេចក្តីសម្រេចត្រួតពិនិត្យអំពីធម្មនុញ្ញភាពខាងលើដែរ ។

ឧទាហរណ៍ : សេចក្តីសម្រេចអំពីការការបកស្រាយច្បាប់. ក្រុមប្រឹក្សាធម្មនុញ្ញ ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០០០

ក្រុមប្រឹក្សាធម្មនុញ្ញ

សំអាងហេតុ

អត្ថបទយោង
- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា ·
- បានឃើញព្រះរាជក្រមលេខ ០៨/រកម/០៩៩៨/០៦ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីអំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

ពាក្យបណ្តឹង
- បានឃើញលិខិតលេខ ២៥៨ /១០០០/ពស/អក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០០ របស់ប្រធានព្រឹទ្ធសភា ស្នើមកក្រុមប្រឹក្សាធម្មនុញ្ញ ដោយសុំឱ្យមានការបកស្រាយមាត្រា ១១២ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលអគ្គលេខាធិការ ដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០០
-បានឃើញឯកសារ ដែលទទួលបានពីរដ្ឋសភា ទាក់ទិនទៅនឹងកិច្ចពិភាក្សាលើមាត្រា ១១២ ថ្មី នៃរដ្ឋធម្មនុញ្ញ ។

ក្រោយពីបានស្តាប់រជ្ជការណ៍របស់សមាជិករាជការណ៍
ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

អង្គហេតុ(ខ្លឹមសារនៃមាត្រា)
- យល់ឃើញថា មាត្រា ៩៩ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចែងថា ព្រឹទ្ធសភា គឺជាស្ថាប័នដែលមាន អំណាចនីតិបញ្ញត្តិ
- យល់ឃើញថា ភារកិច្ចផ្នែកនីតិបញ្ញត្តិរបស់ព្រឹទ្ធសភា គឺត្រូវបានកំណត់រួចជាស្រេចដោយមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ។ ដូច្នេះ ភារកិច្ចដែលមានចែងក្នុងមាត្រា ១១២ ថ្មី នៃរដ្ឋធម្មនុញ្ញ : "ព្រឹទ្ធសភា មានតួនាទីសម្របសម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាល" គឺជាតួនាទីនយោបាយរបស់ព្រឹទ្ធសភា
- យល់ឃើញថា ព្រឹទ្ធសភា មានភារកិច្ចជួយធ្វើការសម្របសម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាល ដើម្បីរកដំណោះស្រាយនូវវិបត្តិនយោបាយ ក្នុងពេលដែល

Scanned with CamScanner

កើតមានឡើង ។ ការងារនេះ មានវិសាលភាពធំធេងដែលមិនអាច កំណត់ព្រំដែន ដោយលិខិតបទដ្ឋានគតិយុត្តអ្វីមួយ ឬដោយការបញ្ជាក់បន្ថែមក្នុងច្បាប់មួយក្រោយ ទៅលើមាត្រា ១១២ ថ្មីនោះទេ

ការបកស្រាយរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

- យល់ឃើញថា មាត្រា ១១២ ថ្មី បានផ្តល់អំណាចដល់ព្រឹទ្ធសភាក្នុងការធ្វើអន្តរាគមន៍ទាន់ពេលវេលា ដើម្បីស្វែងរកដំណោះស្រាយនូវរាល់វិបត្តិផ្សេងៗ ទោះធំ ឬតូច និងនូវរាល់កិច្ចការនយោបាយរវាងរដ្ឋសភា និងរាជរដ្ឋាភិបាល ដោយប្រើប្រាស់មធ្យោបាយផ្សេងៗ ដែលមាន និងមិនកំណត់រយៈពេល។ ការណ៍ដែលមាត្រា ១១២ថ្មី ផ្តល់ទៅឱ្យព្រឹទ្ធសភានូវសិទ្ធិអំណាច និងទំនុកចិត្ត បង្ហាញឱ្យឃើញថា តួនាទីសម្របសម្រួលផ្នែកនយោបាយរបស់ព្រឹទ្ធសភា គឺមានសារៈសំខាន់ណាស់ ចំពោះការរស់រានរបស់ប្រទេសជាតិ
- យល់ឃើញថា តាមរយៈបក្ខភាពផ្នែកនយោបាយ ព្រឹទ្ធសភាមានតួនាទីសម្របសម្រួលនយោបាយប្រកបដោយ ប្រសិទ្ធភាព រវាងរដ្ឋសភា និងរាជរដ្ឋាភិបាល
- យល់ឃើញថា តាមរយៈតួនាទីនយោបាយរបស់ខ្លួន ព្រឹទ្ធសភាពុំមានន្ទូវអំណាចចាប់បង្ខំទៅលើរដ្ឋសភា ក៏ដូចជារាជរដ្ឋាភិបាល ឱ្យអនុវត្តតាមការណែនាំរបស់ខ្លួននោះ ទេ។ កិច្ចសម្របសម្រួលរបស់ព្រឹទ្ធសភា អាចនឹងទទួលបានលទ្ធផលវិជ្ជមានបាន បើសិនរដ្ឋសភា និងរាជរដ្ឋាភិបាល ទទួលយកការឯកភាពព្រមព្រៀងគ្នា ។

សម្រេច :

ផ្នែកសេចក្តីសម្រេច

សេចក្តីសម្រេច

ប្រការ ១ : ដោយផ្អែកតាមការយល់ឃើញខាងលើ តួនាទីរបស់ព្រឹទ្ធសភា ក្នុងការសម្របសម្រួលកិច្ចការរវាងរដ្ឋសភា និងរាជរដ្ឋាភិបាល ដែលចែងក្នុងមាត្រា ១១២ ថ្មី នៃរដ្ឋធម្មនុញ្ញ គឺជាតួនាទីនយោបាយ ។

ប្រការ ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០០០ ដោយក្រុមប្រឹក្សាធម្មនុញ្ញ ក្នុង សម័យប្រជុំពេញអង្គ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា និងមានអានុភាពអនុវត្តទៅលើអំណាចសាធារណៈទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

Scanned with CamScanner

ឧទាហរណ៍ : សេចក្ដីសម្រេចអំពីវិវាទបោះឆ្នោត. ក្រុមប្រឹក្សាធម្មនុញ្ញ ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០៣

អត្ថបទច្បាប់

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៩៩៨/០៦ ចុះថ្ងៃទី ០៨-០៤-១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦-១២-១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧-០៩-២០០២ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-បានឃើញព្រះរាជសារលិខិតរបស់សម្ដេចក្រុមព្រះនរោត្តម រណឬទ្ធិ ប្រធានគណបក្សហ៊្វុនស៊ិនបិច លេខ ៦៨២ ហសប/ជស ចុះថ្ងៃទី ០៦-០៨-២០០៣ ផ្ទេរសិទ្ធិថ្វាយស្ដេចក្រុមឃុន នរោត្តម សីរីវុឌ្ឍ អគ្គលេខាធិការគណបក្សហ៊្វុនស៊ិនបិច ដើម្បីជាតំណាងក្នុងរឿងប្ដឹងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បណ្ដឹងលេខ ៦៥៧ ហសប/សរ ចុះថ្ងៃទី ០៧-០៨-២០០៣

ពាក្យបណ្ដឹង

-បានឃើញពាក្យបណ្ដឹងរបស់ស្ដេចក្រុមឃុន នរោត្តម សីរីវុឌ្ឍ អគ្គលេខាធិការគណបក្សហ៊្វុនស៊ិនបិច លេខ ៦៥៧ ហសប/សរ ចុះថ្ងៃទី ០៧-០៨-២០០៣ ប្ដឹងពីគណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោតដែលបានបំពេញភារកិច្ចរៀបចំការបោះឆ្នោតមានភាពលំអៀង អសមត្ថភាព ខ្ជិលច្រអូស និងគ្មានការទទួលខុសត្រូវនាំឱ្យលទ្ធផលនៃការបោះឆ្នោតផ្ទុយពីឆន្ទៈរបស់ប្រជាពលរដ្ឋ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ០៨-០៨-២០០៣ វេលាម៉ោង ១១:៣០ នាទី

-បានឃើញលិខិតរបស់គណបក្សហ៊្វុនស៊ិនបិចលេខ ៦៦៧ ហសប.សណ ចុះថ្ងៃទី ១១-០៨-២០០៣ ឧទ្ទេសនាមលោក សុន អារុណ ជាប្រធានការិយាល័យមេធាវី និងលោក ម៉ី ច័ន្ទវាសនា ជាប្រធានផ្នែករដ្ឋបាលមេធាវីរបស់គណបក្ស ដើម្បីបំពេញភារកិច្ចដាក់ពាក្យបណ្ដឹង និងចំនាក់ចំនងជាមួយក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញកំណត់ហេតុសួរយកចម្លើយ ដែលបញ្ជាក់បន្ថែមទៅលើពាក្យបណ្ដឹងរបស់គណបក្សហ៊្វុនស៊ិនបិច កាលពីថ្ងៃទី ១៥-០៨-២០០៣

-បានឃើញកំណត់ហេតុសួរយកចម្លើយ ពីតំណាងគណៈកម្មាធិការរៀបចំការបោះឆ្នោត កាល ពីថ្ងៃទី ១៥-០៨-២០០៣

-បានឃើញលិខិតពីងពាក់មេធាវីលេខ ៦៧៨ ហសប.សណ ចុះថ្ងៃទី ២០-០៨-២០០៣ របស់ស្ដេចក្រុមឃុន នរោត្តម សីរីវុឌ្ឍ អគ្គលេខាធិការគណបក្សហ៊្វុនស៊ិនបិច សុំឱ្យមេធាវី

Scanned with CamScanner

៦ រូប ដើម្បីជាតំណាងក្នុងពេលសវនាការរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញលិខិតលេខ ០៨.១៦៨៦/០៣ គ.ជ.ប ចុះថ្ងៃទី ២០-០៨-២០០៣ របស់ឯកឧត្តម អ៊ឹម សូស្តី ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចាត់តាំងតំណាង គ ជ ប ឱ្យចូលរួមក្នុងសវនាការជំនុំជម្រះរបស់ក្រុមប្រឹក្សាធម្មនុញ្ញ និងលិខិតលេខ ០៨. ១៦៩០/ ០៣/គ.ជ.ប ចុះថ្ងៃទី ២២-០៨-២០០៣ របស់ឯកឧត្តម អ៊ឹម សូស្តី ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្តីពីការបន្ថែមសមាជិក គ.ជ.ប ចំនួន ៣ រូប ដើម្បីចូលរួមក្នុងសវនាការជំនុំជម្រះរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

ក្រោយពីស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី

ក្រោយពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

ការទទួលពាក្យបណ្តឹង

-យល់ឃើញថា ស្តេចក្រុមឃុន នរោត្តម សិរីវុឌ្ឍ អគ្គលេខាធិការគណបក្សហ៊្វុនស៊ិនប៉ិច បានដាក់ពាក្យបណ្តឹងលេខ ៦៥៧ ហសប.សរ ចុះថ្ងៃទី ០៧-០៨-២០០៣ មកក្រុមប្រឹក្សាធម្មនុញ្ញ ។ ដោយផ្អែកតាមមាត្រា ១៣៦ ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ២៥ នៃព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨-០៤-១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បណ្តឹងនេះអាចទទួលយកមកពិនិត្យបាន

-យល់ឃើញថា បណ្តឹងនេះបានដាក់ក្នុងរយៈពេល ៧២ ម៉ោង បន្ទាប់ពីការប្រកាសលទ្ធផលបណ្តោះអាសន្នរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

អង្គហេតុ
(ខ្លឹមសារនៃមាត្រា)

-យល់ឃើញថា គណបក្សហ៊្វុនស៊ិនប៉ិច សុំប្តឹងពីគណកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលគេយល់ថា បានបំពេញភារកិច្ចរៀបចំការបោះឆ្នោតមានភាពលំអៀង អសមត្ថភាព ខ្ជីខ្ជា និងគ្មានការទទួលខុសត្រូវ នាំឱ្យលទ្ធផលនៃការបោះឆ្នោតផ្ទុយពីឆន្ទៈរបស់ប្រជាពលរដ្ឋ ។ ពាក្យបណ្តឹងនេះសុំឱ្យផ្តន្ទាទោសគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតតាមច្បាប់ជាធរមាន

-យល់ឃើញថា ពីដំបូងលោក សុន អរុណ បានឆ្លើយថា លោកមិនមែនជាតំណាងមេធាវីដើមបណ្តឹងទេ លោកជាមេធាវីតំណាងដើមចោទជាមួយនឹងមេធាវី ៥ នាក់ទៀត ។ ក្រោយពីឯកឧត្តមប្រធានសួរបញ្ជាក់ថា តើមានដើមបណ្តឹងមកទេ ពេលនោះលោក សុន អរុណ ឆ្លើយថា គាត់ជាមេធាវីតំណាងដើមបណ្តឹង ហើយឯកឧត្តមប្រធានអនុញ្ញាតឱ្យគាត់ឡើងនិយាយក្នុងនាមជាដើមបណ្តឹង ។ លោក សុន អរុណ ក៏ឡើងមកសុំប្តឹងក្រុមប្រឹក្សាធម្មនុញ្ញអំពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបានបំពេញភារកិច្ច

Scanned with CamScanner

រៀបចំការបោះឆ្នោតមានភាពលំអៀង អសមត្ថភាព ខ្វីខ្វា និងគ្មានការទទួលខុសត្រូវ នាំឱ្យលទ្ធផលនៃការបោះឆ្នោតផ្ទុយពីឆន្ទៈរបស់ប្រជាពលរដ្ឋ

-យល់ឃើញថា លោក មាន សខិ តំណាងឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានឆ្លើយដោះសាចំពោះមុខក្រុមប្រឹក្សាធម្មនុញ្ញថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានរៀបចំការបោះឆ្នោតស្របតាមច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងទៅតាមបទបញ្ជា និងនីតិវិធីរបស់ខ្លួន

-យល់ឃើញថា ឯកឧត្តមប្រធានបានសួរលោក សុន អរុណ ថាមានសាក្សីឬទេ ? លោក សុន អរុណ បានឆ្លើយថា មានសាក្សី ១៧៦ នាក់ តែមានវត្តមានតែ ៩៩ នាក់ ទេ។ ឯកឧត្តមប្រធានសុំឱ្យលោក សុន អរុណ នាំសាក្សីម្នាក់ក្នុងខេត្តណាមួយ ក្នុងរឿងណាមួយ មកបំភ្លឺក្រុមប្រឹក្សាជំនុំជម្រះអំពីភាពលំអៀងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ ប៉ុន្តែ លោក សុន អរុណ បែរជាសូរកលិខិតចាត់តាំងមេធាវីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងលិខិតតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទៅវិញ ។ ឯកឧត្តមប្រធាន សូរទៅតំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាចុងចម្លើយឱ្យបង្ហាញសាក្សី តែលោក មាន សខិ បានបញ្ជាក់ថា លោកគ្មានសាក្សីទេ មានតែឯកសារ និងមន្ត្រីរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់

-យល់ឃើញថា លោក សុន អរុណ បានលើកដៃ ហើយឡើងសួរឯកឧត្តមប្រធានក្រុមប្រឹក្សាជំនុំជម្រះរបស់ក្រុមប្រឹក្សាធម្មនុញ្ញ មានរួចហើយ

-យល់ឃើញថា លោក សុន អរុណ បានចោទក្រុមប្រឹក្សាធម្មនុញ្ញថា បានលាក់ទុកនីតិវិធីមិនឱ្យកូនក្តីដឹង ។ ឯកឧត្តមប្រធានក្រុមប្រឹក្សាជំនុំជម្រះបានបំភ្លឺលោក សុន អរុណ ថានីតិវិធីនេះបានកសាង និងផ្សព្វផ្សាយតាំងពីឆ្នាំ ១៩៩៨ ។ ពេលនោះមានមេធាវីម្នាក់របស់ដើមបណ្តឹងបានលើកដៃហើយក្រោកឡើងនិយាយថា ក្នុងចំណោមមេធាវីទាំង ៦ នាក់ ពុំមានអ្នកណាជាប្រធាននោះទេ

-យល់ឃើញថា ក្នុងខណៈនោះមេធាវីទាំង ៦ នាក់ របស់ដើមបណ្តឹង ក៏បានក្រោកឡើងដើរចេញពីសវនាការនៅម៉ោង ៨:៣២ នាទី

-យល់ឃើញថា ក្នុងពេលដំណាលគ្នានោះ ឯកឧត្តមប្រធានក្រុមប្រឹក្សាជំនុំជម្រះបន្តនីតិវិធីដោយសុំឱ្យសមាជិកក្រុមប្រឹក្សាជំនុំជម្រះសួរដើមចោទ និងចុងចម្លើយ ។ ឯកឧត្តមប្រាក់ សុខ បានសុំឱ្យលេខាអានកំណត់ហេតុសួរយកចម្លើយពីលោក សុន អរុណ ត្រង់ទំព័រទី ៤ កាល់ពីថ្ងៃទី ១៥-០៨-២០០៣ ។ លេខាបានអានថា លោក សុន អរុណ បានឆ្លើយថា : មិនប្តឹងពីលទ្ធផលនៃការបោះឆ្នោតទេ គឺប្តឹងអំពីការលំអៀងរបស់គណៈកម្មា

Scanned with CamScanner

អំណះអំណាងរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

ធិការជាតិរៀបចំការបោះឆ្នោត ទាំងតវិយាបទ និងទាំងការអនុវត្តរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

-យល់ឃើញថា ទោះបីជាមានការដកខ្លួនថយចេញពីសវនាការរបស់មេធាវីតំណាងឱ្យដើមបណ្តឹង ក៏ក្រុមប្រឹក្សាជំនុំជម្រះ នៅតែមានសុពលភាពគ្រប់គ្រាន់ក្នុងការបន្តនីតិវិធីជំនុំជម្រះក្នុងរឿងក្តីនេះ

-យល់ឃើញថា ពាក្យបណ្តឹងនេះ មិនប្តឹងពីលទ្ធផលនៃការបោះឆ្នោតទេ គឺប្តឹងអំពីអាកប្បកិរិយារបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតសុទ្ធសាធក្នុងការរៀបចំបោះឆ្នោត

-យល់ឃើញថា តាមមាត្រា ១២៦ ថ្មី និងវាក្យខណ្ឌទី ៣ នៃមាត្រា ១៥ ថ្មី នៃព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧-០៩-២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ការដាក់ទណ្ឌកម្មគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មិនមែនជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ

-យល់ឃើញថា ពុំមានមាត្រានៃច្បាប់ណាដែលចែងថា ក្រុមប្រឹក្សាធម្មនុញ្ញត្រូវដោះស្រាយបណ្តឹងរបស់គណបក្សនយោបាយដែលប្តឹងពីតវិយាបថ និងសកម្មភាពរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីផ្តន្ទាទោសតាមច្បាប់ជាធរមាននោះទេ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញពុំអាចឆ្លើយតបតាមពាក្យសុំរបស់គណបក្សហ៊្វុនស៊ិនប៉ិចបានឡើយ ។

សម្រេច

ចំពោះមុខគូភាគី

សេចក្តីសម្រេចស្តីពី ធម្មនុញ្ញភាព

មាត្រា ១ : ទទួលពាក្យបណ្តឹងលេខ ៦៥៧ ហសប.សរ ចុះថ្ងៃទី ០៧-០៨-២០០៣ របស់ស្តេចក្រុមឃុន នរោត្តម សិរីវុឌ្ឍ អគ្គលេខាធិការគណបក្សហ៊្វុនស៊ិនប៉ិច ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយបណ្តឹងនេះមិនស្ថិតនៅក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

មាត្រា ២ : សេចក្តីសម្រេចនេះ ប្រកាសនាសវនាការជាសាធារណៈនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥-០៨-២០០៣ ជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

Scanned with CamScanner

កថាខណ្ឌទី ៣ : វិធីសាស្ត្រក្នុងការធ្វើសលាកប័ត្រសេចក្តីសំរេចក្រុមប្រឹក្សាធម្មនុញ្ញ (ថេង ច័ន្ទសង្វារ)

សលាកប័ត្រសេចក្តីសម្រេចក្រុមប្រឹក្សាធម្មនុញ្ញ គឺជាការបង្ហាញដោយមិនលំអៀងនូវសេចក្តីសម្រេចនោះ ។ យើងត្រូវសំយោគសេចក្តីសម្រេចនោះ ប៉ុន្តែ មិនត្រូវធ្វើអោយបាត់បង់នូវធាតុសំខាន់ៗរបស់វាឡើយ ។ សលាកប័ត្រនេះមានបួនចំណុចសំខាន់គឺ : អង្គហេតុ នីតិវិធី បញ្ហាគតិយុត្ត ដំណោះស្រាយ ហើយអាចមានធាតុទីប្រាំបន្ថែមទៀតគឺ អនុភាព ឬសារៈសំខាន់របស់សេចក្តីសម្រេច ។

ក-អង្គហេតុ

ជាគោលការណ៍ អង្គហេតុគឺជាព្រឹត្តិការណ៍ទាំងឡាយដែលបង្កឡើងដោយមនុស្ស ឬដោយអ្វីៗផ្សេងៗទៀត ដោយចេតនា ឬអចេតនា ហើយដែលនាំអោយកើតជាវិវាទ ។នៅក្នុងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ អង្គហេតុភាគច្រើនមានលក្ខណៈស្រដៀង១គ្នា ហើយមិនសូវត្រូវបានលើកឡើងលំអិតដោយក្រុមប្រឹក្សាឡើយ ។

សំរាប់សេចក្តីសម្រេចដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ការត្រួតពិនិត្យធ្វើឡើងនៅខណៈឬនៅក្រោយការអនុម័តច្បាប់ ឬបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា ឬរបស់ព្រឹទ្ធសភា ដោយរដ្ឋសភា ឬ ដោយព្រឹទ្ធសភា ។

ចំពោះសេចក្តីសម្រេចពាក់ព័ន្ធនឹងការបកស្រាយបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ អង្គហេតុភាគច្រើនមានភាពទូលំទូលាយ ហើយជាទូទៅនាំអោយមានការលំបាកក្នុងការញែកអោយបានដាច់នូវហេតុផ្សេងៗ នៅក្នុងសេចក្តីសម្រេចនោះ ។ និស្សិតអាចគ្រាន់តែលើកនូវព្រឹត្តិការណ៍ណាមួយ ដែលនាំអោយមានបណ្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញជាការស្រេច។ ព្រឹត្តិការណ៍នោះអាចពាក់ព័ន្ធនឹងនយោបាយ ឬអាចជាបញ្ហាបច្ចេកទេសសុទ្ធសាធ ។

ចំពោះសេចក្តីសម្រេចពាក់ព័ន្ធនឹងវិវាទនៃការបោះឆ្នោត និស្សិតត្រូវរៀបរាប់ឡើងវិញនូវព្រឹត្តិការណ៍ ដែលបានកើតឡើងមុនការប្តឹងមកក្រុមប្រឹក្សាធម្មនុញ្ញ មានន័យថា និស្សិតត្រូវមានសមត្ថភាពញែកនូវហេតុការណ៍ជាច្រើនដែលកើតឡើងបន្តបន្ទាប់គ្នា ។

ខ-នីតិវិធី

នៅក្នុងនីតិវិធី និស្សិតបញ្ជាក់អំពីបុគ្គលដែលប្តឹងមកក្រុមប្រឹក្សាធម្មនុញ្ញ ឬតួភាគីនៃវិវាទក្នុងករណីបណ្តឹងពាក់ព័ន្ធនឹងវិវាទនៃការបោះឆ្នោត ហើយត្រូវបញ្ជាក់អំពីប្រភេទនៃបណ្តឹង មានន័យថា តើជាបណ្តឹងសុំអោយបកស្រាយ ឬជាបណ្តឹងសុំអោយត្រួតពិនិត្យធម្មនុញ្ញភាព ។ ចុងក្រោយបង្អស់ និស្សិតត្រូវបញ្ជាក់អំពីទម្រង់របស់បណ្តឹង មានន័យថាជាបណ្តឹងផ្ទាល់មកក្រុមប្រឹក្សាធម្មនុញ្ញ ឬជាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់ស្ថាប័នរៀបចំការបោះឆ្នោតផ្សេងៗ ។

សំរាប់សេចក្តីសម្រេចពាក់ព័ន្ធនឹងការត្រួតពិនិត្យធម្មនុញ្ញភាពមុនចូលជាធរមាន បណ្តឹងត្រូវធ្វើឡើងដោយឥស្សរជនដែលមានចែងនៅក្នុងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញពោលគឺ ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា សមាជិករដ្ឋសភាមួយភាគដប់ ប្រធានព្រឹទ្ធសភា និងសមាជិកព្រឹទ្ធសភាមួយភាគបួន ។ ករណីការត្រួតពិនិត្យធ្វើឡើង

Scanned with CamScanner

ក្រោយការចូលជាធរមាន ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលបណ្តឹងពីតុលាការតាមស្មារតីនៃមាត្រា ១៤១ ថ្មី នៃរដ្ឋធម្ម-នុញ្ញ ។

ចំពោះសេចក្តីសម្រេចពាក់ព័ន្ធនឹងការបកស្រាយទាំងរដ្ឋធម្មនុញ្ញ ទាំងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រុមប្រឹក្សាធម្មនុញ្ញ ពុំមានបទដ្ឋានណាមួយបានបញ្ជាក់អោយច្បាស់អំពីបុគ្គលដែលអនុញ្ញាតអោយប្តឹងទៅក្រុម-ប្រឹក្សាធម្មនុញ្ញឡើយ។ ក្នុងការអនុវត្ត អ្នកធ្វើបណ្តឹងច្រើនតែបុគ្គលដដែល។ដែលមានចែងនៅក្នុងមាត្រា ១៤០ និង ១៤១ ថ្មីនៃរដ្ឋធម្មនុញ្ញ ។

ចំពោះសេចក្តីសំម្រេចពាក់ព័ន្ធនឹងវិវាទនៃការបោះឆ្នោត នីតិវិធីមានលក្ខណៈស្មុគ្រស្មាញជាងករណីផ្សេង។ទៀត ។ និស្សិតត្រូវបញ្ជាក់អំពីប្រភេទនៃបណ្តឹង និងគូភាគីនៃវិវាទ ។ ជាធម្មតា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គឺជា ចុងចម្លើយជានិច្ច រីឯដើមបណ្តឹងអាចជាបុគ្គលឯកជន ឬជាគណបក្សនយោបាយ ។ និស្សិតត្រូវបញ្ជាក់ផងដែរថា តើតាម រយៈបណ្តឹងនោះក្រុមប្រឹក្សាធម្មនុញ្ញគឺជាចៅក្រមជំនុំជម្រះជាលើកទី ១ និងជាលើកចុងក្រោយ ឬជាចៅក្រមឧទ្ធរណ៍ ។

គ-បញ្ហាគតិយុត្ត

គ្រប់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទាំងអស់ សុទ្ធតែឆ្លើយទៅនឹងបញ្ហាមួយ ឬច្រើនដែលត្រូវបាន ដាក់មកក្រុមប្រឹក្សា ។ និស្សិតត្រូវលើកបង្ហាញអំពីបញ្ហានោះ ។ បញ្ហាគតិយុត្តនៅក្នុងសេចក្តីសម្រេចមួយអាចប្លែក។ គ្នាច្រើន ។ និស្សិតមិនគួរលើកបញ្ហាគតិយុត្តអោយលើសពីពីរឡើយ ។

ឃ-ដំណោះស្រាយ

ចម្លើយទៅនឹងបញ្ហាគតិយុត្តបង្កើតបានជាដំណោះស្រាយចំពោះសេចក្តីសម្រេច ។ នៅពេលបង្ហាញដំណោះ ស្រាយរបស់ក្រុមប្រឹក្សាធម្មនុញ្ញ និស្សិតមិនត្រូវភ្លេចលើកអំពីសំអាងហេតុដែលអនុញ្ញាតអោយគេយល់អំពីអត្ថន័យ របស់សេចក្តីសម្រេចឡើយ ។

ង-អានុភាព

សាស្ត្រាចារ្យមិនសូវតម្រូវអោយនិស្សិតវិភាគទៅលើអានុភាព ឬសារៈសំខាន់របស់សេចក្តីសម្រេចនោះទេ ។ ភាគច្រើនគេតែងលើកចំណុចនេះមកធ្វើការពិភាក្សារួមគ្នានៅមៅងការងារប្រតិបត្តិ ។ ចំណុចនេះមានលក្ខណៈពិបាក ព្រោះយើងមិនអាចទាញវាចេញពីសេចក្តីសម្រេចទាំងស្រុងឡើយ ។ គេតែងសិក្សាអំពីអានុភាពនៃសេចក្តីសម្រេចនៅ ក្នុងលំហាត់មួយផ្សេង។ទៀតដែលមានឈ្មោះថា អត្ថាធិប្បាយសេចក្តីសំម្រេចតុលាការ ។ ត្រង់នេះតម្រូវអោយនិស្សិត កំណត់អំពីអត្ថប្រយោជន៍របស់សេចក្តីសម្រេចចំពោះនីតិជាទូទៅ ។

ដើម្បីរកអោយឃើញនូវអត្ថប្រយោជន៍នោះ និស្សិតមិនត្រូវពិនិត្យតែលើខ្លឹមសារនៃសេចក្តីសម្រេច ដោយឥត លំអៀងនោះឡើយ ផ្ទុយទៅវិញ និស្សិតត្រូវចោទសួរខ្លួនឯងនូវសំណួរជាច្រើនដូចជា តើសេចក្តីសម្រេចនោះមានសារៈ ប្រយោជន៍អ្វីខ្លះ ? តើវាបាននាំមកនូវអ្វីសំរាប់នីតិ និងការអភិវឌ្ឍន៍នីតិ ? តើទៅអនាគត ខ្លឹមសារនៃសេចក្តីសំម្រេច

Scanned with CamScanner

នោះនឹងមានការប្រែប្រួល ឬនៅរក្សាដដែល ? តើវាបានផ្លាស់ប្តូរ ឬកែប្រែវិធានណាមួយដែលមានស្រាប់ដែរឬទេ ? ឬផ្ទុយទៅវិញ វាគ្រាន់តែអនុវត្តគោលការណ៍ណាមួយ ដែលគេស្គាល់ច្បាស់ពីមុនមកហើយ ? ចម្លើយចំពោះសំណួរទាំងនេះតម្រូវអោយនិស្សិតមានពុទ្ធិខាងនីតិសាស្ត្រអោយបានប្រាកដប្រជា ។

តថាខណ្ឌទី ៤ : លំហាត់អនុវត្តន៍ជាក់ស្តែង

ក-ប្រធាន

ចូរអ្នកធ្វើសលាកប័ត្រនៃសេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញខាងក្រោម :

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញលិខិតប្រធានរដ្ឋសភាលេខ ០៤៥ រស ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០១ ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពី" ការបង្កើតអោយឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តិឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ" ដែលរដ្ឋសភាបានអនុម័តយល់ព្រមកាលពីថ្ងៃទី ០២ ខែមករា ឆ្នាំ ២០០១ នាសម័យប្រជុំលើកទី ៥ នីតិកាល ទី ២ ហើយព្រឹទ្ធសភាក៏បានពិនិត្យចប់សព្វគ្រប់នៅថ្ងៃទី ១៥ ខែ ឆ្នាំដដែល នាសម័យប្រជុំពេញអង្គលើកទី ៤ នីតិកាលទី ១ ដោយបាយអនុម័តយល់ស្របតាមលើទម្រង់ឯកតិនៃច្បាប់ទាំងស្រុង គ្មានការកែប្រែអ្វី ឡើយ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០១ ។

ក្រោយពីបានស្តាប់រចនាការណ៍របស់សមាជិករចនាការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា រដ្ឋសភា និងព្រឹទ្ធសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទ ដែលមានចែងនៅក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យអនុម័តច្បាប់ខាងលើនេះ ។

-យល់ឃើញថា រដ្ឋសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទ ដែលមានចែងក្នុងមាត្រា ១៤០ ថ្មីនៃរដ្ឋធម្មនុញ្ញ វាក្យខណ្ឌទី ២ ក្នុងការបញ្ជូនមកឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងច្បាប់នេះត្រូវប្រកាសឱ្យប្រើ ។

- យល់ឃើញថា មាត្រា ៣ វាក្យខណ្ឌទី ១ នៃច្បាប់នេះ បានយោងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ និងចង្អុលមាត្រានៃក្រមព្រហ្មទណ្ឌនេះចំនួនដប់ ដែលក្នុងចំណោមនោះ មាត្រា ២០៩ ៥០០ ៥០៦ និង ៥០៧ បានចែងថា : "... ត្រូវមានទោសឧក្រិដ្ឋថ្នាក់ទី ៣ " ។ មាត្រា ២១ នៃក្រមព្រហ្មទណ្ឌដដែល បានបញ្ជាក់ថា "... ទោសឧក្រិដ្ឋថ្នាក់ទី ៣ គឺជាទោស

Scanned with CamScanner

សម្លាប់ " ដូច្នេះ ទាំងអក្សរ ទាំងខ្លឹមសារវាក្យខណ្ឌពាក់ព័ន្ធនេះ មានន័យផ្ទុយនឹងរដ្ឋធម្មនុញ្ញ ដែលមាត្រា ៣២ វាក្យខណ្ឌ ទី ២ បានចែងថា : " ទោសប្រហារជីវិតមិនត្រូវឱ្យមានឡើយ" ។

-យល់ឃើញថា មាត្រា ៣ វាក្យខណ្ឌទី ២ នៃច្បាប់នេះ បានពន្យារពេលបន្ថែម ២០ ឆ្នាំទៀត ទៅលើអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាសំរាប់ឧក្រិដ្ឋកម្ម ដែលមាត្រា ១០៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ បានកំណត់ត្រឹមតែដប់ឆ្នាំ ។ អានុភាពនៃមាត្រា ៣ វាក្យខណ្ឌទី ២ នេះ បានធ្វើឱ្យប៉ះពាល់ដល់គោលការណ៍សារវន្តមួយ : "ភាពគ្មានប្រតិសកម្មនៃច្បាប់ថ្មីលើបទល្មើស ដែលបានកើតឡើងក្នុងអតីតកាល" ដែលប្រទេសកម្ពុជា ក៏ដូចជាអារ្យប្រទេសមួយចំនួន បានទទួលស្គាល់ជាទូទៅក្នុងសម័យមុនឆ្នាំ ១៩៧៥ ក៏ដូចជាសម័យក្រោយឆ្នាំ ១៩៧៨ ដោយរាប់បញ្ចូលទាំងសម័យអន្តរកាលនៃក្រុមប្រឹក្សាជាតិជាន់ខ្ពស់ផង ។ ប៉ុន្តែ កម្ពុជាមិនបានបញ្ជាក់ថា គោលការណ៍ជាសារវន្តនេះ មានតម្លៃស្មើនឹងរដ្ឋធម្មនុញ្ញឡើយ ហេតុដូច្នេះហើយបានជាសភាធម្មនុញ្ញដែលជាអង្គការជ្រើសតាំងតាមនីតិវិធីស្របច្បាប់ និងតំណាងឱ្យប្រជារាស្ត្រពិត-ប្រាកដ ក្នុងការតាក់តែងរដ្ឋធម្មនុញ្ញ មិនបានបញ្ញត្តពីគោលការណ៍នេះក្នុងមាត្រាណាឡើយ ក្នុងបុព្វកថាក៏មិនមានដែរ ។ លើសពីនេះទៅទៀត ទុកជាគោលការណ៍នេះមានតម្លៃស្មើនឹងអ្វីក៏ដោយ ឬត្រូវបានចារឹកជាលាយលក្ខណ៍អក្សរ ឬក៏គ្មានក៏គេត្រូវគោរពតាមគោលការណ៍មួយទៀត "រាល់គោលការណ៍មានសមាសពលពីរ : វិធាន និងអញ្ញត្រកម្ម" បើវិធានមានតម្លៃស្មើអ្វី អញ្ញត្រកម្មក៏មានតម្លៃដូចគ្នា ។ ភាពគ្មានប្រតិសកម្មដែលមិនត្រូវបានចែងក្នុងរដ្ឋធម្មនុញ្ញ គេបានឃើញនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ។ គោលការណ៍ត្រឹះនៃក្រមព្រហ្មទណ្ឌនេះក៏មានការវៀរលែងដែរ ។ មាត្រា ៦ វាក្យខណ្ឌ ទី ២ បានចែងថា : "...ប៉ុន្តែបើច្បាប់ថ្មីនេះលុបចោលបទល្មើសណាមួយ ឬសម្រាលរបស់ជនល្មើសណាមួយវិញ បទល្មើស ដែលបានប្រព្រឹត្តមុនច្បាប់នេះ ត្រូវបានរួចផុតពីទោស ឬក៏ត្រូវបានសម្រាលទោសនោះតាមច្បាប់ថ្មី កុំឱ្យតែបទល្មើសនោះបានទទួលទោសជាស្ថាពររួចទៅហើយ" ។ ត្រង់នេះ ច្បាប់ថ្មី ដែលយើងកំពុងពិនិត្យបានបំពេញលក្ខខណ្ឌបានដោយបរិបូរណ៌ ។ មាត្រា ៣៨ និង៣៩ បានបន្ថយទោសប្រហារជីវិត មកត្រឹមតែទោសជាប់គុកអស់មួយជីវិតតែប៉ុណ្ណោះ ។ ម្យ៉ាងទៀត ទោសជាប់គុកដោយបង្ខំឱ្យធ្វើការជាទម្ងន់ (travaux forcés) ឬទោសដាក់គុកបង្ខំឱ្យធ្វើការ និងបង្ខាំងមិនឱ្យចេញ (réclusion) មកត្រឹមតែទោសដាក់គុកធម្មតា (emprisonnement) ។ អំណះអំណាងអំណោយផលមួយទៀត គឺការគោរពលក្ខខណ្ឌចង្អៀតនៃច្បាប់ព្រហ្មទណ្ឌ ទន្ទឹមនឹងចរិតលក្ខណៈពិសេសនៃករណី ។ មាត្រាមួយនៃច្បាប់នេះ បានកំណត់លក្ខខណ្ឌជាច្រើន ដូចជាធាតុផ្សំនៃបទល្មើស (éléments constitutifs de l'infraction) ទៅក្នុងលក្ខខណ្ឌជាទម្លាប់ ដែលមានស្រាប់នៅក្នុងមាត្រាទាំងឡាយដែលគេចង្កុលក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ។ លក្ខខណ្ឌបន្ថែមទាំងនោះគឺ :

-ចំពោះពិរុទ្ធជនមានតែមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត

- ចំពោះបទល្មើសកើតត្រឹមឧក្រិដ្ឋកម្ម និងការរំលោភធ្ងន់ធ្ងរ

- ចំពោះចិរវេលាកើតត្រឹមថ្ងៃទី ១៧-០៤-១៩៧៥ ដល់ថ្ងៃទី ០៦-០១-១៩៧៩ ។

រួមសេចក្តីទៅ គ្មានឃើញអ្វីធ្វើឱ្យប៉ះពាល់ដល់ធម្មនុញ្ញភាពនោះទេ ។

Scanned with CamScanner

-យល់ឃើញថា មាត្រា ៩ ដល់មាត្រា ៣២ ដែលបានបញ្ញត្តពីសមាសភាពចៅក្រមជំនុំជម្រះ ការតែងតាំង ការសម្រេច-សេចក្តី សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត ប្រធាន អនុប្រធាន ការិយាល័យរដ្ឋបាល និងបុគ្គលិកជំនួយការផ្សេងៗ មានភាគីខ្មែរ និងភាគីមកពីអង្គការសហប្រជាជាតិ ដូចមានតារាងសំយោគខាងក្រោមនេះ :

សមាសភាព	សាលាដំបូង	សាលាឧទ្ធរណ៍	តុលាការកំពូល	ការិយាល័យរដ្ឋបាល
១-ចៅក្រមជំនុំជម្រះ				
- ខ្មែរ (ប្រធាន)	៣	៤	៥	
- អ.ស.ប.	២	៣	៤	
សរុប	៥	៧	៩	
២-សម្លេងអប្បបរមាក្នុងការសំរេច	៤	៥	៦	
៣-សហព្រះរាជអាជ្ញា				
- ខ្មែរ (ប្រធាន)	១	១	១	
- អ.ស.ប.	១	១	១	
សរុប	២	២	២	
៤-សហចៅក្រមស៊ើបអង្កេត				
- ខ្មែរ (ប្រធាន)	១	១	១	
- អ.ស.ប.	១	១	១	
សរុប	២	២	២	
៥-ការិយាល័យរដ្ឋបាល				
- ខ្មែរ (ប្រធាន)				១
- អ.ស.ប.				១
សរុប				២

ដើម្បីបំពេញការអង្គជុំនំជម្រះវិសាមញ្ញនេះ ទាំងភាគីខ្មែរ ទាំងភាគីមកពីអង្គការសហប្រជាជាតិ សុទ្ធតែត្រូវបានតែងតាំងឡើងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលជាស្ថាប័នកំពូលជាតិខ្មែរសុទ្ធសាធ សូម្បីតែប្រធាន និងអនុ-ប្រធានការិយាល័យរដ្ឋបាល ក៏ត្រូវបានតែងតាំងដោយអាជ្ញាធរកម្ពុជាដែរ ។ អង្គការសហប្រជាជាតិ មានការកិច្ចត្រឹមស្នើបញ្ជីបេក្ខជនតែប៉ុណ្ណោះ ហើយគ្មានសិទ្ធិសម្រេចទេ ។ គេពុំឃើញមានមាត្រាណាមួយនៃរដ្ឋធម្មនុញ្ញហាមឃាត់មិនឱ្យ

Scanned with CamScanner

ស្ថាប័នជាតិ ជាពិសេសឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម តែងតាំងជនមកពីអង្គការសហប្រជាជាតិ ដែលកម្ពុជាជាសមាជិកដែរនោះទេ ។ បើនិយាយឱ្យអស់ទៅ ក្នុងឋានៈខ្លួនជាអង្គការប្រមូលផ្តុំប្រជាជាតិ ស្ទើរតែទាំងអស់ក្នុងពិភពលោក អង្គការសហប្រជាជាតិអាចឧទ្ទេសនាមបេក្ខជនគ្រប់សញ្ជាតិ រួមទាំងខ្មែរ ឬខ្មែរមានសញ្ជាតិពីរផង ។ គ្រប់លំដាប់ថ្នាក់នៃអង្គជំនុំជម្រះក្តី : តុលាការថ្នាក់ទី ១, សាលាឧទ្ធរណ៍, តុលាការកំពូល ភាគីខ្មែរសុទ្ធតែមានចំនួនភាគច្រើន ហើយសុទ្ធតែខ្មែរដែលត្រូវបានទទួលឋានៈជាប្រធាន ។ ប៉ុន្តែ ចំនួនសំលេងអប្បបរមាក្នុងសេចក្តីសម្រេច ដែលមានតម្លៃខ្ពស់ជាយន្តការតុល្យការមួយ ធ្វើឱ្យមានសមភាពខាងផ្លូវយុត្តិធម៌ ព្រោះភាគីទាំងពីរ ចាំបាច់ត្រូវសហការគ្នាដោយខានមិនបាន ។ ការយកប្រព័ន្ធតុលាការកម្ពុជាដែលមានស្រាប់ និងការរើសយករាជធានីភ្នំពេញជាទីតាំងដំណើរការ ជាការគាំពារថ្មីមួយទៀតដល់អធិបតេយ្យរបស់ព្រះរាជាណាចក្រកម្ពុជា ។ ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជុំនំជម្រះវិសាមញ្ញនេះ បានយោងច្បាប់ចំនួនប្រាំមួយ ដែលមានចែងក្នុងមាត្រា ៣, ៤, ៥, ៦, ៧ និង៨ ។ ក្នុងចំណោមនេះ មានប្រាំមាត្រា (ប្រាំចុងក្រោយ) ជាសន្ធិសញ្ញាអន្តរជាតិ ។ ដូច្នេះ ការទាមទារឱ្យមានការចូលរួមចំណែកពីសំណាក់អង្គការសហប្រជាជាតិជាការចាំបាច់ ។

- យល់ឃើញថា មាត្រា ៤០ ដែលបានហាមឃាត់មិនឱ្យរាជរដ្ឋាភិបាលកម្ពុជា ស្នើអោយមានការលើកលែងទោស ឬការអនុគ្រោះទោស ពុំធ្វើឱ្យប៉ះពាល់ដល់ធម្មនុញ្ញភាពទេ ពីព្រោះមាត្រា ២៧ នៃរដ្ឋធម្មនុញ្ញបានបញ្ជាក្តីពីព្រះមហាក្សត្រ មិនមែនពីរាជរដ្ឋាភិបាល ។ មាត្រានេះចែងថា "ព្រះមហាក្សត្រទ្រង់មានព្រះរាជសិទ្ធិបន្ធូរបន្ថយទោស និងលើកលែងទោស" ។

សំរេច

មាត្រា ១.- ផ្អែកតាមមូលបទខាងលើ ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជុំនំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០០១ និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ កាលពីថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០១ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងតែបទប្បញ្ញត្តិទាំងឡាយដែលបានចែងថា: "... ត្រូវមានទោសថ្នាក់ទីបី" ដែលជាទោសសម្លាប់ក្នុងមាត្រា ២០៩, ៥០០, ៥០៦, និង៥០៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ដែលត្រូវបានចង្អុលក្នុងមាត្រា ៣ នៃច្បាប់នេះ ។

មាត្រា ២.- សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និងជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០០១

ស.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ចាន់ សុភ

Scanned with CamScanner

ខ-តំណែ

១-<u>អង្គហេតុ</u>

ក្រោយពីបានចុះកិច្ចព្រមព្រៀងជាមួយអង្គការសហប្រជាជាតិ រាជរដ្ឋាភិបាលបានរៀបចំសេចក្តីព្រាងច្បាប់ស្តីពី "ការបង្កើតអោយឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីជំនុំជម្រះសេចក្តីអំពីឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តិនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិប្បតេយ្យ" ដែលត្រូវបានរដ្ឋសភាអនុម័តយល់ព្រមកាល ពីថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០០១ ហើយព្រឹទ្ធសភាអនុម័តនៅថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០១ ។

២-<u>និតិវិធី</u>

ដោយសារជាច្បាប់រៀបចំអង្គការ ច្បាប់ខាងលើត្រូវបានប្រធានរដ្ឋសភាបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញតាមស្មារតីនៃមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ ដើម្បីពិនិត្យធម្មនុញ្ញភាព ។

៣-<u>បញ្ហាគតិយុត្ត</u>

ក្រុមប្រឹក្សាធម្មនុញ្ញប្រឈមនឹងបញ្ហាគតិយុត្តយ៉ាងតិចចំនួនពីរ :

១-តើគោលការណ៍ប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌមានតម្លៃគតិយុត្តជាអ្វី ?

២-តើវត្តមានចៅក្រមបរទេសនៅក្នុងអង្គជំនុំជម្រះក្តីនៃតុលាការកម្ពុជា ប៉ះពាល់ដល់អធិបតេយ្យភាពរបស់កម្ពុជាដែរឬទេ ?

៤-<u>ដំណោះស្រាយ</u>

ក្រុមប្រឹក្សាធម្មនុញ្ញបាននូវចម្លើយដូចខាងក្រោម :

១-គោលការណ៍ប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ គ្មានតម្លៃស្មើនឹងរដ្ឋធម្មនុញ្ញនោះទេ ។ ក្រុមប្រឹក្សាអះអាងថា សភាធម្មនុញ្ញពុំបានបញ្ចូលគោលការណ៍នេះទៅក្នុងរដ្ឋធម្មនុញ្ញ ឬទៅក្នុងបុព្វបទរដ្ឋធម្មនុញ្ញទេ ។

២-វត្តមានចៅក្រមបរទេសនៅក្នុងដំណើរការជម្រះក្តីនៅកម្ពុជា ពុំប៉ះពាល់ដល់អធិបតេយ្យភាពរបស់កម្ពុជាឡើយ ប្រសិនបើមានការគោរពនូវលក្ខខណ្ឌចំនួនបួនគឺ ចៅក្រមបរទេសត្រូវស្នើឡើងដោយអង្គការសហប្រជាជាតិដែលកម្ពុជាជាសមាជិក ចៅក្រមបរទេសត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អង្គជម្រះក្តីត្រូវធ្វើការសម្រេចដោយមតិភាគច្រើនដែលភាគីកម្ពុជាមានប្រៀបជាងភាគីបរទេស និងសាលាជម្រះក្តីត្រូវមានទីតាំងនៅរាជធានីភ្នំពេញ ហើយត្រូវប្រើប្រាស់ប្រព័ន្ធតុលាការកម្ពុជាដែលមានស្រាប់ ។

៤-<u>ខ្លឹមសារ "បន្ទាប់បន្សំ"</u>

អំណើះតទៅ សភាអាចធ្វើអញ្ចត្រកម្មនៃគោលការណ៍ប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ដោយពុំប៉ះពាល់ដល់រដ្ឋធម្មនុញ្ញឡើយ (សភាអាចអនុម័តច្បាប់មួយដែលមិនគោរពគោលការណ៍នេះ) ។ ម្យ៉ាងវិញទៀត ការចូលរួមរបស់ចៅក្រមបរទេសក្នុងការជំនុំជម្រះក្តីនៅកម្ពុជា មិនប្រាកដជាធ្វើឱ្យប៉ះពាល់ដល់អធិបតេយ្យភាពរបស់កម្ពុជាឡើយ ។

Scanned with CamScanner

ភាគទី ២ :

អត្ថាធិប្បាយអត្ថបទតាមន័យ

ខ្ទុលាយ

Scanned with CamScanner

ភាគទី ២ :
អត្ថាធិប្បាយអត្ថបទតាមន័យទូលាយ

លំហាត់អត្ថាធិប្បាយអត្ថបទ អនុញ្ញាតអោយផ្សៀងផ្ទាត់សមត្ថភាពរបស់និស្សិត ឬបេក្ខជនប្រឡងមិនត្រឹមតែដើម្បីអោយយល់ពីអត្ថបទនោះទេ តែថែមទាំងដើម្បីពន្យល់ និងវាយតម្លៃលើអត្ថបទនោះទៀតផង ។ ដូចច្នេះ លំហាត់ដ៏ពិបាកនេះទាមទារយ៉ាងចាំបាច់ ក្រៅពីចំណេះដឹងដ៏រឹងមាំ ត្រូវយល់អំពីការដេញរកហេតុផលគតិយុត្តដ៏ម៉ឺងម៉ាត់មួយផងដែរ ។ ប្រភេទអត្ថបទដែលអាចធ្វើជាកម្មវត្ថុនៃការធ្វើអត្ថាធិប្បាយ អាចប្រែប្រួលខុសៗជាច្រើន ដូចជាអត្ថបទរបស់អ្នកនិពន្ធ ឬសេចក្តីស្រង់ពីស្បៀវភៅដែលសរសេរដោយអ្នកនិពន្ធណាម្នាក់, មាត្រានៃច្បាប់ក្នុងន័យសំការៈ, សេចក្តីសម្រេចរបស់តុលាការ..... ។ សេចក្តីសម្រេចរបស់តុលាការបង្ហាញនូវលក្ខណៈពិសេសខ្លះៗ បើធ្យើបទៅនឹងអត្ថបទផ្សេងៗទៀត ហើយលំហាត់អត្ថាធិប្បាយអត្ថបទ និងអត្ថបទរបស់អ្នកនិពន្ធ (ផ្នែកទី១) នឹងត្រូវលើកឡើងបកស្រាយដាច់ដោយឡែកពីលំហាត់អត្ថាធិប្បាយនៃសេចក្តីសម្រេចរបស់តុលាការ (ផ្នែកទី២) ។

ផ្នែកទី ១ : បរិមាណធិប្បាយអត្ថបទ និងអត្ថបទរបស់អ្នកនិពន្ធ : (បេអាទ្រីស ចាលីវ៉ែ)

និស្សិត ឬបេក្ខជនប្រឡង ពុំអាចអានត្រឹមតែការបង្ហាញអំពីវិធីសាស្ត្រអត្ថាធិប្បាយអត្ថបទ និងអត្ថបទរបស់អ្នកនិពន្ធ ដើម្បីយល់បានពីលំហាត់ដ៏ពិបាកទាំងនោះទេ (កថាខណ្ឌទី១) ។ មានលំហាត់ខុសគ្នាៗជាច្រើន (កថាខណ្ឌទី២) អនុញ្ញាតអោយដោះស្រាយនូវការលំបាកពិសេសមួយចំនួន ។ និស្សិត ឬបេក្ខជន ត្រូវតែមានសមត្ថភាពទាញយកនូវគំនិតសំខាន់ៗទាំងឡាយ និងមានសមត្ថភាពរៀបចំគំនិតទាំងនេះ នៅក្នុងករណីដែលអត្ថបទនោះវែង ។ បើមិនដូច្នោះទេ កិច្ចការអត្ថាធិប្បាយយ៉ាងម៉ត់ចត់របស់យើង ពុំអាចត្រូវបានធ្វើឡើងនោះទេ ។ បន្ទាប់មក ឧទាហរណ៍ក្នុងការអនុវត្តវិធី-សាស្ត្រនឹងត្រូវលើកមកបង្ហាញតាមដំណាក់កាលនីមួយៗ (កថាខណ្ឌទី៣) ។ ចុងបញ្ចប់ និស្សិត ឬបេក្ខជនប្រឡងអាចសាកល្បងនូវចំណេះដឹងដ៏ល្អរបស់ខ្លួន ក្នុងការធ្វើអត្ថាធិប្បាយអត្ថបទ និងអត្ថបទរបស់អ្នកនិពន្ធ ដោយអនុវត្តវិធីសាស្ត្រទាំងនេះទៅក្នុងលំហាត់ខ្លះ (កថាខណ្ឌទី៤) ។

កថាខណ្ឌទី ១ : ការបង្ហាញពីរបៀបអត្ថាធិប្បាយអត្ថបទ និងអត្ថបទរបស់អ្នកនិពន្ធ

មានប្រភេទអត្ថបទជាច្រើនដែលអាចធ្វើជាកម្មវត្ថុនៃការធ្វើអត្ថាធិប្បាយបាន :

- អត្ថបទនីតិប្បញ្ញត្តិ : ច្បាប់, មាត្រានៃក្រម, មាត្រានៃរដ្ឋធម្មនុញ្ញ, ក្រឹត្យ...
- បទប្បញ្ញត្តិនៃច្បាប់បរទេស សេចក្តីព្រាងច្បាប់...
- អត្ថបទរបស់អ្នកនិពន្ធផ្សេងៗ : លទ្ធិ: អត្ថបទការសែត...
- ឯកសារទាំងឡាយដែលចេញមកពីការអនុវត្ត ។

Scanned with CamScanner

ទោះបីជាអត្ថបទដែលដាក់អោយនិស្សិត ឬបេក្ខជនប្រឡងមានប្រភេទយ៉ាងដូចម្តេចក៏ដោយ អ្នកត្រួតពិនិត្យ រង់ចាំនូវចំណេះដឹងដ៏ច្បាស់លាស់ទាំងឡាយលើប្រធានបទដែលត្រូវធ្វើ ហើយនិស្សិត ឬបេក្ខជនប្រឡងត្រូវមានសមត្ថ ភាព អនុវត្តចំណេះដឹងរបស់ខ្លួនទៅក្នុងអត្ថបទដែលត្រូវធ្វើអត្ថាធិប្បាយ ។

ដើម្បីសម្រេចបាននូវការធ្វើអត្ថាធិប្បាយអត្ថបទ ឬអត្ថបទរបស់អ្នកនិពន្ធ យើងត្រូវគោរតាមដំណាក់កាលជា ច្រើន :

ដំណាក់កាលទី ១ : ការកំណត់ស្ថានភាព

និស្សិត ឬបេក្ខជនពុំត្រូវសញ្ជឹងគិតតែទៅលើអត្ថន័យរបស់អត្ថបទនោះទេ គឺត្រូវសាកល្បងដាក់អត្ថន័យនេះក្នុង បរិបទរបស់វា ។ ការងារបឋមនៃការធ្វើអត្ថាធិប្បាយ គឺត្រូវប្រមូលព័ត៌មានខ្លះៗដែលទាក់ទងនឹងអត្ថបទដែលត្រូវធ្វើ ។ បន្ទាប់ពីអានអត្ថបទរួច យើងឈានដល់ការឆ្លើយទៅវាល់សំណួរដូចខាងក្រោម :

- អត្ថបទនេះមានប្រភេទជាអ្វី ? និងមានប្រភពមកពីណា ?

សំណួរធម្មតានេះ ទាមទារយ៉ាងចាំបាច់អោយនិស្សិត ឬបេក្ខជនប្រឡងឆ្លើយទៅនឹងសំណួរទាំងនេះ :

- តើអត្ថបទដែលត្រូវធ្វើអត្ថាធិប្បាយមានប្រភេទជាអ្វី ? "ច្បាប់. ក្រឹត្យ. អត្ថបទទ្រឹស្តីអ្នកនិពន្ធ..."
- តើអត្ថបទមានប្រភពមកពីណា ឬអ្នកនិពន្ធឈ្មោះអ្វី ? "ក្រមរដ្ឋប្បវេណី. នាយករដ្ឋមន្ត្រី. អ្នកនិពន្ធ ល្បីល្បាញ..."
- តើអត្ថបទនេះត្រូវបានសរសេរ ឬត្រូវបានផ្សព្វផ្សាយនៅកាលបរិច្ឆេទណា?
- ប្រសិនបើអត្ថបទដាក់អោយគ្រាន់តែជាសេចក្តីស្រង់ពីស្បៃវ៉ែកៅ យើងត្រូវសាកល្បងកំណត់អត្តសញ្ញាណ ស្បៃវ៉ែកៅដែលអត្ថបទនោះដកស្រង់ចេញ ។

- តើអត្ថបទមានវិស័យទូទៅអ្វីខ្លះ ? និងកម្មវត្ថុដ៏ច្បាស់លាស់របស់វាមានអ្វីខ្លះ ?
- តើអត្ថបទត្រូវបានបង្ហាញឡើងយ៉ាងដូចម្តេចខ្លះ ?

យើងត្រូវកំណត់ :

- ទំហំនៃអត្ថបទ
- ការបែងចែកជាក់ស្តែង

ដំណាក់កាលទី ២ : វិភាគអត្ថបទ

ការវិភាគអត្ថបទដ៏ល្អទាមទារយ៉ាងចាំបាច់នូវការអានអោយបានច្រើនដង ។ យើងពុំត្រូវរារែកក្នុងការកំណត់ ចំណាំអត្ថបទ ក្នុងការបែងចែកអត្ថបទដោយវង់ដង្កៀប ដើម្បីអាចមើលឃើញនូវគំនិតផ្សេងៗដែលបង្ហាញនៅក្នុងអត្ថ-បទនេះ និងគូសពីក្រោមពាក្យទាំងឡាយដែលយើងត្រូវពន្យល់ ។

- *ស្វែងរកពាក្យ ដើម្បីគូសពីក្រោម :*

Scanned with CamScanner

ពាក្យនីមួយៗនៅក្នុងអត្ថាធិប្បាយអត្ថបទត្រូវតែធ្វើការវិភាគ ។ ក្នុងអត្ថបទដ៏ខ្លីមួយ ពាក្យនីមួយៗ (ឧទាហរណ៍ : អាច ឬត្រូវតែ) អាយតនិបាតនីមួយៗ (និង/ឬ), គុណកិរិយានីមួយៗ (ដោយច្បាស់, តាមចំលាប់) អាចមានសារៈសំខាន់ហេតុដូច្នេះហើយ យើងត្រូវតែកត់សំគាល់ ហើយពន្យល់ ក្នុងករណីចាំបាច់ ។

សញ្ញាណតិយុត្តទាំងឡាយត្រូវតែកំណត់អោយបានច្បាស់លាស់ ។ ជួនកាលពាក្យនៃភាសានិយាយក៏អាចមានការចាំបាច់ផងដែរ។ ជាវិស្សុតកម្ម ក្នុងប្រធានបទមួយមានចំណងជើងថា "អំណាចរបស់ចៅក្រមក្នុងករណីស្បៃមស្ងាត់ឬភាពពុំច្បាស់លាស់របស់ច្បាប់" សំណួនវោហាស័ព្ទ "ក្នុងករណីស្បៃមស្ងាត់ ឬភាពពុំច្បាស់លាស់នៃច្បាប់" ទាមទារចាំបាច់ឱ្យមានការកំណត់និយមន័យឱ្យបានច្បាស់លាស់នៃពាក្យស្ងប់ស្បៃម និងភាពពុំច្បាស់លាស់ ដែលពុំមែនជាសញ្ញាណតិយុត្តឡើយ ។

- ការស្វែងរកវចនាសម្ព័ន្ធរបស់អត្ថបទ :

- ទាក់ទិននឹងវចនាសម្ព័ន្ធនៃការរៀបពាក្យ ឬនៃវេយ្យាករណ៍ :

និស្សិត ឬបេក្ខជនប្រឡង ត្រូវតែប្រុងប្រយត្ននូវការបែងចែកអត្ថបទជាកថាខណ្ឌ ឬជាវាក្យខណ្ឌ រួមទាំងវិធីប្រើវណ្ណយុត្តផងដែរ ។ ការបែងចែកទាំងនេះ មានសារៈសំខាន់ខ្លាំងណាស់ ពីព្រោះ វាបានលើកបង្ហាញអោយដឹងជាញឹកញាប់នូវរបៀបដែលអ្នកនិពន្ធបានរៀបចំរចនាសម្ព័ន្ធអត្ថបទ ហើយដែលវាអនុញ្ញាតឱ្យទាញចេញជាប្លង់អត្ថបទដែលអាចជាប្លង់សម្រាប់ធ្វើអត្ថាធិប្បាយ ។

- ទាក់ទិននឹងគំនិត ឬវចនាសម្ព័ន្ធតក្កវិជ្ជានៃអត្ថបទ :

និស្សិត ឬបេក្ខជនប្រឡងត្រូវតែកត់សម្គាល់នូវគំនិតផ្សេងៗក្នុងអត្ថបទ ។ ប្រសិនបើអត្ថបទមានការលើកឡើងនូវអំណះអំណាង ឬហេតុផល យើងត្រូវតែបញ្ជាក់នូវអំណះអំណាងទាំងនោះ ។

- ស្វែងរកអត្ថន័យនៃអត្ថបទ :

និស្សិត ឬបេក្ខជនប្រឡងត្រូវលើកឡើងនូវគំនិតទាំងឡាយរបស់ខ្លួនលើប្រធានបទ ។ យើងមិនត្រូវចម្លងឃ្លានៅក្នុងអត្ថបទនោះទេ ប៉ុន្តែ បន្ទាប់ពីបានទាញចេញនូវគំនិតរបស់អ្នកនិពន្ធ យើងត្រូវពន្យល់ និងសិក្សាវាយតម្លៃអំពីគំនិតទាំងនោះ ។

ដើម្បីធ្វើកិច្ចការពន្យល់នេះ និស្សិត ឬបេក្ខជនប្រឡង ត្រូវរំលឹកឡើងវិញនូវចំណេះដឹងដែលយើងធ្លាប់ទទួលបានក្នុងការសិក្សា ឬតាមរយៈការអានមានលក្ខណៈផ្ទាល់ខ្លួន... ។ គោលបំណង គឺសំដៅពន្យល់អំពីសំណើទាំងឡាយរបស់អ្នកនិពន្ធក្នុងអត្ថបទ ។

នៅពេលដែលគំនិតរបស់អ្នកនិពន្ធដែលលើកឡើងក្នុងអត្ថបទត្រូវបានពន្យល់រួចហើយ និស្សិត ឬបេក្ខជនប្រឡងត្រូវតែសិក្សាវាយតម្លៃគំនិតទាំងនេះ ។ ក្នុងដំណាក់កាលទី១ ការសិក្សាវាយតម្លៃត្រូវតែធ្វើឡើងជាលំដាប់តតិយុត្ត ។ និស្សិត ឬបេក្ខជនប្រឡង អាចធ្វើឱ្យមានភាពប្រសើរអំពីការវិភាគរបស់អ្នកនិពន្ធ ដោយចាត់ទុកថា ការវិភាគនេះស្របទៅនឹងវិធានតតិយុត្តណាមួយ ឬស្របទៅនឹងលទ្ធិ ឬយុត្តិសាស្ត្រដែលមានពាក់ព័ន្ធនឹងបញ្ហានេះ ។ ផ្ទុយទៅវិញ ប្រសិនបើ

Scanned with CamScanner

និស្សិត ឬបេក្ខជនប្រឡង ពុំឯកភាពតាមលក្ខណៈគតិយុត្តជាមួយគំនិតដែលសំដែងឡើងនោះទេ យើងអាចរិះគន់ជាអវិជ្ជមាននូវគំនិតនោះ ដោយធ្វើការកត់សំគាល់ថា គំនិតទាំងនោះផ្ទុយនឹងវិធានគតិយុត្តណាមួយ ឬគួរចំណាំថា សំណើនេះមានលក្ខណៈពុំគ្រប់គ្រាន់ ឬពុំច្បាស់លាស់ ដោយហេតុថា សេចក្តីសម្រេចរបស់តុលាការដែលចេញលើចំណុចនេះ ក៏ពុំបានវិនិច្ឆ័យផងដែរ ។ ក្នុងដំណាក់កាលទី២ គំនិតត្រូវតែត្រូវបានវាយតម្លៃ យោងតាមទិន្នន័យសង្គមកិច្ច សេដ្ឋកិច្ច សីលធម៌។ ហេតុដូច្នេះ គំនិតមួយត្រូវបានទទួលយក ប្រសិនបើគំនិតនេះចូលរួមក្នុងការធានានូវការការពារអ្នកប្រើប្រាស់ ឬផ្តល់ភាពពេញចិត្តក្នុងការធ្វើពាណិជ្ជកម្ម ។

ទោះបីយ៉ាងណាក៏ដោយ និស្សិត ឬបេក្ខជនប្រឡង គឺជាអ្នកជំនាញការច្បាប់ ឬអនាគតអ្នកជំនាញការច្បាប់ យើងពុំត្រូវទទួលយកនូវគំនិតទាំងអស់នោះទេ ។ ផ្ទុយទៅវិញ យើងត្រូវតែធ្វើយុត្តកម្មនូវគោលជំហររបស់ខ្លួន ។ ដូចនេះ ប្រសិនបើគំនិតរបស់អ្នកនិពន្ធត្រូវបានទទួលការរិះគន់ដោយនិស្សិត ឬបេក្ខជនប្រឡង ទោះបីការរិះគន់នោះជាវិជ្ជមាន ឬអវិជ្ជមាន ជានិច្ចជាកាល យើងត្រូវតែពន្យល់អោយបានច្បាស់លាស់អំពីមូលហេតុ ។

ដំណាក់កាលទី ៣ : ការបង្កើតប្លង់

ជាទូទៅ អត្ថាធិប្បាយអត្ថបទត្រូវបានបង្កើតឡើងយោងតាមប្លង់អត្ថបទ ។ បើមិនដូច្នេះទេ និស្សិត ឬបេក្ខជនប្រឡង ត្រូវតែបង្កើតប្លង់ចេញពីប្លង់គំនិតដែលបង្ហាញឡើងនៅក្នុងអត្ថបទ ។ ប្លង់ អាចត្រូវបានបែងចែកទៅតាមភាគជាច្រើន ដោយយោងតាមគំនិតបង្ហាញឡើង ។ សារៈសំខាន់គឺថា គំនិតទាំងឡាយត្រូវតែបានរៀបចំទៅតាមរបៀបដែលប្រកបដោយវិចារណញ្ញាណ ។

ដំណាក់កាលទី ៤ : ការតាក់តែងអត្ថាធិប្បាយអត្ថបទ

ដំណាក់កាលនៃការត្រៀមរៀបចំអត្ថាធិប្បាយអត្ថបទត្រូវបានបញ្ចប់ ។ អំណើះតទៅ យើងត្រូវតែធ្វើការលើសំណៅកិច្ចការ ពុំមែនលើក្រដាសព្រាងឡើតទេ លើកលែងតែសេចក្តីផ្តើម ។ ជាពិសេស នៅថ្ងៃប្រឡង និស្សិត ឬបេក្ខជនប្រឡងគ្មានពេលតាក់តែងកិច្ចការទាំងអស់របស់អ្នកលើក្រដាសព្រាង បន្ទាប់មកចម្លងឡើងវិញទៅក្នុងសំណៅកិច្ចការទាំងនោះឡើយ ។

ការបង្ហាញសំណៅកិច្ចការ មានសារៈសំខាន់ណាស់ ។ យើងត្រូវតែផ្តិតផ្តង់ចំពោះការសរសេររបស់ខ្លួន បានសេចក្តីថា មិនត្រូវធ្វើការឆូតលុបចោល ហើយសរសេរដោយងាយអាន ។ យើងត្រូវទុកចន្លោះឱ្យបានគ្រប់គ្រាន់ ដោយកុំរាវែកចុះបន្ទាត់ នៅរាល់ពេលដែលអ្នកចាប់ផ្តើមគំនិតថ្មី ។

កិច្ចការត្រូវចាប់ផ្តើមដោយសេចក្តីផ្តើម ។ ការអត្ថាធិប្បាយនេះមានសារៈសំខាន់ណាស់ និងត្រូវផ្តិតផ្តង់ជាពិសេស ។ សេចក្តីផ្តើមត្រូវតែឆ្លើយតបទៅនឹងកម្មវត្ថុមួយចំនួន ។ សេចក្តីផ្តើមចូលរួមដោយធាតុផ្សំដូចខាងក្រោមដែលត្រូវចាប់ផ្តើមពីបរិបទទូទៅ ទៅបរិបទពិសេស ។

- វិស័យទូទៅ (ចំណុចដែលត្រូវបកស្រាយជាទូទៅ ដើម្បីអនុញ្ញាតឱ្យបង្ហាញជាពិសេស ចំណុចដែលលើកឡើងក្នុងអត្ថបទ)

Scanned with CamScanner

- ប្រធានបទច្បាស់លាស់ (ត្រូវតែលើកយកពាក្យទាំងឡាយនៃប្រធានបទក្នុងករណីដែលអាចធ្វើបាន)
- រកស្ថានភាពរបស់អត្ថបទ (ប្រភេទ, ប្រភព ឬអ្នកនិពន្ធ, កាលបរិច្ឆេទ, ទីកន្លែង)
- បង្ហាញរចនាសម្ព័ន្ធនៃអត្ថបទ
- បង្ហាញបន្លង់អត្ថាធិប្បាយ

បន្ទាប់មក ត្រូវចាប់ផ្តើមការអត្ថាធិប្បាយតួសេចក្តីលើប្រធានបទ ។ ភាគនីមួយ១ចាប់ផ្តើមដោយឃ្លាផ្តើមដែលបង្ហាញអំពីការបែងចែកភាគរង ។ យើងត្រូវធ្វើឃ្លាភ្ជាប់រវាងភាគនីមួយ១ ដើម្បីបង្ហាញអោយបានល្អនូវដំណើរការនៃការដេញរកហេតុផល ។ ភាគទាំងឡាយអាចមានចំណងជើងមួយ ប៉ុន្តែ វាពុំមានលក្ខណៈចាំបាច់នោះទេ ។ ផ្ទុយទៅវិញ យើងត្រូវប្រុងប្រយ័ត្នចំពោះការគោរពបន្លង់ដែលបានបង្ហាញនៅចំណុចចុងក្រោយនៃសេចក្តីផ្តើម ។

ក្នុងភាគរងនីមួយ១ យើងកុំភ្លេចគំនិតចេញពីអត្ថបទ ដើម្បីជ្រៀសវាងការលើកឡើងមេរៀនដែលគ្មានទំនាក់ទំនងជាមួយនឹងប្រធានបទ ។

តថាខណ្ឌទី ២ : លំហាត់អនុវត្តសម្រាប់ស្រង់ចេញនូវគំនិតសំខាន់ៗពីអត្ថបទ និងរៀបចំគំនិតទាំងនេះ : (បេអាទ្រីស ចាលីវ៉ែ)

១. ថ្លែងសេចក្តី

ចូរស្រង់គំនិតសំខាន់ៗទាំងឡាយនៃអត្ថបទខាងក្រោមនេះ ហើយសាកល្បងរៀបចំគំនិតទាំងនេះប្រកបដោយលក្ខណៈតក្កវិជ្ជា : ក.ស និង ល.ដ. «*បទល្មើសផ្លូវភេទកើនឡើងជាបន្តបន្ទាប់ ថ្វីត្បិតតែនគរបាលកាន់តែមានប្រសិទ្ធភាពក៏ដោយ*», នៅក្នុងកាំបូងស័រ ចុះថ្ងៃទី ១៩, ២០ និង ២១-១២- ២០០៣, ទំព័រ ៧ :

ការប្រឆាំងនឹងបទល្មើសផ្លូវភេទ និងការជួញដូរមនុស្ស បានកើនឡើងយ៉ាងជាក់ច្បាស់ ចាប់ពីមានការបង្កើតកម្មវិធីស៊ើបអង្កេត *លីសិក* កាលពីខែ មេសា ឆ្នាំ ២០០០ ដោយក្រសួងមហាផ្ទៃ និងដោយមានការគាំទ្រពីសហប្រតិបត្តិការជាមួយប្រទេសហូឡង់ ។«មានមនុស្សជាង ៣៦០ នាក់ ត្រូវបានចាប់ខ្លួន និងបញ្ជូនខ្លួនទៅតុលាការ ពីបទឧក្រិដ្ឋប្រភេទនេះ ចាប់ពីខែ មករា ដល់ខែ វិច្ឆិកា ឆ្នាំនេះ ។ ជនទាំងនេះមានចំនួនត្រឹមតែ ជាងសាមសិបនាក់ប៉ុណ្ណោះ ក្នុងឆ្នាំ ១៩៩៩». នេះជាការប្រាប់ឱ្យដឹងកាលពីថ្ងៃព្រហស្បតិ៍ ដោយលោក ត្រីស្ថាន គុត, អ្នកទទួលខុសត្រូវម្នាក់នៃគម្រោងនៅពេលបើកសិក្ខាសាលាវាយតម្លៃថ្នាក់ជាតិ ដែលត្រូវបានអញ្ជើញចូលរួមដោយមន្ត្រីនគរបាលជាន់ខ្ពស់ជាងដប់នាក់ នៅទីក្រុងភ្នំពេញ ។

ប៉ុន្តែ ប្រសិនបើកំណើននៃចំនួនរឿងដែលត្រូវបានបំភ្លឺនេះ បានចង្អុលបង្ហាញនូវប្រសិទ្ធភាពកើនឡើងដប់ដងនៃការងាររបស់កម្លាំងនគរបាល ក៏ដូចជាការបរិហារដែលកាន់តែមានលក្ខណៈស្ងួយប្រវត្តិថែមទៀតនូវអំពើដោយជនរងគ្រោះ ឬដោយអ្នកនៅជុំវិញទៀតនោះ ដោយសារជាអាទិ៍ មកពីមានការបង្កើតប្រព័ន្ធខ្សែទូរស័ព្ទអចិន្ត្រៃយ៍ កំណើននៃចំនួនរឿងដែលត្រូវបំភ្លឺនេះ លាតត្រដាងផងដែរនូវកំណើននៃចំនួនករណី នេះបើតាមការទទួលសារភាពរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឯកឧត្តម ស ខេង ។ ហេតុការណ៍ដែលគួរឱ្យព្រួយបារម្ភយ៉ាងខ្លាំងនោះគឺ : ពាក់កណ្តាលនៃជន

Scanned with CamScanner

រងគ្រោះចំនួន ៦៤១ នាក់ ដែលត្រូវបានធ្វើជម្រឿន នៅក្នុងរយៈពេល ១១ ខែ ចុងក្រោយនេះ សុទ្ធសឹងជាអ្នកនីតិជន ។ យោងតាមអ្នកជំនាញមួយចំនួន ប្រសិនបើការកើនឡើងនៃចំនួនហាងការ្វេដែលនៅទីនោះមានការចាក់ផ្សាយខ្សែភាពយន្តអាសអាភាសនោះ អាចពន្យល់បញ្ជាក់មួយចំណែកនូវការកើនឡើងដ៏ឆាប់រហ័សនៃឧក្រិដ្ឋកម្មផ្លូវភេទនោះឯកឧត្តម ស ខេង បានមានប្រសាសន៍ថា គឺជាលើកដំបូងបំផុត ហានិភ័យដ៏អន់ខ្សោយក្នុងការឆ្លើយតបចំពោះអំពើរបស់ខ្លួន នាំឱ្យមានការផ្តន្ទាទោសពីបទឧក្រិដ្ឋ ។

ពីព្រោះថាពិរុទ្ធជនដ៏ច្រើនលើសលប់បន្តរត់គេចពីទណ្ឌកម្មព្រហ្មទណ្ឌ ដោយមូលហេតុមកពីភាពអន់ខ្សោយនៅក្នុងនីតិវិធីនៃការស៊ើបសួរ និងមានកិច្ចព្រមព្រៀងផ្ទែកហិរញ្ញវត្ថុ ដែលត្រូវបានធ្វើឡើងជាមួយគ្រួសាររបស់ជនរងគ្រោះ ជាក់ស្តែងដូចជាករណីមានការដោះលែងដោយភ្ជាក់ផ្អើលនូវជនជាតិអូទ្រីសម្នាក់ដែលសង្ស័យថារួមភេទជាមួយកុមារ ។ «ប៉ុន្តែ ការផ្តន្ទាទោសចារីនៃឧក្រិដ្ឋកម្មផ្លូវភេទផ្សេងទៀត ពុំមែនគ្រាន់តែជាករណីយកិច្ចផ្ទែកសីលធម៌ធម្មតាប៉ុណ្ណោះទេ: នេះគឺជាកាតព្វកិច្ចនីតិរាជ្យ ៦» នេះជាការរំលឹកឡើងវិញរបស់តំណាងអង្គការយូនីសេហ្វនៅកម្ពុជាឈ្មោះ រ៉ូតនី ហាតហ្វីល ។

ក្រៅពីនេះ ឧបករណ៍ស៊ើបអង្កេតរបស់នគរបាល បានទទួលនូវប្រសិទ្ធភាពគួរឱ្យកត់សម្គាល់ នៅនឹងកន្លែង ជាមួយនឹងការបង្កើតនៅក្នុងក្របខណ្ឌនៃកម្មវិធី *ស៊ីស៊ិក* នូវក្រុមនគរបាលជំនាញចំនួន ១៥០ រូប ដែលត្រូវបែងចែកនៅទូទាំងប្រទេស ។ «ចាប់ពីពេលនេះតទៅ ក្រុមនគរបាលទាំងនេះមានសមត្ថភាពចាប់ផ្តើមការស៊ើបអង្កេត នៅខេត្តសៀមរាប និងបញ្ចប់ការស៊ើបអង្កេតនៅខេត្តស្វាយរៀង ប៉ុន្តែ កាលពីពេលមុន ខេត្តទាំងឡាយត្រូវបានខ័ណ្ឌចែកដាច់ពីគ្នាយ៉ាងញឹកញាប់បំផុត» នេះជាការគូសបញ្ជាក់របស់ឈ្មោះ ត្រីស្យង់ ហ្គត ដែលបានថា ការពឹងពាក់កោសលវិច័យវេជ្ជសាស្ត្រ ការពឹងផ្ទែកលើសំណុំរឿងដែលមានរូបថត និងការពឹងផ្ទែកលើការពណិនាតាមកាលទេសៈ នូវទីកន្លែងកើតហេតុ ក្លាយជាលក្ខណៈស្ងួយប្រវត្តិ ដើម្បីពង្រឹងសំណាងក្នុងការផ្តន្ទាទោសតាមផ្លូវតុលាការ ។

ការបញ្ចូលជាបន្តបន្ទាប់នូវស្ត្រីទៅក្នុងកងឯកភាពទាំងនេះ គឺផ្តល់នូវផ្លែផ្កាខ្លាំងណាស់ នេះបើតាមប្រសាសន៍របស់លោកអធិការប្រចាំខេត្តសៀមរាប លោក ទួន បូផល ។ លោកបានបញ្ជាក់ថា «ជនរងគ្រោះទាំងឡាយមានអារម្មណ៍ធូរស្បើយក្នុងការដាក់ពាក្យបណ្តឹង និងរៀបរាប់រឿងរ៉ាវក្នុងបណ្តឹង» ។ នៅក្នុងខេត្តនេះ ៣៣ រឿងក្នុងចំណោម ៨៤ រឿងដែលទទួលបានក្នុងអំឡុង ១១ ខែ ចុងក្រោយនេះ នឹងត្រូវបានបំភ្លឺ ហើយមនុស្សចំនួន ៤៨ នាក់ ត្រូវបានចាប់ខ្លួន ។ប៉ុន្តែ បើតាមលោកអធិការ ការគម្រាមកំហែងពីសំណាក់ឧក្រិដ្ឋជន មកលើជនរងគ្រោះ នៅតែបង្កើតបានជាឧបសគ្គដ៏សំខាន់ដល់ការងាររបស់នគរបាល ហើយមាននគរបាលមូលដ្ឋានជាច្រើនហួសប្រមាណដែលមានត្រឹមតែគំនិតប្រហាក់ប្រហែល ចំពោះថា តើអ្វីទៅជាឧក្រិដ្ឋកម្មផ្លូវភេទ ។ «ពុំមែនជាការកម្រទេដែលថា មាននគរបាលមួយចំនួនពុំយល់អំពីជលប្រយោជន៍ក្នុងការចុះបញ្ជីនូវករណីរំលោភសេពសន្ថវៈលើកូនប្រសារដោយឪពុកក្មេក ដោយចាត់ទុកថា នេះគ្រាន់តែជារឿងគ្រួសារធម្មតាមួយប៉ុណ្ណោះ» លោកអធិការបានមានប្រសាសន៍ដូច្នេះ ។

«ការផ្លាស់ប្តូរផ្តត់គំនិត និងអាកប្បកិរិយា ចំពោះឧក្រិដ្ឋកម្មផ្លូវភេទ ត្រូវតែកើតមានឡើងទាំងនៅក្នុងភូមិជនបទ ទាំងនៅក្នុងទីប្រជុំជនក្នុងក្រុង» នេះជាសេចក្តីសង្ខេបរបស់ ឡូរ៉ង ហ្គាយ នៃអង្គការមិនមែនរដ្ឋាភិបាល ទស្សនៈ

Scanned with CamScanner

ពិភពលោក ដែលចូលរួមក្នុងកម្មវិធី *លីសិក* ដែលបានរំលឹកថា មានតែការផ្តន្ទាទោសពីបទព្រហ្មទណ្ឌជាលក្ខណៈស្ថេរ-ប្រវត្តិទេ ទើបអាចហាមឃាត់យ៉ាងមានប្រសិទ្ធភាព និងពិតប្រាកដ ចំពោះឧក្រិដ្ឋជន ។

២. តំណែ

តាមទម្រង់ អត្ថបទនេះត្រូវបានបែងចែកជា ៦ កថាខណ្ឌ ហើយទាំងប្រាំមួយកថាខណ្ឌដែលកថាខណ្ឌទាំងនេះពុំបានឆ្លើយតបយ៉ាងចាំបាច់ទៅនឹងគំនិតខុសៗគ្នានោះទេ ។

ដំណាក់កាលទី ១ :

ដើម្បីឱ្យប្រាកដថា ពុំបានភ្លេចចំណុចសំខាន់នោះទេ ជាបឋម យើងនឹងជម្រឿនមួយកថាខណ្ឌម្តងៗ នូវចំណុចផ្សេងៗទាំងឡាយដែលត្រូវបានអធិប្បាយនៅក្នុងអត្ថបទនេះទាក់ទងទៅនឹងបទល្មើសផ្លូវភេទ និងការជួញដូរមនុស្ស ។

កថាខណ្ឌទី ១ លើកឡើងអំពីស្ថានភាពនៃបទល្មើសផ្លូវភេទនៅកម្ពុជា បន្ទាប់ពីមានការបង្កើតកម្មវិធី *លីសិក* នៅខែ មេសា ឆ្នាំ ២០០០ ។ ការពិនិត្យកត់ត្រាបានបង្ហាញឱ្យឃើញអំពីកំណើននៃចំនួនរឿងដែលត្រូវបានបំភ្លឺនៅក្នុងវិស័យនេះ ។

នៅក្នុងកថាខណ្ឌទី ២ មានពីរចំណុចដែលត្រូវបានបកស្រាយ :

- ការកើនឡើងនៃចំនួនរឿងត្រូវបានបំភ្លឺ និងបកស្រាយ ។ ហេតុផលបីយ៉ាងត្រូវបានលើកឡើង :
  - ប្រសិទ្ធភាពការងាររបស់កម្លាំងនគរបាល
  - ការបរិហារកាន់តែមានលក្ខណៈស្ថេរប្រវត្តិនូវអំពើល្មើស ដោយជនរងគ្រោះ
  - កំណើននៃចំនួនករណី ជាពិសេសករណីដែលអនីតិជនក្លាយជាជនរងគ្រោះ ។
- ក៏ប៉ុន្តែ មានគំនិតមួយទៀតដែលស្ថិតនៅក្នុងកថាខណ្ឌនេះ ពីព្រោះថា គេបានតូសបញ្ជាក់ថា ដែនកំណត់មួយចំនួននៃប្រសិទ្ធភាពរបស់កម្លាំងនគរបាល នៅតែមានដដែល គោលការណ៍សំខាន់មកពីមូលហេតុពីរយ៉ាង :
  - ការកើនឡើងនៃទីកន្លែងបញ្ជាំងខ្សែភាពយន្តអាសអាភាស
  - កម្រិតអន់ខ្សោយនៃហានិភ័យក្នុងការទទួលខុសត្រូវចំពោះអំពើទាំងនោះ ។

នៅក្នុងថាខណ្ឌទី ៣ អ្នកនិពន្ធបានពន្យល់អំពីមូលហេតុទាំងឡាយដែលនាំឱ្យអាចគេចផុតពីការផ្តន្ទាទោសពីបទល្មើសព្រហ្មទណ្ឌ។ ត្រូវបានលើកឡើងអំពីភាពអន់ខ្សោយនៃការស៊ើបសួរ និងលទ្ធភាពនៃចរចាខាងផ្នែកហិរញ្ញវត្ថុជាមួយគ្រួសាររបស់ជនរងគ្រោះ ។

កថាខណ្ឌទី ៤ បានលើកឡើងអំពីការពង្រឹងប្រសិទ្ធភាពនៃនគរបាល ជាមួយនឹងការបង្កើតក្រុមនគរបាលជំនាញចំនួន ១៥០ នាក់ ដែលអាចបំពេញបេសកកម្មនៅទូទាំងផ្ទៃប្រទេស ។

កថាខណ្ឌទី ៥ លើកឡើងអំពីការបញ្ជូនស្ត្រីទៅក្នុងកងឯកភាពជំនាញទាំងនេះ ដែលការបញ្ជូលនេះបង្ហាញនូវផ្លែផ្កាដ៏មានអត្ថប្រយោជន៍ ។ គេបានលើកឡើងជាថ្មីថា ការលំបាកមួយចំនួននៅតែមាន សម្រាប់បំភ្លឺសំណុំរឿង និង

Scanned with CamScanner

ទទួលការផ្តន្ទាទោសព្រហ្មទណ្ឌ ដោយហេតុ គម្រាមកំហែងពីសំណាក់ឧក្រិដ្ឋជនមកលើជនរងគ្រោះ និងលើចំណេះដឹងខ្លះ ចន្លោះរបស់កម្លាំងនគរបាលទាក់ទងនឹងឧក្រិដ្ឋកម្មផ្លូវភេទ ។

ជាចុងក្រោយ កថាខណ្ឌទី ៦ បាកតាក់តែជាសេចក្តីសន្និដ្ឋានដ៏តូចមួយ ជាមួយនឹងការអំពាវនាវឱ្យមានការកែប្រែនូវផ្នត់គំនិត ទាំងនៅតាមទីជនបទ និងនៅក្នុងទីក្រុង ។

ដំណាក់កាលទី ពីរ :

នៅក្នុងកិច្ចជំរឿនអំពីព័ត៌មានសំខាន់ៗ ដែលមាននៅក្នុងអត្ថបទនេះ យើងបានពិនិត្យឃើញនូវការលើកឡើងជាច្រើនសានូវគំនិតតែមួយ នៅក្នុងកថាខណ្ឌខុសៗគ្នា ។ ឧទាហរណ៍ គំនិតទាក់ទងនឹងការកើនឡើងនៃចំនួនរឿងដែលត្រូវបានបំភ្លឺ គឺមួយចំណែកបណ្តាលមកពីប្រសិទ្ធភាពរបស់នគរបាល គំនិតនេះលេចឡើងក្នុងកថាខណ្ឌទី ២ ហើយក៏លើកឡើងម្តងទៀត នៅក្នុងកថាខណ្ឌទី ៤ និងទី ៥ ។ នៅក្នុងសេចក្តីអត្ថាធិប្បាយរបស់អ្នក និស្សិត ឬបេក្ខជនប្រឡងត្រូវតែចៀសវាងការនិយាយច្រំដែល ។ ចំណុចនេះត្រូវតែលើកឡើងតែម្តងគត់ ដោយគិតអំពីព័ត៌មានដែលមាននៅក្នុងកថាខណ្ឌនីមួយៗ ។ ដូច្នេះ យើងនឹងសាកល្បងទាញចេញនូវគំនិតសំខាន់ៗ ហើយយើងនឹងអធិប្បាយនូវគំនិតទាំងនេះ ។

អត្ថបទនេះហាក់ដូចជាមានគំនិតសំខាន់ៗពីរ :

- ហេតុផលនៃការកើនឡើងនៃចំនួនរឿងទាក់ទងនឹងបទល្មើសផ្លូវភេទ ដែលជាកម្មវត្ថុនៃការផ្តន្ទាទោសព្រហ្មទណ្ឌ
- ដែនកំណត់នៃការកើនឡើងនៃចំនួនរឿងទាក់ទងនឹងបទល្មើសផ្លូវភេទ ដែលជាកម្មវត្ថុនៃការផ្តន្ទាទោសព្រហ្មទណ្ឌ ។

បន្ទាប់មកទៀត អ្នកនិពន្ធអត្ថបទនេះបានអធិប្បាយគំនិតទាំងពីរនេះ ម្តងមួយៗ :

- ទាក់ទងនឹងគំនិតទីមួយ គេបានលើកឡើងនូវហេតុផលបីយ៉ាង :
  - ប្រសិទ្ធភាពនៃការងាររបស់កម្លាំងនគរបាល ដោយមានការបង្កើតនូវក្រុមជំនាញមានសមត្ថកិច្ចលើផ្ទៃប្រទេស និងការបញ្ចូលស្ត្រីទៅក្នុងអង្គភាពនេះ ។
  - ការប្តឹងបរិហារកាន់តែមានលក្ខណៈស្ម័យប្រវត្តិនូវអំពើល្មើស ដោយជនរងគ្រោះ
  - ការកើនឡើងនូវចំនួនករណី ជាពិសេសករណីដែលអនីតិជនជាជនរងគ្រោះ ។

- ទាក់ទងនឹងគំនិតទីពីរ មានចំណុចសំខាន់ពីរដែលត្រូវបានលើកឡើង :
  - ការកើនឡើងនៃចំនួនទីកន្លែងបញ្ជាំងខ្សែភាពយន្តអាសអាភាស
  - ហានិភ័យអន់ខ្សោយនៃការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ដោយមូលហេតុមកពី :
    - មានការគម្រាមកំហែងពីសំណាក់ឧក្រិដ្ឋជន មកលើគ្រួសារនៃជនរងគ្រោះ
    - ភាពអន់ខ្សោយនៃនីតិវិធីនៃការស៊ើបសួរ
    - កិច្ចព្រមព្រៀងផ្ទៃកហិរញ្ញវត្ថុ ដែលធ្វើឡើងជាមួយគ្រួសារនៃជនរងគ្រោះ

Scanned with CamScanner

-ចំណេះដឹងអន់ខ្សោយស្តីពីឧក្រិដ្ឋកម្មផ្លូវភេទរបស់កម្លាំងនគរបាល ជាពិសេសនៅពេលដែលបទ-
ល្មើស កើតមានឡើងនៅក្នុងវង្វង់គ្រួសារ ។

អ្នកនិពន្ធបានគូសបញ្ជាក់ថា ចំណុចទីមួយ គឺប្រាកដជាមានសារៈសំខាន់តិចជាងចំណុចទីពីរ ដែលចំណុចទីពីរនេះ គឺជាសារៈសំខាន់នៃដែនកំណត់ ។

និស្សិត ឬបេក្ខជនប្រឡង ត្រូវសាកល្បងប្រមូលផ្តុំនូវគំនិតទាំងឡាយដែលអាចប្រហាក់ប្រហែលគ្នា ។ ទាក់ទង នឹងអំណះអំណាងស្តីពីហានិភ័យអន់ខ្សោយនៃការទទួលខុសត្រូវលើអំពើរបស់ខ្លួន យើងអាចពិនិត្យឃើញថា ការគម្រាម កំហែងមកលើគ្រួសារនៃជនរងគ្រោះ និងកិច្ចព្រមព្រៀងដែលធ្វើឡើងជាមួយនឹងគ្រួសារនៃជនរងគ្រោះបង្ហាញនូវចំណុច រួមមួយ : នៅក្នុងករណីទាំងពីរនេះ គឺជាបញ្ហានៃអាកប្បកិរិយារបស់គ្រួសារនៃជនរងគ្រោះ ។ដូច្នេះ យើងត្រូវអធិប្បាយ ចំណុចទាំងពីរនេះជាមួយគ្នា ។ ដូចគ្នាដែរ ភាពអន់ខ្សោយនៃនីតិវិធីនៃការស៊ើបសួរ ព្រមទាំងចំណេះដឹងអន់ខ្សោយអំពី ឧក្រិដ្ឋកម្មផ្លូវភេទរបស់អាជ្ញាធរនគរបាល បង្កើតបានជាការរិះគន់ចំពោះអាជ្ញាធរតុលាការ ។ ដូច្នេះ ចំណុចទាំងពីរនេះ អាចត្រូវបានអធិប្បាយនៅក្នុងអនុផ្នែកតែមួយ ។

ជំណាក់កាលទី ៣ :

ក្នុងករណីដែលគំនិតទាំងឡាយត្រូវបានទាញចេញមក និងត្រូវបានរៀបចំ យើងអាចតាក់តែងប្លង់សំរាប់ធ្វើអត្ថា
អធិប្បាយ :

I. មូលហេតុនៃការកើនឡើងសំណុំរឿងទាក់ទងនឹងបទល្មើសផ្លូវភេទដែលជាកម្មវត្ថុនៃការផ្តន្ទាទោសព្រហ្មទណ្ឌ

ចំនួនរឿងដែលបានធ្វើជាកម្មវត្ថុនៃការផ្តន្ទាទោសព្រហ្មទណ្ឌ បានកើនឡើងគួរឱ្យកត់សម្គាល់ ចាប់ពីឆ្នាំ ១៩៩៩ ដោយសារមូលហេតុសំខាន់ៗបីយ៉ាង ដែលនឹងត្រូវលើកឡើងជាបន្តបន្ទាប់នេះ ។

ក. ប្រសិទ្ធភាពនៃនគរបាល

នៅក្នុងអនុផ្នែកនេះ គេត្រូវអធិប្បាយអំពីការពង្រឹងតួនាទីរបស់នគរបាល ដោយមានការបង្កើតនូវក្រុមនគរ-បាលជំនាញចំនួន ១៥០ នាក់ ។ ក្រុមនគរបាលទាំងនេះ កាន់តែមានប្រសិទ្ធភាពដោយសារតែឯកទេសកម្មរបស់ខ្លួន និង ដោយសារតែសមត្ថកិច្ចលាតសន្ធឹងលើផ្ទៃប្រទេសទាំងមូល ។ ម្យ៉ាងទៀត គួរគូសបញ្ជាក់អំពីការបញ្ចូលប្រកបដោយ អត្ថប្រយោជន៍នូវស្ត្រីទៅក្នុងអង្គភាពនេះ ។

ខ. ការប្តឹងចរិហារកម្មរំលើអាយុជនរងគ្រោះ

មធ្យោបាយមួយចំនួន ត្រូវបានបង្កើតឡើង ដើម្បីអនុញ្ញាតឱ្យជនរងគ្រោះ អាចប្តឹងបរិហារកាន់តែងាយស្រួល ចៃមទៀតពីជនល្មើស ។ យើងត្រូវធ្វើឱ្យការបង្កើតប្រព័ន្ធខ្សែទូរស័ព្ទអចិន្ត្រៃយ៍កាន់តែឈានទៅមុខ ។

Scanned with CamScanner

ជ. ការកើនឡើងនៃចំនួនការណី

ជាចុងបញ្ចប់ ប្រសិនបើចំនួនករណីដែលត្រូវបានបំភ្លឺកើនឡើង ប្រហែលជាបណ្តាលមកពីមានការកើនឡើងនៃចំនួនករណីផងដែរ ជាអាទិ៍ ករណីដែលអនីតិជនជាជនរងគ្រោះ ។

II. ដែនកំណត់ចំពោះការកើនឡើងនៃចំនួនរឿង ទាក់ទងនឹងបទល្មើសផ្លូវភេទដែលធ្វើជាកម្មវត្ថុនៃការផ្តន្ទាទោសព្រហ្មទណ្ឌ

ក្រៅពីការបើកនូវកន្លែងបញ្ចាំងខ្សែភាពយន្តអាសអាភាសដែលកាន់តែកើនឡើង មានប្រាំងពីរសំខាន់ៗដែលកម្រិតការកើនឡើងនៃចំនួនរឿងដែលអាចធ្វើជាកម្មវត្ថុនៃការផ្តន្ទាទោសព្រហ្មទណ្ឌ ។ ប្រាំងទាំងនេះ មានប្រភពចេញមកពីភាពអន់ខ្សោយរបស់នគរបាល (ក) និងអាកប្បកិរិយារបស់គ្រួសារនៃជនរងគ្រោះ (ខ) ។

ក. ភាពអន់ខ្សោយនៃអាជ្ញាធរតុលាការ

ផ្នែកនេះទាក់ទងនឹងភាពពុំគ្រប់គ្រាន់នៃនីតិវិធីស៊ើបសួរ និងចំណេះដឹងអន់ខ្សោយរបស់នគរបាល ស្តីពីបទល្មើសផ្លូវភេទ ។

ខ. អាកប្បកិរិយារបស់គ្រួសារនៃជនរងគ្រោះ

គ្រួសារនៃជនរងគ្រោះ ពុំមានប្រតិកម្មឆ្លើយតបយ៉ាងចាំបាច់ទៅកាន់អាជ្ញាធរ ដើម្បីឱ្យមានការផ្តន្ទាទោសព្រហ្មទណ្ឌឡើយ ជួនកាលបណ្តាលមកពីគ្រួសារទាំងនោះភ័យខ្លាចចំពោះជនល្មើស ជួនកាលទៀតបណ្តាលមកពីគ្រួសារទាំងនោះបានព្រមព្រៀងខាងផ្នែកហិរញ្ញវត្ថុជាមួយជនល្មើស ។

ការងារលើក្រដាសព្រាងបានចប់សព្វគ្រប់ យើងអាចតាក់តែងការអធិប្បាយផ្នែកនីមួយៗ ។

តថាខណ្ឌទី ៣ : លំហាត់អនុវត្តន៍ធីសាស្ត្រតាមដំណាក់កាលនីមួយៗ :
(បេអាទ្រីស ចាលីវ៉ូ)

ក. ការអធិប្បាយលើមាត្រា ៨ នៃក្រឹត្យ-ច្បាប់លេខ ៣៨ ចុះថ្ងៃទី ២៨-១០-១៩៨៨ ស្តីពីតិចួសន្យា និងការទទួលខុសត្រូវត្រៅតិចួសន្យា

មាត្រា ៨ នៃ ក្រឹត្យ-ច្បាប់លេខ ៣៨ ចែងថា :

"ការភ័ន្តច្រឡំនឹងទៅជាមូលហេតុមោឃភាពនៃកិច្ចសន្យាបាន បើមានការភ័ន្តច្រឡំទៅលើសារជាតិនៃរបស់ដែលជាកម្មវត្ថុនៃកិច្ចសន្យា ។

ការភ័ន្តច្រឡំទៅលើបុគ្គល មិនអាចចាត់ទុកជាមូលហេតុមោឃភាពនៃកិច្ចសន្យាបានឡើយលើកលែងតែបុគ្គលនោះជា មូលហេតុចម្បងនៃកិច្ចសន្យា ។"

Scanned with CamScanner

ខ- តំណែលំហាត់ :

ដើម្បីអធិប្បាយអត្ថបទ យើងត្រូវគោរពតាមលំដាប់ដូចខាងក្រោមនេះ :

ដំណាក់កាលទី ១ : ការកំណត់ស្ថានភាព

យើងពុំត្រូវសញ្ជឹងគិតភ្លាម១ទៅលើអត្ថបទនោះទេ ។ យើងត្រូវប្រមូលផ្តុំជាបឋមនូវព័ត៌មានទាំងឡាយដែលបង្កើតជាដំណាក់កាលមួយមានឈ្មោះថា "ការកំណត់ស្ថានភាពនៃអត្ថបទ" ។ ក្រោយពីបានអាន យើងត្រូវចេះឆ្លើយតបទៅនឹងសំណួរដូចខាងក្រោម :

- តើអត្ថបទនេះមានប្រភេទជាអ្វី និងមានប្រភពមកពីណា ?
  - ប្រភេទនៃអត្ថបទ : ក្រឹត្យ-ច្បាប់
  - កាលបរិច្ឆេទ : ២៨-១០-១៩៨៨ (មុនរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ : មាត្រា ១៥៨ នៃរដ្ឋធម្មនុញ្ញ : ក្នុងករណីដែលគ្មានអត្ថបទថ្មីនោះទេ យើងអាចលើកយកក្រឹត្យ-ច្បាប់នេះមកអនុវត្តបាន) ។
  - ទីកន្លែងដកស្រង់ក្នុងអត្ថបទ ឬស្បៀវភៅ : ក្រឹត្យ-ច្បាប់លេខ ៣៨ ចុះថ្ងៃទី ២៨-១០-១៩៨៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ។ ជំពូកទី ១ ស្តីពីកិច្ចសន្យា, ផ្នែកទី ៣ ស្តីពីការប្រកាសមោឃភាពកិច្ចសន្យា ។

- តើវិស័យទូទៅនៃអត្ថបទ និងកម្មវត្ថុយ៉ាងជាក់ច្បាស់របស់វាមានអ្វីខ្លះ ?

វិស័យទូទៅ គឺជាលក្ខខណ្ឌនៃការបង្កើតកិច្ចសន្យា និងការប្រកាសមោឃភាព ។ វិស័យយ៉ាងជាក់ច្បាស់របស់វាគឺការៈនៃការបង្ហាញឆន្ទៈ ជាពិសេស ការព័ន្ធច្រឡំ ។

- តើប្រធានបទនេះត្រូវបានបង្ហាញយ៉ាងដូចម្តេច ?
  - ទំហំ : អត្ថបទខ្លី ហើយមានតែពីរកថាខណ្ឌប៉ុណ្ណោះ ។
  - ការបែងចែកជាចំហរ : ពីរវាក្យខណ្ឌ ។

ដំណាក់កាលទី ២ : ការវិភាគប្រធានបទ

ការវិភាគអត្ថបទដ៏ល្អត្រូវការជាចាំបាច់នូវការអានឱ្យបានច្រើនដង ។ ដោយអនុវត្តនីតិវិធីនៃការអាននេះ យើងត្រូវកំណត់ចំណាំនៅក្នុងអត្ថបទ ត្រូវបែងចែកដោយវង់ដង្កៀប ដើម្បីអាចមើលឃើញនូវគំនិតផ្សេង១ដែលបានបង្ហាញនៅក្នុងអត្ថបទនេះ ហើយត្រូវគូសបន្ទាត់ពីក្រោមពាក្យដែលត្រូវពន្យល់ ។

"<u>ការព័ន្ធច្រឡំនឹងទៅជាមូលហេតុមោឃភាពនៃកិច្ចសន្យាបាន</u> **បើមានការព័ន្ធច្រឡំទៅលើ<u>សារជាតិនៃរបស់</u>** ដែលជា<u>កម្មវត្ថុនៃកិច្ចសន្យា</u> ។

Scanned with CamScanner

ការភ័ន្តច្រឡំទៅលើបុគ្គល **<u>មិនអាចចាត់ទុកជាមូលហេតុមោឃភាពនៃកិច្ចសន្យាបានឡើយ</u>** **<u>លើកលែងតែបុគ្គលនោះជាមូលហេតុចម្បងនៃកិច្ចសន្យា</u>** ។"

- ស្វែងរកពាក្យដើម្បីគូសបន្ទាប់ពីក្រោម :

ក្នុងអត្ថបទដ៏ខ្លី ពាក្យនីមួយ១ "ឧទាហរណ៍ អាច ឬត្រូវតែ" អាយតនិបាតនីមួយ១ "និង/ឬ" គុណកិរិយានីមួយ ១ "យ៉ាងជាក់ច្បាស់, ជាទម្លាប់" ត្រូវធ្វើការកំណត់សម្គាល់ និងពន្យល់ ។

ការភ័ន្តច្រឡំ : ការបង្ហាញពុំពិតប្រាកដនៃភាពជាក់ស្តែងមួយ ។

មោឃភាព : ការលុបចោលដោយមានអានុភាពប្រតិសកម្មចំពោះលិខិត ដោយមូលហេតុនៃការពុំគោរពតាមលក្ខខណ្ឌ ណាមួយនៃការបង្កើតកិច្ចសន្យា ។

កិច្ចសន្យា : មាត្រា ១ នៃក្រឹត្យ-ច្បាប់លេខ ៣៨ : កិច្ចសន្យា គឺជាឆន្ទៈព្រមព្រៀងរវាងបុគ្គលពីរនាក់ ឬច្រើននាក់ ដើម្បីបង្កើត កែប្រែ ឬ រំលត់ កាតព្វកិច្ចមួយ ឬច្រើនដែលទាក់ទិននឹងខ្លួន។

វត្ថុ : កម្មវត្ថុដែលសិទ្ធិបុគ្គលវិស័យមានវត្តមានទាក់ទង់វា ។

ការភ័ន្តច្រឡំលើវត្ថុ : ការបង្ហាញពុំពិតប្រាកដនូវសារជាតិនៃវត្ថុ ដែលជាកម្មវត្ថុនៃកាតព្វកិច្ច ។ ឧទាហរណ៍ ខ្ញុំបានទិញគ្រឿងអលង្ការមួយ ដែលខ្ញុំយល់ថាវាធ្វើពីមាស ប៉ុន្តែ តាមពិតវាស្រោបពីមាសទេវិញ ។ ប៉ុន្តែ ការបកស្រាយនេះ មានលក្ខណៈតឹងរឹង ។ មានអ្នកខ្លះលើកសំណើ ដោយលាតសន្ធឹងរហូតដល់គុណភាពសំខាន់របស់វត្ថុ ។ តាមពិត នៅពេលយើងទិញផ្ទាំងគំនូរមួយ ដោយជឿជាក់ថា គឺជាផ្ទាំងគំនូររបស់ចិត្រករដ៏ល្បីដូចជា ពីកាសូ វាពុំមានការភ័ន្តច្រឡំលើសារជាតិនៃវត្ថុទេ តែគ្រាន់តែមានការភ័ន្តច្រឡំលើគុណភាពសំខាន់ ។ ក្នុងយោបល់ភាគច្រើន គុណភាពសំខាន់ គឺជាគុណភាពនៃវត្ថុដែលអ្នកភ័ន្តច្រឡំ មានបំណងជាចម្បងនូវអ្វីដែលកំណត់អំពីឆន្ទៈរបស់គាត់ ហើយធាតុនោះអវត្តមាន បើសិនជាគាត់ដឹងថាគ្មាន គាត់នឹងមិនចុះកិច្ចសន្យានោះទេ ។

ប្រភេទ : ប្រភេទនៃវត្ថុ សំដៅទៅលើសារជាតិដែលបង្កើតជាលក្ខណៈពិសេសរបស់វា ។

កម្មវត្ថុនៃកិច្ចសន្យា : កម្មវត្ថុនៃកិច្ចសន្យាគឺជាតាវកាលិក ដែលភាគីម្ខាក់មានកាតព្វកិច្ចត្រូវធ្វើ ។ ដោយនិយាយលើសពីនេះ វត្ថុគឺជាកម្មវត្ថុនៃកិច្ចសន្យា ប៉ុន្តែ វាគ្រាន់តែជាកម្មវត្ថុនៃកាតព្វកិច្ចតែប៉ុណ្ណោះ ។ ឧទាហរណ៍ ក្នុងកិច្ចសន្យាលក់មួយ កម្មវត្ថុនៃកិច្ចសន្យាគឺការផ្ទេរកម្មសិទ្ធិនៃវត្ថុ ។ ការផ្ទេរសិទ្ធិកម្មសិទ្ធិនៃវត្ថុ គឺជាកាតព្វកិច្ចរបស់អ្នកលក់ ។ កាតព្វ-កិច្ចនេះមានកម្មវត្ថុ គឺទ្រព្យ ឬវត្ថុ ។

ការភ័ន្តច្រឡំលើបុគ្គល : ការបង្ហាញពុំពិតប្រាកដនូវបុគ្គលជាភាគីនៃកិច្ចសន្យា ។ ការភ័ន្តច្រឡំនេះ ជាប្រភពនៃការប្រ-កាសមោឃភាព តែក្នុងករណីដែលកិច្ចសន្យា គុណភាពបុគ្គលមានលក្ខណៈចាំបាច់ប៉ុណ្ណោះ ។ គឺជាករណីនៃកិច្ចសន្យាកុសលកម្ម ដូចជាប្រទានកម្ម ដែលអ្នកទទួលអំណោយដើរតួនាទីយ៉ាងសំខាន់ ។ ដូចគ្នាដែរ ករណីកិច្ចសន្យាមុលាមួយចំនួន : កិច្ចសន្យាអណត្តិ កិច្ចសន្យាជួលអចលនវត្ថុ កិច្ចសន្យាការងារ។ ការភ័ន្តច្រឡំទាក់ទងនឹងធាតុផ្សំនៃបុគ្គលិកលក្ខ-ណៈនៃភាគីកិច្ចសន្យា ដែលការបង្ហាញឆន្ទៈរបស់គាត់មានលក្ខណៈសំខាន់ ។ វាក៏អាចជាការភ័ន្តច្រឡំលើអត្តសញ្ញាណរូបរាងខាងក្រៅរបស់ភាគីកិច្ចសន្យាដែរ "ការសម្រាកព្យាបាលនៅមន្ទីរពេទ្យបន្ទាប់ពីជួបប្រទះគ្រោះថ្នាក់, ការដោះដូរ

Scanned with CamScanner

ឯកសារ ។ ដូច្នេះ យើងភ័ន្តច្រឡំទៅលើជនរងគ្រោះ និងតួភាគីដែលចូលរួមចរចា ។ ការភ័ន្តច្រឡំអាចទាក់ទងនឹងអត្ត សញ្ញាណរដ្ឋប្បវេណី ឬគុណភាពសំខាន់របស់បុគ្គល : កិត្តយស, អនាគត... ។ល ។

មូលហេតុចម្បងនៃកិច្ចសន្យា : ធាតុផ្សំសំខាន់នៃកិច្ចសន្យា ។

- ការស្វែងរកចនាសម្ព័ន្ធអត្ថបទ :

គឺជាដំណាក់ដែលយើងត្រូវសួរអំពីបែបបទនៃការបង្កើតអត្ថបទ ។

- រចនាសម្ព័ន្ធនៃវិធីរៀបអក្សរបោះពុម្ព ឬវេយ្យាករណ៍ :

អត្ថបទត្រូវបានបែងចែកជាពីរភាគ : ភាគទី ១ : វាក្យខណ្ឌទី ១ និងភាគទី ២ : វាក្យខណ្ឌទី ២ ។

- រចនាសម្ព័ន្ធតាមបែបតក្កវិជ្ជា :

ល្បៈទី ១ : ការភ័ន្តច្រឡំលើវត្ថុ

ល្បៈទី ២ : ការភ័ន្តច្រឡំលើបុគ្គល

- ការស្វែងរកអត្ថន័យនៃអត្ថបទ

គឺជាការសិក្សាអំពីវិការៈនៃការបង្ហាញឆន្ទៈ ដែលជាមូលហេតុនៃការប្រកាសមោឃភាព ។ ករណី និងលក្ខខណ្ឌ ទាំងឡាយត្រូវបានបញ្ជាក់ ក្នុងករណីដែលការភ័ន្តច្រឡំបណ្តាលឱ្យមានការប្រកាសមោឃភាព ។

ដំណាក់កាលទី ៣ : ពាក់ព័ន្ធបន្ថែម

ជាទូទៅ អត្ថាធិប្បាយអត្ថបទ ត្រូវបានបង្កើតឡើងដោយបន្ថែមរបស់អត្ថបទខ្លួនឯង ។ បើពុំដូច្នោះទេ និស្សិត ឬ បេក្ខជនប្រឡងត្រូវបង្កើតបន្ថែមគំនិត ។ ក្នុងករណីនេះ ទាំងរចនាសម្ព័ន្ធខាងវេយ្យាករណ៍ និងខាងតក្កវិជ្ជា អនុញ្ញាតឱ្យមាន ការបែងចែកការអធិប្បាយជាពីរភាគសំខាន់ ភាគីទី ១ ទាក់ទងនឹងការភ័ន្តច្រឡំលើវត្ថុ និងភាគទី ២ ទាក់ទងនឹងការភ័ន្ត ច្រឡំលើបុគ្គល ។

គំនិតសំខាន់ទាំងពីរនេះត្រូវតែបញ្ជាក់លើកឡើងដើម្បីកំណត់អំពីភាគរង ។

I. ការភ័ន្តច្រឡំលើវត្ថុ :

ការភ័ន្តច្រឡំលើវត្ថុអាចធ្វើជាមូលហេតុនៃការប្រកាសមោឃភាពកិច្ចសន្យា តែក្នុងករណីដែលការភ័ន្តច្រឡំ ទាក់ទងនឹងធម្មជាតិនៃវត្ថុ សារធាតុនៃវត្ថុ ។ យើងអាចសួរថា តើសញ្ញាណនេះត្រូវបានទទួលយកតែក្នុងន័យជាវត្ថុ វិស័យ និងត្រូវតម្រង់តែចំពោះសារធាតុដែលចូលរួមបង្កើតវត្ថុនោះ ឬតើសញ្ញាណនេះ អាចលាតសន្ធឹងដោយអត្ថវិស័យ និងត្រូវតែបូកផ្សំនូវរាល់គុណភាពសំខាន់របស់វត្ថុ ។

ចំណុចទាំងពីរនេះនឹងត្រូវបកស្រាយដាច់ពីគ្នា ដោយចាប់ផ្តើមពីការអានដោយម៉ឺងម៉ាត់មាត្រា ៨ នៃក្រឹត-ច្បាប់លេខ ៣៨ (ក) បន្ទាប់មក ការអានដោយទូលំទូលាយ ដែលអនុញ្ញាតឱ្យយើងអាចប្រមូលផ្តុំនូវរាល់គុណភាពសំខាន់ របស់វត្ថុ (ខ) ។

Scanned with CamScanner

ក. ការភ័ន្តច្រឡំលើសារធាតុរបស់វត្ថុ

ខ. ការភ័ន្តច្រឡំលើគុណភាពសំខាន់របស់វត្ថុ

II. ការភ័ន្ត ច្រឡំលើបុគ្គល

មាត្រា ៨ នៃក្រឹត-ច្បាប់លេខ ៣៨ ចែងជាគោលការណ៍ថា : ការភ័ន្តច្រឡំលើបុគ្គលពុំត្រូវបានចាត់ទុកជាមូលហេតុនៃការប្រកាសមោឃភាពកិច្ចសន្យានោះទេ (ក) ។ ប៉ុន្តែ បដិបញ្ញត្តិលើកឡើងថា ការភ័ន្តច្រឡំអាចជាមូលហេតុនៃការប្រកាសមោឃភាព ចំពោះកិច្ចសន្យាដែលគុណភាពរបស់បុគ្គលមានលក្ខណៈសំខាន់ (ខ) ។ ការបែងចែកជាគំនិតមានលក្ខណៈជាក់ស្តែងក្នុងអត្ថបទនេះ ។

ក. កិច្ចសន្យាធម្មតា

ខ. កិច្ចសន្យាដែលគុណភាពរបស់បុគ្គលមានលក្ខណៈសំខាន់

តថាខណ្ឌទី ៤ : លំហាត់អនុវត្តន៍ជាក់ស្តែង

ដើម្បីអាចហ្វឹកហាត់ខ្លួនឯង និស្សិត ឬបេក្ខជនប្រឡងអាចធ្វើអត្ថាធិប្បាយអត្ថបទដែលត្រូវបានបង្ហាញក្នុងមុខវិជ្ជានីមួយ ១ ។

ក. និតិភាណិជ្ជតម្ម

១. ប្រែសាន្តបទ

ចូរធ្វើអត្ថាធិប្បាយមាត្រា ១១២ នៃក្រឹត្យ-ច្បាប់ លេខ ៣៨ ចុះថ្ងៃ ២៨-១០-១៩៨៨ :

"កិច្ចធានាដោយបុគ្គលជាកិច្ចសន្យាដែលតតិយជនម្នាក់ហៅថាអ្នកធានា សន្យានឹងដើមបំណុលថាខ្លួននឹងបំពេញកាតព្វកិច្ចជំនួសកូនបំណុល ប្រសិនបើកូនបំណុលនេះមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនទេ ។ កិច្ចសន្យាត្រូវសរសេរជាលាយលក្ខណ៍អក្សរ ។"

២. សេចក្តីអត្ថាធិប្បាយ : (សុម សុខម្ង)

ក្រោយពីមានការផ្លាស់ប្តូរយ៉ាងប្រយុត្តប្រយែងពីរបបសេដ្ឋកិច្ចផែនការមករបបសេដ្ឋទីផ្សារសេរី យើងសង្កេតឃើញមានការកើនឡើងឥតឈប់ឈរនូវថ្លៃចាយវាយចាំបាច់សម្រាប់ចិញ្ចឹមជីវិត ។ ការណ៍នេះបានជំរុញឱ្យបុគ្គលមួយចំនួនដែលជួបប្រទះនឹងការលំបាកត្រូវបង្ខំចិត្តរត់ទៅរកបច្ចេកទេសនានាស្តីពីការខ្ចីបុលចងការប្រាក់ ឬនិយាយជារួមការប្រើប្រាស់ឥណទានដើម្បីរក្សា ឬកែរលម្អរកម្រិតជីវភាពរបស់ខ្លួន ។ តែបញ្ហាចម្បងដែលតែងតែចោទឡើងគ្រប់កាលគ្រប់វេលានៅក្នុងសង្គមមួយដែលមានការរត់ប្រណាំងគ្នារវាងភាពមានបាន និងភាពក្រីក្រ នោះគឺការចង់ដឹងចង់ឮថាតើមានបែបបទអ្វីខ្លះ ដែលបុគ្គលម្នាក់យល់ព្រមផ្តល់ប្រាក់ឥណទានទៅដល់បុគ្គលម្នាក់ទៀត ក្នុងករណីស្ថានភាពហិរញ្ញវត្ថុរបស់បុគ្គលក្រោយមានលក្ខណៈគួរឱ្យសង្ស័យដោយគ្មានសំណាងនឹងបានទទួលប្រាក់សំណងនោះត្រលប់វិញទេមើលទៅ ។ ដោយយល់ពីបញ្ហានេះហើយ ទើបម្ចាស់បំណុល ឬឥណទាយកជាច្រើនតែងតែទាមទារឱ្យមានជាញឹកញាប់នូវការដាក់

Scanned with CamScanner

ការធានាពីកូនបំណុលដែលវាអាចជាករណីនៃការដាក់របស់បញ្ចាំ (ការអនុវត្តន៍ប្រាតិភោគប្រត្យក្ស) ឬការធានាពីបុគ្គលណាម្នាក់ទៀត (តតិយជន ពោលគឺជនទីទែក្រៅពីកិច្ចសន្យាដើម) ដែលគាត់អាចទុកចិត្តបាន មុននឹងគាត់ផ្តល់ឥណទាន ។

ទោះបីជាកិច្ចធានាដោយបុគ្គលត្រូវបានគេប្រើប្រាស់ជាញឹកញាប់ក៏ដោយ ក៏អត្ថន័យនឹងវិបាករបស់វានៅតែមានលក្ខណៈស្រពិចស្រពិលសម្រាប់អ្នកអនុវត្តដដែល ។ កង្វះខាតនូវការស្រាយបញ្ហាក៏ដ៏ល្អិតល្អន់លើបញ្ហានេះ បានបង្កឱ្យមានការលំបាកជាច្រើន ជាពិសេសវាក៏បានក្លាយជាប្រភពនៃវិវាទជាច្រើនផងដែរ ។ ដើម្បីឆ្លើយតបនឹងតម្រូវការនេះ ក្រុមប្រឹក្សានៃសាធារណរដ្ឋប្រជាមានិតកម្ពុជាបានអនុម័តផ្តល់និយមន័យដល់ពាក្យថា កិច្ចធានាដោយបុគ្គលដូចមានចែងយ៉ាងច្បាស់នៅក្នុងបញ្ញត្តិនៃមាត្រា ១១២ នៃផ្នែកទី ៩ របស់ក្រ-ច លេខ ៣៨ ចុះថ្ងៃ ២៨-១០-១៩៨៨ ស្តីពីកិច្ចសន្យានិងការទទួលខុសត្រូវក្រៅកិច្ចសន្យា ។ មាត្រានេះបានឱ្យនិយមន័យកិច្ចធានាដោយបុគ្គលថា " *ជាកិច្ចសន្យាដែលតតិយជនម្នាក់ហៅថាអ្នកធានា សន្យានឹងដើមបំណុលថា ខ្លួននឹងបំពេញកាតព្វកិច្ចជំនួសកូនបំណុល ប្រសិនបើកូនបំណុលនេះមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនទេ ។ កិច្ចសន្យាត្រូវសរសេរជាលាយលក្ខណ៍អក្សរ ។* "

ទោះបីជាក្រុមប្រឹក្សារដ្ឋពង្រឹងធ្វើការកំណត់និយមន័យលើកិច្ចធានា និងធ្វើការបំភ្លឺប្រតិបត្តិការខាងកិច្ចសន្យាក៏ដោយ មាត្រាខាងលើនៅតែបន្សល់ទុកនូវមន្ទិលទាំងលើលក្ខខណ្ឌនានានៃការបង្កើតកិច្ចសន្យាប្រភេទនេះ ក៏ដូចជាអានុភាពផ្សេងៗរបស់វាដែរ ។ អំណានមាត្រានេះតែម៉្យាង ពុំគ្រប់គ្រាន់សម្រាប់ឱ្យយើងរកឱ្យឃើញអំពីលក្ខណសុពលភាព ឬការអនុវត្តន៍កិច្ចសន្យានោះទេ ។ នេះមានន័យថា ភាពស្រពិចស្រពិលស្តីពីការបង្កើត ព្រមទាំងអានុភាពរបស់វា (II) អាចនឹងស្រាយបំភ្លឺបាន តែខណៈពេលដែលយើងធ្វើការពិនិត្យយ៉ាងល្អិតល្អន់លើកាតព្វកិច្ចធានារបស់តតិយជនដែលជាអ្នកធានាជាបឋម (I) ។

I. ចរិតលក្ខណៈរបស់កិច្ចសន្យាធានាដោយបុគ្គល :

មាត្រា ១១២ នៃផ្នែកទី ៩ របស់ក្រ-ច លេខ ៣៨ ចុះថ្ងៃ ២៨-១០-១៩៨៨ បានចែងយ៉ាងច្បាស់ឥតមន្ទិលថា អ្នកធានាក្តី កូនបំណុលចម្បងក្តី គឺត្រូវទទួលខុសត្រូវចំពោះបំណុលតែមួយដូចគ្នា ។ នេះដោយហេតុថា អ្នកធានាបានសន្យាចំពោះមុខដើមបំណុលថាខ្លួននឹងបំពេញកាតព្វកិច្ចជំនួសកូនបំណុល ប្រសិនបើកូនបំណុលនេះពុំអនុវត្តកាតព្វកិច្ចរបស់ខ្លួនទេនោះ ។

ដូចនេះប្រភេទកាតព្វកិច្ចរបស់អ្នកធានាអាស្រ័យទាំងស្រុងទៅលើប្រភេទកាតព្វកិច្ច ដែលកើតពីចំណងគតិយុត្តរវាងម្ចាស់បំណុល និងកូនបំណុល ។ ក្នុងន័យនេះដែរ ការប្តឹងទាមទារការទទួលខុសត្រូវពីអ្នកធានាក៏ពឹងផ្អែកផងដែរ លើការបំពេញ ឬមិនបំពេញកាតព្វកិច្ចរបស់កូនបំណុល ពោលគឺអ្នកធានានឹងទទួលបំពេញកាតព្វកិច្ចជំនួសកូនបំណុលបានតែក្នុងករណីដែលកូនបំណុលនោះអនុវត្តកាតព្វកិច្ចរបស់ខ្លួនមិនបានល្អប៉ុណ្ណោះ ។ ទាំងនេះសរឱ្យឃើញនូវលក្ខណៈបន្ទាប់បន្សំរបស់កិច្ចសន្យាធានាធៀបទៅនឹងកិច្ចសន្យាដែលធ្វើឡើងរវាងម្ចាស់បំណុលនិងកូនបំណុលដែលជាកិច្ចសន្យាចម្បង(ក) ។ អំណានមាត្រាដដែលខាងលើអាចអនុញ្ញាតឱ្យយើងរកឃើញផងដែរ នូវចរិតលក្ខណៈពិសេស២ដទៃទៀតរបស់វានោះគឺលក្ខណៈពិសេសដែលជួនកាលបានមកពីមូលហេតុនៃកិច្ចសន្យា ឯជួនកាលទៀតបានមកពីទម្រង់បែបបទក្នុងការបង្កើតវាផ្ទាល់តែម្តង (ខ) ។

Scanned with CamScanner

ក. កិច្ចធានាដោយបុគ្គល : កិច្ចសន្យាបន្ទាប់បន្សំរវាងនីតិកាតព្វកិច្ចចម្បង

តាមពិត កិច្ចសន្យាធានាដោយបុគ្គលដែលត្រូវបានគេចាត់ថ្នាក់ជាប្រភេទប្រាតិភោគបុគ្គលនោះ មិនខុសពីប្រាតិភោគដទៃៗឡើតទេ គឺគ្រាន់តែជាកាតព្វកិច្ចបន្ទាប់បន្សំប៉ុណ្ណោះ ដោយហេតុថាកាតព្វកិច្ចក្នុងកិច្ចធានាដោយបុគ្គលពុំអាចមានអត្ថិភាពបានទេ បើគ្មានកាតព្វកិច្ចចម្បង (បំណុលដែលកើតពីកិច្ចសន្យារវាងម្ចាស់បំណុល និងកូនបំណុល) ដែលអ្នកធានាត្រូវធានាបំណុលនោះ ។ យោងតាមការពិនិត្យលើមាត្រាខាងលើនេះ កាតព្វកិច្ចរបស់អ្នកធានា និងកាតព្វកិច្ចរបស់កូនបំណុល ពិតជាមានទំនាក់ទំនងគ្នាទៅវិញទៅមក។ ទំនាក់ទំនងនេះស្តែងឡើងតាមពីរកម្រិត ។

កម្រិតទី ១ យើងអាចចាត់ទុកថា កាតព្វកិច្ចទាំងនោះមានលក្ខណៈពឹងគ្នាទៅវិញទៅមក ដោយហេតុថា អ្នក-ធានា និងកូនបំណុលចម្បង ចូលរួមគ្នាក្នុងការបំពេញកាតព្វកិច្ចតែមួយដូចគ្នា ។ ដូចមានសេចក្តីបញ្ជាក់ក្នុងបញ្ញត្តិនៃមាត្រា ១១២ ថា : " ...តតិយជនម្នាក់ហៅថាអ្នកធានា សន្យានឹងដើមបំណុលថា ខ្លួននឹងបំពេញកាតព្វកិច្ចជំនួសកូនបំណុល ។" ក្នុងករណីនេះ គឺមានបំណុលតែមួយប៉ុណ្ណោះ ។ តាមពិត កូនបំណុលភ្ជាប់កាតព្វកិច្ចបង់ប្រាក់សងបំណុលហើយអ្នកធានាភ្ជាប់កាតព្វកិច្ចជំនួសកូនបំណុល តែក្នុងករណីដែលកូនបំណុលចម្បងពុំបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនតែប៉ុណ្ណោះ ។

ប៉ុន្តែ អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះគឺថា គេពុំឃើញមានទំនាក់ទំនងក្នុងកិច្ចសន្យាណាមួយត្រូវបានបង្កើតឡើងរវាងម្ចាស់បំណុល និងអ្នកធានាឡើយ ។ ម្យ៉ាងទៀត មាត្រា ១១២ នៃក្រ-ច លេខ ៣៨ ជ្រើសរើសពាក្យតតិយជនដែលសំដៅទៅលើជនដែលគ្មានទំនាក់ទំនងជាមួយនឹងកិច្ចសន្យាចម្បងនោះទេ ។ប៉ុន្តែ ដូចដែលយើងបានគូសចំណាំពីខាងលើ ប្រសិនបើឈរលើគោលការណ៍តតិយុត្ត កិច្ចសន្យាចម្បង គឺកិច្ចសន្យាមួយដែលបុគ្គលម្នាក់ជាតតិយជនអាចអនុវត្តកាតព្វកិច្ចដែលកូនបំណុលជាអ្នកបង្កើត ។ នេះកាន់តែសឱ្យឃើញថា កាតព្វកិច្ចរបស់អ្នកធានាកើតពីទំនាក់ទំនងនៃកិច្ច-សន្យារបស់កូនបំណុល និងម្ចាស់បំណុល ។ នៅពេលដែលគាត់ភ្ជាប់កាតព្វកិច្ច តតិយជននៃកិច្ចសន្យាចម្បង យល់ព្រមថាកិច្ចសន្យាចម្បងអាចជំទាស់ប្រឆាំងជាមួយគាត់បាន ។

ក្នុងកម្រិតទី ២ កាតព្វកិច្ចរបស់អ្នកធានាពឹងផ្អែកគ្នាទៅវិញទៅមកជាមួយនឹងកាតព្វកិច្ចរបស់កូនបំណុលចម្បងក្នុងករណីដែលអ្នកធានាភ្ជាប់កាតព្វកិច្ចត្រូវអនុវត្តកាតព្វកិច្ចជំនួសកូនបំណុល ប៉ុន្តែ គ្រាន់តែក្នុងករណីដែលកូនបំណុលពុំអនុវត្តកាតព្វកិច្ចរបស់ខ្លួនប៉ុណ្ណោះ ។ ករណីនេះបង្ហាញថា អ្នកធានាភ្ជាប់កាតព្វកិច្ចមានលក្ខណៈបន្ទាប់បន្សំ ។ ដូច្នេះអ្នកធានាមានគុណភាពជាកូនបំណុលបន្ទាប់បន្សំ ឬទី ២ ។ យើងគួរកត់សម្គាល់ថា ក្រៅពីចរិតលក្ខណៈបន្ទាប់បន្សំ យោងតាមមាត្រាខាងលើនេះ យើងក៏អាចកំណត់នូវចរិតលក្ខណៈផ្សេងទៀតរបស់វាបានដែរ ។

Scanned with CamScanner

ខ. ចរិតលក្ខណៈផ្សេងទៀតនៃកិច្ចសន្យាធានាដោយបុគ្គល

ក្រៅពីលក្ខណៈបន្ទាប់បន្សំ មាត្រា ១១២ នៃក្រ-ច លេខ ៣៨ លើកឡើងនូវចរិតលក្ខណៈផ្សេងទៀតនៃកិច្ចធានាដោយបុគ្គលផងដែរ : គឺជាកិច្ចសន្យាឯកតោភាគី ដែលអាចជាមុខ[១១២] ឬ មូលា[១១៣] ហើយក៏អាចជាកិច្ចសន្យាដែលត្រូវគោរពតាមទម្រង់ណាមួយ ។

១. លក្ខណៈឯកតោភាគីនៃកិច្ចសន្យាធានាដោយបុគ្គល :

អនុលោមតាមនិយមន័យរបស់មាត្រា ១១២ នៃក្រ-ច ខាងលើ មានតែអ្នកធានាប៉ុណ្ណោះដែលសន្យា តាមរយៈកិច្ចសន្យាធានាដោយបុគ្គល ។ បើសិនជាគ្មានកាតព្វកិច្ចណាមួយចេញពីកិច្ចសន្យានេះសម្រាប់ម្ចាស់បំណុលនោះទេ ការបង្កើតកិច្ចសន្យានេះទាមទារជាចាំបាច់នូវការព្រមព្រៀងពីម្ចាស់បំណុល ។ ការព្រមព្រៀងរបស់ម្ចាស់បំណុល បញ្ជាក់អំពីការជួបការព្រមព្រៀងគ្នា ដែលអនុញ្ញាតឱ្យមានការបង្កើតកិច្ចសន្យា ។ ប៉ុន្តែ កាតព្វកិច្ចនេះពុំត្រូវបានលើកឡើងនៅក្នុងមាត្រា ១១២ នៃក្រ-ច លេខ ៣៨ ដែលចែងថា តតិយជនភ្ជាប់សន្យា ចំពោះម្ចាស់បំណុល នៅក្នុងការអនុវត្តកាតព្វកិច្ច ។ ប៉ុន្តែ ស្វីការដែលលើកឡើងដោយម្ចាស់បំណុលបែបនេះ តាមនិយមន័យ គឺទាមទារយ៉ាងចាំបាច់នូវការបង្កើតចំណងតាមកិច្ចសន្យា ។ លើសពីនេះទៀត កិច្ចសន្យាធានាដោយបុគ្គល គឺជាកិច្ចសន្យាដែលការពារដល់សិទ្ធិរបស់ម្ចាស់បំណុល ។ កិច្ចសន្យានេះទាមទារយ៉ាងចាំបាច់ថា ម្ចាស់បំណុលអាចជ្រើសរើសអ្នកធានា និងយកអ្នកធានាដែលមានប្រាក់ដើម្បីសងបំណុល ។ ដូច្នេះ ការព្រមព្រៀងរបស់ម្ចាស់បំណុលត្រូវការជាចាំបាច់ ដោយហេតុថា កិច្ចសន្យាធានាដោយបុគ្គល គឺជាកិច្ចសន្យាដែលគុណភាពរបស់បុគ្គលមានលក្ខណៈសំខាន់ ហើយការជ្រើសរើសអ្នកធានាដែលគ្មានប្រាក់សងបំណុល បង្ហាញនូវភាពគ្មានផលប្រយោជន៍ចំពោះម្ចាស់បំណុល ។

២. លក្ខណៈមុខ ឬ មូលានៃកិច្ចសន្យាធានាដោយបុគ្គល

ការកំណត់ថាកិច្ចសន្យាធានាដោយបុគ្គលជាកិច្ចសន្យាមុខ ឬមូលា បានមកពីកំណត់អំពីមូលហេតុនៃកាតព្វកិច្ចរបស់អ្នកធានា ។ និយាយម៉្យាងទៀត ហេតុអ្វីក៏អ្នកធានាភ្ជាប់កាតព្វកិច្ចសងបំណុលជំនួសកូនបំណុល ។

មាត្រា ១១២ នៃក្រ-ច លេខ ៣៨ មិនបានចែងថា កិច្ចធានាដោយបុគ្គលអាចជាកិច្ចសន្យាមុខ ឬមូលា ទេ ។ ការដែលថា កិច្ចសន្យាធានាអាចជាមុខ ឬមូលា ពុំបានបញ្ជាក់ថា កិច្ចសន្យាធានានេះត្រូវបានធ្វើឡើងដោយគ្មានមូលហេតុនោះទេ ។ តាមពិត មូលហេតុនៃកាតព្វកិច្ចត្រូវបានបង្កើតឡើង ដោយទំនាក់ទំនងរវាងកូនបំណុលចម្បង និងម្ចាស់បំណុល ។ អ្នកតាក់តែងមាត្រានេះ បានកំណត់ថា កិច្ចសន្យាធានា ជួនជាសេវាមួយដែលផ្តល់ដោយមិនគិតកម្រៃរវាងញាតិ ឬមិត្ត ចំពោះកូនបំណុល ជួនជាសេវាដែលផ្តល់ដោយយកកម្រៃ ដោយស្ថាប័នឥណទាន ។ ជាសេចក្តីសន្និដ្ឋាន កិច្ចសន្យាធានាដោយបុគ្គល អាចជាកិច្ចសន្យាមុខ ឬមូលា ។

---

[១១២] ឥតយកកម្រៃ= à titre gratuit

[១១៣] ដោយយកកម្រៃ= à titre onéreux

Scanned with CamScanner

វាជាការចាប់អារម្មណ៍ក្នុងការពិនិត្យមើលថា តើអ្នកធានាត្រូវបានប្រតិបត្តិដូចគ្នាដែរ ឬទេ ក្នុងករណីដែលគាត់មាន ឬគ្មានផលប្រយោជន៍ក្នុងប្រតិបត្តិការនេះ ។ មាត្រា ១១២ នៃ ក្រ-ច លេខ ៣៨ បច្ចុប្បន្ននេះ ពុំបានកំណត់អំពីលទ្ធភាពនេះទេ ។

ខ. លក្ខណៈនៃការព្រមព្រៀង ឬលក្ខណៈជាទម្រង់នៃកិច្ចសន្យា :

មាត្រា ១១២ ចែងថា កិច្ចសន្យាធានាដោយបុគ្គលត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ បានសេចក្តីថា ទោះក្នុងករណីណាក៏ដោយ កិច្ចសន្យាធានាដោយបុគ្គល ពុំអាចត្រូវបានធ្វើឡើងជាផ្ទាល់មាត់នោះទេ ទោះបីជាតម្លៃនៃកាតព្វកិច្ចទាមជាង ៥.០០០ រៀល ក៏ដោយ[១១៤] ។ ហេតុដូច្នេះ ការគ្រាន់តែមានការព្រមព្រៀងរវាងម្ចាស់បំណុល និងកូនបំណុលចម្បង មានលក្ខណៈពុំគ្រប់គ្រាន់ ដើម្បីបង្កើតកិច្ចសន្យាធានាដោយបុគ្គលនោះទេ ។ មាត្រានេះចាប់បង្ខំបង្កើតនូវទម្រង់ដោយឡែកមួយ ដែលយើងអាចចាត់ទុក វាជាកិច្ចសន្យាដែលត្រូវគោរពតាមទម្រង់មួយជាក់លាក់ ។

II. លទ្ធផលដែលទាញរចញពីលក្ខណៈនៃកិច្ចសន្យាធានាដោយបុគ្គល

ឆ្លងតាមបំណកស្រាយខាងលើ កិច្ចសន្យាធានាដោយបុគ្គលមិនត្រឹមតែជាកិច្ចសន្យាបន្ទាប់បន្សំប៉ុណ្ណោះទេ តែថែមទាំងជាកិច្ចសន្យាឯកតោភាគី និងជាកិច្ចសន្យាទម្រង់និយមផង ។ លក្ខណៈពិសេសទាំងអស់នេះជះឥទ្ធិពលទៅលើលក្ខខណ្ឌនានាស្តីពីការបង្កើតកិច្ចសន្យាធានាដោយបុគ្គល ព្រមទាំងអានុភាពរបស់វាចំពោះគូភាគី និងចំពោះតតិយជន ។

ក. ការបង្កើតកិច្ចសន្យាធានារដាយបុគ្គល : លក្ខខណ្ឌសុពលភាពនានា

អនុលោមតាមមាត្រា ១១២ នៃក្រ-ច លេខ ៣៨ ខាងលើ កិច្ចសន្យាធានាដោយបុគ្គលគ្រាន់តែជាប្រភេទកិច្ចសន្យាមួយដែលកម្មវត្ថុរបស់វា ដូចគ្នាទៅនឹងកម្មវត្ថុនៃកិច្ចសន្យាចម្បងដែលធ្វើឡើងរវាងកូនបំណុល និងម្ចាស់បំណុលដែរ ។ ហេតុនេះ វាមិនខុសពីកិច្ចសន្យាពិសេសដទៃទៀតទេ ដាច់ខាតត្រូវតែគោរពលក្ខខណ្ឌទូទៅស្តីពីសុពលភាពនៃកិច្ចសន្យាដែលចាប់បង្ខំដោយមាត្រា ៣ នៃក្រ-ច នេះ និងលក្ខខណ្ឌពិសេសដែលមានចែងក្នុងមាត្រា ១១២ ខាងលើផងដែរ ។

១. លក្ខខណ្ឌទូទៅស្តីពីសុពលភាពនៃកិច្ចសន្យា : លក្ខខណ្ឌគ្រឹះ

មាត្រា ៣ នៃក្រ-ច ខាងលើចែងថា : " កិច្ចសន្យាទាំងឡាយនិងយកជាការបាន លុះណាតែកាតព្វកិច្ចដែលកើតចេញអំពីពីកិច្ចសន្យានោះ :

- កើតចេញពីការព្រមព្រៀងដោយពិតប្រាកដ និងដោយសេរី

---

[១១៤] វាមានសារៈសំខាន់ដែលត្រូវលើកឡើងសាជាថ្មីឡើងវិញអំពីបទប្បញ្ញត្តិនៃមាត្រា ៤ នៃ ក្រ-ច លេខ ៣៨ "កិច្ចសន្យាអាចមានទម្រង់ជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ ។ ច្បាប់អាចកំណត់ទម្រង់ជាក់លាក់ណាមួយចំពោះកិច្ចសន្យា ។ រាល់កិច្ចសន្យាដែលបង្កើតឡើងដោយមិនគោរពតាមទម្រង់ដែលកំណត់ដោយច្បាប់ ត្រូវបានចាត់ទុកជាមោឃៈ លើកឡើងតែមានបទប្បញ្ញត្តិចែងផ្ទុយពីនេះ ។ គ្រប់ប្រភេទកិច្ចសន្យាទាំងអស់ ដែលកម្មវត្ថុរបស់វាជាវត្ថុ ឬជាសាច់ប្រាក់មានតម្លៃចាប់ពី ៥ ០០០ រៀល ឡើងទៅ ត្រូវតែធ្វើឡើងជាលាយលក្ខ៍អក្សរ ។"

វាជាការចាប់អារម្មណ៍ដែរថា អត្រាប្តូរប្រាក់នាពេលបច្ចុប្បន្ននេះរវាងប្រាក់រៀល និងដុល្លារអាមេរិក គឺ ១ ដុល្លារអាមេរិក = ៤.១៥០ រៀល ។ ប៉ុន្តែ ការតាក់តែងកិច្ចសន្យាជាលាយលក្ខ៍អក្សរ គឺកម្រឃើញមានតាមការអនុវត្តជាក់ស្តែងណាស់ ដោយហេតុថា តម្លៃប្រាក់រឿលត្រូវបានជាប់បង់គួរឱ្យកត់សម្គាល់ ។

Scanned with CamScanner

- កើតចេញពីជនដែលមានសមត្ថភាពចុះកិច្ចសន្យា
- មានវត្ថុមួយដែលជាក់លាក់ ដែលអាចធ្វើកើត និងដែលស្របច្បាប់ របៀបរៀបរយសាធារណៈ ឬទំនៀមទម្លាប់ប្រពៃណីដ៏ល្អ ។

ក្រៅពីលក្ខខណ្ឌដែលទាក់ទងនឹងសមត្ថភាពរបស់គូភាគី និងកម្មវត្ថុនៃកិច្ចសន្យា អនុលោមតាមមាត្រានេះ កិច្ចសន្យាធានាដោយបុគ្គល មានសុពលភាពតែក្នុងករណីដែលវាត្រូវបានបង្កើតឡើងដោយឆន្ទៈនៃការព្រមព្រៀងដោយពិតប្រាកដ និងដោយសេរី ។ តើឆន្ទៈដោយពិតប្រាកដ និងដោយសេរីមានន័យយ៉ាងដូចម្តេច ? ដើម្បីជៀសវាងរាល់ការខ្វែងគំនិតគ្នា អ្នកតាក់តែងបានចែកក្នុងមាត្រា ៧ នៃ ក្រ-ច ដដែលនេះថា ឆន្ទៈពុំត្រូវបានចាត់ទុកថាដោយពិតប្រាកដ និងដោយសេរី ក្នុងករណីដែលឆន្ទៈត្រូវបានបង្ហាញឡើងដោយមានការភ័ន្តច្រឡំ ការប្រើអំពើហិង្សា និងការបន្ទំ ។ ហេតុដូច្នេះ អ្នកធានាភ្ជាប់កាតព្វកិច្ចចំពោះម្ចាស់បំណុលតែក្នុងករណីដែលឆន្ទៈរបស់គាត់ពុំមានវិការៈ មានន័យថាគ្មានការភ័ន្តច្រឡំ ការប្រើអំពើហិង្សា និងការបន្ទំ ។

ករណីនៃការភ័ន្តច្រឡំ សំណួរត្រូវបានចោទឡើងថា តើគ្រប់ការភ័ន្តច្រឡំទាំងអស់អាចជាមូលហេតុនៃការប្រកាសមោឃភាពដែរឬទេ ? ដើម្បីផ្តល់ចម្លើយទៅនឹងសំណួរនេះ យើងត្រូវពិនិត្យមើលទៅលើប្រភេទនៃការភ័ន្តច្រឡំ ។ ក្រឹត្យ-ច្បាប់លេខ ៣៨ បែងចែករវាងការភ័ន្តច្រឡំលើសារធាតុសំខាន់របស់វត្ថុ និងរបស់បុគ្គល ។ ការភ័ន្តច្រឡំលើកម្មវត្ថុនៃកិច្ចសន្យា ត្រូវបានទទួលយកជាទូទៅ ដោយអាចចាត់ទុកជាមូលហេតុនៃការប្រកាសមោឃភាពកិច្ចសន្យា ។ ប៉ុន្តែវាពុំមែនដូច្នោះទេ ចំពោះការភ័ន្តច្រឡំលើបុគ្គល ។ ដើម្បីឆ្លើយបំភ្លឺចំពោះករណីនេះ មាត្រា ៨ នៃក្រ-ច លេខ ៣៨ បានចែងថា ការភ័ន្តច្រឡំលើបុគ្គលពុំអាចចាត់ទុកជាមូលហេតុនៃការប្រកាសមោឃភាពនៃកិច្ចសន្យានោះទេ លើកលែងតែបុគ្គលនោះគឺជាមូលហេតុចម្បងនៃកិច្ចសន្យា ។ ការភ័ន្តច្រឡំលើបុគ្គលអាចត្រូវបានលើកឡើងតែក្នុងករណីដែលកិច្ច-សន្យាយកគុណភាពបុគ្គលជាធាតុចម្បងតែប៉ុណ្ណោះ ។ វាជាករណីនៃកិច្ចសន្យាធានាដោយបុគ្គល ដោយហេតុថា គ្មានបុគ្គលណាម្នាក់ភ្ជាប់កាតព្វកិច្ចជំនួសកូនបំណុលដែលពុំស្គាល់នោះទេ ។ ក្នុងន័យនេះ តតិយជនដែលជាអ្នកធានាមានសិទ្ធិលើកឡើងនូវការប្រកាសមោឃភាព បើសិនជាគាត់មានការភ័ន្តច្រឡំលើអត្តសញ្ញាណរបស់កូនបំណុល ។

តើអត្តសញ្ញាណរបស់កូនបំណុលអាចត្រូវបានចាត់ទុកជាមូលហេតុនៃការប្រកាសមោឃភាព ដោយហេតុថាខុសកម្មវត្ថុដែរឬទេ ? ចំពោះយើង ចម្លើយមានលក្ខណៈវិជ្ជមាន ។ អ្វីដែលបង្កើតជាកម្មវត្ថុនៃកិច្ចសន្យាធានាដោយបុគ្គល គឺកាតព្វកិច្ចដែលកើតចេញពីកិច្ចសន្យាចម្បង តែចំពោះការសន្យារវាងកូនបំណុល និងម្ចាស់បំណុលតែប៉ុណ្ណោះ ពុំមែនជាមួយអ្នកណាផ្សេងនោះទេ មានន័យថា អត្តសញ្ញាណរបស់កូនបំណុលជាលក្ខខណ្ឌចាំបាច់ ដើម្បីកំណត់អំពីអត្តសញ្ញាណនៃកម្មវត្ថុនៃកិច្ចសន្យាធានាដោយបុគ្គល ។ ក្នុងករណីនេះ អ្នកធានាភ្ជាប់កាតព្វកិច្ចចំពោះតែកាតព្វកិច្ចដែលភ្ជាប់ជាមួយនឹងបុគ្គលតែប៉ុណ្ណោះ ។ ក្រៅពីការភ័ន្តច្រឡំលើអត្តសញ្ញាណរបស់បុគ្គល យើងគួរកំណត់ដូចគ្នាដែរថា តើការភ័ន្តច្រឡំលើសាធនភាពរបស់កូនបំណុលអាចត្រូវបានចាត់ទុកជាមូលហេតុនៃការប្រកាសមោឃភាពកិច្ចសន្យាដែរឬទេ?

ក្នុងករណីនៃការប្រើអំពើហិង្សា និងការបន្ទំ វាបង្ហាញនូវផលលំបាកតិចតួចប៉ុណ្ណោះ ។ តែ ប្រសិនបើទង្វើទាំងនេះត្រូវបានប្រព្រឹត្តដោយម្ចាស់បំណុល វាអាចនាំឱ្យមានការប្រកាសមោឃភាពកិច្ចសន្យាធានាដោយបុគ្គល ។ ប៉ុន្តែ

Scanned with CamScanner

ប្រសិនបើការបន្ទំត្រូវបានប្រព្រឹត្តដោយកូនបំណុលចម្បង ចំពោះអ្នកធានា វាជាករណីនៃការបន្ទំដែលធ្វើឡើងដោយតតិយជន ដែលពុំអាចលើកឡើងធ្វើជាមូលហេតុប្រកាសមោឃភាពកិច្ចសន្យានោះទេ ។ ម៉្យាងវិញទៀត បញ្ហាតែមួយគត់ដែលអ្នកជំនាញវិជ្ជាជីវៈជួបប្រទះ គឺការបង្ហាញភស្តុតាង ។ ប៉ុន្តែ ប្រសិនបើសិនជាព្រឹត្តិការណ៍គតិយុត្ត ភស្តុតាងអាចត្រូវបានបង្ហាញតាមគ្រប់មធ្យោបាយទាំងអស់ ។

ផ្ទុយទៅនឹងកិច្ចសន្យាមួយចំនួនទៀត ការបង្កើតកិច្ចសន្យាធានាដោយបុគ្គល ត្រូវការជាចាំបាច់នូវការគោរពលក្ខខណ្ឌជាទម្រង់ជាលាយលក្ខណ៍អក្សរ ដើម្បីឱ្យកិច្ចសន្យានោះមានសុពលភាព ។

២. លក្ខខណ្ឌជាទម្រង់ : លាយលក្ខណ៍អក្សរ

កិច្ចសន្យាធានាដោយបុគ្គល គឺជាកិច្ចសន្យាទម្រង់និយម ដូចដែលមានចែងក្នុងមាត្រា ១១២ នៃក្រ-ច លេខ ៣៨ ដែលក្នុងនោះ កិច្ចសន្យានេះត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ ។ ដោយអនុវត្តបទប្បញ្ញត្តិនេះ គ្មានករណីលើកលែងណាមួយអាចត្រូវបានធ្វើឡើងចំពោះលក្ខខណ្ឌនេះ ទោះជាតម្លៃនៃកិច្ចសន្យាមានទំហំទាបក៏ដោយ ។

ព្រមពេលជាមួយគ្នានេះដែរ សំណួរមួយទៀតត្រូវបានចោទឡើងផងដែរថា តើទម្រង់ជាលាយលក្ខណ៍អក្សរយ៉ាងដូចម្តេច ដែលតម្រូវដោយអ្នកតាក់តែងមាត្រា ១១២ នៃក្រ-ច លេខ ៣៨ នេះ ? ដោយកង្វះខាតនូវសេចក្តីបញ្ជាក់លិខិតជាលាយលក្ខណ៍អក្សរ សំដៅទៅលើរាល់ទម្រង់ជាសម្ភារៈ រួមទាំងទម្រង់ជាលិខិតអេឡិចត្រូនិច និងជាលិខិតឯកជន ឬលិខិតយថាភូត ។

នៅពេលដែលលក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាត្រូវបានគោរពតាម យើងត្រូវកំណត់ជាបន្តអំពីអានុភាពរបស់វា ។

ខ. អានុភាពនៃកិច្ចធានាដោយបុគ្គល :

អានុភាពនៃកិច្ចសន្យាធានាដោយបុគ្គលត្រូវបានបកស្រាយតាមរយៈលក្ខណៈបន្ទាប់បន្សំនៃកិច្ចសន្យានេះ បើធៀបទៅនឹងកិច្ចសន្យាចម្បង ដែលត្រូវបានធ្វើឡើងរវាងកូនបំណុល និងម្ចាស់បំណុល ។ លក្ខណៈបន្ទាប់បន្សំនេះ នាំឱ្យបាននូវលទ្ធផលគួរឱ្យកត់សម្គាល់ស្តីពីអត្ថិភាព និងការរំលត់នៃកាតព្វកិច្ចរបស់អ្នកធានា ។ កាតព្វកិច្ចរបស់អ្នកធានា កើតមានចំពោះតែកាតព្វកិច្ចរបស់កូនបំណុលចម្បងប៉ុណ្ណោះ ។ មាត្រា ១១២ នៃក្រ-ច លេខ ៣៨ ចែងថា"អ្នកធានាភ្ជាប់កាតព្វកិច្ចចំពោះមុខម្ចាស់បំណុល ក្នុងការអនុវត្តកាតព្វកិច្ចជំនួសកូនបំណុល បើសិនជាកូនបំណុលពុំព្រមអនុវត្តនោះទេ ....។" បទប្បញ្ញត្តិនេះ នាំឱ្យយើងចោទជាសំណួរស្តីពីខ្លឹមសារនៃកាតព្វកិច្ចរបស់អ្នកធានា និងការអនុវត្តកាតព្វកិច្ច ។ តើយើងអាចនិយាយថា កូនបំណុលពុំព្រមអនុវត្តកាតព្វកិច្ចចាប់ពីពេលណា ?

មានសម្មតិកម្មពីរអាចត្រូវបានលើកឡើង : សម្មតិកម្មទី ១ សំដៅថា ក្នុងករណីដែលកូនបំណុលពុំអនុវត្តកាតព្វកិច្ចទាំងស្រុង ចំណែកសម្មតិកម្មទី ២ សំដៅថា ចាត់ទុកថាជាការពុំអនុវត្តកាតព្វកិច្ច ក្នុងករណីដែលកូនបំណុលចម្បងពុំព្រមអនុវត្តកាតព្វកិច្ចដោយផ្នែកណាមួយ ចំពោះម្ចាស់បំណុល ។ ក្នុងករណីចុងក្រោយនេះ អ្នកធានាត្រូវអនុវត្តចំពោះតែកាតព្វកិច្ចដែលពុំត្រូវបានអនុវត្តដោយកូនបំណុលចម្បងប៉ុណ្ណោះ ដោយហេតុថា កិច្ចសន្យាធានាដោយបុគ្គលមានលក្ខណៈបន្ទាប់បន្សំទៅនឹងកាតព្វកិច្ចចម្បង ។ ដូចគ្នាដែរ ម្ចាស់បំណុលពុំអាចប្តឹងអ្នកធានាទៅតុលាការ មុននឹងប្តឹងទៅកូន

Scanned with CamScanner

បំណុលចម្បងនោះទេ ។ ម្ចាស់បំណុលអាចប្តឹងក្នុងពេលជាមួយគ្នា ចំពោះអ្នកធានា និងកូនបំណុលចម្បង ឬប្តឹងអ្នកធានាជាក្រោយ បន្ទាប់ពីបានប្តឹងកូនបំណុលចម្បងរួចហើយ ។

សំណូនវ៉ោហាស័ព្ទ "អ្នកធានាភ្ជាប់កាតព្វកិច្ចចំពោះម្ចាស់បំណុល ក្នុងការអនុវត្តកាតព្វកិច្ចជំនួសកូនបំណុលប្រសិនបើកូនបំណុលពុំអនុវត្តកាតព្វកិច្ចនោះទេ" បញ្ជាក់ថា កាតព្វកិច្ចរបស់អ្នកធានានឹងត្រូវផុតរលត់ ប្រសិនបើកូនបំណុលចម្បងបានអនុវត្តកាតព្វកិច្ចរបស់ខ្លួន ។ កាតព្វកិច្ចរបស់អ្នកធានាពុំមានមូលហេតុ ហើយត្រូវបានរលាយបាត់ដោយការអនុវត្តទ្រឹស្តី *លក្ខណៈបន្ទាប់បន្សំតែរពតាមលក្ខណៈចម្បង*[115] ។

ទីបញ្ចប់ មាត្រា ១១២ នៃ ក្រ-ច ចែងថា អ្នកធានាភ្ជាប់កាតព្វកិច្ចចំពោះការសងបំណុលដូចគ្នានឹងកូនបំណុលចម្បង ។ វិសាលភាពនៃកាតព្វកិច្ចរបស់អ្នកធានាត្រូវបានចោទជាបញ្ហា ។ ប្រសិនបើអ្នកធានាមានាកាតព្វកិច្ចដូចគ្នាទៅនឹងកូនបំណុលចម្បង តើអ្នកធានាអាចលើកឡើងនូវករណីដែលលើកឡើងដូចជាកូនបំណុលដែរឬទេ ? តើអ្នកធានាអាចលើកឡើងនូវករណីលើកលែងដែលមានលក្ខណៈបុគ្គលចំពោះកូនបំណុល ឬគាត់អាចលើកឡើងត្រឹមតែករណីលើកលែងដែលទាក់ទងនឹងបំណុល ?

ប្រសិនបើបទប្បញ្ញត្តិនៃមាត្រា ១១២ ចង់កំណត់អំពីនិយមន័យនៃកិច្ចសន្យាធានាដោយបុគ្គល បទប្បញ្ញត្តិនេះហាក់ដូចជាមានលក្ខណៈពុំត្រប់គ្រាន់ ចំពោះភាពពុំច្បាស់លាស់នៃពាក្យដែលត្រូវបានប្រើប្រាស់ និងភាពពុំច្បាស់លាស់ស្តីពីភាពខុសគ្នានៃអានុភាពដែលចេញមកដោយផ្ទាល់ ឬដោយប្រយោលពីលក្ខណៈបន្ទាប់បន្សំនៃកិច្ចសន្យាធានាដោយបុគ្គល ។ ភាពពុំច្បាស់លាស់នេះ អាចជាមូលហេតុយ៉ាងជាក់ច្បាស់នៃវិវាទទាក់ទងនឹងកិច្ចសន្យាធានាដោយបុគ្គលនេះ ។ សេចក្តីទាំងអស់នេះ បង្ហាញថា កិច្ចអន្តរាគមន៍របស់នីតិករ ឬចៅក្រមមានភាពចាំបាច់ដើម្បីចូលរួមបំភ្លឺ ឬបញ្ជាក់បន្ថែមអំពីកិច្ចសន្យាធានាដោយបុគ្គល និងពង្រឹងការការពារផលប្រយោជន៍ប្រឆាំងគ្នារវាងម្ចាស់បំណុល អ្នកធានា និងកូនបំណុលចម្បង ។

ខ. នីតិគារវៈ

១. ច្បាប់ធានាបន្ត

អត្ថាធិប្បាយមាត្រា ២២៧ នៃច្បាប់ការងារឆ្នាំ ១៩៩៧ :

"១- ភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈ ឬសហភាពអង្គការវិជ្ជាជីវៈណាមួយ ត្រូវបានទទួលស្គាល់ក្នុងក្របខ័ណ្ឌភូមិសាស្ត្រ ឬវិជ្ជាជីវៈ ឬករណីចាំបាច់ទៅតាមប្រភេទដែលសហជីពនេះបានចុះបញ្ជីធ្វើសកម្មភាព ។ ភាពជាតំណាងនេះត្រូវកំណត់តាមលក្ខណៈវិនិច្ឆ័យដូចតទៅ :

ក- បានចុះបញ្ជីការ៉ែមត្រូវ ដូចមានចែងក្នុងមាត្រា ២៦៨ ខាងលើ ។

ខ- មានចំនួនសមាជិកដែលមានប័ណ្ណសំគាល់សមាជិកភាពត្រឹមត្រូវច្រើនជាងគេ ។ សហជីពណាដែលមានចំនួនសមាជិកច្រើនជាងគេក្នុងលំដាប់ថ្នាក់លេខមួយ និងលេខពីរ ត្រូវចាត់ទុកថា ជាសហជីពដែលមានភាពជាតំណាងនៅក្នុងសហ-

[115] *Accessorium sequitur principale.*

Scanned with CamScanner

គ្រាស ។ ប៉ុន្តែ សហជីពណាដែលមានសមាជិកចំនួនហាសិបមួយភាគរយ (៥១%) ឡើងទៅនៃចំនួនសមាជិករបស់សហគ្រាស ត្រូវចាត់ទុកថាជាសហជីពដែលមានភាពជាតំណាងបំផុត ។

គ- បានទទួលប្រាក់ភាគទានយ៉ាងហោចណាស់សាមសិបបីភាគរយនៃចំនួនសមាជិក ។

ឃ- មានកម្មវិធី និងសកម្មភាពដែលបង្ហាញថា សហជីពនោះមានលទ្ធភាពផ្តល់សេវាខាងវិជ្ជាជីវៈ វប្បធម៌ និងអប់រំដល់សមាជិករបស់ខ្លួន ដូចមានចែងក្នុងមាត្រា ២៦៦ នៃច្បាប់នេះ ។

២- ក្នុងរយៈពេលហុកសិបថ្ងៃយ៉ាងយូរ ក្រោយពីបានទទួលសំណុំបែបបទដើម្បីសុំទទួលស្គាល់ភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈ ក្រសួងទទួលបន្ទុកវិស័យការងារ ត្រូវសំរេចជាផ្លូវការអំពីការទទួលស្គាល់ភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈណាដែលបានបំពេញលក្ខណៈវិនិច្ឆ័យ ដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើ ។

៣- បទប្បញ្ញត្តិទាំងឡាយនៃច្បាប់ការងារ អាចភ្ជាប់ភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈដែលក្រសួងទទួលបន្ទុកវិស័យការងារ បានទទួលស្គាល់ទៅតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ទៅនឹងការទទួលអត្ថប្រយោជន៍ដែលទាក់ទងទៅនឹង :

- ការបែងចែកអាសនៈនៅក្នុងអង្គការមួយចំនួន ដែលបានកំណត់ក្នុងច្បាប់ការងារ

- សមត្ថកិច្ចនៃការចរចាជាសមូហភាព

- ការឧទ្ទេសនាមបេក្ខជនក្នុងការបោះឆ្នោតលើកទីមួយនៃការជ្រើសរើសប្រតិភូបុគ្គលិក ។

៤- ក្រសួងទទួលបន្ទុកវិស័យការងារអាចចាត់អោយមានការអង្កេត ក្នុងករណីដែលត្រូវកំណត់លក្ខណៈនៃភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈណាមួយ ឬការពិនិត្យទ្វេភាពស្ថិតស្ថេរនៃអង្គការនេះ ។

អង្គការវិជ្ជាជីវៈដែលជាប់ពាក់ព័ន្ធរឿងនេះ ត្រូវផ្តល់នូវឯកសារបញ្ជាក់ទាំងអស់តាមការស្នើសុំពីមន្ត្រីមានសមត្ថកិច្ច ។ កាលណាបើគ្មានឯកសារបញ្ជាក់ ឬក៏ឯកសារនោះមិនគ្រប់គ្រាន់ ការទទួលស្គាល់ភាពជាតំណាងត្រូវតែបដិសេធ ឬត្រូវព្យួរទុក រហូតដល់មានឯកសារគ្រប់គ្រាន់បញ្ជាក់ពីរឿងនេះ ។ អត្ថប្រយោជន៍ទាក់ទងនឹងភាពជាតំណាងដែលរាល់អង្គការវិជ្ជាជីវៈត្រូវទទួលបាននោះ ក៏ត្រូវតែលុបចោល ឬត្រូវព្យួរទុកដែរ ។"

២. អំណះ : (ថ្នាំរ៉ង ឌីប័រ)

បុព្វកថានៃរដ្ឋធម្មនុញ្ញនៃអង្គការអន្តរជាតិស្តីពីការងារឆ្នាំ ១៩១៩ ប្រកាស ក្នុងចំណោមមធ្យោបាយដែលអាចធ្វើបាន ដើម្បីលើកតម្កើនលក្ខខណ្ឌបំពេញការងាររបស់និយោជិត និងធានាសន្តិភាព ថា "ការធានានូវគោលការណ៍នៃសេរីភាពសហជីព" ។ សេចក្តីប្រកាសនៅទីក្រុងហ្ស៊ីឡាដែលហ្ស៊ីរ បានលើកលើងសាជាថ្មីថា "សេរីភាពក្នុងការសំដែង និងចូលក្នុងសមាគម គឺជាលក្ខខណ្ឌចាំបាច់ចំពោះការវិវត្តន៍" ។ តាមន័យនេះហើយ សេរីភាពសហជីពដែលត្រូវបានអនុវត្តនៅក្នុងអនុសញ្ញាឆ្នាំ ១៩៨៧ នៃអង្គការអន្តរជាតិស្តីពីការងារដែលត្រូវបានផ្តល់សច្ចាប័នដោយកម្ពុជា ត្រូវបានទទួលស្គាល់ដូចជាគោលការណ៍ត្រឹះក្នុងកម្រិតអន្តរជាតិ ។

សេរីភាពនេះអនុញ្ញាតឱ្យមានការកើនឡើងជាលំដាប់នៃសហជីព ។ ប៉ុន្តែ នៅក្នុងប្រព័ន្ធហ៊ុនិយម តាមនិយមន័យរបស់វា អង្គការនិយោជិតជាច្រើន ព្រមទាំងនិយោជក មានសិទ្ធិចូលរួមគ្នាដោយសេរី ហើយវាជាការចាំបាច់ត្រូវបំរុង

Scanned with CamScanner

ទុកនូវអភ័យឯកសិទ្ធិមួយចំនួន ចំពោះតែសហជីពខ្លះតែប៉ុណ្ណោះ ។ វាគឺជាករណីសហជីពតំណាង ។ ម៉្យាងទៀត ចំពោះការចូលរួមសហជីពទៅក្នុងសន្ធិសិទ្ធអន្តរជាតិស្តីពីការងារ "សន្ធិសញ្ញាទីក្រុងវែរស្សៃឆ្នាំ ១៩១៩" ដែលទម្រង់នៃការតំណាងត្រូវបានប្រើប្រាស់ជាលើកដំបូង ។

នីតិកម្មជា ទទួលស្គាល់សេរីភាពសហជីព ដែលមានចែងក្នុងជំពូកទី ១១ នៃច្បាប់ការងារ ។ សេរីភាពនេះមានមូលដ្ឋានជាធម្មតាស្តីពីពហុនិយមនៃសហជីព ។ សេរីភាពនេះតម្រូវថា សិទ្ធិមួយចំនួនត្រូវបានបម្រុងទុកតែចំពោះអង្គការសហជីពតំណាងប៉ុណ្ណោះ ។

តាមទស្សនៈអន្តរជាតិ ទស្សនទានៃការតំណាងពុំគោរពលក្ខណៈវិនិច្ឆ័យច្បាស់លាស់នោះទេ ។ បណ្តារដ្ឋទាំងឡាយមានសេរីភាពក្នុងការកំណត់ខ្លឹមសារ តែពុំត្រូវប៉ះពាល់ទៅដល់សេរីភាពសហជីព និងពហុនិយមនៃសហជីព ។ ទង្វើនេះ បណ្តាប្រព័ន្ធទាំងឡាយមានភាពខុសគ្នា ទាំងក្នុងលទ្ធភាពដែលត្រូវផ្តល់ឱ្យអង្គការ ដើម្បីទទួលស្គាល់តំណាងរបស់ខ្លួន និងក្នុងធាតុផ្សំ ឬមធ្យោបាយចាំបាច់ចំពោះការទទួលស្គាល់តំណាងទាំងនេះ ។ តាមពិត ការតំណាងនេះអាចត្រូវបានសន្មត ឬផ្ទុយមកវិញ ត្រូវតែបង្ហាញនៅចំពោះមុខតុលាការ ឬរដ្ឋបាលការងារ ហើយការតំណាងនេះ អាច ឬពុំអាចចំណុះទៅនឹងក្របខណ្ឌភូមិសាស្ត្រ វិជ្ជាជីវៈ ឬចរិតលក្ខណៈណាមួយ ។ ចំពោះធាតុផ្សំ ឬមធ្យោបាយចាំបាច់ក្នុងការកំណត់ចរិតលក្ខណៈនៃការតំណាង គឺការទាញមករកភាពជិតគ្នានូវចំនួនភាគច្រើនដាច់ខាត និងការទាញរកភាពជិតគ្នានូវចំនួនភាគច្រើនដែលមានតុល្យភាព តាមរយៈលក្ខណៈវិនិច្ឆ័យផ្សេងៗ ឬប្រព័ន្ធផ្សេងៗដែលឈរលើមូលដ្ឋាននៃធាតុផ្សំដែលមានលក្ខណៈឯករាជ្យ ពីការទាញមករកភាពជិតគ្នានូវចំនួនភាគច្រើន ដូចជាករណីនៃនីតិបាវ៉ាង ។

ប៉ុន្តែ នីតិកម្មជាអនុម័តនូវទស្សនទានតាមចំនួនភាគច្រើន : ចំនួនភាគច្រើននេះត្រូវតែផ្សេងផ្គាត់ ក្នុងក្របខណ្ឌភូមិសាស្ត្រ វិជ្ជាជីវៈ ថែមទាំងចរិតលក្ខណៈដែលអង្គការនោះមានបំណងចង់ចុះបញ្ជីសកម្មភាពរបស់ខ្លួន ។

មាត្រា ២៧៧ នៃច្បាប់ការងារកម្ពុជា ដែលរួមផ្សំដោយ ៤ កថាខណ្ឌ កំណត់នូវលក្ខខណ្ឌពីរដំបូងនៃការតំណាង "I" បន្ទាប់មក កថាខណ្ឌទី ៣ និង ៤ ទាក់ទងនឹងការប្រជុំយប្រថ៌ានៃការតំណាង "II" ។

I. លក្ខខណ្ឌនៃការតំណាងជាសហជីព

អនុលោមតាមមាត្រា ២៧៧ នៃច្បាប់ការងារ ការតំណាងត្រូវបានវាយតម្លៃ យោងតាមវិធានស្របគ្នារវាងកម្រិតនៃការវាយតម្លៃ និងក្របខ័ណ្ឌដែលអង្គការមានបំណងចង់បំពេញសកម្មភាពរបស់ខ្លួន ។ ដូច្នេះ វាស្ថិតនៅក្នុងក្របខ័ណ្ឌជាកំណត់មួយ (ក) ដែលអង្គការសហជីព ត្រូវបង្ហាញភស្តុតាងនៅចំពោះមុខក្រសួងទទួលបន្ទុកការងារដែលអង្គការសហជីពរួមផ្សំនូវលក្ខណៈវិនិច្ឆ័យតាមច្បាប់ (ខ) ។

ក. ក្របខណ្ឌនៃការវាយតម្លៃ

វាក្យខណ្ឌទី ១ នៃមាត្រា ២៧៧ នៃច្បាប់ការងារចែងថា " *ភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈ ឬសហភាពអង្គការវិជ្ជាជីវៈណាមួយ ត្រូវបានទទួលស្គាល់ក្នុងក្របខ័ណ្ឌភូមិសាស្ត្រ ឬវិជ្ជាជីវៈ ឬករណីចាំបាច់ទៅតាមប្រភេទដែលសហជីពនេះបានចុះបញ្ជីធ្វើសកម្មភាព ។* "

Scanned with CamScanner

មាត្រានេះសំដៅថា ក្របខ័ណ្ឌនៃភាពជាតំណាងមានលក្ខណៈបន្ទាប់បន្សំ ហើយលក្ខណៈវិនិច្ឆ័យដែលបានលើកឡើងនៅក្នុងវាក្យខណ្ឌបន្តបន្ទាប់ត្រូវតែរួមផ្សំគ្នាក្នុងទីតាំងភូមិសាស្ត្រមួយក្នុងផ្នែកមួយ និងក្នុងវិជ្ជាជីវៈមួយ ដើម្បីឱ្យសហជីពនោះ អាចត្រូវបានទទួលស្គាល់សហជីពតំណាង ដើម្បីអាចអនុវត្តសិទ្ធិដែលទទួលស្គាល់ដោយច្បាប់ដែលកំណត់ចំពោះតែអង្គការតំណាង ។ ប្រសិនបើភាពជាតំណាងនេះត្រូវបានទទួលស្គាល់ក្នុងក្របខ័ណ្ឌមួយជាកំណត់ ភាពជាតំណាងនេះអាចទទួលបានផលប្រយោជន៍តែក្នុងក្របខ័ណ្ឌនោះប៉ុណ្ណោះ ។ ដូច្នេះ ឧទាហរណ៍ បើសិនជាអង្គការសហជីពបានបញ្ជាក់ពីភាពជាតំណាងរបស់ខ្លួននៅក្នុងសហគ្រាស ឬក្រុមហ៊ុនណាមួយ អង្គការនេះពុំអាចមាននៅក្នុងសហគ្រាស ឬក្រុមហ៊ុនប្រកួតប្រជែងនោះទេ ។ ដូចគ្នាដែរ អង្គការតំណាងនៅក្នុងតំបន់ ឬផ្នែកណាមួយពុំចាំបាច់ស្ថិតនៅក្នុងតំបន់ ឬផ្នែកផ្សេងនោះទេ ។ ឧទាហរណ៍ អង្គការតំណាងដែលស្ថិតនៅក្នុងក្របខ័ណ្ឌណាមួយ ពុំអាចមានវត្តមាននៅក្នុងវិជ្ជាជីវៈណាមួយទេ ។

ប៉ុន្តែ ទាំងអស់នេះ ស្ថិតនៅជាទ្រឹស្តី ក្នុងវិធានដែលសិទ្ធិភាគច្រើន ដែលត្រូវបានភ្ជាប់ទៅនឹងការទទួលស្គាល់នូវភាពជាតំណាង ត្រូវបានអនុវត្តនៅក្នុងក្របខ័ណ្ឌសហគ្រាសណាមួយ ។ ដោយអនុវត្តទស្សនទាននៃចំនួនភាគច្រើន ការកាត់បន្ថយត្រូវធ្វើឡើងក្នុងក្របខ័ណ្ឌសហគ្រាស ។ ដូច្នេះ ក្របខណ្ឌនេះមានលក្ខណៈស្ទើរតែជាចំខាត ដែលភាពជាតំណាងចេញមកពីអំពើនៃច្បាប់នេះត្រូវបានទទួលស្គាល់ ។ អង្គការដែលមានចំនួនសមាជិកភាគច្រើន ហើយដែលត្រូវបានទទួលស្គាល់ថាជា "*សហជីពដែលមានភាពតំណាងបំផុត*" សហជីពដែលសមាជិករបស់វាមានលើសពី ៥១ ភាគរយនៃនិយោជិតនៅក្នុងសហគ្រាស ។ តាមពិត លក្ខខណ្ឌនៃចំនួនសមាជិកនេះបង្កើតបានជាលក្ខណៈវិនិច្ឆ័យសំខាន់មួយ ។

ខ. លក្ខណៈវិនិច្ឆ័យ :

មាត្រា ២៧៧ នៃក្រមការងារបន្តចែងទៀតថា "*ភាពជាតំណាងនេះ ត្រូវកំណត់តាមលក្ខណៈវិនិច្ឆ័យដូចតទៅ :*

ក- បានចុះបញ្ជីការត្រឹមត្រូវ ដូចមានចែងក្នុងមាត្រា ២៦៨ ខាងលើ ។

ខ- មានចំនួនសមាជិកដែលមានប័ណ្ណសំគាល់សមាជិកភាពត្រឹមត្រូវច្រើនជាងគេ ។ សហជីពណាដែលមានចំនួនសមាជិកច្រើនជាងគេក្នុងលំដាប់ថ្នាក់លេខមួយ និងលេខពីរ ត្រូវចាត់ទុកថា ជាសហជីពដែលមានភាពជាតំណាងនៅក្នុងសហគ្រាស ។ ប៉ុន្តែ សហជីពណាដែលមានសមាជិកចំនួនហាសិបមួយភាគរយ (៥១%) ឡើងទៅនៃចំនួនសមាជិករបស់សហគ្រាស ត្រូវចាត់ទុកថាជាសហជីពដែលមានភាពជាតំណាងបំផុត ។

គ- បានទទួលប្រាក់ភាគទានយ៉ាងហោចណាស់សាមសិបបីភាគរយនៃចំនួនសមាជិក ។

ឃ- មានកម្មវិធី និងសកម្មភាពដែលបង្ហាញថា សហជីពនោះមានលទ្ធភាពផ្តល់សេវាខាងវិជ្ជាជីវៈ វប្បធម៌ និងអប់រំដល់សមាជិករបស់ខ្លួន ដូចមានចែងក្នុងមាត្រា ២៦៦ នៃច្បាប់នេះ ។

២- ក្នុងរយៈពេលហុកសិបថ្ងៃយ៉ាងយូរ ក្រោយពីបានទទួលសំណុំបែបបទដើម្បីសុំទទួលស្គាល់ភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈ ក្រសួងទទួលបន្ទុកវិស័យការងារ ត្រូវសំរេចជាផ្លូវការអំពីការទទួលស្គាល់ភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈណាដែលបានបំពេញលក្ខណៈវិនិច្ឆ័យ ដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើ ។

Scanned with CamScanner

ដូច្នេះ ដើម្បីអាចត្រូវបានចាត់ទុកដូចជាភាពជាតំណាង ត្រូវមានចុះបញ្ជីការនៅចំពោះមុខនាយកដ្ឋាននៃក្រសួងទទួលបន្ទុកការងារ ។ វាគឺជាលក្ខខណ្ឌទី ១ ក្នុងករណីដែលការចុះបញ្ជីការនេះផ្តល់នូវគុណភាពជាអង្គការសហជីព ។ អង្គការមួយដែលពុំត្រូវបានចុះបញ្ជី ពុំមានគុណភាពដូចមានចែងក្នុងបញ្ញត្តិខាងលើនោះទេ ហើយក៏ពុំអាចត្រូវបានចាត់ទុកជាមុនថា ជាអង្គការដែលមានភាពតំណាងដែរ ។ បន្ទាប់មក ត្រូវមានការចូលរួមភាគទានពីសមាជិកដែលមានចំនួនសមល្មម គឺជាចំនួនមួយដែលត្រូវតែវាយតម្លៃក្នុងក្របខណ្ឌដែលអង្គការចង់ ត្រូវបានទទួលស្គាល់មានភាពជាតំណាង ។ ជានិច្ចជាកាលក្នុងក្របខណ្ឌដែលភាពជាតំណាងត្រូវបានស្នើសុំ ត្រូវមានកម្មវិធី និងសកម្មភាពដែលទាក់ទងនឹងគុណភាពនៃសហជីព ។ តាមពិត សហជីពត្រូវការជាចាំបាច់នូវសកម្មភាពវិជ្ជាជីវៈ និងសង្គម ដែលវាត្រូវផ្តល់សកម្មភាពទាំងនេះឱ្យទៅសមាជិករបស់ខ្លួន ។ ប៉ុន្តែ សមាជិកក៏អាចបានទទួលក្រៅពីផលប្រយោជន៍នេះផងដែរ ដូចជាសហជីពអាចមានសកម្មភាពវប្បធម៌ ឬការអប់រំ ។ វាត្រូវតែគោរពនូវគោលការណ៍វិជ្ជាជីវៈ ដែលមានចែងក្នុងសហលក្ខន្តិកៈ ក្នុងន័យថាសហជីពមានកម្មវត្ថុផ្តាច់មុខលើការសិក្សា ការបង្ហាញ ការពារសិទ្ធិ ថែមទាំងផលប្រយោជន៍ជាសម្ភារៈ និងសីលធម៌ទាំងផលប្រយោជន៍រួម និងឯកជនរបស់បុគ្គលដែលបានរាយនៅក្នុងសហលក្ខន្តិកៈខាងលើនោះ ។ ចុងបញ្ចប់ ត្រូវមានចំនួនសមាជិកចូលរួមភាគច្រើន ។ លើសពីនេះទៀត ប្រសិននៅក្នុងសហគ្រាស អង្គការមួយ មានសមាជិកតំណាងចំនួន ៥១ ភាគរយ អង្គការនេះមានភាពតំណាង ដោយហេតុថា អង្គការនេះត្រូវបានចាត់ទុកថា ជាអង្គការដែលមានភាពជាតំណាងបំផុត ។

ទោះបីជាយ៉ាងណាក៏ដោយ រដ្ឋមន្ត្រីទទួលបន្ទុកការងារ ត្រូវតែផ្តល់ចម្លើយក្នុងរយៈពេល ៦០ ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានពាក្យសុំទទួលស្គាល់ភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈមួយ ។ ប្រសិនបើភាពជាតំណាងនេះ ត្រូវគោរពតាមលក្ខខណ្ឌណាមួយ មានន័យថា ផលប្រយោជន៍របស់វាក៏មានចំនួនច្រើនផងដែរ ។

II. ការប្រទូយប្រថានទាត់ទងនឹងភាពជាតំណាងសហជីព :

អនុលោមតាមមាត្រា ២៧៧ នៃច្បាប់ការងារ ភាពជាតំណាងសហជីព ផ្តល់សិទ្ធិមួយចំនួនឱ្យទៅអង្គការនេះ (ក) ។ ប៉ុន្តែ ភាពជាតំណាងពុំស្ថិតនៅយូរអង្វែងនោះទេ (ខ) ។ លក្ខណៈនៃភាពជាតំណាងពុំត្រឹមតែជាប្រធានបទក្នុងការពិភាក្សានោះទេ ថែមទាំងអាចត្រូវបានលុបចោល ឬព្យួរផងដែរ ។

ក. សិទ្ធិទាក់ទងនឹងភាពជាតំណាងសហជីព :

" បទប្បញ្ញត្តិទាំងឡាយនៃច្បាប់ការងារ អាចភ្ជាប់ភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈដែលក្រសួងទទួលបន្ទុកវិស័យការងារ បានទទួលស្គាល់ទៅតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ទៅនឹងការទទួលអត្ថប្រយោជន៍ដែលទាក់ទងទៅនឹង :

- ការបែងចែកអាសនៈនៅក្នុងអង្គការមួយចំនួន ដែលបានកំណត់ក្នុងច្បាប់ការងារ

- សមត្ថកិច្ចនៃការចរចាជាសមូហភាព

- ការឧទ្ធរណ៍នាមបក្ខជនក្នុងការបោះឆ្នោតលើកទីមួយនៃការជ្រើសរើសប្រតិភូបុគ្គលិក ។"

Scanned with CamScanner

កថាខណ្ឌទី ៣ នៃមាត្រា ២៧៧ នៃច្បាប់ការងារបានចែងអំពីសិទ្ធិដែលត្រូវផ្តល់ឱ្យទៅអង្គការដែលមានភាពជាតំណាង ។ តាមពិត នៅពេលដែលអង្គការមួយត្រូវបានចាត់ទុកថាមានភាពជាតំណាង អង្គការនេះអាចតែងតាំងអ្នកតំណាងទៅក្នុងអង្គការចាត់តាំង បើសិនបើច្បាប់បានសម្រេចដូច្នេះ ។ ប៉ុន្តែ អង្គការនេះក៏អាចចូលរួមជាពិសេសទៅក្នុងការចរចាជារួម និងមានសិទ្ធិផ្តាច់មុខក្នុងការឧទ្ទេសនាមបេក្ខជនក្នុងការបោះឆ្នោតលើកទីមួយនៃការជ្រើសរើសប្រតិភូ-បុគ្គលិក ផងដែរ ។

យោងតាមមាត្រា ៩៦ នៃច្បាប់ការងារ អនុសញ្ញារួមត្រូវបានធ្វើឡើងរវាងនិយោជក ឬនិយោជកមួយក្រុម ឬអង្គការតំណាងនិយោជកមួយ ឬច្រើន ជាមួយនឹងអង្គការសហជិពដែលមានភាពជាតំណាងនិយោជិតមួយ ឬច្រើន ។ អនុសញ្ញានេះអាចត្រូវបានអនុវត្តនៅក្នុងសហគ្រាសមួយ ឬសហគ្រាសមួយក្រុម ឬក្នុងវិស័យឧស្សាហកម្ម ឬផ្នែកណាមួយនៃវិស័យឧស្សាហកម្ម ឬផ្នែកណាមួយ ឬផ្នែកជាច្រើននៃសកម្មភាពសេដ្ឋកិច្ច ។ ហេតុដូច្នេះ មានតែអង្គការសហជិពដែលមានភាពជាតំណាងក្នុងកម្រិតដែលបានរៀបរាប់ខាងលើប៉ុណ្ណោះ ដែលមានសមត្ថកិច្ចចុះអនុសញ្ញារួមដែលអាចអនុវត្តបានក្នុងកម្រិតក្របខណ្ឌនោះ ។

ក្នុងកម្រិតសហគ្រាស ច្បាប់បានផ្តល់ឱ្យទៅអង្គការសហជិពដែលមានភាពជាតំណាងនូវការឧទ្ទេសនាមបេក្ខជនក្នុងការបោះឆ្នោតលើកទីមួយនៃការជ្រើសរើសប្រតិភូបុគ្គលិក ។ គឺមានតែក្នុងសម្មតិកម្មដែលគ្មានបេក្ខជនផ្សេងទៀតត្រូវបានធ្វើជាតំណាងអង្គការដែលមានភាពជាតំណាងក្នុងសហគ្រាសប៉ុណ្ណោះ ឬប្រសិនបើចំនួនអ្នកចូលរួមបោះឆ្នោត ពុំបានដល់កម្រិតពាក់កណ្តាលនៃអ្នកដែលបានចុះឈ្មោះនៅដំណាក់កាលទី ១ ហើយដែលអាចមានដំណាក់កាលទី ២ ដែលក្នុងនោះបេក្ខជនអាច ឬពុំអាចត្រូវបានឧទ្ទេសនាម ដោយអង្គការសហជិព ។

ទោះបីជាកម្រិតដែលអង្គការសហជិពត្រូវបានទទួលស្គាល់មានទំហំយ៉ាងដូចម្តេចក៏ដោយ យើងឃើញផលប្រយោជន៍ដែលផ្សារភ្ជាប់ជាមួយនឹងការទទួលស្គាល់គុណភាពនេះមានច្រើន ។ ប៉ុន្តែ ភាពជាតំណាងនេះពុំបានស្ថិតនៅយូរអង្វែងនោះទេ ។

ខ. ព្រំដែននៃភាពជាតំណាង :

យោងតាមកថាខណ្ឌចុងក្រោយនៃមាត្រា ២៧៧ នៃច្បាប់ការងារ " *ក្រសួងទទួលបន្ទុកវិស័យការងារអាចចាត់អោយមានការអង្កេត ក្នុងករណីដែលត្រូវកំណត់លក្ខណៈនៃភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈណាមួយ ឬការពិនិត្យនូវភាពស្ថិតស្ថេរនៃអង្គការនេះ ។*

អង្គការវិជ្ជាជីវៈដែលជាប់ពាក់ព័ន្ធរឿងនេះ ត្រូវផ្តល់នូវឯកសារបញ្ជាក់ទាំងអស់តាមការស្នើសុំពីមន្ត្រីមានសមត្ថកិច្ច ។ កាលណាបើគ្មានឯកសារបញ្ជាក់ ឬក៏ឯកសារនោះមិនគ្រប់គ្រាន់ ការទទួលស្គាល់ភាពជាតំណាងត្រូវតែបដិសេធ ឬត្រូវព្យួរទុក រហូតដល់មានឯកសារគ្រប់គ្រាន់បញ្ជាក់ពីរឿងនេះ ។ អត្ថប្រយោជន៍ទាក់ទងនឹងភាពជាតំណាងដែលរាល់អង្គការវិជ្ជាជីវៈត្រូវទទួលបាននោះ ក៏ត្រូវតែលុបចោល ឬត្រូវព្យួរទុកដែរ ។"

យើងអាចនិយាយបានម៉្យាងទៀតថា រដ្ឋមន្ត្រីមានតួនាទីផ្សៀងផ្ទាត់ជាបឋមនូវលក្ខណៈនៃភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈមួយ ។ សេចក្តីនេះស្ថិតនៅក្នុងភាពតក្កវិជ្ជានៃអត្ថបទអន្តរជាតិ ក្នុងករណីដែលគ្រប់អង្គការសហជីពទាំង

Scanned with CamScanner

អស់ពុំអាចអនុវត្តសិទ្ធិទាំងឡាយ ហើយដែលត្រូវតែមានប្រព័ន្ធនៃការទទួលស្គាល់ភាពជាតំណាងនេះ ។ ប៉ុន្តែ លក្ខណៈវិនិច្ឆ័យនៃភាពជាតំណាង យោងតាមនិយមន័យតាមបែបវិវត្តន៍ គឺជាលក្ខណៈវិនិច្ឆ័យទាំងឡាយណាដែលអាចត្រូវបានបាត់បង់ទៅវិញ ។ ដូច្នេះ វាត្រូវតែបង្កជាបញ្ហាចំពោះភាពជាតំណាងនេះ និងត្រូវបដិសេធចំពោះអង្គការសហជីព នូវលទ្ធភាពអនុវត្តសិទ្ធិដែលភាពជាតំណាងនេះ បានផ្តល់ឱ្យទៅអង្គការសហជីពទាំងនោះ ។

មាត្រា ២៧៧ នៃច្បាប់ការងារមានភាពសម្បូរបែបក្នុងការបង្ហាត់បង្រៀន និងត្រូវបានបញ្ចូលក្នុងក្របខណ្ឌនៃអនុសញ្ញាអន្តរជាតិស្តីពីសេរីភាពសហជីព ដែលត្រូវបានផ្តល់សច្ចាប័នដោយប្រទេសកម្ពុជាផងដែរ ។

ក. និតិសាធារណៈ

១. ម្ចាស់ការបទ

មាត្រា ៤៤ នៃរដ្ឋធម្មនុញ្ញចុះថ្ងៃទី ២៤-០៩-១៩៩៣ ចែងថា "*ជនណាក៏ដោយ ទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធ ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី ។*

កម្មសិទ្ធឯកជនស្របច្បាប់ ឋិតនៅក្រោមការគាំពារនៃច្បាប់ ។ ដែលនឹងដកហូតកម្មសិទ្ធអំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈតម្រូវអោយធ្វើក្នុងករណីដែលច្បាប់បានបញ្ជាក់ទុក ហើយត្រូវផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌ ។"

២. កំណែ : (ស្វ សុជាតិ)

មាត្រា ៤៤ នៃរដ្ឋធម្មនុញ្ញចុះថ្ងៃទី ២៤-០៩-១៩៩៣ ត្រូវបានបញ្ចូលក្នុងជំពូកទី៣ ដែលទាក់ទងនឹងសិទ្ធិ និងកាណើយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ ។ រដ្ឋធម្មនុញ្ញ ១៩៩៣ គឺជាច្បាប់កំពូល និងជាច្បាប់ត្រឹះដែលបង្កើតអោយមានបំរែបំរួលទាំងស្រុងនូវមជ្ឈដ្ឋាននយោបាយ និងគតិយុត្ត នៅព្រះរាជាណាចក្រកម្ពុជា ។ ការវិវត្តន៍ដ៏ធំនោះ គឺការផ្លាស់ប្តូរពីរបបកុម្មុយនីស្ត ទៅជារបបប៉ែបបណ្តាប្រទេសលោកខាងលិច ។ ប្រព័ន្ធសេរីនិយមបែបបស្ចឹមប្រទេសដែលសម្រេចអនុវត្តយកតាមដោយសភាធម្មនុញ្ញឆ្នាំ ១៩៩៣ បង្កើតអោយមានការទទួលស្គាល់សិទ្ធិត្រឹះសំខាន់ៗ សើរភាពជាសារវ័ន្តរបស់មនុស្ស របស់ប្រជាពលរដ្ឋខ្មែរ ។ ក្នុងចំណោមសិទ្ធិជាត្រឹះសំខាន់ៗទាំងនេះ យើងសង្កេតឃើញមានការទទួលស្គាល់នូវសិទ្ធិដ៏សំខាន់មួយដែលជាកម្មវត្ថុនៃមាត្រា ៤៤ នេះ : "សិទ្ធិជាម្ចាស់កម្មសិទ្ធិឯកជន" ។ ការកកើតឡើងវិញនូវកម្មសិទ្ធិឯកជននេះ គឺមានលក្ខណៈគួរអោយកត់សំគាល់ ព្រោះថា វាជាការបំបាត់ ឬជាការបោះបង់ចោលនូវរបបសង្គមនិយមនៃសិទ្ធកម្មសិទ្ធិ ដែលអនុវត្តកន្លងមក មុនពេលមានច្បាប់រដ្ឋធម្មនុញ្ញថ្មីនេះ មានន័យថា ប្រពន្ធ័សិទ្ធកម្មសិទ្ធិរួម ឬសមូហភាវូបនីយកម្មនៃសិទ្ធកម្មសិទ្ធិ ដែលបដិសេធនូវសិទ្ធិកម្មសិទ្ធិឯកជន ត្រូវបានបោះបង់ចោលទាំងស្រុង ។

ជាការពិត មាត្រា ៤៤ នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ នេះ បង្កើតឡើងវិញទាំងកម្មសិទ្ធិឯកជន និងការផ្តល់ការការពារដោយច្បាប់នូវកម្មសិទ្ធិឯកជននេះ ។ កម្មសិទ្ធិនេះ គឺជាសញ្ញាណគតិយុត្តមួយដែលមានអត្ថន័យ ពីរយ៉ាង ។ ជាដំបូង កម្មសិទ្ធិត្រូវបានចាត់ទុកថា ជាអំណាចផ្តាច់មុខរបស់បុគ្គលម្នាក់ទៅលើវត្ថុមួយ ឬជាកន្សោមនៃសិទ្ធិ បុព្វសិទ្ធិ និង

Scanned with CamScanner

ផលប្រយោជន៍ផ្សេងៗ ដែលបុគ្គលម្នាក់អាចមាន ឬអាចទាញយកបានអំពីវត្ថុនោះ ។ អត្ថន័យម្យ៉ាងទៀត ចង់សំដៅថា កម្មសិទ្ធិ គឺជាចំណងដែលភ្ជាប់វត្ថុមួយ ទៅនឹងមនុស្សម្នាក់ និងត្រូវបានប្រដូច ជាវត្ថុនោះតែម្តង ដែលយើងហៅថា ទ្រព្យ មានន័យថា កម្មសិទ្ធិរបស់បុគ្គលម្នាក់ គឺ "*ជាទ្រព្យដែលកាប់កាប់ដោយបុគ្គលនោះ ដូចជាដីធ្លី សំណង់អគារ ជាដើម*" ។ អត្ថន័យទាំងពីរបែបនេះ គ្មានអ្វីដែលធ្វើឱ្យមានការយល់ច្រឡំនោះទេ ដោយអត្ថន័យទីមួយ ចង់សំដៅទៅលើ "សិទ្ធិកម្ម-សិទ្ធិ" ឯអត្ថន័យទីពីរ គឺបញ្ជាក់អំពី "កម្មវត្ថុនៃសិទ្ធិនេះ" ។ ដូច្នេះ យើងអាចចោទជាសំនួរថា **តើសិទ្ធិកម្មសិទ្ធិនៃមាត្រា ៤៤ មានអត្ថន័យយ៉ាងដូចម្តេច ?**

បើយើងវិភាគអោយបានម៉ត់ចត់នូវមាត្រា ៤៤ នេះ យើងនឹងសង្កេតឃើញថា **សិទ្ធិកម្មសិទ្ធិ គឺជាសិទ្ធគ្រឹះសំខាន់ផង (I) និងជាសិទ្ធិដែលត្រូវបានកំណត់ព្រំដែនផងដែរ** ។ រដ្ឋធម្មនុញ្ញបានបញ្ជាក់អំពីដែនកំនត់នៃសិទ្ធិកម្មសិទ្ធិនេះ ដោយបង្ហាញអំពីសញ្ញាណដ៏សំខាន់ក្នុងនីតិសាធារណៈគឺ "អស្សាមិករណ៍ "(II) ។

I. សិទ្ធិកម្មសិទ្ធិ : សិទ្ធិគ្រឹះសំខាន់

លក្ខណៈគ្រឹះនៃសិទ្ធិកម្មសិទ្ធិ គឺស្ថែងឡើងតាមរយៈតម្លៃគតិយុត្តដែលសភាធម្មនុញ្ញ ១៩៩៣ បានផ្តល់ឱ្យទៅលើសិទ្ធិនេះ (ក) ។ ម្យ៉ាងទៀត ព្រោះថា ជាសិទ្ធិដែលមានលក្ខណៈផ្តាច់មុខ និងពុំអាចរំលោភបាន (ខ) ។

ក. លក្ខណៈធម្មនុញ្ញភាពនៃសិទ្ធិកម្មសិទ្ធិ :

តាមបញ្ញត្តិនៃមាត្រា ៤៤ ខាងលើនេះ "*ជនណាក៏ដោយ ទោះជាបុគ្គលក្តី ជាសម្ព័ន្ធភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ (.....) កម្មសិទ្ធិឯកជនស្របច្បាប់ ឋិតនៅក្រោមការគាំពារនៃច្បាប់*" ។ ដូច្នេះ វាមានលក្ខណៈច្បាស់លាស់ទៅហើយថា លក្ខន្តិកៈធម្មនុញ្ញភាពនៃសិទ្ធិកម្មសិទ្ធិឯកជននោះត្រូវបានទទួលស្គាល់ មានន័យថា សភាធម្មនុញ្ញមានឆន្ទៈទទួលស្គាល់ថា សិទ្ធិកម្មសិទ្ធិឯកជន គឺជាសិទ្ធិគ្រឹះ និងចាំបាច់សំរាប់ប្រជាពលរដ្ឋខ្មែរ ។

នៅក្នុងប្រវត្តិធម្មនុញ្ញនៃកម្ពុជា ការចែងអំពីសិទ្ធិកម្មសិទ្ធិនៅក្នុងច្បាប់កំពូលត្រូវបានធ្វើឡើងចាប់តាំងពីមានរដ្ឋធម្មនុញ្ញលើកដំបូងមកម្ល៉េះ គឺមាត្រា ៧ នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៤៧ "កម្មសិទ្ធិឋិតនៅក្រោមការការពារនៃច្បាប់ ។ គ្មានបុគ្គលណាម្នាក់ ដែលអាចត្រូវបានដកហូតកម្មសិទ្ធិឡើយ បើមិនមែនជាករណីនៃផលប្រយោជន៍សាធារណៈ កំណត់ឡើងដោយច្បាប់ និងត្រូវមានសំណងត្រឹមត្រូវជាមុន" ។ ក្រោយរដ្ឋប្រហារឆ្នាំ ១៩៧០ **រដ្ឋធម្មនុញ្ញថ្មីឆ្នាំ ១៩៧២ ត្រូវបានអនុ-ម័ត** ហើយរបបថ្មីនេះពុំបានបោះបង់ការទទួលស្គាល់ និងចែងជាថ្មីឡើងវិញនូវសិទ្ធិកម្មសិទ្ធិនោះទេ ។ **មាត្រា ១៤ នៃរដ្ឋ-ធម្មនុញ្ញឆ្នាំ ១៩៧២** ចែងតាមរបៀបថ្មីថា "**រដ្ឋទទួលស្គាល់ និងធានានូវកម្មសិទ្ធិឯកជន ។ រដ្ឋជួយជំរុញឱ្យមានការបង្កើតកម្មសិទ្ធិឯកជន** ។ ការប៉ះពាល់ទាំងឡាយទៅលើកម្មសិទ្ធិ ត្រូវបានហាមឃាត់ លើកលែងតែករណីប្រយោជន៍សាធារណៈដែលកំណត់ឡើងដោយច្បាប់ ។ នៅក្នុងលក្ខខណ្ឌនេះ ម្ចាស់កម្មសិទ្ធិមានសិទ្ធិទទួលនូវសំណងជាមុន សមរម្យ និងត្រឹមត្រូវ" ។ ប៉ុន្តែ **ចាប់តាំងពីឆ្នាំ ១៩៧៥** មក របបកុម្មុយនីស្ត និងរបបសង្គមនិយម បានបំបាត់ចោលនូវ**របបកម្មសិទ្ធិឯកជន** នេះ ។ គ្មានម្ចាស់កម្មសិទ្ធិឯកជននោះទេនៅកម្ពុជា ក្នុងសម័យកាលនោះ ។ យើងត្រូវរង់ចាំរហូតដល់**ការអនុម័តរដ្ឋធម្ម-នុញ្ញ**នៃចន្ទសើរនិយមឆ្នាំ ១៩៩៣ ទើបរបបកម្មសិទ្ធិឯកជនត្រូវបានទទួលស្គាល់ឡើងវិញចំពោះប្រជាពលរដ្ឋខ្មែរ ។

Scanned with CamScanner

មាត្រា ៤៤ នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ទទួលស្គាល់របបកម្មសិទ្ធិឯកជន ដោយមានទម្រង់ពីរបែប ។ តាមពាក្យពេជន៍ផ្តាល់នៃមាត្រានេះ "ជនណាក៏ដោយ ទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ" ។ បទប្បញ្ញត្តិនេះ បង្ហាញអំពីទម្រង់នៃកម្មសិទ្ធិឯកជន និងកម្មសិទ្ធិសមូហភាព ។ វត្ថុមួយនៅលើដែនដីនៃប្រទេសកម្ពុជា អាចត្រូវបានចាប់យកជាកម្មសិទ្ធិដោយបុគ្គលម្នាក់ ឬដោយសមូហភាព ។ វាក្យខណ្ឌទី ១ នៃមាត្រាខាងលើនេះបានចែងបន្តទៀតថា "មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី" ។ នីតិបុគ្គលដូចជារូបវន្តបុគ្គលដែរ អាចជាម្ចាស់លើទ្រព្យដែលបានដោយស្របច្បាប់ ។ ការទទួលស្គាល់ដល់នីតិបុគ្គលនូវសិទ្ធិកម្មសិទ្ធិនេះ បង្កើតអោយមានចម្ងល់ជាច្រើន ព្រោះថា នីតិបុគ្គលគ្រាន់តែជា "ការច្នៃប្រឌិតក្នុងក្របខណ្ឌច្បាប់ ហើយចាំបាច់សម្រាប់វិស័យសេដ្ឋកិច្ចជាពិសេស" ប៉ុណ្ណោះ ។ ជាធម្មតា សិទ្ធិកម្មសិទ្ធិ ផ្សារភ្ជាប់ទៅនឹងបុគ្គលដែលជារូបវន្តបុគ្គល ។ វាគួរអោយពិចារណាស់ដែលយើងត្រូវគិតថា សិទ្ធិគ្រឹះដ៏សំខាន់នេះ ត្រូវបានទទួលស្គាល់ផងដែរ ចំពោះនីតិបុគ្គលដែលគ្រាន់តែជាបច្ចេកទេសគតិយុត្តមួយក្នុងការផ្តល់នូវតម្រូវការដល់បុគ្គលតែប៉ុណ្ណោះ ។ ប៉ុន្តែ ក្នុងសភាពគតិយុត្ត នីតិបុគ្គលគឺជាប្រធាននៃនីតិពេញលក្ខណៈ ។ គឺដោយសារបុគ្គលភាពគតិយុត្តនេះហើយ ដែលជំរុញអោយមានការប្រដូចទៅនឹងរូបវន្តបុគ្គលក្នុងទំនាក់ទំនងគតិយុត្តជាមួយទ្រព្យ ។ លក្ខខណ្ឌចុងក្រោយដែលតម្រូវដោយច្បាប់កំពូល ចំពោះការទទួលស្គាល់សិទ្ធិកម្មសិទ្ធិនេះ គឺការមានសញ្ជាតិខ្មែររបស់ម្ចាស់កម្មសិទ្ធិ ។ សភាធម្មនុញ្ញឆ្នាំ ១៩៩៣ ធ្វើការបែងចែកជាដំបូងរវាងកម្មសិទ្ធិលើចលនទ្រព្យ និងលើអចលនទ្រព្យ ដើម្បីកំណត់នូវលក្ខខណ្ឌនេះ ។ លក្ខខណ្ឌនៃសញ្ជាតិទាមទារតែក្នុងករណីនៃការចាប់យកដីធ្លីមកធ្វើជាកម្មសិទ្ធិតែប៉ុណ្ណោះ ។

ខ. តារាងផ្តាច់មុខ និងតារាងមិនអាចរំលោភបាននៃសិទ្ធិកម្មសិទ្ធិ :

មាត្រា ៤៤ ខាងលើពុំបានកំណត់និយមន័យនៃសិទ្ធិកម្មសិទ្ធិនេះទេ ។ សភាធម្មនុញ្ញគ្រាន់តែបញ្ជាក់អំពីការធានាដោយរដ្ឋធម្មនុញ្ញនូវសិទ្ធិគ្រឹះនេះប៉ុណ្ណោះ : "កម្មសិទ្ធិឯកជនស្របច្បាប់ គឺឯកនៅក្រោមការគាំពារនៃច្បាប់" (វាក្យខណ្ឌទី ២) ។ និយមន័យនៃពាក្យថា កម្មសិទ្ធិ ត្រូវបានបញ្ជាក់តាមក្រោយ ដោយនីតិករបានបញ្ជូតវាក្នុងច្បាប់ភូមិបាលចុះថ្ងៃទី ៣០-០៨-២០០១ ។ សិទ្ធិកម្មសិទ្ធិឯកជនត្រូវបានចាត់ទុកថាជា "សិទ្ធិប្រើប្រាស់ អាស្រ័យផល និងចាត់ចែងទ្រព្យរបស់ខ្លួនយ៉ាងផ្តាច់មុខ និងទូលំទូលាយ កុំអោយតែយកទ្រព្យនោះទៅប្រើប្រាស់ក្នុងបទណាមួយដែលច្បាប់បានហាមឃាត់" (មាត្រា៨៥) ។ និយមន័យនេះមានលក្ខណៈស្មើតែដូចគ្នាទៅនឹងអ្វីដែលបានអនុម័តឡើងដោយនីតិករបារាំង[116] ។ នីតិករកម្ពុជា មានឆន្ទៈមុតមាំក្នុងការទទួលស្គាល់ដល់កម្មសិទ្ធិករនូវសិទ្ធិប្រើប្រាស់ អាស្រ័យផល និងចាត់ចែងទ្រព្យទៅតាមសេចក្តីត្រូវការ ។ គួរកត់សំគាល់ថា គ្មានអ្វីក្រៅពីធាតុសំខាន់ទាំងបីនៃកម្មសិទ្ធិនេះទេ : ប្រើប្រាស់, អាស្រ័យផល និងចាត់ចែង ដែលប្រភពដើមនៃធាតុគតិយុត្តទាំង ៣ នេះ គឺជាមរតកដែលបន្តមកពីនីតិវ៉ូម៉ាំងដែលពន្យល់អំពីការឯកភាព និងភាពពេញលេញនូវសិទ្ធិកម្មសិទ្ធិ ។

[116] មាត្រា ៥៤៤ នៃក្រមរដ្ឋប្បវេណីបារាំងចែងថា " កម្មសិទ្ធិ គឺសិទ្ធិប្រើប្រាស់ និងចាត់ចែងវត្ថុដោយដាច់ខាត កុំអោយតែយកទ្រព្យនោះ ទៅប្រើប្រាស់ដោយខុសច្បាប់ ឬបទបញ្ជាផ្សេងៗ" ។

Scanned with CamScanner

កម្មសិទ្ធិករអនុវត្តសិទ្ធិកម្មសិទ្ធិ ក្រោមទម្រង់មួយដោយពេញលេញ មានន័យថា "ជាសិទ្ធិប្រើប្រាស់វត្ថុ សម្រាប់រាល់ការបំរើបំរាស់ដែលអាចទៅរួច, សិទ្ធិអាស្រ័យផលដោយទទួលនូវបច្ច័យ និងផលគ្រប់យ៉ាងពីវត្ថុ និងសិទ្ធិចាត់ចែងវត្ថុដែលអាចរហូតដល់ការកំទេចវត្ថុ ប្រើប្រាស់តាមការបរិភោគ ឬលក់ដូរ ជួលជាដើម" ។ លក្ខខណ្ឌតែមួយគត់ គឺត្រូវប្រើប្រាស់វត្ថុដោយគោរពទៅតាមច្បាប់ និងបទបញ្ជាជាធរមាន ។ ដូច្នេះ សិទ្ធិកម្មសិទ្ធិបង្ហាញអោយឃើញនូវលក្ខណៈផ្តាច់មុខចំពោះម្ចាស់កម្មសិទ្ធិករ ។ កម្មសិទ្ធិករ គឺជាម្ចាស់តែម្នាក់គត់លើទ្រព្យរបស់គាត់ ដោយមានអំណាចរារាំងដល់ជនដទៃ ដោយពុំរង់ចាំថា ការរំលោភនោះបានបង្ករឱ្យមានព្យសនកម្មខាងផ្លូវចិត្ត ឬជាសម្ភារៈ ។ ជាគោលការណ៍ កម្មសិទ្ធិករអាចហាមឃាត់គ្រប់ការប៉ះពាល់ ការឈ្លានពានលើទ្រព្យរបស់ខ្លួន ព្រោះថាគាត់មានសិទ្ធិផ្តាច់មុខលើវត្ថុ ។

បន្ថែមពីលើភាពផ្តាច់មុខនេះទៀត សិទ្ធិកម្មសិទ្ធិ គឺជាសិទ្ធិដែលពុំអាចរំលោភបំពានបាននោះទេ ។ ដើម្បីឱ្យមានភាពផ្តាច់មុខ សិទ្ធិកម្មសិទ្ធិត្រូវមានភាពមិនអាចរំលោភបំពានបាន ដែលគាំពារដោយច្បាប់ ។ ដូច្នេះ សិទ្ធិកម្មសិទ្ធិមានលក្ខណៈផ្តាច់មុខ និងមិនអាចរំលោភបំពានបាន ដែលជាសិទ្ធិគ្រឹះនៅក្នុងសង្គម ។ សិទ្ធិកម្មសិទ្ធិនេះ ទទួលបាននូវការគាំពារ ដោយរារាំងមិនអោយមានការប៉ះពាល់ ឬឈ្លានពាននោះទេ ។

ប៉ុន្តែ សិទ្ធិកម្មសិទ្ធិ ពុំមានលក្ខណៈដាច់ខាតនោះទេ ។ ការកំណត់ព្រំដែន ឬការដកហូត គឺអាចធ្វើទៅបាន ។

II. សិទ្ធិកម្មសិទ្ធ : សិទ្ធិដែលត្រូវបានកំណត់ព្រំដែនដោយអំណាចរឹបអូសរបស់មុគ្គលសាធារណៈ

មាត្រា ៤៤ នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ បង្ហាញអំពីសញ្ញាណ "អស្សាមិករណ៍" ដូចជាការកំណត់ព្រំដែនដោយស្របច្បាប់ចំពោះសិទ្ធិកម្មសិទ្ធិឯកជន ។ អស្សាមិករណ៍ត្រូវបានកំណត់និយមន័យថា ជាអំណាចធម្មតាមួយដែលប្រគល់ឱ្យទៅនីតិបុគ្គលសាធារណៈ ដើម្បីដកហូតយកអចលនទ្រព្យផ្សេងៗ ក្នុងគោលដៅបម្រើផលប្រយោជន៍ទូទៅរបស់ប្រជាពលរដ្ឋទាំងអស់ ហើយដែលកម្មសិទ្ធិករប្រកែកមិនព្រមលក់ជូនរដ្ឋ ។ ជាគោលការណ៍ កម្មសិទ្ធិឯកជនស្របច្បាប់ត្រូវតែគោរព មិនអាចបំពានបាន ។ ប៉ុន្តែ លក្ខណៈ "មិនអាចរំលោភបំពានបាន" នៃកម្មសិទ្ធិឯកជននេះត្រូវសម្របសម្រួលជាមួយនឹងសញ្ញាណនៃ "ផលប្រយោជន៍សាធារណៈ" ឬប្រយោជន៍រួមនៃមនុស្សជាតិ (ក) ។ អស្សាមិករណ៍ បង្កើតកាតព្វកិច្ចចំពោះម្ចាស់កម្មសិទ្ធិដែលពាក់ព័ន្ធ ក្នុងការប្រគល់ទ្រព្យរបស់ខ្លួនឱ្យទៅរដ្ឋ ។ តែរដ្ឋបាលសាធារណៈ ពុំអាចទទួលយកទ្រព្យនេះបាន ដោយមិនបង់ថ្លៃឱ្យទៅម្ចាស់ទ្រព្យនោះទេ ។ មាត្រា ៤៤ ចង្អុលបង្ហាញច្បាស់លាស់ណាស់ថា "ត្រូវសងជាសំណងការខូចខាតជាមុន ដោយសមរម្យ និងត្រឹមត្រូវ" (ខ) ។

ក. ប្រយោជន៍សាធារណៈ: យុត្តិកម្មនៃការដកហូតកម្មសិទ្ធិឯកជន

ការអនុវត្តនីតិវិធីអស្សាមិករណ៍ លើកឡើងនូវការកំណត់ព្រំដែននៃសិទ្ធិកម្មសិទ្ធិដែលពុំមានភាពដាច់ខាតនោះទេ ព្រោះថា ម្ចាស់កម្មសិទ្ធិអាចបាត់បង់សិទ្ធិកម្មសិទ្ធិ ដែលធ្វើឡើងផ្ទុយពីឆន្ទៈរបស់គាត់ ។ ជានិច្ចជាកាល បច្ចេកទេសនៃការផ្ទេរកម្មសិទ្ធិដោយបង្ខំនេះ អាចប្រែក្លាយទៅជាការផ្ទេរកម្មសិទ្ធិដោយមានការព្រមព្រៀងគ្នាបាន បន្ទាប់ពីបានទទួលបានការយល់ស្របពីម្ចាស់វត្ថុ ។ ការចែងនូវសញ្ញាណអស្សាមិករណ៍ នៅក្នុងវាក្យខណ្ឌចុងក្រោយនៃមាត្រា ៤៤ នេះ បញ្ជាក់អោយឃើញពីឆន្ទៈនៃនីតិករខ្មែរក្នុងការកំណត់អំពីសិទ្ធិកម្មសិទ្ធិថា ជា "សិទ្ធិផ្តាច់មុខ មិនអាចរំលោភបំពានបាន ត្រូវតែគោរព តែមិនមែនជាសិទ្ធិដាច់ខាត" ។ ការដកហូតអាចធ្វើទៅរួច បើមានមូលហេតុត្រឹមត្រូវបញ្ជាក់អំពី

Scanned with CamScanner

ប្រយោជន៍សាធារណៈ : "……ការដកហូតកម្មសិទ្ធិជនណាមួយអាចធ្វើទៅបាននោះ តែក្នុងករណីដើម្បីបម្រើប្រយោជន៍សាធារណៈ ដែលត្រូវបានអនុញ្ញាតដោយច្បាប់ប៉ុណ្ណោះ…." ។

អស្សាមិករណ៍ ត្រូវបានចាត់ទុកថា ជាបុព្វសិទ្ធិធម្មតារបស់រដ្ឋអំណាច ហើយដែលភាពជាធម្មានុរូបនៃនីតិវិធីនេះអាស្រ័យទៅលើមូលហេតុត្រឹមត្រូវ : "ប្រយោជន៍សាធារណៈ" ។ ការប្រើប្រាស់នីតិវិធីអស្សាមិករណ៍ពុំមានភាពងាយស្រួលនោះទេ ដោយហេតុថា នីតិវិធីនេះអាចធ្វើបាន បន្ទាប់ពីមានការប្រកាសអំពីប្រយោជន៍សាធារណៈនៃទ្រព្យដែលត្រូវរឹបអូស ។ ផលលំបាកស្ថិតនៅក្នុងនិយមន័យនៃប្រយោជន៍សាធារណៈនេះ ។ ផលប្រយោជន៍សាធារណៈ គ្រាន់តែជាលេសមួយតែប៉ុណ្ណោះ បើសិនវាមានលក្ខណៈតូចចង្អៀតពេក ឬមានលក្ខណៈមិនច្បាស់លាស់ មិនពិតប្រាកដ ឬបើសិនវាមានលក្ខណៈទូលាយពេក ។ នៅក្នុងគ្រប់ករណីជាក់ស្តែងទាំងអស់ ការអនុវត្តនីតិវិធីនេះ ផ្តល់នូវការងារស្មុគ្រស្មាញនៃការវាយតម្លៃនូវចិន្តន័យផ្សេងៗ ទៅតាមកាលទេសៈនិមួយៗនៃប្រតិបត្តិការ ។ ប្រយោជន៍សាធារណៈពុំត្រូវបានកំណត់ជានិយមន័យដោយអត្ថបទច្បាប់ណាមួយនោះទេ ។ អត្ថន័យនៃសញ្ញាណច្បាប់មួយនេះ តែងតែប្រែប្រួលជានិច្ចជាកាលទៅតាមការវិវត្តន៍របស់សង្គមមនុស្ស ។ ចំណុចសំខាន់ដែលត្រូវកត់ចំណាំនោះគឺ លក្ខខណ្ឌនៃការអនុវត្តនីតិវិធីនេះ អាចត្រូវបានកំណត់ក្នុងពេលអនុវត្តនីតិវិធីនេះតែម្តង ។ បរិបទនៃសញ្ញាណផលប្រយោជន៍សាធារណៈ អាចនឹងប្រែប្រួលទៅតាមបំលាស់ប្តូរនៃបេសកកម្មដែលត្រូវបានចាត់ទុកដូចជាឧបករណ៍របស់រដ្ឋ ។ ជាធម្មតា ផលប្រយោជន៍សាធារណៈតែងតែភ្ជាប់ជាមួយសកម្មភាពនៃការសាងសង់ការ្យសាធារណៈ ការសាងសង់ផ្នែកសាធារណៈការ ការបង្កើនទ្រព្យសម្បត្តិសាធារណៈ ជាដើម ។ ផលប្រយោជន៍សាធារណៈ សំដៅទៅលើផលប្រយោជន៍នៃមនុស្សភាគច្រើន ដោយលុបលើប្រយោជន៍ផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ ។ ប៉ុន្តែ ក្នុងករណីខ្លះ សញ្ញាណនៃផលប្រយោជន៍សាធារណៈ ផ្តល់ភាពពេញចិត្តចំពោះតម្រូវការរបស់ប្រភេទបុគ្គលមួយចំនួន ឬក្រុមបុគ្គលឯកជនមួយចំនួន ។ ស្ថានភាពទាំងនេះត្រូវបានបកស្រាយថាគ្រាន់តែជាផលវិបាកនៃនីតិវិធីអស្សាមិករណ៍ តែពុំមែនជាកម្មវត្ថុ ឬគោលបំណងនៃនីតិវិធីនោះទេ ។

ប្រយោជន៍សាធារណៈ គ្រាន់តែជាយុត្តិកម្មនៃការដកហូតសិទ្ធិកម្មសិទ្ធិឯកជន ។ ការប៉ះពាល់សិទ្ធិនេះ គឺធ្វើឡើងដោយស្របច្បាប់ តែត្រូវភ្ជាប់មកជាមួយនូវការធានាមួយដ៏សក្តិសម ។ ច្បាប់កំពូលបានធានាដល់កម្មសិទ្ធិករដែលរងគ្រោះ ដោយនីតិវិធីអស្សាមិករណ៍នេះ នូវសំណងមួយដែលសមរម្យ និងត្រឹមត្រូវ ។

ខ. "សំណងជាមុន ដោយសមរម្យ និងត្រឹមត្រូវ" : ការធានាចំពោះសិទ្ធិតម្លៃសិទ្ធិ

រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ បញ្ជាក់យ៉ាងច្បាស់ថា "……ការដកហូតកម្មសិទ្ធិអំពីជនណាមួយអាចធ្វើបាន….ដោយត្រូវផ្តល់សំណងជាមុន ដោយសមរម្យ និងយុត្តិធម៌" (វាក្យខណ្ឌទី ៣ នៃមាត្រា៤៤) ។ ច្បាប់ភូមិបាលចុះថ្ងៃទី ៣០-០៨-២០០១ បញ្ជាក់បន្ថែមអំពីកិច្ចធានាគតិយុត្តិដោយរដ្ឋធម្មនុញ្ញ ចំពោះសិទ្ធិកម្មសិទ្ធិឯកជនស្របច្បាប់ (មាត្រា ៥) ។ តាមពិត អស្សាមិករណ៍ត្រូវបានចាត់ទុកដូចជាការលក់ដោយបង្ខំ រវាងរដ្ឋបាលសាធារណៈ ជាមួយបុគ្គលឯកជនម្នាក់ ។ ដូចគ្នាទៅនឹងកិច្ចសន្យាលក់ធម្មតាដែរ អ្នកទិញមានកាតព្វកិច្ចបង់ប្រាក់ថ្លៃទំនិញ ឱ្យទៅអ្នកលក់ ។ ដូច្នេះ រដ្ឋបាលសាធារណៈត្រូវបានចាត់ទុកដូចជាអ្នកទិញធម្មតាដែរ ដែលមានកាតព្វកិច្ចបង់ប្រាក់ថ្លៃទ្រព្យដែលត្រូវរឹបអូស ឱ្យទៅម្ចាស់ទ្រព្យ ។ ច្បាប់កំពូលបានទាមទារអោយមានសំណង "ជាមុន ដោយសមរម្យ និងយុត្តិធម៌" ។ ការចាប់យកទ្រព្យមក

Scanned with CamScanner

កាន់កាប់ដោយបុគ្គលសាធារណៈ អាចធ្វើបាន លុះត្រាតែមានការផ្តល់ជាសំណងរួចរាល់ហើយ មានន័យថាត្រូវបង់ប្រាក់ជាមុននូវតម្លៃនៃវត្ថុ ឱ្យទៅម្ចាស់ទ្រព្យ។ លក្ខណៈ"ជាមុន"នៃសំណង គឺជាការធានាដ៏សំខាន់ ដើម្បីជំទាស់ប្រឆាំងទៅនឹងចេតនាទុច្ចរិត ឬឆន្ទៈវៀចវេររបស់បុគ្គលសាធារណៈ ។ ម្យ៉ាងទៀត សំណងត្រូវមានលក្ខណៈសមរម្យ និងយុត្តិធម៌ ។ បានសេចក្តីថា សំណងត្រូវមានតម្លៃស្មើទៅនឹងការខូចខាតទាំងស្រុងដែលបង្ករដោយអាជ្ញាធររដ្ឋបាល ។ បញ្ញត្តិ ឬសេចក្តីសម្រេចទាំងឡាយ ដែលបង្ខំអោយមានការផ្ទេរសិទ្ធិកម្មសិទ្ធិ ដោយឥតមានបង់ប្រាក់ ឬក្នុងតម្លៃមួយទាប ដែលមិនអាចទទួលយកបាន ត្រូវបានចាត់ទុកថា ផ្ទុយនឹងរដ្ឋធម្មនុញ្ញ ។ ប្រាក់ដែលត្រូវបង់ដោយអំណាចសាធារណៈ ត្រូវគ្របដណ្តប់ទៅលើតម្លៃវត្ថុ និងការខូចខាតទាំងឡាយដែលទទួលរង ។

ការខូចខាតដែលអាចបង្កអោយមានសំណង គឺត្រូវមានលក្ខណៈផ្ទាល់ និងពិតប្រាកដ ។ វាមានលក្ខណៈផ្ទាល់ ព្រោះវាកើតចេញមកពីការអនុវត្តនីតិវិធីអស្សាមិករណ៍នេះ ហើយមានទំនាក់ទំនងហេតុផលច្បាស់លាស់ ។ ឧទាហរណ៍ ដូចជាការខូចខាតបណ្តាលមកពីការបញ្ឈប់ជាបណ្តោះអាសន្ននូវសកម្មភាពប្រកបមុខរបរ ដែលមានទីតាំងនៅចំកន្លែងដែលត្រូវរឹបអូស ។ ការកំណត់អំពីលក្ខណៈផ្ទាល់នៃការខូចខាតនេះ គឺមានគោលបំណង ដើម្បីចៀសវាងនូវការជួសជុលការខូចខាតទាំងឡាយដែលមានប្រភពផ្សេងក្រៅពីការផ្ទេរកម្មសិទ្ធិនេះ ។ ដូច្នេះ ចំណុចសំខាន់ គឺស្ថិតនៅលើចំណងទាក់ទងហេតុ និងបច្ចុយ ។ ការខូចខាតមានលក្ខណៈពិតប្រាកដ លុះត្រាតែមានភាពពិត និងនាពេលបច្ចុប្បន្ន ។ ការខូចខាតជាយថាហេតុ ពុំត្រូវបានទទួលយកនោះទេ ។ ការផ្តល់ជាសំណង ធ្វើឡើងចំពោះតែការខូចខាតជាសម្ភារៈ ដែលមានភាពពិត និងនាពេលបច្ចុប្បន្នប៉ុណ្ណោះ មានន័យថា ការខូចខាតផ្លូវចិត្តពុំអាចទទួលស្គាល់នោះទេ ដោយហេតុថាពិបាកក្នុងការវាយតម្លៃ ។

ដូច្នេះ អស្សាមិករណ៍បង្កើតជាព្រំដែនកំណត់ស្របច្បាប់នៃសិទ្ធិកម្មសិទ្ធិ នៅពេលដែលមានការបញ្ជាក់អំពីប្រយោជន៍សាធារណៈនៃប្រតិបត្តិការនេះ និងត្រូវភ្ជាប់មកជាមួយនូវសំណងជាមុន ដោយសមរម្យ និងយុត្តិធម៌ ។ ក្នុងករណីពុំគោរពតាមលក្ខខណ្ឌណាមួយ ក្នុងចំណោមលក្ខខណ្ឌទាំងពីរខាងលើនេះ ទង្វើនេះនាំឱ្យមានការប៉ះពាល់ដោយខុសច្បាប់ទៅដល់សិទ្ធិកម្មសិទ្ធិឯកជន ។

សិទ្ធិកម្មសិទ្ធិ គឺជាសិទ្ធិត្រឹះ ។ នីតិនៃប្រទេសដទៃទៀត ជាអាទិ៍ នីតិបារាំង ឬអឺរ៉ុប បានអះអាងនូវលក្ខណៈជាត្រឹះនៃសិទ្ធិសិទ្ធិកម្មសិទ្ធិនេះ ដោយស្ថិតនៅបន្ទាត់តែមួយនឹងសេរីភាពរបស់មនុស្ស ។ វាគឺជាសិទ្ធិដែលមានភាពផ្តាច់មុខ ពុំអាចរំលោភបំពានបាន និងត្រូវតែគោរព ។ ប៉ុន្តែ សិទ្ធិនេះពុំមែនជាសិទ្ធិមានលក្ខណៈយ៉ាងដាច់ខាតនោះទេ។ អស្សាមិករណ៍ គឺជាឧទាហរណ៍មួយ ដែលបញ្ជាក់អំពីការដកហូតសិទ្ធិកម្មសិទ្ធិឯកជននេះ។ វាក៏អាចមានការប៉ះពាល់ដទៃផ្សេងទៀត ដូចជាករណី សេវភាពជាដើម ។ លើសពីនេះ នីតិនគរូបនីយវិទ្យា នៅក្នុងបទប្បញ្ញត្តិទាក់ទងទៅការសាងសង់ គឺជាសំណុំវិធានដែលអាចប៉ះពាល់តិច ឬច្រើនទៅលើសិទ្ធិកម្មសិទ្ធិនេះ ។ ប៉ុន្តែ ក្នុងគ្រប់ករណីទាំងអស់ ការប៉ះពាល់ត្រូវមានច្បាប់អនុញ្ញាតជាមុន និងឋិតនៅក្រោមការត្រួតពិនិត្យពីតុលាការ ដែលជាអ្នកការពារកម្មសិទ្ធិឯកជន ។ ការធានាជាអប្បបរមាដោយច្បាប់ ត្រូវផ្តល់ឱ្យទៅជនរងគ្រោះនៃការដកហូតសិទ្ធិកម្មសិទ្ធិនេះ ។ ការដកហូតដោយខុសច្បាប់ ត្រូវបានហាមឃាត់ និងមានការដាក់ទណ្ឌកម្មដោយច្បាប់ជាធរមាន ។

Scanned with CamScanner

ផ្នែកទី ២ : វិធីសាស្ត្រអត្ថាធិប្បាយសេចក្តីសម្រេចរបស់តុលាការ

វិធីសាស្ត្រអត្ថាអធិប្បាយសេចក្តីសម្រេចរបស់តុលាការនឹងត្រូវបានលើកឡើងមកបង្ហាញ "កថាខណ្ឌទី ១" បន្ទាប់មកក៏មានការលើកឡើងនូវលំហាត់អនុវត្តផងដែរ "កថាខណ្ឌទី ២" ។

កថាខណ្ឌទី ១ : ការបង្ហាញវិធីសាស្ត្រ : (បេអាទ្រីស បាលីវ៉ែ)

មានដំណាក់កាលជាច្រើនដែលយើងត្រូវការពេ ដើម្បីតាក់តែងសេចក្តីអត្ថាធិប្បាយសេចក្តីសម្រេចរបស់តុលាការ ។ វាជាការចាំបាច់ជាដំបូងដែលនិស្សិត ឬបេក្ខជន ត្រូវមានចំណេះដឹងដ៏ល្អអំពីវិធីសាស្ត្រនៃការធ្វើសលាកប័ត្រនៃសេចក្តីសម្រេចរបស់តុលាការ ។ បើពុំនោះសោត យើងត្រូវត្រលប់ទៅមើលភាគទី ១ នៃស្បៃវែកៅនេះ ស្តីពីវិធីសាស្ត្រធ្វើសលាកប័ត្រសេចក្តីសម្រេចរបស់តុលាការ ។

ក. ការយល់ប្រធានបទ

ក.១ យើងត្រូវអានសាលដីកាចំនួន ពីរ ទៅ បីដង ដើម្បីឱ្យបានយល់ច្បាស់ ។

ក.២ បន្ទាប់មក យើងត្រូវដកស្រង់ចេញយកនូវព័ត៌មានមួយចំនួន :

-**តុលាការ** : ធាតុនេះមានសារៈសំខាន់ខ្លាំងណាស់ ពីព្រោះថា សេចក្តីសម្រេចមួយដែលត្រូវបានចេញដោយតុលាការខេត្ត ឬក្រុង ណាមួយ ពុំមានខ្លឹមសារ ឬតម្លៃដូចគ្នា ទៅនឹងសាលដីកាដែលចេញដោយតុលាការកំពូលឡើយ ។

-**កាលបរិច្ឆេទ**នៃការចេញសេចក្តីសម្រេចរបស់តុលាការ ។ ចំណុចនេះមានសារៈសំខាន់នៅពេលដែលវិវាទច្បាប់ត្រូវបានចោទជាបញ្ហានៅក្នុងពេលវេលាណាមួយ ។ វាមានសារៈសំខាន់ដូចគ្នាដែរ ដើម្បីដាក់ប្រធានបទមួយនៃសេចក្តីសម្រេចដែលអាចជាកម្មវត្ថុនៃការវិវត្តន៍ទៅក្នុងស្ថានភាព ឬពេលវេលាណាមួយ ។

- **រចនាសម្ព័ន្ធរបស់សាលដីកា** : ចូរមើលភាគទី ១ ទាក់ទងនឹងការសិក្សាអំពីរចនាសម្ព័ន្ធសេចក្តីសម្រេចរបស់តុលាការ ។

ក.៣ បន្ទាប់មក យើងត្រូវកំណត់អត្តសញ្ញាណធាតុផ្សំនៃអង្គហេតុ នីតិវិធី សេចក្តីសម្រេចរបស់ចៅក្រមថ្នាក់ទី ១ សំអាងហេតុលើកឡើងដោយដើមបណ្តឹង ឬចុងបណ្តឹងឧទ្ធរណ៍ សេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ អំណះអំណាងរបស់ភាគី ដើមបណ្តឹងសាទុក្ខ និងសេចក្តីសម្រេចរបស់តុលាការកំពូល នៅក្នុងសេចក្តីសំរេចតុលាការដែលគេដាក់ជូននិស្សិត ឬបេក្ខជនប្រលង ។

ខ. ការស្រាវជ្រាវរកធាតុផ្សំនៃចម្លើយ

ជំរឿននូវរាល់ធាតុទាំងអស់សម្រាប់ចំម្លើយ មុននឹងរៀបចំធាតុទាំងនេះតាមរបៀបដែលធ្វើឱ្យលេចចេញជាប្លង់ ។

១. ជំរឿនឆ្វេងរាល់ធាតុផ្សំនៅក្នុងសេចក្តីសម្រេច

កាលណាធាតុផ្សំផ្សេងៗនៃសលាកប័ត្រសាលដីកាត្រូវបានកំណត់អត្តសញ្ញាណរួចហើយ និស្សិត ឬបេក្ខជនប្រឡង ត្រូវពិនិត្យចំណុចទាំងនេះឡើងវិញ ហើយធ្វើការសំយោគធាតុផ្សំទាំងនោះ ។ យើងត្រូវយល់ឱ្យបានជាក់ច្បាស់

Scanned with CamScanner

ផ្នែកអង្គហេតុ និងវិចារណកិច្ចដែលធ្វើឡើងដោយតុលាការទាំងសងខាង និងចៅក្រម ។ បន្ទាប់មកទៀត និស្សិត ឬបេក្ខជនប្រឡង អាចបង្កើតបញ្ហាគតិយុត្តមួយ ឬច្រើន ជាមួយនឹងភាពច្បាស់លាស់ ។

ដំណាក់កាលនៃការចោទបញ្ហាគតិយុត្តនេះ មានលក្ខណៈស្មុគស្មាញខ្លាំងណាស់ នៅក្នុងសេចក្តីសម្រេចរបស់តុលាការខ្មែរ ពីព្រោះថា ជាញឹកញាប់ វាជាការពិភាក្សាលើអង្គហេតុ តែមិនមែនលើអង្គច្បាប់នោះទេ ។ កត្តានេះធ្វើឱ្យការងាររបស់អ្នកអធិប្បាយជួបប្រទះនូវភាពកាន់តែស្មុគស្មាញថែមទៀត.។

២. ការវែងរកឆាតុផ្សឹនៅក្នុងបរិបទ

ក្រៅពីអក្សរដែលមាននៅក្នុងសេចក្តីសម្រេច យើងត្រូវវិភាគអត្ថន័យ លក្ខណៈ និងតម្លៃរបស់វា ។

២.១. អត្ថន័យនៃសេចក្តីសម្រេច

ជាញឹកញាប់ តុលាការកំពូលលើកឡើងអំពីអង្គហេតុ ទោះបីជាតុលាការនេះជំនុំជម្រះលើអង្គច្បាប់ក៏ដោយ ។ ការងារទាំងអស់របស់អ្នកអធិប្បាយ គឺត្រូវយល់អំពីវិចារណកិច្ចគតិយុត្តដែលអនុញ្ញាតឱ្យយើងអាចឈានទៅរកដំណោះស្រាយមួយចេញដោយតុលាការកំពូល ។ ត្រូវបង្កើតវិចារណកិច្ចគតិយុត្តសាជាថ្មីឡើងវិញ ហើយត្រូវពន្យល់វិចារណកិច្ចនោះ ។ ដូច្នេះ ចំណេះដឹងដ៏ល្អអំពីមេរៀន ត្រូវការចាំបាច់ណាស់ ។ យើងក៏ចាំបាច់ត្រូវធ្វើការថ្លឹងថ្លែងនីតិវិធីដែលមានលើបញ្ហានេះដែរ ។

២.២. តម្លៃនៃសេចក្តីសម្រេច

យើងត្រូវកំណត់ថាតើសេចក្តីសម្រេចនេះត្រូវបានទទួលការឯកភាព ឬការរិះគន់ ហើយថាតើយោងទៅលើមូលហេតុអ្វីខ្លះ ? និស្សិត ឬបេក្ខជនប្រឡង ត្រូវដាក់ខ្លួនឱ្យស្ថិតនៅក្នុងស្ថានភាពនៃការដោះស្រាយលំហាត់អនុវត្តមួយ ។ ដោយពុំត្រូវបណ្តោយឱ្យសេចក្តីសម្រេចនេះជះឥទ្ធិពលលើយើង និស្សិត ឬបេក្ខជនប្រលងត្រូវកំណត់នូវដំណោះស្រាយមួយដោយយោងតាមចំណេះដឹងគតិយុត្តដែលយើងទទួលបាន ។ ដូច្នេះ វានឹងមានភាពងាយស្រួលក្នុងការវាយតម្លៃអំពីដំណោះស្រាយដែលចេញដោយតុលាការ ។ ដូចជានៅក្នុងគ្រប់ការអត្ថាធិប្បាយអត្ថបទទាំងអស់ យើងពុំអាចគ្រាន់តែនិយាយថា ដំណោះស្រាយនេះត្រឹមត្រូវតាមច្បាប់ ឬក៏គ្មាននោះទេ យើងចាំបាច់ត្រូវតែបញ្ជាក់អំពីជំហររបស់អ្នក តាមរយៈ ការច្ងៃវិចារណកិច្ច ។

ម្យ៉ាងទៀត ដើម្បីប្រកាសនូវគោលជំហររបស់ខ្លួន និស្សិត ឬបេក្ខជនប្រឡងត្រូវតែប្រុងប្រយ័ត្នចំពោះ :

- ភាពជាច់ខាតនៃតក្កវិជ្ជា :

វិចារណកិច្ចរបស់ចៅក្រម ត្រូវតែមានលក្ខណៈតក្កវិជ្ជា ។ ចៅក្រមពុំត្រូវទាញវិចារណកិច្ចផ្ទុយគ្នា សេចក្តីសន្និដ្ឋានខុស ឬដោយចៃដន្យនោះទេ ។

- ភាពជាច់ខាតខាងផ្នែកគតិយុត្ត :

ដំណោះស្រាយត្រូវតែមានភាពស៊ីសង្វាក់គ្នា ជាមួយនឹងគោលការណ៍គតិយុត្តសំខាន់ៗ វិធានដែលមានប្រភពចេញពីច្បាប់ ឬយុត្តិសាស្ត្រ. . . ។

Scanned with CamScanner

តើដំណោះស្រាយនោះ ត្រឹមត្រូវ ហើយមានកាលនុវត្តភាពដែរ ឬទេ ?

- ភាពជាច់ខាតខាងផ្នែកសង្គកិច្ច :

តើដំណោះស្រាយអនុគ្រោះដល់សុវត្ថិភាពនៃការដោះដូរ ភាពឆាប់រហ័ស ភាពងាយស្រួលនៃការដោះដូរដែរ ឬទេ ? តើដំណោះស្រាយនេះ អនុគ្រោះដល់កូនបំណុល ម្ចាស់បំណុល ឬអ្នកប្រើប្រាស់ឬទេ ?

- ភាពជាច់ខាតខាងផ្នែកសង្គម :

តើដំណោះស្រាយនោះ ការពារដំពូកមនុស្សដែលមានកិរិតទាប ឬខ្ពស់នៅក្នុងសង្គមដែរឬទេ ?

- ភាពជាច់ខាងខាងផ្នែកសីលធម៌ :

តើដំណោះស្រាយនោះ ធានាការគោរពមនុស្សជាតិ សេចក្តីថ្លៃថ្នូររបស់មនុស្សដែរឬទេ ?

វាមានលក្ខណៈសំខាន់ខ្លាំងណាស់ដែលដំណោះស្រាយមួយត្រូវបានវិភាគ ដោយផ្អែកតាមភាពជាច់ខាតខាងផ្នែកគតិយុត្ត ។ ចំពោះភាពជាច់ខាតផ្សេងទៀត យើងអាចលើកឡើងតែក្នុងករណីចាំបាច់តែប៉ុណ្ណោះ ។

២.៣. ខ្លឹមសារនៃដំណោះស្រាយ

យើងត្រូវសាកល្បងវាស់វែងអំពីឥទ្ធិពលនៃសេចក្តីសម្រេចនេះ :

ប្រសិនបើជាសេចក្តីសម្រេចចាស់ ឬបុរាណយូរមកហើយ យើងត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់លើផលវិបាក និងតួនាទីដែលដំណោះស្រាយនេះមានពិតប្រាកដ ។ ប្រសិនបើសេចក្តីសម្រេចនេះទើបតែចេញនាពេលថ្មីៗទេនោះ យើងត្រូវសាកល្បងទស្សន៍ទាយអំពីផលវិបាកនៃសេចក្តីសម្រេចនោះ ។ ផលវិបាកទាំងនេះអាស្រ័យលើប្រភេទ អំណាច និងតម្លៃនៃសេចក្តីសម្រេចនោះ ។ សេចក្តីសម្រេចនវកាវ (ដែលមានការបញ្ចូលថ្មី) ជាទូទៅមានផលវិបាកច្រើនជាងសេចក្តីសម្រេចអនុវត្តន៍ ។ ប៉ុន្តែ សេចក្តីសម្រេចអនុវត្តន៍ អាចពន្លាតដែនអនុវត្តន៍បានផងដែរ ។

ចំពោះសេចក្តីសម្រេចជាគោលការណ៍ ឬជាការផ្លាស់ប្តូរថ្មី ខ្លឹមសារគឺជាចំណុចដ៏សំខាន់នៃការអត្ថាធិប្បាយ (តាមការអនុវត្តជាញឹកញាប់ តើដំណោះស្រាយនោះអាចពង្ហាតដល់ស្ថានភាពផ្សេងៗប្រហាក់ប្រហែលបានដែរឬទេ. តើដំណោះស្រាយនេះ ស្ថិតនៅជាធរមានជានិច្ចជាកាលដែរឬទេ ? តើអ្វីទៅជាអត្ថន័យនៃការវិវត្តន៍នៅពេលក្រោយមកទៀត ឬនៃការវិវត្តន៍ដែលអាចទស្សន៍ទាយទុកជាមុន ? តើដំណោះស្រាយនេះត្រូវបានបញ្ចូលក្នុងបទប្បញ្ញត្តិច្បាប់ដែរឬទេ ?) ប្រសិនបើសាលដីកាដែលត្រូវបានអធិប្បាយចេញពីតុលាការកំពូល សាលដីកាអាចកំណត់ជាយុត្តិសាស្ត្រ ឬជាការអនុវត្តគោលការណ៍ណាមួយ ។ ប្រសិនបើសាលដីកានោះចេញមកពីតុលាការជាន់ទាប យើងអាចចោទសួរអំពីវាសនានៃសាលដីកានេះ បន្ទាប់ពីចប់រឿងក្តី ។

៨. តាត់តែងបន្ថែម

បន្ទាត់ត្រូវបានតាក់តែងឡើង យោងទៅតាមវិចារណកិច្ចរបស់អ្នកផ្តល់ដំណោះស្រាយ ។

១. រៀបចំសេចក្តីអត្ថាធិប្បាយរបស់អ្នក តាមរបៀបតក្កវិជ្ជា

- គំនិតទាំងអស់របស់យើង ត្រូវតែប្រទាក់គ្នាទៅវិញទៅមក ។

Scanned with CamScanner

- យើងត្រូវកំណត់បញ្ហាទាំងឡាយដែលមានលក្ខណៈសំខាន់ជាងគេ យោងតាមចំណុចដែលយើងត្រូវវិភាគ ។ ប្រសិនបើមានសំណួរជាច្រើនមានសារៈសំខាន់ ចូរលើកឡើងអំពីចំណងតក្កវិជ្ជាដែលមានរវាងសំណួរទាំងនេះ ប្រសិនបើមាន ។
- បន្ទាប់មកទៀត ចំពោះសំណួរនីមួយៗ និស្សិត ឬបេក្ខជន ត្រូវតែលើកឡើងនូវនូវធាតុផ្សំខុសៗគ្នាក្នុងការពិភាក្សា, ត្រូវពិនិត្យឡើងវិញនូវរាល់ទិន្នន័យទាំងអស់ដែលចាំបាច់សម្រាប់យល់សំណួរ ហើយត្រូវបង្ហាញអំពីទិន្នន័យទាំងនោះ ។ ចូរកុំភ្លេចធ្វើឃ្លាភ្ជាប់ ដើម្បីផ្ទៀងផ្ទាត់អំពីភាពប្រទាក់គ្នានៃគំនិតរបស់យើង ។ គំនិតថ្មីនីមួយៗ ត្រូវធ្វើជាកម្មវត្ថុនៃការបកស្រាយក្នុងកថាខណ្ឌនីមួយៗ ដាច់ដោយឡែកពីគ្នា ។ យើងពុំត្រូវនិយាយជ្រុំដែរនោះទេ ។

២. ឧទ្ទេសនៃប្លង់របស់អ្នក

- សេចក្តីអត្ថាធិប្បាយ ត្រូវបានរៀបចំឱ្យមានរចនាសម្ព័ន្ធ ទៅតាមចំនួនផ្នែកដែលស្មើនឹងចំនួនគំនិត ។
- ចូរផ្តិតផ្តួងចំណងជើង ។ ការអានត្រឹមតែចំណងជើងត្រូវតែអនុញ្ញាតឱ្យយល់ថា តើអ្វីជាបញ្ហាដែលចោទឡើង និងរបៀបដោះស្រាយបញ្ហាទាំងនេះ ។
- ចូរកុំភ្លេចឃ្លាភ្ជាប់សេចក្តី នៅពេលដែលនិស្សិត ឬបេក្ខជនត្រូវឆ្លងចូលពីផ្នែកមួយទៅផ្នែកមួយទៀត និងពីអនុផ្នែកមួយទៅអនុផ្នែកមួយទៀត ព្រមទាំងឃ្លាផ្តើមសេចក្តីផងដែរ ។

ឃ. សរសេរសេចក្តីអត្ថាធិប្បាយសាលដីកា

១. សេចក្តីផ្តើម

សេចក្តីផ្តើមត្រូវធ្វើនៅចុងក្រោយគេបង្អង់ ។ សេចក្តីផ្តើមត្រូវតែមានទំហំស្មើនឹងមួយភាគបីនៃការងារ ។ កម្មវត្ថុនៃសេចក្តីផ្តើម គឺត្រូវបញ្ជាក់អំពីអត្ថប្រយោជន៍ចំពោះអ្នកអាន និងធ្វើឱ្យអ្នកអានទទួលយកប្លង់ដែលបានសម្រេចយក ។ សេចក្តីផ្តើមនេះត្រូវធ្វើឡើងដោយមានច្រើនដំណាក់កាល :

- ឃ្លាផ្តើម
- បរិបទគតិយុត្ត, សេដ្ឋកិច្ច...នៃសេចក្តីសម្រេច
- ការប្រកាសសេចក្តីសម្រេច (តុលាការ និងកាលបរិច្ឆេទ)
- សលាកប័ត្រនៃសាលដីកា "ដែលបានលើកឡើង" :(និស្សិត ឬបេក្ខជនប្រឡងត្រូវតែបញ្ជាក់ឱ្យច្បាស់ ហើយខ្លីលើអង្គហេតុ និងលើសេចក្តីអធិប្បាយដែលនឹងត្រូវពិនិត្យឡើងវិញនៅក្នុងការពិភាក្សា, ចូរផ្តិតផ្តួងលើការតែងសំណួរគតិយុត្ត) ។
- ការបង្ហាញអំពីដំណើរការដែលនឹងត្រូវបានប្រកាន់យក
- ការប្រកាសប្លង់

២. ការសរសេរ

- ត្រូវមានភាពហ្មត់ចត់ ។ និស្សិត ឬបេក្ខជនប្រលងត្រូវបង្ហាញឱ្យបានច្បាស់លាស់ និងជាក់លាក់ ហើយត្រូវប្រុងប្រយ័ត្នចំពោះវាក្យស័ព្ទរបស់អ្នក (ប្រើពាក្យច្បាប់) និងអក្ខាវិរុទ្ធ ព្រមទាំងវាក្យសម្ព័ន្ធ ។

Scanned with CamScanner

- ការតាក់តែងលើសំណៅដើម អាចចាប់ផ្តើមតែក្នុងករណីដែលយើងបានរៀបចំបួងដ៏ពិស្តារបំផុតនៅលើក្រដាសព្រាងរួចហើយប៉ុណ្ណោះ ។ ការគ្រប់គ្រងពេលវេលាបានល្អជាការចាំបាច់ : ចំពោះលំហាត់ក្នុងរយៈពេល ៣ ម៉ោង យើងត្រូវទុករយៈពេលយ៉ាងតិច ១ ម៉ោង ៣០ នាទី សំរាប់សរសេរលើសំណៅដើមចុងក្រោយ ។

- វាជាការចាំបាច់ក្នុងការផ្តល់យោបល់ចំពោះនិស្សិត ឬបេក្ខជនប្រឡង ដែលត្រូវតាក់តែងសេចក្តីផ្តើមលើក្រដាសព្រាង ព្រោះថា ពាក្យនីមួយៗត្រូវតែថ្លឹងថ្លែងឱ្យបានត្រឹមត្រូវ ។ បន្ទាប់មកទៀត យើងត្រូវចម្លងសាជាថ្មីឡើងវិញ ហើយសរសេរដោយផ្តាល់លើសំណៅដើមនូវអ្វីដែលសល់ពីសេចក្តីអត្ថាធិប្បាយរបស់យើង ។

- យើងត្រូវតាក់តែងនូវឃ្លាខ្លីៗ ដើម្បីទទួលបាននូវភាពច្បាស់លាស់ ។

ពុំត្រូវធ្វើសេចក្តីសន្និដ្ឋាននៅក្នុងការធ្វើអត្ថាធិប្បាយនោះទេ ។

ឥទាហរណ៍ទី ២ : លំហាត់អនុវត្តលើនីតិរដ្ឋប្បវេណី

ក. សេចក្តីថ្លែង

ចូរធ្វើអត្ថាធិប្បាយលើសាលដីការបស់តុលាការកំពូលចុះថ្ងៃទី ២៣-០៧-១៩៩៦

នាមនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី ២៣-០៧-១៩៩៦ (.....)

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុកពីសាដីកាលេខ ៤៩៨ ចុះថ្ងៃទី ២២-១១-១៩៩៥ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៤៧៤ ចុះថ្ងៃទី ០៥-១០-១៩៩៥ របស់សាលាឧទ្ធរណ៍ ។

រវាងមូាស់បណ្តឹងសាទុក្ខឈ្មោះ ម៉ៅ វណ្ណសាម អាយុ ២៤ ជាតិ ខ្មែរ របររកស៊ីលក់ដូរ ទីលំនៅផ្ទះលេខ ៧៩ អ៊ីសូឡ ផ្លូវ ១៩៩ សង្កាត់ទួលស្វាយព្រៃទី ២ ខណ្ឌចំការមន ក្រុងភ្នំពេញ ឪពុកឈ្មោះ ម៉ៅ គី "រ" ម្តាយឈ្មោះ ប៊ុក សួន "រ" ប្រពន្ធឈ្មោះ លី ងួនហួ ។

និងចុងបណ្តឹងសាទុក្ខឈ្មោះ លី ងួនហួ អាយុ ២១ ឆ្នាំ ជាតិខ្មែរ របររកស៊ី នៅផ្ទះ ទីលំនៅផ្ទះលេខ ១៦ អ៊ីសូឡ ក្រុមទី ៧ ផ្លូវ ២៨៨ សង្កាត់ទួលស្វាយព្រៃទី ១ ខណ្ឌ ចំការមន ក្រុងភ្នំពេញ ឪពុកឈ្មោះ លី ហួ "រ" ម្តាយឈ្មោះ រេង នេម "រ" ប្តីឈ្មោះ ម៉ៅ វណ្ណសាម ។

បានឃើញបណ្តឹងសាទុក្ខលេខ ០៣ ចុះថ្ងៃទី ០៥-០១-១៩៩៦ របស់ឈ្មោះ ម៉ៅ វណ្ណសាម ប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ ៤៩៨ ចុះថ្ងៃទី ២២-១១-១៩៩៥ របស់សាលាឧទ្ធរណ៍ លើសេចក្តីសម្រេចទាំងមូល ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៥១ ចុះថ្ងៃទី ២៨-០២-១៩៩៦ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ២៥-១២-១៩៩៤ របស់ដើមចោទឈ្មោះ លី ងួនហួ ប្តឹងសុំផ្តាច់សមគ្គសង្វាសពីប្តីឈ្មោះ ម៉ៅ វណ្ណសាម ដោយមូលហេតុថា អស់មនោសញ្ចេតនានឹងគ្នា ។

Scanned with CamScanner

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៦៧ "ក" ចុះថ្ងៃទី ០៨-០៥-១៩៩៥ របស់តុលាការក្រុងភ្នំពេញ សំរេចចំពោះមុខគូភាគី ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងចុះថ្ងៃទី ២៩-១២-១៩៩៤ របស់ដើមចោទឈ្មោះ លី ងួនហួ មានលក្ខណៈត្រឹមត្រូវតាមទំរង់ច្បាប់ និងគតិច្បាប់ ។

២-ឱ្យឈ្មោះ លី ងួនហួ និងឈ្មោះ ម៉ៅ វណ្ណសាម ដាច់សមគ្គសង្វាសពីគ្នា ចាប់តាំងពីថ្ងៃប្រកាសសាលក្រមនេះតទៅ តាមមាត្រា ៣៩ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ។

៣-ឱ្យឈ្មោះ លី ងួនហួ ស្ថិតនៅក្នុងភាពមេម៉ាយចំនួន ៣០០ ថ្ងៃ គិតពីថ្ងៃប្រកាសសាលក្រមនេះ ។

៤-ឱ្យឈ្មោះ លី ងួនហួ បង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី ពន្ធហ្វឹង ១.៨០០ រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០ រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ៣.០០០ រៀល រង្វាន់សាក្សី ២.០០០ រៀល បូករួម ៧.០០០ រៀល ប្រាក់នេះត្រូវកាត់យកពីប្រាក់ ៧.០០០ រៀល ដែលដើមចោទ បានបង់រួចជាស្រេច ។ កាលបើហួសបណ្តឹងឧទ្ធរណ៍ បង្គាប់ឱ្យឈ្មោះ ម៉ៅ វណ្ណសាម បង់ប្រាក់ ៧.០០០ រៀល មកឈ្មោះ លី ងួនហួ វិញ ។

៥-សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខគូភាគី ហើយសំរេចបើកផ្លូវឧទ្ធរណ៍ រយៈពេល ២ ខែ គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍ លេខ ៧៥ ចុះថ្ងៃទី ១៧-០៧-១៩៩៥ របស់ឈ្មោះ ម៉ៅ វណ្ណសាម ប្តឹងមិនសុខចិត្តនឹងសាលក្រមលេខ ៦៧ "ក" ចុះថ្ងៃទី ០៨-០៥-១៩៩៥ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៤៩៨ ចុះថ្ងៃទី ២២-១១-១៩៩៥ របស់សាលាឧទ្ធរណ៍ សំរេចចំពោះមុខគូក្តី ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៧-០៧-១៩៩៥ របស់ឈ្មោះ ម៉ៅ វណ្ណសាម ទុកជាត្រឹមត្រូវតាមច្បាប់តែលើកចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ៦៧ "ក" ចុះថ្ងៃទី ០៨-០៥-១៩៩៥ របស់តុលាការក្រុងភ្នំពេញទុកជាបានការតទៅ ។

៣- រីបអូសប្រាក់ប្រដាប់ក្តីចំនួន ១៣.០០០ រៀល ដែលឈ្មោះ ម៉ៅ វណ្ណសាម បានបង់រួចហើយ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្វឹង ២.៥៥០ រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០ រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០ រៀល និងចំណាយលើអាជ្ញាធរតុលាការ ៥.០០០ រៀល សរុប ១៣.០០០ រៀល ។

៤-សាលដីកានេះជំនុំជំរះជាសម្ងាត់ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ០៣ ចុះថ្ងៃទី ០៥-០១-១៩៩៦ របស់ឈ្មោះ ម៉ៅ វណ្ណសាម ប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ ៤៩៨ ចុះថ្ងៃទី ២២-១១-១៩៩៥ របស់សាលាឧទ្ធរណ៍ លើសេចក្តីសម្រេចទាំងមូល ធ្វើឡើងក្នុងកំណត់ច្បាប់ ។

Scanned with CamScanner

បានឃើញសារណាចុះថ្ងៃទី ២៦-០៤-១៩៩៦ របស់ឈ្មោះ ម៉ៅ វណ្ណសាម

បានឃើញសារណាតប ចុះថ្ងៃទី ០៨-០៥-១៩៩៦ របស់ឈ្មោះ លី ងួនហួ

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេក្តីសន្និដ្ឋានរបស់តំណាងអយ្យការ :

សាលដីការបស់សាលាឧទ្ធរណ៍ ដែលសំរេចសេចក្តីមកនេះ គឺមានលក្ខណៈត្រឹមត្រូវតាមគតិច្បាប់ហើយ

ហេតុដូច្នេះ សូមក្រុមប្រឹក្សាជំនុំជំរះ សំរេចតាមច្បាប់តទៅ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ម៉ៅ វណ្ណសាម ជាចុងចម្លើយ និងជាដើមបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថា : ខ្លួនមិនសុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍ ព្រោះថា ខ្លួនបានរៀបការជាមួយនឹងនាង លី ងួនហួ ពេញច្បាប់ តែក្រោយរៀបការហើយ នាងមិនព្រមរួមរស់ជាមួយខ្លួនទេ ដោយចោទខ្លួនថា អពលានុភាពនៃលិង្គ ដោយឱ្យបងប្រុសរបស់ខ្លួនជាអ្នកពិនិត្យប្រដាប់បន្តពូជរបស់ខ្លួន ដោយយកបងប្រុសរបស់ខ្លួនធ្វើជាសាក្សី តែតាមការពិតប្រដាប់បន្តពូជរបស់ខ្លួននៅល្អទេ ដោយមានលិខិតបញ្ជាក់ពីវេជ្ជបណ្ឌិតត្រឹមត្រូវ តែពេលសវនាការនៅក្រុង និងសាលា-ឧទ្ធរណ៍ ខ្លួនមិនបានដាក់លិខិតបញ្ជាក់នោះទេ ។ ពេលភ្ជាប់ពាក្យ ខ្លួនបានជូន ២.០០៤ ដុល្លារអាមេរិក និងចិញ្ចៀនត្រា ៣ ជី និងលុយខ្មែរ ១០០.៤០០ រៀល ។ នៅថ្ងៃរៀបអាពាហ៍ពិពាហ៍ ខ្លួនបានជូនជាជំនូនចំនួន ២.០០៤ ដុល្លារអាមេរិក ខ្សែករពេជ្រមួយខ្សែ ចិញ្ចៀនពេជ្រមួយវង់ និងខ្សែដៃមាសពីរតម្លឹង និងប្រាក់កាក់ ១២ រៀល ស្មើនឹង ១០០ ដុល្លារអាមេរិក។ ដោយនាង លី ងួនហួរ សុំលែងខ្លួន ខ្លួនក៏សុខចិត្តដែរ តែខ្លួនសុំទាមទារយកបណ្តាការទាំងនោះវិញ និងប្រាក់ចំនួន ៤.២០០ ដុល្លាអាមេរិក ដែលឪពុកក្មេកខ្លួនខ្ចី ។

បានស្តាប់ចម្លើយរបស់ឈ្មោះ លី ងួនហួ ជាដើមចោទ និងចុងបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះបានឆ្លើយថា : ខ្លួនគ្មានអ្វីបញ្ជាក់ខ្សែតទេ ព្រោះខ្លួនបានធ្វើសារណារួចជាស្រេច ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ០៣ ចុះថ្ងៃទី ០៥-០១-១៩៩៦ របស់ឈ្មោះ ម៉ៅ វណ្ណសាម ប្តឹងពីសាលដីកាលេខ ៤៩៨ ចុះថ្ងៃទី ២២-១១-១៩៩៥ របស់សាលាឧទ្ធរណ៍ លើសេចក្តីសម្រេចទាំងមូល ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពសាលាជំរះក្តី ។

-យល់ឃើញថា រឿងក្តីនេះប៉ះពាល់ដល់ប្រពៃណីល្អ របស់សង្គមជាតិ តុលាការកំពូល គប្បីជំនុំជំរះជាសម្ងាត់តាមមាត្រា ១២៩ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

Scanned with CamScanner

-យល់ឃើញថា ចុងចម្លើយឈ្មោះ ម៉ៅ វណ្ណសាម ពិតជាបានព្រមព្រៀងលែងលះ នាង លី ងួនហួ ជាប្រពន្ធប្រាកដមែន ។

-យល់ឃើញថា គ្រឿងអលង្កាមាន ខ្សែករពេជ្រមួយខ្សែ ចិញ្ចៀនពេជ្រមួយវង់ សរុបជាតម្លៃ ៥.៤៨០ ដុល្លារអាមេរិក ចិញ្ចៀនត្រា ៣ ជី មាស និងខ្សែកមាសពីរតម្លឹង ដែលចុងចម្លើយបានជូនទៅដើមចោទ ឈ្មោះ លី ងួហួ ក្នុងពីធីភ្ជាប់ពាក្យ និងក្នុងពីធីលើកជំនូន ថ្ងៃរៀបអាពាហ៍ពិពាហ៍នោះ ចុងចម្លើយពុំមានសិទ្ធិទាមទារយកវិញបានឡើយ ព្រោះចុងចម្លើយបានធ្វើអំណោយដល់ដើមចោទរួចហើយ ។

-យល់ឃើញថា ប្រាក់ចំនួន ៤.២០០ ដុល្លារអាមេរិក ដែលចុងចម្លើយបានអះអាងថា បានឱ្យឈ្មោះ លី ហួត ជាឪពុកក្មេកខ្លីនេះ ជារឿងអង្គសេចក្តីមួយផ្សេងទៀត ។

-យល់ឃើញថា ការលើកឡើងរបស់ឈ្មោះ ម៉ៅ វណ្ណសាម ក្នុងសារណា ចុះថ្ងៃទី ២៦-០៤-១៩៩៦ សុទ្ធតែជារឿងនៃអង្គហេតុ ដែលតុលាការថ្នាក់ក្រោមបានពិចារណារួចហើយ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៤៩៨ ចុះថ្ងៃទី ២២-១១-១៩៩៥ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈទាំងទំរង់ និងគតិច្បាប់ហើយ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តី ចំពោះមុខគូក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ ០៣ ចុះថ្ងៃទី ០៥-០១-១៩៩៦ របស់ឈ្មោះ ម៉ៅ វណ្ណសាម ទុកជាត្រឹមត្រូវតាមច្បាប់ ប៉ុន្តែបដិសេធដោយខុសនីតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ ៤៩៨ ចុះថ្ងៃទី ២២-១១-១៩៩៥ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីជាន់តុលាការកំពូល ចំនួន ១៥.០០០ រៀល ដែលឈ្មោះ លី ងួនហួ បានបង់ជូនទុកជាមុនគឺ :

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្លឹង ចំនួន ៤.០០០ រៀល ប៉ុន្តែ ប្រាក់នេះ ត្រូវកាត់ចំនួន ៨០០ រៀល សំរាប់ជាអ្នកនាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០ រៀល សរុប ១៥.០០០ រៀល ហើយតម្រូវឱ្យឈ្មោះ ម៉ៅ វណ្ណសាម សងប្រាក់ចំនួន ១៥.០០០ រៀល ទៅនាង លី ងួនហួវិញ ។

៤-សាលដីកានេះជំនុំជំរះជាសម្ងាត់ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ២៣-០៧-១៩៩៦ ។

ខ. តំណែ : (ឆ្លុន ជារ៉ាវុធ និង បេអាទ្រីស ចាលីវ៉ែ)

ដូចលោក កូឡូប៊ែរ បានសរសេរថា "ភ្នានស្នាដៃណាមួយរបស់មនុស្ស ទទួលបាននូវភាពឥតខ្ចោះនោះទេ" ។ វាជាការណីរបស់នីតិកម្មខ្មែរ ដែលទាក់ទងនឹងការរំលាយចោលចំណងមាតិកភណ្ឌ ។ ការលែងលះ គឺជាបញ្ហាមួយដ៏ស្មុគ្រស្មាញ ហើយវានឹងបង្កនូវផលលំបាកថែមទៀត ប្រសិនបើយើងចង់រកដំណោះស្រាយខាងផ្នែកហិរញ្ញវត្ថុ ដោយមូលហេតុជាអាទិ៍

Scanned with CamScanner

កង្វះខាត ឬភាពខ្វះចន្លោះរបស់ច្បាប់ ។ ការលែងលះ ក្លាយជាកម្មវត្ថុនៃវិវាទ ដែលមានការកើនឡើងជាខ្លាំងនៅចំពោះមុខតុលាការកំពូល ។

សាលដីកាដែលចេញដោយតុលាការកំពូល ចុះថ្ងៃទី ២៣-០៧-១៩៩៦ អនុញ្ញាតឱ្យយើងស្គាល់អំពីករណីខាងលើនេះ។ នៅក្នុងអង្គហេតុ អ្នកស្រី "ខ" បានប្តឹងពីការលែងលះនៅចំពោះមុខតុលាការក្រុងភ្នំពេញ ដោយហេតុថា អ្នកស្រីអស់មនោសញ្ចេតនាជាមួយប្តីរបស់អ្នកស្រី ។ ប៉ុន្តែ ប្តីអ្នកស្រី បដិសេធអំពីការលែងលះ ។ តុលាការក្រុងភ្នំពេញ នៅក្នុងសាលក្រមចុះថ្ងៃទី ០៨-០៥-១៩៩៥ បានប្រកាសការលែងលះ ដោយទទួលយកពាក្យបណ្តឹងរបស់អ្នកស្រី ដោយយោងតាមមាត្រា ៣៩ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ។ លោក "ក" បានប្តឹងឧទ្ធរណ៍ ។ សាលាឧទ្ធរណ៍ បានចេញសាលដីកាចុះថ្ងៃទី ២២-១១-១៩៩៥ បន្ទាប់ពីការបើកការជំនុំជំរះជាសម្ងាត់ ដោយតម្កល់សាលក្រមរបស់តុលាការក្រុងភ្នំពេញ ទុកជាបានការពេញទាំងមូល ។ លោក "ក" ប្តឹងសាទុក្ខទៅតុលាការកំពូល ។ គាត់លើកឡើងថា បន្ទាប់ពីរៀបអាពាហ៍ពិពាហ៍ ប្រពន្ធរបស់គាត់ពុំយល់ព្រមរួមដំណេកជាមួយគាត់នោះទេ ដោយហេតុថា លោក "ក" អពលានុភាពនៃលឹង្គ ។ តាមការពិត គាត់ពុំមានជម្ងឺបែបនេះទេ យោងតាមលិខិតបញ្ជាក់ពីវេជ្ជបណ្ឌិត ។ ម៉្យាងវិញទៀត ប្រសិនបើប្រពន្ធរបស់គាត់មានបំណងចង់លែងលះ គាត់ក៏យល់ព្រមដែរ តែគាត់សុំទាមទារយកអំណោយ ដែលគាត់បានប្រគល់ឱ្យនៅពេលភ្ជាប់ពាក្យ និងការរៀបអាពាហ៍ពិពាហ៍ ។

នៅក្នុងរឿងវិវាទនេះ ក្រៅពីការភ្ញាក់ផ្អើលអំពីការបើកសវនាការជាសម្ងាត់ មានបញ្ហាគតិយុត្តពីរត្រូវបានចោទឡើង ។ ម៉្យាង ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ទទួលស្គាល់តែការលែងលះដែលប្តឹងដោយភាគីណាម្នាក់ យោងតាមមូលហេតុណាមួយជាក់លាក់ (មាត្រា ៣៩) ឯការលែងលះដោយព្រមព្រៀងគ្នា (មាត្រា ៤០) ។ ដូច្នេះ តើមានមូលដ្ឋានគតិយុត្តអ្វីខ្លះ ក្នុងករណីដែលការលែងលះខាងលើនេះ ត្រូវបានធ្វើឡើងដោយមានការព្រមព្រៀងពីភាគីចុងចោទ នាពេលដំណើរការនីតិវិធីនៃការលែងលះ ដែលប្តឹងដោយសហព័ទ្ធរបស់គាត់ ? ម៉្យាងវិញទៀត ប្រសិនបើអាពាហ៍ពិពាហ៍មានភាពប្រេះស្រាំ តើសហព័ទ្ធប្រពន្ធត្រូវសងអំណោយដែលទទួលបានក្នុងពេលភ្ជាប់ពាក្យ និងរៀបអាពាហ៍ពិពាហ៍ត្រលប់ឱ្យទៅប្តីវិញដែរ ឬទេ ?

តុលាការកំពូល បានឆ្លើយតបសំណួរទាំងពីរនោះនៅក្នុងសាលដីកាចុះថ្ងៃទី ២៣-០៧-១៩៩៦ បន្ទាប់ពីមានការជំនុំជំរះជាសម្ងាត់ ។ តុលាការកំពូលបដិសេធបណ្តឹងសាទុក្ខរបស់លោក "ក" ដោយហេតុថា ចុងបណ្តឹង និងដើមបណ្តឹងសាទុក្ខ យល់ព្រមលែងលះ ។ ម៉្យាងវិញទៀត គ្រឿងអលង្កា និងប្រាក់ ដែលមានតម្លៃ ៥.៤៨០ ដុល្លារអាមេរិក ពុំអាចត្រូវបានទាមទារដោយលោក "ក" នោះទេ ពីព្រោះវាគឺជាអំណោយ ។ ដើម្បីយល់កាន់តែច្បាស់អំពីដំណោះស្រាយរបស់តុលាការកំពូល យើងត្រូវស្គាល់ជាដំបូងអំពីបញ្ហានៃការលែងលះ (I) ដើម្បីឱ្យដឹងថា តើតុលាការកំពូលសំរេច ដោយមានមូលដ្ឋានគតិយុត្តអ្វីខ្លះ ? យើងក៏ត្រូវស្គាល់អំពីដំណោះស្រាយចំពោះអានុភាពខាងផ្នែកហិរញ្ញវត្ថុ មានន័យថា តើមានការសងត្រលប់មកវិញនូវអំណោយនៅពេលពីធីភ្ជាប់ពាក្យ និងរៀបអាពាហ៍ពិពាហ៍ដែរឬទេ (II)?

Scanned with CamScanner

I. **ការលែងលះ :**

នៅក្នុងសំណុំរឿងនេះ មានចំណុចពីរយ៉ាងដែលទាក់ទងនឹងការលែងលះនេះ គឺ ភាពស្មុគ្រស្មាញនៃនីតិវិធី និងមូលហេតុដែលនាំឱ្យមានការលែងលះ ។ ដើម្បីឱ្យច្បាស់ជាងនេះ គឺ យើងចង់ដឹងថា តើមានមូលហេតុអ្វីដែលអង្គសវនាការត្រូវបានធ្វើឡើងដោយសម្ងាត់ (ក) និងតើករណីណាខ្លះដែលការលែងលះក្នុងនីតិកម្មជាអាចទទួលយកបាន (ខ) ?

ក. សវនាការជាសម្ងាត់ :

គោលការណ៍នៃការបើកអង្គសវនាការរបស់តុលាការ គឺជាគោលការណ៍គ្រឹះនៃនីតិកម្មជា ។ គោលការណ៍នេះត្រូវបានចែងក្នុងមាត្រា ១២៨ នៃច្បាប់ឆ្នាំ ១៩៩៣ ស្តីពីនីតិវិធីព្រហ្មទណ្ឌ[១១៧] ហើយការមិនគោរពនីតិវិធីនេះ នាំឱ្យមានការប្រកាសមោឃភាពនីតិវិធី ។ ប៉ុន្តែ មាត្រា ១២៩ នៃច្បាប់ដដែលនេះក៏បានចែងករណីលើកលែងមួយចំនួនផងដែរ ។ សវនាការអាចធ្វើឡើងជាសម្ងាត់ ប្រសិនបើការជំនុំជំរះអាចប៉ះពាល់នឹងសណ្តាប់ធ្នាប់សាធារណៈ សីលធម៌ និងប្រពៃណីល្អរបស់សង្គម ។ ការវាយតម្លៃអំពីសញ្ញាណនេះ គឺជាសិទ្ធិអំណាចរបស់ចៅក្រម ។ សាលដីការបស់តុលាការកំពូលចុះថ្ងៃទី ២៣-០៧-១៩៩៦ គឺជាឧទាហរណ៍មួយនៃការអនុវត្តមាត្រា ១២៩ នៃច្បាប់ខាងលើ ។ តុលាការកំពូលបានសំរេចបើកសវនាការជាសម្ងាត់ ដោយហេតុថា សំណុំរឿងនេះ ប៉ះពាល់ដល់សីលធម៌ល្អរបស់សង្គមជាតិ ។ ប៉ុន្តែ តុលាការកំពូលពុំបានបញ្ជាក់បំភ្លឺអំពីមូលហេតុ ដែលប៉ះពាល់ដល់សីលធម៌របស់សង្គមជាតិនោះទេ ។ យើងអាចដឹងយ៉ាងច្បាស់តាមរយៈភាពខ្វាសអៀន ដែលជាចរិតលក្ខណៈរបស់សង្គមជាតិខ្មែរ ជាពិសេសលើភាពទាក់ទាញនៅក្នុងរឿងគ្រួសារ ។ បើទោះបីជាវិវាទគ្រួសារ គឺជាវិវាទទី ២ យោងតាមអាជ្ញាធរដែនដីក៏ដោយ ការលែងលះត្រូវបានដាក់ទណ្ឌកម្មក្នុងប្រពៃណីរបស់ខ្មែរ ។ ដោយយោងតាមមូលហេតុនេះ ជាញឹកញាប់ សហព័ទ្ធលែងលះ ដោយគ្មានបំពេញទំរង់តាមច្បាប់នោះទេ ដើម្បីចៀសវាងការប្រកាសផ្សាយអំពីការលែងលះរបស់ពួកគេ ។ ប្រជាពលរដ្ឋខ្មែរសុខចិត្តដោះស្រាយវិវាទគ្រួសារដោយខ្លួនឯង ។ ពួកគាត់ជ្រើសរើសយកនីតិវិធីតាមច្បាប់ តែក្នុងករណីដែលពួកគាត់មានបំណងចង់រៀបអាពាហ៍ពិពាហ៍ជាថ្មីម្តងទៀតប៉ុណ្ណោះ ។ សំណើចុងក្រោយនេះអាចទទួលយកបាន ដោយហេតុថា សីលធម៌មានការវិវត្ត ជាពិសេសចំពោះប្រជាពលរដ្ឋដែលរស់នៅក្នុងទីក្រុងភ្នំពេញ ។ នារីប្តឹងលែងលះកាន់តែច្រើន ដោយយោងទៅលើមូលហេតុផ្សេងៗគ្នា ។ ជាញឹកញាប់ យើងតែងតែឃើញមានមូលហេតុដូចជា : ភាពក្រីក្រ អសីលធម៌របស់សហព័ទ្ធប្តី ដូចជា ការស្រវឹងស្រាការលេងល្បែង ការប្រើអំពើហិង្សា ដែលនាំឱ្យនារីប្តឹងទៅតុលាការ ។ នៅក្នុងអង្គហេតុ វាប្រហែលថា មូលហេតុដែលលើកឡើងដោយសហព័ទ្ធប្រពន្ធ ចេញមកពីអពលានុភាពនៃលិង្គរបស់ប្តីគាត់ ដែលនាំឱ្យការបើកសវនាការធ្វើឡើងដោយសម្ងាត់ ។ ចំណោទបញ្ហានេះប៉ះពាល់ទូវភាពខ្វាសអៀនរបស់សហព័ទ្ធប្តី ។

ខ. ការលែងលះ

ច្បាប់ឆ្នាំ ១៩៨៩ ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ទទួលស្គាល់ការលែងលះ តែក្នុងករណីមានការប្តឹងពីសហព័ទ្ធណាម្នាក់ ដោយយោងទៅលើមូលហេតុជាកំណត់នៅក្នុងមាត្រា ៣៩ និងការលែងលះតាមការព្រមព្រៀងគ្នា (មាត្រា

[១១៧] យើងអនុវត្តផងដែរច្បាប់នេះ នៅក្នុងរឿងរដ្ឋប្បវេណី នៅក្នុងករណីដែលយើងពុំទាន់មានច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណី ។

Scanned with CamScanner

៤០) ។ នីតិកម្មជាពុំបានទទួលស្គាល់ ជាអាទិភាព តាមមធ្យោបាយនៃការប្តឹងលែងលះដែលត្រូវបានធ្វើឡើងដោយមានការព្រមព្រៀងគ្នានោះទេ មានន័យថា នៅក្នុងករណីដែលការប្តឹងនៃការលែងលះត្រូវបានធ្វើឡើងដោយសហព័ទ្ធម្នាក់បន្ទាប់មក សហព័ទ្ធម្ខាងទៀតក៏បានយល់ព្រមផងដែរ ។ ករណីនេះ កាន់តែមានភាពលំបាកនៅក្នុងអង្គហេតុខាងលើនេះ ដោយហេតុថា សហព័ទ្ធប្តីពុំបានឯកភាពលែងលះ នៅដំណាក់កាលនៃនីតិវិធីនៅចំពោះមុខតុលាការក្រុងភ្នំពេញ និងសាលាឧទ្ធរណ៍នោះទេ តែយល់ព្រមលែងលះនៅចំពោះមុខតុលាការកំពូល ។ ដូច្នេះ តើវាជាការលែងលះដែលប្តឹងដោយសហព័ទ្ធម្នាក់ ឬការលែងលះតាមការព្រមព្រៀងគ្នា ? តុលាការកំពូលពុំបានឆ្លើយទៅនឹងសំណួរនេះឱ្យបានច្បាស់នោះទេ ។ តុលាការកំពូលយោងតែទៅលើការយល់ព្រមរបស់សហព័ទ្ធប្តីលើបញ្ហានៃការលែងលះប៉ុណ្ណោះ ហើយតុលាការកំពូលពុំបានបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ ដែលតម្កល់ទុកសាលក្រមរបស់តុលាការក្រុងភ្នំពេញដែលតុលាការទាំងពីរនេះជំនុំជំរះយោងទៅលើមាត្រា ៣៩ នៃច្បាប់ខាងលើនោះទេ ។ តុលាការកំពូលពុំបានលើកឡើងទាំងមាត្រា ៣៩ និងមាត្រា ៤០ នៃច្បាប់ខាងលើ ។ តុលាការកំពូលលើកឡើងអំណះអំណាងរបស់ខ្លួន យោងតែទៅលើការឯកភាពរបស់ភាគីសហព័ទ្ធប្តីប៉ុណ្ណោះ ។ ប៉ុន្តែ ការឯកភាពរបស់សហព័ទ្ធប្តី ពុំមែនជាលក្ខខណ្ឌនៃការលែងលះដែលមានចែងក្នុងមាត្រា ៣៩ នៃច្បាប់ខាងលើនោះទេ ។ ម៉្យាងវិញទៀត ការលែងលះតាមការព្រមព្រៀងគ្នា ត្រូវការជាចាំបាច់នូវការព្រមព្រៀងរបស់សហព័ទ្ធទាំងពីរ តាំងពេលដាក់ពាក្យបណ្តឹងទៅតុលាការ មានន័យថា គឺជាបណ្តឹងរួមគ្នា ។ ដូច្នេះ ការឯកភាពរបស់សហព័ទ្ធប្តីដែលស្តែងឡើងជាលើកទី ១ នៅចំពោះមុខតុលាការកំពូល ហើយដែលត្រូវកំណត់ចំណាំដោយតុលាការកំពូល ពុំអនុញ្ញាតឱ្យមានការលែងលះគ្នាយោងទៅលើមាត្រា ៣៩ ឬ ៤០ នៃច្បាប់អាពាហ៍ពាហ៍ និងគ្រួសារបាននោះទេ ។ ករណីនេះ អាចត្រូវបានបកស្រាយថា ការនៅស្ងប់ស្ងៀមរបស់តុលាការកំពូលលើមូលដ្ឋានគតិយុត្ត នាំឱ្យតុលាការកំពូល មានអំណះអំណាងចំពោះសេចក្តីសម្រេចរបស់ខ្លួនអំពីការលែងលះនេះ ។ ដំណោះស្រាយនេះ មានលក្ខណៈយ៉ាងពិតប្រាកដជាសេចក្តីសម្រេចកាលនុវត្ត ។ តាមការពិត តុលាការកំពូល បានសំរេចស្របពេលជាមួយគ្នាទាំងស្ថានភាពគតិយុត្តរបស់សហព័ទ្ធ និងស្ថានភាពអង្គហេតុ ។ ដូច្នេះ តុលាការកំពូលប្រកាសអំពីការផ្តាច់សមគ្គីសង្វាសរបស់សហព័ទ្ធទាំងពីរ ។ ប៉ុន្តែ សេចក្តីសម្រេចនេះពុំសូវមានភាពភ្ញាក់ផ្អើលនោះទេ តាមទស្សនៈគតិយុត្ត ដោយហេតុថា សេចក្តីសម្រេចនេះ នាំឱ្យមានការបង្កើតនូវប្រភេទថ្មីមួយនៃការលែងលះដោយតុលាការកំពូល ដែលពុំមានចែងក្នុងច្បាប់ : ការលែងលះស្តីពីបណ្តឹងដែលឯកភាពដោយសហព័ទ្ធទាំងពីរ ។ តាមពិត ចៅក្រមប្រកាសអំពីការលែងលះ ទៅលើពាក្យបណ្តឹងជាឯកតោភាគីរបស់សហព័ទ្ធម្ខាង គាត់បានបង្ហាញអំពីការឯកភាពពីសហព័ទ្ធម្ខាងទៀត ដោយគ្មានយោងទៅលើមាត្រា ៣៩ និង៤០ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារនោះទេ ។

ការលែងលះត្រូវបានប្រកាស តែយើងត្រូវពិនិត្យអំពីអានុភាពរបស់វា ។

II. អានុភាពនៃការលែងលះ : តើសេចក្តីអំណាយត្រូលបំបែកគ្នាឬ ?

បញ្ហានេះ ជាបញ្ហាចំបងនៅក្នុងសង្គមខ្មែរ ។ យើងត្រូវកំណត់អំពីប្រភេទគតិយុត្តនៃបណ្តាការដែលធ្វើឡើងមុន និងពេលរៀបអាពាហ៍ពិពាហ៍ (ក) និងរបបគតិយុត្តរបស់វា (ខ) ។

Scanned with CamScanner

ក. ប្រតេឆគតិយុត្តនៃបណ្ណាការ :

សំណួរនេះត្រូវបានចោទឡើងជាញឹកញាប់ តាមការអនុវត្តជាក់ស្តែង ។ មុនពេលរៀបអាពាហ៍ពិពាហ៍ គ្រួសារខាងប្រុស ប្រគល់នូវគ្រឿងអលង្កា និងប្រាក់កាស ឱ្យទៅគ្រួសារខាងនារី ដែលជាអនាគតសហព័ន្ធប្រពន្ធ ។ ប្រាក់ទាំងនេះ ឆ្លើយតបទៅនឹងរាល់ការចំណាយដែលត្រូវបានធ្វើឡើងដោយឪពុកម្តាយដែលបានចិញ្ចឹមបីបាច់ថែរក្សានារីរហូតដល់ថ្ងៃរៀបអាពាហ៍ពិពាហ៍ ដែលយើងតែងតែហៅថា "ថ្លៃទឹកដោះ" ។ ចំនួនទឹកប្រាក់នេះ ពេលខ្លះ គ្រាន់តែជានិមិត្តរូបតែប៉ុណ្ណោះ តែពេលខ្លះ ក៏មានលក្ខណៈសំខាន់ ហើយត្រូវតែមានជាដាច់ខាតផងដែរ តាមការអនុវត្ត ។ នៅក្នុងអង្គហេតុ លោក "ក" បានប្រគល់ឱ្យទៅអ្នកស្រី "ខ" មុនពេលរៀបអាពាហ៍ពិពាហ៍ នូវទឹកប្រាក់ចំនួន ៥.៤៨០ ដុល្លារអាមេរិកដែលក្នុងនោះ មានចំនួនទឹកប្រាក់ ២.០០៤ ដុល្លារ. ខ្សែកមាស និងចិញ្ចៀនមួយវង់ ត្រូវបានប្រគល់ឱ្យនៅពេលពីធីភ្ជាប់ពាក្យ ។ តើក្នុងករណីលែងលះ ត្រូវប្រគល់វត្ថុទាំងនេះសងត្រលប់ទៅវិញដែរ ឬទេ ?

ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ ១៩៨៩ បង្ហាញនូវភាពខ្វះចន្លោះ ទាក់ទងនឹងបញ្ហានេះ ។ ហេតុដូច្នេះហើយបានជាតុលាការកំពូល មានតួនាទីយ៉ាងសំខាន់នៅក្នុងវិស័យនេះ ដោយហេតុថា គាត់ត្រូវតែជំនុំជំរះ ដើម្បីចៀសវាងយុត្តិនិសេធ ។ តុលាការកំពូលបានកំណត់ទង្វើដែលសហព័ន្ធប្តី ប្រគល់នូវទ្រព្យមួយចំនួននានាពេលភ្ជាប់ពាក្យ និងការរៀបអាពាហ៍ពិពាហ៍ គឺជាអំណោយ ។ សំណូរហោហាស័ព្ទរបស់តុលាការកំពូលមានលក្ខណៈសាមញ្ញ តែច្បាស់លាស់ ។ តុលាការកំពូលបង្ហាញថា លោក "ក" បានធ្វើជាអំណោយឱ្យទៅសហព័ន្ធប្រពន្ធនូវទឹកប្រាក់ចំនួន ៥.៤៨០ ដុល្លារអាមេរិក ខ្សែករមាស និងចិញ្ចៀនមួយវង់ ។ តុលាការកំពូល ពុំបានបែងចែងភាពខុសគ្នារវាងអំណោយធ្វើនៅពេលភ្ជាប់ពាក្យ និងការរៀបអាពាហ៍ពិពាហ៍នោះទេ ។ ទោះបីជាតុលាការកំពូលចាត់ទុកបណ្ណាការទាំងនេះ គឺជាអំណោយ តែវាគ្រាន់តែជាអំណោយដែលធ្វើឡើងមុនពេលរៀបអាពាហ៍ពិពាហ៍ ។

យើងត្រូវកំណត់របបគតិយុត្តរបស់អំណោយទាំងនេះ ។

ខ. របបគតិយុត្តនៃបណ្ណាការ :

មុននឹងចោទសួរថា តើមានរបបគតិយុត្តដោយឡែកដែលត្រូវបានអនុវត្តទៅក្នុងប្រភេទនៃអំណោយដែរឬទេ ? វាជាការចាំបាច់ដែលយើងត្រូវកំណត់ចំណាំថា គ្មានវិធានជារួមដែលអនុវត្តទៅលើគ្រប់ប្រភេទនៃអំណោយនោះទេ ។ យើងអាចរកឃើញបទប្បញ្ញត្តិស្តីពីអំណោយទាក់ទងនឹងអចលនវត្ថុនៅក្នុងច្បាប់ភូមិបាល ។ ប៉ុន្តែ គ្មានបទប្បញ្ញត្តិណាមួយស្តីពីអំណោយទាក់ទងនឹងចលនវត្ថុនោះទេ ទោះបីជានៅក្នុងក្រឹត្យ-ច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យាក៏ដោយ ។ ដោយប្រឈមមុខនឹងភាពខ្វះចន្លោះនេះ វិធាននៃអំណោយជាអចលនវត្ថុ ដែលចែងថា អំណោយដែលធ្វើរួចហើយពុំអាចត្រូវបានទាមទារត្រលប់មកវិញ អាចលាតសន្ធឹងទៅដល់អំណោយជាចលនវត្ថុបាន ។ នៅប្រទេសកម្ពុជា យើងមានសុភាសិតមួយ ដែលថា "ឱ្យ គឺឱ្យ យើងពុំអាចទាមទារត្រលប់មកវិញនោះទេ " ។ វាហាក់ដូចជាជាពុំលក្ខណៈសំខាន់សោះដែលយើងបែងចែករវាងចលនវត្ថុ និងអចលនវត្ថុដែលនៅក្នុងសុភាសិតខាងលើនេះ ពុំមានការបែងចែកដូច្នេះទេ ។ ដំណោះស្រាយនៅក្នុងសាលដីកានេះ ស្របតាមអត្ថិភាពនៃវិធានខាងលើនេះ ។ តុលាការកំពូលសំរេចថា លោក "ក" ពុំអាចទាមទារចំនួនទឹកប្រាក់ និងគ្រឿងអលង្កា ដែលត្រូវបានប្រគល់ឱ្យ មុនពេលរៀបអាពាហ៍ពិពាហ៍បាននោះទេ ដោយ

Scanned with CamScanner

ហេតុថា វាជាអំណោយឱ្យទៅអ្នកស្រី "ខ" ។ ដំណោះស្រាយនេះ បង្ហាញថា បណ្ណាការដែលត្រូវបានប្រគល់ឱ្យ មុនពេលរៀបអាពាហ៍ពិពាហ៍ ពុំអាចដកហូតបាននោះទេ ។ នេះគឺជាការអនុវត្តរបបគតិយុត្តទូទៅនៃអំណោយ ។

នៅក្នុងករណីខ្លះ ដំណោះស្រាយរបស់តុលាការកំពូលអាចប្រឆាំងបាន ដូចជាករណីការរំលាយកំជាប់ពាក្យ ។ បើសិនជាការរំលាយបណ្ដាលមកពីកំហុសរបស់នារី បុរសពុំអាចទាមទារសំណងបណ្ណាការនោះទេ ។ ដំណោះស្រាយនេះមានលក្ខណៈគួរឱ្យភ្ញាក់ផ្អើល ។ តាមពិត សេចក្ដីព្រាងក្រមរដ្ឋប្បវេណី រៀបរៀបនៅឆ្នាំ ២០០៤ ចែងអំពីសំណងបណ្ណាការ ប្រសិនបើការរំលាយកំជាប់ពាក្យពុំមែនបណ្ដាលមកពីកំហុសរបស់បុរស ។

Scanned with CamScanner

ភាគទី ៣
លំហាត់អនុវត្ត

Scanned with CamScanner

ភាគទី ៣
លំហាត់អនុវត្ត

នៅក្នុងលំហាត់អនុវត្ត និស្សិត ឬបេក្ខជនប្រឡងជួបប្រទះនូវស្ថានភាពអង្គហេតុមួយដែលចោទជាបញ្ហាគតិយុត្ត ។ កិច្ចការនេះតម្រូវឱ្យមានការស្រាវជ្រាវនូវមូលដ្ឋានគតិយុត្តដែលទាក់ទងជាមួយនឹងស្ថានភាពនៃអង្គហេតុ ហើយយកមូលដ្ឋានគតិយុត្តនោះទៅអនុវត្តក្នុងអង្គហេតុ ដើម្បីទទួលបាននូវដំណោះស្រាយមួយ ។ លំហាត់នេះ មានលក្ខណៈមួយយ៉ាងសំខាន់ ចំពោះអនាគតអ្នកជំនាញវិជ្ជាជីវៈច្បាប់ ។ តាមពិត ការស្វែងរកដំណោះស្រាយចំពោះករណីវិវាទមួយ គឺជាមុខងារចម្បងរបស់ចៅក្រម ដោយហេតុថា ដើម្បីដោះស្រាយនូវវិវាទមួយបាន គាត់ត្រូវបញ្ជាក់បង្ហាញអំពីគោលការណ៍នៃនីតិ ដើម្បីយកវាទៅអនុវត្តនៅក្នុងអង្គហេតុ ។ ប៉ុន្តែ ការងារនេះក៏ជាតួនាទីរបស់មេធាវីផងដែរ ដោយហេតុថា គាត់ត្រូវបានពិគ្រោះយោបល់ ជាមួយអតិថិជនរបស់គាត់ដែលចង់ដឹងពីគន្លឹះមួយចំនួន ដើម្បីឈ្នះក្តីវិវាទ ។ ដូច្នេះ ដើម្បីឆ្លើយទៅនឹងសំណួររបស់អតិថិជន គាត់ត្រូវពិនិត្យមើលលើវិធាននៃនីតិ ដែលអាចអនុវត្តទៅក្នុងអង្គហេតុ ។

ដើម្បីរកដំណោះស្រាយចំពោះលំហាត់អនុវត្ត និស្សិត ឬបេក្ខជនប្រឡង ត្រូវយល់ដឹងអំពីវិធីសាស្ត្រនៃការដោះស្រាយលំហាត់អនុវត្ត "ផ្នែកទី ២". ប៉ុន្តែ ជាដំបូង ត្រូវដឹងអំពីវិធីនៃការដេញរកហេតុផល ដែលត្រូវបានចាត់ទុកជាវិចារណកិច្ចគតិយុត្ត និងត្រូវមានសមត្ថភាពក្នុងការកំណត់ចរិតលក្ខណៈគតិយុត្តនៃអង្គហេតុ "ផ្នែកទី ១" ។

ផ្នែកទី ១ : ចំណេះដឹងចាំបាច់នូវធាតុផ្សំចាំបាច់ក្នុងការយល់ឱ្យបានល្អអំពីលំហាត់អនុវត្ត

(បេអាទ្រីស ចាលីវេ និង កាន ច័ន្ទមេត្តា)

ការដោះស្រាយលំហាត់អនុវត្ត ត្រូវការជាចាំបាច់ជាបឋមនូវការយល់ដឹងអំពីវិចារណកិច្ចគតិយុត្ត "កថាខណ្ឌទី ១" និងការកំណត់ចរិតលក្ខណៈគតិយុត្តនៃអង្គហេតុ "កថាខណ្ឌទី ២" ។

កថាខណ្ឌទី ១ : ការយល់ដឹងអំពីវិចារណកិច្ចគតិយុត្ត

បន្ទាប់ពីមានការបង្ហាញអំពីការដេញរកហេតុផល "ក" មានឧទាហរណ៍ជាច្រើនដែលនឹងត្រូវលើកយកមកពន្យល់ បង្ហាញ "ខ" ។

គ. ការបង្ហាញអំពីវិចារណកិច្ចគតិយុត្ត

វិចារណកិច្ចគតិយុត្ត គឺជារបៀបដេញរកហេតុផលមួយដែលជាមូលដ្ឋាននៃលំហាត់គតិយុត្ត ។ វិចារណកិច្ចគតិយុត្ត អាចត្រូវបានផ្តល់និយមន័យជាលក្ខណៈទូទៅថា ជាប្រតិបត្តិការខាងផ្នែកបញ្ញាដែលនៅក្នុងនោះយើងទាញទំនាក់ទំនងនូវធាតុពីរជាមួយនឹងធាតុទី ៣ ដែលយើងឱ្យឈ្មោះថា ធាតុកណ្តាល ហើយយើងសន្និដ្ឋាននូវទំនាក់ទំនងនៃធាតុទាំងនោះរវាងគ្នាទៅវិញទៅមក ។

យើងមានឧទាហរណ៍ដូចជា បើសិនជា (ក)=(ខ) ហើយចំណែក (ខ)= (គ) ហេតុដូច្នេះ យើងបាន (ក)=

Scanned with CamScanner

(គ) ។ ក្នុងការដេញរកហេតុផលនេះ យើងអាចទាញបាននូវសំណើបីយ៉ាង គឺ បដិញ្ញាធំ "ឬគោលការណ៍", បដិញ្ញាតូច "អង្គហេតុ" និងសន្និដ្ឋាន ។

ឧទាហរណ៍ :

បដិញ្ញាធំ ឬ គោលការណ៍ : មនុស្សគ្រប់រូបត្រូវតែស្លាប់

បដិញ្ញាតូច ឬ អង្គហេតុ : ឱណា គឺជាមនុស្ស

សន្និដ្ឋាន : ឱណាក៏ត្រូវតែស្លាប់ ។

ការដេញរកហេតុផលនេះក៏អាចសរសេរតាមបែបផែនផ្សេងទៀតផងដែរ ដូចជា : ប្រសិនបើយើងជាមនុស្ស ដូច្នេះមនុស្សត្រូវតែស្លាប់ ក៏ប៉ុន្តែ ឱណាគឺជាមនុស្ស ដូច្នេះ ឱណាក៏ត្រូវតែស្លាប់ ។

ដើម្បីឱ្យច្បាស់ជាងនេះទៀត វិចារណកិច្ចគតិយុត្តអាចត្រូវបានកំណត់និយមន័យថា ជាប្រតិបត្តការមួយដែលអនុញ្ញាតឱ្យយើងអនុវត្តនូវដំណោះស្រាយដែលមានចែងនៅក្នុងវិធាននៃនីតិ ទៅក្នុងស្ថានភាពនៃអង្គហេតុមួយ ។ នៅក្នុងករណីដែលស្ថានភាពនៃអង្គហេតុបំពេញនូវរាល់លក្ខខណ្ឌនៃការអនុវត្តវិធាននៃនីតិ យើងនឹងយកដំណោះស្រាយនៃវិធាននោះទៅអនុវត្តនៅក្នុងអង្គហេតុ ។ វិចារណកិច្ចគតិយុត្តនេះ ត្រូវបានផ្សំឡើង ដូចជាករណីខាងលើដែរ គឺមាន បីផ្នែក :

ផ្នែកទី ១ គឺបដិញ្ញាធំដែលបង្ហាញនូវវិធាននៃនីតិ និងការពន្យល់ ។ ហេតុដូច្នេះ វិធាននេះត្រូវតែបង្ហាញឱ្យបានច្បាស់-លាស់ និងមានលក្ខណៈអរូបី ដែលក្នុងនោះ បើសិនជាសម្មតិកម្មមួយត្រូវបានបំពេញ វានឹងផ្តល់នូវលទ្ធផល ឬអានុភាពដូច្នោះដែរ ។ ជាញឹកញាប់ ការគ្រាន់តែបង្ហាញអំពីវិធានគតិយុត្តមានលក្ខណៈមិនគ្រប់គ្រាន់នោះទេ ។ វាត្រូវតែបំពេញបន្ថែមទៀត ដោយការបង្ហាញនូវរាល់លក្ខខណ្ឌអនុវត្តនៃវិធាននោះថែមទៀត ។

ផ្នែកទី ២ គឺ បដិញ្ញាតូច : វាមានកម្មវត្ថុ និងគោលដៅប្រៀបធៀបស្ថានភាពនៃអង្គហេតុ ជាមួយនឹងវិធាននៃនីតិដែលត្រូវបានបញ្ជាក់នៅផ្នែកទី ១ បដិញ្ញាធំ ។

ផ្នែកទី ៣ គឺ សន្និដ្ឋាន : យោងតាមបដិញ្ញាតូច យើងត្រូវដេញរកថា តើលទ្ធផល ឬអានុភាពដែលមានចែងក្នុងវិធាននៃនីតិ អាច ឬមិនអាចត្រូវបានអនុវត្តនៅក្នុងស្ថានភាពនៃអង្គហេតុ ។

ឧទាហរណ៍ :

វិទ្ធ មានអាយុ ១២ ឆ្នាំ ។ គាត់បានទិញតែម្នាក់ឯងនូវម៉ូតូមួយគ្រឿង ។ តើកិច្ចសន្យានេះមានសុពលភាពដែរឬទេ ?

បដិញ្ញាធំ : យោងតាមមាត្រា ១៥ នៃក្រិត្យ-ច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា អនីតិជនពុំអាចបង្កើតកាតព្វកិច្ចតែម្នាក់ឯងនោះទេ ។ មាត្រានេះចែងយ៉ាងច្បាស់ថា អនីតិជន គឺជាអសមត្ថជននៅក្នុងការចុះកិច្ចសន្យា ប្រសិនគ្មានការយល់ព្រមពីអាណាព្យាបាលស្របច្បាប់ ។

Scanned with CamScanner

បដិញ្ញាតូច : រិទ្ធ គឺជាអនីតិជន ដែលបានចុះកិច្ចសន្យាតែម្នាក់ឯង ។

សន្និដ្ឋាន : ហេតុដូច្នេះ កិច្ចសន្យាខាងលើត្រូវបានបង្កើតឡើងដោយគ្មានសុពលភាព ។

ខ. លំហាត់អនុវត្ត

ដើម្បីផ្ទៀងផ្ទាត់ថា តើយើងយល់ដឹងអំពីការដេញរកហេតុផលនេះដែរឬទេ យើងត្រូវព្យាយាមអនុវត្តវិធីនេះតាមរយៈលំហាត់ខាងក្រោម :

១. លំហាត់

១.១. លំហាត់ទី ១

តើផ្ទះគឺជាអចលនវត្ថុដែរឬទេ ?

១.២. លំហាត់ទី ២

សុជាតាមានអាយុ ១៧ ឆ្នាំ ។ នាងមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយសំណាងដែលមានអាយុ ១៩ ឆ្នាំ ដោយគ្មានការយល់ព្រមពីឪពុកម្តាយរបស់នាង ។ តើនាងអាចអាពាហ៍ពិពាហ៍បានដែរ ឬទេ ?

២. កំណែ

២.១. កំណែលំហាត់ទី ១

បដិញ្ញាធំ : អនុលោមតាមមាត្រា ២ នៃច្បាប់ភូមិបាល ចុះថ្ងៃទី ៣០-០៨-២០០១ ត្រូវបានចាត់ទុកជាអចលនវត្ថុ តាមន័យច្បាប់នោះ មានអចលនវត្ថុពីកំណើត មានដីធម្មជាតិដូចជា ដីព្រៃឈើ ដីកាប់វាន ដីដាំដុះ ដីទុកចំនេរ ឬមិនអាចដាំដុះ ដីលិច ទឹកដោយទឹកនៅនឹង ឬទឹកហូរ និងសំណង់ ឬការរៀបចំទាំងឡាយ ដែលស្ថិតនៅជាប់មួយកន្លែង កើតឡើងដោយអំពើរបស់មនុស្ស ហើយមិនអាចរំកិល ឬផ្លាស់ប្តូរកន្លែងបាន ។

បដិញ្ញាតូច : ផ្ទះគឺជាវត្ថុមួយដែលកើតឡើងដោយសារអំពើរបស់មនុស្ស, ជាអាទិកាល ដែលនៅស្ថិតជាប់នៅលើដី ហើយដែលមិនអាចផ្លាស់ប្តូរទីកន្លែងបាននោះទេ ។

សន្និដ្ឋាន : ផ្ទះគឺជាអចលនវត្ថុ និយាយឱ្យកាន់តែស៊ីជំរៅគឺជាអចលនវត្ថុតាមធម្មជាតិ ។

២.២. កំណែលំហាត់ទី ២

បដិញ្ញាធំ : ស្របតាមមាត្រា ៥ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ចុះថ្ងៃទី ២៦-០៧-១៩៨៥ អាពាហ៍ពិពាហ៍ អាចត្រូវបានធ្វើឡើងជាគោលការណ៍ រវាងបុរសដែលមានអាយុចាប់ពី ២០ ឆ្នាំ និងនារីដែលមានអាយុចាប់ពី ១៨ ឆ្នាំ ។ ក៏ប៉ុន្តែ មានករណីលើកលែង បុរសមានអាយុតិចជាង ២០ ឆ្នាំ ហើយនារីមានអាយុតិចជាង ១៨ ឆ្នាំ អាចរៀបអាពាហ៍

Scanned with CamScanner

ពិពាហ៍បាន លុះណាតែនារីមានផ្ទៃពោះ និងមានការយល់ព្រមពីឪពុកម្តាយរបស់នារី ។

ចដិញ្ញាតូច : សំណាងមានអាយុតិចជាង ២០ ឆ្នាំ ហើយសុជាតា មានអាយុតិចជាង ១៨ ឆ្នាំ ។ ក៏ប៉ុន្តែ ទោះបីជាសុជាតា មានផ្ទៃពោះ តែនាងគ្មានការយល់ព្រមពីឪពុកម្តាយរបស់នាង ដើម្បីរៀបអាពាហ៍ពិពាហ៍នោះទេ ។

សន្និដ្ឋាន : សុជាតា ពុំអាចរៀបអាពាហ៍ពិពាហ៍ជាមួយសំណាងបាននោះទេ ។

គថាខណ្ឌទី ២ : ការផ្ដួចផ្ដើមក្នុងការកំណត់ចរិតលក្ខណៈគតិយុត្តនៃអង្គហេតុ

និស្សិត ឬបេក្ខជនប្រឡង ពុំអាចរកដំណោះស្រាយនៃលំហាត់អនុវត្ត ដោយមិនបានស្គាល់ជាបឋមអំពីការកំណត់ចរិតលក្ខណៈគតិយុត្តនៃអង្គហេតុនោះទេ ។ ស្ថានភាពភាគច្រើននៃអង្គហេតុ ស្តែងឡើងតាមរយៈភាសានិយាយដែលតាមពិតបង្កប់មកជាមួយនូវធាតុផ្សំគតិយុត្ត ។ អ្នកច្បាប់ ត្រូវតែមានសមត្ថភាពយល់ដឹង អំពីស្ថានភាពនៃអង្គហេតុដែលកើតឡើងដោយភ្ជាប់វាទៅនឹងធាតុផ្សំគតិយុត្ត ។ ប្រតិបត្តិការនេះមានលក្ខណៈសំខាន់ ដោយហេតុថា វាកំណត់នូវការអនុវត្តរបបគតិយុត្តមួយច្បាស់លាស់ ។

ឧទាហរណ៍ : ចំពោះអ្នកច្បាប់, សត្វគោគឺជាចលនវត្ថុតាមធម្មជាតិ ។

ក. លំហាត់

នៅក្នុងអង្គហេតុខាងក្រោមនេះ យើងត្រូវកំណត់នូវរាល់ស្ថានភាពទាំងអស់ដែលអាចធ្វើការប្រៀបធៀបជាមួយនឹងធាតុផ្សំគតិយុត្ត ហើយត្រូវកំណត់នូវចរិតលក្ខណៈគតិយុត្ត ប្រសិនបើយើងយល់ថា ស្ថានភាពទាំងនោះមានលក្ខណៈស្របគ្នាជាមួយនឹងអង្គហេតុនោះ ។

ពេលព្រឹកនេះ ស៊ីណា បានភ្ញាក់ពីគេងនៅម៉ោង ៦ និង ៣០ នាទី ។ នាងក្រោកយឺត ដោយហេតុថា នាងត្រូវចាប់ផ្តើមការងារជាជាងកាត់ដេរ នៅផ្សារអូរឬស្សីនៅម៉ោង ៧ ព្រឹក ។ ប្រធានរបស់នាង នឹងមិនសប្បាយចិត្តចំពោះនាងនោះទេ ដោយហេតុថា តាំងពីដើមខែ នាងមកធ្វើការយឺតចំនួនបីដងរួចមកហើយ ។ នាងកំដៅទឹក ដើម្បីរៀបចំញ៉ាំតែក្នុងអំឡុងពេលដែលនាងកំពុងមុជទឹក ។ នាងបានស្លៀកសំពត់លំអរដោយផ្កាដែលនាងបានទិញនៅផ្សារអូឡាំពិក កាលពីថ្ងៃសៅរ៍មុន ។ បន្ទាប់ពីបានញ៉ាំតែយ៉ាងប្រញាប់ប្រញាល់ នាងក៏បានចាកចេញពីផ្ទះល្វែងថ្មីដ៏តូចរបស់នាង ។ នៅវេលាម៉ោង ៦ និង ៥០ នាទី នៅពេលដែលនាងមកដល់ផ្សារ នាងមានពេលត្រឹមតែស្រស់ស្រួបអាហារពេលព្រឹកប៉ុណ្ណោះ ។ នាងបានជ្រើសរើសយកបាយសាច់ជ្រូក ដើម្បីជំនួសសំឡសុីបដែលនាងបានញ៉ាំជាញឹកញាប់ ។ នាង គីម ជាអ្នកទទួលភ្ញៀវ និងជាមិត្តភ័ក្តរបស់នាង បានលើកបាយសាច់ជ្រូកមកឱ្យនាង ។ នាង គីម មានអារម្មណ៍ពុំសូវសប្បាយចិត្តនោះទេនាថ្ងៃនេះ ។ នាងបានពន្យល់ទៅ ស៊ីណា ថា កាលពីម្សិលមិញ នៅពេលដែលនាងត្រលប់ទៅផ្ទះ នាងបានជិះម៉ូតូឌុប ហើយនៅពីក្រោយម៉ូតូឌុប កាបូបរបស់នាងត្រូវបានឆក់ដោយក្រុមក្មេងស្ទាវដែលជិះម៉ូតូតាមពីខាងក្រោយនាង ។ តាមពិត នាងទើបតែបានទទួលប្រាក់ឈ្នួល ហេតុដូច្នេះ នាងមិនដឹងថាធ្វើយ៉ាងដូចម្តេច ដើម្បីបំពេញជីវភាពនៅក្នុងខែនោះទេ ។ ស៊ីណាក៏បានឱ្យប្រាក់ទៅនាង គីម ចំនួន ៥ ដុល្លារអាមេរិក ដើម្បីឱ្យនាងអាចទិញរបស់ខ្លះបំពេញជីវភាព ។

Scanned with CamScanner

ក្រោយពីបញ្ចប់ការងារ ស៊ីណា បានប្រញាប់ប្រញាល់ ដោយហេតុថា នាងត្រូវបង្រៀននៅមជ្ឈមណ្ឌលវប្បធម៌បារាំង ហើយថ្នាក់របស់នាងនឹងចាប់ផ្តើមនៅ ២០ នាទី ខាងមុខនេះ ។ នាងភ្លេចយកក្រដាស និងប៊ិចសរសេរ ។ សិស្សម្នាក់ បានឱ្យនាងខ្ចីប៊ិចមួយ និងសិស្សផ្សេងទៀតបានឱ្យក្រដាសទៅនាងផងដែរ ។ ជាការផ្លាស់ប្តូរ នាងនឹងអញ្ជើញពួកគេទៅញ៉ាំកាហ្វេទឹកកកនៅអាហារដ្ឋាននៅក្នុងសាលា នាពេលសំរាក ។ ស៊ីណាត្រលប់ទៅផ្ទះរបស់នាង នៅវេលាម៉ោង ១៩ ។ នាងមានអារម្មរណ៍មិនសូវល្អនោះទេ បន្ទាប់ពីបានទទួលទានអាហារនៅអាហារដ្ឋាននៅផ្សារអូរឬស្សី ។ សាច់ជ្រូកប្រហែលជាពុំសូវស្រស់ល្អ ។ ម៉្យាងវិញទៀត នៅពេលដែលនាងចេញពីមជ្ឈមណ្ឌលវប្បធម៌បារាំង នាងបានឃើញគ្រោះថ្នាក់ដ៏អាក្រក់មួយ ដោយមានឡានមួយបានបើកបុកម៉ូតូ ដោយធ្វើឱ្យម៉ូតូឃ្លាតចូលទៅក្នុងហាងលក់គ្រឿងសង្ហារឹម ស្ថិតនៅជាប់នឹងដងផ្លូវ ហើយអ្នកបើកបររថយន្តដ៏សាហាវនោះមិនបានឈប់នោះទេ ។ ស៊ីណា មានអារម្មណ៍កាន់តែរន្ធត់ថែមទៀត ។

ខ. កំណែលំហាត់ដាក់ឆន្ទនិយការកំណត់ចរិតលក្ខណៈគតិយុត្ត

កំណែត្រូវបានធ្វើឡើង ដោយសំគាល់តាមរយៈអក្សរផ្តេកនៅក្នុងអត្ថបទ :

ពេលព្រឹកនេះ ស៊ីណា (*រូបវន្តបុគ្គល ឈ្មោះ*) បានភ្ញាក់ពីគេងនៅម៉ោង ៦ និង ៣០ នាទី ។ នាងក្រោកយឺតដោយហេតុថា នាងចាប់ផ្តើមការងារជាជាងកាត់ដេរនៅផ្សារអូរឬស្សី នៅម៉ោង ៧ ព្រឹក ។ (*នៅក្នុងស្ថានភាពនេះយើងគ្មានធាតុផ្សំនៃអង្គហេតុគ្រប់គ្រាន់នោះទេ ។ ហេតុដូច្នេះ មានចរិតលក្ខណៈគតិយុត្តច្រើនអាចត្រូវបានលើកឡើង : គាត់ជាសិប្បករ ឬភ្ជាប់ជាមួយកិច្ចសន្យាហ៊ីរហ៊ឺន ឬកិច្ចសន្យាក្រុមហ៊ុន ឬកិច្ចសន្យាការងារដែលក្នុងនោះ គុណភាពបុគ្គលជាធាតុផ្សំសំខាន់, កិច្ចសន្យាទ្វេភាគី និងកិច្ចសន្យាដូរ ។ បន្ទាប់មកទៀត តាមរយៈអង្គហេតុខាងលើ ចរិតលក្ខណៈសំខាន់នៃកិច្ចសន្យានោះ គឺជាកិច្ចសន្យាការងារ*) ។ និយោជករបស់នាងនឹងមិនសប្បាយចិត្តចំពោះនាងនោះទេ ដោយហេតុថាតាំងពីដើមខែ នាងបានមកធ្វើការយឺតចំនួនបីដងមកហើយ "*កំហុសវិជ្ជាជីវៈ, មូលហេតុនៃការបណ្តេញចេញ*" ។ នាងកំដៅទឹក(*កិច្ចសន្យាជាវ*) ដើម្បីរៀបចំញ៉ាំតែ (*ចលនវត្ថុតាមធម្មជាតិ, អាចបរិភោគបាន, អាចផ្លាស់ប្តូរបាន*) ក្នុងអំឡុងពេលដែលនាងកំពុងតែមុជទឹក (*កិច្ចសន្យាជាវ*) ។ នាងបានស្បែកសំពត់លំអរដោយផ្កា (*ចលនវត្ថុ មិនអាចបរិភោគបានអាច ឬមិនអាចផ្លាស់ប្តូរបាន*) ដែលនាងបានទិញ (*កិច្ចសន្យាលក់ : កិច្ចសន្យាទ្វេភាគី, កិច្ចសន្យាដូរ, កិច្ចសន្យាមុលា*) នៅផ្សារអូឡាំពិចកាលពីថ្ងៃសៅរ៍មុន ។ បន្ទាប់ពីបានញ៉ាំតែ (*ចលនវត្ថុតាមធម្មជាតិ,អាចបរិភោគបាន, អាចផ្លាស់ប្តូរបាន*) យ៉ាងប្រញាប់ប្រញាប់ នាងក៏បានចាកចេញពីផ្ទះល្វែងថ្មីដ៏តូច (*អចលនវត្ថុតាមធម្មជាតិ, កិច្ចសន្យាលក់, ឬកិច្ចសន្យាជួល*) របស់នាង ។ វេលាម៉ោង ៦ និង ៥០ នាទី នៅពេលដែលនាងមកដល់ផ្សារ នាងមានពេលត្រឹមតែស្រស់ស្រូបអាហារពេលព្រឹក (*កិច្ចសន្យាជាវ*) ។ នាងបានជ្រើសរើសយកបាយសាច់ជ្រូក (*ចលនវត្ថុតាមធម្មជាតិ, រូបី, អាចបរិភោគបាន, អាចផ្លាស់ប្តូរបាន*) ដើម្បីផ្លាស់ប្តូរនូវសំឡសុីប (*ចលនវត្ថុតាមធម្មជាតិ, រូបី, អាចបរិភោគបាន,អាចផ្លាស់ប្តូរបាន*) ដែលនាងតែងតែញ៉ាំជាញឹកញាប់ ។ នាង គីម (*រូបវន្តបុគ្គល ឈ្មោះ*) អ្នកទទួលភ្ញៀវ(*កិច្ចសន្យាការងារ*) និងជាមិត្តភ័ក្តរបស់នាង បានលើកទុ្ចយសាច់ជ្រូក (*ចលនវត្ថុ, អាចបរិភោគបាន, អាច ឬមិនអាចផ្លាស់ប្តូរបាន*) ជូននាង ។ នាងមានអារម្មណ៍មិនសូវសប្បាយចិត្តនោះទេថ្ងៃនេះ ។ នាងបានពន្យល់ប្រាប់ ស៊ីណា ថា កាលពីម្សិលមិញ នៅពេល

Scanned with CamScanner

ដែលនាងត្រលប់ទៅផ្ទះ នាងបានជិះម៉ូតូឌុប ហើយនៅពីក្រោយម៉ូតូឌុប (*កិច្ចសន្យាដឹកជញ្ជូន, កិច្ចសន្យាទ្វេភាគី, មូលា និងដូរ*) កាបូបរបស់នាង (*ចលនវត្ថុតាមធម្មជាតិ, មិនអាចបរិភោគបាន, មិនអាចផ្លាស់ប្តូរបាន*) ត្រូវបានឆក់ដោយក្មេងស្ទាវ (*រូបវន្តបុគ្គល*) ដែលជិះម៉ូតូតាមពីខាងក្រោយនាង (*លួច, បទល្មើសព្រហ្មទណ្ឌ, បទល្មើសមជ្ឈឹម*) ។ តាមពិតនាងទើបតែបានទទួលប្រាក់ឈ្នួល ដូច្នេះ នាងមិនដឹងថាធ្វើយ៉ាងដូចម្តេច ដើម្បីបំពេញជីវភាពនៅក្នុងខែនេះទេ ។ ស៊ីណា ក៏បានឱ្យប្រាក់ទៅនាង គីម ចំនួន ៥ ដុល្លារអាមេរិក ដើម្បីឱ្យនាងអាចទិញរបស់ខ្លះ (*កិច្ចសន្យាអំណោយ, កិច្ចសន្យាមុខា*) ដើម្បីឱ្យនាងអាចទិញរបស់ខ្លះបំពេញជីវភាព ។ ក្រោយពីបញ្ចប់ការងាររបស់នាង ស៊ីណា ប្រញាប់ប្រញាល់ដោយហេតុថា នាងត្រូវបង្រៀននៅមជ្ឈមណ្ឌលវប្បធម៌បារាំង ហើយថ្នាក់របស់នាងនឹងចាប់ផ្តើមនៅ ២០ នាទី ខាងមុខនេះ ។ នាងភ្លេចយកក្រដាស (*ចលនវត្ថុតាមធម្មជាតិ, រូបី, មិនអាចបរិភោគបាន, អាចផ្លាស់ប្តូរបាន*) និងប៊ិច (*ចលនវត្ថុតាមធម្មជាតិ, រូបី, មិនអាចបរិភោគបាន,អាចផ្លាស់ប្តូរបាន*) ។ សិស្សម្នាក់បានឱ្យនាងខ្ចីប៊ិចមួយ និងសិស្សផ្សេងទៀតបានឱ្យក្រដាសទៅនាងផងដែរ ។ ជាការផ្លាស់ប្តូរ នាងនឹងអញ្ជើញពួកគេទៅញ៉ាំការហ្វេទឹកកកនៅអាហារដ្ឋាននៅក្នុងសាលា នាពេលសំរាក (*កិច្ចសន្យាដោះដូរ*) ។ ស៊ីណា ត្រលប់មកផ្ទះរបស់នាងនៅម៉ោង ១៩ ។ នាងមានអារម្មណ៍ពុំសូវល្អនោះទេ បន្ទាប់ពីបានទទួលទានអាហារនៅអាហារដ្ឋានផ្សារអូរឬស្សី ។ សាច់ជ្រូកប្រហែលជាពុំសូវស្រស់ល្អនោះទេ (*ការទទួលខុសត្រូវតាមកិច្ចសន្យារបស់ម្ចាស់អាហារដ្ឋាន*) ។ ម៉្យាងវិញទៀត នៅពេលដែលនាងចេញពីមជ្ឈមណ្ឌលវប្បធម៌បារាំង នាងបានឃើញនូវគ្រោះថ្នាក់ដ៏អាក្រក់មួយ (*ការទទួលខុសត្រូវក្រៅកិច្ចសន្យា*) ដោយឡានមួយ (*ចលនវត្ថុតាមធម្មជាតិ, រូបី, មិន អាចបរិភោគបាន, អាច ឬមិនអាចផ្លាស់ប្តូរបាន*) បានបើកបុកម៉ូតូ (*ចលនវត្ថុតាមធម្មជាតិ, រូបី, មិនអាចបរិភោគបាន, អាច ឬមិនអាចផ្លាស់ប្តូរបាន : ព្យសនកម្មខាងសំភារៈ*) ដែលធ្វើឱ្យម្ចាស់ម៉ូតូឃាត (*ព្យសនកម្មរូបរាងកាយ*) ទៅក្នុងហាងលក់គ្រឿងសង្ហារឹម (*ព្យសនកម្មខាងសំភារៈ*) ស្ថិតនៅជាប់នឹងផ្លូវ ហើយអ្នកបើកបរដំស៊ាហាវនោះមិនបានឈប់នោះទេ ។ ស៊ីណា មានអារម្មណ៍កាន់តែខ្វល់ថែមទៀត ។

ផ្នែកទី ២ : និទីសាស្ត្រលំហាត់អនុវត្ត : (បេអាទ្រីស ចាលីវ៉ែ និង កាន ចំន្តមេត្តា)

ការបង្ហាញអំពីវិធីសាស្ត្រ (កថាខណ្ឌទី ១) និងការអនុវត្តលំហាត់ នឹងត្រូវលើកយកមកបង្ហាញ ដើម្បីអនុញ្ញាតឱ្យយើងស្គាល់អំពីមុខវិជ្ជាសំខាន់ៗ ក្នុងការត្រៀមរៀបចំប្រឡងប្រជែង (កថាខណ្ឌទី ២) ។

កថាខណ្ឌទី ១ : ការបង្ហាញអំពីវិធីសាស្ត្រ

ការអនុវត្តលំហាត់ភ្ជាប់ជាមួយនឹងវិធីសាស្ត្រ (ខ) នឹងត្រូវបកស្រាយបន្ទាប់ពីបានសិក្សាពីវិធីសាស្ត្រ (ក) ។

ក. វិធីសាស្ត្រ

ដើម្បីដោះស្រាយនូវលំហាត់អនុវត្ត យើងត្រូវពិនិត្យទៅលើដំណាក់កាលជាច្រើន :

Scanned with CamScanner

-ដំណាក់កាលទី ១ : យល់ដឹងអំពីអង្គហេតុ នៅក្នុងលំហាត់អនុវត្ត

និស្សិត ឬបេក្ខជនប្រឡង ត្រូវស្ថិតនៅក្នុងស្ថានភាពមួយ ដូចជាអ្នកជំនាញវិជ្ជាជីវៈច្បាប់ ដែលត្រូវផ្តល់យោបល់ឱ្យទៅអតិថិជនរបស់ខ្លួន ។ តាមនិយមន័យ អតិថិជនមិនមែនជាអ្នកច្បាប់នោះទេ ។ គាត់អាចរៀបរាប់នូវព្រឹត្តិការណ៍ដ៏ស្មុគ្រស្មាញផ្សេងៗ ដោយបន្ថែមនូវគំនិតមតិផ្ទាល់ខ្លួន ឬស៊ីជំរៅចំពោះអង្គហេតុ ដែលគ្មានប្រយោជន៍ខាងផ្នែកច្បាប់ ។ លើសពីនេះទៀត គាត់បង្ហាញនូវស្ថានភាពអង្គហេតុតាមរយៈភាសានិយាយ ។ ជាការធម្មតា បើសិនជាយើងមិនអាចយល់បានតាមរយៈការអានលើកទី ១ ។ និស្សិត ឬបេក្ខជនត្រូវអានឱ្យបានជាច្រើនដងនូវអង្គហេតុ ។ ការអានលើកទី ១ មានលក្ខណៈទូទៅ ។ ការអាននេះ អនុញ្ញាតឱ្យយើងទទួលបាននូវការយល់ដឹងយ៉ាងទូលាយទៅលើអង្គហេតុទាំងមូល ។ ការអានលើកទី ២ ត្រូវម៉ត់ចត់ជាងមុន ។ យើងត្រូវគូសបន្ទាត់ពីក្រោមពាក្យ. កាលបរិច្ឆេត. ចំនួនលេខ និងការស៊ីជំរៅផ្សេងទៀតដែលមានលក្ខណៈសំខាន់ ។

-ដំណាក់ទី ២ : ការវិភាគទៅលើអង្គហេតុ

ការរៀបរាប់អង្គហេតុដោយអតិថិជនអាចវែងអន្លាយ និងមិនសូវច្បាស់នោះទេ ។ បន្ទាប់ពីបានអានជាច្រើនលើករួចហើយ យើងត្រូវពិនិត្យឱ្យបានម៉ត់ចត់នូវរាល់ធាតុផ្សំសំខាន់ទាំងឡាយ ហើយត្រូវញែកចេញចំពោះធាតុផ្សំដែលពុំសូវច្បាស់លាស់ ។ យើងមិនត្រូវទុកចិត្តចំពោះមតិយោបល់ផ្ទាល់ខ្លួនរបស់អតិថិជនដែលមិនមែនជាអ្នកច្បាប់ ហើយដែលអាចផ្តល់នូវព័ត៌មានមិនត្រឹមត្រូវនោះទេ ។ ដូច្នេះ យើងត្រូវទទួលយកតែអង្គហេតុសំខាន់ដែលអាចត្រូវបានលើកឡើងស្របតាមពាក្យបច្ចេកទេសច្បាប់ប៉ុណ្ណោះ ។ ផ្ទុយមកវិញ ធាតុផ្សំសំខាន់ៗខ្លះអាចនឹងត្រូវបានលាក់ទុក ។ កាលណាធាតុផ្សំណាមួយនៃអង្គហេតុអវត្តមាន យើងត្រូវលើកឡើងសម្មតិកម្មជាច្រើនដែលអាចធ្វើបាន ហើយដេញរកហេតុផលចំពោះសម្មតិកម្មនីមួយៗ ដើម្បីផ្ទៀងផ្ទាត់មើលថា តើយើងអាចលះបង់នូវសម្មតិកម្មណាមួយ ដើម្បីយកសម្មតិកម្មផ្សេងទៀតដែរឬទេ ? ដើម្បីឱ្យបានច្បាស់ថា យើងអាចយល់ដឹងបានល្អអំពីព្រឹត្តិការណ៍ទាំងនោះ វាជាការចាំបាច់ដែលយើងត្រូវលើកឡើងនូវលំដាប់ថ្នាក់នៃអង្គហេតុនីមួយៗនៅលើបន្ទាត់ ឬតារាងមួយ ។ យើងត្រូវគូសបន្ទាត់នៃពេលវេលាដើម្បីកំណត់អំពីព្រឹត្តិការណ៍សំខាន់ៗនីមួយៗ. ការកើតឡើងនូវលិខិតគតិយុត្ត ឬរយៈពេលណាមួយ..... រាល់ធាតុផ្សំទាំងអស់នៃអង្គហេតុត្រូវតែលេចឡើងជាពាក្យបច្ចេកទេសច្បាប់ ។ នៅក្នុងករណីនេះ គឺជាតំណាក់កាលនៃការកំណត់ចរិតលក្ខណៈគតិយុត្ត ។ "ការកំណត់ចរិតលក្ខណៈគតិយុត្ត គឺជាប្រតិបត្តិការមួយដែលក្នុងនោះ វិធាននៃនីតិកំណត់ចរិតលក្ខណៈ. ស្ថានភាព និងអង្គហេតុ ដែលត្រូវយកមកពិនិត្យវាយតម្លៃ" ។ ទង្វើនេះអនុញ្ញាតឱ្យយើងអាចកំណត់បានតាមវិធានគតិយុត្តនូវស្ថានភាពមួយ ឬអង្គហេតុមួយ ដោយភ្ជាប់វាទៅនឹងចរិតលក្ខណៈគតិយុត្តមួយដែលជាគំរូ ។ ប្រតិបត្តិការនេះមានលក្ខណៈមួយសំខាន់ ដោយហេតុថា ការភ្ជាប់ ឬការប្រៀបធៀបទៅនឹងចរិតលក្ខណៈមួយអរូបី អាចកំណត់បាននូវការអនុវត្តរបបគតិយុត្តមួយ ។

-ដំណាក់កាលទី ៣ : ការស្វែងរក និងការកំណត់អំពីបណ្តាគតិយុត្ត

កាលណាយើងយល់បានយ៉ាងច្បាស់អំពីស្ថានភាពនៃអង្គហេតុទាំងនោះ យើងត្រូវព្យាយាមភ្ជាប់ និងប្រៀបធៀបស្ថានភាពនៃអង្គហេតុទាំងនោះទៅនឹងសញ្ញាណ ឬយន្តការគតិយុត្ត ដែលបានបកស្រាយនៅក្នុងមេរៀន ។ លំហាត់

Scanned with CamScanner

អនុវត្តអាចចង្អុលបង្ហាញច្បាស ឬមនច្បាសចពោះសណ្ឋរ ។ នៅក្នុងករណីខ្លះ សំណួរត្រូវបានចោទឡើង ហើយយើងគ្រាន់តែឆ្លើយទៅនឹងសំណួរទាំងនោះតែប៉ុណ្ណោះ ។ ប៉ុន្តែ មានករណីផ្សេងទៀត គ្មានសំណួរណាមួយត្រូវបានចោទឡើងនោះទេ បន្ទាប់ពីបានអាននូវអង្គហេតុទាំងនោះ ហេតុដូច្នេះ យើងត្រូវស្វែងរក និងកំណត់នូវសំណួរគតិយុត្តដោយខ្លួនឯង ។

-ជំណាក់កាលទី ៤ : ការកំណត់អំពីវិធានគតិយុត្ត

កាលណានិស្សិត ឬបេក្ខជនបានកំណត់អំពីបញ្ហាគតិយុត្ត យើងត្រូវរកដំណោះស្រាយចំពោះបញ្ហាទាំងនោះ ។ ដើម្បីអាចរកដំណោះស្រាយបាន យើងត្រូវកំណត់អំពីវិធានគតិយុត្ត ។ យើងត្រូវកំណត់ និងស្វែងរកនូវវិធានជាច្រើនដែលអាចធ្វើបាន ហើយផ្សេងផ្ទាត់វិធាននីមួយៗ ថាតើលក្ខខណ្ឌនៃការអនុវត្តរបស់វាត្រូវបានបំពេញដែរឬទេ ? រាល់វិធានទាំងអស់ត្រូវសរសេរជាតំបូងនៅលើក្រដាសព្រាង ។ ដូច្នេះ យើងក៏អាចបង្ហាញទៅដល់អតិថិជនរបស់យើងនូវវិធានទាំងទាយណាដែលអាចអនវតបានជាមយភាពចាកដរបជា. វិធានណាខះដែលមិនសវចាស់លាស់ និងវិធានណាខ្លះទៀតដែលមិនគួរលើកឡើងនោះទេ ។ ការកំណត់អំពីវិធាគតិយុត្ត ធ្វើឡើងជាទូទៅតាមរយៈមេរៀនដែលយើងបានសិក្សានៅក្នុងមុខវិជ្ជានីមួយៗដែលពាក់ព័ន្ធ ។ ដូច្នេះ ដើម្បីងាយស្រួលនៅក្នុងការកំណត់អំពីវិធាននេះ យើងត្រូវយល់ដឹងឱ្យបានច្បាស់អំពីមេរៀនរបស់យើង ។

-ជំណាក់កាលទី ៥ : ការផ្ទឿងផ្ទាត់អំពីការអនុវត្តវិធានជាមួយនឹងអង្គហេតុ

ការពិគ្រោះយោបល់ត្រូវតែធ្វើឡើងដោយសមភាព ។ យើងត្រូវតែផ្តល់យោបល់ត្រឹមត្រូវ ហើយត្រូវបង្ហាញនូវគ្រាល់ឧបសគ្គទាំងឡាយដែលយើងអាចជួបប្រទះ និងអំណះអំណាងផ្ទុយ ដើម្បីជំទាស់ប្រឆាំងជាមួយគូភាគីម្ខាងទៀត ។ ប៉ុន្តែករណីនេះ ពុំបានបដិសេធចោលនូវផ្នែកនៃការវិភាគវាឃតម្លៃនោះទេ ។ រវាងដំណោះស្រាយពីរ ឬច្រើនដែលអាចមាន យើងអាចបញ្ជាក់អំពីដំណោះស្រាយណាមួយ ដែលមានលក្ខណៈពិសេស ដោយយោងទៅលើជោគវាសនាក្នុងការឈ្នះ ឬយោងទៅលើអានុភាព ឬលទ្ធផលនៃដំណោះស្រាយនីមួយៗ ។

-ជំណាក់កាលទី ៦ : ការតាក់តែងលំហាត់អនុវត្ត

កាលណាដំណោះស្រាយត្រូវបានរកឃើញ និងផ្ទៀងផ្ទាត់ យើងត្រូវតាក់តែងលំហាត់អនុវត្ត ។ ដូចជាកិច្ចការគតិយុត្តផ្សេងទៀតផងដែរ លំហាត់អនុវត្តត្រូវចាប់ផ្តើមដោយសេចក្តីផ្តើមដ៏ខ្លី ។ យើងគ្រាន់តែកំណត់អំពីវិស័យពាក់ព័ន្ធ. សង្ខេបអង្គហេតុ និងចោទបញ្ហាគតិយុត្តតាមលំដាប់លំដោយ ។ បន្ទាប់មកទៀត និស្សិត ឬបេក្ខជន ត្រូវឆ្លើយជាបន្តបន្ទាប់រាល់សំណួរទាំងឡាយ ដែលត្រូវបានចោទឡើង ។ ការតាក់តែងត្រូវគោរពតាមរបៀបវិចារណកិច្ចគតិយុត្ត ។ និស្សិត ឬបេក្ខជន ត្រូវតាក់តែងចម្លើយចំពោះសំណួរពាក់ព័ន្ធ ដោយគោរពតាមលំដាប់ថ្នាក់ :

-បដិញ្ញាធំ មានន័យថាសំដៅទៅលើវិធាន ឬគោលការណ៍ ដែលត្រូវអនុវត្តចំពោះអង្គហេតុ ។ យើងត្រូវចាប់ផ្តើមតាមរយៈការរៀបរាប់នូវគោលការណ៍ ដោយបញ្ជាក់ឱ្យបានច្បាស់អំពីលេខនៃមាត្រា ឬច្បាប់ទាក់ទង. បន្ទាប់មកត្រូវពន្យល់អំពីអត្ថន័យនៃគោលការណ៍នេះ មានន័យថា កំណត់អំពីលក្ខខណ្ឌនៃការអនុវត្តរបស់វា ។

Scanned with CamScanner

-**បដិញ្ញាតូច** : មានន័យថា អនុវត្តបដិញ្ញាធំទៅក្នុងអង្គហេតុ ។ យើងត្រូវប្រៀបធៀបវិធាននៃនីតិជាមួយនឹងស្ថានភាពនៃអង្គហេតុ ។ យើងត្រូវផ្ទៀងផ្ទាត់ថា តើរាល់លក្ខខណ្ឌនៃការអនុវត្តវិធាន ត្រូវបានបំពេញស្របតាមស្ថានភាពនៃអង្គហេតុដែរឬទេ ?

-**សន្និដ្ឋាន**: យើងត្រូវបង្ហាញអំពីលទ្ធផលនៃការប្រៀបធៀប ដោយបញ្ជាក់ថា តើវិធាននៃនីតិត្រូវបានអនុវត្តទៅក្នុង អង្គហេតុដែរឬទេ ?

នៅពេលបញ្ចប់កិច្ចការ វាជាការប្រសើរដែរ បើសិនជាយើងលើកឡើងសាជាថ្មីនូវរាល់ដំណោះស្រាយដែលបានរកឃើញពីដំបូងជាបន្តបន្ទាប់ ។

ខ. ការប្រតិបត្តិតាមជាមួយនីតិវិធីសាស្ត្រនៃលំហាត់អនុវត្ត

លោក តូ សំណាង បានណាត់ជួបជាមួយអ្នក ។ គាត់បានពន្យល់ប្រាប់អ្នកថា គាត់បានរៀបអាពាហ៍ពិពាហ៍នៅថ្ងៃទី ១៥-០៤-២០០០ ជាមួយកញ្ញាដ៏ស្រស់ស្អាតម្នាក់ឈ្មោះ ពូ សុជាតា ។ នៅថ្ងៃទី ១៨-០៥-២០០០ កូនទី ១ របស់គាត់បានផ្តល់កំណើតដែលមានឈ្មោះថា សត្យា ។ នៅពេលដែលសត្យាផ្តល់កំណើត លោក តូ សំណាង ស្នាក់នៅក្រៅប្រទេស ។ សត្យា ត្រូវបានប្រកាសចុះបញ្ជីអត្រានុកូលដ្ឋាន ដោយម្តាយរបស់គាត់តែម្នាក់ឯងប៉ុណ្ណោះ ។ នៅថ្ងៃទី ១៥-០៥-២០០៣ កូនស្រីម្នាក់ទៀតរបស់អ្នកទាំងពីរបានផ្តល់កំណើត ដែលមានឈ្មោះថា ធានី ។ សំណាង ប្រាកដខ្លួនឯងថាប្រពន្ធរបស់ខ្លួនបានកុហក ហើយផិតក្បត់នឹងគាត់ ដោយហេតុថា ជាញឹកញាប់ គាត់តែងតែអវត្តមាន ដើម្បីកិច្ចការជំនាញវិជ្ជាជីវៈ ។ គាត់មានការសង្ស័យផងដែរអំពីបិតុភាពនៃកូនទាំងពីរនោះ ។ ដូច្នេះ គាត់ក៏សុំលែងលះ ។ នៅថ្ងៃទី ២៨-០៥-២០០៣ តុលាការបង្គាប់ឱ្យបំបែកលំនៅសង្វាស ហើយនៅថ្ងៃទី ១៥-០៦-២០០៤ តុលាការប្រកាសការលែងលះ ។ ប៉ុន្តែ សុជាតា បានផ្តល់កំណើតកូនម្នាក់ទៀតនៅថ្ងៃទី ៣-០៧-២០០៤ ឈ្មោះ លីដា និងថ្ងៃទី ២៥-០៤-២០០៥ កូនម្នាក់ទៀតឈ្មោះ លក្ខិណា ។ លោក តូ សំណាង ចោទជាសំណួរ ចំពោះចំណងគតិយុត្តរវាងគាត់ និងកូនម្នាក់ៗ ហើយគាត់គិតថា គ្មានកូនណាម្នាក់ជាកូនរបស់គាត់នោះទេ ។

១. ការយល់ដឹងអំពីលំហាត់អនុវត្ត

យើងត្រូវអនុវត្តនូវដំណាក់កាលទី ១ និងទី ២ នៃវិធីសាស្ត្រលំហាត់អនុវត្ត ។ យើងត្រូវធ្វើគំនូសតាងនៃពេលវេលាដែលក្នុងនោះយើងត្រូវកត់សំគាល់ចំពោះធាតុផ្សំនៃអង្គហេតុដែលមានលក្ខណៈសំខាន់ ។

ដំណាក់កាលទី ១ : បន្ទាប់ពីបានអានលើកទី១ យើងឃើញលំហាត់អនុវត្តនេះទាក់ទងនឹងបញ្ហាចំណងបុត្រភាព ។ បន្ទាប់ពីបានអានលើកទី ២ និងទី ៣ លំហាត់នេះចោទនូវបញ្ហាសំខាន់ពីរយ៉ាងគឺ ប្រភេទនៃចំណងបុត្រភាព និងលទ្ធភាពក្នុងការបដិសេធចំណងបុត្រភាព ។


លោក តូ សំណាង បានណាត់ជួបជាមួយអ្នក ។ គាត់បានពន្យល់ប្រាប់អ្នកថា គាត់បានរៀបអាពាហ៍ពិពាហ៍នៅថ្ងៃទី ១៥-០៤-២០០០ ជាមួយកញ្ញាដ៏ស្រស់ស្អាតម្នាក់ឈ្មោះ ពូ សុជាតា ។ នៅថ្ងៃទី ១៨-០៥-២០០០ កូនទី ១ របស់គាត់បានផ្តល់កំណើតដែលមានឈ្មោះថា សត្យា ។ នៅពេលដែលសត្យាផ្តល់កំណើត លោក តូ សំណាង ស្នាក់នៅក្រៅ

Scanned with CamScanner

ប្រទេស ។ សត្យា ត្រូវបានប្រកាសចុះបញ្ជីអត្រានុកូលដ្ឋាន ដោយម្តាយរបស់គាត់តែម្នាក់ឯងប៉ុណ្ណោះ ។ នៅ ថ្ងៃទី ១៥-០៥-២០០៣ កូនស្រីម្នាក់ទៀតបានផ្តល់កំណើតដែលមានឈ្មោះថា ធានី ។ សំណាងជ្រាកដខ្លួនឯងថា ប្រពន្ធរបស់ខ្លួនបានកុហក ហើយជិតក្បត់និងគាត់ ដោយហេតុថា ជាញឹកញាប់ គាត់តែងតែអវត្តមាន ដើម្បីកិច្ចការជំនាញវិជ្ជាជីវៈ ។ គាត់មានការសង្ស័យផងដែរ អំពីបិតុភាពនៃកូនទាំងពីរនោះ ។ ដូច្នេះ គាត់ក៏សុំលែងលះ ។ នៅថ្ងៃទី ២៨-០៩-២០០៣ តុលាការបង្គាប់ឱ្យបំបែកលំនៅសង្ឃាស ហើយនៅថ្ងៃទី ១៥-០៦-២០០៤ តុលាការប្រកាសការលែងលះ ។ ប៉ុន្តែ សុជាតា បានផ្តល់កំណើតកូនម្នាក់ទៀតនៅ ថ្ងៃទី ៣-០៧-២០០៤ ឈ្មោះ លីដា និងថ្ងៃទី ២៥-០៤-២០០៥ កូនម្នាក់ទៀតឈ្មោះ លក្ខិណា ។ លោក តូ សំណាង ចោទជាសំណួរចំពោះចំណងគតិយុត្តរវាងគាត់ និងកូនម្នាក់ៗ ហើយគាត់គិតថា ក្មានកូនណាម្នាក់ជាកូនរបស់គាត់នោះទេ ។


ដំណាក់កាលទី ២ : បន្ទាប់ពីបានអានលំហាត់អនុវត្ត យើងសង្កេតឃើញអំពីសារៈសំខាន់នៃកាលបរិច្ឆេទ ។ ដូច្នេះ យើងត្រូវប្រុងប្រយ័ត្នចំពោះព្រឹត្តិការណ៍ជាបន្តបន្ទាប់នេះ ។ តំនូសតាងដ៏តូចមួយ មានលក្ខណៈចាំបាច់ ដើម្បីច្បៀវរាងនូវរាល់ការភ័ន្តច្រឡំទៅលើការយល់ដឹងអំពីអង្គហេតុ ។ តំនូសតាងនេះ បញ្ជាក់ពីភាពត្រឹមត្រូវចំពោះស្ថានភាពនៃអង្គហេតុដែលក្នុងនោះ រយៈពេលមានផ្ទៃពោះ និងពេលវេលានៃការផ្តល់កំណើត រួមជាមួយស្ថានភាពខាងក្រៅផ្សេងទៀតដូចជា ការរៀបអាពាហ៍ពិពាហ៍, ការបង្គាប់បំបែកលំនៅសង្ឃាស ឬការលែងលះ មានលក្ខណៈមួយយ៉ាងសំខាន់ ។

តំនូសតាងទូទៅ




តំនូសតាងដោយឡែក

- សត្យា



-ធានី




Scanned with CamScanner

-លីដា



-លក្ខិណា



២. ការស្វែងរកសំណួរគតិយុត្ត

ការចង្អុលបង្ហាញអំពីសំណួរគតិយុត្តត្រូវបានលើកឡើងនៅចុងបញ្ចប់នៃលំហាត់ ។ លោក តូ សំណាង ចោទសួរអំពីចំណងបុត្រភាពរវាងគាត់ជាមួយកូនទាំងអស់ និងអានុភាពរបស់វា ។ ដូច្នេះ យើងត្រូវសិក្សាអំពីករណីនៃកូននីមួយៗ ។ យើងត្រូវផ្ទាស់ប្តូរករណីទាំងនោះទៅជាពាក្យបច្ចេកទេសច្បាប់គឺ តើចំណងបុត្រភាពរវាងកូននីមួយៗ ជាប្រភេទចំណងគតិយុត្តអ្វី ?

ចំណែកឃ្លាចុងក្រោយនៃលំហាត់អនុវត្តតម្រូវឱ្យយើងចោទជាសំណួរមួយទៀត ។ លោក តូ សំណាង ពុំជឿថាគាត់គឺជាឪពុករបស់កូនណាម្នាក់នោះទេ ។ ចំណោទបញ្ហាគតិយុត្តត្រូវបានចោទឡើងថា បើសិនជាចំណងបិតុភាពត្រូវបានបង្កើតឡើង តើលោក តូ សំណាង អាចមានលទ្ធភាពបដិសេធដែរឬទេ ? ហេតុដូច្នេះ យើងត្រូវឆ្លើយតបជាបន្តបន្ទាប់នូវសំណួរពីរ គឺ :

-តើចំណងបុត្រភាពជាមួយកូនម្នាក់ៗ ជាប្រភេទចំណងបុត្រភាពអ្វី ?

-ក្នុងករណីដែលបិតុភាពត្រូវបានបង្កើតឡើង តើលទ្ធភាពនៃការបដិសេធបិតុភាពអាចធ្វើបានដែរឬទេ ?

៣. ការស្វែងរកគោលការណ៍អនុវត្តចំពោះបញ្ហាគតិយុត្ត

គោលការណ៍ទាំងឡាយ ដែលអាចអនុវត្តចំពោះបញ្ហាខាងលើនេះ ស្ថិតនៅក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ចុះថ្ងៃ ទី ២៦-០៧-១៩៨៩ ។

បញ្ហាទី ១ ទាក់ទងនឹងបញ្ហាប្រភេទគតិយុត្តនៃចំណងបុត្រភាពរបស់កូន ។ ចំណែកបញ្ហាទី ២ ទាក់ទងនឹងលទ្ធភាពក្នុងការបដិសេធបិតុភាព ។

បញ្ហាខាងលើទាក់ទងនឹងចំណងបុត្រភាព ហេតុដូច្នេះ យើងត្រូវពិគ្រោះរាល់បទប្បញ្ញត្តិទាំងឡាយដែលទាក់ទងនឹងមុខវិជ្ជានេះ មានន័យថា នៅក្នុងមាត្រា ៨២ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ។ ចំណែកបញ្ហាទាក់ទងនឹងការបដិ-

Scanned with CamScanner

សេចក្តីបិតភាព យើងត្រូវអនុវត្តមាត្រា ៨៥ និង ៨៦ នៃច្បាប់ដដែល ។ ចំពោះការតាក់តែងលំហាត់អនុវត្ត ចូរមើល (បដិញ្ញាធំ) ។

៤. ការអនុវត្តគោលការណ៍ ឬវិធានណែនាំចំពោះអង្គហេតុ

នៅក្នុងការតាក់តែងលំហាត់អនុវត្ត ចូរមើល (បដិញ្ញាតូច) ។

៥. ការតាក់តែងលំហាត់អនុវត្ត

សេចក្តីផ្តើមត្រូវរំលឹកដ៏ខ្លីឡើងវិញនូវអង្គហេតុសំខាន់ៗ ។

សេចក្តីផ្តើម

សំណាង និងសុជាតា បានរៀបអាពាហ៍ពិពាហ៍នៅថ្ងៃទី ១៥-០៤-២០០០ ។ ៥ ខែក្រោយមក កូនទី ១ របស់គាត់ ឈ្មោះសត្យា បានផ្តល់កំណើត និង ៣០ខែ ក្រោយមក សុជាតា បានផ្តល់កំណើតធានី ។ ជាញឹកញាប់ សំណាងតែងតែអវត្តមានពីលំនៅដ្ឋាន ដោយមូលហេតុការងារវិជ្ជាជីវៈរបស់ខ្លួន ហើយគាត់សង្ស័យទៅលើភាពពុំស្មោះត្រង់ចំពោះប្រពន្ធរបស់គាត់ និងទៅលើចំណងបុត្រភាពជាមួយកូនម្នាក់ៗរបស់គាត់ ។ គាត់បានប្តឹងលែងលះគ្នា ។ តុលាការបានប្រកាសការលែងលះ បន្ទាប់ពីបានចេញដីកាបង្គាប់បំបែកលំនៅសង្ឃាសនៅថ្ងៃទី ១៥-០៦-២០០៤ ។ មួយខែក្រោយមក សុជាតា បានផ្តល់កំណើត លីដា ហើយប្រហែលជាមួយឆ្នាំក្រោយមក លក្ខិណា ក៏បានផ្តល់កំណើតផងដែរ ។

បញ្ហាគតិយុត្តពីរត្រូវបានចោទឡើង : តើកូនទាំងនេះមានប្រភេទចំណងបុត្រភាពអ្វី ជាមួយនឹងសំណាង ហើយក្នុងករណីដែលមានចំណងបុត្រភាពពិតប្រាកដមែន តើវាអាចចោទជាបញ្ហាចំពោះសំណាងដែរឬទេ ?

ដើម្បីដោះស្រាយលំហាត់អនុវត្តនេះ យើងត្រូវពិនិត្យជាបន្តបន្ទាប់ចំពោះករណីកូននីមួយៗ ។

ការបកស្រាយ :

១. តរណីសត្យា : នៅពេលដែលគាត់បានបង្ករកំណើត ឪពុកម្តាយរបស់គាត់នៅមិនទាន់បានរៀបអាពាហ៍ពិពាហ៍នោះទេ ។ សត្យាបានផ្តល់កំណើតក្នុងរយៈពេលតិចជាង ១៨០ ថ្ងៃ គិតពីថ្ងៃរៀបអាពាហ៍ពិពាហ៍នៃឪពុកម្តាយរបស់គាត់ ។

សំនួរទី ១ : តើប្រភេទគតិយុត្តនៃចំណងបុត្រភាពរបស់គាត់ជាអ្វី ?

បដិញ្ញាធំ : យើងត្រូវអនុវត្តមាត្រា ៨៣ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ។

នៅពេលណាដែលយើងរកឃើញអំពីមូលដ្ឋានគតិយុត្ត យើងត្រូវបង្ហាញអំពីលេខលំដាប់ និងបង្ហាញមាត្រាបន្ទាប់ មកត្រូវពន្យល់អំពីមាត្រានោះផងដែរ ។ យើងត្រូវចាប់ផ្តើមជានិច្ចជាកាលពីគោលការណ៍ :

យោងទៅលើគោលការណ៍ ដើម្បីចាត់ទុកជាកូនមានខាន់ស្លា គឺកូនទាំងឡាយណាដែលកើតក្នុងរយៈពេលដែលឪពុកម្តាយមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ មានន័យថា ក្នុងរយៈពេល ១៨០ ថ្ងៃ គិតចាប់ពីថ្ងៃរៀបអាពាហ៍ពិពាហ៍ ឬ ៣០០ ថ្ងៃ គិតចាប់ពីថ្ងៃផ្តាច់ចំណងអាពាហ៍ពិពាហ៍ ។ ប៉ុន្តែ មាត្រា ៨៣ ចែងថា បើសិនជាកូននោះកើតក្នុងរយៈពេលតិចជាង ១៨០ ថ្ងៃ ក្រោយពីថ្ងៃរៀបអាពាហ៍ពិពាហ៍ កូននោះអាចចាត់ទុកជាកូនមានខាន់ស្លា ។ ការចាត់ទុកដូច្នេះ ត្រូវ

Scanned with CamScanner

ការជាចាំបាច់នូវការបំពេញនូវលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌពីរយ៉ាងគឺ ប្តីរបស់នារីត្រូវតែដឹងថា នារីមានផ្ទៃពោះនៅមុនពេលរៀបអាពាហ៍ពិពាហ៍ ឬកូននោះត្រូវបានទទួលស្គាល់ដោយឪពុករបស់កូន ។

បដិញ្ញាតូច :

យោងតាមអង្គហេតុ សត្យាកើតក្នុងរយៈពេលតិចជាង ១៨០ ថ្ងៃ ចាប់ពីថ្ងៃរៀបអាពាហ៍ពិពាហ៍របស់សំណាង និង សុជាតា ។ បើសិនជាពិនិត្យទៅដល់ស្ថានភាពនៃការរៀបអាពាហ៍ពិពាហ៍ យើងអាចនិយាយថា ប្រហែលជាសំណាងមិនបាន យកចិត្តទុកដាក់អំពីការមានផ្ទៃពោះរបស់សុជាតានោះទេ ។

សន្និដ្ឋាន :

មាត្រា ៨៣ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ អនុវត្តចំពោះករណីខាងលើនេះ ។ សត្យាមានចំណងបុត្រភាពមានខាន់ស្លាដែលចងភ្ជាប់រវាងសំណាង និងសត្យា ។

សំណួរទី ២ : តើសំណាងមានលទ្ធភាពក្នុងការបដិសេធបិតុភាពដែរឬទេ ?

បដិញ្ញាធំ :

យោងទៅលើមាត្រា ៨៣ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ប្តីនៃនារីដែលមិនបានយកចិត្តទុកដាក់អំពីការមានផ្ទៃពោះរបស់នារី ឬដែលមិនទទួលស្គាល់ចំពោះកូន អាចបដិសេធបិតុភាព ដោយមិនចាំបាច់បង្ហាញអំពីភស្តុតាងនោះទេ ។ ប៉ុន្តែ ពាក្យបណ្តឹងបដិសេធបិតុភាពនោះ ត្រូវគោរពនូវលក្ខខណ្ឌដ៏តឹងរឹងមួយ ។ អនុលោមតាមមាត្រា ៨៤ និង ៨៦ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ពាក្យបណ្តឹងបដិសេធបិតុភាពត្រូវតែធ្វើឡើង ដោយសហព័ទ្ធជាប្តីជំទាស់ទៅនឹងនារី និងកូន ក្នុង រយៈពេល ២ ខែ គិតចាប់ពីថ្ងៃដែលបុរសបានដឹងអំពីកំណើតរបស់កូន ។

បដិញ្ញាតូច : សំណាងបានដឹងអំពីកំណើតរបស់សត្យាជាច្រើនឆ្នាំកន្លងមកហើយ ។

សន្និដ្ឋាន : ពាក្យបណ្តឹងបដិសេធបិតុភាពមិនអាចត្រូវបានធ្វើឡើងនោះទេ ដោយហេតុថា ពាក្យបណ្តឹងនោះត្រូវបានផុតអាជ្ញាយុកាល ហើយពាក្យបណ្តឹងនោះមិនអាចទទួលយកបាននោះទេ ។

២. គូនទី ២ ឈ្មោះ ធានី

សំណួរទី ១ : តើចំណងបុត្រភាពរបស់គាត់ស្ថិតនៅក្នុងប្រភេទគតិយុត្តអ្វី ?

បដិញ្ញាធំ :

អនុលោមតាមគោលការណ៍ដែលមានចែងក្នុងមាត្រា ៨២ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ដើម្បីចាត់ទុកជាកូនមានខាន់ស្លា គឺកូនទាំងឡាយណាដែលកើតក្នុងរយៈពេលដែលឪពុកម្តាយមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ មានន័យថា ក្នុងរយៈពេល ១៨០ ថ្ងៃ គិតចាប់ពីថ្ងៃរៀបអាពាហ៍ពិពាហ៍ ឬ ៣០០ ថ្ងៃ គិតចាប់ពីថ្ងៃផ្តាច់ចំណងអាពាហ៍-ពិពាហ៍ ។

Scanned with CamScanner

បដិញ្ញាតូច :

ធានី កើតក្នុងរយៈពេលចំណងអាពាហ៍ពិពាហ៍ស្របច្បាប់របស់ឪពុកម្តាយរបស់នាង ។

សន្និដ្ឋាន : មាត្រា ៨២ ខាងលើអាចត្រូវបានអនុវត្ត ហេតុដូច្នេះ ធានី ត្រូវបានចាត់ទុកជាកូនមានខាន់ស្លា ។ ចំណងបុត្រភាពមានខាន់ស្លា ត្រូវបានកើតឡើងរវាងសំណាង និងធានី ។

សំណួរទី ២ : តើសំណាងមានលទ្ធភាពអាចប្តឹងបដិសេធបិតុភាពដែរ ឬទេ ?

បដិញ្ញាធំ :

លទ្ធភាពក្នុងការធ្វើពាក្យបណ្តឹងបដិសេធបេតុភាពត្រូវបានចែងក្នុងមាត្រា ៨៥ និង៨៦ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ។ ពាក្យបណ្តឹងបដិសេធបេតុភាពត្រូវតែធ្វើឡើងដោយសហព័ទ្ធជាប្តីជំទាស់ទៅនឹងនារី និងកូន ហើយត្រូវធ្វើនៅចំពោះមុខតុលាការប្រជាជនខេត្ត ក្រុង នៅទីលំនៅរបស់នារីជាម្តាយ ក្នុងរយៈពេល ២ ខែ គិតចាប់ពីថ្ងៃដែលបុរសបានដឹងអំពីកំណើតរបស់កូន ។ ឪពុកនៃកូនអាចប្តឹងបដិសេធបាន ដោយបង្ហាញនូវភស្តុតាងនៃស្ថានភាពណាមួយក្នុងចំណោមស្ថានភាពទាំងពីរ គឺគាត់អវត្តមាននៅលំនៅដ្ឋានសង្វាស ឬគាត់មានជំងឺអពលានុភាពនៃលិង្គ ។

បដិញ្ញាតូច :

ប្តីរបស់នារីបានដឹងជាយូរមកហើយអំពីថ្ងៃកំណើតរបស់ធានី ហើយគាត់ក៏មិនបានចាកចេញលំនៅសង្វាស ឬអសុពលភាពនៃលិង្គនោះទេ ។

សន្និដ្ឋាន :

ពាក្យបណ្តឹងបដិសេធបិតុភាពមិនអាចធ្វើបាននោះទេ ពីព្រោះអាជ្ញាយុកាលត្រូវបានផុតរលត់ ។ ពាក្យបណ្តឹងក៏គ្មានមូលដ្ឋានគតិយុត្តត្រឹមត្រូវ ដោយហេតុថា លក្ខខណ្ឌពុំត្រូវបានបំពេញនោះទេ ។

៣. គូនទី ៣ ឈ្មោះ លីដា :

សំណួរទី ១ : តើចំណងបុត្រភាពរបស់គាត់ស្ថិតនៅក្នុងប្រភេទគតិយុត្តអ្វី ?

បដិញ្ញាធំ :

ស្របតាមគោលការណ៍ដែលមានចែងក្នុងមាត្រា ៨២ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ដើម្បីចាត់ទុកជាកូនមានខាន់ស្លា គឺកូនទាំងឡាយណាដែលកើតក្នុងរយៈពេលដែលឪពុកម្តាយមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ មានន័យថា ក្នុងរយៈពេល ១៨០ ថ្ងៃ គិតចាប់ពីថ្ងៃរៀបអាពាហ៍ពិពាហ៍ ឬ៣០០ ថ្ងៃ គិតចាប់ពីថ្ងៃផ្តាច់ចំណងអាពាហ៍ពិពាហ៍ ។ សច្ចធារណ៍បិតុភាពដែលទាញចេញពីមាត្រានេះ គ្រាន់តែជាសច្ចធារណ៍សាមញ្ញប៉ុណ្ណោះ ។ លើសពីនេះទៀត ច្បាប់គ្រាន់តែចែងថា ការបំបែកលំនៅសង្វាសអាចផ្តល់អានុភាពចំពោះតែការចាប់ផ្តើមគិតនៃរយៈពេលវិធវភាព ពុំមែនគិតចាប់

Scanned with CamScanner

ថ្ងៃលែងលះគ្នានោះទេ តែគិតចាប់ពីថ្ងៃចេញដីកាបំបែកលំនៅសង្ឃាសទៅវិញ (មាត្រា ៩ នៃច្បាប់ដដែល) និងអាចផ្តល់អានុភាពទៅលើមធ្យោ បាយនៃការបង្ហាញភស្តុតាងជាយថាហេតុផ្សេងទៀតផងដែរ (មាត្រា ៨៦ នៃច្បាប់ដដែលនេះ) ។

បដិញ្ញាតូច :

នាង លីដា កើតតិចជាងមួយខែ ក្រោយពីការលែងលះ សំណាង និងសុជាតា ហើយផ្តល់កំណើតក្នុងរយៈពេលបំបែកនៅសង្ឃាសរបស់ឪពុកម្តាយ ។

សន្និដ្ឋាន :

មាត្រា ៨២ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ត្រូវបានអនុវត្ត ។ លីដា គឺជាកូនមានខាន់ស្លា ដែលបង្កើតចំណងបុត្រភាពជាមួយសំណាង ។

សំណួរទី ២ : តើបណ្តឹងបដិសេធបិតុភាពអាចធ្វើបានដែរឬទេ ?

បដិញ្ញាធំ :

លទ្ធភាពអាចរកបាន តាមបទប្បញ្ញត្តិដែលមានចែងក្នុងមាត្រា ៨៥ និង ៨៦ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ។ ពាក្យបណ្តឹងបដិសេធបិតុភាពត្រូវតែធ្វើឡើងដោយសហព័ទ្ធជាប្តីជំទាស់ទៅនឹងនារី និងកូន ហើយត្រូវធ្វើឡើងនៅចំពោះមុខតុលាការប្រជាជនខេត្ត ក្រុង នៅទីលំនៅរបស់នារីជាម្តាយ ក្នុងរយៈពេល ២ ខែ គិតចាប់ពីថ្ងៃដែលបុរសបានដឹងអំពីកំណើតរបស់កូន ។ ឪពុកនៃកូនអាចប្តឹងបដិសេធបាន ដោយបង្ហាញនូវភស្តុតាងនៃស្ថានភាពណាមួយក្នុងចំណោមស្ថានភាពទាំងពីរ គឺ គាត់ចាកចោលលំនៅដ្ឋានសង្ឃាស ឬគាត់មានជំងឺអពលានុភាពនៃលិង្គ ។

បដិញ្ញាតូច :

តាមរយៈដីកាបង្គាប់បំបែកលំនៅសង្ឃាស សំណាងអាចបង្ហាញថា គាត់បានបែកលំនៅសង្ឃាសពីសហព័ទ្ធប្រពន្ធរបស់គាត់ ។ ប៉ុន្តែ រយៈពេល ២ ខែ ដើម្បីប្តឹងត្រូវបានកន្លងហួសផុតហើយ ។

សន្និដ្ឋាន :

ពាក្យបណ្តឹងបដិសេធបិតុភាពមិនអាចទទួលយកបាននោះទេ ។

៤. គូនទី ៤ លគ្គិណា

សំណួរទី ១ : តើចំណងបុត្រភាពរបស់គាត់ស្ថិតនៅក្នុងប្រភេទគតិយុត្តអ្វី ?

បដិញ្ញាធំ :

យោងតាមមាត្រា ៩០ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ កូនដែលកើតក្នុងរយៈពេលដែលឪពុកម្តាយជ្ឈានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ គឺជាកូនឥតខាន់ស្លា ។ ដើម្បីឱ្យចំណងបុត្រភាពអាចត្រូវបានបង្កើតឡើងចំពោះឪពុក-ម្តាយទាំងពីរនាក់ កូនត្រូវតែត្រូវបានប្រកាសទទួសស្គាស់នៅចំពោះមុខមន្ត្រីអាត្រានុកូលដ្ឋាន ។ ការទទួលស្គាស់ក៏អាចត្រូវបានធ្វើឡើង ក្រោយពីការផ្តល់កំណើតនៃកូននោះបាន បើសិនជាកូននោះមិនត្រូវបានទទួលស្គាល់ដោយឪពុករបស់

Scanned with CamScanner

កូននោះទេ ។ មាត្រា ៥៩ នៃច្បាប់ខាងលើ បានកំណត់ថា តុលាការប្រជាជនអាចតម្រូវអោយបុរសជាឪពុកទទួលស្គាល់កូនឥតខាន់ស្លាបាន : បើ បុរសនោះបាននាំពង្រត់ ឬបានចាប់សេពសន្ថវៈនារីជាម្តាយដោយរំលោភ ហើយបើសម័យនាំពង្រត់ ឬចាប់រំលោភសេពសន្ថវៈ នោះត្រូវគ្នានឹងសម័យដែលនារីនោះមានគភ៌ ។ បើបុរសនោះបានខ្លួននារី ដោយឧបាយ-កលបោកបញ្ឆោត ដោយការរំលោភអំណាច ឬដោយការសន្យាថានឹងរៀបអាពាហ៍ពិពាហ៍ជាមួយនារីនោះ ។ បើមានភស្តុតាងជាលាយលក្ខណ៍អក្សរពីបុរសនោះ បង្ហាញអោយឃើញច្បាស់ថា បុរសនោះពិតជាឪពុករបស់កូននោះ ។ បើបុរស និងនារី ជាឪពុក និងជាម្តាយរបស់កូននោះ បានរួមរស់នឹងគ្នាជាអនីតិសង្វាសជាក់ស្តែងក្នុងសម័យនីត្យានុកូលដែលនារីនោះមានគភ៌ ។ បើបុរសនោះបានផ្តត់ផ្តង់ ឬបាន ចូលរួមក្នុងការបីបាច់រក្សា និងការអប់រំកូននោះក្នុងឋានៈខ្លួនជាឪពុក ។ ក៏ប៉ុន្តែ ពាក្យបណ្តឹងរបស់ម្តាយ ឬអាណាព្យាបាលនៃកូននោះមិនអាចទទួលយកបាននោះទេ បើសិនមានភស្តុតាងបង្ហាញថា នារីជាម្តាយមានទំនាក់ទំនងកាមគុណនឹងប្រុសដទៃទៀត ក្នុងសម័យនីត្យានុកូល ដែលនារីនោះមានគភ៌ ឬបើក្នុងសម័យនីត្យានុកូលដែលនារីមានគភ៌ បុរសដែលត្រូវប្រកាន់ថា ជាឪពុករបស់កូននោះគ្មានលទ្ធភាពរួមដំណេកជាមួយនារីជាម្តាយនោះ ដោយរស់នៅឆ្ងាយពីគ្នា ឬដោយមកពីមានគ្រោះថ្នាក់ ។

បដិញ្ញាតូច :

លក្ខិណា បានផ្តល់កំណើតនៅក្នុរយៈពេលដែលម្តាយរបស់ខ្លួនបានលែងលះរួចហើយ ។ ប៉ុន្តែ មានសំណួរខ្លះត្រូវបាន ចាទឡើងផងដែរថា តើការលែងលះនេះត្រូវបានធ្វើឡើងដោយរំលោភទៅនឹងមាត្រា ៦៨ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារដែរឬទេ ? តើមានលទ្ធភាពណាខ្លះ ដែលអាចជំទាស់ប្រឆាំងទៅនឹងសេចក្តីសម្រេចលែងលះនេះបាន ដើម្បីភ្ជាប់ចំណងបុត្រភាពជាកូនមានខាន់ស្លា ? ដោយយោងតាមមាត្រា ៦ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពសាលាជម្រះក្តីនៃរដ្ឋកម្ពុជាចុះថ្ងៃទី ៨-០២-១៩៩៣ សេចក្តីសម្រេចរបស់តុលាការអាចត្រូវបានប្រឆាំង តាមរយៈការធ្វើពាក្យបណ្តឹងជំទាស់ប្រឆាំងធម្មតា ។ ដើម្បីស្គាស់អំពីពាក្យបណ្តឹងជំទាស់ និងរយៈពេលនៃការធ្វើពាក្យបណ្តឹងនោះ យើងត្រូវពិនិត្យមើល ថាតើសេចក្តីសម្រេចនោះ គឺជាសាលក្រមចំពោះមុខ ឬកំបាំងមុខ ។

បើសិនជាសាលក្រមនោះ គឺជាសាលក្រមចំពោះមុខ សាលក្រមនេះអាចធ្វើជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ក្នុងរយៈពេល ២ ខែ គិតចាប់ពីថ្ងៃប្រកាសសាលក្រម ដោយយោងតាមមាត្រា ៧ នៃច្បាប់ខាងលើ ។ ក្រោយពីសាលាឧទ្ធរណ៍បានចេញសាលដីកា សាលក្រមនោះអាចធ្វើជាកម្មវត្ថុនៃបណ្តឹងសាទុក្ខក្នុងរយៈពេល ២ ខែ គិតចាប់ពីថ្ងៃប្រកាសសាលដីកា ។ បើសិនជាសាលក្រមកំបាំងមុខ បណ្តឹងទាស់អាចត្រូវបានធ្វើឡើងក្នុងរយៈពេល ១៥ ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានដំណឹងពីសាលក្រមនោះ ។

បើសិនជារយៈពេលប្តឹងទាស់ត្រូវបានផុតរលត់ ពាក្យបណ្តឹងឧទ្ធរណ៍អាចធ្វើបានក្នុងរយៈពេល ២ ខែ គិតចាប់ពីថ្ងៃផុតរលត់នៃបណ្តឹងទាស់ យោងតាមមាត្រា ៧ និង ៨ នៃច្បាប់ខាងលើ ។

នៅក្នុងករណីអង្គហេតុខាងលើ រយៈពេលនៃការប្តឹងខាងលើត្រូវបានផុតរលត់ ។ ហេតុដូច្នេះ ទោះបីជាការលែងលះត្រូវបានធ្វើឡើងដោយរំលោភទៅលើមាត្រា ៦៨ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ការលែងលះនេះមិនអាចជំទាស់ប្រឆាំងបាននោះឡើយ ។

Scanned with CamScanner

សន្និដ្ឋាន :

លក្ខិណា គឺជាកូនឥតខាន់ស្លា ។ ចំណងបុត្រភាពរបស់គាត់អាចនឹងត្រូវបានបង្កើតតែក្នុងករណីដែលលោក សំណាង ប្រកាសទទួលស្គាស់ ឬគាត់បំពេញកិច្ចការក្នុងឋានៈជាឪពុកតែប៉ុណ្ណោះ ។ ដូច្នេះ យើងត្រូវផ្តល់យោបល់ចំពោះគាត់ ដោយពុំត្រូវបំពេញកិច្ចការណាមួយ ក្នុងឋានៈជាឪពុករបស់កូននោះទេ បើសិនជាគាត់មិនចង់ឱ្យចំណងបុត្រភាពត្រូវបានបង្កើតឡើង ។

សំណួរទី ២ : តើមានលទ្ធភាពជំទាស់ប្រឆាំងចំពោះចំណងបុត្រភាពនេះដែរឬទេ ?

ចំណោទបញ្ហានេះមិនត្រូវបានចោទឡើងនោះទេ ពីព្រោះថាគ្មានចំណងបុត្រភាពណាមួយត្រូវបានបង្កើតឡើងនោះទេ ។ ដូច្នេះ គាត់មិនចាំបាច់ជំទាស់ប្រឆាំងអ្វីឡើយ ។

ឧទាហរណ៍ទី ២ : លំហាត់អនុវត្តន៍ផ្ទាល់ខ្លួន

ដើម្បីអនុញ្ញាតឱ្យនិស្សិត ឬបេក្ខជនប្រឡង អាចផ្ទៀងផ្ទាត់ថា តើគាត់អាចយល់បានអំពីវិធីសាស្ត្រនេះដែរឬទេ ? មានលំហាត់ជាច្រើនដែលត្រូវបានលើកឡើង ហើយដែលវាទាក់ទងនឹងមុខវិជ្ជាចម្បងនីមួយៗ ។ ជាដំបូងយើងត្រូវព្យាយាមសិក្សា និងរកដំណោះស្រាយដោយខ្លួនឯង បន្ទាប់មកយើងធ្វើការផ្ទៀងផ្ទាត់ដំណោះស្រាយរបស់យើងជាមួយដំណោះស្រាយដែលត្រូវបានបកស្រាយក្នុងសៀវភៅនេះ ។ និស្សិត ឬបេក្ខជនប្រឡង ពុំត្រូវរារែកក្នុងការធ្វើលំហាត់ខាងក្រោមឱ្យបានច្រើនដងនោះទេ ។ យើងត្រូវហ្វឹកហាត់រហូតដល់ដំណាក់កាលមួយដែលដំណោះស្រាយរបស់យើងមានលក្ខណៈស្រដៀងគ្នានឹងដំណោះស្រាយក្នុងសៀវភៅនេះ ។

ក. និតិវិធីប្បវេណី

១. អន្តហេតុ

លោក ដុយប៉ុង មានអាយុ ៥០ឆ្នាំ ជាប្រធានរោងចក្រផលិតសំលៀកបំពាក់មួយនៅទីក្រុងភ្នំពេញ ។ ការរីកចំរើនលូតលាស់នៃក្រុមហ៊ុនរបស់គាត់តម្រូវឱ្យគាត់ត្រូវសម្រេចនូវការវិនិយោគជាច្រើនទៀត ។ ដើម្បីបន្ថែមសមត្ថភាពផលិតកម្ម. កាលពីខែមុន គាត់បានទាក់ទងនឹងក្រុមហ៊ុន (អ៊ិច) ដែលមានជំនាញខាងការផ្គត់ផ្គង់នូវសំភារៈអាជីវកម្មទៅដល់ក្រុមហ៊ុនផលិតសំលៀកបំពាក់ ។ ក្រោយពីមានការចរចាក្នុងរយៈពេលដ៏ខ្លី គាត់បានចុះកិច្ចព្រមព្រៀងមួយ ជាមួយក្រុមហ៊ុន (អ៊ិច) ដែលក្នុងនោះ គាត់យល់ព្រមទិញម៉ាស៊ីនដេរចំនួន ១០ គ្រឿង ដែលមានតំរូ (អ៊ីម ១៥) ក្នុងតម្លៃ ៧០០ ដុល្លារអាមេរិក ។ នៅពេលដែលគាត់ទទួលបានវិក័យប័ត្រ គាត់ឃើញថា ក្រុមហ៊ុន(អ៊ិច) បានស្នើឱ្យគាត់បង់ប្រាក់ចំនួន ៧.០០០ ដុល្លារអាមេរិក ។ គាត់ក៏បានជូនដំណឹងទៅផ្នែកគណនេយ្យរបស់ក្រុមហ៊ុន (អ៊ិច) ថា ប្រហែលជាមានការភ័ន្តច្រឡំ ។ ប៉ុន្តែ ផ្នែកគណនេយ្យរបស់ក្រុមហ៊ុន (អ៊ិច) ក៏បានឆ្លើយវិញផងដែរថា ចំនួនទឹកប្រាក់ដែលមានក្នុងវិក័យប័ត្រនោះពិតជាត្រឹមត្រូវមែន ហើយចំនួនទឹកប្រាក់ ៧០០ ដុល្លារអាមេរិក ដែលចែងក្នុងកិច្ចសន្យា តាមទំលាប់ពាណិជ្ជកម្ម ឆ្លើយតបទៅនឹងតម្លៃនៃគ្រឿងម៉ាស៊ីនដេរនីមួយៗប៉ុណ្ណោះ ។ តាមរយៈការអានដោយប្រុងប្រយ័ត្នសាជាថ្មី

Scanned with CamScanner

ឡើងវិញនូវកិច្ចសន្យា លោក ដុយប៉ុង អាចយល់បានពិតប្រាកដមែនថា គាត់មានការភ័ន្តច្រឡំ ។ គាត់មានអារម្មណ៍ត្រូវបានគេបោកប្រាស់ ពីព្រោះថា នៅលើទីផ្សារនៅក្នុងទីក្រុងភ្នំពេញ តម្លៃជាមធ្យមនៃម៉ាស៊ីនដេរមួយគ្រឿងគឺ ១០០ ដុល្លារអាមេរិក ។ គាត់មានអារម្មណ៍ពុំសប្បាយចិត្តអំពីការទិញនោះទេ ពីព្រោះថា វាមិនអាចធ្វើឱ្យគាត់ទទួលបានផលចំណេញខ្លះពីផលិតកម្មដែលបានគិត ។ តាមពិត ក្រុមហ៊ុន (អ៊ិច) មានបំណងចង់ជម្រះស្តុករបស់គាត់ ដែលម៉ាស៊ីនគំរូខាងលើនេះមិនអាចលក់បាននោះទេ ហើយដែលក្រុមហ៊ុននេះបានធ្វើឱ្យលោក ដុយប៉ុង ជឿជាក់ថា ទំនិញទាំងនោះមានគុណភាពល្អ តែតាមការពិតពុំមែនដូច្នោះទេ ។ ដើម្បីធ្វើឱ្យមានការជឿជាក់ឡើងវិញចំពោះការធានានេះ ក្រុមហ៊ុន (អ៊ិច) បានកែប្រែខ្លឹមសារកិច្ចសន្យាដែលត្រូវប្រគល់ឱ្យអ្នកទិញ និងធ្វើការ កំណត់អំពីលក្ខណៈនៃទំនិញដែលត្រូវបានលក់នោះ ។

ការព្រួយបារម្ភរបស់លោក ដុយប៉ុង មិនទាន់ត្រូវបានបញ្ចប់នោះទេ ។ ដោយត្រូវការប្រាក់ជាបន្ទាន់ ដើម្បីជម្រះបញ្ជីក្រុមហ៊ុនរបស់គាត់ គាត់ក៏បានទាក់ទងទៅធនាគារដើម្បីសុំខ្ចីប្រាក់ ប៉ុន្តែ ធនាគារមិនបានយល់ព្រមនោះទេ ។ ក្រោយពីការពិចារណាយ៉ាងយូរ គាត់ក៏បានសម្រេចចិត្តលក់តម្រង់នោមរបស់គាត់មួយចំហៀងក្នុងតម្លៃ ៥.000 ដុល្លារអាមេរិក ឱ្យទៅអ្នកជ្បែរខាងរបស់គាត់ ឈ្មោះ ដូរ៉ង់ ដែលគាត់កំពុងតែរង់ចាំព្យាបាល ។ ការព្យាបាលនោះត្រូវបានធ្វើឡើងកាលពីសប្តាហ៍មុន ប៉ុន្តែ លោក ដូរ៉ង់ បានប្រាប់ថា គាត់គ្មានបំណងបង់ប្រាក់តាមអ្វីដែលមានចែងក្នុងកិច្ចសន្យានោះទេ ។ លោក ដុយប៉ុង បាន មកសាកសួរយោបល់ពីអ្នកថា តើអាចជួយរកដំណោះស្រាយចំពោះការលំបាករបស់គាត់ដែរ ឬទេ ?

២. កិច្ចណែនាំហាត់ (នីកូឡាវីយ៉ាស)

លោក ដុយប៉ុង មានអាយុ ៥០ ឆ្នាំ ជាប្រធានក្រុមហ៊ុនមួយ ។ គាត់បានចុះកិច្ចសន្យាមួយ ដើម្បីផ្លាស់ប្តូរសំភារៈផលិតកម្មរបស់ខ្លួនសាជាថ្មី ។ ដោយមានការភ័ន្តច្រឡំទៅលើតម្លៃនៃទំនិញដែលបានទិញ និងដោយត្រូវទទួលរងការបោកបន្លំទៅលើចរិតលក្ខណៈបច្ចេកទេស កិច្ចសន្យាមិនបានផ្តល់ភាពពេញចិត្តដល់គាត់នោះទេ ។ ម្យ៉ាងវិញទៀត គាត់បានលក់តម្រង់នោមរបស់គាត់មួយចំហៀងក្នុងតម្លៃ ៥.000 ដុល្លារអាមេរិក ។ ការវះកាត់ព្យាបាលតម្រង់នោមត្រូវបានធ្វើឡើង តែអ្នកទិញបានបដិសេធមិនព្រមបង់ប្រាក់ទេ ។ ដើម្បីព្យាយាមរកដំណោះស្រាយជម្លោះរបស់លោក ដុយប៉ុង យើងត្រូវកំណត់មូលដ្ឋានគតិយុត្តថា តើគាត់អាចរួចផុតពីកិច្ចសន្យាទិញដែលបានចុះជាមួយក្រុមហ៊ុន អ៊ិច ហើយគាត់អាចទទួលបានការបង់ប្រាក់ចំនួន ៥.000 ដុល្លារអាមរិកដោយ លោក ដូរ៉ង់ ដែរឬទេ ?

I. មធ្យោបាយដែលអនុញ្ញាតឱ្យលោក ដុយប៉ុង រួចផុតពីកិច្ចសន្យាទិញដែលគាត់បានចុះជាមួយក្រុមហ៊ុន (អ៊ិច) :

(បដិញ្ញាធំ) : យោងតាមមាត្រា ៤ នៃក្រឹត្យ-ច្បាប់លេខ ៣៨ ចុះថ្ងៃទី ២៨-១០-១៩៨៨ ការតាក់តែងកិច្ចសន្យាជាលិខិតលាយល័ក្ខណ៍អក្សរ គឺជាលក្ខខណ្ឌទម្រង់មួយដែលតម្រូវចំពោះកិច្ចសន្យាទាំងអស់ដែលមានតម្លៃជាប្រាក់ចាប់ពី ៥.000 រៀលឡើងទៅ ។

Scanned with CamScanner

(បដិញ្ញាតូច) : នៅក្នុងអង្គហេតុ កិច្ចសន្យាមានតម្លៃជាប្រាក់លើសពី ៥.000 រៀល ដោយហេតុថា តម្លៃសរុបគឺ ៧.000 ដុល្លារអាមេរិក ។ លក្ខខណ្ឌនេះត្រូវបានគោរពតាម នៅពេលដែលលោក ដុយប៉ុង បានអានខ្លឹមសារនៃកិច្ចសន្យាសាជាថ្មីឡើងវិញ ។

(សន្និដ្ឋាន) : ហេតុដូច្នេះ ការលើកឡើងនូវមធ្យោបាយខាងលើនេះ ពុំអាចធ្វើឱ្យមានការប្រកាសមោឃភាពនៃកិច្ចសន្យាទេ ។

ក. លក្ខខណ្ឌជាគ្រឹះ

លក្ខខណ្ឌជាគ្រឹះ មានចែងក្នុងមាត្រា ៣, ១១ និង១២ នៃក្រឹត្យ-ច្បាប់លេខ ៣៨ ចុះថ្ងៃទី ២៨-១០-១៩៨៨ ។ លក្ខខណ្ឌទាំងនេះមានលក្ខណៈខុសគ្នាជាច្រើន ដែលយើងត្រូវពិនិត្យលើករណីនិមួយៗ ។

១. លក្ខខណ្ឌដែលចែងក្នុងមាត្រា ៣ នៃក្រឹត្យ-ច្បាប់លេខ ៣៨ :

លក្ខខណ្ឌជាគ្រឹះដែលមានចែងក្នុងមាត្រា ៣ នៃក្រឹត្យ-ច្បាប់លេខ ៣៨ កំណត់ថា កិច្ចសន្យាត្រូវបានបង្កើតដោយការបង្ហាញឆន្ទៈសើរ ពិតប្រាកដ, គូភាគីត្រូវមានសមត្ថភាពក្នុងការបង្កើតកិច្ចសន្យា ហើយកិច្ចសន្យាត្រូវមានកម្ម-វត្ថុស្របច្បាប់ និងច្បាស់លាស់ ។ ក្នុងចំណោមលក្ខខណ្ឌទាំងនេះ យើងឃើញថា លក្ខខណ្ឌទាំងពីរចុងក្រោយ ពុំបានចោទជាផលវិបាកអ្វីនោះទេ ។ លោក ដុយប៉ុង មានអាយុ ៥០ ឆ្នាំ គាត់មានសមត្ថភាពក្នុងការចុះកិច្ចសន្យា យោងតាមមាត្រា ១៤ នៃក្រឹត្យ-ច្បាប់លេខ ៣៨ ។ ម៉្យាងវិញទៀត កម្មវត្ថុនៃកិច្ចសន្យា គឺការលក់ម៉ាស៊ីនដេរចំនួន ៥០ គ្រឿង ។ ប៉ុន្តែការបង្ហាញឆន្ទៈរបស់គូភាគីទាំងសងខាង អាចចោទជាផលលំបាកកើតឡើង ហើយត្រូវធ្វើការពិភាក្សា ។ យោងតាមមាត្រា ៧ នៃក្រឹត្យ-ច្បាប់លេខ ៣៨ ត្រូវបានចាត់ទុកជាវិការៈនៃការបង្ហាញឆន្ទៈ ប្រសិនបើការបង្ហាញឆន្ទៈនេះភ្ជាប់ជាមួយនូវការភ័ន្តច្រឡំ ការបន្លំ ឬការប្រើអំពើហិង្សា ។ ស្របតាមអង្គហេតុ មានវិការៈនៃការបង្ហាញឆន្ទៈពីរយ៉ាង អាចត្រូវបានលើកឡើងគឺ ការភ័ន្តច្រឡំ និងការបន្លំ ។

១.១. ការភ័ន្តច្រឡំ

(បដិញ្ញាធំ) : ការភ័ន្តច្រឡំ គឺជាវិការៈនៃការបង្ហាញឆន្ទៈ ជាការបង្ហាញនូវស្ថានភាពជាក់ស្តែងដែលមានលក្ខណៈមិនពិតប្រាកដ ។ ប៉ុន្តែ ការភ័ន្តអាចត្រូវបានចាត់ទុកជាមូលហេតុនៃការប្រកាសមោឃភាព ក្នុងករណីដែលវាត្រូវបានធ្វើឡើងដូចមានចែងក្នុងមាត្រា ៨ នៃក្រឹត្យ-ច្បាប់លេខ ៣៨ ទាក់ទងនឹងធម្មជាតិ ឬគុណភាពនៃវត្ថុ ។

(បដិញ្ញាតូច) : នៅក្នុងអង្គហេតុ ការភ័ន្តច្រឡំពុំមានការពាក់ព័ន្ធនឹងវត្ថុនោះទេ តែមានការភ័ន្តច្រឡំលើតម្លៃទៅវិញ ។ លោក ដុយប៉ុង ជឿជាក់ថា ម៉ាស៊ីនដេរចំនួន ១០ គ្រឿង មានតម្លៃ ៧០០ ដុល្លារអាមេរិក តែតាមពិត ជាតម្លៃនៃម៉ាស៊ីនដេរមួយគ្រឿងប៉ុណ្ណោះ ។

(សន្និដ្ឋាន) : ដូច្នេះ ការភ័ន្តច្រឡំពុំអាចត្រូវបានលើកឡើងធ្វើជាមូលហេតុនៃការប្រកាសមោឃភាពនៃកិច្ចសន្យាបាននោះទេ ។ ចុះចំណែកការបន្លំវិញ ?

១.២. ការបន្លំ :

Scanned with CamScanner

(បដិញ្ញាធំ) : យោងតាមមាត្រា ១០ នៃក្រឹត្យ-ច្បាប់លេខ ៣៨ ការបន្លំបោកប្រាស់ គឺជាមូលហេតុមួយនៃការប្រកាសមោឃភាពកិច្ចសន្យា កាលណាមានឧបាយកលបោកបញ្ឆោត អំពើបន្លំភូតភរប្រព្រឹត្តដោយភាគីណាមួយដែលជាហេតុបញ្ជាក់ច្បាស់ថា បើគ្មានកិច្ចកលទាំងនោះទេ ភាគីម្ខាងទៀតប្រាកដជាមិនធ្វើកិច្ចសន្យានោះឡើយ ។ យើងអាចនិយាយម៉្យាងទៀតថា ការបន្លំតែឯងគ្មានចរិតលក្ខណៈនាំឱ្យមានការប្រកាសមោឃភាពនៃកិច្ចសន្យានោះទេ ។ ការបន្លំ ត្រូវតែចាត់ទុកជាធាតុផ្សំមួយយ៉ាងសំខាន់ មានន័យថា ប្រសិនបើគ្មានការបន្លំនោះទេ ភាគីម្ខាងនៃកិច្ចសន្យានឹងមិនចុះកិច្ចសន្យានោះទេ ។

(បដិញ្ញាតូច) : យោងតាមអង្គហេតុ ក្រុមហ៊ុន អ៊ិច បានកែប្រែខ្លឹមសារនៃកិច្ចសន្យាដែលត្រូវប្រគល់ឱ្យទៅលោក ដុយប៉ុង និងកែប្រែខ្លឹមសារដែលកំណត់អំពីស្ថានភាពនៃទំនិញដែលត្រូវលក់ ។ កិច្ចកលទាំងនេះត្រូវបានប្រើប្រាស់ ដើម្បីឱ្យអ្នកទិញ ជឿជាក់ថា ម៉ាស៊ីនដេរទាំងនោះពិតជាមានគុណភាព និងលក្ខណៈបច្ចេកទេសល្អពិតប្រាកដមែន ។ ទាំងធាតុសំការៈ និងធាតុសត្យានុម័តនៃការបន្លំត្រូវបានបំពេញ ។ ការបន្លំនេះមានលក្ខណៈយ៉ាងច្បាស់ ដោយហេតុថា បើសិនជាលោក ដុយប៉ុង បានដឹងអំពីស្ថានភាព និងគុណភាពនៃទំនិញនោះពិតប្រាកដ គាត់នឹងមិនទិញនូវទំនិញទាំងនោះទេ ហើយគោលបំណងរបស់គាត់ គឺយកម៉ាស៊ីនទាំងនោះទៅបង្កើនសមត្ថភាពផលិតកម្មនៃក្រុមហ៊ុនរបស់គាត់ ។

(សន្និដ្ឋាន) : ដូច្នេះ លក្ខខណ្ឌនៃការបន្លំត្រូវបានបំពេញ ហើយអាចត្រូវបានលើកឡើង ដើម្បីធ្វើជាមូលហេតុនៃការប្តឹងប្រកាសមោឃភាពនៃកិច្ចសន្យាដែលធ្វើជាមួយក្រុមហ៊ុន អ៊ិច នោះបាន ។

២. លក្ខខណ្ឌដែលមានចែងក្នុងមាត្រា ១១ នៃក្រឹត្យ-ច្បាប់លេខ ៣៨

(បដិញ្ញាធំ) : អនុលោមតាមមាត្រា ១១ នៃក្រឹត្យ-ច្បាប់លេខ ៣៨ នៅពេលចុះកិច្ចសន្យា បើភាគីម្ខាងឆ្លៀតទាញយកផលចំណេញពីស្ថានភាពរបស់ភាគីម្ខាងទៀត ធ្វើកិច្ចសន្យាដោយមានផលចំណេញច្រើនមិនសមស្របមកលើខ្លួន ភាគីរងគ្រោះ អាចប្តឹងបដិសេធកិច្ចសន្យានោះបានជានិច្ច ។

(បដិញ្ញាតូច) : យើងឃើញថាស្ថានភាពនេះមិនត្រូវបានចោទឡើងចំពោះអង្គហេតុនោះទេ ។

(សន្និដ្ឋាន) : មូលហេតុនេះមិនអាចធ្វើជាមូលដ្ឋាននៃការប្រកាសមោឃភាពកិច្ចសន្យាបានទេ ។

៣. លក្ខខណ្ឌ ដែលមានចែងក្នុងមាត្រា ១២ នៃក្រឹត្យ-ច្បាប់លេខ ៣៨

(បដិញ្ញាធំ): ចុងបញ្ចប់ ស្របតាមមាត្រា ១២ នៃក្រឹត្យ-ច្បាប់លេខ ៣៨ កិច្ចសន្យាមិនត្រូវមានភាពខុសគ្នាមិនសមស្របរវាងតម្លៃនៃតាវកាលិក និងតម្លៃនៃតាវកាលិកតបវិញ ភាគីរងគ្រោះអាចប្តឹងបដិសេធកិច្ចសន្យានោះបាន ក្នុងលក្ខណៈដែលខ្លួនពុំមានបំណងធ្វើអំណោយនោះទេ ។

(បដិញ្ញាតូច): នៅក្នុងអង្គហេតុ អតុល្យភាពនៃតាវកាលិករវាងលោក ដុយប៉ុង និងក្រុម ហ៊ុន អ៊ិច ត្រូវបានបង្កើតឡើងព្រោះថា លោក ដុយប៉ុង ភ្ជាប់កាតព្វកិច្ចបង់ប្រាក់ចំនួន ៧.000 ដុល្លារអាមេរិក ដែលឆ្លើយតបទៅនឹងម៉ាស៊ីនដេរចំនួន ១០ គ្រឿង។ ប៉ុន្តែ នៅលើទីផ្សារនៅទីក្រុងភ្នំពេញ ម៉ាស៊ីនដេរមួយគ្រឿងមានតម្លៃជាមធ្យមត្រឹមតែ ១00 ដុល្លារអាមេរិកប៉ុណ្ណោះ។

Scanned with CamScanner

(**សន្និដ្ឋាន**) : លោក ដុយប៉ុង អាចលើកឡើងពីអុតល្យភាពនេះ ដើម្បីទទួលបានការប្រកាសមោឃភាពកិច្ចសន្យាបាន ។

(**សន្និដ្ឋានទូទៅ**) : ដូច្នេះ លោក ដុយប៉ុង អាចមានសង្ឃឹមទទួលបានការប្រកាសមោឃភាព តាមរយៈការលើកឡើងការបន្ទំ ឬអតុល្យភាពនៃតាវកាលិក ។ តាមពិត របបគតិយុត្តពិតប្រាកដ ដោយយោងទៅលើមូលដ្ឋានគតិយុត្តចុងក្រោយនេះ មានលក្ខណៈមិនសូវច្បាស់នោះទេ ព្រោះថា គ្មានអត្ថបទណាមួយចែងបញ្ជាក់អំពីលទ្ធភាពនោះទេ ។ ចំណែកពាក្យបណ្តឹង ប្រកាសមោឃភាព ដោយយោងទៅលើការបន្ទំមានលក្ខណៈមួយច្បាស់លាស់ជាង ។ ដោយយោងតាមមាត្រា ១៩ វាក្យខណ្ឌទី ១-២ នៃក្រឹត្យ-ច្បាប់លេខ ៣៨ លោក ដុយប៉ុង ត្រូវជូនដំណឹងអំពីការប្រកាសមោយ-ភាពទៅក្រុមហ៊ុន អ៊ិច ។ អានុភាពប្រតិសកម្មនៃការប្រកាសមោឃភាពអនុញ្ញាតឱ្យលោក ដុយប៉ុង ទទួលបាននូវភាពពេញចិត្ត : គាត់ទទួលបានការសងប្រាក់ត្រលប់មកវិញក្នុងចំនួន ៧.000 ដុល្លារអាមេរិក ហើយគាត់ត្រូវសងម៉ាស៊ីនដេរចំនួន ១០ គ្រឿង ឱ្យទៅក្រុមហ៊ុន អ៊ិច វិញ ។ បន្ទាប់មកទៀត យើងពិនិត្យអំពីមូលដ្ឋានគតិយុត្តជាបន្ត ដើម្បីឱ្យលោក ដុយប៉ុង ទទួលបាននូវចំនួនទឹកប្រាក់ ដែលគាត់យល់ថា គាត់ជាម្ចាស់បំណុលរបស់លោក ដូរ៉ង់ ។

II. មូលដ្ឋានគតិយុត្តដើម្បីទទួលបានប្រាក់ ៥.000 ដុល្លារអាមេរិក ពីលោក ដូរ៉ង់ :

(**បដិញ្ញាធំ**) : យោងតាមមាត្រា ៣៤ នៃក្រឹត្យ-ច្បាប់លេខ ៣៨ កិច្ចសន្យាលក់ គឺជាកិច្ចសន្យាមួយ ដែលបុគ្គលម្នាក់មានកាតព្វកិច្ចផ្ទេរកម្មសិទ្ធិនៃវត្ថុមួយឱ្យទៅបុគ្គលម្នាក់ទៀត ដែលបុគ្គលនេះមានកាតព្វកិច្ចត្រូវប្រគល់ប្រាក់ថ្លៃវត្ថុ ឬសិទ្ធិនោះមកវិញ។ ចំណែកឯ មាត្រា ៥៤ វាក្យខណ្ឌទី ១ នៃច្បាប់ដដែល បញ្ជាក្តថា បើដល់ថ្ងៃសន្នតហើយ អ្នកទិញពុំបានបង់ថ្លៃ អ្នកលក់អាចសុំរំលាយការលក់នោះវិញបាន ប្រសិនបើអ្នកលក់មិនចង់ប្តឹងទារថ្លៃនោះទេ ។ ក៏ប៉ុន្តែ មុននឹងកិច្ច-សន្យាអាចធ្វើ ជាកម្មវត្ថុការអនុវត្តដោយបង្ខំបាន លុះណាតែកិច្ចសន្យានោះត្រូវបានបង្កើតឡើងដោយមានសុពលភាព ។ កិច្ចសន្យាលក់ ពុំត្រឹមតែគោរពតាមបទប្បញ្ញត្តិពិសេសដែលមានចែងក្នុងផ្នែកទី ១ នៃជំពូក ២ "*កិច្ចសន្យាពិសេស*" នៃក្រឹត្យ-ច្បាប់លេខ ៣៨ ប៉ុណ្ណោះទេ តែកិច្ចសន្យាក៏ត្រូវគោរពបទប្បញ្ញត្តិទូទៅដែលមានចែងក្នុងក្រឹត្យ-ច្បាប់លេខ ៣៨ ផងដែរ ។ កិច្ចសន្យានោះ ត្រូវតែគោរពតាមលក្ខខណ្ឌនៃការបង្កើតកិច្ចសន្យាដែលមានចែងក្នុងមាត្រា ៣, ៤, ៥, ១១ និង១២ នៃក្រឹត្យ-ច្បាប់លេខ ៣៨ ។ យោងតាមមាត្រា ៣ វាក្យខណ្ឌទី ៣ នៃក្រឹត្យ-ច្បាប់ លេខ ៣៨ កម្មវត្ថុនៃកិច្ច-សន្យាត្រូវតែពិតប្រាកដ ស្របច្បាប់ ស្របរបៀបរៀបរយសាធារណៈ និងទំនៀមទំលាប់ល្អរបស់សង្គម ។ លើសពីនេះទៀត ស្របតាមមាត្រា ១៧ នៃក្រឹត្យ-ច្បាប់លេខ ៣៨ កម្មវត្ថុនៃកិច្ចសន្យាត្រូវបានចាត់ទុកថាខុសច្បាប់ នៅពេលដែលកិច្ចសន្យានោះមានវត្ថុស្ថិតនៅក្រៅវិស័យពាណិជ្ជកម្ម ។

(**បដិញ្ញាតូច**) : នៅក្នុងអង្គហេតុ លោក ដុយប៉ុង អាចលើកឡើងនូវកិច្ចសន្យាដែលត្រូវបានបង្កើតឡើងជាមួយលោក ដូរ៉ង់ ។ តាមពិត គាត់បានលក់តម្រង់នោមរបស់គាត់ ជាថ្នូរមកវិញនូវការបង់ប្រាក់ ។ ប៉ុន្តែ វត្ថុដែលជាកម្មវត្ថុនៃកាតព្វ-កិច្ច គឺជាតម្រង់នោម មានន័យថា ជាចំណែកមួយនៃសារពាង្គកាយរបស់មនុស្ស ។ វត្ថុនេះមិនស្ថិតនៅក្នុងវិស័យពាណិជ្ជកម្ម នោះទេ ។

(**សន្និដ្ឋាន**) : ដើម្បីទទួលបានការបង់ប្រាក់ចំនួន ៥.000 ដុល្លារអាមេរិក លោក ដុយប៉ុង ពុំអាចលើកឡើងដោយជោគជ័យនូវមាត្រា ៥៤ វាក្យខណ្ឌទី ១ នៃក្រឹត្យ-ច្បាប់លេខ ៣៨ នេះទេ ។ តែការលើកឡើងអំពីកម្មវត្ថុមិនស្របច្បាប់នៃ

Scanned with CamScanner

កិច្ចសន្យា អាចមានលក្ខណៈគ្រប់គ្រាន់ ដើម្បីឱ្យលោក ដុយប៉ុង អាចទទួលបាននូវការប្រកាសមោឃភាពនៃកិច្ចសន្យានោះ ។ ការប្រកាសមោឃភាពនៃកិច្ចសន្យានេះមានលក្ខណៈដាច់ខាត (មាត្រា ៥ នៃក្រឹត្យ-ច្បាប់លេខ ៣៨) ។ បុគ្គលទាំងអស់អាចលើកឡើងបានគ្រប់ពេលវេលាទាំងអស់ (មាត្រា ១៨ នៃក្រឹតនក្រឹត្យ-ច្បាប់លេខ ៣៨) ។ នៅពេលដែលកិច្ចសន្យានោះ ត្រូវបានប្រកាសមោឃភាព ស្ថានភាពទាំងឡាយដែលកើតឡើងត្រូវត្រលប់មករកភាពដើមវិញ ដូចមុនពេលចុះកិច្ចសន្យា មានន័យថា លោក ដុយប៉ុង ពុំត្រូវបានចាត់ទុកជាម្ចាស់បំណុលរបស់លោក ដូរ៉ង់ ដែលពុំព្រមបង់ប្រាក់នោះទេ ។ ហេតុដូច្នេះ លោក ដុយប៉ុង គ្មានមធ្យោបាយគតិយុត្តណាមួយ ដើម្បីបានប្រាក់ចំនួន ៥.០០០ ដុល្លារអាមេរិកដែលគាត់ធ្លាប់គិតថា ជាម្ចាស់បំណុលចំពោះលោក ដូរ៉ង់ នោះទេ ។ ប៉ុន្តែ ឆ្លើយតបនឹងបញ្ហានេះ តម្រង់នោមរបស់លោក ដុយ ប៉ុង ត្រូវសងត្រលប់ទៅគាត់វិញ ។ បើសិនជាការសងនោះមិនអាចត្រូវបានធ្វើឡើងនោះទេ ការសងអាចនឹងត្រូវបានធ្វើឡើងជាសាច់ប្រាក់ដែលមានតម្លៃស្មើ ។

(សន្និដ្ឋានខ្ទង់ទៅ) :

-ក្នុងករណីទី ១ : ជាមួយនឹងក្រុមហ៊ុន អ៊ិច. លោក ដុយប៉ុង អាចធ្វើការទាមទារចំនួនទឹកប្រាក់របស់គាត់ត្រលប់មកវិញតាមរយៈមូលដ្ឋាននៃការប្តឹងប្រកាសមោឃភាពកិច្ចសន្យា ដែលធ្វើឡើងដោយមានការបន្ទំ ។

-ចំណែកករណីទី ២ : ជាមួយនឹងលោក ដូរ៉ង់. លោក ដុយប៉ុង ដើម្បីទាមទារនូវការបង់ប្រាក់ពីលោក ដូរ៉ង ត្រូវប្តឹងប្រកាស មោឃភាពកិច្ចសន្យា ដោយមូលហេតុថា កម្មវត្ថុនៃកិច្ចសន្យានោះមិនស្ថិតនៅក្នុងវិស័យធ្វើជំនួញពាណិជ្ជកម្ម ។

ខ. នីតិកាណិជ្ជកម្ម

១. អង្គហេតុ

លោក សុខ សុគន្ធ មានអាយុ ៣៥ ឆ្នាំ បានទិញផ្ទះមួយខ្នងដែលមានទីតាំងល្អសំរាប់រកស៊ី នៅថ្ងៃទី ២០-០២-២០០៤ ។ ដោយសារចំណេះខាងជាងឈើដែលឪពុកគាត់ចែកឱ្យ គាត់មានបំណងចង់បើករោងជាងមួយក្នុងផ្ទះនេះ ដើម្បីផលិត តុ ទូ បង្ខូច កៅអី ទ្វារ និងសិង្ហារិមផ្សេងៗទៀតធ្វើអំពីឈើ ។ តែដោយយោលទៅលើតម្រូវការនាពេលបច្ចុប្បន្ន គាត់ ចង់លក់ទាំងផលិតផលគាត់ផលិតខ្លួនឯងដោយមានជំនួយពីកម្មករ ០៨ រូបផង. ទាំងគ្រឿងសិង្ហារិមអំពីដែរ និងអាលុយ-មីញ៉ូមដែលគាត់បញ្ជារទិញពីប្រទេសជិតខាងផង ។ ដូចនេះទើបគាត់មកជួបអ្នក ដើម្បីចង់ដឹងថាតើសំណុំបែបបទរដ្ឋបាលអ្វីខ្លះដែលគាត់ត្រូវបំពេញ ដើម្បីឱ្យគាត់អាចប្រកបអាជីវកម្មរបស់គាត់ត្រឹមត្រូវតាមផ្លូវច្បាប់ ។

២. កិច្ចការ : (លោក ស៊ុម សុខអ្ង)

លោក សុខ សុគន្ធ មានបំណងចង់បើករោងជាងមួយដែលមានជំនាញក្នុងការផលិតនូវគ្រឿងសង្ហារិមធ្វើអំពីឈើ ។ ម៉្យាងវិញទៀត គាត់លក់គ្រឿងសិង្ហារិមធ្វើអំពីដែរ និងអំពីអាលុយមីញ៉ូមផងដែរ ។ ដើម្បីផ្តល់ចម្លើយត្រឹមត្រូវដល់លោក សុខ សុគន្ធ ជាការចាំបាច់ដែលយើងត្រូវស្គាល់ជាបឋមថា តើលក្ខន្តិកៈគតិយុត្តពិតប្រាកដ[១១៨]របស់គាត់ជាអ្វី

[១១៨] គួរកត់សំគាល់ថា ការស្វែងរកឱ្យឃើញនូវលក្ខន្តិកគតិយុត្តរបស់ពាណិជ្ជករ និងវិជ្ជាជីវៈដទៃទៀត នៅតែជាបញ្ហាដែលគួរឱ្យចាប់អារម្មណ៍ ដោយហេតុថា ទីតាំងជ្ជមានៃព្រះរាជាណាចក្រកម្ពុជាមិនទាន់បានដោះស្រាយឱ្យបានដាច់ស្រឡះ ដូចសំណើរបស់លោក ខែក ភារី រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម

Scanned with CamScanner

ធ្យើបទៅនឹងសកម្មភាពអាជីវកម្មនាពេលអនាគតដែលគាត់បំរុងនិងប្រកប (១) ។ ការវែកញែកលក្ខន្តិកៈគតិយុត្ត ដើម្បីអនុញ្ញាតឱ្យ គាត់អាចប្រកបអាជីវកម្មដោយស្របច្បាប់ តម្រូវឱ្យយើងពិនិត្យផងដែរ ដោយខានមិនបានទូវផល វិបាកនានាដែលកើតចេញដោយផ្ទាល់ ឬដោយប្រយោលអំពីលក្ខន្តិកៈនោះ (២) ។ ចំណោទបញ្ហាទាំងពីរនេះ នឹងត្រូវលើក យកមកសិក្សាជាបន្តបន្ទាប់ ។

១. លក្ខន្តិកៈគតិយុត្តិរបស់លោក សុខ សុគន្ធ :

គួររំឭកថា ការជ្រើសរើសត្រឹមតែបរជាជាងឈើ ធ្វើឱ្យយើងនឹកភ្ជាកភ្ជាមដល់វិជ្ជាជីវៈជាសិប្បករ(ក) ។ ក៏ប៉ុន្តែ ស្ថានភាពរបស់លោក សុខ សុគន្ធ ធ្វើឱ្យយើងសុគស្ញាញ ដោយសារតែគាត់មិនត្រឹមតែលក់គ្រឿងសិង្ហារឹមដែលគាត់ផលិត ខ្លួនឯងប៉ុណ្ណោះទេ តែថែមទាំងលក់សិង្ហារឹមដែលគាត់នាំចូលពីបរទេសទៀតផង ។ សកម្មភាពបែបនេះ នាំឱ្យយើងត្រូវ តែពិនិត្យជាបន្ទាប់ដោយស្ងប់ប្រវត្តិ លើលក្ខន្តិកៈជាពាណិជ្ជករ (ខ) ។

ក. លក្ខន្តិក :ជាសិប្បករ :

ជាដំបូង សំណួរត្រូវបានចោទឡើងថា តើលោក សុខ សុគន្ធ ប្រកបវិជ្ជាជីវៈជាសិប្បករ ដែរឬទេ ?

(**បដិញ្ញាធំ**) : អនុលោមតាមបញ្ញត្តិនៃមាត្រា ៧ វាក្យខណ្ឌទី ១ នៃច្បាប់ការងារឆ្នាំ ១៩៩៧ សញ្ញាណនៃសិប្បករត្រូវ បានគេឱ្យនិយមន័យថា ជាបុគ្គលដែលធ្វើរបរហត្ថកម្មផ្ទាល់ខ្លួនហើយជាប្រយោជន៍ខ្លួនឯង ទោះនៅនឹងផ្ទះខ្លួនក្តី នៅក្រៅ ក្តី មានប្រើកំលាំងយន្តដែលជាម៉ាស៊ីនស្ងប់ប្រវត្តិក្តី គ្មានក្តី មានបើកផ្ទះដាក់សញ្ញាក្តី គ្មានក្តី ។ នីតិករបានបញ្ជាក់បន្ថែម ទៀត តាមរយៈមាត្រាដដែលនេះថា សិប្បករច្រើនតែលក់ផលិតផលនៃការងាររបស់ខ្លួនផ្ទាល់ ដែលធ្វើម្នាក់ឯងក្តី មានប្តីឬ ប្រពន្ធ និងសមាជិកនានានៃគ្រួសារដែលធ្វើការមិនយកប្រាក់ឈ្នួលក្តី ព្រមទាំងកម្មករ ឬកូនជាងជួយផងក្តី ប៉ុន្តែ ត្រូវឱ្យ រោងជាងទាំងមូលស្ថិតនៅក្រោមការដឹកនាំរបស់ខ្លួនតែម្នាក់ឯង ។ មាត្រា ៧ វាក្យខណ្ឌទី ២ នៃច្បាប់ដដែល[១១៩] បានរក្សាទុកលក្ខន្តិកៈជាសិប្បករចំពោះតែបុគ្គលណា ដែលចិញ្ចឹមជីវិតដោយសារការងារហត្ថកម្មផ្ទាល់របស់គាត់ប៉ុណ្ណោះ ហើយដែលប្រើកម្មករមិនលើសពី ០៧ នាក់ ។ គំនិតនេះចង់ លើកឡើងថា សិប្បកម្ម គឺជាសកម្មភាពទាំងឡាយណា ដែលប្រាស់ចាកពីរាល់គំនិតបរិកប្ប (កេងចំណេញ ឬកេងយកកម្រៃ) ទាំងលើកំលាំងពលកម្មរបស់អ្នកដទៃ ក៏ដូចលើវត្ថុ ធាតុដើម ឬសម្ភារៈ ។ មាត្រាដដែលនេះក៏បានបន្ថែមទៀតថា នៅពេលដែលគាត់ប្រើកម្មកររលើសពី ០៧ នាក់ គាត់នឹង បាត់ដោយស្ងប់ប្រវត្តិនូវលក្ខន្តិកៈ របស់គាត់ជាសិប្បករ ។

ដែលបានពោល ឡើងថា : "*អង្គការក្រៅរដ្ឋាភិបាល និងក្រុមហ៊ុនតូច១ អាចទទួលបានវិញ្ញាបនបត្រប្រកពដើមនៃទំនិញ ដោយពុំមានចំនួនកំណត់នៃប្រាក់ មូលធនឡើយ ។ ពួកគេត្រូវការចុះបញ្ជីនៅក្រសួង ប៉ុន្តែមិនមែនក្នុងនាមក្រុមហ៊ុនទេ ។ លោកបានបន្ថែមទៀតថា មនុស្សមួយចំនួននៅក្នុងក្រសួងរបស់ខ្ញុំ មិនយល់អំពីនីតិវិធីនេះ*"។ រីឯមន្ត្រីមួយចំនួនបានមានប្រសាសន៍ថា : " ដើម្បីទទួលបាន វិញ្ញាបនបត្រប្រភពដើមនៃទំនិញ ក្រុមហ៊ុនត្រូវតែចុះបញ្ជីនៅក្រម ប្រឹក្សាសំរាប់អភិវឌ្ឍន៍កម្ពុជា ដោយមានមូលធនចំនួន ១ លានដុល្លារ" ។ ដកស្រង់ពី ឱ ឃែមបុឌា ដេលី ថ្ងៃសុក្រ ទី ១៥-០៣-២០០៤ ដែលមានចំលងជើងថា : "*ក្រុមសិប្បករនិយាយថា ដំណើរការនៃអាជ្ញាបណ្ណ័នាំចេញពោរពេញទៅដោយសំណុក*" ។

[១១៩] មាត្រា ៧ បច្ចឹមវាក្យខណ្ឌនៃច្បាប់ការងារ ១៩៩៧ បានចែងថា : "កម្មករក្រៅពីគ្រួសារដែលធ្វើការជានិច្ចកាលដោយសិប្បករមិនអាចមានចំនួនច្រើនជាង ៧ នាក់បានទេ បើលើសពី ៧ នាក់និយោជកនេះបាត់លក្ខណៈជាសិប្បករ" ។

Scanned with CamScanner

(បដិញ្ញាតូច) : ក្នុងរឿងរបស់យើង លោក សុខ សុគន្ធ មានបំណងចង់ផលិតគ្រឿងសង្ហារិមធ្វើអំពីឈើ ដូចជា គ្រែ ឬ កៅអីឈើ.... ។ ផលិតផលទាំងនេះគឺជាលទ្ធផលនៃការងារហត្ថកម្មរបស់លោក សុខ សុគន្ធ ដែលគាត់បានបំពេញ ដើម្បីផលប្រយោជន៍របស់គាត់ ។ គ្រាន់តែថា គាត់បំពេញការងារ ដោយមានជំនួយពីកម្មករចំនួន ០៨ នាក់ផ្សេងទៀតប៉ុណ្ណោះ ។

(សន្និដ្ឋាន) : ដូច្នេះ លោក សុខ សុគន្ធ មិនអាចទទួលបានលក្ខន្តិកៈ ឬគុណភាពជាសិប្បករបានទេ ព្រោះថា គាត់ប្រើកម្មកររហូតដល់ ០៨ នាក់ ដើម្បីជួយការងាររបស់គាត់ ។ បញ្ហាដែលកើតឡើងក្នុងខណៈនេះគឺថា តើលក្ខន្តិកៈគតិយុត្តពិតប្រាកដរបស់គាត់ជាអ្វី ? បើតាមការពិនិត្យមើលលើអង្គហេតុទាំងអស់ដែលគាត់បានលើកបង្ហាញ បានស្តែងអោយឃើញនូវដាននានា ដែលនាំយើងឱ្យធ្វើការពិចារណាលើសញ្ញាណគតិយុត្តនៃពាណិជ្ជករ ។

ខ. លក្ខន្តិក:ជាពាណិជ្ជករ :

(បដិញ្ញាធំ): មាត្រា ១ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ចុះថ្ងៃទី ២៦-០៦-១៩៩៥ ដែលត្រូវបានធ្វើវិសោធនកម្មនៅថ្ងៃ ១៨-១១-១៩៩៩[120] បានអោយនិយមន័យលើសញ្ញាណពាណិជ្ជករថា ជារូបវន្តបុគ្គល ឬនីតិបុគ្គលដែលប្រកបពាណិជ្ជកិច្ច ហើយដែលយកពាណិជ្ជកិច្ចនេះជាមុខរបរខ្លួនជាប្រចាំ។ ដូចនេះ ការផ្តល់និយមន័យលើវាក្យស័ព្ទ "ពាណិជ្ជករ" ត្រូវផ្អែកទាំងស្រុងលើនិយមន័យនៃពាណិជ្ជកិច្ច ។ ចុះអ្វីទៅជាពាណិជ្ជកិច្ច ?

ដើម្បីបំភ្លឺលើបញ្ហានេះ នីតិកររបានចូលខ្លួនសាជាថ្មី តាមរយៈការបន្ថែមវាក្យខណ្ឌទី ២ ដល់មាត្រាខាងលើដោយបានចែងថា : " ពាណិជ្ជកិច្ច ជាសកម្មភាពទិញ លក់ចំនិញ ឬសេវា ដែលត្រូវបានអនុវត្តជាប្រចាំក្នុងគោលដៅដោះដូរ និងស្វែងរកចំណេញ[121] ។ អំណាននៃបញ្ញត្តិទាំងអស់នេះ អនុញ្ញាតអោយយើងនិយាយបានថា ចាត់ទុកជាពាណិជ្ជកិច្ច :

១. រាល់សកម្មភាពទិញចំនិញ ឬសេវា ដើម្បីធ្វើការលក់ទៅវិញ ទោះក្នុងសភាពដើមក្តី ឬក្រោយការកែប្រែក្តី ។

២. ហើយសកម្មភាពនោះត្រូវតែអនុវត្តន៍ជាទៀងទាត់ ជាប្រចាំ ពោលគឺមិនមែនធ្វើឡើងម្តងម្កាលនោះទេ ផ្ទុយទៅវិញត្រូវធ្វើក្នុងលក្ខណៈជាអាជីពតែម្តង ។

---

[120] អត្ថបទ ច្បាប់នេះ និង ច្បាប់ដទៃទៀតមាននៅលើគេហទំព័រ www.moc.gov.kh ។

[121] ក្នុងន័យធ្វើអោយកាន់តែច្បាស់ឡើង នូវសញ្ញាណនៃពាណិជ្ជកិច្ចមាត្រា ២ នៃច្បាប់ដែលបានបញ្ញត្តថា :

" ត្រូវចាត់ទុកជាពាណិជ្ជកិច្ចរាល់សកម្មភាពដែលមានចែងជាអាទិ៍ដូចខាងក្រោម :

- ការទិញដើម្បីលក់ទៅវិញ គិតបញ្ចូលទាំងវិស័យអចលនៈទ្រព្យ
- រាល់សកម្មភាពនៃសហគ្រាសជួល សហគ្រាសការណកម្ម សហគ្រាសយកកំរែជើងសារ សហគ្រាសដឹកជញ្ជូន សហគ្រាសបោះពុម្ពផ្សាយ និងសេវាដទៃ ។
- ប្រតិបត្តិការនៃធនាគារ ប្តូររូបិយវត្ថុ
- ការផ្តល់សេវាអន្តរការ សេវាទីភ្នាក់ងារការិយាល័យសំរបសំរួលកិច្ចការសេវាវិប្បធម៌ និងការចាត់ចែងផ្នាំងទស្សនីយ៍ភាពជាសារធារណៈ ។
- ប្រតិបត្តិការនៃសហគ្រាសសំណង់ ការទិញ ឬ ជួលនាវាដឹកជញ្ជូនក្នុងប្រទេស ឬ ក្រៅប្រទេសការដឹកជញ្ជូន និងការផ្ទេរបញ្ជូនតាមផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស ។
- ការធានារ៉ាប់រងគ្រប់ប្រភេទ
- អាជីវកម្មនេសាទ អាជីវកម្មព្រៃឈើ និងរ៉ែ ។

Scanned with CamScanner

៣. សកម្មភាពនោះក៏ត្រូវធ្វើឡើងក្នុងគោលបំណងសំខាន់ពីរយ៉ាង ពោលគឺការដោះដូរ និងការស្វែងរកផលចំណេញ ។ និយាយម្យ៉ាងទៀតថា ពាណិជ្ជករ គឺជាបុគ្គលដែលធ្វើគ្រប់យ៉ាងនៅក្នុងព្រំដែននៃច្បាប់ ដើម្បីភាពមានបានផ្គាល់ខ្លួនដោយប្រើប្រាស់ភាពឆ្លាតវៃរបស់ខ្លួនក្នុងការធ្វើបរិកប្ប[១២២] មានន័យថា មិនចាត់ទុកជាពាណិជ្ជករទេ រាល់បុគ្គលទាំងឡាយណាដែលធ្វើការជាប្រចាំ និងជាអាជីពដើម្បីអ្នកដទៃ។ ការណ៍នេះធ្វើឱ្យលេចឡើងនូវលក្ខខណ្ឌទី ៤ ស្តីពីឯករាជ្យ-ភាពក្នុងការបំពេញកិច្ចការរបស់ខ្លួន ។

៤. លក្ខខណ្ឌស្តីពីឯករាជ្យភាពនេះ ជាលក្ខខណ្ឌចាំបាច់មិនអាចខ្វះបានសំរាប់ប្រាប់លក្ខណៈជាពាណិជ្ជករ ព្រោះថា កង្វះឯករាជ្យភាពក្នុងការប្រកបវិជ្ជជីវៈនឹងនាំឱ្យគេក្លាយជានិយោជិត ។ លក្ខខណ្ឌនេះត្រូវបានគេឃើញនៅក្នុងមាត្រា ៥ នៃច្បាប់ចុះថ្ងៃទី ១៨-១១-១៩៩៩ ដែលចែងថា : "បុគ្គលដែលគ្រាន់តែជួយលក់ទំនិញរបស់សហធម្មិខ្លួនដែលជាពាណិ-ជ្ជករ មិនចាត់ទុកថាជាពាណិជ្ជករឡើយ ។ និយោជិតដែលលក់តែទំនិញរបស់ម្ចាស់សហគ្រាសដែលជាពាណិជ្ជករ មិនចាត់ទុកថាជាពាណិជ្ជករឡើយ ។"

ការប្រើប្រាស់វិធីសាស្ត្របកស្រាយច្បាប់តាមបដិលោមវិធី[១២៣] ធ្វើឱ្យលេចចេញយ៉ាងច្បាស់នូវគំនិតនីតិករដែលចង់ ឱ្យសកម្មភាពមួយត្រូវបានចាត់ទុកជាពាណិជ្ជកិច្ច លុះណាតែសកម្មភាពនោះបំពេញលក្ខខណ្ឌទាំងបួនខាងលើ ។

(បដិញ្ហាតួច) : រីឯក្នុងករណីរបស់យើង សកម្មភាពរបស់លោក សុខ សុគន្ធ គឺជាការលក់គ្រឿងសិង្ហារិមជាឈើ ដែលគាត់ផលិតខ្លួនឯងផង និងដោយមានជំនួយពីកម្មករចំនួន ០៨ នាក់ផង ព្រមជាមួយនឹងគ្រឿងសិង្ហារិមជាអាលុយមីញ៉ូមជាដើរ នាំចូលពីប្រទេសជិតខាងផង ។ នេះសរឱ្យឃើញថា សកម្មភាពរបស់គាត់ ជាការទិញដើម្បីលក់ទៅវិញ ហើយដែលតាមរយៈ ទង្វើរបៀបនេះទើបធ្វើឱ្យគេឃើញផងដែរនូវគំនិតដោះដូរ និងស្វែងរកផលចំណេញរបស់គាត់។ ក្រៅពីនេះវាក៏ជាសកម្មភាពដែលអនុវត្តន៍ជាប្រចាំ ជាអាជីព និងមិនមែនម្តងម្កាលទេ នេះបើផ្អែកតាមសំដីរបស់គាត់ដែលលើកឡើងក្នុងលំហាត់អនុវត្តនេះថា : "គាត់មានបំណងចង់បើករោងជាងមួយក្នុងផ្ទះនេះ ដើម្បីធ្វើការផលិត តុ ទូ បង្ហួច កៅអីទ្វារ និងសិង្ហារិមផ្សេងៗ ទៀតអំពីឈើ ។ (...) គាត់ចង់លក់ទាំងរបស់គាត់ផលិតខ្លួនឯង ដោយមានជំនួយរបស់កម្មករ ០៨ រូបផង និងគ្រឿងសិង្ហារិម អំពីដើរ និងអាលុយមីញ៉ូម ដែលគាត់បញ្ជារទិញពីប្រទេសជិតខាងផង។"

យើងនៅសល់តែលក្ខខណ្ឌចុងក្រោយប៉ុណ្ណោះ ដែលត្រូវពិចារណា ពោលគឺឯករាជ្យភាពក្នុងការចាត់ចែង និងគ្រប់គ្រងលើអាជីវកម្មរបស់គាត់. ។ យោងតាមអង្គហេតុខាងលើ យើងអាចសន្និដ្ឋានបាន ថាគាត់ពិតជាមានឯករាជ្យភាពពេញបរិបូរណ៌សំរាប់ធ្វើអាជីវកម្មរបស់គាត់ ។ ពំនោលបែបនេះ គឺឈរទាំងស្រុងលើបញ្ញត្តិដែលដែលគាត់បានពោលមកខាងលើ ជាពិសេសតាមរយៈវាក្យស័ព្ទ : "(...) គាត់ចង់លក់ទាំងរបស់គាត់ផលិតខ្លួនឯង ដោយមានជំនួយពីកម្មករចំនួន ០៨ នាក់ (...) និងគ្រឿងសិង្ហារិមអំពីដើរ និងអាលុយមីញ៉ូម ដែលគាត់បញ្ជារទិញពីប្រទេសជិតខាងផង" ។ និយាយឱ្យចំឯករាជ្យភាពក្នុងការ គ្រប់គ្រងអាជីវកម្ម ក៏ដូចក្នុងការសម្រេចចិត្តនានា លើបញ្ហាក្រុមហ៊ុន រួមបញ្ចូលទាំងការទទួលខុសត្រូវចំពោះលទ្ធផលអាជីវកម្មស្តែងចេញយ៉ាងច្បាស់ក្រឡែត មិនត្រឹមតែតាមរយៈការជ្រើសរើស និងការ

---

[១២២] មានន័យថា ការរកចំណេញ ឬកេងយកចំណេញ (speculation) ។

[១២៣] ដោយបញ្ច្រាស់ = Interprétation *a contrario* ។

Scanned with CamScanner

ប្រើប្រាស់កម្មករចំនួន ០៨ នាក់ប៉ុណ្ណោះ ទេ តែថែមទាំងតាមរយៈអត្ថិភាពនៃអំណាចចេញសេចក្តីសំរេចបញ្ជាទិញ ចំនិញពីបរទេសដោយគ្មានសុំការអនុញ្ញាតជាមុន ពីនរណាម្នាក់ថែមទៀតផង ។

(សន្និដ្ឋាន) : ដូច្នេះ សកម្មភាពរបស់លោក សុខ សុគន្ធ គឺជាពាណិជ្ជកិច្ចនៅក្នុងន័យ នៃច្បាប់ស្តីអំពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មដែលប្រកាសឱ្យប្រើនៅឆ្នាំ ១៩៩៩ ។ គុណវុឍ្ឍិ[១២៤] ខាងលើនេះ អនុញ្ញាតឱ្យយើងឆ្លើយដោយផ្ទាល់ទៅនឹងបញ្ហាទាំងឡាយពាក់ព័ន្ធនិងសំណុំបែបបទរដ្ឋបាលដែលត្រូវបំពេញដើម្បីគាត់អាចបើកអាជីវកម្មបាន ។

២. វិធាកនានាបណ្តាលមកពីលក្ខន្តិកៈគតិយុត្តិជាពាណិជ្ជករ :

អំណានបញ្ញត្តិនៃមាត្រា ១ នៃច្បាប់ស្តីអំពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម អនុញ្ញាតឱ្យយើងនិយាយភ្លាមថា គុណភាពជាពាណិជ្ជករអាចទទួលបានដោយស្វ័យប្រវត្តិ នៅពេលដែលសកម្មភាពសេដ្ឋកិច្ចមួយបំពេញនូវលក្ខណៈទាំងបួនខាងលើ ។ ក៏ប៉ុន្តែ ដើម្បីឱ្យសកម្មភាពពាណិជ្ជកម្មនោះអាចអនុវត្តបានដោយស្របច្បាប់ ច្បាប់តម្រូវឱ្យគោរពនីតិវិធីនៃការចុះបញ្ជីពាណិជ្ជកម្ម(ក) ។ ក្រៅពីកាតព្វកិច្ចចុះបញ្ជីពាណិជ្ជកររនៅមានកាតព្វកិច្ចជាសារវន្តមួយទៀតគឺ កាតព្វកិច្ចខាងគណនេយ្យ (ខ) ។

ក. កាតព្វកិច្ចចុះបញ្ជីពាណិជ្ជកម្ម :

(បដិញ្ញាធំ) : អនុលោមតាមបញ្ញត្តិនៃមាត្រា ១២ នៃច្បាប់ដដែល ពាណិជ្ជករ និងក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយដែលមានគ្រឹះស្ថានរបស់ខ្លួន(...) នៅព្រះរាជាណាចក្រកម្ពុជាមានកាតព្វកិច្ចចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនេះ ។ តាមន័យនេះវា ជាកាតព្វកិច្ចនីត្យានុកូល[១២៥] ដែលគ្មាននរណាម្នាក់អាចនឹងមិនគោរពបានឡើយ ព្រោះថាវាជាបញ្ញត្តិដែលមានចរិតលក្ខណៈជាច្បាប់អាជ្ញាបញ្ជារ ពោលគឺគាត់ត្រូវតែគោរពដោយខានមិនបាន ។ ក៏ប៉ុន្តែ ក្នុងគោលបំណងលើកទឹកចិត្តឱ្យមានការប្រកបរបរពាណិជ្ជកម្ម នីតិករ នៅឆ្នាំ ១៩៩៩ បានបន្ធូរបន្ថយបែបបទរដ្ឋបាលដល់ពាណិជ្ជកររួមួយចំនួន ដូចមានចែងបញ្ជាក់បន្ថែមនៅក្នុងមាត្រា ១២ បច្ចិមវាក្យខណ្ឌ[១២៦] ថា ពាណិជ្ជករ(...) ដែលមានគ្រឹះស្ថានរបស់ ខ្លួន(...)នៅព្រះរាជាណាចក្រកម្ពុជា មានកាតព្វកិច្ចចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនេះ *លើកលែងតែពាណិជ្ជកររដែលមិនជាប់ពន្ធលើប្រាក់ចំណេញ* ។ ហេតុនេះហើយ ទើបវាមានលក្ខណៈចាំបាច់ ដែលត្រូវដឹងថាអ្វីទៅជាលក្ខខណ្ឌនៃការរួចពន្ធលើប្រាក់ចំណេញ ។ ចម្លើយទៅនិងសំនួរនេះស្ថិតក្នុងបញ្ញត្តិនៃមាត្រា ២០ ថ្មី វាក្យខណ្ឌទី ៥ នៃច្បាប់សារពើពន្ធដែលប្រកាសឱ្យប្រើនៅថ្ងៃទី ៣១-០៣-២០០៣ ។ មាត្រាខាងលើ បានធ្វើបញ្ជីរាយចំនួនទឹកប្រាក់ចំណេញជាប់ពន្ធ ព្រមទាំងអត្រាពន្ធលើប្រាក់ចំណេញនីមួយៗដែលក្នុងនោះគេឃើញ មានផលរបរប្រភេទទីមួយដែលរួបវន្តបុគ្គល ឬនីតិបុគ្គលរកបានជាប់ពន្ធត្រឹមតែសូន្យភាគរយ (0%) ប្រសិនបើចំនួនប្រាក់ ចំណេញប្រចាំឆ្នាំរកបានមិនលើសពី ៦ លាន រៀលទេ ។

---

[១២៤] មានន័យថា ការបង្ហាញ ឬការប្រាប់លក្ខណៈសម្បត្តិ ។

[១២៥] កាតព្វកិច្ចដែលតំរូវដោយច្បាប់ ។

[១២៦] វាក្យខណ្ឌចុងក្រោយបង្អស់= alinea *in fine* ។

Scanned with CamScanner

អនុលោមតាមមាត្រា ១២ បច្ចិមវាក្យខណ្ឌ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម និងមាត្រា ២០ ថ្មី វាក្យខណ្ឌទី ៥ នៃច្បាប់សារពើពន្ធ មានតែពាណិជ្ជករ ឬសហគ្រាសឯកបុគ្គលដែលមិនអាចរកប្រាក់ចំណេញប្រចាំឆ្នាំលើលពី ៦ លានរៀលទេ ដែលអាចប្រកបអាជីវកម្មដោយមិនចាំបាច់ធ្វើការចុះបញ្ជីពាណិជ្ជកម្មបាន ។

(បដិញ្ញាតួច) : លោក សុខ សុគន្ធ គឺជាពាណិជ្ជករ ហើយគាត់មានបំណងចង់ប្រកបអាជីវកម្មមានទម្រង់ទ្រង់ទ្រាយធំជាងដែរ ដែលអាចរកប្រាក់ចំណេញលើសពី ៦ លានរៀល ។ តម្លៃនេះមានលក្ខណៈសមហេតុផលគ្រប់គ្រាន់[១២៧] ។

(សន្និដ្ឋាន) : និយាយឱ្យចំ លោក សុខ សុគន្ធ ត្រូវចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្នុងនាមជាពាណិជ្ជករ មុនពេលចាប់ផ្តើមអាជីវកម្ម ។ ការចុះបញ្ជីត្រូវធ្វើនៅកន្លែងធ្វើអាជីវកម្ម និងយ៉ាងយូរបំផុតក្នុងរវាង ១៥ ថ្ងៃ មុនពេលចាប់ផ្តើមអាជីវកម្ម ដូចមានចែងក្នុងមាត្រា ១៤ ថ្មី នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ។

ចំពោះឯកសារដែលត្រូវប្រគល់ វាក្យខណ្ឌ ៣ នៃមាត្រាដដែលបានចែងរៀបរាប់យ៉ាងលំអិតដូចខាងក្រោមថា "ពាណិជ្ជករត្រូវប្រគល់ទៅទីកន្លែងទទួលពាក្យចុះបញ្ជីនូវប្រតិវេទន៍[១២៨] មួយធ្វើជាពីរច្បាប់ មានហត្ថលេខា ឬស្នាមមេដៃរបស់សាមីខ្លួន ។ ប្រតិវេទន៍ត្រូវចែងអំពី : អត្តសញ្ញាណ រហស្សនាម ថ្ងៃ ខែ ឆ្នាំកំណើត សញ្ជាតិ កម្មវត្ថុអាជីវកម្ម ទីកន្លែង ប្រភេទអាជីវកម្ម ផ្លាកសញ្ញាពាណិជ្ជកម្ម ហត្ថលេខា និងស្នាមត្រាគំរូ ក្រឹះស្ថានចាស់ដែលអ្នកស្នើសុំបានធ្វើអាជីវកម្មពីមុន ឬកំពុងធ្វើអាជីវកម្ម លិខិតផ្តោលទោសរបស់អ្នកស្នើរសុំ ចុះឈ្មោះក្នុងបញ្ជីរពាណិជ្ជកម្មថា គ្មានជាប់ទោសក្នុងកិច្ចការជំនួញ ព្រមទាំងលិខិតអនុញ្ញាតឱ្យប្រកបមុខរបរ ចំពោះមុខរបរណាដែលតម្រូវឱ្យមានសេចក្តីអនុញ្ញាត ។"

ក្នុងនាមជាពាណិជ្ជករដែលចុះបញ្ជី លោក សុខ សុគន្ធ ដូចពាណិជ្ជករដទៃទៀតដែរ មានសិទ្ធិ និងកាតព្វកិច្ចដែលកើតចេញពីលក្ខន្តិកៈជាពាណិជ្ជករ[១២៩] ដែលក្នុងនោះមានផងដែរនូវកាតព្វកិច្ចគណនេយ្យ ។

ខ. កាតព្វកិច្ចខាងគណនេយ្យ :

(បដិញ្ញាធំ) : មាត្រា ៤៧ នៃច្បាប់ខាងលើបានចែងថា : រាល់ពាណិជ្ជករ (...) មានកាតព្វកិច្ចកាន់កាប់គណនេយ្យមួយ ទៅតាមវិធានគណនេយ្យ និងតាមបទប្បញ្ញត្តិគណនេយ្យជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងការណែនាំផ្សេងៗទៀតដែលទាក់ទងនឹងការអនុវត្តន៍ មានន័យថា រាល់ពាណិជ្ជករត្រូវតែគោរពវិធានគណនេយ្យ និងគតិយុត្តដែលមានចែងក្នុងច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្ម និងវិជ្ជាជីវៈគណនេយ្យចុះថ្ងៃទី ០៨-០៧-២០០២[១៣០] និងវិធានផ្សេងៗទៀតរបស់ស្តង់ដារគណនេយ្យនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ១៦-១០-២០០៣ ។ ក្នុងន័យនេះដែរ មាត្រា ៤៩ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មបានបន្ថែមថា រាល់ពាណិជ្ជកិច្ចដែលធ្វើឡើងរវាងអាជីវករ និងអាជីវករត្រូវមានវិក្កយបត្រយ៉ាងហោចណាស់ពីរច្បាប់ ។ ច្បាប់ដើមមួយសន្លឹកសំរាប់ផ្តល់ជូនអតិថិជន ហើយសន្លឹកផ្សេងទៀត

---

[១២៧] អត្រាប្តូរប្រាក់រៀល ធៀបនឹង ដុល្លារ នៅថ្ងៃ ០៥-១២-២០០៥ គឺ ៤.១៥៥ រៀល ក្នុង ១ ដុល្លាអាមេរិក ។

[១២៨] សេចក្តីប្រកាសសុំចុះបញ្ជី *(declaration)* ។

[១២៩] មាត្រា ៨ : សិទ្ធិ និងកាតព្វកិច្ចរបស់ពាណិជ្ជករត្រូវស្ថិតនៅក្រោមអំណាចនៃច្បាប់ពាណិជ្ជកម្ម លើកលែងតែមានកស្តុតាងផ្ទុយ ។

[១៣០] អត្ថបទជាភាសាអង់គ្លេសស្តីពីច្បាប់នេះ មាននៅលើគេហទំព័រ www.moc.gov.kh ។

Scanned with CamScanner

ត្រូវរក្សាទុកដោយអ្នកលក់ ។ ប៉ុន្តែ ចំពោះការលក់ចំនិញ ឬការធ្វើសេវាឱ្យអ្នកប្រើប្រាស់ពុំចាំបាច់ធ្វើវិក្កយប័ត្រ ឬសក្តីប័ត្រទេ លើកលែងតែអតិថិជនទាមទារ ។

វិក្កយប័ត្រត្រូវមានចុះយ៉ាងហោចណាស់នូវនិទ្ទេសដែលកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញ-វត្ថុ ជាអាទិ៍ នាម កាលបរិច្ឆេទ តម្លៃ ។ល។ លើសពីនេះ អនុលោមតាមបញ្ញត្តិនៃមាត្រា ៥៣ នៃច្បាប់ដែលរាល់ប្រតិបត្តិការរវាង ពាណិជ្ជករ និងពាណិជ្ជករដែលមានតម្លៃចាប់ពី ១០ លានរៀល ឬសមមូលជារូបិយបណ្ណបរទេស ត្រូវតែធ្វើការទូទាត់ដោយ មូលប្បទានបត្រ ឬដោយផលបត្រពាណិជ្ជកម្ម ។

(បដិញ្ហាតុច) : លោក សុខ សុគន្ធ គឺជាពាណិជ្ជករ ។

(សន្និដ្ឋាន) : បើសិនជាលោក សុខ សុគន្ធ មានបំណងចង់បើកហាងជាងរបស់ខ្លួនស្របច្បាប់ គាត់ត្រូវតែគោរពនីតិវិធី និង កាតព្វកិច្ចទាំងឡាយខាងផ្នែកគណនេយ្យ ។

គ. នីតិព្រហ្មទណ្ឌ

១. អង្គហេតុ

កាលពីថ្ងៃទី ០១-០១-២០០១ មានបទល្មើសចោរកម្មមួយបានកើតឡើង ដោយលោក សុិន សារុន បានលួចយកម៉ូតូបានចំនួនមួយគ្រឿងរបស់អ្នកស្រី ចន្ធ ដែលគាត់ទើបនឹងទិញក្នុងតម្លៃ ១.២០០ ដុល្លារអាមេរិក ។ ស្អែកឡើង លោក សុិន សារុន បានយកម៉ូតូនោះទៅលក់ឱ្យមិត្តរបស់ខ្លួន គឺលោក ប៊ុន សិរិទ្ធ ក្នុងតម្លៃ ៤០០ ដុល្លារអាមេរិក ។ លោក ប៊ុន សិរិទ្ធ បានសម្រេចចិត្តទិញយកម៉ូតូនោះភ្លាម ទោះបីជាគាត់មានការសង្ស័យថា ម៉ូតូនោះជាម៉ូតូដែលចេញមកពីបទល្មើសចោរកម្មក៏ ដោយ ។ ក្រោយពីបានទិញម៉ូតូនោះបានមួយថ្ងៃរួចមក លោក ប៊ុន សិរិទ្ធ ក៏បានទទួលដំណឹងពិតប្រាកដថា ម៉ូតូដែលខ្លួនបានទិញនោះ គឺពិតជាម៉ូតូដែលលោក សុិន សារុន បានលួចពីអ្នកស្រី ចន្ធ ពិតប្រាកដមែន ។ លោក ប៊ុន សិរិទ្ធ ក៏យកម៉ូតូនោះទៅលាក់ទុកដើម្បីកុំឱ្យគេរកឃើញ ។ មួយឆ្នាំក្រោយមកទើប លោក ប៊ុន សិរិទ្ធ បានសម្រេចចិត្តយកម៉ូតូនោះមកប្រើប្រាស់ ។ ក្រោយមកទៀត គាត់បានទទួលដំណឹងថា លោក សុិន សារុន ត្រូវនគរបាលចាប់ខ្លួនបានកាលពីដើមឆ្នាំ ២០០៥ ចំពោះបទ ល្មើសលួចមួយទៀត ដែលគាត់បានប្រព្រឹត្តនាចុងឆ្នាំ ២០០៤ ។ លោក សុិន សារុន បានសារភាពចំពោះមុខនគរបាលថា លោកធ្លាប់បានលួចបានម៉ូតូមួយគ្រឿងកាលពីដើមឆ្នាំ ២០០១ ហើយបានយកម៉ូតូនោះ ទៅលក់ឱ្យមិត្តរបស់ខ្លួនគឺ លោក ប៊ុន សិរិទ្ធ ក្នុងតម្លៃ ៤០០ ដុល្លារអាមេរិក ។ ប្រសិនបើអ្នកជាព្រះរាជអាជ្ញា តើអ្នកយល់យ៉ាងណាដែរ ចំពោះករណីលោក សុិន សារុន និង ករណីលោក ប៊ុន សិរិទ្ធ ? សូមធ្វើការបកស្រាយដោយឈរលើមូលដ្ឋាននៃអាជ្ញាយុកាលនៃបណ្តឹងអាជ្ញា ។

២. កំណែ : (កើត វិទ្ធ)

កាលពីថ្ងៃទី ០១-០១-២០០១ លោក សុិន សារុន បានលួចម៉ូតូថ្មីមួយគ្រឿងរបស់អ្នកស្រី ចន្ធ ហើយគាត់បានយកម៉ូតូនេះ ទៅលក់ឱ្យលោក ប៊ុន សិរិទ្ធ ។ លោក ប៊ុន សិរិទ្ធ បានទិញយក និងរក្សាម៉ូតូនោះទុក ទោះបីជាដឹងថា ម៉ូតូ

Scanned with CamScanner

ខាងលើជា ផលនៃអំពើចោរកម្មក៏ដោយ ។ ក្រោយមកទៀត លោក ស៊ិន សារុន បានប្រព្រឹត្តអំពើចោរកម្មជាថ្មីម្តងទៀត នាចុងឆ្នាំ ២០០៤ ប៉ុន្តែ គាត់ត្រូវបាននគរបាលចាប់ខ្លួន នាដើមឆ្នាំ ២០០៥ ។

បើយោងតាមអង្គហេតុខាងលើនេះ បញ្ហាចំបងដែលចោទឡើង គឺថា បើឈរលើមូលដ្ឋាននៃបណ្តឹងអាជ្ញា តើ លោក ស៊ិន សារុន និងលោក ប៊ុន សិរិទ្ធ អាចទទួលរងនូវការចោទប្រកាន់ និងផ្តន្ទាទោសចំពោះអំពើរបស់ខ្លួនខាងលើដែរ ឬទេ ?

ដើម្បីដោះស្រាយបញ្ហាខាងលើ យើងសូមធ្វើការបែងចែកសម្មតិកម្មជាពីរដូចខាងក្រោម :

១. ករណីលោក ស៊ិន សារុន :

យោងតាមអង្គហេតុខាងលើ លោក ស៊ិន សារុន បានប្រព្រឹត្តបទល្មើសចោរកម្មចំនួនពីរលើកគឺ នៅថ្ងៃទី ០១-០១-២០០១ ម្តង និងនាខែ ធ្នូ ឆ្នាំ ២០០៤ ម្តងទៀត ហើយក្រោយមកទៀត គាត់ត្រូវបាននគរបាលចាប់ខ្លួននាខែ មករា ឆ្នាំ ២០០៥ ។ ចំពោះសម្មតិកម្មនេះ បញ្ហាដែលចោទគឺថា តើលោក ស៊ិន សារុន អាចត្រូវទទួលរងការចោទប្រកាន់ចំពោះអំពើ ណាខ្លះ ?

(បដិញ្ញាធំ) : ជាគោលការណ៍ ព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់ជនណាម្នាក់បាន លុះត្រាតែបទល្មើសដែលជនល្មើស បានប្រព្រឹត្តមិនទាន់ផុតអាជ្ញាយុកាល ។ អាជ្ញាយុកាលនេះ គឺជារបៀបមួយនៃការរំលត់បណ្តឹងអាជ្ញា ។ នៅក្នុងនីតិព្រហ្មទណ្ឌ អាជ្ញាយុកាលត្រូវបានបែងចែកជាពីរប្រភេទ គឺ អាជ្ញាយុកាលនៃទោស និងអាជ្ញាយុកាលនៃបទល្មើស (បណ្តឹងអាជ្ញា) ។ អាជ្ញាយុកាលនៃទោស គឺជាយន្តការមួយ ដែលធ្វើឱ្យទោសព្រហ្មទណ្ឌមិនអាចត្រូវបានគេយកទៅអនុវត្តបានឡើយ ប្រសិនបើទោសព្រហ្មទណ្ឌនោះមិនត្រូវបានគេអនុវត្ត ក្នុងរយៈពេលមួយកំណត់ (០៣ ឆ្នាំ សម្រាប់បទល្មើសមជ្ឈិម និង ១០ ឆ្នាំ សម្រាប់បទល្មើសឧក្រិដ្ឋ) ដោយចាប់ផ្តើមរាប់គិតពីថ្ងៃដែលសាលក្រម ឬសាលដីកាផ្តន្ទាទោសចូលជាស្ថាពរ[១៣១] ។ ចំណែកឯអាជ្ញា យុកាលនៃបទល្មើសវិញ គឺជារយៈពេលមួយដែលការកន្លងផុតទៅនៃរយៈពេលនេះបណ្តាលឱ្យបណ្តឹងអាជ្ញាត្រូវផុតរលត់ មានន័យម្យ៉ាងទៀតថា ព្រះរាជអាជ្ញាលែងមានអំណាចដើម្បីធ្វើការចោទប្រកាន់អ្វីបានទៀតហើយ កាលបើរយៈពេលដែលជាអាជ្ញាយុកាលនោះបានកន្លងផុតទៅ ។ បើយោងតាមមាត្រា ៣០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី ១០-០៩-១៩៩២ អាជ្ញាយុកាលនៃបទល្មើស មានរយៈពេល ៣ ឆ្នាំ សម្រាប់បទល្មើសមជ្ឈិម និងមានរយៈពេល ១០ ឆ្នាំ សម្រាប់បទល្មើសឧក្រិដ្ឋ[១៣២] ។ ជាគោលការណ៍ អាជ្ញាយុកាលនេះត្រូវចាប់ផ្តើមរាប់គិតចាប់ពីថ្ងៃប្រព្រឹត្តបទល្មើស ។ ប៉ុន្តែ ការរាប់របៀបនេះ អាចអនុវត្តបានតែក្នុងករណីនៃបទល្មើសដែលគេចាត់ចូលជាប្រភេទបទល្មើសភ្លាម១តែប៉ុណ្ណោះ គឺមិនអនុវត្តចំពោះករណីបទល្មើសដែលជាបទល្មើសជាប់ជាហូរហែរ ឬហៅម្យ៉ាងទៀតថា ជាបទល្មើសនិរន្តរ៍នោះទេ ។ ការបែងចែកបទល្មើសភ្លាម១ ពីបទល្មើសជាប់ជាហូរហែរ ឬនិរន្តរ៍នេះ ផ្អែកលើ

---

[១៣១] មាត្រា ១១៧ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ។

[១៣២] បើយោងតាមមាត្រា ១០៩ នៃក្រមព្រហ្មទណ្ឌចាស់ អាជ្ញាយុកាលនៃបទល្មើសមានរយៈពេល ១០ ឆ្នាំ សំរាប់បទឧក្រិដ្ឋ ៥ ឆ្នាំ សំរាប់បទមជ្ឈិម (ឬទោសកម្ម) និង១២ ខែ សំរាប់បទលហុ ។ ចំណែកឯ អាជ្ញាយុកាលនៃទោសវិញគឺ មានរយៈពេល ២០ ឆ្នាំ សំរាប់ទោសឧក្រិដ្ឋ ១០ ឆ្នាំ សំរាប់ទោសមជ្ឈិម និង ២ ឆ្នាំ សំរាប់ ទោសលហុ (មាត្រា ១៧២ នៃក្រមព្រហ្មទណ្ឌចាស់) ។

Scanned with CamScanner

មូលដ្ឋាននៃការអនុវត្តអំពើជាសំភារៈនៃបទល្មើស ។ ដូចនេះ ត្រូវបានគេចាត់ទុកជាបទល្មើសភ្លាម។ នៅពេលការសម្រេចបទល្មើសនោះធ្វើឡើងក្នុងរយៈពេលមួយដ៏ខ្លី ដូចក្នុងករណីអំពើមនុស្សឃាដជាដើម ។ ផ្ទុយទៅវិញ ត្រូវបានគេចាត់ចូលក្នុងប្រភេទនៃបទល្មើសជាប់ជាហូរហែរ ឬនិរន្តរ៍ នៅពេលដែលការសម្រេចបទល្មើស ជាពិសេសអំពើជាសំភារៈនៃបទ-ល្មើសនោះ ធ្វើឡើងដោយអូសបន្លាយនៅក្នុងរយៈពេលមួយវែងប្រកបដោយចេតនាទុច្ចរិត របស់ជនល្មើសដែលនៅជាប់ជាហូរហែរហូត ដូចជាករណីបទល្មើសបង្ខាំងមនុស្សដោយខុសច្បាប់ជាដើម ។

(បដិញ្ញាតូច) : យោងតាមសម្មតិកម្មខាងលើ អំពើរបស់លោក ស៊ិន សារុន មិនទាន់ត្រូវបានតុលាការធ្វើការជំនុំជម្រះនៅឡើយទេ ។ ដូចនេះ បញ្ហានៃអាជ្ញាយុកាលនៃទោសមិនត្រូវលើកយកមកពិភាក្សានៅទីនេះឡើយ ។ ប៉ុន្តែ បញ្ហាអាចចោទឡើងទាក់ទងទៅនឹងអាជ្ញាយុកាលនៃបទល្មើស ឬនៃបណ្តឹងអាជ្ញា ។ បទល្មើសដែលលោក ស៊ិន សារុន បានប្រព្រឹត្ត គឺជាបទល្មើសចោរកម្ម ។ បទល្មើសចោរកម្មនេះ មានចែង និងផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ ខែ ដល់ ៥ ឆ្នាំ ដោយមាត្រា ៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី ១០-០៩-១៩៩២ ។ ដោយហេតុថា បទល្មើសចោរកម្មជាបទល្មើសដែលមានចែង និងផ្តន្ទាទោសដោយមាត្រា ៤៣ នៅក្នុងមាតិកា ៥ ស្តីអំពីបទល្មើសមជ្ឈិមនៃច្បាប់ព្រហ្មទណ្ឌខាងលើ ដូចនេះ បទល្មើសចោរកម្មត្រូវបានគេចាត់ទុកថា ជាបទល្មើសមជ្ឈិម ហើយមានអាជ្ញាយុកាលរយៈពេល ៣ ឆ្នាំ ។ ម្យ៉ាងទៀត បទល្មើសចោរកម្ម គឺជាបទល្មើសដែលគេចាត់ចូលក្នុងប្រភេទបទល្មើសភ្លាម។ ព្រោះការសម្រេចអំពើនេះ គឺធ្វើឡើងក្នុងរយៈពេលមួយដ៏ខ្លី ។

ដូចនេះ អាជ្ញាយុកាលនៃបទល្មើសចោរកម្មមានរយៈពេល ៣ ឆ្នាំ ហើយអាជ្ញាយុកាលត្រូវចាប់រាប់គិតពីថ្ងៃប្រព្រឹត្តបទល្មើស ។ ដោយហេតុថា លោក ស៊ិន សារុន បានប្រព្រឹត្តបទល្មើសចោរកម្មចំនួនពីរលើក គឺនៅក្នុងឆ្នាំ ២០០១ ម្តង និងនៅចុងឆ្នាំ ២០០៤ ម្តងទៀត ។ បន្ទាប់មក គាត់ត្រូវចាប់ខ្លួនបានដោយនគរបាលនៅចុងឆ្នាំ ២០០៥ ។ ដូចនេះ យើងនឹងធ្វើការពិនិត្យអាជ្ញាយុកាលនៃអំពើចោរកម្មទាំងពីរនេះ ដើម្បីដឹងថា តើព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់បាន ឬមិនបាន ដោយផ្អែកលើអង្គហេតុខាងលើដូចតទៅ :

- អំពើចោរកម្មដែលលោក ស៊ិន សារុន បានប្រព្រឹត្តកាលពីចុងឆ្នាំ ២០០៤ : អំពើនេះត្រូវបានប្រព្រឹត្តនាពេលថ្មីៗនេះ ដែលពុំទាន់ផុតរយៈពេល ៣ ឆ្នាំ នៅឡើយទេ ។

- អំពើចោរកម្មដែលលោក ស៊ិន សារុន បានប្រព្រឹត្តនាដើមឆ្នាំ ២០០១ : អំពើនេះបើគិតចាប់តាំងពីថ្ងៃប្រព្រឹត្តបទល្មើស គឺនៅថ្ងៃទី ០១-០១-២០០១ រហូតដល់ថ្ងៃចាប់ខ្លួន គឺនៅខែ មករា ឆ្នាំ ២០០៥ គឺមានរយៈពេលលើសពី ៣ ឆ្នាំ ។

(សន្និដ្ឋាន) : ព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់គាត់បានពីបទចោរកម្ម ដែលលោក ស៊ិន សារុន បានប្រព្រឹត្ត កាលពីចុងឆ្នាំ ២០០៤ ព្រោះថាអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាមិនទាន់រលត់ គឺអាជ្ញាយុកាលស្ថិតនៅក្នុងរយៈពេលដែលលោក ស៊ិន សារុន ត្រូវបានចាប់ខ្លួន ។ ប៉ុន្តែ ព្រះរាអាជ្ញាមិនអាចចោទប្រកាន់លោក ស៊ិន សារុន ដោយឈរលើមូលដ្ឋាននៃអំពើលួចដែលលោក ស៊ិន សារុន បានប្រព្រឹត្តកាលពីថ្ងៃទី ០១-០១-២០០១ បានឡើយ ដោយហេតុថា បទល្មើសនេះ បាន

Scanned with CamScanner

ផុតអាជ្ញាយុកាលដែលបណ្តាលឱ្យរំលត់បណ្តឹងអាជ្ញាទៅហើយ លើកលែងតែក្នុងករណីដែលមានមូលហេតុផ្សេងទៀតមកផ្អាក ឬផ្តាច់អាជ្ញាយុកាលនៃបណ្តឹងអាជ្ញានេះ ។

២. ករណីលោក ប៊ុន សិរិទ្ធ :

យោងតាមអង្គហេតុខាងលើ អំពើដែលលោក ប៊ុន សិរិទ្ធ បានទទួលទិញម៉ូតូពីលោក ស៊ិន សារុន កាលពីដើមឆ្នាំ ២០០១ ក្នុងតម្លៃ ៤០០ ដុល្លារអាមេរិកដែលម៉ូតូថ្មីមានតម្លៃ ១.២០០ ដុល្លារអាមេរិក ។ ក្រោយមកពីបានដឹងថា ម៉ូតូនោះ មានប្រភពចេញពីអំពើលួច លោក ប៊ុន សិរិទ្ធ បានយកម៉ូតូនោះទៅលក់ទុក ហើយមួយឆ្នាំក្រោយមក ទើបយកម៉ូតូចេញមកប្រើ ។ ដូចនេះ តើលោក ប៊ុន សិរិទ្ធ អាចទទួលរងការចោទប្រកាន់ពីព្រះរាជអាជ្ញាបានដែរ ឬទេ ?បើបានតើពីបទល្មើសអ្វី ?

ការកំណត់បទល្មើស :

(បដិញ្ញាធំ) :មាត្រា ៥១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី ១០-០៩-១៩៩២ ចែងថា "ជនណាដែលទទួល ឬទិញទ្រព្យសម្បត្តិដែលខ្លួនបានដឹងថា ទ្រព្យសម្បត្តិនោះបានមកអំពីអំពើចោរកម្ម ពីការឆបោក ឬមកអំពីបទមជ្ឈិម ឬបទឧក្រិដ្ឋ ណាមួយត្រូវមានទោសមជ្ឈិមពីបទទទួលផលចោរកម្ម ហើយត្រូវផ្តន្ទាទោសដាក់គុកពី ១ ឆ្នាំ ទៅ ៥ ឆ្នាំ..."

យោងតាមបទប្បញ្ញត្តិនៃមាត្រានេះ ចាត់ទុកជាបទល្មើសទទួលផលចោរកម្មបាននៅពេល ដែលជនល្មើសបានទទួល ឬទិញទ្រព្យសម្បត្តិ ដោយដឹងថា ទ្រព្យសម្បត្តិនោះមានប្រភពចេញពីបទល្មើសមជ្ឈិម ឬបទល្មើសឧក្រិដ្ឋ ។

(បដិញ្ញាតូច): យោងតាមអង្គហេតុខាងលើ លោក ប៊ុន សិរិទ្ធ បានទិញ និងរក្សាម៉ូតូនោះ ដោយបានដឹងយ៉ាងច្បាស់ថា ម៉ូតូ នោះ ជាម៉ូតូដែលជាផលចោរកម្មរបស់លោក ស៊ិន សារុន ។ ចេតនាទុច្ចិតរបស់លោក ប៊ុន សិរិទ្ធ ក្នុងអំពើរឹតតែស្តែងចេញយ៉ាងច្បាស់ទៀត ដោយយោងតាមធាតុមួយចំនួនដូចតទៅ :

- លោក ប៊ុន សិរិទ្ធ បានសំរេចទិញម៉ូតូនោះភ្លាម។ ទោះបីជាគាត់មានការសង្ស័យថា ម៉ូតូនោះអាចជាម៉ូតូដែលជាផលនៃចោរកម្មក៏ដោយ ។ ការសង្ស័យនេះ រឹតតែច្បាស់ថែមទៀតបើយើងពិនិត្យទៅលើតម្លៃម៉ូតូដែលលោក ស៊ិន សារុន បានលក់ឱ្យគាត់ ។ អង្គហេតុត្រឹមនេះ ក៏អាចបញ្ជាក់អំពីចេតនាទុច្ចរិតបេស់លោក ប៊ុន សិរិទ្ធ ក្នុងអំពើទទួលផល-ចោរកម្មនោះ ។ នេះយើងមិនទាន់ពិនិត្យដល់សម្មតិកម្មដែលថា ម៉ូតូដែលលោក ប៊ុន សិរិទ្ធ បានទិញគ្មានប័ណ្ណសំគាល់ទោចចក្រយាន យន្តនោះផង ដែលសម្មតិកម្មនេះអាចបញ្ជាក់យ៉ាងច្បាស់អំពីប្រភពដើមរបស់ម៉ូតូនោះ ។ ហេតុដូច្នេះ លោក ប៊ុន សិរិទ្ធ ពុំ អាចលើកឡើងនូវអំណះអំណាងដែលគួរឱ្យជឿជាក់ថា គាត់បានទិញម៉ូតូដោយមានចេតនាសុចរិត ហើយថា គាត់ទិញម៉ូតូ ដោយមិនដឹងថាជាម៉ូតូដែលចេញពីការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនោះទេ ។

- ជាងនេះទៅទៀត ចេតនាទុច្ចរិតរបស់លោក ប៊ុន សិរិទ្ធ រឹតតែច្បាស់ នៅពេលដែលគាត់បានយកម៉ូតូនោះទៅលាក់ទុក បន្ទាប់ពីបានទទួលដំណឹងយ៉ាងពិតប្រាកដថា ម៉ូតូដែលខ្លួនបានទិញនោះពិតជាម៉ូតូដែលលោក ស៊ិន សារុន បានលួចពីអ្នកស្រី ចន្ទ ពិតប្រាកដមែន ។ និយាយម៉្យាងទៀតថា ការយកម៉ូតូទៅលាក់ទុកក្នុងផ្ទះ និងការយកម៉ូតូមកប្រើ

Scanned with CamScanner

ប្រាស់ នាពេលមួយឆ្នាំក្រោយពីការទិញ បង្ហាញយ៉ាងជាក់ច្បាស់អំពីចេតនាទុច្ចរិតរបស់លោក ប៊ុន សិរិទ្ធ ក្នុងការលាក់ទុកវត្ថុចោរកម្ម និងដើម្បីមិនអនុញ្ញាតឱ្យនគរបាល ឬជនដទៃផ្សេងទៀត អាចរកម៉ូតូនោះឃើញ ។

(សន្និដ្ឋាន) : ដូចនេះ លោក ប៊ុន សិរិទ្ធ ពិតជាបានប្រព្រឹត្តអំពើទទួលផលចោរកម្មដែលជាបទល្មើសមានចែង និងផ្តន្ទាទោស ដោយមាត្រា ៥១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

អាជ្ញាយុកាលក្នុងការចោទប្រកាន់ :

(បដិញ្ញាធំ) : ដោយហេតុថា មាត្រា ៥១ ស្ថិតនៅក្នុងមាតិកា ៥ ស្តីពី "បទល្មើសមជ្ឈិម" នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ដូចនេះ បទល្មើសទទួលផលចោរកម្ម គឺជាប្រភេទបទល្មើសមជ្ឈិម ។ ដូចនេះ អាជ្ញាយុកាលសំរាប់បទល្មើសទទួលផលចោរកម្ម គឺមានរយៈពេល ៣ ឆ្នាំ ដោយឈរលើមូលដ្ឋាននៃមាត្រា ៣០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។ ជាទូទៅ អាជ្ញាយុកាលនេះ ត្រូវចាប់ផ្តើមរាប់ គិតពីថ្ងៃប្រព្រឹត្តបទល្មើស ប្រសិនបើបទល្មើសនោះត្រូវបានគេចាត់ចូលក្នុងប្រភេទបទល្មើសភ្លាមៗ ពុំមែនជាបទល្មើសហូរហែ ឬនិរន្តរ៍ ។ ចំណែកបទល្មើហូរហែ ឬនិរន្តរ៍ អាជ្ញាយុកាលត្រូវចាប់ផ្តើមរាប់ជាគោលការណ៍ ចាប់ពីថ្ងៃដែលអំពើជាសំភារៈចុងក្រោយនៃបទល្មើសត្រូវបានបំពេញ ។

(បដិញ្ញាតូច) : នៅក្នុងអង្គហេតុ បទល្មើសទទួលផលចោរកម្មមិនមែនជាប្រភេទបទល្មើសភ្លាមៗទេ ផ្ទុយទៅវិញ ការទទួលផលចោរកម្ម គឺត្រូវបានគេចាត់ចូលក្នុងប្រភេទបទល្មើសជាប់ជាហូរហែរ ឬបទល្មើសនិរន្តរ៍ ព្រោះថា អំពើទទួលផលចោរកម្ម នេះជាអំពើដែលការប្រព្រឹត្តអំពើនេះអូសបន្លាយ នៅក្នុងរយៈពេលមួយរំពែងប្រកបដោយចេតនាទុច្ចរិតជាប់រហូតរបស់ជនល្មើសក្នុងការរក្សា ឬទទួលផលពីវត្ថុដែលចេញពីបទល្មើសនោះ ។ ដូចនេះ អាជ្ញាយុកាលសម្រាប់បទល្មើសទទួលផលចោរកម្មដែលជាប្រភេទមួយនៃបទល្មើសនិរន្តន៍នោះ ត្រូវចាប់ផ្តើមរាប់គិតពីថ្ងៃដែលបទល្មើសនោះបានបញ្ចប់ គឺនៅថ្ងៃដែលវត្ថុនោះ លែងនៅក្នុងដៃរបស់ជនល្មើស ឬត្រូវបានជនល្មើសរំលួសវត្ថុនោះចេញ ឬនិយាយជាទូទៅ គឺនៅពេលអំពើសំភារៈចុងក្រោយ នៃការទទួលផលចោរកម្មបានបញ្ចប់[១៣៣] ។

(បដិញ្ញាតូច) : យោងតាមអង្គហេតុខាងលើ យើងសង្កេតឃើញថា លោក ប៊ុន សិរិទ្ធ បានប្រព្រឹត្តអំពើទទួលផលចោរកម្ម ចាប់តាំងពីឆ្នាំ ២០០១ ហើយនៅតែរក្សា និងប្រើប្រាស់ម៉ូតូជារឿងរហូតមក ដោយហេតុថា គ្មានអ្វីបញ្ជាក់ថា គាត់បានផ្តាច់ចេញពីម៉ូតូនោះទេ ផ្ទុយមកវិញ គាត់ទើបតែបានយកម៉ូតមកប្រើប្រាស់ចាប់តាំងពីឆ្នាំ ២០០២ ប៉ុណ្ណោះ ។ ដូចនេះ ការទទួលផលចោរកម្មរបស់លោក ប៊ុន សិរិទ្ធ មិនទាន់បានបញ្ចប់ទេ ហើយអាជ្ញាយុកាលនៃអំពើនេះ ក៏មិនទាន់ត្រូវចាប់ផ្តើមរាប់គិតពីឆ្នាំ ២០០១ នោះដែរ ។ តាមពិត លោក ប៊ុន សិរិទ្ធ មិនទាន់បានបញ្ចប់នូវអំពើជាសំភារៈនៃបទល្មើសទទួលផលចោរកម្ម នោះទេ ។

---

[១៣៣] បើយោងតាមមាត្រា ១១១ នៃក្រមព្រហ្មទណ្ឌចាស់ អាជ្ញាយុកាលនៃបទល្មើសត្រូវកំណត់ថ្ងៃពីត្រឹមថ្ងៃឈប់ធ្វើនូវអំពើដែលជាតួនៃបទល្មើសនោះ ប្រសិនបើបទល្មើសនោះត្រូវប្រព្រឹត្តជាប់រឿងមក ឬប្រព្រឹត្តច្រើនមក (ដែលបទល្មើសប្រភេទនេះ គេឱ្យឈ្មោះថាជាបទល្មើសជាប់ជាហូរហែរ ឬជាបទល្មើសនិរន្តរ៍) ។

Scanned with CamScanner

(សន្និដ្ឋាន) : ដូចនេះ អាជ្ញាយុកាលនៃបណ្តឹងអាជ្ញាមិនទាន់រលត់ ព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់លោក ប៊ុន សិរិទ្ធ ពីបទទទួលផលចោរកម្មបានដោយឈរលើមូលដ្ឋាននៃមាត្រា ៥១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលដែលគាត់បានទិញម៉ូតូ ដែលបានមកពីបទល្មើសលួចប្រព្រឹត្តដោយលោក ស៊ិន សារុន ។

(សន្និដ្ឋានទូទៅ) : បណ្តឹងអាជ្ញាមិនទាន់ត្រូវបានផុតអាជ្ញាយុកាលនោះទេ ។ ព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់លោក ស៊ិន សារុន បានចំពោះអំពើចោរកម្មដែលលោក ស៊ិន សារុន ប្រព្រឹត្តកាលពីចុងឆ្នាំ ២០០៤ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបទប្បញ្ញត្តិនៃមាត្រា ៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងលោក ប៊ុន សិរិទ្ធ ពីបទទទួលផលចោរកម្ម យោងតាមមាត្រា ៥១ នៃច្បាប់ដដែលនេះ ។ ផ្ទុយទៅវិញ ព្រះរាជអាជ្ញា មិនអាចធ្វើការចោទប្រកាន់លោក ស៊ិន សារុន ដោយឈរលើអំពើចោរកម្មដែល លោក ស៊ិន សារុន បានប្រព្រឹត្តកាលពីថ្ងៃទី ០១-០១-២០០១ បានឡើយ ព្រោះថា បទល្មើសនេះ បានផុតអាជ្ញាយុកាលដែលជាហេតុធ្វើឱ្យមានការរំលត់បណ្តឹងអាជ្ញាទៅហើយ ។

ឃ. និតិគារខារ :

១. អត្ថហេតុ

សណ្ឋាគារដ៏ធំមួយឈ្មោះ ឥន្ទ្រៈ ចាប់ផ្តើមការវិនិយោគរបស់ខ្លួននៅទីក្រុងភ្នំពេញនៅឆ្នាំ ១៩៩៨ ។ សណ្ឋាគារនេះ បានចាប់ផ្តើមជ្រើសរើសនិយោជិតចំនួន ១០ នាក់ ផ្នែកសន្តិសុខ, ១០ នាក់ទៀត ផ្នែកសំអាត និងនិយោជិតក្នុងមុខងារផ្សេងៗទៀត ។ នៅថ្ងៃទី ០១-០៥-១៩៩៨ កុសល, វិរៈ, ចិន្តា, និមិត្ត និងកុម្ភៈ បានចុះកិច្ចសន្យាការងារខាងផ្នែកសន្តិសុខ មានរយៈពេលចំនួន ១ ឆ្នាំ អាចបន្តកិច្ចសន្យាសាជាថ្មីបាន ។ មីនា, មេសា, ឧសភា បានចុះកិច្ចសន្យាការងារខាងផ្នែកសំអាត មានរយៈពេលកំណត់ចំនួន ៥ ខែ អាចបន្តកិច្ចសន្យាសាជាថ្មីបាន ។ ដល់រយៈពេលកំណត់នៃកិច្ចសន្យាទាំងពីរប្រភេទខាងលើ កិច្ចសន្យាទាំងនេះត្រូវបានបន្តសាជាថ្មីជាលើកទី ១ ។ នៅពេលចុងបញ្ចប់នៃការបន្តសាជាថ្មីនៅលើកទី ១ នេះ កិច្ចសន្យាទាំងពីរប្រភេទដដែលក៏ត្រូវបានបន្តសាជាថ្មីទៀតជាលើកទី ២ ។ កុម្ភៈ ក៏បានជ្រើសតាំងជាប្រតិភូបុគ្គលិកនៃសណ្ឋាគារ ។ ក៏ប៉ុន្តែ នៅឆ្នាំ ២០០៣ ដោយមូលហេតុនៃជំងឺសាស ចំនួនភ្ញៀវទេសចរណ៍ត្រូវបានថយចុះដែលធ្វើឱ្យសណ្ឋាគារ ជួបប្រទះផល លំបាកខាងផ្នែកសេដ្ឋកិច្ច ។ នៅខែ មករា ឆ្នាំ ២០០៤ សណ្ឋាគារក៏បានសម្រេចបញ្ឈប់ការងារនិយោជិតចំនួន ៨ នាក់ ភ្លាមៗ ដោយគ្មានទទួលបានទូវាប្រាក់ជម្ងឺចិត្តពីការបណ្តេញចេញនោះទេ ដែលក្នុងនោះមាន កុសល, វិរៈ, កុម្ភៈ, និមិត្ត, ចិន្តា, មីនា, មេសា និងឧសភា ។ បីខែក្រោយមក សណ្ឋាគារចាប់ផ្តើមដំណើរការសាជាថ្មីឡើងវិញ ហើយអតិថិជនក៏ចាប់មានត្រលប់មកវិញផងដែរ ។ ក៏ប៉ុន្តែ សណ្ឋាគារទទួលយកតែកុសល ម្នាក់គត់ឱ្យចូលបំរើការងារឡើងវិញ ហើយជ្រើសរើសនិយោងជិតចំនួន ១០ នាក់ថ្មីទៀត ដើម្បីបំពេញការងារផ្នែកសំអាត និងសន្តិសុខ ។ និយោជិតទាំង ៧ នាក់ ដែលត្រូវបានបណ្តេញចេញ មានការខឹងសម្បាជាខ្លាំង ហើយក៏បានមកសាកសួរយោបល់ពីអ្នក អំពីការបញ្ជូលពួកគេឱ្យបំពេញការងារជាថ្មីឡើងវិញ ។

Scanned with CamScanner

២. កិច្ចសន្យាការងារ (កាន ច័ន្ទមេត្តា)

កិច្ចសន្យាការងារមានរយៈពេលកំណត់ចំនួន ០៨ ត្រូវបានធ្វើឡើងរវាងនិយោជក សណ្ឋាគារឥន្ទ្រៈ និងនិយោជិត ដែលមានឈ្មោះ កុសល វិរៈ ចិន្តា និមិត្ត កុម្ភៈ មីនា មេសា និងឧសភា ។ កិច្ចសន្យាការងារចំនួន ០៥ ដំបូង ទាក់ទងនឹងមុខងារខាងសន្តិសុខ សម្រាប់រយៈពេលមួយឆ្នាំ ចំណែកកិច្ចសន្យាការងារចំនួន ០៣ បន្ទាប់ទៀត ទាក់ទងនឹងមុខងារខាងសំអាត សម្រាប់រយៈពេល ៩ ខែ ។ ក្រោយពីការមានបន្តកិច្ចសន្យាសាជាថ្មីចំនួន ០២ លើក និយោជិតចំនួន ០៨ នាក់ ដែលក្នុងនោះមាន កុម្ភៈ ផងដែរ ជាប្រតិភូបុគ្គលិកនៃសណ្ឋាគារ ត្រូវបានចូលទៅក្នុងបញ្ជីនៃការបណ្តេញចេញភ្លាម ១ បន្ទាប់ពីមានការថយចុះនៃភ្ញៀវទេសចរណ៍នៅឆ្នាំ ២០០៤ ដោយមូលហេតុនៃជម្ងឺសាស ។ បន្ទាប់ពីមានការស្តារសកម្មភាពរបស់សណ្ឋាគារឡើងវិញ មាននិយោជិតថ្មីជាច្រើននាក់ត្រូវបានជ្រើសរើសឱ្យចូលបំពេញការងារ ដែលក្នុងនោះមាន កុសល ផងដែរ ប៉ុន្តែ គ្មាននិយោជិតចាស់ទាំង ០៧ នាក់ ដែលត្រូវបានបណ្តេញចេញនោះទេ ។

ក្នុងករណីនេះ បញ្ហាគតិយុត្ត ត្រូវបានចោទឡើងទាក់ទងនឹងភាពប្រក្រតី ឬមិនប្រក្រតីនៃការបណ្តេញចេញជារួម និងអានុភាពរបស់វា ។

I. ភាពមិនប្រក្រតីនៃការបណ្តេញចេញជារួម

មុននឹងដឹងថា តើការបណ្តេញចេញដែលត្រូវបានធ្វើឡើងដោយនិយោជក មានភាពប្រក្រតី ឬគ្មាន យើងត្រូវកំណត់ជាដំបូងថា តើច្បាប់ការងារអាចត្រូវបានអនុវត្តក្នុងរឿងវិវាទនេះដែរឬទេ ? ហើយថាតើកិច្ចសន្យាការងារទាំង ០៨ ខាងលើនោះ មានចរិតលក្ខណៈជាប្រភេទកិច្ចន្យាការងារអ្វី ?

ក. ដែនអនុវត្តនៃច្បាប់ការងារចុះថ្ងៃទី ១៣.០៣.១៩៩៧ :

(បដិញ្ញាធំ) : វាក្យខណ្ឌទី ១ និងទី ២ នៃមាត្រា ១ នៃច្បាប់ការងារ ចែងថា ច្បាប់នេះគ្រប់គ្រងរាល់ទំនាក់ទំនងដែលកើតចេញពីកិច្ចសន្យាការងាររវាងនិយោជក និងកម្មករនិយោជិត ដើម្បីយកមកអនុវត្តលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទោះបីកិច្ចសន្យានោះធ្វើឡើងនៅទីណាក៏ដោយ ទោះបីភាគីទាំងនោះមានសញ្ជាតិជាអ្វី ហើយស្នាក់នៅទីណាក៏ដោយ ។ ច្បាប់នេះ អនុវត្តចំពោះសហគ្រាស ឬគ្រឹះស្ថានឧស្សាហកម្ម រ៉ែ ពាណិជ្ជកម្ម សិប្បកម្ម សេវាកសិកម្ម ដឹកជញ្ជូនតាមផ្លូវគោក ឬតាមផ្លូវទឹក ទោះជាប្រយោជន៍សាធារណៈ ពាក់កណ្តាលសាធារណៈ ឬឯកជន ក្រៅសាសនា ឬក្នុងសាសនាក៏ដោយ ទោះមានលក្ខណៈជាការបង្រៀនវិជ្ជាជីវៈ ឬជាការកុសលក៏ដោយ ព្រមទាំងវិជ្ជាជីវៈសើរនៃសមាគម ឬនៃក្រុមប្រភេទណាក៏ដោយ ។

(បដិញ្ញាតូច): សណ្ឋាគារឈ្មោះ ឥន្ទ្រៈ មានទីតាំងនៅក្នុងទីក្រុងភ្នំពេញ រាជធានីនៃព្រះរាជាណាចក្រកម្ពុជា ហើយកិច្ចសន្យាការងារចំនួន ០៨ ខាងលើ ត្រូវបានធ្វើឡើង ដើម្បីអនុវត្តក្នុងទីក្រុងភ្នំពេញនេះតែម្តង ។ ម៉្យាងវិញទៀត សកម្មភាពរបស់សណ្ឋាគារឥន្ទ្រៈ គឺជាសកម្មភាពពាណិជ្ជកម្មដែលត្រូវបានគ្រប់គ្រង ដោយច្បាប់ស្តីពីការចុះបញ្ជី ពាណិជ្ជកម្ម ។

(សន្និដ្ឋាន) : បទប្បញ្ញត្តិនៃច្បាប់ការងារចុះថ្ងៃទី ១៣-០៣-១៩៩៧ ត្រូវបានអនុវត្តក្នុងរឿងវិវាទខាងលើនេះ ។

យើងត្រូវកំណត់ចរិតលក្ខណៈ ឬប្រភេទនៃកិច្ចសន្យាការងារទាំង ០៨ ជាបន្តទៀត ។

Scanned with CamScanner

ខ. ការកំណត់ចរិតលក្ខណៈនៃកិច្ចសន្យាការងារទាំង ០៨

(បដិញ្ញាធំ) : អនុលោមតាមមាត្រា ៦៦ នៃច្បាប់ការងារ ជនម្នាក់ៗអាចធ្វើការយកឈ្នួលបានតែតាមពេលវេលា ទោះក្នុងចិរវេលាកំណត់ក្តី ចំពោះកិច្ចការណាមួយជាកំណត់ ទោះក្នុងចិរវេលាមិនកំណត់ក្តី ។ ក្នុងន័យនេះ កិច្ចសន្យាការងារត្រូវបានបែងចែកជាពីរប្រភេទ គឺកិច្ចសន្យាការងារមានរយៈពេលកំណត់ និងមានរយៈពេលមិនកំណត់ ។ ប៉ុន្តែ ចំនុចទី ២ នៃមាត្រា ៦៧ នៃច្បាប់ដដែល ចែងបន្ថែមទៀតថា កិច្ចសន្យាការងារដែលធ្វើឡើងដោយការព្រមព្រៀងគ្នា ដោយមានកំណត់ចិរវេលាពិតប្រាកដ មិនអាចមានរយៈពេលលើសពីពីរឆ្នាំបានឡើយ ។ កិច្ចសន្យានេះអាចបន្តសាជាថ្មីម្តង ឬច្រើនដងបាន ដរាបណាការបន្តសាជាថ្មីនោះមានចិរវេលាអតិបរមាមិនលើសពីពីរឆ្នាំ ។ ការអនុវត្តផ្ទុយនឹងវិធានខាងដើម នាំឱ្យកិច្ចសន្យាការងារ នោះក្លាយជាកិច្ចសន្យាដែលគ្មានកំណត់ចិរវេលាពិតប្រាកដ ។

(បដិញ្ញាតូច) : យោងតាមអង្គហេតុ ក្នុងចំណោមកិច្ចសន្យាការងារចំនួន ០៨ ខាងលើ មានកិច្ចសន្យាការងារចំនួន ០៥ មានរយៈពេលកំណត់ចំនួន ១០ ខែ និងកិច្ចសន្យាការងារចំនួន ០៣ ទៀត មានរយៈពេលកំណត់ចំនួន ០៩ ខែ ។ កិច្ចសន្យាការងារទាំង ០៨ នោះ ត្រូវបានបន្តសាជាថ្មីចំនួន ០២ លើកជាបន្តបន្ទាប់ មានន័យថា រយៈពេលសរុបនៃកិច្ចសន្យាការងារចំនួន ០៥ ដំបូង គឺ ៣ ឆ្នាំ ចំណែករយៈពេលសរុបនៃកិច្ចសន្យាការងារចំនួន ០៣ ចុងក្រោយ គឺ ២៧ ខែ ។ រយៈពេលនៃកិច្ចសន្យាទាំង ០៨ នេះ សុទ្ធសឹងតែលើសរយៈពេល ២៤ ខែ ។

(សន្និដ្ឋាន) : ហេតុដូច្នេះ កិច្ចសន្យាការងារទាំង ០៨ នេះ ត្រូវបានកំណត់ចរិតលក្ខណៈសាជាថ្មី គឺជាប្រភេទកិច្ចសន្យាការងារមានចិរវេលាមិនកំណត់ ។

គ.ភាពមិនប្រក្រតីនៃការបណ្តេញចេញពីការងាររួមគ្នានៃនិយោជិតដែលភ្ជាប់ដោយកិច្ចសន្យាការងារមានចិរវេលាមិនកំណត់ :

(បដិញ្ញាធំ) : ស្របតាមបទប្បញ្ញត្តិនៃមាត្រា ៧៤ នៃច្បាប់ការងារ កិច្ចសន្យាការងារដែលមានចិរវេលាមិនកំណត់ អាចរំលាយតាមឆន្ទៈភាគីតែម្ខាងបាន ។ ការរំលាយកិច្ចសន្យានេះត្រូវអនុវត្តទៅតាមរបៀបអោយដំណឹងមុនជាលាយលក្ខណ៍អក្សរ ដែលភាគីមានបំណងចង់រំលាយកិច្ចសន្យាត្រូវអោយទៅភាគីម្ខាងទៀត ។ ក៏ប៉ុន្តែ គ្មានការបញ្ឈប់ណាមួយ អាចធ្វើទៅបាន ដោយគ្មានហេតុផលសមរម្យទាក់ទងនឹងសម្បទា ឬចរិយានៃកម្មករនិយោជិត យោលទៅលើភាពចាំបាច់នៃដំណើរបស់សហគ្រាស របស់គ្រឹះស្ថាន ឬរបស់ក្រុមឡើយ ។ ម៉្យាងវិញទៀត មាត្រា ៩៥ វាក្យខណ្ឌទី ១ ដល់ទី ៤ នៃច្បាប់ដដែល បញ្ជាក់ថា ការបញ្ឈប់ការងារដោយមកពីការបន្ថយសកម្មភាពនៃគ្រឹះស្ថាន ឬមកពីការរើរៀបចំផ្ទៃក្នុងដែលនិយោជកមានបំណងធ្វើ ត្រូវប្រតិបត្តិតាមនីតិវិធីដូចតទៅ :

- និយោជកត្រូវរៀបចំលំដាប់នៃការបញ្ឈប់ការងារ ដោយគិតទៅតាមគុណសម្បត្តិនៃវិជ្ជាជីវៈ អតីតភាពក្នុងគ្រឹះស្ថាន និងបន្ទុកគ្រួសារនៃកម្មករនិយោជិត

Scanned with CamScanner

- និយោជកត្រូវអោយដំណឹងជាលាយលក្ខណ៍អក្សរ ទៅតំណាងកម្មករនិយោជិត ដើម្បីទទួលសេចក្តីស្នើអំពីជននេះ ជាអាទិ៍ វិធានការសំរាប់ប្រាប់មុននូវការបន្ថយចំនួនបុគ្គលិក និងវិធានការដើម្បីធ្វើអោយការបន្ថយបុគ្គលិកនោះ ប៉ះពាល់ជាអប្បរមា ទៅលើស្ថានភាពនៃសាមីកម្មករនិយោជិត

- ជាបឋម ត្រូវបញ្ឈប់ការងារកម្មករនិយោជិតណាដែលមានសម្បទាខាងវិជ្ជាជីវៈអន់ជាងគេ ។ បន្ទាប់មកក៏ត្រូវបញ្ឈប់កម្មករនិយោជិតដែលមានអតីតភាពតិចជាងគេ ។ អតីតភាពនេះត្រូវតំលើងមួយឆ្នាំសំរាប់កម្មករនិយោជិតណាដែលមានគូស្រករ ហើយនិងមួយឆ្នាំថែមទៀតក្នុងកូនធីមួយ១នៅក្នុងបន្ទុក ។

ក្នុងករណីការបណ្តេញចេញប្រតិភូបុគ្គលិក មាត្រា ២៩៣ វាក្យខណ្ឌទី ១ នៃច្បាប់ចាប់បង្ខំចំពោះនិយោជកត្រូវជូនសុំការអនុញ្ញាតជាមុនពីអធិការកិច្ចការងារ ។

(បដិញ្ញាតួច) : និយោជក សណ្ឋាគារ ឥន្ទ្រៈ បានបញ្ឈប់ការងារនិយោជិតចំនួន ០៨ នាក់ ដោយគ្មានការជូនដំណឹងជាមុន ដោយមូលហេតុនៃជម្ងឺ សាស ដែលបានកាត់បន្ថយភ្ញៀវទេសចរណ៍យ៉ាងសន្ធឹក ហើយការកាត់បន្ថយនេះ អាចត្រូវបានចាត់ទុកជាមូលហេតុនៃការបញ្ឈប់ពីការងារជារួមដែលមានចែងក្នុងមាត្រាខាងលើ ។ ប៉ុន្តែ និយោជក ពុំបានគោរពតាមនីតិវិធីដែលមានចែងក្នុងច្បាប់ការងារជាធរមាននោះទេ ។ តាមពិត និយោជក សណ្ឋាគារ ឥន្ទ្រៈ ពុំបានរៀបចំលំដាប់នៃការបញ្ឈប់ ដោយយោងទៅតាមគុណសម្បត្តិនៃវិជ្ជាជីវៈ អតីតភាពរបស់និយោជិតទាំង ០៨ នាក់ នៅក្នុងគ្រឹះស្ថាននោះទេ ។ ម៉្យាងវិញទៀត កុម្ភៈ ជាប្រតិភូបុគ្គលិកនៃសណ្ឋាគារ តែនិយោជកពុំបានពិគ្រោះយោបល់ជាមួយគាត់ ដើម្បីឱ្យដឹងពីមតិរបស់គាត់ទាក់ទងនឹងវិធានការ ដើម្បីទប់ស្កាត់ការកាត់បន្ថយបុគ្គលិកនោះទេ ជាពិសេស ដោយហេតុថា គាត់ជាប្រតិភូបុគ្គលិក សណ្ឋាគារ ដែលចង់បណ្តេញគាត់ចេញពីការងារ ត្រូវតែសុំការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីអធិការកិច្ចការងារ ។ នៅចុងបញ្ចប់ និយោជិតទាំង ០៧ នាក់ ពុំត្រូវបានកោះហៅឱ្យចូលបម្រើការងារឡើងវិញនោះទេ បន្ទាប់ពីមានការកើនឡើងភ្ញៀវ ទេសចរណ៍សាជាថ្មីឡើងវិញ តែសណ្ឋាគារបែរជាជ្រើសរើសយកនិយោជិតថ្មីទៀតដែលមានអតីតភាពការងារតិចជាង និយោជិតខាងលើទៅវិញ ។

(សន្និដ្ឋាន) : ដូច្នេះ យើងអាចលើកឡើងនូវការរំលោភវិធានដែលមានចែងក្នុងច្បាប់ការងារខាងលើនោះបាន ។ ចំណែកឯ ការបញ្ឈប់ការងារនិយោជិតទាំង ០៨ នាក់នោះ ត្រូវបានធ្វើឡើងដោយមានភាពមិនប្រក្រតី ។ ក៏ប៉ុន្តែ តើការបញ្ឈប់ការងារ ជារួមដែលមានភាពមិនប្រក្រតីនេះ ផ្តល់នូវអានុភាពអ្វីខ្លះ ?

II. អានុភាពនៃការបញ្ឈប់ពីការងារជារួមគ្មានប្រក្រតី : ការទទួលឱ្យចូលបម្រើការងារសាជាថ្មី ?

សំណួរសួរថា តើនិយោជិតទាំង ០៧ នាក់ អាចចូលបម្រើការងារសាជាថ្មីនៅក្នុងសណ្ឋាគារបានដែរ ឬទេ ? តើពួកគាត់អាចទាមទារឱ្យបង់សោហ៊ុយបណ្តេញចេញ បន្ទាប់ពីអនុវត្តនីតិវិធីនៃការដោះស្រាយវិវាទទាក់ទងនឹងចំណុចមួយ ក្នុងចំណោមចំណុចវិវាទខាងលើនេះដែរឬទេ ?

Scanned with CamScanner

ក. ការបញ្ឈូលនិយោជិតទៅក្នុងសហគ្រាស និងការបង់សោហ៊ុយបណ្តេញចេញ :

(បដិញ្ញាធំ) : ស្របតាមបទប្បញ្ញត្តិនៃមាត្រា ៩៥ វាក្យខណ្ឌទី ៥-៨ នៃច្បាប់ការងារ កម្មករនិយោជិតដែលត្រូវបញ្ឈប់ពីការងារនេះ ត្រូវបានរក្សាទុករវាងពីរឆ្នាំ នូវអាទិភាពក្នុងការទទួលអោយធ្វើការវិញក្នុងមុខងារប្រភេទដូចគ្នា ក្នុងសហគ្រាស។ កម្មករនិយោជិតដែលមានអាទិភាពទទួលអោយធ្វើការ ត្រូវអោយដំណឹងទៅនិយោជកអំពីការផ្លាស់ប្តូរអាសយដ្ឋានជាដរាប ចាប់តាំងពីថ្ងៃចេញពីក្រឹះស្ថានមក ។ ក្នុងករណីដែលមានកន្លែងទំនេរ និយោជកត្រូវប្រាប់សាមីខ្លួនតាមសំបុត្រអនុសិដ្ឋដែលមានបញ្ជាក់ថា បានទទួលហើយ ឬសំបុត្រជូនផ្ទាល់ដៃដែលមានចុះហត្ថលេខាថាបានទទួលហើយ ហើយដែលផ្ញើទៅអាសយដ្ឋានចុងក្រោយបង្អស់នៃកម្មករនិយោជិត ។ កម្មករនិយោជិតត្រូវទៅបង្ហាញខ្លួននៅក្រឹះស្ថាននោះ ក្នុងរយៈពេលប្រាំបីថ្ងៃ យ៉ាងយូរបំផុត ចាប់តាំងពីថ្ងៃទទួលសំបុត្រអោយដំណឹង ។

ម៉្យាងវិញទៀត អនុលោមតាមមាត្រា ៨៩ នៃច្បាប់ដដែល ប្រសិនបើកិច្ចសន្យាការងារត្រូវបញ្ឈប់ដោយឆន្ទៈរបស់និយោជកតែម្ខាង វើ្រលែងតែក្នុងករណីដែលកម្មករនិយោជិតមានកំហុសធ្ងន់ និយោជកត្រូវតែអោយទៅកម្មករនិយោជិត ដែលខ្លួនបញ្ឈប់ក្រៅពីអត្ថប្រយោជន៍នៃការអោយដំណឹងមុនដូចមានចែងក្នុងផ្នែកនេះស្រាប់ នូវប្រាក់បំណាច់បណ្តេញចេញដែលមានកិរិតស្មើនឹងប្រាក់ឈ្នួល ព្រមទាំងប្រាក់បន្ទាប់បន្សំចំនួនដប់ប្រាំថ្ងៃក្នុងមួយឆ្នាំការងារ ប្រសិនបើចិរវេលាធ្វើការលើសពីដប់ពីរខែឡើងទៅ ។ ប្រាក់បំណាច់បណ្តេញចេញអតិបរមាមិនអាចលើសប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំប្រាំមួយខែ នោះទេ ។

(បដិញ្ញាតូច) : និយោជកបានទទួលយក កុសល មកបម្រើការងារវិញ តែនិយោជិតចំនួន ០៧ នាក់ មិនត្រូវបានទទួលឱ្យចូលធ្វើការវិញនោះទេ បន្ទាប់ពីសកម្មភាពរបស់សណ្ឋាគារត្រូវបានស្តាជាថ្មីឡើងវិញ ។ ម៉្យាងវិញទៀត និយោជិតទាំង ០៧ នាក់នេះ ក៏ដូច កុសល ដែរ គឺមានអាទិភាពក្នុងការទទួលឱ្យចូលធ្វើការវិញក្នុងរយៈពេល ០២ ឆ្នាំ ដើម្បីបំពេញការងារប្រភេទដូចគ្នា ។ សណ្ឋាគារមិនបានគោរពតាមអាទិភាពនេះទេ ដោយហេតុថា និយោជកបានជ្រើសរើសយកនិយោជិតចំនួន ១០ នាក់ ថ្មីផ្សេងទៀត ដើម្បីបំពេញមុខងារដូចគ្នា មានន័យថា មានកន្លែងទំនេរចំនួន ១០ ផ្សេងទៀត ។ ប៉ុន្តែ និយោជកពុំបានជូនដំណឹងតាមសំបុត្រអនុសិដ្ឋ ឬសំបុត្រផ្ទាល់ដែលមានចុះហត្ថលេខថាបានទទួល ផ្ញើទៅអាសយដ្ឋានរបស់និយោជិតទាំង ០៧ នោះទេ ។ លើសពីនេះទៀត នៅពេលបញ្ឈប់ការងារ និយោជកក៏ពុំបានបង់សោហ៊ុយបណ្តេញ ចញ្ញដែលកម្រិតដោយច្បាប់ការងារខាងលើ ឱ្យទៅនិយោជិតនោះដែរ ។

(សន្និដ្ឋាន) : ហេតុដូច្នេះ និយោជិតទាំង ០៧ នាក់ អាចស្នើសុំទៅអធិការកិច្ចការងារ ដើម្បីឱ្យពួកគាត់អាចចូលបំពេញការងារសាជាថ្មីឡើងវិញ ដោយមូលហេតុនៃការរំលោភបំពាននីតិវិធីនៃការបញ្ឈប់ និងស្នើសុំឱ្យសណ្ឋាគារបង់សោហ៊ុយបណ្តេញចេញមកឱ្យខ្លួន ។

ចំណុចពិភាក្សាចុងក្រោយស្ថិតត្រង់ថា តើមាននីតិវិធីណាខ្លះដែលត្រូវបានអនុវត្តក្នុងការរកដំណោះស្រាយជម្លោះ ក្នុងសម្ថតិកម្មដែលនិយោជកពុំព្រមទទួលយកនិយោជិតទាំង ០៧ នាក់ ឱ្យចូលបម្រើការងារវិញ និងពុំព្រមបង់សោហ៊ុយបណ្តេញចេញ ?

Scanned with CamScanner

ខ. នីតិវិធីដែលត្រូវអនុវត្តដើម្បីរកដំណោះស្រាយនៃវិវាទ

(បដិញ្ញាធំ) : ស្របតាមទប្បញ្ញត្តិនៃមាត្រា ៣០២-៣១០ នៃច្បាប់ការងារ វិវាទការងារមួម គឺជាវិវាទដែលកើតឡើងរវាងនិយោជកម្នាក់ ឬច្រើននាក់ នឹងបុគ្គលរបស់ខ្លួនមួយចំនួន អំពីរឿងល័ក្ខខ័ណ្ឌការងារ ការប្រើប្រាស់សិទ្ធិដែលប្រគល់ឱ្យអង្គការវិជ្ជាជីវៈ ការត្រូវទទួលស្គាល់អង្គការវិជ្ជាជីវៈក្នុងសហគ្រាស បញ្ហានៃការទាក់ទងរវាងនិយោជក និងកម្មករនិយោជិត ហើយវិវាទនេះអាចបណ្តាលឱ្យសហគ្រាសប្រព្រឹត្តទៅពុំបានស្រួល ឬធ្វើអោយខូចសន្តិភាពសង្គម ។ ក្នុងករណីនេះ រឿងវិវាទត្រូវតែត្រូវបានជូនដំណឹងទៅអធិការកិច្ចការងារដែលមានសមត្ថកិច្ចតាមដែនដីដើម្បីធ្វើការផ្សះផ្សា ។ រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារត្រូវចាត់តាំងអ្នកផ្សះផ្សាម្នាក់ ។ ក្នុងករណីដែលការផ្សះផ្សាបានសម្រេច ការព្រមព្រៀងសះជា មានតម្លៃ និងអានុភាពដូចគ្នានឹងអនុសញ្ញារួមរវាងភាគីដែរ ។ ប៉ុន្តែ ក្នុងករណីដែលគ្មានការសះជានឹងគ្នានោះទេ រដ្ឋមន្ត្រីក្រសួងទទួល បន្ទុកវិស័យការងារត្រូវប្តឹងទៅក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេល បីថ្ងៃ ក្រោយពីបានទទួលរបាយការណ៍ពីអ្នកផ្សះផ្សា។

(បដិញ្ញាតូច): ការបញ្ឈប់ជារួមពីការងារ បង្កើតបានជាវិវាទរួម ដោយហេតុថា វិវាទនេះកើតឡើងរវាងនិយោជកសណ្ឋាគារឥន្ទ្រៈ និងនិយោជិតចំនួន ០៧ នាក់ ទាក់ទងនឹងលក្ខខណ្ឌនៃការបំពេញការងារ និងការទទួលស្គាល់អង្គការវិជ្ជាជីវៈនៅក្នុងសហគ្រាសក្រុមហ៊ុន ជាពិសេសដោយមូលហេតុនៃការកាត់បន្ថយភ្ញៀវទេសចរណ៍ និងសកម្មភាព ដើម្បីធានានូវទីផ្សាការងារ ឬសន្តិភាពសង្គម ។ ក្នុងករណីដែលសណ្ឋាគារពុំព្រមទទួលយកនិយោជិតទាំង ០៧ នាក់ឱ្យចូលបម្រើការងារវិញ និយោជិតអាចជូនដំណឹងទៅអធិការកិច្ចការងារ ។ បន្ទាប់ពីការជូនដំណឹង រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារចាត់តាំង អ្នកផ្សះផ្សាម្នាក់ ដើម្បីស្វែងរកចំណុចឯកភាពរវាងនិយោជិត និងនិយោជក ។ ប្រសិនបើនិយោជកគ្មានការឯកភាព បន្ទាប់ ពីបានធ្វើការសម្របសម្រួលនោះទេ រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារត្រូវប្តឹងទៅក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេល ០៣ ថ្ងៃ បន្ទាប់ពីបានទទួលរបាយការណ៍ពីអ្នកផ្សះផ្សា ។

(សន្និដ្ឋាន) : ដោយគោរពតាមនីតិវិធីនេះ និយោជិតទាំង ០៧ នាក់ អាចរង់ចាំសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញា-កណ្តាល ។ ភស្តុតាងអំពីការរំលោភនីតិវិធីនៃការបញ្ឈប់ជារួមពីការងារ និងការពុំបានទទួលនូវសោហ៊ុយបណ្តេញចេញនៅពេលបញ្ឈប់ ការងារ មានលក្ខណៈគ្រប់គ្រាន់ ដើម្បីអាចបានទទួលនូវសេចក្តីសម្រេចគួរឱ្យពេញចិត្តមួយ ។

ខ. និតិរដ្ឋបាល

១. អង្គហេតុ : (បណ្ឌិត ឈន សុភាព)

សាលាក្រុងភ្នំពេញ បានសម្រេចចុះកិច្ចសន្យាជាមួយក្រុមហ៊ុន ខេមរា ក្នុងការជុសជុលផ្លូវប្រវែង ៩ គម និងទទឹងផ្លូវទំហំ ១២ គម ។ កិច្ចសន្យានេះ ត្រូវបានធ្វើឡើងតាមនីតិវិធីត្រឹមត្រូវ បន្ទាប់ពីបានសុំការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ កិច្ចសន្យាបានកំណត់ថា ការជុសជុលត្រូវបញ្ចប់ក្នុងរយៈពេល ១ ឆ្នាំ ។ ប៉ុន្តែ ៦ ខែ ក្រោយមក សាលាក្រុងបានពិនិត្យឃើញថា ការជុសជុលទើបតែធ្វើរួចបានតែ ១០% ប៉ុណ្ណោះ ។ ដោយក្រុមហ៊ុនបំពេញការងារមាន

Scanned with CamScanner

លក្ខណៈយឺតយ៉ាវ សាលាក្រុងភ្នំពេញក៏បានសម្រេចលុបកិច្ចសន្យាមុនពេលកំណត់ បន្ទាប់ពីបានទទួលការយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

១.បើក្រុមហ៊ុនបដិសេធជំរុញការងារឱ្យបានល្អឿន

តើសាលាក្រុងមានសិទ្ធិលុបកិច្ចសន្យាជាឯកតោភាគីបានឬទេ ? ២.តើក្រុមហ៊ុន ខេមរា ទទួលបាននូវសិទ្ធិអ្វីខ្លះ បើកិច្ចសន្យាត្រូវបានលុបចោលមុនពេលកំណត់ ?

២. អំណះ : (ស៊ូ សុជាតិ)

កិច្ចសន្យាត្រូវបានធ្វើឡើងរវាងនីតិបុគ្គលសាធារណៈ (សាលាក្រុងភ្នំពេញ) និងក្រុមហ៊ុនឯកជនមួយ (ក្រុមហ៊ុន ខេមរា) ដែលទទួលខុសត្រូវក្នុងការសាងសង់ផ្លូវ ក្នុងរយៈពេលកំណត់ ១ ឆ្នាំ ។ ប៉ុន្តែ បន្ទាប់ពីរយៈពេល ៦ ខែ កន្លងទៅ លោកអភិបាលក្រុង បានសម្រេចលុបកិច្ចសន្យានេះជាឯកតោភាគី ដោយមូលហេតុនៃការយឺតយ៉ាវ ព្រោះថា ការជុសជុលផ្លូវទើបតែបានសម្រេចត្រឹមតែ ១០ % ប៉ុណ្ណោះ ។

ដើម្បីដឹងថា តើសាលាក្រុងអាចលុបចោលកិច្ចសន្យាដោយឯកតោភាគី ដែឬទេ ហើយតើមានលទ្ធផលអ្វីខ្លះចំពោះ ក្រុមហ៊ុន ខេមរា យើងត្រូវកំណត់ជាបឋមអំពីប្រភេទនៃកិច្ចសន្យានោះ ។

I. ចំពោះសំនួរទីមួយ :

ក. ប្រភេទគតិយុត្តនៃកិច្ចសន្យា :

វាជាការចាំបាច់ដែលយើងត្រូវដឹងថា តើកិច្ចសន្យាខាងលើជាប្រភេទកិច្ចសន្យាឯកជន ឬកិច្ចសន្យារដ្ឋបាល ដោយ ហេតុថា ការកំណត់ចរិតលក្ខណៈនេះ អាចនាំឱ្យយើងអាចកំណត់បានថា តើវិធាននៃនីតិឯកជន មានន័យថា ក្រឹត្យ-ច្បាប់លេខ ៣៨ ចុះថ្ងៃទី ២៨-១០-១៩៨៨ ឬវិធាននៃនីតិសាធារណៈ មានន័យថាអនុក្រឹត្យលេខ ៦០ ចុះថ្ងៃទី ៣១-០៧-១៩៩៥ ស្តីពី លទ្ធកម្មសាធារណៈ ដែលត្រូវអនុវត្តក្នុងករណីខាងលើនេះ ។

(បដិញ្ញាធំ) : ដើម្បីកំណត់ថា តើកិច្ចសន្យាមួយជាកិច្ចសន្យារដ្ឋបាល ឬកិច្ចសន្យាឯកជន គុណភាពរបស់ភាគីមានលក្ខណៈពុំគ្រប់គ្រាន់ក្នុងការវាយតម្លៃនោះទេ ។ តាមពិត វត្តមានរបស់នីតិបុគ្គលសាធារណៈតែឯង ក្នុងនាមជាភាគីនៃកិច្ចសន្យាមិនអនុញ្ញាតឱ្យយើងអាចកំណត់កិច្ចសន្យានោះ គឺជាកិច្ចសន្យារដ្ឋបាលនោះទេ ។ ការកំណត់ដូច្នេះ ត្រូវមានលក្ខណៈបន្ថែមទៀត គឺ ឬមួយ កិច្ចសន្យាត្រូវបានបង្កើតឡើងដើម្បីបម្រើសេវាសាធារណៈ ឬមួយមានវត្តមាននៃធាតុផ្សំហួសប្រមាណដែលផ្តាច់ចេញពីនៃនីតិរូម ។

(បដិញ្ញាតូច) : យោងតាមអង្គហេតុ កិច្ចសន្យាត្រូវបានបង្កើតឡើងរវាងរដ្ឋបាល និងក្រុមហ៊ុនឯកជន ។ កិច្ចសន្យានេះមានកម្មវត្ថុសាងសង់ផ្លូវមួយខ្សែ ។ ជាគោលការណ៍ ការសាងសង់ផ្លូវ គឺជាផ្នែកមួយនៃសមត្ថកិច្ចរបស់អាជ្ញាធររដ្ឋបាល ដោយហេតុថា វាជាសេវាសាធារណៈ ។ កិច្ចសន្យាដែលមានកម្មវត្ថុបម្រើសេវាសាធារណៈ និងដែលត្រូវបានធ្វើឡើងដោយមានភាគីម្ខាងជាអាជ្ញាធររដ្ឋបាល ត្រូវគោរពតាមគោលការណ៍ដែលបានចែងខាងលើ ។

Scanned with CamScanner

(សន្និដ្ឋាន) : ដូច្នេះ កិចសន្យាដែលត្រូវបានធ្វើឡើងរវាងសាលាក្រុង និងក្រុមហ៊ុនឯកជន ត្រូវបានចាត់ទុកជាកិច្ចសន្យាដែលមានលក្ខណៈជារដ្ឋបាល ។ កិចសន្យានេះស្ថិតនៅក្រោមការអនុវត្តនៃបទប្បញ្ញត្តិនៃអនុក្រឹត្យលេខ ៦០ ចុះថ្ងៃទី ៣១-០៧-១៩៩៥ ស្តីពីលទ្ធកម្មសាធារណៈ មានន័យថា ជារបបពិសេសមួយដែលក្នុងនោះមាត្រា ១ ចែងថា អនុក្រឹត្យនេះ មានកម្មវត្ថុកំណត់អំពីការធ្វើលទ្ធកម្មសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ កម្មវត្ថុនៃអនុក្រឹត្យ គឺបង្កើតជាវិធានផ្សេងៗ អនុវត្តទៅលើលទ្ធកម្មសាធារណៈ ។ បទប្បញ្ញត្តិទាំងនេះ មានទិសដៅធានាអោយបាននូវតម្លាភាព, ភាពត្រឹមត្រូវ និងការឯកភាព នៅក្នុងនីតិវិធីចុះលទ្ធកម្មសាធារណៈ ព្រមទាំងធានាសេដ្ឋកិច្ច និងប្រសិទ្ធភាពនៃការធ្វើលទ្ធ-កម្មផ្គត់ផ្គង់, លទ្ធកម្មសេវាសាធារណការ និងកិច្ចសន្យាទីប្រឹក្សា ។

ខ. លទ្ធភាពក្នុងការលុបចោលកិច្ចសន្យាជាឯកតោភាគីដោយអាជ្ញាធររដ្ឋបាល :

(បដិញ្ញាធំ) : កិច្ចសន្យារដ្ឋបាលស្ថិតនៅក្រោមរបបពិសេសដែលធ្វើបដិបញ្ញត្តជាមួយនឹងវិធាននៃនីតិរូម ។ វិធានដែលគ្រប់គ្រងលើការអនុវត្តកិច្ចសន្យារដ្ឋបាល ពុំមានភាពដូចគ្នានឹងវិធានដែលគ្រប់គ្រងលើកិចសន្យាឯកជននោះទេ ជាពិសេសយោងតាមមាត្រា ២២ នៃក្រឹត្យ-ច្បាប់លេខ ៣៨ កិច្ចសន្យាមិនអាចត្រូវបានលុបចោលមុនពេលកំណត់នោះទេ ដោយឆន្ទៈជាឯកតោភាគីរបស់ភាគីម្ខាងនោះទេ គឺត្រូវឡើងដោយឆន្ទៈរបស់គូភាគីទាំងសងខាង ។ ផ្ទុយមកវិញ ចំពោះកិច្ច-សន្យារដ្ឋបាល បុព្វសិទ្ធិរបស់អាជ្ញាធរសាធារណៈមានសារៈសំខាន់គួរឱ្យកត់សំគាល់ ។ អាជ្ញាធររដ្ឋបាលមានអំណាចក្នុងការត្រួតពិនិត្យ ដឹកនាំ ដាក់ទណ្ឌកម្ម កែប្រែ និងលុបចោលកិច្ចសន្យាដោយឯកតោភាគី មានន័យថា ដោយពុំចាំបាច់មានការយល់ព្រមពីភាគីម្ខាង ទៀតនោះទេ ។ បុព្វសិទ្ធិនេះ ស្ថិតនៅជារបស់អាជ្ញាធររដ្ឋបាល ទោះបីជាលក្ខខណ្ឌនេះពុំបានចែងឱ្យបានច្បាស់នៅក្នុងកិច្ចសន្យាក៏ដោយ ។ សិទ្ធិអំណាចក្នុងការលុបចោលកិច្ចសន្យាជាឯកតោភាគីអាចត្រូវបានអនុវត្តដោយអាជ្ញាធររដ្ឋបាលជាភាគីនៃកិច្ចសន្យា ឬមួយក្នុងន័យជាការដាក់ទណ្ឌកម្ម ឬមួយក្នុងន័យដើម្បីបម្រើផល-ប្រយោជន៍សាធារណៈ បើទោះបីជាភាគីម្ខាង ទៀតពុំបានប្រព្រឹត្តនូវកំហុសក៏ដោយ ។

(បដិញ្ញាតូច) : នៅក្នុងអង្គហេតុ សាលាក្រុងភ្នំពេញ គឺជាបុគ្គលសាធារណៈ មានអំណាចហួសប្រមាណ គឺអំណាចក្នុងការលុបចោលកិច្ចសន្យាដោយឯកតោភាគី ។ សាលាក្រុងអាចអនុវត្តសិទ្ធិអំណាចនេះ ដោយហេតុថា ក្រុមហ៊ុន ខេមរា មិនបានគោរពតាមរយៈពេលនៃការសាងសង់ដែលមានចែងក្នុងកិច្ចសន្យានោះទេ ។ រយៈពេលពាក់កណ្តាល ត្រូវបានកន្លងផុតរួចហើយ តែការងារសាងសង់ទើបតែសម្រេចបានត្រឹមតែ ១០ ភាគរយប៉ុណ្ណោះ ។ ដើម្បីលុបចោលកិចសន្យានេះ សាលាក្រុងពុំចាំបាច់សុំការយល់ព្រមពីភាគីក្រុមហ៊ុន ខេមរា នោះទេ ។

(សន្និដ្ឋាន) : ដូច្នេះ សាលាក្រុងភ្នំពេញ អាចលុបចោលកិច្ចសន្យាខាងលើនេះ ដោយឯកតោភាគី ដោយពុំអាចមានការជំទាស់ប្រឆាំងពីក្រុមហ៊ុន ខេមរា នោះឡើយ ។

II. សំណួរទី ២

ក្នុងករណីនេះ យើងត្រូវកំណត់អំពីអានុភាពនៃការលុបចោលកិច្ចសន្យាដោយឯកតោភាគីចំពោះក្រុមហ៊ុន ខេមរា ជាពិសេសយើងចង់ដឹងថា តើក្រុមហ៊ុននេះអាចទទួលបាននូវសោហ៊ុយអ្វីខ្លះ ?

Scanned with CamScanner

(បដិញ្ញាធំ) : ក្នុងករណីដែលកិច្ចសន្យាមួយត្រូវបានលុបចោលអាជ្ញាធររដ្ឋបាល ភាគីម្ខាងទៀតអាចមានសិទ្ធិទទួលបានទូវសោហ៊ុយ បើសិនជាភាគីនោះមិនបានប្រព្រឹត្តទូវកំហុសអ្វីនោះទេ ។

(បដិញ្ញាតុច) : នៅក្នុងអង្គហេតុ សាលាក្រុងភ្នំពេញសម្រេចលុបចោលកិច្ចសន្យាដោយឯកតោភាគី ដោយហេតុថា ការសាងសង់ផ្លូវត្រូវបានសម្រេចត្រឹមតែ ១០ ភាគរយប៉ុណ្ណោះ ក្នុងរយៈពេល ៦ ខែ ។ យើងអាចទាញថា ទោះបីជា យើងរង់ចាំរហូតដល់ពេលកំណត់នៃកិច្ចសន្យា មានន័យថារហូតដល់រយៈពេល ១ ឆ្នាំ ការសាងសង់នេះនឹងមិនអាចត្រូវបានបញ្ចប់នោះទេ ។ ពិតប្រាកដណាស់ គឺក្រុមហ៊ុនគ្មានកម្លាំងពលកម្ម និងសម្ភារៈគ្រប់គ្រាន់ ដើម្បីបំពេញទូវភាគព្វកិច្ចនេះទេ ។ ការយឺតយ៉ាវក្នុងការអនុវត្តភាគព្វកិច្ចនេះ បង្កើតបានជាកំហុសមួយរបស់ក្រុមហ៊ុន ។ ប៉ុន្តែ ក្រុមហ៊ុន ខេមរា បានសម្រេចការសាងសង់ចំនួន ១០ ភាគរយ សម្រាប់សាលាក្រុងភ្នំពេញ ដែលយើងគួរគិតគូផងដែរអំពីការសម្រេចនេះ ។

(សន្និដ្ឋាន) : ដូច្នេះ ក្រុមហ៊ុន ខេមរា គ្មានសិទ្ធិទទួលបានទូវសោហ៊ុយអ្វីនោះទេ ។ ក្រុមហ៊ុននេះអាចទទួលបានត្រឹមតែការសងមកវិញទូវការសម្រេចសាងសង់ផ្លូវរួចចំនួន ១០ ភាគរយប៉ុណ្ណោះ ។ មុននឹងបង់ប្រាក់ សាលាក្រុងភ្នំពេញ អាចបង្កើតជាគណៈកម្មការមួយ ដើម្បីវាយតម្លៃអំពីថ្លៃនៃការសាងសង់ចំនួន ១០ ភាគរយនោះ ។ ប្រាក់រង្វាន់ដែលត្រូវប្រគល់ឱ្យទៅក្រុមហ៊ុន នឹងត្រូវបានកំណត់ ដោយយោងតាមលទ្ធផលនៃការវាយតម្លៃ ។

Scanned with CamScanner

ភាគទី ៤

ប្រធានបែបបរិមាធិប្បាយគតិយុត្ត

Scanned with CamScanner

ភាគទី ៤
ប្រធានបែបបរិមាធិប្បាយគតិយុត្ត

ប្រធានបែបបរិមាធិប្បាយគឺជាលំហាត់មួយដែលមានគោលដៅបង្ហាញនូវចំណេះដឹងទាំងឡាយ តែក៏មានគោលដៅពន្យល់ ឬពិភាក្សានូវរាល់វិធានគតិយុត្តផងដែរ ដែលកិច្ចការទាំងនេះតម្រូវឱ្យមានការអនុវត្តនូវចំណេះដឹង និងការដេញរកហេតុផលដ៏តឹងរឹងមួយ។ និស្សិត ឬ បេក្ខជនប្រឡង ស្ថិតក្នុងស្ថានភាពមួយដូចជាសាស្ត្រាចារ្យដែលកំពុងតែរៀបចំតាក់តែងមេរៀនរបស់ខ្លួន។ ដូចនេះ និស្សិត ឬបេក្ខជនប្រឡង ត្រូវតែបង្ហាញនូវបញ្ហាឱ្យបានច្បាស់លាស់តាមលទ្ធភាពដែលអាចធ្វើបាន ដោយមិនត្រូវភ្លេចនូវទិដ្ឋភាពណាមួយឡើយ ។ ដើម្បីធ្វើកិច្ចការនេះបាន និស្សិត ឬបេក្ខជនប្រឡងពុំត្រូវបានតម្រូវឱ្យរៀបរាប់ឡើងនូវមេរៀនរបស់ខ្លួនដែលបានទន្ទិញចាំរត់មាត់នោះទេ ។ ជាញឹកញាប់ ប្រធានបែប-បរិមាធិប្បាយ ពុំតម្រូវឱ្យអ្នកតាក់តែងធ្វើការពណិនានោះទេ ប៉ុន្តែ ឱ្យអ្នកតាក់តែងចេះពិចារណា និងសញ្ជឹងគិតទៅដល់បញ្ហាដែលត្រូវបានលើកឡើងដោយប្រធានបទ បន្ទាប់មកធ្វើការអត្ថាធិប្បាយលើបញ្ហាទាំងនេះ។

ហេតុដូច្នេះ ក្រៅពីចំណេះដឹងខាងលើនេះ ប្រធានបែបបរិមាធិប្បាយត្រូវការជាចាំបាច់នូវការគោរពវិធីសាស្ត្រដ៏ច្បាស់លាស់ (ផ្នែកទី១) ហើយ ដើម្បីយល់អំពីវិធីសាស្ត្រឱ្យបានច្បាស់ យើងត្រូវការអនុវត្តវិធីសាស្ត្រនេះ ឱ្យបានច្រើនដង ជាមួយនឹងលំហាត់ជាច្រើនតាមមុខវិជ្ជានីមួយៗ (ផ្នែកទី ២) ។

ផ្នែកទី ១ : វិធីសាស្ត្រដោះស្រាយប្រធានបែបបរិមាធិប្បាយ: (បេអាទ្រីស ពាលីវ៉ែ)

វិធីសាស្ត្រដែលត្រូវបានបង្ហាញ (កថាខណ្ឌទី ១) នឹងត្រូវបានស្នើឡើងជាមួយនឹងលំហាត់អនុវត្តវិធីសាស្ត្រនេះក្នុងដំណាក់កាលមួយដ៏ស្មុគស្មាញ : ការរៀបចំតាក់តែងប្លង់ (កថាខណ្ឌទី ២)និងការអនុវត្តវិធីសាស្ត្រទៅតាមដំណាក់កាលនីមួយៗ (កថាខណ្ឌទី ៣) ។

កថាខណ្ឌទី ១ : ការបង្ហាញវិធីសាស្ត្រ

ដើម្បីសម្រេចបាននូវលំហាត់នេះ អ្នកត្រូវប្រតិបត្តិតាមដំណាក់កាលជាច្រើន :

ដំណាក់កាលទី ១ : ការអានប្រធានបទ

ដំណាក់កាលនេះអាចបង្ហាញនូវភាពងាយស្រួល ប៉ុន្តែ អ្នកត្រូវសង្កត់ធ្ងន់សាជាថ្មីលើដំណាក់កាលនៃការអានប្រធានបទ ។ ក្នុងពេលប្រឡង សំណៅកិច្ចការជាច្រើនបង្ហាញនូវការយល់ខុស ឬការប្រញាប់ប្រញាល់ហួសហេតុក្នុងការអានប្រធានបទ ។

ប្រធានបទត្រូវតែអានឱ្យបានច្រើនដង :

- អានលើកទី មួយ អនុញ្ញាតឱ្យយល់ដឹងជាលក្ខណៈទូទៅលើប្រធានបទ
- អានលើកទី ពីរ អនុញ្ញាតឱ្យកំណត់អំពីព្រំដែននៃប្រធានបទ
- អានលើកទី បី ធានាដល់ការយល់កាន់តែប្រសើរឡើងនូវភាពល្អិតល្អន់របស់ប្រធានបទ ។

Scanned with CamScanner

អ្នកត្រូវធ្វើការកត់សំគាល់ :

- ***វិធីប្រើវណ្ណយុត្ត***

ឧទាហរណ៍ : ប្រធានបទស្តីពី "តើយុត្តិសាស្ត្រជាប្រភពមួយរបស់នីតិដែរឬទេ ?" មិនមែនដូចគ្នានឹងប្រធានបទទាក់ទងនឹង "យុត្តិសាស្ត្រ" នោះទេ ។ ប្រធានបទទីមួយ បញ្ជាក់អំពីការចាប់យកគោលជំហររបស់និស្សិត ឬបេក្ខជនប្រឡង ក្នុងការលើកឡើងនូវអំណះអំណាង ។ នៅក្នុងប្រភេទលំហាត់បែបនេះ អ្នកតាក់តែងត្រូវតែផ្តល់ចម្លើយឱ្យបានច្បាស់លាស់ដែលឆ្លើយតបទៅនឹងសំណួរនោះ ដោយមិនត្រូវភ្លេចនូវការបង្ហាញអំណះអំណាងចំពោះចម្លើយទាំងនោះឡើយ ។ ប្រធានបទទីពីរ មានលក្ខណៈស្មុកស្មាញខ្លាំង ពីព្រោះបញ្ហាមិនត្រូវបានបង្ហាញជាមុនឡើយ ។ ដូចនេះ អ្នកត្រូវកំណត់ឱ្យបានល្អនូវផលប្រយោជន៍នៃប្រធានបទ និងត្រូវតាក់តែងប្លង់ ដោយយោងតាមបញ្ហាដែលអ្នកនឹងត្រូវលើកឡើង ។

- ***ឯកវចនៈ ឬពហុវចនៈ***

ចំណងជើងប្រធានបទ "*នីតិយោបាយ*" ខុសគ្នាពីចំណងជើងមួយទៀតគឺ "*នីតិយោបាយទាំងឡាយ*" ។ ចំណងជើងនៃប្រធានបទទីមួយតម្រូវឱ្យមានការពិចារណាជាទូទៅទៅលើទណ្ឌកម្មដែលបង្កើតជាការប្រកាសនីតិយោបាយ ជាពិសេសដែលវាផ្ទុយនឹងទណ្ឌកម្មផ្សេងទៀត ដូចជាការលុបចោលកិច្ចសន្យាអនុវត្តភ្លាម។[134] ការលុបចោលកិច្ចសន្យាអនុវត្តបន្តបន្ទាប់[135] , ភាពមិនអាចជំទាស់ប្រឆាំងបាន... ។ ចំណែកឯ ចំណងជើងនៃប្រធានបទទីពីរ ទាក់ទិនទៅនឹងការវិភាគពីប្រភេទផ្សេងៗនៃនីតិយោបាយ ។

- ***ធ្នាក់ ដូចជា : និង, ឬ ...***

កាលណាប្រធានបទមួយមាន "*និង*" ធ្នាក់នេះ កំណត់សំគាល់អំពីអន្តរវិសាលភាពរវាងធាតុផ្សំពីរនៃប្រធានបទ ។ ដូចនេះ និស្សិត ឬបេក្ខជនប្រឡង ត្រូវតែគិតនូវរាល់ចំណុចផ្សេងៗ ដែលអាចទាញធាតុផ្សំទាំងពីរ ឱ្យមានភាពជិតគ្នា នូវរាល់ចំណុចផ្សេងៗដែលជំទាស់ប្រឆាំងរវាងគ្នា ឬដែលអាចបែងចែកភាពផ្ទុយគ្នា ។ ឧទាហរណ៍ "*នីតិយោបាយ និងការលុបចោលកិច្ចសន្យាអនុវត្តភ្លាម*" ។ អ្នកតាក់តែងមិនត្រូវបង្ហាញជាបន្តបន្ទាប់នូវចំណេះដឹងរបស់ខ្លួនជាបឋមទាក់ទងនឹងនីតិយោបាយ រួចបន្តចូលការបង្ហាញនូវចំណេះដឹងទាក់ទងនឹងការលុបចោលកិច្ចសន្យាអនុវត្តភ្លាមៗនោះទេ ប៉ុន្តែកិច្ចការរបស់អ្នកត្រូវតែរៀបចំឡើង ដោយមានរចនាសម្ព័ន្ធត្រឹមត្រូវ តាមរយៈការប្រៀបធៀបរវាងសញ្ញាណទាំងពីរនេះ ។

- ***គូសពីក្រោមរាល់ពាក្យតូចៗ ដូចជា : នៅ ឬដោយ ឬអំពី, នៅក្នុង, អំពី ឬក្នុងមុខវិជ្ជា ឬ,ក្នុងករណី, ...***

ឧទាហរណ៍ : "*នីតិយោបាយក្នុងមុខវិជ្ជានីតិគ្រួសារ*" មិនមែនជាប្រធានបទដូចគ្នានឹង "*នីតិយោបាយ*" នោះទេ ។ ប្រធានបទទីមួយ ត្រូវបានកំណត់ត្រឹមតែនីតិគ្រួសារ ចំណែកប្រធានបទទីពីរ ត្រូវការជាចាំបាច់នូវការសិក្សាជាសាកលពីនីតិយោបាយនៅក្នុងគ្រប់ផ្នែកនៃនីតិ ។

[134] Résolution
[135] Résiliation

Scanned with CamScanner

ពាក្យ ឬសញ្ញានីមួយ១ទាំងនេះ បង្កើតជាធាតុផ្សំ ដើម្បីអនុញ្ញាតឱ្យយើងយល់កាន់តែប្រសើរឡើង និងកំណត់ព្រំដែននៃប្រធានបទ ។

ជំណាក់កាលទី២ : ការរៀបចំតាក់តែងលើក្រដាសព្រាង

១- ការសញ្ជឹងគិតជាបឋម

ពាក្យនីមួយ១នៃប្រធានបទត្រូវតែកំណត់និយមន័យឱ្យបានច្បាស់លាស់ ។ ចូរអ្នកត្រូវធ្វើការប្រុងប្រយ័ត្នគ្រប់ពាក្យឈ្មោះទាំងអស់ និងជាពិសេស ចូរអ្នកកុំបញ្ឈប់ការសិក្សាត្រឹមតែការពន្យល់ពាក្យតែមួយ ។ ប្រសិនបើពាក្យទាំងនោះអាចមានអត្ថន័យច្រើន អ្នកត្រូវតែសិក្សាបរិបទរបស់វាឱ្យបានច្បាស់ ដើម្បីជ្រើសរើសយកអត្ថន័យពិតប្រាកដដែលទាក់ទងនឹងប្រធានបទ ។ ការបែងចែកភាពខុសគ្នារវាងពាក្យទាំងឡាយនៃប្រធានបទ ជាមួយសញ្ញាណផ្សេង១ទៀតដែលនៅជុំវិញពាក្យទាំងនោះ គឺមានសារៈប្រយោជន៍ផងដែរ ។ ឧទាហរណ៍ : ប្រសិនបើប្រធានបទទាក់ទងនឹង "*រមាយភាព*" ដើម្បីកំណត់ឱ្យបានច្បាស់អំពីសញ្ញាណនេះ ការរកភាពខុសគ្នារវាងសញ្ញាណនេះជាមួយនឹងសញ្ញាណប្រហាក់ប្រហែលផ្សេង១ទៀត មានលក្ខណៈមួយយ៉ាងសំខាន់ ដូចជាភាពផ្ទុយគ្នារវាងសញ្ញាណនៃការលុបចោលកិច្ចសន្យាអនុវត្តភ្លាម១ ឬការលុបចោលកិច្ចសន្យាអនុវត្តបន្តបន្ទាប់ ។

២- ការសញ្ជឹងគិតស៊ីជំរៅ

យើងត្រូវបែងចែកឱ្យបានច្បាស់អំពីពេលវេលាក្នុងការធ្វើប្រធានបរិមាធិប្បាយនេះ បានសេចក្តីថា យើងដោះ-ស្រាយលំហាត់នេះ ក្នុងពេលធ្វើសំណួរសរសេរ, ការប្រឡងប្រជែង ឬយើងធ្វើដោយមានពេលវេលាមិនកំណត់ (ឧទាហរណ៍ : គ្រូបង្រៀនកិច្ចការប្រតិបត្តិ ប្រគល់កិច្ចការនេះឱ្យទៅអ្នក ហើយអ្នកមានពេលមួយ ឬពីរសប្តាហ៍ សម្រាប់ធ្វើកិច្ច-ការនេះ) ។

ប្រសិនបើប្រធានបរិមាធិប្បាយត្រូវបានធ្វើឡើងក្នុងចិរវេលាកំណត់ អ្នកត្រូវតែកត់ចំណាំនូវរាល់ការវិភាគ ការពិចារណាដែលអ្នកទាញចេញពីប្រធានបទនៅលើក្រដាសព្រាង ។ ចូរអ្នករំលឹកឡើងវិញនូវចំណេះដឹងទាំងឡាយដែលអ្នកបានទទួលពីការសិក្សានៅក្នុងសាលធំ ឬការសិក្សានៅក្នុងការងារប្រតិបត្តិ និងការចងចាំទាំងឡាយទាក់ទងនឹងអត្ថបទផ្សេង១ដែលអ្នកបានអានទាក់ទងនឹងចំណោទបញ្ហានេះ ដែលអាចជាអត្ថបទច្បាប់ក្នុងន័យសំភារៈដូចជា អត្ថបទរបស់អ្នកនិពន្ធ ឬសេចក្តីសម្រេចរបស់តុលាការ ។ អ្នកត្រូវតែសរសេរនូវរាល់គំនិត, រាល់ចំណេះដឹង និងរាល់និយមន័យទាំងអស់នៅក្នុងក្រដាសព្រាង ។ អ្នកត្រូវទាញគំនិតនីមួយ១ទៅរកភាពជិតគ្នា, ធ្វើការប្រៀបធៀប និងលើកឡើងនូវភាពផ្ទុយគ្នានៃគំនិតទាំងនោះ ដើម្បីទទួលបាននូវបន្ទាត់គោលផ្សេង១ ដែលទាក់ទងនឹងប្រធានបទ ។ ការប្រមូលផ្តុំនូវរាល់គំនិតទាំងនោះមានភាពចាំបាច់ ដើម្បីបង្កើតជាប្លង់ ។ អ្នកពុំត្រូវរារែកក្នុងការលុបចោលនូវរាល់គំនិតទាំងឡាយណាដែលពុំទាក់ទងដោយផ្ទាល់ជាមួយនឹងប្រធានបទនោះទេ ។

ប្រសិនបើការធ្វើបរិមាធិប្បាយមិនត្រូវបានធ្វើក្នុងចិរវេលាកំណត់នោះទេ អ្នកអាច ឬអ្នកត្រូវតែសិក្សាស៊ីជំរៅនូវចំណេះដឹងរបស់អ្នកដោយការបំពេញកិច្ចការនៅក្នុងបណ្ណាល័យ ។ ចូរអ្នកស្រាវជ្រាវរាល់អត្ថបទច្បាប់ អត្ថបទរបស់

Scanned with CamScanner

អ្នកនិពន្ធ ឬសេចក្តីសម្រេចរបស់តុលាការដែលទាក់ទងជាយថាហេតុលើបញ្ហានេះ ។ ចំណែកពេលវេលាដែលនៅសេសសល់ អ្នកត្រូវអនុវត្តវិធីសាស្ត្របន្ត ដូចដែលបានរៀបរាប់ខាងលើដែរ ដើម្បីឱ្យការបរិមាធិប្បាយរបស់អ្នកត្រូវបានធ្វើឡើងក្នុងចិរវេលាមួយជាក់លាក់ ។

ដំណាក់កាលទី ៣ : ការបង្កើតប្លង់

ក្នុងដំណាក់កាលនេះ អ្នកត្រូវចាត់វិធានការបង្កើតប្លង់នៃប្រធានបទបរិមាធិប្បាយ បានសេចក្តីថា អ្នកត្រូវរៀបចំឱ្យបានសមស្រប និងត្រឹមត្រូវនូវរាល់ចំណុចដែលទាញចេញពីការបំពេញការងារវិភាគ និងពិចារណានៅលើក្រដាស់ព្រាងខាងលើ ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលចោទឡើងនៅក្នុងប្រធានបទ ។ ក្នុងករណីណាមួយដែលអ្នកត្រូវបង្កើតប្លង់ មុនពេលធ្វើការវិភាគ និងស្វែងរកគំនិតនោះទេ ពីព្រោះរាល់គំនិតទាំងនេះ ជាធាតុផ្សំក្នុងការបង្កើតប្លង់ ។ ការដេញរកហេតុផលត្រូវតែធ្វើឡើងជារួម សមស្រមតាមការបកស្រាយដែលមានលក្ខណៈតក្ក ដោយគ្មានការលើកឡើងជ្រុលដែល និងគ្មានការលើកឡើងត្រលប់ថយក្រោយនោះទេ ឧទាហរណ៍ អញ្ជត្រកម្មពុំត្រូវបានលើកយកមកធ្វើអត្ថាធិប្បាយ មុនវិធានជាគោលការណ៍នោះទេ ។ ប្លង់ត្រូវតែបង្កើតឡើងទៅតាមបន្ទាត់គំនិតដែលអ្នកចង់បង្ហាញ ឬចង់បំផ្លាញចោល ។ កិច្ចការគតិយុត្តត្រូវតែមានកម្មវត្ថុច្បាស់លាស់ ។ *របកគំនប្រឡងទាំងឡាយ គួរបង្កើតប្លង់ជាពីរភាគ និងជាពីរភាគរង* ។ ប៉ុន្តែ អ្នកអាចជ្រើសរើសយកប្លង់ ដោយយោងតាមការបែងចែកនៃចំនួនគំនិតផ្សេងៗដែលអ្នកនឹងយកមកធ្វើអត្ថាធិប្បាយផងដែរ ។ ឧទាហរណ៍ : ប្រសិនបើអ្នកធ្វើអត្ថាធិប្បាយគំនិតបីផ្សេងគ្នា អ្នកក៏អាចជ្រើសរើសយកប្លង់ជាបីភាគផងដែរ ។

- **ប្លង់គំរូ** : ជាប្លង់ទូទៅ ដែលអាចសម្របបាន ចំពោះគ្រប់ប្រធានបទដែលមានប្រភេទដូចគ្នា ។

ដូចនេះ ប្រសិនបើប្រធានបទមួយទាក់ទងនឹង**សញ្ញាណគតិយុត្ត** :

ឧទាហរណ៍ : "នីតិបុគ្គល" ឬ"ការមិនរាំងចាល" ។ ប្លង់អាចជា :

I. សញ្ញាណ ឬនិយមន័យ ឬប្រភេទ ឬធាតុផ្សំ (ដោយថាហេតុ តួនាទី ឬមុខងាររបស់វា)

II. ការអនុវត្ត (ទម្រង់, ទណ្ឌកម្ម, កស្តុតាង)

ប្រសិនបើប្រធានបទទាក់ទងនឹង**របបគតិយុត្ត**[136] **មួយ** : ឧទាហរណ៍ : "ការរៀបអាពាហ៍ពិពាហ៍" ។ ប្លង់អាចជា :

I. លក្ខខណ្ឌ

II. អានុភាព

ប្រសិនបើប្រធានបទទាក់ទង**យន្តការគតិយុត្តមួយ** : ឧទាហរណ៍ : "ការលុបចោលលិខិតរដ្ឋបាលពីបទរំលោភអំណាច" ។ ប្លង់អាចជា :

[136] សំដៅទៅលើទម្រង់ ឬរចនាសម្ព័ន្ធទាំងឡាយ ដែលត្រូវបានបង្កើតឡើងដោយច្បាប់ ឬទំនៀមទម្លាប់ « Institution ou régime »

Scanned with CamScanner

I. ករណី

II. របបគតិយុត្ត

ប្រសិនបើប្រធានបទទាក់ទងនឹង**សិទ្ធិមួយ** : ឧទាហរណ៍ : "កម្មសិទ្ធិ" ។ ប្លង់អាចជា :

I. ការបង្កើត ឬលទ្ធកម្ម

II. ដំណើរការរបពីតទៅ បការអនវត

III. ការបញ្ចប់ ឬការរលត់ (ជាយថាហេតុ)

ប្រសិនបើប្រធានបទជា**ប្រធានប្រៀបធៀបរវាងទស្សនទានពីរ** ។ ប្លង់អាចជា :

I. ចំណុចរួម

II. ចំណុចដោយឡែក

ប្លង់ភាគច្រើនក្នុងចំណោមប្លង់ដែលបានរៀបរាប់ខាងលើនេះនេះ គឺជាប្លង់ពណិនា ហើយប្លង់ទាំងនេះតម្រូវជាពិសេស ដល់ការវិភាគ, ការពិពណិនា ឬការបញ្ជាក់បង្ហាញ ។

ដើម្បីការពារនូវមតិ ឬដំណោះស្រាយមួយ ការដាក់នូវអំណះអំណាងដែលផ្តល់ភាពពេញចិត្តចំពោះគោលដំហរបស់អ្នក ឱ្យកាន់តែមានតម្លៃ និងការលើកឡើងនូវការជំទាស់ប្រឆាំងរវាងអំណះអំណាងទាំងនោះ អាចផ្តល់នូវភាពប្រសើរមួយ ។

ដូចនេះ ប្លង់គំរូគឺ :

I. ការបដិសេធទៅនឹងអំណះអំណាងប្រឆាំង

II. ការការពារ និងយុត្តិកម្មលើអំណះអំណាងរបស់អ្នក

- **ប្លង់គំនិត :**

គឺជាប្លង់ដើមដែលលើកឡើងបង្ហាញនូវការគិតពិចារណាផ្ទាល់ខ្លួន និងស៊ីជំរៅរបស់និស្សិត ឬបេក្ខជនប្រឡង ។ ប៉ុន្តែ គ្មានរបមនសមាបរកបងណាមយដេលកេតទេរងដោយហេតអសារនោះទេ រពោះថា បងតេរបានបដេតចេញមក ពីគំនិតទាំងទាយដែលអកបានលើកទើងកងបធានបទ ។ ដចេះ បង់មានការបែរបលទៅតាមរបធានបទនីមយ១ ។

ដំណាក់កាលទី ៤ : ការសរសេរតាក់តែងប្រធានបទបែបបរិមាធិប្បាយ

ដំណាក់កាលនៃការរៀបចំប្រធានបទបែបបរិមាធិប្បាយត្រូវបានបញ្ចប់ ។ អំណើះតទៅ អ្នកត្រូវតែបន្តការងារនៅលើសំណៅកិច្ចការ ពុំមែននៅលើក្រដាសព្រាងឡែតទេ ។ ដោយឡែកនៅថ្ងៃប្រឡង ឬថ្ងៃប្រឡងប្រជែង អ្នកពុំមានពេលវេលាសរសេរកិច្ចការរបស់អ្នកលើក្រដាស់ព្រាង ហើយបន្ទាប់មកទើបចម្លងកិច្ចការទាំងនេះឡើងវិញនោះទេ ។ ការតាក់តែងប្រធានបែបបរិមាធិប្បាយ គឺជាដំណាក់កាលចុងក្រោយនៃវិធីសាស្ត្រ ប៉ុន្តែ ការតាក់តែងនេះ គឺជាដំណាក់កាលដែលត្រូវចំណាយពេលវេលាយូរ ។ ដូចនេះ អ្នកត្រូវតែគ្រប់គ្រងពេលវេលារបស់អ្នកឱ្យបានត្រឹមត្រូវ ។ ចំពោះ

Scanned with CamScanner

ប្រធានបរិមាធិប្បាយដែលត្រូវធ្វើក្នុងរយៈពេលបីម៉ោង អ្នកត្រូវចំណាយ ១ ម៉ោង ទៅ ១ ម៉ោង ១៥ នាទី ដើម្បីរៀបចំកិច្ចការនៅលើក្រដាសព្រាង និង ១ ម៉ោង ៤៥ នាទី ទៅ ២ ម៉ោង សម្រាប់ការតាក់តែង ។

ការបង្ហាញការតាក់តែងប្រធានបែបបរិមាធិប្បាយនៅក្នុងសំណៅកិច្ចការ គឺជាការចាំបាច់ខ្លាំង ។ អ្នកត្រូវតែផ្ចិតផ្ចង់ចំពោះការសរសេររបស់អ្នក ហើយអ្នកត្រូវសរសេរដោយមានលក្ខណៈងាយអានផងដែរ ។ ចូរអ្នកកុំរាវរែកក្នុងការចុះបន្ទាត់រាល់ពេលដែលអ្នកចាប់ផ្តើមនូវគំនិតថ្មី ។

កិច្ចការរបស់អ្នកចាប់ផ្តើមដោយសេចក្តីផ្តើមមួយ ។ សំណៅកិច្ចការមួយត្រូវបានវិនិច្ឆ័យលើសេចក្តីផ្តើម និងលើប្លង់ ។ សេចក្តីផ្តើមត្រូវតែឆ្លើយតបទៅនឹងគោលដៅមួយចំនួន ។ សេចក្តីផ្តើមត្រូវបញ្ជាក់បង្ហាញអំពីប្រធានបទ និងប្លង់របស់អ្នក ។ សេចក្តីផ្តើមត្រូវធ្វើឡើងដោយមានទម្រង់ដូចជាជីរឡាវ បានសេចក្តីថា យើងចាប់ផ្តើមពីការបង្ហាញនូវទិដ្ឋ-ភាពទូទៅរហូតដល់ទិដ្ឋភាពដោយឡែក ។ ជាបឋម សេចក្តីផ្តើម ត្រូវអនុញ្ញាតឱ្យកំណត់ទីតាំងនៃប្រធានបទក្នុងបរិបទមួយដែលមានភាពទូលំទូលាយ ។ អ្នកត្រូវតែបញ្ជាក់បង្ហាញថា តើប្រធានបទនេះស្ថិតនៅជាផ្នែកណាមួយនៃនីតិ និងបកស្រាយ ជាបន្តបន្ទាប់ពីបញ្ហារហូតដល់ចំណុចដែលត្រូវធ្វើអត្ថាធិប្បាយ ។ ជាទូទៅ អ្នកគួរចាត់ផ្តើមសេចក្តីមផ្តើមដោយឃ្លាភ្ជាប់មួយ ដែលជាឃ្លារបស់អ្នកនិពន្ធ ដើម្បីទាក់ទាញការប្រុងប្រយ័ត្នរបស់អ្នកអាន តាំងពីពាក្យដំបូងនៃកិច្ចការរបស់អ្នក ។

បន្ទាប់មក អ្នកត្រូវបង្ហាញប្រធានបទ និងពន្យល់ប្រធាននេះ ។ អ្នកត្រូវបញ្ជាក់ផងដែរអំពីផលប្រយោជន៍នៃសំណូរ ។ នៅពេលដែលប្រធានបទត្រូវបានបង្ហាញ. ត្រូវបានពន្យល់ និងត្រូវបានកំណត់ព្រំដែន អ្នកត្រូវតែបង្ហាញអំពីប្លង់នៃប្រធានបែបបរិមាធិប្បាយ ។ អ្នកត្រូវដកស្រង់យកគំនិតសំខាន់ៗ ដែលអ្នកត្រូវបកស្រាយ ដោយពន្យល់អំពីវិធីសាស្ត្រដែលធ្វើឱ្យគំនិតទាំងនោះមានចំណងទាក់ទងគ្នា ។

បន្ទាប់មក ការធ្វើអត្ថាធិប្បាយលើប្រធានបទរបស់អ្នកត្រូវបានបន្ត ។ ភាគនីមួយៗត្រូវផ្តើមដោយឃ្លាផ្តើមមួយដែលបង្ហាញនូវភាគរងទាំងឡាយ ។ ឃ្លាផ្តើមទាំងនេះ ព្រមទាំងឃ្លាភ្ជាប់រវាងកថាខណ្ឌទាំងឡាយ មានលក្ខណៈចាំបាច់ជាខ្លាំង ពីព្រោះឃ្លាទាំងនេះអនុញ្ញាតឱ្យអ្នកអានងាយយល់អំពីការដេញរកហេតុផលរបស់អ្នកសរសេរ ។ រាល់ភាគទាំងអស់អាច មានឈ្មោះមួយ ប៉ុន្តែ វាមិនមែនជាការចាំបាច់នោះទេ ។ ចូរអ្នកបន្តប្លង់របស់អ្នកដោយប្រុងប្រយ័ត្ន ពីព្រោះនៅពេលកំពុងសរសេរ អ្នកពុំមានពេលវេលាគ្រង់គ្រាន់ ដើម្បីកែប្រែប្លង់ ដែលអ្នកបានជ្រើសរើសនោះទេ ។

តថាខណ្ឌទី ២ : លំហាត់ទាក់ទងនឹងការរៀបចំបច្ចេកទេសប្លង់

លំហាត់ដែលទាក់ទងនឹងប្លង់គំរូនឹងត្រូវបានបង្ហាញ ក្នុងគោលដៅដើម្បីបង្កើតលក្ខណៈស្ទាយប្រវត្តិដល់និស្សិត ឬបេក្ខជនប្រឡង ទោះបីជាការរៀបចំប្លង់គំនិតផ្តល់នូវភាពពេញចិត្តក៏ដោយ ។

ក. លំហាត់

ចូរអ្នកសាកល្បងស្វែងរកប្លង់នៃប្រធាននីមួយៗ ដោយយោងតាមប្លង់គំរូដែលអ្នកបានសិក្សាវិធីសាស្ត្រប្រធានបែបបរិមាធិប្បាយ និងរៀបចំប្លង់ ដោយប្រុងប្រយ័ត្នទៅលើការដាក់ឈ្មោះនៃភាគនីមួយៗ :

Scanned with CamScanner

ប្រធានបទទី១ : សិទ្ធិផលុបភោគ

ប្រធានបទទី២ : អាណាព្យាបាល

ប្រធានបទទី៣ : ភោគៈ និងកម្មសិទ្ធិ

ប្រធានបទទី៤ : ការលែងលះ

ប្រធានបទទី៥ : បទល្មើសលួច

ប្រធានបទទី៦ : ការទទួលខុសត្រូវទោសកម្មរដ្ឋប្បវេណី ឬការទទួលខុសត្រូវក្រៅកិច្ចសន្យា

ខ. តំណែ

ប្រធានបទទី ១ : ប្រធានបទទាក់ទងនឹងសិទ្ធិ ។ ដូចនេះ បួងតំរូតី :

I. ការបង្កើតសិទ្ធិផលុបភោគ

II. ការអនុវត្តសិទ្ធិផលុបភោគ

III. ការរំលត់សិទ្ធិផលុបភោគ

ប្រធានបទទី ២ : ប្រធានបទទាក់ទងនឹងរបបគតិយុត្តមួយ ។ ដូចនេះ បួងតំរូតី :

I. លក្ខខណ្ឌនៃអាណាព្យាបាល

II. របបគតិយុត្តនៃអាណាព្យាបាល

ប្រធានបទទី ៣ : ប្រធានបទទាក់ទងនឹងការប្រៀបធៀបរវាងទស្សនទានពីរ ។ ដូចនេះ បួងតំរូតី :

I. ចំនុចរួមនៃភោគៈ និងកម្មសិទ្ធិ

II. ចំនុចដោយឡែករបស់ភោគៈ និង កម្មសិទ្ធិ

ប្រធានបទទី ៤ : ប្រធានបទទាក់ទងនឹងរបបគតិយុត្តមួយ ។ ដូចនេះ បួងតំរូតី :

I. លក្ខខណ្ឌនៃការលែងលះ

II. អានុភាពនៃការលែងលះ

ប្រធានបទទី ៥ : ប្រធានបទទាក់ទងនឹងសញ្ញាណគតិយុត្ត ។ ដូចនេះ បួងតំរូតី :

I. ធាតុផ្សំនៃបទល្មើសលួច

II. ការអនុវត្តបទល្មើសលួច

ប្រធានបទទី ៦ : ប្រធានបទទាក់ទងនឹងសញ្ញាណគតិយុត្ត ។ ដូចនេះ បួងតំរូតី :

I. លក្ខខណ្ឌនៃការទទួលខុសត្រូវខាងទោសកម្មរដ្ឋប្បវេណី

II. ការអនុវត្តការទទួលខុសត្រូវខាងទោសកម្មរដ្ឋប្បវេណី

Scanned with CamScanner

តថាខណ្ឌទី ៣ : ការអនុវត្តវិធីសាស្ត្រតាមដំណាក់កាលនីមួយៗរហូតដល់ដំណាក់កាលនៃការរៀបចំប្លង់

គោលបំណងនៃលំហាត់នេះគឺថា និស្សិត ឬបេក្ខជនប្រឡងសាកល្បងសម្រេចឱ្យបានការតាក់តែងប្រធានបទបែបបរិមាធិប្បាយជាដំបូងរបស់ខ្លួនដោយគិតពិចារណាឱ្យបានត្រឹមត្រូវថា ដំណាក់កាលនីមួយៗនៃវិធីសាស្ត្រមានសារៈសំខាន់ណាស់ ។ ចំពោះប្រធានបទមួយ (ក) និស្សិត ឬបេក្ខជនប្រឡងត្រូវព្យាយាម និងសាកល្បងអនុវត្តដំណាក់កាលនីមួយៗដោយខ្លួនឯង ។ បន្ទាប់មក និស្សិត ឬបេក្ខជនប្រឡងអាចពិនិត្យ ពិគ្រោះកំណែចម្លើយជាក្រោយ (ខ) ។

ក. ប្រធានបទ

" ការបង្កើតអាពាហ៍ពិពាហ៍

ខ. កំណែប្រធានបទ

ដំណាក់កាលទី ១ : ការកំណត់និយមន័យនៃពាក្យទាំងឡាយនៅក្នុងប្រធានបទ

ការបង្កើត : សកម្មភាពបង្កើត របៀបដែលរបស់អ្វីមួយត្រូវបានបង្កើតឡើង ឬលេចឡើង ។

អាពាហ៍ពិពាហ៍ : មាត្រា ៣ នៃច្បាប់ចុះថ្ងៃទី ២៦-០៧-១៩៨៩ ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ : អាពាហ៍ពិពាហ៍គឺជាកិច្ចសន្យាដ៏ឱឡារិកមួយធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ដែលប្តេជ្ញាថា ខ្លួននឹងរួមសមគ្គសង្វាស ជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួន ។

ការស្វែងយល់ប្រធានបទ : គឺត្រូវបង្ហាញបែបបទនៃការបង្កើតអាពាហ៍ពិពាហ៍ ។ ដូច្នេះ ប្រធានបទនេះ ពុំរាប់បញ្ចូលទៅការសិក្សាអំពីអានុភាព ឬការបញ្ចប់អាពាហ៍ពិពាហ៍ ដោយមូលហេតុនៃការលែងលះ ឬមរណភាពឡើយ ។

ដំណាក់កាលទី ២ :

- ប្រមូលផ្តុំនូវគ្រាល់ធាតុផ្សំនៃចំណេះដឹងទាំងអស់ ដែលអ្នកមាន :

  * មេរៀនរបស់សាស្ត្រាចារ្យរបស់អ្នក នៅក្នុងមុខវិជ្ជាពាក់ព័ន្ធ

នៅក្នុងឧទាហរណ៍របស់យើង គឺជាមេរៀននីតិគ្រួសារ និងជាពិសេស សេចក្តីអធិប្បាយស្តីពីអាពាហ៍ពិពាហ៍ ។

- ឯកសារផ្សេងពីនេះទៀត ដែលអ្នកអាចស្គាល់ ដោយសារការស្រាវជ្រាវផ្ទាល់ខ្លួន ជាអាទិ៍ :

  * មាត្រានៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ចុះថ្ងៃទី ២៦-០៧-១៩៨៩ ដែលទាក់ទងនឹងការបង្កើតអាពាហ៍ពិពាហ៍ :

"ផ្នែកទី១ : អំពីលក្ខខណ្ឌដែលត្រូវមាន ដើម្បីរៀបអាពាហ៍ពិពាហ៍

មាត្រា ៣ : អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឱឡារិកមួយធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ដែលប្តេជ្ញាថា ខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួន ។

Scanned with CamScanner

អាពាហ៍ពិពាហ៍នឹងមានអានុភាពពេញលក្ខណៈច្បាប់បាន លុះត្រាតែអាពាហ៍ពិពាហ៍នោះធ្វើឡើងស្របតាមក្បួនខ្នាតដែលមានចែងក្នុងច្បាប់នេះ ។

មាត្រា ៤ : បុរស និងនារីដែលមានអាយុពេញលក្ខណៈច្បាប់មានសិទ្ធិពេញលេញក្នុងការសម្រេចអាពាហ៍ពិពាហ៍ ។ ភាគីម្ខាងមិនអាចបង្ខំឆន្ទៈរបស់ភាគីម្ខាងទៀតបានឡើយ ។

គ្មាននរណាមួយអាចបង្ខំបុគ្គលម្នាក់អោយរៀប ឬរារាំងមិនអោយរៀបអាពាហ៍ពិពាហ៍បានឡើយ បើអាពាហ៍ពិពាហ៍នោះរៀបតាមក្បួនខ្នាតដែលមានចែងក្នុងច្បាប់នេះ ។

មាត្រា៥ : អាចរៀបអាពាហ៍ពិពាហ៍បាន បុរសចាប់ពីអាយុ២០ឆ្នាំឡើង នារីចាប់ពីអាយុ១៨ឆ្នាំឡើង ។ ក្នុងករណីពិសេស បុរសដែលមានអាយុមិនទាន់ដល់ ២០ ឆ្នាំ និងនារីដែលមានអាយុមិនទាន់ដល់ ១៨ ឆ្នាំ អាចរៀបអាពាហ៍ពិពាហស្របច្បាប់បាន ប្រសិនបើនារីមានផ្ទៃពោះ ហើយមានការអនុញ្ញាតពីឪពុកម្តាយ ឬអ្នកអាណាព្យាបាល ។

មាត្រា ៦ : មិនអាចរៀបអាពាហ៍ពិពាហ៍បាន :

- បុគ្គលមានភេទដូចគ្នា
- បុគ្គលគ្មានពលានុភាពនៃលិង្គ
- បុគ្គលមានជម្ងឺឃ្លង់ របេង មហារីក កាមរោគ ដែលមិនទាន់ព្យាបាលបានជាដាច់
- ជនវិកលចរិត ជនមិនដឹងខុសត្រូវ
- បុគ្គលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយ ។

មាត្រា ៧ : អាពាហ៍ពិពាហ៍ត្រូវហាមឃាត់រវាងបុគ្គលដែលជាប់ចំណងញាតិលោហិត ឬញាតិពន្ធក្នុងខ្សែផ្ចាល់គ្រប់ថ្នាក់ ទោះចំណងនោះមានខាន់ស្លាក្តី ឥតខាន់ស្លាក្តី ឬសាច់ចិញ្ចឹមក្តី ។

មាត្រា ៨ : អាពាហ៍ពិពាហ៍ត្រូវហាមឃាត់ រវាងសាខាញាតិ ទោះសាខាញាតិនោះមានខាន់ស្លាក្តី ឥតមានខាន់ស្លាក្តី សាច់ចិញ្ចឹមក្តី រួមម្តាយក្តី រួមឪពុកក្តី រួមឪពុកម្តាយក្តី ជាញាតិលោហិតក្តី ឬជាញាតិពន្ធក្តី រហូតដល់ថ្នាក់ទី៣ រាប់ទាំងថ្នាក់ទី៣ នេះផង ។ ក្នុងករណីពិសេស ប្រសិនបើសហព័ទ្ធណាមួយស្លាប់ សហព័ទ្ធដែលនៅរស់អាចរៀបអាពាហ៍ពិពាហ៍ជាមួយសាខាញាតិពន្ធថ្នាក់ទី ២ ឬថ្នាក់ទី ៣ បាន ។

មាត្រា ៩ : ក្រោយពីអាពាហ៍ពិពាហ៍រលាយដោយមូលហេតុប្តីស្លាប់ មោឃភាពនៃអាពាហ៍ពិពាហ៍ ឬលែងលះគ្នា នារីអាចរៀបអាពាហ៍ពិពាហ៍ថ្មីមួយទៀតបាន ប៉ុន្តែ ត្រូវស្ថិតនៅក្នុងវិធីវភាព "*ភាពរមាំយ*" ចំនួន ៣០០ ថ្ងៃ គិតពីថ្ងៃដែលប្តីស្លាប់ ឬពីថ្ងៃប្រកាសសាលក្រមដែលសម្រេចពីមោឃភាពនៃអាពាហ៍ពិពាហ៍ ឬពីថ្ងៃប្រកាសសាលក្រមស្ថាពរនៃការលែងលះ ។ ក្នុងករណីដែលតុលាការប្រជាជនបានចេញដីកាសម្រេចអោយប្តីប្រពន្ធនៅបែកគ្នានោះ សាលក្រមនៃការលែងលះត្រូវគិតវិធីវភាពតាំងពីថ្ងៃដែលចេញដីកានេះ ។

ប៉ុន្តែ បើនារីរៀបអាពាហ៍ពិពាហ៍មុនផុតរយៈពេល ៣០០ ថ្ងៃ ប្តីនៃការរៀបអាពាហ៍ពិពាហ៍ថ្មីនេះ ត្រូវចាត់ទុកជាឪពុករបស់កូនដែលកើតក្នុងអាពាហ៍ពិពាហ៍ថ្មីនេះ លើកលែងតែមានការជំទាស់ពីប្តីមុន ដោយមានភស្តុតាងច្បាស់លាស់ ។

Scanned with CamScanner

មាត្រា ១០ : ក្នុងករណីដែលសហព័ទ្ធណាមួយបាត់ខ្លួនកន្លងហួសពីមួយឆ្នាំ គិតពីថ្ងៃដែលបាត់ខ្លួននោះមក ដោយគ្មានដំណឹងអ្វីសោះ ហើយក៏គ្មាននរណាដឹងថា ជននោះស្លាប់ ឬរស់ សហព័ទ្ធម្នាក់ទៀត អាចនឹងរៀបអាពាហ៍ពិពាហ៍ទៀតបានបើផុតរយៈពេល ១៥ ថ្ងៃ គិតពីថ្ងៃប្រកាសសាលក្រមដែលបញ្ជាក់ថាជននោះបានបាត់ខ្លួនពិតមែន ។

ជនណាក៏ដោយ មិនអាចប្តឹងសុំបដិសេធអាពាហ៍ពិពាហ៍ថ្មីនេះបានឡើយ ទោះបីសហព័ទ្ធដែលបាត់ខ្លួននោះត្រឡប់មកវិញក៏ដោយ ។

មាត្រា ១១ : មុនពេលរៀបអាពាហ៍ពិពាហ៍ អនាគតប្តី ប្រពន្ធ ត្រូវប្តឹងដល់គណៈកម្មាធិការប្រជាជនឃុំ ឬសង្កាត់ខាងលំនៅរបស់នារី ដោយមានឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលចូលរួមផងក៏បាន ។

មាត្រា ១២ : ប្រធាន ឬសមាជិកនៃគណៈកម្មាធិការប្រជាជនឃុំ ឬសង្កាត់ក្នុងឋានៈជាមន្ត្រីអត្រានុកូលដ្ឋាន ត្រូវប្រកាសផ្សាយជាសាធារណៈនូវអាពាហ៍ពិពាហ៍នោះ ដោយបិទប័ណ្ណប្រកាសនៅលំនៅរបស់នារី និងនៅទីស្នាក់ការឃុំ ឬសង្កាត់របស់ខ្លួន ។

ប័ណ្ណប្រកាសពីរទៀត ត្រូវផ្ញើទៅជូនមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ខាងបុរស ដើម្បីយកទៅបិទនៅលំនៅរបស់បុរស និងនៅទីស្នាក់ការឃុំ ឬសង្កាត់របស់ខ្លួន ។

ប័ណ្ណប្រកាសត្រូវចុះ :

១- ត្រកូល ឈ្មោះ អាយុ មុខរបរ និងលំនៅនៃអនាគតប្តី និងប្រពន្ធ

២- ត្រកូល ឈ្មោះ អាយុ មុខរបរ និងលំនៅរបស់ឪពុកម្តាយនៃអនាគតប្តី ប្រពន្ធ "បើឪពុក ឬម្តាយស្លាប់ ត្រូវដាក់ថា ស្លាប់ ផង" ។

៣- រយៈពេលប្តឹងជំទាស់

មាត្រា ១៣ : ប័ណ្ណប្រកាសត្រូវបិទផ្សាយក្នុងរយៈពេល ១០ ថ្ងៃ ដើម្បីអោយជនដែលមានផលប្រយោជន៍ក្នុងរឿងនេះដឹងឮ ហើយអាចប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះបាន ប្រសិនបើមានការមិនយល់ស្របនឹងអាពាហ៍ពិពាហ៍នោះ ។ ផុតរយៈពេល ១០ ថ្ងៃនេះ ពិធីអាពាហ៍ពិពាហ៍អាចធ្វើទៅបានបើគ្មានការប្តឹងជំទាស់ ។

មាត្រា ១៤ : អាពាហ៍ពិពាហ៍នឹងចាត់ទុកជាត្រឹមត្រូវតាមលក្ខណៈច្បាប់បាន លុះត្រាតែបុរស និងនារី ដែលស្ម័គ្រចិត្តយកគ្នាជាប្តីប្រពន្ធ ចុះកិច្ចសន្យាអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានខាងលំនៅរបស់នារី ។ កិច្ចសន្យានេះត្រូវចុះក្នុងបញ្ជីអាពាហ៍ពិពាហ៍ហើយត្រូវចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាន ប្តីប្រពន្ធ និងសាក្សីគ្រប់អាយុការពីរនាក់ ។

ផ្នែកទី២: អំពីបណ្តឹងទាស់មិនអោយរៀបអាពាហ៍ពិពាហ៍

មាត្រា ១៥ : ក្នុងរយៈពេល ១០ថ្ងៃ គិតពីថ្ងៃដែលបិទផ្សាយជាសាធារណៈ ញាតិក្តី ជនដែលមានប្រយោជន៍ក្នុងរឿងនេះក្តី អាចនឹងប្តឹងជំទាស់មិនអោយរៀបអាពាហ៍ពិពាហ៍បាន ។

មាត្រា ១៦ : បណ្តឹងទាស់នេះនឹងយកជាការបាន លុះណាតែអ្នកប្តឹងជំទាស់ចុះហត្ថលេខាលើពាក្យរបស់ខ្លួន ដោយផ្ទាល់ដៃខ្លួនឯង ។

Scanned with CamScanner

បណ្តឹងនេះត្រូវចង្អុលពីមូលហេតុនៃការប្តឹងទាស់ ។ មូលហេតុដែលអាចយកមកប្តឹងជំទាស់បាននោះ គឺអសមត្ថភាពរបស់បុរស ឬនារី ឬមានប្រការណាមួយដែលច្បាប់ហាមឃាត់ក្នុងមាត្រា ៥ វាក្យខណ្ឌទី ១ មាត្រា៦ មាត្រា៧ និងមាត្រា៨នៃច្បាប់នេះ ។

មាត្រា ១៧ : បណ្តឹងទាស់នោះត្រូវអ្នកប្តឹងជំទាស់ ឬតំណាងរបស់ខ្លួនយកទៅជូនគណៈកម្មាធិការប្រជាជនឃុំ ឬសង្កាត់ខាងលំនៅនៃអនាគតប្រពន្ធ ។ គណៈកម្មាធិការនេះ ត្រូវសម្រេចក្នុងរយៈពេល ៣ ថ្ងៃ គិតពីថ្ងៃទទួលបណ្តឹងទាស់ ។ បើអ្នកប្តឹងជំទាស់ ឬអនាគតប្តីប្រពន្ធ មិនសុខចិត្តនឹងសេចក្តីសម្រេចនេះ គណៈកម្មាធិការប្រជាជនឃុំ ឬសង្កាត់ ត្រូវបញ្ជូនសំណុំរឿងទៅតុលាការប្រជាជនក្នុងរយៈពេល ៥ ថ្ងៃ យ៉ាងយូរ គិតពីថ្ងៃទទួលបណ្តឹងទាស់ ដើម្បីសម្រេច ។

មាត្រា ១៨ : តុលាការប្រជាជន ត្រូវសម្រេចសេចក្តីពីបណ្តឹងទាស់ក្នុងរយៈពេល ៧ ថ្ងៃ យ៉ាងយូរគិតពីថ្ងៃបានទទួលសំណុំរឿង ។ សាលក្រមរបស់តុលាការប្រជាជន មិនអាចប្តឹងតវ៉ាបានឡើយ ទោះបីសាលក្រមនោះវាជាសាលក្រមកំប៉ាំងមុខក៏ដោយ ។

មាត្រា ១៩ : បើតុលាការប្រជាជនបដិសេធបណ្តឹងទាស់ចោល អនាគតប្តី ប្រពន្ធ អាចរៀបអាពាហ៍ពិពាហ៍បាន ។ បើតុលាការប្រជាជនចាត់ទុកបណ្តឹងទាស់នោះជាត្រឹមត្រូវ មន្ត្រីអត្រានុកូលដ្ឋានត្រូវបញ្ឈប់មិនអោយរៀបអាពាហ៍ពិពាហ៍ ។

មាត្រា ២០ : នៅពេលដែលដឹងថា បុរស ឬនារី ជាអសមត្ថជន ឬមានប្រការណាមួយដែលច្បាប់ហាមឃាត់ដូចមានចែងក្នុងមាត្រា ១៦ មន្ត្រីអត្រានុកូលដ្ឋានមានសិទ្ធិជំទាស់មិនអោយរៀបអាពាហ៍ពិពាហ៍ ដោយធ្វើរបាយការណ៍ពីបណ្តឹងទាស់នេះ ជូនទៅតុលាការប្រជាជនក្នុងរយៈពេល ២ ថ្ងៃ យ៉ាងយូរ ដើម្បីសម្រេច ។
តុលាការប្រជាជន ត្រូវសម្រេចសេចក្តីតាមបទប្បញ្ញត្តិដែលមានចែងក្នុងមាត្រា ១៨ និង ១០ ខាងលើ ។

ផ្នែកទី៣ : អំពីមោឃភាពនៃអាពាហ៍ពិពាហ៍

មាត្រា ២១ : អាពាហ៍ពិពាហ៍ត្រូវទុកជាមោឃៈ ប្រសិនបើអាពាហ៍ពិពាហ៍នោះចុះបញ្ជីនៅពេលដែលសហព័ទ្ធណាម្នាក់ឆ្លត ឬមិនដឹងខុសត្រូវ ។ តែបើសហព័ទ្ធនោះបានជាស្រួលឡើងវិញហើយ ហេតុដែលនាំអោយទុកជាមោឃៈនោះត្រូវរលាយទៅវិញដែរ ។

មាត្រា ២២ : អាពាហ៍ពិពាហ៍រវាងបុរសអាយុតិចជាង ២០ឆ្នាំ ឬនារីអាយុតិចជាង ១៨ ឆ្នាំ ត្រូវទុកជាមោឃៈ ។
អាពាហ៍ពិពាហ៍ដែលទុកជាមោឃៈនោះ នឹងលែងមោឃៈទៅវិញ កាលបើប្តី ឬប្រពន្ធនោះចំរើនវ័យដល់អាយុតាមបញ្ញត្តិច្បាប់ ឬក្នុងករណីដែលមានចែងក្នុងមាត្រា៥ វាក្យខណ្ឌទី ២ ។

មាត្រា ២៣ : អាពាហ៍ពិពាហ៍ត្រូវទុកជាមោឃៈ កាលបើសហព័ទ្ធណាម្នាក់ប្តឹងថា ខ្លួនត្រូវគេចាប់បង្ខំអោយរៀបអាពាហ៍ពិពាហ៍ ។ ការប្តឹងសុំមោឃភាពនៃអាពាហ៍ពិពាហ៍ត្រូវផុតអាជ្ញាយុកាល ប្រសិនបើការប្តឹងនោះមិនធ្វើក្នុងរយៈ ៦ ខែ គិត ពីថ្ងៃដែលគេលែងបង្ខំនោះមក ។

មាត្រា ២៤ : អាពាហ៍ពិពាហ៍ត្រូវទុកជាមោឃៈ បើចំណងអាពាហ៍ពិពាហ៍មុនរបស់សហព័ទ្ធណាម្នាក់មិនទាន់រលាយ ។

Scanned with CamScanner

ការប្តឹងសុំមោឃភាពនៃអាពាហ៍ពិពាហ៍ក្រោយ មិនអាចធ្វើបានឡើយ បើក្រោយពីថ្ងៃចុះអាពាហ៍ពិពាហ៍ក្រោយនេះមក អាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ។

មាត្រា ២៥ : អាពាហ៍ពិពាហ៍រវាងញាតិលោហិត ឬញាតិពន្ធក្នុងថ្នាក់ដែលច្បាប់ហាមឃាត់ត្រូវទុកជាមោឃៈ លើកលែងតែករណីដែលមានចែងក្នុងមាត្រា ៨ វាក្យខណ្ឌទី ២ ។ ការប្តឹងសុំមោឃភាពនៃអាពាហ៍ពិពាហ៍ខាងលើនេះ មិនអាចផុតអាជ្ញាយុកាលឡើយ ។

មាត្រា ២៦ : មានតែសហព័ទ្ធ រដ្ឋអាជ្ញា និងជនដែលមានប្រយោជន៍ស្របច្បាប់ក្នុងការប្តឹងសុំមោឃភាពនៃអាពាហ៍-ពិពាហ៍ទេ ទើបអាចដាក់ពាក្យប្តឹងសុំមោឃភាពនៃអាពាហ៍ពិពាហ៍ទៅតុលាការប្រជាជនបាន ។

បើជនដែលបានដាក់ពាក្យប្តឹងនោះស្លាប់ សិទ្ធិវិន្តអាចប្តឹងជំនួសបាន ។

មាត្រា២៧ : កូនកើតអំពីអាពាហ៍ពិពាហ៍ដែលតុលាការបានប្រកាសជាមោឃៈ ត្រូវទុកជាកូនមានខាន់ស្លា ទោះបីហេតុដែលនាំអោយមានមោឃភាពនោះយ៉ាងណាក៏ដោយ ។

សិទ្ធិ និងកាតព្វកិច្ចរបស់ឪពុក ម្តាយ និងកូន ត្រូវមានដូចគ្នាក្នុងករណីនៃឪពុកម្តាយលែងលះគ្នា ។

ការចែកទ្រព្យសម្បត្តិរវាងប្តី ប្រពន្ធ នៃអាពាហ៍ពិពាហ៍ដែលតុលាការប្រកាសជាមោឃៈក៏ត្រូវធ្វើដូចក្នុងករណីលែងលះគ្នាដែរ ។

មាត្រា២៨ : តុលាការប្រជាជន ត្រូវចាត់ចែងអោយចម្លងសេចក្តីវិនិច្ឆ័យនៃសាលក្រមស្ថាពរដែលប្រកាសមោឃភាពអាពាហ៍ពិពាហ៍ ចុះនៅរឹមចំពីរនៃសំបុត្រអាពាហ៍ពិពាហ៍ដែលត្រូវទុកជាមោឃៈ ។"

📖 អត្ថបទលទ្ធិ ស្តីពីប្រធានបទនេះ : អាទិ :

Marion SIMONET, Docteur en droit, Avocate, « Le droit de la famille au Cambodge, Droit officiel, norme sociale et pratique judiciaire », *in Annales de la Faculté de droit et des sciences économiques de Phnom Penh* 1999, p. 23 et s.

- ដកស្រង់យកនូវគំនិតចម្បងដែលទាញចេញពីចំណេះដឹងរបស់អ្នកទាក់ទងនឹងប្រធានបទ :

ផ្អែកតាមចំណេះដឹង និងការអានរបស់អ្នក អ្នកលើកឡើងបង្ហាញនូវរាល់ចំណុចទាំងឡាយដែលអ្នកដកស្រង់ចេញពីប្រធានបទ ដោយពុំទាន់រៀបចំគំនិតទាំងនោះ :

* ការរៀបអាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាឱឡារិក

* សមត្ថភាពមាតិកភណ្ឌ

* ការព្រមព្រៀង "សហព័ទ្ធ. ការយល់ព្រមពីឪពុកម្តាយ ឬអាណាព្យាបាល"

* ការហាមឃាត់រៀបអាពាហ៍ពិពាហ៍ សម្រាប់បុគ្គលទាំងឡាយដែលពុំមានសម្បទាខាងរូបកាយ និងស្មារតី បុគ្គលដែលមានភេទដូចគ្នា

* ការហាមឃាត់រៀបអាពាហ៍ពិពាហ៍ ជាអាទិ៍ រវាងបច្ឆាជាតិ និងបុព្វជាតិ

Scanned with CamScanner

* ទម្រង់នៃការរៀបអាពាហ៍ពិពាហ៍ : ដាក់ពាក្យបណ្តឹងទៅគណៈកម្មាធិការប្រជាជនឃុំ ឬសង្កាត់ខាងលំនៅរបស់នារី ការប្រកាសផ្សាយជូនដំណឹងអំពីការរៀបអាពាហ៍ពិពាហ៍ ទីកន្លែងរៀបចំអាពាហ៍ពិពាហ៍ ឬទីកន្លែងរៀបចំអាពាហ៍ពិពាហ៍តាមច្បាប់ ។

* ការធ្វើពាក្យបណ្តឹងជំទាស់ទៅនឹងការរៀបអាពាហ៍ពិពាហ៍ : ប្តឹងទាស់

* មោឃភាពអាពាហ៍ពិពាហ៍

មុននឹងសិក្សាឱ្យបានស៊ីជម្រៅ និងប៉ុនប៉ងព្យាយាមរៀបចំលើចំណុចទាំងនេះ អ្នកត្រូវផ្ទៀងផ្ទាត់ថា អ្នកពុំបានភ្លេចចំណុចណាផ្សេងទៀតនោះទេ ហើយម៉្យាងវិញទៀតថា តើគ្មានចំណុចណាមួយដែលនាំឱ្យការបកស្រាយរបស់អ្នកចាកប្រធាននោះទេ ។ ដូច្នេះ អ្នកត្រូវតែលើកឡើងសាជាថ្មីឡើងវិញ ហើយសួរថា តើចំណុចទាំងនេះពិតជាមានទំនាក់ទំនងយ៉ាងត្រឹមត្រូវជាមួយប្រធានបទដែរឬទេ? "*ការបង្កើតអាពាហ៍ពិពាហ៍* ។ ឧទាហរណ៍ : ក្នុងករណីដែលនិស្សិតគិតដល់ចំណុចដែលទាក់ទងនឹងអានុភាពនៃការរៀបអាពាហ៍ពិពាហ៍ គំនិតនេះនឹងត្រូវញែកចោល ដោយហេតុថា គំនិតនេះពុំទាក់ទងនឹងការបង្កើតអាពាហ៍ពិពាហ៍នោះទេ ។ ក្រោយពីបានពិនិត្យសាជាថ្មីឡើងវិញរួចហើយ អ្នកត្រូវកំណត់ព្រំដែនឱ្យបានត្រឹមត្រូវនូវគ្រោះថ្នាក់ក្នុងការបកស្រាយ ដែលអាចទាក់ទងនឹងការចាកប្រធាន ឬភាពមិនពេញលេញ ។

<u>ដំណាក់កាលទី ៣ : ការបង្កើតបន្ថែម</u>

- ពេលវេលាទី ១ អ្នកត្រូវព្យាយាមចងក្រងប្រមែប្រមូលចំណុចទាំងឡាយ ក្នុងចំណោមចំណុចដែលបានដកស្រង់ខាងលើ ដែលស្ថិតនៅក្នុងគំនិតតែមួយដូចគ្នា ដោយបង្កើតជាចង្កោមនៃគំនិតមួយ :

ឧទាហរណ៍ : យើងអាចចាត់ទុក ចំណុចដែលថា ការរៀបអាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាឌ្វេភាគី និងចំណុចដែលកំណត់ពីភាពចាំបាច់ក្នុងការបំពេញនូវលក្ខខណ្ឌដើម្បីឱ្យកិច្ចសន្យានេះមានសុពលភាព ស្ថិតនៅក្នុងគំនិតរួមមួយដូចគ្នា: ការរៀបអាពាហ៍ពិពាហ៍ត្រូវគោរពតាមលក្ខខណ្ឌជាទម្រង់ ។

សមត្ថភាពមាតិកភណ្ឌ និងការព្រមព្រៀង បង្ហាញថា ការបង្កើតអាពាហ៍ពិពាហ៍ ត្រូវការជាចាំបាច់នូវលក្ខខណ្ឌដែលយើងឱ្យឈ្មោះថា ជាលក្ខខណ្ឌនៃការបង្កើតកិច្ចសន្យា ។

ការហាមឃាត់អាពាហ៍ពិពាហ៍ ដោយមូលហេតុទាក់ទងនឹងភេទ ឬសមត្ថភាពខាងរូបកាយ ឬស្មារតី គឺជាលក្ខខណ្ឌ ដែលយើងឈ្មោះថា ជាលក្ខខណ្ឌខាងសរីរសាស្ត្រ ។

ការហាមឃាត់អាពាហ៍ពិពាហ៍រវាងបច្ចាញ្ញាតិ និងបុព្វញ្ញាតិ បញ្ជាក់ពីលក្ខខណ្ឌខាងសង្គមសាស្ត្រនៃការរៀបអាពាហ៍ពិពាហ៍ ។

ទីបញ្ចប់ ការប្តឹងទាស់នឹងការរៀបអាពាហ៍ពិពាហ៍ និងមោឃភាពអាពាហ៍ពិពាហ៍ បង្កើតជាទណ្ឌកម្មចំពោះការបង្កើតអាពាហ៍ពិពាហ៍មិនត្រឹមត្រូវតាមច្បាប់ ។ និយាយឱ្យច្បាស់ជាងនេះ បណ្តឹងទាស់គឺជាទណ្ឌកម្មរដ្ឋប្បវេណី ដែលអាចធ្វើបានមុនពេលរៀបអាពាហ៍ពិពាហ៍ ។ បណ្តឹងនេះធ្វើឡើងក្នុងគោលដៅ ដើម្បីជៀសវាងអាពាហ៍ពិពាហ៍ ត្រូវបាន

Scanned with CamScanner

បង្កើតឡើងពុំត្រឹមត្រូវតាមច្បាប់ ។ ចំណែកឯ មោឃភាពអាពាហ៍ពិពាហ៍ គឺជាទណ្ឌកម្មតាមផ្លូវតុលាការ ដែលអាចបង្កើតបានជាអានុភាព ប្រសិនបើអាពាហ៍ពិពាហ៍ត្រូវបានបង្កើតឡើង ប៉ុន្តែ គ្មានសុពលភាព ។

- ពេលវេលាទី ២ : អ្នកត្រូវរៀបចំគំនិតខាងលើរវាងគ្នា ដោយស្របតាមភាពតក្ក មានន័យថា កំណត់ពីទំនាក់ទំនងនៃគំនិតទាំងនោះរវាងគ្នា ។

ចំពោះប្រធានបទនេះ មានគំនិតចំនួន ០៥ ដែលយើងអាចរៀបចំជាមុន : លក្ខខណ្ឌជាទម្រង់នៃការរៀបអាពាហ៍ពិពាហ៍, លក្ខខណ្ឌនៃការបង្កើតកិច្ចសន្យា, លក្ខខណ្ឌខាងសរីរសាស្ត្រ, លក្ខខណ្ឌខាងសង្គមសាស្ត្រ និងទណ្ឌកម្ម : បណ្តឹងទាស់ និងមោឃភាព ។

អ្នកត្រូវពន្យល់បន្ថែមឡើតអំពីវិធីសាស្ត្រ ក្នុងការបង្កើតនូវទំនាក់ទំនងនៃគំនិតទាំងនោះរវាងគ្នា ។ ក្នុងឧទាហរណ៍របស់យើង ដើម្បីបង្កើតកិច្ចសន្យាអាពាហ៍ពិពាហ៍មួយឱ្យមានសុពលភាព វាត្រូវបំពេញនូវលក្ខខណ្ឌមួយចំនួន ។ ប្រសិនជាមានទណ្ឌកម្មក៏អាចត្រូវបានអនុវត្តផងដែរ ។ យើងអាចទាញបាននូវគោលគំនិតចម្បងពីរគឺ លក្ខខណ្ឌនៃការបង្កើតអាពាហ៍ពិពាហ៍ និងទណ្ឌកម្មនៃការបង្កើតអាពាហ៍ពិពាហ៍ ។ ដូច្នេះ ប្រធានបទរបស់យើងនឹងត្រូវបកស្រាយជុំវិញគោលគំនិតចម្បងទាំងពីរនេះ ។ អាពាហ៍ពិពាហ៍ត្រូវបានបង្កើតឡើងដោយមានសុពលភាព ប្រសិនបើលក្ខខណ្ឌរបស់វាជាច្រើនត្រូវបានបំពេញ : លក្ខខណ្ឌជាគ្រឹះ លក្ខខណ្ឌជាទម្រង់ ដែលក្រសោបនូវលក្ខខណ្ឌផ្សេងៗជាច្រើនទៀត ដូចជា លក្ខខណ្ឌនៃការបង្កើតកិច្ចសន្យា លក្ខខណ្ឌខាងសរីរសាស្ត្រ និងខាងសង្គមសាស្ត្រ ។ ប្រសិនបើ លក្ខខណ្ឌទាំងនេះ ឬលក្ខខណ្ឌណាមួយពុំត្រូវបានបំពេញនោះទេ ទណ្ឌកម្មអាចនឹងត្រូវអនុវត្ត : ទណ្ឌកម្មរដ្ឋប្បវេណី "*ប្តឹងទាស់*" និងទណ្ឌកម្មតាមផ្លូវតុលាការ "*មោឃភាព*" ។

- ពេលវេលាទី ៣ : បន្ទាប់បានរៀបចំនូវគំនិតទាំងឡាយខាងលើរួចរាល់ហើយ យើងអាចទាញ និងកំណត់បានជាប្លង់មួយ :

I. លក្ខខណ្ឌនៃការបង្កើតអាពាហ៍ពិពាហ៍

A. លក្ខខណ្ឌជាគ្រឹះនៃការបង្កើតអាពាហ៍ពិពាហ៍

B. លក្ខខណ្ឌជាទម្រង់នៃការបង្កើតអាពាហ៍ពិពាហ៍

II. ទណ្ឌកម្មចំពោះលក្ខខណ្ឌនៃការបង្កើតអាពាហ៍ពិពាហ៍

A. ទណ្ឌកម្មមុនពេលបង្កើតអាពាហ៍ពិពាហ៍ ឬទណ្ឌកម្មរដ្ឋប្បវេណី

B. ទណ្ឌកម្មក្រោយពេលបង្កើតអាពាហ៍ពិពាហ៍ ឬទណ្ឌកម្មតាមផ្លូវតុលាការ

បន្ទាប់ពីបានប្លង់ យើងគ្រាន់តែបំពេញដំណាក់កាលចុងក្រោយ គឺការសរសេរតាក់តែងប៉ុណ្ណោះ ។

Scanned with CamScanner

ផ្នែកទី ២ : លំហាត់អនុវត្តន៍ទីសាស្ត្រ

គថាខណ្ឌទី ១ : នីតិរដ្ឋប្បវេណី

ក. ប្រធានបទ

"ការការពាររូបកាយមនុស្ស"

ខ. តំណែ : (ណន ប៊ុនណា)

បុគ្គលិកលក្ខណៈគតិយុត្ត គឺជាសម្បទាដែលត្រូវបានទទួលស្គាល់ចំពោះគ្រប់រូបវន្តបុគ្គលទាំងអស់ដែលជាម្ចាស់សិទ្ធិ និងជាប្រធាននៃកាតព្វកិច្ច ។ គ្រប់រូបវន្តបុគ្គលដែលមានបុគ្គលិកលក្ខណៈគតិយុត្តទទួលបាននូវការការពារពីច្បាប់ និងតាមរយៈតុលាការ ។ ក្នុងករណីនេះ រូបវន្តបុគ្គលមានសិទ្ធិទាមទារ និងធ្វើឱ្យមានការគោរពសិទ្ធិទាំងឡាយដែលគាត់ជាម្ចាស់ ដែលក្នុងនោះយើងអាចរាប់បានមាន សិទ្ធិក្នុងការការពាររូបកាយ ដែលលេចឡើងនូវសារៈសំខាន់មួយ ដោយហេតុថា វាទាក់ទងនឹងសិទ្ធិទីមួយរបស់មនុស្ស គឺ សិទ្ធិមានជីវិតរស់នៅ ។

បើសិនជាច្បាប់ការពារដល់រូបកាយនៃរូបវន្តបុគ្គល យើងត្រូវដឹងថា តើរូបកាយនេះទទួលបាននូវការពារតាមច្បាប់ចាប់ផ្តើមពីពេលវេលាណាមួយ និងរហូតដល់ពេលវេលាណាមួយ ។ ការចាប់ផ្តើមមានវត្តមាននៃការការពាររូបកាយរបស់រូបវន្តបុគ្គលតាមច្បាប់ គឺអាស្រ័យទៅលើថ្ងៃទទួលបានបុគ្គលិកលក្ខណៈគតិយុត្ត ។ ជាគោលការណ៍ បុគ្គលិកលក្ខណៈគតិយុត្តទទួលបានចាប់តាំងពីពេលមានកំណើត និងបាត់បង់ទៅវិញនៅពេលស្លាប់[១៣៧] ។ប៉ុន្តែ រូបរាងកាយមនុស្សមានវត្តមានមុនពេលផ្តល់កំណើត ចាប់ផ្តើមតាំងពីមានជីវិត មានន័យថា តាំងពីពេលបង្កកំណើតដំបូងម្ល៉េះ ។ ប៉ុន្តែ វាមិនមែនជារូបរាងកាយ ដែលទទួលបានការការពារពីរដ្ឋធម្មនុញ្ញ ពីអត្ថបទច្បាប់អន្តរជាតិ និងពីច្បាប់នោះទេ ។ ដូចគ្នាដែរ ការរលាយបាត់នៃបុគ្គលិកលក្ខណៈគតិយុត្ត ដោយមូលហេតុស្លាប់ បណ្តាលឱ្យមានការបញ្ចប់នូវការការពាររូបកាយរបស់មនុស្ស ។ ប៉ុន្តែ រូបកាយមនុស្សដែលបានស្លាប់ ក៏អាចមានភ័ព្វសំណាងទទួលបាននូវការការពារផងដែរ ទាំងខាងបូរណ-ភាពខាងសម្ភារៈ បើសិនជាសម្ភារៈទាំងនេះមិនត្រូវបានរលាយបាត់នោះទេ និងខាងបូរណភាពខាងផ្លូវចិត្ត ជាពិសេសទាក់ទងនឹងការថែរក្សាកិត្តិយសរបស់សព ។ ក្រោយពីការស្លាប់ សាកសពអាចទទួលបាននូវការការពារពីការបំផ្លិចបំផ្លាញ ទោះបីជាគ្មានអត្ថបទចែងឱ្យបានច្បាស់លាស់ក៏ដោយ ។ ដូច្នេះ រូបកាយដែលទទួលបានការការពារ លាតសន្ធឹងទាំងរូបកាយមានជីវិត និងអាចរស់បានដែលមានបុគ្គលិកលក្ខណៈគតិយុត្ត ។

អង្គនីតិបញ្ញត្តិកម្ពុជាបានផ្សារភ្ជាប់គោលការណ៍នៃការគោរព និងការការពារទៅដល់រូបកាយមនុស្សដែលត្រូវបានធានាដូចគ្នាផងដែរ នៅក្នុងមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញចុះថ្ងៃទី ២១-០៩-១៩៩៣ ។ ព្រះរាជាណាចក្រកម្ពុជា ក៏ជាសមាជិកនៃអនុសញ្ញាអន្តរជាតិជាច្រើនដែលប្រកាសអំពីការគោរពរូបកាយមនុស្ស និងបូរណភាពមនុស្សជាតិ ជាពិសេសអនុសញ្ញារបស់អង្គសហប្រជាជាតិស្តីពីការប្រឆាំងនឹងការដាក់ទណ្ឌកម្ម និងទោសផ្សេងទៀត ឬការប្រព្រឹត្តអំពើដ៏សាហាវយង់ខ្ពង អមនុស្សធម៌ ដែលត្រូវបានអនុម័តនៅថ្ងៃទី ១០-១០-១៩៨៤ ចូលជាធរមាននៅថ្ងៃទី ២២-០៦-១៩៨៧

---

[១៣៧] យោងតាមមាត្រា ៨ នៃសេចក្តីព្រាងក្រមរដ្ឋប្បវេណី ។ ទោះបីជាអត្ថបទនេះ ពុំបានបកស្រាយអំពីករណីនេះក៏ដោយ យើងអាចគិតបានថា បុគ្គលិកលក្ខណៈគតិយុត្តទទួលបាននាពេលមានកំណើត ប៉ុន្តែចំពោះតែក្មេងដែលបានផ្តល់កំណើតរួចហើយ មានជីវិតរស់នៅ និងអាចរស់បាន ។

Scanned with CamScanner

និងត្រូវបានចុះហត្ថលេខាដោយភាគីកម្ពុជានៅថ្ងៃទី ២២-០៩-១៩៩២ ។ យោងតាមអត្ថបទទាំងនេះ ការការពាររូបកាយមនុស្សត្រូវបានកំណត់ជានិយមន័យថា ជាសិទ្ធិរបស់បុគ្គលម្នាក់ដែលចង់ឃើញនូវរូបកាយរបស់គាត់ត្រូវបានគោរព មិនត្រឹមតែចំពោះករណីបូរណភាពរូបកាយរបស់គាត់នោះទេ ថែមទាំងចំពោះភាពមិនអាចចាត់ចែងជាប្រាក់លើរូបកាយរបស់គាត់ ឬជាតុផ្សំផ្សេងទៀតនៃសិទ្ធិនេះ ។ ការការពាររូបកាយមនុស្សផ្សារភ្ជាប់នូវគោលការណ៍ពីរយ៉ាង : គោលការណ៍មិនអាចរំលោភបំពានបានលើរូបកាយមនុស្ស (I) និងគោលការណ៍មិនអាចផ្ទេរបាននៃរូបកាយមនុស្ស (II) ។

I. ភាពមិនអាចរំលោភបានលើរូបកាយមនុស្ស :

គ្រប់រូបវន្តបុគ្គលទាំងអស់មានសិទ្ធិចំពោះការគោរពរូបកាយផ្ទាល់ខ្លួន ដោយប្រឆាំងរាល់គ្រប់រូបភាពនៃការរំលោភបំពាន (A) ។ ប៉ុន្តែ អត្តចរិតខ្លះ បង្កើតបានជាអំពើយុត្តិកម្មដែលរួចផុតពីការដាក់ទណ្ឌកម្មក្នុងករណីមានការរំលោភបំពានទៅដល់រូបកាយមនុស្ស (B) ។

A. ការហាមឃាត់រាល់ការប៉ះពាល់ទៅដល់រូបកាយមនុស្ស :

គោលការណ៍នៃភាពមិនអាចរំលោភបំពានលើរូបកាយមនុស្សត្រូវបានការការពារដោយរដ្ឋធម្មនុញ្ញ ។ គោលការណ៍នេះមានចែងយ៉ាងជាក់ច្បាស់នៅក្នុងមាត្រា ៣២ និង ៣៨ នៃរដ្ឋធម្មនុញ្ញ ។ មាត្រា ៣២ ចែងថា "គ្រប់បុគ្គលទាំងអស់មានសិទ្ធិរស់រានមានជីវិត សិទ្ធិសេរីភាព និងសន្តិសុខបុគ្គល ។ ទោសប្រហារជីវិតមិនត្រូវឱ្យមាននោះទេ ។" ចំណែកមាត្រា ៣៨ វិញ ចែងនូវករណីជាច្រើន ដែលក្នុងនោះការប៉ះពាល់ទៅដល់បូរណភាពរូបកាយត្រូវបានហាមឃាត់ ថែមទាំងត្រូវបានផ្តន្ទាទោស ។ យោងតាមបទប្បញ្ញត្តិនេះ "ច្បាប់ហាមឃាត់រាល់ការរំលោភបំពាន់លើរូបកាយរបស់បុគ្គល (...)" ។ ការចាប់បង្ខំ ការដាក់ទណ្ឌកម្ម ឬរាល់ការប្រព្រឹត្តដាក់ទម្ងន់ទោសចំពោះជនជាប់ជាប់ ឬទណ្ឌិតត្រូវបានហាមឃាត់ ។ ចារី ឬសហចារី និងជនសមគំនិតនៃការប្រព្រឹត្តនេះ ត្រូវតែផ្តន្ទាទោសយោងតាមបទប្បញ្ញត្តិរបស់ច្បាប់(...) ។"

ម៉្យាងវិញទៀត រាល់ការប៉ះពាល់ខុសច្បាប់ទៅរូបកាយមនុស្សក៏បង្កើតបានជាបទល្មើសព្រហ្មទណ្ឌផងដែរ ហើយត្រូវបានផ្តន្ទាទោសដោយច្បាប់ព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី ១០-០៩-១៩៩២ នៅក្នុងផ្នែកទី ៤ និងទី ៥ ដែលកំណត់អំពីបទល្មើសឧក្រិដ្ឋ និងមជ្ឈឹម ប្រឆាំងនឹងមនុស្ស ដូចជា បទល្មើសមនុស្សឃាដគិតទុកជាមុន (មាត្រា ៣១), បទល្មើសមនុស្សឃាដដោយចេតនា (មាត្រា ៣២), បទល្មើសរំលោភសេពសន្ថវៈ (មាត្រា ៣៣), បទល្មើសប្លន់ (មាត្រា ៣៤), បទល្មើសប្រើប្រាស់អាវុធខុសច្បាប់ (មាត្រា ៣៥), បទល្មើសមនុស្សឃាដដោយអចេតនា (មាត្រា ៤០), បទល្មើសបង្ករបួសស្នាមដោយចេតនា (មាត្រា ៤១), បទល្មើសប្បើតប្បើនកេរ្តិ៍ខ្មាស (មាត្រា ៤២) ។ ការអនុម័តក្រមព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌដែលត្រូវបានរៀបចំដោយសហប្រតិបត្តិការរបស់បារាំង នាពេលខាងមុខ អនុញ្ញាតឱ្យមានការធានាយ៉ាងមានប្រសិទ្ធិភាព ក្នុងការការពារបូរណភាពរូបកាយរបស់បុគ្គល និងធានាឱ្យកាន់តែប្រសើរឡើងនូវភាពមិនអាចរំលោភបំពានបាន ទៅដល់រូបកាយមនុស្ស ។

យើងគួរកត់ចំណាំថា រាល់ការបំពានទៅដល់រូបកាយមនុស្ស ត្រូវបានផ្តន្ទាទោស ប្រសិនបើទង្វើទាំងនោះត្រូវបានប្រព្រឹត្តដោយគ្មានការយល់ព្រមបុគ្គលនោះខ្លួនឯង ។ សំណួរអាចត្រូវបានចោទឡើងថា តើការយល់ព្រមអាចកែ

Scanned with CamScanner

តម្រូវចំពោះការបំពានទៅលើរូបកាយមនុស្សដែរ ឬទេ ជាពិសេសក្នុងករណីសុមរណ៍ ។ នាពេលបច្ចុប្បន្ននេះ សណ្តាប់ធ្នាប់គតិយុត្តកម្ពុជាពុំទាន់មានបទប្បញ្ញត្តិច្បាស់លាស់ ដើម្បីឆ្លើយតបទៅសំណួរខាងលើនេះទេ ។ តាមទស្សនៈគតិយុត្ត បុគ្គលពុំមែនជាម្ចាស់រូបកាយរបស់ខ្លួន ។ តាមពិត វាពុំមានភាពតក្កនោះទេ ក្នុងការលប់ចោលនូវការទទួលខុសត្រូវរបស់វិជ្ជបណ្ឌិត ទោះបីជាការយល់ព្រមពីអ្នកជម្ងឺក៏ដោយ ។ ដូច្នេះ ក្នុងន័យនេះហើយ ដែលអត្ថបទនីតិបញ្ញត្តិបារាំងមានគោលដៅកំណត់អំពីផ្នែកសុមរណ៍នេះ ដែលអំពើនេះនៅតែចាត់ទុកជាបទល្មើសមនុស្សឃាដដោយចេតនាដដែល ។

ប៉ុន្តែ គោលការណ៍នៃការហាមឃាត់រាល់ការបំពានទៅដល់រូបកាយមនុស្ស អាចត្រូវបានញែកចេញ នៅក្នុងករណីដែលមានអំពើ ឬស្ថានភាពខ្លះ អាចកែតម្រូវចំពោះរាល់ការបំពាន យោងតាមទ្រឹស្តីនៃការដាក់ទណ្ឌកម្ម ។

B. អំពើយុត្តិការនៃការប៉ះពាល់ទៅដល់រូបកាយមនុស្ស :

អត្តចរិតមួយចំនួន ដែលត្រូវបានកែតម្រូវដោយមានភាពចាំបាច់ ឬដែលត្រូវបានអនុគ្រោះដោយចំនៀមទម្លាប់ប្រពៃណី ឬច្បាប់របស់ប្រទេសមួយ អាចត្រូវបានរួចផុតពីការដាក់ទណ្ឌកម្មរដ្ឋប្បវេណី ឬព្រហ្មទណ្ឌ ។ ដូច្នេះ ការបំពានខុសច្បាប់ទៅលើរូបកាយមនុស្ស ធ្វើសម្បទាន ជាពិសេសចំពោះមុខការប្រើប្រាស់ដ៏សមស្រមមួយនូវសិទ្ធិកែលំអរ និងអប់រំពីឪពុកម្តាយ ចំពោះកូន ។ សិទ្ធិកែលំអរ និងអប់រំរបស់ឪពុកម្តាយនេះ មានចែងក្នុងមាត្រា ១០៤២ នៃសេចក្តីព្រាងក្រមរដ្ឋប្បវេណី ដែលត្រូវបានរៀបចំដោយកិច្ចសហការជាមួយជប៉ុន ។ ប៉ុន្តែ សិទ្ធិកែលំអរនេះពុំមែនគ្មានព្រំដែនកំណត់នោះទេ ហើយការប្រើប្រាស់ដោយរំលោភបំពានទៅលើសិទ្ធិនេះ នាំឱ្យមានការបាត់បង់នូវអំណាចមេបា ដែលជាទណ្ឌកម្មត្រូវបានធ្វើឡើងដោយតុលាការ ស្របតាមបទប្បញ្ញត្តិនៃមាត្រា ១១៩-១២១ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ ១៩៨៩ (មាត្រា ១០៤៥ នៃសេចក្តីព្រាងក្រមរដ្ឋប្បវេណីខាងលើ) ។

យើងត្រូវកំណត់ចំណាំស្របគ្នានេះដែរ ក្នុងសង្គមខ្មែរ មានស្ត្រីជាច្រើនធ្លាប់ជាជនរងគ្រោះ ដោយមូលហេតុនៃការប្រើអំពើហិង្សាក្នុងគ្រួសារ ។ ស្ត្រីទាំងនោះ មានពេលខ្លះ ទទួលរងនូវការបំពានយ៉ាងធ្ងន់ធ្ងរ ដូចជាការបង្ករបួសស្នាមទៅលើបូរណភាពរូបកាយ និងផ្លូវចិត្តរបស់គាត់ ។ អំពើប្រព្រឹត្តក្នុងក្របខណ្ឌគ្រួសារនេះ មិនត្រូវបានចាត់ទុកជាអំពើយុត្តិការនៃភាពមិនអាចរំលោភបំពានបានលើរូបកាយមនុស្សនោះទេ ។ អំពើទាំងនេះត្រូវបានចាត់ទុកយ៉ាងត្រឹមត្រូវជាការរំលោភបំពានខុសច្បាប់លើរូបកាយមនុស្ស ។ កាលពីមុន ការទទួលខុសត្រូវរបស់ចារីនៅក្នុងអំពើនេះពុំអាចត្រូវបានធ្វើឡើង ទាំងតាមច្បាប់ និងតាមផ្លូវតុលាការ ដោយហេតុថា យើងមានកង្វះខាតអត្ថបទដែលចែង និងដាក់ទណ្ឌកម្មអំពីអំពើជាពិសេសនេះ ។ បច្ចុប្បន្នកាលនេះ ការអនុម័តច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការជនរងគ្រោះ នៅថ្ងៃទី ១៩-០៩-២០០៥ អនុញ្ញាតឱ្យមានការទប់ស្កាត់ និងការបង្ក្រាប ដោយមានលក្ខណៈជាទូទៅ ចំពោះរាល់អំពើហិង្សាដែលប៉ះពាល់ដល់បូរណភាពរូបកាយ និងផ្លូវចិត្ត របស់មនុស្ស ។ យើងសង្ឃឹមថា ការអនុវត្តច្បាប់ខាងលើនេះនឹងអនុញ្ញាតឱ្យមានការគោរពយ៉ាងពេញទំហឹងនូវការគោរពគោលការណ៍សិទ្ធិស្មើភាពគ្នារវាងបុរស និងនារីដែលត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ ចំពោះអំពើខាងលើនេះ ។

ភាពមិនអាចរំលោភបំពានបាន ត្រូវបានលុបចោលនៅក្នុងផលប្រយោជន៍ផ្នែកវិជ្ជសាស្ត្រផងដែរ ដូចជាក្នុងករណីមានការជួយសង្គ្រោះជីវិតរបស់អ្នកជម្ងឺម្នាក់ដែលស្ថិតនៅក្នុងគ្រោះអាសន្ន ជាបន្ទាន់ ។ ជាធម្មតា វិជ្ជបណ្ឌិតត្រូវ

Scanned with CamScanner

ទទួលបានការយល់ព្រមជាបឋមអំពីអ្នកជម្ងឺ មុននឹងធ្វើប្រតិបត្តិការវះកាត់ ។ ប៉ុន្តែ ក្នុងសមតិកម្មនេះ ការបំពានទៅលើបូរណភាពរូបកាយរបស់អ្នកជម្ងឺអាចត្រូវដោះសារដោយផលប្រយោជន៍នៃភាពមានជីវិតរបស់គាត់ ។ ក្នុងមុខវិជ្ជានេះ ព្រះរាជាណាចក្រកម្ពុជា ពុំទាន់មានអត្ថបទច្បាប់វិជ្ជមាននោះទេ ។ ដំណោះស្រាយនៃបញ្ហានេះត្រូវបានធ្វើឡើងដោយយោងតាមទំនៀមទម្លាប់ និងសមធម៌ ។

នៅទីបញ្ចប់ ករណីមួយទៀតនៃការបំពានដល់រូបកាយមនុស្សដែលអាចត្រូវបានកែតម្រូវ ស្ថិតនៅក្នុងលទ្ធភាពរបស់ស្ត្រីម្នាក់ដែលមានផ្ទៃពោះ ហើយចង់រំលូតកូន ។ តាមទស្សនៈវិស័យខាងជីវសាស្ត្រ, ខាងទស្សនៈវិទូ និងខាងសាសនា គភ៌ ឬទារកក្នុងផ្ទៃម្តាយ ក៏ជាមនុស្សផងដែរ ដោយសារតែមាននៃរូបកាយ ។ មុនផ្តល់កំណើត ទារកក្នុងផ្ទៃម្តាយ ស្ថិតនៅក្រោមរបបគតិយុត្តពិសេស ។ ច្បាប់ខ្មែរទទួលស្គាល់អំពីនីត្យនុកូលភាពនៃការរំលូតកូន បើសិនជាការរំលូតកូននេះត្រូវបានធ្វើឡើងដោយគោរពតាមបទប្បញ្ញត្តិមាត្រា ៨ នៃច្បាប់ចុះថ្ងៃទី ១២-១១-១៩៩៧ ស្តីពីការរំលូតកូន[១៣៨] ដែលចែងថា ការរំលូតកូនអាចធ្វើបានតែក្នុងករណី ដែលម្តាយមានគភ៌មិនលើសពី ១២ សប្តាហ៍ ។ ប៉ុន្តែ បើសិនជាម្តាយមានគភ៌លើសពី ១២ សប្តាហ៍ ការរំលូតកូនអាចធ្វើបានតែក្នុងករណីដូចខាងក្រោមនេះ : ការមានផ្ទៃពោះពុំមានការវិវត្តន៍ដូចធម្មតា ហើយដែលធ្វើឱ្យប៉ះពាល់ដល់ជីវិតរបស់ម្តាយ, កូនដែលនឹងកើតនោះ ទទួលរងនូវជម្ងឺមើលមិនជា, នារីមានគភ៌ដោយមូលហេតុនៃការរំលោភសេពសន្ថវៈ, ការរំលូតអាចត្រូវបានធ្វើឡើង ដោយពុំចាំបាច់គិតគូលើលក្ខខណ្ឌខាងលើនោះទេ តាមការស្នើសុំរបស់ស្ត្រីមានផ្ទៃពោះ បើសិនជាស្ត្រីនោះមានអាយុលើសពី ១៨ ឆ្នាំ និងតាមការស្នើសុំរបស់ឪពុកម្តាយ បើសិនស្ត្រីមានអាយុតិចជាង ១៨ ឆ្នាំ ។

ដូច្នេះ ភាពមិនអាចរំលោភបំពានទៅដល់រូបកាយមនុស្សនេះ ទាក់ទងនឹងការការហាមឃាត់នូវគ្រប់រូបភាពនៃការបំពានខុសច្បាប់ទៅដល់រូបកាយមនុស្ស ។ ប៉ុន្តែ ការការពារតាមច្បាប់ និងតាមផ្លូវតុលាការមិនត្រូវបានកំណត់ត្រឹមតែការប៉ះពាល់លើបូរណភាពរូបកាយនោះទេ ។ តាមពិត រូបកាយមនុស្សទទួលបាននូវការការពារផងដែរ ដើម្បីប្រឆាំងនឹងគ្រប់រូបភាពនៃការលក់ ឬការចាត់ចែងផ្សេង១ ។

II. ភាពពុំអាចនៃរូបកាយមនុស្ស

រូបកាយមនុស្សមិនអាចត្រូវបានចាត់ចែងដោយសេរីនោះទេ មានន័យថា រូបកាយនេះមិនអាចធ្វើជាកម្មវត្ថុនៃសិទ្ធិបេតិកភណ្ឌនោះឡើយ (B) ។ ប៉ុន្តែ មានករណីមួយចំនួន រូបកាយ ឬធាតុផ្សំរបស់វាអាចធ្វើជាកម្មវត្ថុនៃកិច្ចសន្យា (A) ។

A. គោលការណ៍ : ភាពពុំអាចផ្ទេរបាននៃរូបកាយមនុស្ស

រូបកាយមនុស្ស គឺជាវត្ថុទ្រទ្រង់នៃអត្ថិភាពរបស់មនុស្ស ។ ដូច្នេះ រូបកាយមនុស្សស្ថិតនៅក្រៅពាណិជ្ជកម្មដែលពុំអាចធ្វើជាកម្មវត្ថុនៃកិច្ចសន្យានោះទេ ។ គោលការណ៍នេះត្រូវបានផ្សារភ្ជាប់ដោយអត្ថបទច្បាប់ជាច្រើន។ មាត្រា ៥ នៃ

---

[១៣៨] ទាក់ទងនឹងច្បាប់នេះ សូមមើលអត្ថបទរបស់អ្នកស្រី តឹម សត្ថាវី "*បទប្បញ្ញត្តិកម្ពុជាស្តីពីការរំលូតកូន*", នៅក្នុងវិស្សិកប្រវត្តិនៃមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំ ១៩៩៨, ទំព័រ ៥ និងជាបន្តបន្ទាប់ ។

Scanned with CamScanner

ក្រឹត្យ-ច្បាប់លេខ ៣៨ ចុះថ្ងៃទី ២៨-១០-១៩៨៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា រាល់កិច្ចសន្យាមានកម្មវត្ថុមិនស្របច្បាប់ ឬផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ ឬទំនៀមទម្លាប់ដ៏ល្អប្រពៃរបស់សង្គម ត្រូវបានចាត់ទុកជាមោឃៈ ។ ទោះបីជាបទប្បញ្ញត្តិនេះពុំបានចែងឱ្យបានច្បាស់អំពីគោលការណ៍ខាងលើក៏ដោយ ការលក់ ឬការផ្ទេររូបកាយមនុស្ស គឺផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈរបស់ខ្មែរ ផ្ទុយនឹងទំនៀមទម្លាប់ប្រពៃណីដ៏ល្អរបស់ខ្មែរ ។ កាលបើកិច្ចសន្យាមួយដែលត្រូវបានធ្វើឡើង ដោយប្រគល់ខ្លួនធ្វើជាទាសករ[១៣៩] ត្រូវបានចាត់ទុកជាមោឃៈ យោងតាមការអនុវត្តអត្ថបទច្បាប់ខាងលើ ។ ប៉ុន្តែ ការធានាបំពេញកាតព្វកិច្ចដោយកូនបំណុល មានន័យថា បុគ្គលម្នាក់ភ្ជាប់កិច្ចសន្យាបំពេញការងារ ដូចជាអ្នកបំពេញការងារតាមផ្ទះ ទៅដល់ម្ចាស់បំណុល ដើម្បីទូទាត់សងបំណុល[១៤០] គឺជាការអនុវត្តយ៉ាងញឹកញាប់ក្នុងសង្គមខ្មែរ ។ ទង្វើបែបនេះ ក៏ត្រូវបានចាត់ទុកជាការយកមនុស្សធ្វើជាទាសករផងដែរ ។ មូលហេតុដែលនាំឱ្យមានការប្រកាសមោឃភាពនេះ ចេញពីអង្គហេតុមួយដែលថា រូបកាយមនុស្សពុំអាចធ្វើជាកម្មវត្ថុនៃកិច្ចសន្យាបាននោះទេ វាពុំមែនជាវត្ថុ ដូច្នេះ វាពុំអាចធ្វើការផ្លាស់ប្តូរ ឬលក់នោះទេ ។ ក្នុងករណីនេះ ការជួញដូរមនុស្សត្រូវបានផ្តន្ទាទោសដោយច្បាប់ចុះថ្ងៃទី ១៦-០២-១៩៩៦ ស្តីពីការបង្ក្រាបអំពីការពង្រត់ និងការលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស ។ មាត្រា ១ នៃច្បាប់នេះចែងថា ច្បាប់នេះមានគោលដៅបង្ក្រាបអំពើពង្រត់មនុស្សយកទៅលក់ដូរ និងអំពើធ្វើអាជីវកម្មលើមនុស្ស ដើម្បីធ្វើនីតិសម្បទា និងលើកកំពស់ការគោរពប្រពៃណីជាតិល្អ ការការពារសេចក្តីថ្លៃថ្នូររបស់មនុស្ស និងការការពារសុខភាព និងសុខមាលភាពរបស់ប្រជាជន ។ បទប្បញ្ញត្តិនេះចូលរួមទប់ស្កាត់ និងដាក់ទណ្ឌកម្មរាល់អំពើប្រព្រឹត្តចាប់ពង្រត់ និងការជួញដូរកុមារ ក្នុងគោលបំណងដើម្បីយកក្មេងទាំងនេះ ចូលទៅក្នុងទីផ្សារនៃការស្នាំកូនអន្តរជាតិ នៅពេលដែលប្រទេសខ្មែរ ដែលទទួលរងការប៉ះពាល់ជាខ្លាំងតាមរយៈការស្នាំអន្តរជាតិខុសច្បាប់នេះ ពុំទាន់មានអត្ថបទច្បាប់ត្រប់គ្រាន់ ដើម្បីការពារទៅដល់ផលប្រយោជន៍របស់ក្មេង និងធានានូវភាពត្រឹមត្រូវ និងបូរណភាពនៃការស្នាំកូនខ្មែរទាំងឡាយ ។

---

[១៣៩] តទ្វិពលនៃអរិយធម៌ហិណ្ឌូបានបន្សល់ទុកនូវការបែងចែកវណ្ណៈនៅក្នុងសង្គមខ្មែរនាមជ្ឈិមសម័យ ។ នាសម័យនោះ យើងបែងចែកវណ្ណៈសង្គមរវាងសមាជិករាជវង្សានុវង្ស និងក្សត្រ, ខាងសាសនា, មនុស្សដែលមានសេរីភាព និងទាសករ ។ ប្រភពអត្ថបទដែលទាក់ទងនឹងទាសករនេះមានជាច្រើន ។ ទាសករត្រូវបានចាត់ទុកជាចលនវត្ថុ ។ ទាសករអាចធ្វើជាកម្មវត្ថុនៃការលក់, ការដោះដូរ, ការបញ្ចាំ និងការជួល ។ ដូច្នេះ ពួកគេទាំងនេះចាត់បង់នូវសិទ្ធិទាំងឡាយដែលមនុស្សធម្មតាមាន ឬនិយាយម៉្យាងទៀតថា ពួកគេទាំងនេះពុំមែនជាម្ចាស់សិទ្ធិ និងជាប្រធាននៃកាតព្វកិច្ចនោះទេ ។ ទាសករត្រូវបានលុបចោលក្រោមរបបអាណាព្យាបាលបារាំង យោងតាមដីកាឆ្នាំ ១៨៩៧ ហើយនឹងត្រូវលេចចាត់ជាស្ថាពរនៅក្នុងឆ្នាំទី ១ នៃសតវត្សទី ២០ ។ ក្នុងន័យនេះ លោក J. IMBERT "*ប្រវត្តិស្ថាប័នខ្មែរ*" ក្នុងវិស្សិកប្រវត្តិមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំ ១៩៦១, ទំព័រ ៣៧ និងបន្តបន្ទាប់, និងទំព័រ ៩៧ និងបន្តបន្ទាប់ ។

[១៤០] ការអនុវត្តត្រូវបានធ្វើឡើងជាញឹកញាប់មុនការដាក់អាណាព្យាបាល ដោយមានឈ្មោះថា "*ការជួលដើម្បីរំលូសបំណុល*" យោងតាមមាត្រា ១១៦៤ នៃព្រះរាជក្រឹត្យវៃណីកម្ពុជាឆ្នាំ ១៩២០ ។ វាគឺជាកិច្ចសន្យាមួយដែលក្នុងនោះ កូនបំណុលភ្ជាប់កិច្ចសន្យាបំពេញសេវាចំពោះម្ចាស់បំណុល ដើម្បីទូទាត់សងប្រាក់ និងការប្រាក់ដែលជាបំណុល ។ ការអនុវត្តនេះត្រូវបានបានប្រកាសថា ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈនៃការដាក់អាណានិគមបារាំងក្នុងរយៈពេលអាណាព្យាបាល ពីឆ្នាំ ១៨៦៣ ដល់ឆ្នាំ ១៩៥៤ ។ សូមមើល H. SOLUS, "Traité de la condition des indigenes en dt privé, colonie et pays de protectorat et pays sous mandate", Recueil Sirey 1927, p. 318. ទោះបីជាយ៉ាងនេះក៏ដោយ ប្រជាជនខ្មែរនៅតែបន្តអនុវត្តវិធីនៃការសងបំណុលខាងលើនេះដដែល ។

Scanned with CamScanner

ភាពពុំអាចលក់ ឬផ្ទេរបាននៃរូបកាយមនុស្សនេះ បង្កើតបានជាការកាត់បន្ថយសិទ្ធិចាត់ចែងដោយសេរី ឬមួយជារូបកាយខ្លួនឯង ឬមួយទៀត ជារូបកាយរបស់បុគ្គលផ្សេងទៀត ហើយជាញឹកញាប់ជាការហាមឃាត់ចំពោះការអនុវត្តសិទ្ធិនេះតែម្តង ។ ប៉ុន្តែ ការហាមឃាត់នេះពុំមានភាពដាច់ខាតនោះទេ ប្រសិនបើលក្ខខណ្ឌមួយចំនួនដែលកំណត់ដោយច្បាប់ត្រូវបានបំពេញ ។

B. គរុណីលើតំលៃចំពោះគោលការណ៍ខាងលើ : តាពចំនេះនៃសារភាពកាយខ្លួនរបស់មនុស្ស

រហូតមកទល់បច្ចុប្បន្ននេះ គ្មានអត្ថបទណាមួយដែលកំណត់ឱ្យបានច្បាស់អំពីបែបបទ និងលក្ខខណ្ឌនៃការដកហូតជាអំណោយ នៃការផ្សាំសាច់ នៃសរីរាង្គ ឬធាតុផ្សំផ្សេងទៀតនៃរូបកាយមនុស្សនោះទេ ។ បច្ចុប្បន្ននេះ មានតែប្រកាសមួយរបស់ក្រសួងសុខាភិបាលចុះថ្ងៃទី ២៣-០៣-១៩៩៤ ដែលទាក់ទងការគ្រប់គ្រង និងសន្តិសុខលើឈាមតែប៉ុណ្ណោះ ។ អត្ថបទនេះ អនុញ្ញាតឱ្យមានការធ្វើបដិបញ្ញត្តទៅគោលការណ៍នៃភាពពុំចំនេះនៃរូបកាយ ចំពោះអ្វីៗទាក់ទងនឹងការបរិច្ចាកឈាម ។ បដិបញ្ញត្តិនេះ ត្រូវបានចាត់ទុកថា មានសុពលភាព នៅពេលដែលមានការព្រមព្រៀងពីអ្នកបរិច្ចាកជាមុន ។ ការបរិច្ចាកឈាមត្រូវតែធ្វើឡើងដោយមិនគិតប្រាក់ ចំពោះអ្នកបរិច្ចាក និងអ្នកទទួលឈាម (ប្រការ ៤) ។ រាល់ការបំពាននឹងត្រូវបានផ្តន្ទាទោសដោយច្បាប់ (ប្រការ ៨) ។ ប៉ុន្តែ ភាពខ្វះចន្លោះនៃច្បាប់ក្នុងសណ្តាប់ធ្នាប់គតិយុត្តរបស់ខ្មែរ ត្រូវបានចាត់ទុកជាមូលហេតុនៃការរំលោភបំពាន ដោយអ្នកបរិច្ចាកវិជ្ជាជីវៈខ្លះទៀតដែលធ្វើពាណិជ្ជកម្មឈាមរបស់ខ្លួន ។ គោលការណ៍ពុំបង់ប្រាក់ចំពោះរាល់ការចាត់ចែងផលិតផលនៃរូបកាយមនុស្ស មិនត្រូវបានគោរពយ៉ាងពិតប្រាកដនោះទេ ។ វាជាការប្រសើរ ក្នុងការរំពឹងទុកថា អង្គនីតិបញ្ញត្តិ នឹងទទួលបន្ទុកក្នុងការបង្កើតនូវិធានឱ្យកាន់តែប្រសើរ និងមានលក្ខណៈគ្រប់គ្រាន់ ដើម្បីធានានូវប្រសិទ្ធិភាពជារួម នូវការការពាររូបកាយមនុស្ស ។

តថាខណ្ឌទី ២ : នីតិព្រហ្មទណ្ឌ

ក. ប្រធានបទ

"ធាតុផ្សំអត្តនោម័តនៃបទល្មើសព្រហ្មទណ្ឌ"

ខ. តំណែ : (ការីន តូចុំ១)

ការដាក់ឱ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌទៅលើបុគ្គលណាម្នាក់ តម្រូវមិនត្រឹមតែឱ្យមានភស្តុតាងនៃធាតុផ្សំសត្យានុម័តនៃបទល្មើសប៉ុណ្ណោះទេ មានន័យថា ការប្រព្រឹត្តដែលផ្តន្ទាទោសដោយអ្នកតាក់តែងច្បាប់ ប៉ុន្តែ វាក៏តម្រូវឱ្យមានភស្តុតាងនៃធាតុផ្សំអត្តនោម័តផងដែរ ។ នៅពេលស្វែងរកធាតុផ្សំអត្តនោម័តនេះ ចៅក្រមត្រូវតែផ្សាភ្ជាប់ខ្លួនឯងទៅនឹងស្ថានភាពគំនិតរបស់ជនជាប់ចោទនៅក្នុងពេលដែលប្រព្រឹត្តអំពើល្មើស ។ តាមការពិត អ្នកតាក់តែងច្បាប់ផ្តន្ទាទោសអំពើប្រព្រឹត្តមួយ ប៉ុន្តែ គាត់ក៏ត្រូវផ្តន្ទាទោស ជាពិសេសទៅលើអកប្បកិរិយាខ្លះ យោងទៅលើសណ្តាប់ធ្នាប់របស់សង្គមជាកំណត់ផងដែរ ។ ដូច្នេះ តាមរយៈការអានអត្ថបទច្បាប់ព្រហ្មទណ្ឌផ្សេងៗ ជាពិសេសច្បាប់ព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី ១០-០៩-១៩៩២ និងច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋដែលប្រកាសឱ្យប្រើនៅថ្ងៃទី ០៧-០១-

Scanned with CamScanner

២០០២ យើងអាចលើកឡើងនូវអត្ថិភាពតាម លំដាប់នៃធាតុផ្សំអត្តនោម័តដែលគ្រាន់តែជាភាពខុសគ្នាយ៉ាងសាមញ្ញ មួយចំពោះតម្លៃនៃសង្គមដែលទទួលបាននូវការការពារ និងចំពោះការដំទាស់ដ៏ត្រឹមត្រូវនៅក្នុងតម្លៃសង្គមនេះ ។ ជាញឹកញាប់ ប្រសិនបើប្រតិកម្មចំពោះតម្លៃសង្គមនេះ ត្រូវបានសន្និដ្ឋានដោយចៅក្រម អំពីធាតុផ្សំនៃអំពីអំពើប្រព្រឹត្តរបស់ជនជាប់ចោទ គាត់ត្រូវតែកំណត់វាឱ្យបានច្បាស់លាស់ ។ ធាតុផ្សំអត្តនោម័តនេះ បែងចែកហុសព្រហ្មទណ្ឌជាពីរផ្នែកធំៗ ។ យើងគួរតែបែងចែកកំហុសដោយចេតនាដែលជាការដំទាស់ពិតប្រាកដមួយ ទៅនឹងតម្លៃរបស់សង្គមដែលត្រូវបានការពារ និងកំហុសដោយអចេតនាដែលមានភាពប្រហាក់ប្រហែលទៅនឹងការធ្វេស ប្រហែសដ៏សាមញ្ញមួយចំពោះតម្លៃនៃសង្គមខាងលើដូចគ្នា ។ លើសពីនេះទៀត នៅក្នុងប្រភេទកំហុសទីមួយ មានការបែងចែកជាកំហុសជាច្រើនទៀតដែលអ្នកតាក់តែងច្បាប់ចង់ធ្វើយ៉ាងណាឱ្យមានការបង្ក្រាបទៅលើប្រតិកម្មរបស់បុគ្គលម្នាក់ ចំពោះសណ្តាប់ធ្នាប់ដែលត្រូវបានបង្កើតឡើង ឧទាហរណ៍ ដូចជាការបែងចែកគំនិតមុច្ឆរិតទូទៅ ពីគំនិតមុច្ឆរិតពិសេសដែលបង្ហាញពីភាពរឹតនៃការប្រឆាំងទៅនឹងតម្លៃរបស់សង្គមដែលត្រូវបានការពារ ។ ហេតុដូច្នេះ បើសិនជាយើងនិយាយអំពីសញ្ញាណនៃកំហុសដោយអចេតនា វាហាក់ដូចជានាពេលបច្ចុប្បន្ននេះ អ្នកតាក់តែងច្បាប់កម្ពុជាពុំបានធ្វើការបែងចែកភាពរឹតនៃកំហុសប្រភេទទី ២ នេះទេ ។ ដូច្នេះ គេអាចនិយាយបានថា កំហុសនៅក្នុងប្រភេទនេះ មានតែមួយប៉ុណ្ណោះ ទោះបីជាអ្នកតាក់តែងច្បាប់សំដៅទៅលើអំពើប្រព្រឹត្តផ្សេងៗគ្នាក៏ដោយ ។

ប៉ុន្តែ ការកំណត់បង្ហាញអំពីកំហុសព្រហ្មទណ្ឌផ្សេងៗ ចោទជាសំណួរ ទៅលើលក្ខណៈវិនិច្ឆ័យដែលអនុញ្ញាតឱ្យបែងចែកពីកំហុសមួយទៅកំហុសមួយទៀត ។ ជាការពិត ការអនុវត្តអត្ថបទច្បាប់ដ៏ល្អតម្រូវថា លើសពីការលើកឡើងនូវភាពខុសគ្នារវាងកំហុសអចេតនាធម្មតា និងចេតនាមុច្ឆរិតទូទៅ ដើម្បីអាចផ្តន្ទាទោសទៅលើជនម្នាក់ ចៅក្រមអាចកំណត់បានថា តើកំហុសមានធាតុផ្សំអ្វីខ្លះយ៉ាងពិតប្រាកដ ? ប៉ុន្តែ ការសិក្សានូវកំហុសទាំងនេះ នាំឱ្យយើងអាចកំណត់បានថា ការបែងចែកភាពខុសគ្នាយ៉ាងពិតប្រាកដរវាងកំហុសដោយចេតនា និងអចេតនា គឺអំពើប្រព្រឹត្តដោយគ្មានឆន្ទៈ និយាយឱ្យច្បាស់ជាងនេះទៀត គឺឆន្ទៈ ឬយ៉ាងហោចណាស់ ជាមនសិការក្នុងការបង្កការខូចខាតទៅដល់ជនរងគ្រោះ ។ ការកំណត់ដូច្នេះ គឺនាំឱ្យមានការរំលឹកនូវឫសគល់នៃពាក្យចេតនា ។ តាមពិត ពាក្យចេតនាសំដៅការប្រាថ្នាអ្វីមួយក្នុងករណីនេះ គឺការប្រាថ្នាទទួលបាននូវលទ្ធផលមួយ ។

ហេតុដូច្នេះ បន្ទាប់ពីបានប៉ុនប៉ងឱ្យបានច្បាស់លាស់អំពីភាពខុសគ្នានៃកំហុសដោយចេតនា យើងនឹងធ្វើការកំណត់និយមន័យជាបន្តទៀតអំពីកំហុសដោយអចេតនា ព្រមទាំងការវិវត្តន៍របស់វា ។

I. ការកំណត់និយមន័យកំហុសដោយចេតនា

ក្នុងករណីកំហុសដោយចេតនា ច្បាប់របស់ប្រទេសកម្ពុជាសំដៅទៅលើស្ថានភាពនៃគំនិតផ្សេងៗ ដែលគំនិតទាំងអស់នេះកំណត់ចរិតលក្ខណៈប្រឆាំងតិច ឬច្រើនចំពោះបទបញ្ជាជាកំណត់ ហើយដែលត្រូវបានផ្តន្ទាទោសធូស្រាល ឬតឹងរឹងអាស្រ័យទៅតាមកម្រិតនៃការប្រឆាំងដែលកើតឡើង ។ បើសិនជាអំពើប្រព្រឹត្តមានភាពរឹតនៃការប្រឆាំងតិច អំពើនេះត្រូវបានកំណត់ចរិតលក្ខណៈជាចេតនាមុច្ឆរិតទូទៅ (A) ។ មានចេតនាមុច្ឆរិតផ្សេងទៀត ដែលមានភាពរឹតនៃការប្រឆាំងច្រើនចំពោះតម្លៃនៃសង្គមដែលត្រូវបានការពារ (B) ។

Scanned with CamScanner

A. **តារាងប្រសាំងស្រាល : ចេតនាទុច្ចរិតទូទៅ**

ភាពអប្បរមាដែលទាមទារដោយអ្នកតាក់តែងច្បាប់ដើម្បីអាចផ្តន្ទាទោសបុគ្គលណាមួយ ពីបទល្មើសដោយចេតនា គឺវត្តមាននៃគំនិតទុច្ចរិតទូទៅ ។ គំនិតទុច្ចរិតនេះអាចឱ្យនិយមន័យបានថា ជាឆន្ទៈធ្វើអ្វីមួយដែលច្បាប់ហាមឃាត់ ដោយមានមនសិការដឹងអំពីការហាមឃាត់នេះ និងអំពីការបង្កការខូចខាតជាយថាហេតុ ដល់ជនរងគ្រោះនៃបទល្មើស ។ ជារឿយៗ អ្នកតាក់តែងច្បាប់កំណត់គំនិតទុច្ចរិតទូទៅនេះ តាមរយៈវាក្យសព្ទមួយចំនួនដូចជា "*ដោយចេតនា*" រឺ "*ដោយដឹងខ្លួន*" ជាអាទិ៍ ។ ដូចគ្នានេះដែរ មាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ប្រើប្រាស់ពាក្យ "*ដោយចេតនា*" ចំពោះអំពើបង្ករបួសស្នាមដោយចេតនា និងមាត្រា ៥៧ ប្រើប្រាស់ពាក្យ "*ដោយមិនប្រុងប្រយ័ត្ន*" ចំពោះអំពើរំលោភលើសិទ្ធិបុគ្គល ។ ដូចគ្នាដែរ ដោយយោងទៅតាមមាត្រា ៥១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល អំពើទទួលផលចោរកម្ម តម្រូវឱ្យអ្នកប្រព្រឹត្តដឹងថា ទ្រព្យសម្បត្តិបានមកអំពីល្មើសដែលប្រការនេះញាក់អំពីឆន្ទៈប្រព្រឹត្តដោយដឹងពីចំណងហេតុផលច្បាស់លាស់ ។ ក្នុងសម្មតិកម្មទាំងនេះ ចារីដឹងថា អំពើរបស់គាត់ គឺជាអំពើដែលគួរឱ្យបន្ទោស ហើយនឹងបង្កឱ្យមានការខូចខាតដល់តតិយជន តួរយ៉ាងដូចជាការប៉ះពាល់ដល់បូរណៈភាពខាងរូបរាងកាយ ប៉ុន្តែ ទោះបីជាយ៉ាងណាក្តី គាត់នៅតែសម្រេចចិត្តប្រព្រឹត្តអំពើទាំងនេះ ។

B. **តារាងប្រសាំងជានមូនំ : ចេតនាទុច្ចរិតផ្សេងទៀត**

ក៏ប៉ុន្តែ បើសិនចៅក្រមផ្សារភ្ជាប់ខ្លួនឯងទៅនឹងស្ថានភាពគំនិតរបស់ជនប្រព្រឹត្តបទល្មើស យើងមិនត្រូវច្រឡំរវាងចេតនា និងមូលហេតុនោះទេ ។ មូលហេតុ គឺជាហេតុ, មនោសញ្ចេតនាដែលនាំឱ្យមានការប្រព្រឹត្តអំពើ ដូចជាការសងសឹក, ការច្រណែន ឬភាពលោភលន់ ។ មូលហេតុប្រែប្រួល ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ប៉ុន្តែ ជានិច្চកាលចេតនានៅតែមានភាពដូចគ្នា មិនចំពោះបុគ្គលណាម្នាក់នោះទេ នៅពេលដែលបុគ្គលនោះប្រព្រឹត្តបទល្មើសមួយចំនួន ។ ជាគោលការណ៍ មូលហេតុពុំត្រូវបានរាប់បញ្ចូលដោយអ្នកតាក់តែងច្បាប់ទេ ។ ប៉ុន្តែ ពេលខ្លះអ្នកតាក់តែងច្បាប់ ទាមទារឱ្យអ្នកប្រព្រឹត្តមានមូលហេតុមួយចំនួនដើម្បីអាចកំណត់បានជាបទល្មើស ។ អ្នកតាក់តែងច្បាប់អាចកំណត់បានយ៉ាងជាក់-លាក់ ដូចជាក្នុងករណី ការតែបំបាត់ធ្វើឡើងដោយអ្នករាជការ (មាត្រា ៣៧ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលប្រើពាក្យ "*ដើម្បីនីតិ*") ឬជាលក្ខណៈស្ងប់ស្ងៀម ដូចជាក្នុងករណីសក្ខីភាពក្លែងក្លាយ (មាត្រា ៥៦ ច្បាប់ព្រហ្មទណ្ឌអន្តរកាល) ឬការគ្បៀបសង្កត់លើសាក្សី (មាត្រា ៥៥ នៃច្បាប់ដដែល) ។ តាមពិត ក្នុងសម្មតិកម្មទាំងពីរនេះ ចារីមិនត្រឹមតែមានឆន្ទៈប្រព្រឹត្តអំពើល្មើស និងមានឆន្ទៈជំរុញឱ្យអ្នកដទៃផ្តល់សក្ខីភាពក្លែងក្លាយ ឬផ្តល់សក្ខីភាពក្លែងក្លាយដោយខ្លួនឯងប៉ុណ្ណោះទេ ប៉ុន្តែ គាត់ថែមទាំងមានគោលដៅបំភាន់តុលាការថែមទៀតផង ។ ក្នុងសម្មតិកម្មបែបនេះ លើសពីគំនិតទុច្ចរិតទូទៅ វាត្រូវបានចាត់ទុកថាជា គំនិតទុច្ចរិតពិសេស ។

តាមពិត គំនិតទុច្ចរិតពិសេសតម្រូវឱ្យមានឆន្ទៈទទួលយកលទ្ធផលច្បាស់លាស់មួយដែលត្រូវបានកំណត់ដោយអ្នកតាក់តែងច្បាប់ ។ តួយ៉ាង ផ្អែកទៅលើមាត្រា ៣២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល អំពើមនុស្សឃាដដោយចេតនាតម្រូវឱ្យមានឆន្ទៈសម្លាប់ ។ ដូចគ្នាដែរ នាពេលបច្ចុប្បន្ននេះ អំពើលួចត្រូវបានកំណត់និយមន័យក្នុងមាត្រា ៣៨ វាក្យ-ខណ្ឌទី ២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងមាត្រា ៦ នៃច្បាប់ចុះថ្ងៃទី ៧-០៧-២០០២ ជាការបន្លំយកទ្រព្យសម្បត្តិអ្នកដទៃ "*ក្នុងបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន*" ។ អ្នកប្រព្រឹត្តមានបំណងជាក់លាក់មួយ ដែលកំណត់ដោយអ្នក

Scanned with CamScanner

តាក់តែងច្បាប់ដែលគាត់ចង់ឈានទៅដល់ការសម្រេចបំណងនេះតាមរយៈការប្រព្រឹត្តរបស់គាត់ ។ នេះគឺជាការប្រឆាំងពិតប្រាកដមួយទៅនឹងតម្លៃនៃសង្គម ។ ប៉ុន្តែ យើងគួរលើកឡើងថា ការទាមទារឱ្យមានគំនិតទុច្ចរិតពិសេស ក្នុងករណីលួចនេះ ហាក់បីដូចជាត្រូវបានគេធ្វើឱ្យលេចបាត់ ។ ជាបន្ទាប់ អត្ថបទដែលកំពុងតែព្រាង មិនតម្រូវឱ្យមានលើសពីគំនិតទុច្ចរិតទូទៅ តាមការវិការខាងក្រៅដោយលប់ចោលនូវបំណងយកទ្រព្យអ្នកដទៃមកធ្វើជាកម្មសិទ្ធរបស់ខ្លួន នោះទេ ។

ក្រៅពីចេតនាទុច្ចរិតពិសេស អ្នកតាក់តែងច្បាប់ ក៏ផ្តន្ទាទោសផងដែរនូវចេតនាទុច្ចរិតដែលមានស្ថានទំងន់ ឬការគិតទុកជាមុន ។ ចេតនាទុច្ចរិតដែលមានស្ថានទំងន់ ឬការគិតទុកជាមុននេះត្រូវបានផ្តន្ទាទោសធ្ងន់ជាងចេតនាទុច្ចរិតពិសេស ដោយសារការប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅដល់តម្លៃនៃសង្គម ។ ជាការពិត គំនិតទុច្ចរិតទាំងពីរនេះ តម្រូវឱ្យចេតនាដែលនាំឱ្យមានការសម្រេចនូវធាតុផ្សំសម្ភារៈ ស្ថិតនៅក្នុងរយៈពេលវែង ។ ជាអាទិ មាត្រា ៣១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងមាត្រា ៣ នៃច្បាប់ចុះថ្ងៃទី ០៧-០១-២០០២ អំពើមនុស្សឃាដគិតទុកជាមុន ត្រូវបានផ្តន្ទាទោសធ្ងន់ជាងអំពើមនុស្សឃាដសាមញ្ញ ។

ប៉ុន្តែ មានករណីខ្លះ លទ្ធផលពិតប្រាកដដែលសម្រេចបាន អាចមានភាពខុសគ្នាពីលទ្ធផលដែលអ្នកប្រព្រឹត្តចង់បាន ឬយ៉ាងហោចណាស់ខុសពីលទ្ធផលដែលគាត់រំពឹងទុក ដែលយើងឱ្យឈ្មោះថា ជាគំនិតទុច្ចរិតហួសដែនកំណត់ ។ ដូច្នេះ សំណួរសួរថា តើចារីប្រព្រឹត្តត្រូវផ្តន្ទាទោសដោយផ្អែកទៅលើលទ្ធផលដែលគាត់គិតថានឹងទទួលបាន ឬលទ្ធផលដែលបានកើតមានយ៉ាងពិតប្រាកដ ? អ្នកតាក់តែងច្បាប់ មានទំនោរដាក់ទម្ងន់បន្ថែមទៅលើចារីប្រព្រឹត្តបទល្មើស បើប្រៀបធៀបទៅនឹងចារីប្រព្រឹត្តដែលទទួលបានត្រឹមតែលទ្ធផលដែលគាត់រំពឹងទុក ដោយយោងតាមលទ្ធផលដែលត្រូវបានសម្រេចយ៉ាងពិតប្រាកដ ប៉ុន្តែ ចំពោះតែករណីខ្លះដែលកំណត់ជាក់លាក់ប៉ុណ្ណោះ ។ ហេតុដូច្នេះ ក្នុងករណីបង្ករបួសស្នាមដោយចេតនា បុគ្គលទាំងឡាយណាដែលការប្រព្រឹត្តរបស់ខ្លួនបណ្តាលឱ្យជនរងគ្រោះស្លាប់ តែចារីពុំមានចេតនាសម្លាប់ជនរងគ្រោះនោះទេ នឹងត្រូវបានផ្តន្ទាទោសធ្ងន់ជាងការវាយដែលបណ្តាលឱ្យមានការប៉ះទង្គិចធម្មតាដល់បួរណ-ភាពរូបកាយ ។ ដូចគ្នាដែរ អ្នកតាក់តែងច្បាប់ ហាក់ដូចជាមានបំណងចង់រាប់បញ្ចូលគំនិតទុច្ចរិតហួសដែនកំណត់ទៅក្នុងករណីរំលោភសេពសន្ថវៈ ហើយដូចគ្នាផងដែរចំពោះការចាប់ជម្រិត និងការបង្ខាំងមនុស្ស នៅពេលដែលអំពើទាំងនេះបណ្តាលឱ្យជនរងគ្រោះស្លាប់ ដោយចារីប្រព្រឹត្តពុំមានចេតនាសំលាប់នោះទេ ។ យើងសំគាល់ឃើញថា មានការកើនចំនួនសម្មតិកម្មដែលអ្នកតាក់តែងច្បាប់រាប់បញ្ចូលគំនិតទុច្ចរិតហួសដែនកំណត់ដែលដាក់ទម្ងន់បន្ថែម ចំពោះការផ្តន្ទាទោសចារីប្រព្រឹត្ត ដោយផ្អែកទៅលើលទ្ធផលពិតប្រាកដ ទោះបីជាអ្នកប្រព្រឹត្តមិនចង់បានលទ្ធផលនេះក៏ដោយ ។ ដូច្នេះ ចារីប្រព្រឹត្តអំពើនេះត្រូវផ្តន្ទាទោសធ្ងន់ជាងករណីបើសិនគាត់ចង់ទទួលបានត្រឹមតែលទ្ធផលដែលគាត់រំពឹងទុក ប៉ុន្តែស្រាលជាង ក្នុងករណីបើសិនគាត់ស្វែងរកលទ្ធផលដែលបានទទួលដូច្នេះ ។ ក្នុងអង្គហេតុនេះ ការស្លាប់របស់ជនរងគ្រោះ គឺកើតចេញពីអំពើរបស់គាត់ ។

សម្មតិកម្មចុងក្រោយនៃបទល្មើសដោយចេតនា ដែលទាក់ទងយ៉ាងជិតស្និតជាមួយនឹងគំនិតទុច្ចរិតហួសដែនកំណត់នឹងត្រូវតែលើកយកមកពិនិត្យ គឺករណីគំនិតទុច្ចរិតមិនកំណត់ ។ ក្នុងករណីនេះ ចារីស្វែងរកការខូចខាតដែលត្រូវបានកំណត់ដោយច្បាប់ តែចារីនោះមិនបានគិតថា តើការខូចខាតនោះគឺជាអ្វីនោះទេ ។ ឧទាហរណ៍ ក្នុងករណីនេះ គឺការ

Scanned with CamScanner

បង្ករបួសស្នាមដោយចេតនា ។ តាមពិត ចារីនៃបទល្មើសនេះ ដឹងយ៉ាងច្បាស់ថា ការវាយតប់ នឹងធ្វើឱ្យមានការប៉ះពាល់ទៅលើបូរណភាពរូបកាយរបស់មនុស្ស ហើយទង្វើនេះនឹងត្រូវបានផ្តន្ទាទោសដោយច្បាប់ "*ចេតនាទុច្ចរិតទូទៅ*" ។ ប៉ុន្តែចារីមិនខ្វល់ថា តើការវាយតប់នោះបណ្តាលឱ្យមានពិការភាពក្នុងរយៈពេលតិច ឬច្រើនជាង ៦ ខែ នោះទេ ។ បើសិនជាកម្រិតពិការភាពលើសពី ៦ ខែ អំពើនេះត្រូវបានកំណត់ក្នុងមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ដោយមានការផ្តន្ទាទោសពី ១ ឆ្នាំ ទៅ ៥ ឆ្នាំ ។ តែ បើសិនជាតិចជាង ៦ ខែ ការផ្តន្ទាទោសត្រូវបានធ្វើឡើងពី ៦ ខែ ទៅ ២ ឆ្នាំ ។ គំនិតដែលគ្រប់គ្រងលើការបង្ក្រាបក្នុងសម្មតិកម្មនេះគឺថា ចារីប្រព្រឹត្តនូវអំពើនេះ គួរដឹងជាមុនអំពីលទ្ធផលនៃអំពើរបស់ខ្លួន ហើយត្រូវបានផ្តន្ទាទោស ដូចដែលចារីចង់បាននូវលទ្ធផលដែលបានសម្រេច ។ ករណីនេះផ្ទុយនឹងគំនិតទុច្ចរិតហួសដែនកំណត់ ដែលចារីនៃអំពើប្រព្រឹត្ត ឧទាហរណ៍ ការវាយតប់បណ្តាលឱ្យស្លាប់ តែដោយគ្មានចេតនាសម្លាប់នោះទេ ត្រូវបានផ្តន្ទាទោសស្រាលជាង ករណីបើសិនជាចារីមានចេតនាសម្លាប់ជនរងគ្រោះ ។ ប៉ុន្តែ គំនិតទុច្ចរិតហួសដែនកំណត់អនុញ្ញាតឱ្យនីតិករសម្របការបង្ក្រាបតាមរយៈការចោទប្រកាន់នូវស្ថានភាពកណ្តាលមួយ រវាងការវាយតប់ដែលបង្កត្រឹមតែការប៉ះពាល់ដល់បូរណភាពរូបកាយរបស់មនុស្ស និងមនុស្សឃាដដោយចេតនា ។ គំនិតទុច្ចរិតមិនកំណត់អនុញ្ញាតឱ្យផ្តន្ទាទោសយ៉ាងតឹងរឹងចំពោះចារីនៃអំពើប្រព្រឹត្តដែលបង្ហាញអំពីភាពមិនយកចិត្តទុកដាក់ ដោយមិនចង់បាននូវលទ្ធ-ផលដែលចេញពីទង្វើរបស់ខ្លួននោះទេ ។ ហេតុដូច្នេះហើយ អ្នកតាក់តែងច្បាប់ចែងនូវភាពសមាមាត្រទៅនឹងភាពធ្ងន់ធ្ងរនៃការខូចខាតដែលទទួលរងដោយជនរងគ្រោះ ដូចដែលបានលើកឡើងនៅក្នុងឧទាហរណ៍ អំពីបទល្មើសបង្ករបួសស្នាមដោយចេតនានៃមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

ប៉ុន្តែ ក្នុងគ្រប់សម្មតិកម្មទាំងនេះ ប្រសិនបើចារីដឹងថា ទង្វើរបស់ខ្លួននឹងបណ្តាលឱ្យមានការខូចខាតជាក់លាក់ដែលគាត់ចង់ ឬពុំចង់ស្វែងរក និងដែលគាត់ទទួល ឬពុំទទួលបាននូវលទ្ធផល ដែលគាត់រំពឹងទុកនោះ មានពេលខ្លះ អ្នកតាក់តែងច្បាប់ដាក់ទណ្ឌកម្មចំពោះស្ថានភាពដែលចារីនៃអំពើប្រព្រឹត្តគ្មានមនសិការណាមួយ ដើម្បីឱ្យដឹងថា តើអំពើរបស់គាត់អាចឈានទៅដល់ការបង្កការខូចខាតណាមួយយ៉ាងពិតប្រាកដដូចម្តេច ? ហើយដែលអំពើនេះត្រូវបានចាត់ទុកជាកំហុសដោយអចេតនា ។

II. ការកំណត់និយមន័យកំហុសដោយអចេតនា

នាពេលបច្ចុប្បន្ននេះ បើសិនសម្មតិកម្មនៃកំហុសដោយអចេតនារៀបរាប់ដោយអ្នកតាក់តែងច្បាប់ ផ្តន្ទាទោសគ្រប់រាល់ការប្រឆាំងទៅនឹងតម្លៃនៃសង្គម (A) យើងក៏អាចផ្តន្ទាទោសចំពោះកំហុសដោយអចេតនាផ្សេងទៀត ដែលក្នុងនោះយើងអាចកម្រិតបាននូវលំដាប់ថ្នាក់នៃកំហុសដោយអចេតនា (B) ។

A. នីតិវិជ្ជមាន : ការឯកភាពនៃកំហុសដោយអចេតនា

នាពេលបច្ចុប្បន្ន អ្នកតាក់តែងច្បាប់កម្ពុជា ដាក់ទណ្ឌកម្មរាល់អំពើប្រព្រឹត្តទាំងឡាយដែលក្នុងនោះចារីនៃអំពើប្រព្រឹត្ត ពុំចង់ឱ្យមានព្យសនកម្មនោះទេ តែជាគោលការណ៍ ចង់បំពេញអំពើជាសម្ភារៈដែលជាករណីការខ្វះការប្រុងប្រយ័ត្ន ការខ្ជីខ្ជារ ការធ្វេសប្រហែស និងការពុំបានអង្កេតមើលលើបទបញ្ជា ដោយយោងតាមមាត្រា ៤០ នៃច្បាប់ព្រហ្ម-

Scanned with CamScanner

ទណ្ឌអន្តរកាល ។ អ្នកតាក់តែងច្បាប់ផ្តន្ទាទោសរាល់អំពើដែលកើតចេញមកពីការខ្ជីខ្ជារ ឬការខ្វះការប្រុងប្រយ័ត្ន ឬការធ្វេសប្រហែស ។ ការពុំបានអង្កេតមើលលើបទបញ្ជា គឺជាសកម្មភាពរបស់មនុស្សម្នាក់ ឬអំពើអកម្ម ដែលបង្កើតជាការមិនគោរពនូវបទដ្ឋានណាមួយ ដែលបានដាក់ទណ្ឌកម្មលើអំពើនោះ ។ នៅគ្រប់ករណីទាំងអស់ អ្នកតាក់តែងច្បាប់បន្ទោសទៅចារីនៃអំពើល្មើស ចំពោះការមិនគោរពតាមបទដ្ឋានណែនាំ ។ ក្នុងករណីនេះ អ្នកតាក់តែងច្បាប់ផ្តន្ទាទោសទៅលើអំពើមួយដែលសំដែងឡើងនូវការជំទាស់ប្រឆាំងទៅនឹងតម្លៃសង្គម ។ ប្រសិនបើ អ្នកតាក់តែងច្បាប់ លើកឡើងនូវអំពើជាច្រើន អំពើនេះនឹងត្រូវបានផ្តន្ទាទោសដូចគ្នា ។ ភាពផ្សេងគ្នានេះ មិនឆ្លើយតបទៅនឹងឆន្ទៈក្នុងការសម្របការបង្ក្រាបទៅនឹងស្ថានភាពរបស់មនុស្សទេ ប៉ុន្តែ ទៅនឹងឆន្ទៈ ដែលមានលក្ខណៈហួសប្រមាណ និងឆន្ទៈក្នុងការពុំអនុញ្ញាតឱ្យបុគ្គលម្នាក់ដែលបានសំដែងនូវអំពើប្រឆាំនឹងតម្លៃនៃសង្គម ត្រូវបានផ្តន្ទាទោសដោយយកលេសថា អំពើនោះពុំបានឆ្លើយតបនឹងស្ថានភាពដែលត្រូវបានកំណត់ដោយច្បាប់នោះទេ ។ អំពើទាំងនេះត្រូវបានចាត់ទុកជាកំហុសដោយអចេតនា ដោយហេតុថា ព្យសនកម្មត្រូវបានទទួលរងដោយអចេតនា ទោះបីជាអំពើប្រព្រឹត្តត្រូវបានធ្វើឡើងដោយចេតនាក៏ដោយ ។ តាមពិត យើងអាចកំណត់នូវសម្មតិកម្មដែលអំពើធ្វើឡើងដោយចេតនា ឧទាហរណ៍ ក្នុងករណីដែលទាក់ទងនឹងការមិនគោរពតាមបទបញ្ជា ប៉ុន្តែ យើងក៏អាចកំណត់នូវសម្មតិកម្មដែលបុគ្គលនោះមិនចង់បាន ហើយក៏គ្មានមនសិការថា អំពើប្រព្រឹត្តរបស់ខ្លួននឹងបណ្តាលឱ្យមានព្យសនកម្មយ៉ាងពិតប្រាកដចំពោះជនរងគ្រោះនោះទេ ។ សម្មតិកម្មចុងក្រោយនេះចោទជាបញ្ហាអំពីការពុំអាចព្រាងទុកបាន ឬអំពីគំនិតទុច្ចរិតជាយថាហេតុ ។

B. គារវិតត្តន៍ : គារវផ្សេងគ្នានៃកំហុសដោយអចេតនា

ចេតនាទុច្ចរិតជាយថាហេតុកើតឡើង កាលណាបុគ្គលម្នាក់និយាយថា គាត់នាំឱ្យមានគ្រោះថ្នាក់ជាយថាហេតុដែលអាចបណ្តាលឱ្យមានព្យសនកម្ម តែ អំពើប្រព្រឹត្តរបស់គាត់ធ្វើឡើងក្នុងគោលដៅដើម្បីបញ្ឈប់ព្យសនកម្មនោះ ។ ឧទាហរណ៍ ជាទម្លាប់មក ក្នុងករណីដែលអ្នកបើកបរម៉ូតូបើកវ៉ានៅផ្លូវម្ខាងទៀត ដោយមិនយកចិត្តទុកដាក់ថា តើនឹងមានឡានបើកមកនៅទិសបញ្ច្រាស ឬពុំមាននោះទេ ។ នៅពេលនេះ សម្មតិកម្មនេះត្រូវបានផ្តន្ទាទោស សម្រាប់កំហុសដោយអចេតនាសាមញ្ញ ។ តាមពិត អ្នកតាក់តែងច្បាប់កម្ពុជា ពុំបានចែងអំពីការផ្តន្ទាទោសជាពិសេសដែលអាចប្រៀបធៀបបានជាមួយនឹងកំហុសដោយចេតនានៅក្នុងនីតិបារាំងនោះទេ មានន័យថា "*ជាការរំលោភដែលត្រូវបានសំដែងដោយចេតនានូវកាតព្វកិច្ចពុំមានការធ្វេសប្រហែស ឬសន្តិសុខ ដែលត្រូវបានចាប់បង្ខំដោយច្បាប់ ឬបទបញ្ជា*" ។ អ្នកតាក់តែងច្បាប់បារាំង តាំងពីពេលចូលជាធរមាននៃក្រមព្រហ្មទណ្ឌថ្មីនៅឆ្នាំ ១៩៩៤ បានដាក់ទណ្ឌកម្មចំពោះអំពើប្រព្រឹត្តដូច្នេះ ។ ប្រសិនបើចារីនៃអំពើប្រព្រឹត្តនេះមិនបានបង្កឱ្យមានព្យសនកម្ម ចារីនឹងត្រូវបានចោទប្រកាន់អំពីករណីបង្កភ័យន្តរាយចំពោះអ្នកដទៃ ហើយក្នុងករណីបង្កព្យសនកម្ម គាត់នឹងត្រូវចោទប្រកាន់ពីករណីប៉ះពាល់ដោយអចេតនាលើបូរណភាពរូបកាយជាទម្ងន់ ។ ក្នុងករណីនេះ ទង្វើនេះត្រូវបានចាត់ទុកជាការពុំអាចព្រាងទុកជាមុនបានច្បាស់ដែលសញ្ញានេះស្ថិតនៅក្បែរគ្នានឹងសញ្ញាណនៃកំហុសដោយចេតនា ជាងកំហុសដោយអចេតនាសាមញ្ញ ។ ប៉ុន្តែ ការចាប់យកការប្រថុយប្រថាន និងទង្វើនេះ ត្រូវបានធ្វើឡើងដោយមានមនសិការដោយចេតនា ចារីពុំបានសំដែងនូវឆន្ទៈក្នុងការបង្កព្យសនកម្មដោយហេតុថា ផ្ទុយមកវិញ គាត់មានបំណងចង់ច្សៀសវាង ។ ហេតុដូច្នេះ យើងកំណត់ទង្វើនេះ ជាកំហុសដោយអចេតនា

Scanned with CamScanner

ចេតនាត្រូវបានកំណត់ដូចជាឆន្ទៈដើម្បីចង់បាននូវលទ្ធផលមួយ ។ ប្រសិនបើនាពេលនេះ អ្នកតាក់តែងច្បាប់កម្ពុជាពុំទាន់មានលទ្ធភាពគ្រប់គ្រាន់ក្នុងការបោះមួយជំហានទៀតនោះទេ និងក្នុងការដាក់ទណ្ឌកម្មចំពោះគំនិតទុច្ចរិតជាយថាហេតុនោះទេ ការកែប្រែត្រង់ចំណុចនេះ អាចអនុញ្ញាតឱ្យមានការសម្របសម្រួលដ៏ប្រសើរមួយទៅនឹងស្ថានភាពគំនិតរបស់ចារី ។ តាមពិត ការវិវត្តន៍បែបនេះ អនុញ្ញាតឱ្យមានការដាក់ទណ្ឌកម្មយ៉ាងតឹងរឹងចំពោះបុគ្គល ដែលបានលើកឡើងនូវភស្តុតាងអំពីការប្រឆាំងដោយមានមនសិការចំពោះតម្លៃនៃសង្គម ។ ទង្វើរបស់ចារីទាំងនេះ ត្រូវបានដាក់ទណ្ឌកម្មធ្ងន់ជាងចារីដែលបានប្រព្រឹត្តនូវកំហុសដោយធ្វេសប្រហែស ឬខ្ជិខ្ជារ ដោយហេតុថា ចារីក្នុងអំពើប្រព្រឹត្តទី ១ ធ្វើការភ្ជាល់យ៉ាងពិតប្រាកដ ដោយសង្ឃឹមថា ទង្វើរបស់គាត់នឹងពុំបណ្តាលឱ្យមានការខូចខាតទាល់តែសោះ ប៉ុន្តែ ចារីនៃអំពើបានដឹងយ៉ាងប្រាកដថា អំពើរបស់គាត់អាចបណ្តាលឱ្យមានគ្រោះថ្នាក់ដល់តតិយជន ដូចជាការប៉ះពាល់ទៅដល់បូរណភាពរូបកាយរបស់បុគ្គល ។

ទោះបីជាយ៉ាងណាក៏ដោយ សម្មតិកម្មនៃគំនិតទុច្ចរិតជាយថាហេតុអនុញ្ញាតឱ្យយើងដឹងអំពីគន្លឹដែលអាចបែងចែងភាពខុសគ្នាយ៉ាងច្បាស់ពីកំហុសដោយអចេតនា និងកំហុសដោយចេតនា ព្រោះវាពុំមានទាក់ទងត្រឹមតែឆន្ទៈនៃអំពើដែលអាចលើកយកអនុវត្តបានក្នុងករណីទី ១ នោះទេ គឺថែមទាំងឆន្ទៈ ឬយ៉ាងហោចណាស់ភាពប្រាកដប្រជា ក្នុងការបង្កព្យសនកម្មដោយអំពើប្រព្រឹត្តនោះ ។

គថាខណ្ឌទី ៣ : និតិពាណិជ្ជកម្ម

ក. ប្រធានបទ

"ការការពារគតិយុត្តនូវផលិតផល និងសេវា"

ខ. តំណែ : (អេម៉ានុយអែល ឃូរហ្គ័រ, ប្រែសម្រួល និងផ្តល់លក្ខណៈបច្ចុប្បន្នភាព ដោយលោក ស៊ឹម សុខអ្ង[141])

ការបើកទ្វារសេដ្ឋកិច្ចកម្ពុជាឆ្ពោះទៅរកសេដ្ឋកិច្ចទីផ្សារសេរី បាននាំមកជាមួយនូវការតម្រង់ទិសនៃការរៀបចំប្រពន្ធ័គតិយុត្តមួយផងដែរ ។ ព្រមជាមួយគ្នានោះដែរ ការអនុវត្តនយោបាយជម្រុញកំណើនសេដ្ឋកិច្ចជាតិ តាមរយៈការជម្រុញឱ្យមានការបង្កើតថ្មីដែលដើរតួនាទីជាសារវន្តនោះ បានបណ្តាលឱ្យមានវិបាកគតិយុត្តដ៏សំខាន់មួយពោលគឺ ការកាន់កាប់ក្រោមរូបភាពជាកម្មសិទ្ធិឯកជនលើការបង្កើតថ្មី និងការកែច្នៃដែលទទួលស្គាល់ដោយនីតិកម្មសិទ្ធិបញ្ញា ឬនីតិពាណិជ្ជកម្ម ។ ជាការពិតណាស់ ការការពារសិទ្ធិពាក់ព័ន្ធឱ្យមានការគាំទ្រ និងការលើកទឹកចិត្តដល់ការបង្កើតថ្មី និងការកែច្នៃក្រោមរូបភាពជាការផ្តល់ជូននូវលទ្ធភាពក្នុងការទូទាត់ចំណាយសម្រាប់វិនិយោគផ្សេងៗ ។ នេះក៏ជាការចូលរួមបង្កើតនូវធនធានក្នុងស្រុកផងដែរ ពិសេសតាមរយៈការលើកទឹកចិត្តដែលជានិច្ចកាលស្តែងឡើងតាមរយៈការការពារដ៏មានប្រសិទ្ធិភាព ក៏ដូចជាការផ្តល់ជូននូវសិទ្ធិផ្តាច់មុខដល់អ្នកកែច្នៃ និងតក្កវក្នុងការធ្វើពាណិជ្ជកម្មលើស្នាដៃរបស់ខ្លួន ។ ការណ៍នេះបានក្លាយជាកម្លាំងចលករដ៏សំខាន់ក្នុងការអភិវឌ្ឍ និងលើកទឹកចិត្តឱ្យមានវិនិយោគ ។ យុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិ

[141] និស្សិតថ្នាក់បណ្ឌិតនីតិពាណិជ្ជកម្មនៃសាកលវិទ្យាល័យហ្សង់មូឡាំង លីយ៉ុង ៣ និងជាគ្រូបង្រៀននីតិពាណិជ្ជកម្ម នីតិកម្មសិទ្ធិបញ្ញានៃសាកលវិទ្យាល័យបៀលព្រាយ កម្ពុជា ។

Scanned with CamScanner

សង្គមកិច្ច និងវិទ្យាសាស្ត្រ គួបផ្សំជាមួយនឹងការបើកចំហរសេដ្ឋកិច្ចរបស់កម្ពុជាស្របតាមបរិយាកាសសេដ្ឋកិច្ចរបស់អង្គការពាណិជ្ជកម្មពិភពលោក និងអាស៊ាន បានធ្វើឱ្យមានបំលាស់ប្តូរ ក៏ដូចជាការកកើតឡើងនូវវិធានជាតិជាច្រើនក្នុងវិស័យពាណិជ្ជកម្ម និងការការពារកម្មសិទ្ធិបញ្ញា[១៤២] ។

ការត្រៀមលក្ខណៈចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក បាននាំកម្ពុជាឱ្យខិតខំបង្កើតឡើងវិញនូវច្បាប់នានាក្នុងវិស័យកម្មសិទ្ធិបញ្ញាផង និងកែសម្រួលខ្លឹមសារនៃកំណែទម្រង់ផង ។ ដោយហេតុនេះហើយ ទើបបទដ្ឋានអន្តរជាតិមួយចំនួនដូចជា អនុសញ្ញាទីក្រុងប៉ារីសស្តីពីកម្មសិទ្ធិឧស្សាហកម្ម និងអនុសញ្ញាទីក្រុងប៊ែនស្តីពីកម្មសិទ្ធិបញ្ញាត្រូវបានដាក់បញ្ចូលទៅក្នុងកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មអន្តរជាតិ លើទិដ្ឋភាពពាក់ព័ន្ធនឹងវិស័យកម្មសិទ្ធិបញ្ញា[១៤៣] ដែលត្រូវបានតាក់តែងឡើងក្នុងក្របខណ្ឌអង្គការពាណិជ្ជកម្មពិភពលោក ហើយត្រូវបានប្រែសម្រួលរួចជាស្រេចជាភាសាខ្មែរ[១៤៤] ។

សិទ្ធិជាសារវន្តក្នុងចំណោមកម្មសិទ្ធិឧស្សាហកម្ម ជាអាទិ៍ សិទ្ធិកម្មសិទ្ធិលើម៉ាកពាណិជ្ជនាម ការរំលោភលើសិទ្ធិផ្តាច់មុខ តក្កកម្ម គំនូរ នីងម៉ូដែល ត្រូវបានការពារដោយច្បាប់ស្តីពី ម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ដែលប្រកាសឱ្យប្រើដោយព្រះប្រមុខរដ្ឋនៅថ្ងៃ ០៧-០២-២០០២[១៤៥] ឬដោយច្បាប់ស្តីពីប្រកាសនីយបត្រ-តក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម[១៤៦] ។ វិធានគតិយុត្តសម្រាប់ការពារស្នាដៃនិពន្ធ និងអ្នកសម្តែង ព្រមទាំងសិទ្ធិប្រហាក់ប្រហែលដទៃទៀត ត្រូវបានអនុម័ត និងប្រកាសឱ្យប្រើនៅថ្ងៃទី ០៥-០៣-២០០៣[១៤៧] ។

ដូចនេះ របៀបសម្គាល់ផលិតផល និងសេវាដែលបាននាំមកជាមួយនូវតម្លៃបន្ថែម និងភាពផ្តាច់មុខ បានចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ។

ហេតុផលខាងសេដ្ឋកិច្ច ព្រមទាំងសារសំខាន់ក្នុងការស្ថាបនាប្រពន្ធ័គតិយុត្តមួយដែលមានលក្ខណៈស៊ីសង្វាក់គ្នា បានទាមទារឱ្យមានការកំណត់នូវវិធានគតិយុត្តផ្សេងៗ ដើម្បីការពារផលិតផល និងសេវា ។ ការការពារលើលក្ខណៈសម្គាល់នានាទាំងនោះ ធ្វើឡើងតាមរយៈឧបករណ៍គតិយុត្តមួយចំនួនដែលខ្លះមានលក្ខណៈជាឯកជន និងខ្លះទៀតសមូហភាព ។ ដូចនេះ យើងនឹងធ្វើការសិក្សាលើរបៀបការពារទាំងឡាយដែលមានចែងក្នុងច្បាប់កម្មសិទ្ធិបញ្ញា ឬក្រៅក្របខណ្ឌនៃកម្មសិទ្ធិបញ្ញា បើទោះជា ដើម្បីបម្រើបម្រាស់ជាលក្ខណៈឯកជនក្តី ឬសមូហភាពក្តី ។

---

[១៤២] ឯកឧត្តម សុខ ស៊ីផាណា : យុទ្ធសាស្ត្រកំណែទម្រង់ប្រពន្ធ័គតិយុត្ត និងតុលាការនៅកម្ពុជា បោះពុម្ពដោយ CLRDC ២០០២

[143] ADPIC (Accord sur les Droits de Propriété Intellectuelle relatifs au Commerce) ; Or in english TRIPS (Trade Related Aspect on Intellectual Properties). គួរកត់សម្គាល់ថា តាមពិត កម្ពុជាទទួលស្គាល់សិទ្ធិសញ្ញាទាំងនេះ ព្រមជាមួយនឹងច្បាប់ព្រហ្មទណ្ឌអន្តរកាលមកម្ល៉េះ ពុំមែនទើបតែមានក្រោយពេលយើងចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកនោះទេ (សូមអានច្បាប់ព្រហ្មទណ្ឌអន្តរកាល) ។

[១៤៤] ការអភិវឌ្ឍន៍ និងសមិទ្ធិកម្មប្រពន្ធ័កម្មសិទ្ធិបញ្ញាក្នុងព្រះរាជាណាចក្រកម្ពុជា។

[១៤៥] ព្រះរាជក្រមលេខ នស. រកម. ០២០២ .០០៦ ថ្ងៃ ៧ ខែ កុម្ភៈ ២០០២ ។

[១៤៦] ព្រះរាជក្រមលេខ នស. រកម. ០១០៣ .០០៥ ថ្ងៃ ២២ ខែ មករា ២០០៣ ។

[១៤៧] ព្រះរាជក្រមលេខ នស. រកម. ០៣០៣ .០០៨ ថ្ងៃ ២២ ខែ មករា ២០០៣ ។

Scanned with CamScanner

I. រូបភាពនានានៃការយកថ្វីជាកម្មសិទ្ធិឯកជនក្នុងវិស័យកម្មសិទ្ធិបញ្ញា

ដើម្បីនឹងសិក្សាអំពីឧបករណ៍គតិយុត្តទាំងឡាយដែលមានស្រាប់ឱ្យមានលក្ខណៈច្បាស់លាស់ យើងនឹងរក្សាទុកបំណែងចែកតាមបែបបុរាណ រវាងកម្មសិទ្ធិឧស្សាហកម្មដែលការពារការច្នៃប្រឌិតនានាដែលបម្រើឱ្យវិស័យបច្ចេកវិជ្ជា និងកម្មសិទ្ធិលើស្នាដៃអក្សរសិល្ប៍ដែលការពាររាល់ការបង្កើតស្នាដៃផ្សេងៗ ដើម្បីធ្វើជាយាននៃការសិក្សារបស់យើងនាពេលនេះ ។

ក. កម្មសិទ្ធិឧស្សាហកម្ម :

កម្មសិទ្ធិឧស្សាហកម្ម ជាកម្មសិទ្ធិមួយប្រភេទដែលសំដៅការពារការច្នៃប្រឌិតទាំងឡាយ ពោលគឺការពារគ្រប់ផលិតផល និងសេវាថ្មីៗ ដែលកើតចេញពីការខិតខំប្រឹងបញ្ញា ដូចមានចែងបញ្ជាក់ក្នុងច្បាប់ដែលពាក់ព័ន្ធនានា ដូចមានរាយរាប់ខាងលើស្រាប់ ។ លើសពីនេះទៅទៀត អ្វីដែលគួរឱ្យកត់សម្គាល់នោះគឺថា ដើម្បីទទួលបាននូវរាល់ការការពារពីរដ្ឋ កម្មសិទ្ធិឧស្សាហកម្មសុទ្ធតែទាមទារឱ្យមានការពិនិត្យមើល និងការចុះបញ្ជីជាបឋម នៅចំពោះមុខអាជ្ញាធរមានសមត្ថកិច្ច ។

១. ម៉ាក

បើទោះបីជាច្បាប់ស្តីពីពាណិជ្ជសញ្ញា និងសេវាសញ្ញាត្រូវបានអនុម័ត និងប្រកាសឱ្យប្រើនៅថ្ងៃ ១៧-០២-២០០២ ក៏ដោយ ក៏អនុក្រឹត្យសម្រាប់អនុវត្តច្បាប់នេះនៅមិនទាន់បានតាក់តែងរួចជាស្ថាពរនៅឡើយទេ ។ ប៉ុន្តែ ទោះបីជាយ៉ាងនេះក្តី ក៏ក្រសួងពាណិជ្ជកម្មបានបង្កើតរួចជាស្រេចនូវការិយាល័យជំនាញទទួលបន្ទុកការចុះបញ្ជីម៉ាកនេះដែរ ។ ម៉ាកជាសញ្ញាដែលកើតចេញពីអក្សរ លេខ លាយ ឬមិនលាយពណ៌ លាយ ឬមិនលាយរូប ឬមួយក៏គ្រាន់តែជាការយកនាម គោត្តនាម ឬពាក្យអ្វីផ្សេងទៀតមកប្រើក៏បាន ឱ្យតែវាអាចយកទៅប្រើប្រាស់ភ្ជាប់លើផលិតផល ហើយអាចអនុញ្ញាតឱ្យអ្នកប្រើប្រាស់ ឬអតិថិជនអាចសម្គាល់ផលិតផល ឬសេវានីមួយដែលត្រូវបានផ្តត់ផ្គង[១៤៨] ។ ពាណិជ្ជនាម[១៤៩] គំនូរ និងម៉ូដែល ក៏ត្រូវបានការពារដូចគ្នានេះដែរ ។ តាមពិតទៅ វិធានទាំងនោះសុទ្ធសឹងតែជាវិធានអន្តរជាតិដែលត្រូវបានកម្ពុជាធ្វើខេមរនីយកម្មតាមរយៈច្បាប់របស់ខ្លួនជាអាទិ៍ ថ្មី មិនបំភាន់ ស្របសណ្តាប់ធ្នាប់ សាធារណៈ ។ល។[១៥០]

---

[148] មាត្រា ២.-ក- "ម៉ាក គឺជាសញ្ញាដែលមើលឃើញ ហើយអាចសំគាល់លក្ខណៈខុសគ្នានៃទំនិញ ឬសេវានៃសហគ្រាសនីមួយៗ ។ ម៉ាកដែលប្រើប្រាស់សម្រាប់ទំនិញហៅថាពាណិជ្ជសញ្ញា ហើយម៉ាកដែលប្រើប្រាស់សំរាប់សេវាហៅថា សេវាសញ្ញា ។"

[149] មាត្រា ២-គ- ពាណិជ្ជនាម គឺជាឈ្មោះ ឬសញ្ញាសំគាល់ ឬជាឈ្មោះ និងសញ្ញាសំគាល់ សម្រាប់បញ្ជាក់ និងសំគាល់លក្ខណៈខុសៗគ្នានៃសហគ្រាសនីមួយៗ ។

[150] មាត្រា ៤ នៃច្បាបដដែល ចែងថា : ម៉ាកដែលមិនអាចចុះបញ្ជីបានមានដូចតទៅ :

ក-ម៉ាកដែលមិនអាចសំគាល់លក្ខណៈខុសគ្នានៃទំនិញ ឬសេវា របស់ហាគ្រាសមួយទៅនឹងសហគ្រាសមួយផ្សេងទៀត ។

ខ-ម៉ាកដែលបណ្តាលឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សធារណៈ សីលធម៌ ឬប្រពៃណីល្អរបស់ជាតិ ។

គ-ម៉ាកដែលអាចនាំឱ្យសាធារណជន ឬមជ្ឈដ្ឋានពាណិជ្ជកម្មភ័ន្តច្រឡំ ទៅនឹងប្រភពភូមិសាស្ត្រនៃទំនិញ ឬសេវាពាក់ព័ន្ធ ឬចាតុងដើម ឬលក្ខណៈខាងក្រៅរបស់ទំនិញ ឬសេវានោះ ។

Scanned with CamScanner

ការប្រកួតប្រជែងមិនស្មោះត្រង[១៥១] ក្នុងវិស័យសញ្ញាសម្គាល់ និងការរំលោភលើសិទ្ធិផ្តាច់មុខរបស់ម្ចាស់ម៉ាក ដែលច្បាប់កម្មសិទ្ធិបញ្ញាបានការពារ សុទ្ធសឹងតែជាបទល្មើស ហើយត្រូវបានផ្តន្ទាទោសជាប្រាក់ពិន័យពី ១ ទៅ ២០លាន រៀល និង/ឬជាប់ពន្ធនាគា ពី ១ ឆ្នាំ ដល់ ៥ ឆ្នាំ[១៥២] ។

២. ប្រកាសនីយបត្រតក្កកម្ម

សេចក្តីព្រាងច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្មត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីនៅថ្ងៃទី ១២-១០-២០០១ ហើយត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស. រកម. ០១០៣ .០០៥ ថ្ងៃទី ២២-០១-២០០៣ ។ អនុលោមតាមបញ្ញត្តិនៃមាត្រា ៣ នៃច្បាប់ខាងលើប្រកាសនីយបត្រតក្កកម្ម គឺជាវិញ្ញាបនបត្រ ដែលបានផ្តល់ដើម្បីការពារតក្កកម្ម ពោលគឺការពារគំនិតរបស់តក្កករដែលអាចយកទៅអនុវត្តបាននៅក្នុងដំណោះស្រាយបញ្ហាជាក់លាក់ណាមួយក្នុងវិស័យបច្ចេកវិជ្ជា ។ តក្កកម្មអាចជាការរកឃើញផលិតផល ឬដំណើរការផលិតកម្ម ឬអាចជាការរកឃើញអ្វីមួយដែលទាក់ទងទៅនឹងផលិតផល ឬដំណើរការផលិតកម្ម ។ ការការពារដែលបានពោលខាងលើនេះមានចែងនៅក្នុងជំពូក ២ ដោយគូសបញ្ជាក់នូវសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលក្នុងការរៀបចំ និងធានាការគោរពសិទ្ធិផ្តាច់មុខរបស់តក្កករក្នុងការធ្វើអាជីវកម្ម ក្នុងរយៈពេលអតិបរមា ២០ ឆ្នាំគិតចាប់ពីថ្ងៃចុះបញ្ជី[១៥៣] ។

ខ. តម្លៃសិទ្ធិលើស្នាដៃអក្សរសាស្ត្រនិងសិល្បៈ

ការការពារកម្មសិទ្ធិលើស្នាដៃអក្សរសាស្ត្រ និងសិល្បៈធ្វើឡើងដោយស្វ័យប្រវត្តិ[១៥៤] ពោលគឺ វាឥតទាមទារឱ្យមានការបំពេញបែបបទរដ្ឋបាលអ្វីទាំងអស់ ។ នេះមានន័យថា អ្នកនិពន្ធ ឬម្ចាស់សិទ្ធិក្តី អាចតម្កល់ ឬមិនតម្កល់ទុកស្នាដៃនៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ និយាយម្យ៉ាងទៀតថា ការបង្កើតស្នាដៃ គឺជាលក្ខខណ្ឌតែមួយគត់នៃការទទួលបានការការពារពីច្បាប់ និងសន្ធិសញ្ញាអន្តរជាតិដែលពាក់ព័ន្ធក្នុងវិស័យនេះ។ ការការពារនេះផ្តល់ជូនចំពោះតែការបង្កើត

ឃ-ម៉ាកដែលដូចគ្នានិង/ឬច្រាប់តាម ឬមានចំណុចណាមួយដូចសញ្ញាជាតិ ទង់ជាតិ និងនិមិត្តរូបផ្សេង។ ឈ្មោះ ឬឈ្មោះសង្ខេប ឬអក្សរកាត់នៃឈ្មោះ ឬសញ្ញា ឬត្រាជាផ្លូវការ ដែលអនុម័តដោយរដ្ឋណាមួយ អង្គការអន្តររដ្ឋាភិបាល ឬអង្គការដែលបង្កើតដោយអនុសញ្ញាអន្តរជាតិមួយ លើកលែងតែមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋនោះ ឬអង្គការនោះ ។

ង-ម៉ាកដែលដូចគ្នា ឬប្រហាក់ប្រហែល ដែលនាំឱ្យច្រឡំគ្នានឹងម៉ាក ឬពាណិជ្ជនាមមួយដែលល្បីក្នុងព្រះរាជាណាចក្រកម្ពុជា ឬបង្កើតពីការបកប្រែនៃម៉ាក ឬពាណិជ្ជនាមដែលល្បីនោះសម្រាប់ទំនិញ ឬសេវាដូចគ្នា ឬប្រហាក់ប្រហែលគ្នានៃសហគ្រាសមួយទៀត ។

ច-ម៉ាកដែលដូចគ្នា ឬប្រហាក់ប្រហែលដែលនាំឱ្យច្រឡំគ្នានឹងម៉ាក ឬពាណិជ្ជនាមមួយដែលល្បី ឬបង្កើតពីការបកប្រែនៃម៉ាក ឬពាណិជ្ជនាមដែលល្បីនោះ ហើយដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់ទំនិញ ឬសេវា ដែលមិនដូចគ្នា ឬមិនប្រហាក់ប្រហែលគ្នាដោយការប្រើប្រាស់ម៉ាកនោះធ្វើឱ្យខូចប្រយោជន៍របស់ម្ចាស់នៃម៉ាកល្បី ។

ឆ-ម៉ាកដែលដូចគ្នា ឬស្ទើរតែដូចគ្នាទាំងស្រុងទៅនឹងម៉ាកដែលជាកម្មសិទ្ធិរបស់ម្ចាស់ផ្សេងដែលបានចុះបញ្ជីរួចហើយ ឬបានដាក់ពាក្យស្នើសុំចុះបញ្ជីមុន ឬបានទទួលអាទិភាពចុះបញ្ជីមុននៅឯបរទេសចំពោះទំនិញ ឬសេវាដូចគ្នា ឬទំនិញ ឬសេវាដែលពាក់ព័ន្ធគ្នាយ៉ាងជិតស្និទ្ធ ។

[១៥១] សំដៅដល់រាល់សកម្មភាពនានាដែលនាំឱ្យអ្នកប្រើប្រាស់មានការភ័ន្តច្រឡំ (សូមអានមាត្រា ២២ និង ២៣ នៃច្បាប់ដដែល) ។

[១៥២] សូមអាន មាត្រា ៦៤. និងមាត្រា ៦៥ ។

[១៥៣] សូមអាន មាត្រា ៤.រហូតដល់មាត្រា ៤៦ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែល មានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ។

[១៥៤] មាត្រា ៣៨ នៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ។

Scanned with CamScanner

ទាំងឡាយដែលជាផលនៃការប្រើកម្លាំងបញ្ជារបស់ម្ចាស់ស្នាដៃ ពោលគឺតាមរយៈស្នាដៃនោះ គេអាចឆ្លុះបញ្ចាំងឃើញនូវបុគ្គលិកលក្ខណៈរបស់ម្ចាស់វា ។ ដូច្នេះផលិតផល និងសេវាដែលការពារនៅក្នុងន័យនេះ សុទ្ធសឹងតែមានលក្ខណៈសិល្បៈរួមមានស្បៀវភៅ ប្រព័ន្ធទិន្នន័យ កម្មវិធីកុំព្យូទ័រ និងគម្រោងឯកសារសមោធានដែលទាក់ទងទៅនឹងកម្មវិធីទាំងនោះ តន្ត្រី ខ្សែរភាពយន្ត និងការប្រឌិតគ្រប់បែបយ៉ាងដែលបម្រើឱ្យវិស័យពហុព័ត៌មាន[១៥៥] ។

១. សិទ្ធិអ្នកនិពន្ធ : "ជំពូកទី ២"

ជាសិទ្ធិផ្តាច់មុខដែលផ្តល់ជូនដោយច្បាប់ដល់ម្ចាស់ស្នាដៃក្នុងការធ្វើអាជីវកម្ម ផលិតឡើងវិញ និងចាត់ចែងតាមគ្រប់រូបភាពលើស្នាដៃរបស់ខ្លួន ។ រយៈពេលកិច្ចការការពារសិទ្ធិនេះត្រូវប្រព្រឹត្តទៅអស់មួយជីវិត អ្នកនិពន្ធព្រមទាំងប្រព្រឹត្តទៅ ៥០ (ហាសិប)ឆ្នាំ ក្រោយថ្ងៃទទួលមរណៈភាពរបស់អ្នកនិពន្ធ ។ តែក្នុងករណីដែលស្នាដៃនោះជាស្នាដៃសហការវិញ ការការពារប្រព្រឹត្តទៅអស់មួយជីវិតអ្នកនិពន្ធដែលរស់នៅចុងក្រោយគេព្រមទាំងប្រព្រឹត្តទៅរយៈពេល ៥០ (ហាសិប)ឆ្នាំ ក្រោយថ្ងៃទទួលមរណៈភាពរបស់អ្នកនិពន្ធចុងក្រោយនេះ[១៥៦] ។ ថ្វីដ្បិតតែសិទ្ធិនេះជាសិទ្ធិផ្តាច់មុខក៏ដោយ ក៏វានៅមានព្រំដែនមួយចំនួនជាអាទិ៍ :

- ការលើកយកមកធ្វើជាអំណះអំណាងក្នុងអត្ថបទស្រាវជ្រាវ
- ការប្រើប្រាស់ស្នាដៃសំរាប់សិក្សាដោយគ្មានប្រាក់កម្រៃ
- ការសំដែងស្នាដៃជាឯកជនដោយមិនគិតកម្រៃ
- ការផលិតឡើងវិញនូវចំនួនមួយច្បាប់ជាលក្ខណៈឯកជននូវស្នាដៃដែលបានបោះផ្សាយ ហើយសំរាប់ការប្រើប្រាស់ផ្ទាល់ខ្លួន[១៥៧] ។ល។

ក្រៅពីសិទ្ធិបេតិកភណ្ឌដែលរៀបរាប់ខាងលើនេះ នៅមានសិទ្ធិខាងសីលធម៌ដែលជាសិទ្ធិអចិន្ត្រៃយ៍មិនអាចលក់ដូរបាន មិនអាចរឹបអូសបាន និងមិនអាចផុតអាជ្ញាយុកាល[១៥៨] ។ តែ សិទ្ធិនេះអាចត្រូវបានផ្ទេរទៅឱ្យទាយាទរបស់អ្នកនិពន្ធ ដោយមូលហេតុ អ្នកនិពន្ធបានទទួលមរណភាព ឬប្រគល់ជូនតតីយជនបាន ដោយយោងតាមបទបញ្ញត្តិមរតក-សាសន៍ ។ ក្នុងករណីគ្មានអ្នកទទួលមរតក រដ្ឋដែលតំណាងដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈជាអ្នកគ្រប់គ្រងសិទ្ធិនោះ ។

---

[១៥៥] សូមអាន មាត្រា ៧ នៃច្បាប់ខាងលើ ។

[១៥៦] សូមអានមាត្រា ៣០ នៃច្បាប់ដដែល ។

[១៥៧] សូមអានផ្នែកទី ៤ នៃច្បាប់ដដែល ចាប់ពីមាត្រា ២៣.នឹងបន្តរបន្ទាប់ ។

[១៥៨] សូមអានមាត្រា ១៩ នៃច្បាប់ដដែល ។

Scanned with CamScanner

២. សិទ្ធិប្រហាក់ប្រហែល "ឧទ្ធរណ៍ ៣"

ការគាំពារដល់សិទ្ធិដែលប្រគល់ជូនដល់អ្នកនិពន្ធត្រូវបានបំពេញបន្ថែមដោយការទទួលស្គាល់នូវសិទ្ធិដទៃទៀត ចំពោះអ្នកសម្តែង ផលិតករហ្វូណូក្រាម ផលិតករទូរផ្សាយ ផលិតករភាពយន្ត ។ ការការពារ និងការទទួលស្គាល់សិទ្ធិប្រភេទនេះធ្វើឡើងតាមរយៈក្រុមហ៊ុន ឬសហគ្រាស អង្គភាពគ្រប់គ្រងសិទ្ធិរួម[១៥៩] ។

គ. សិទ្ធិតម្លៃសិទ្ធិដោយឡែត[១៦០] :

នៅក្នុងវិស័យកម្មសិទ្ធិបញ្ញាដែល ឬនៅក្រៅវិស័យនេះ គេឃើញមានបែបបទការពារផលិតផល និងសេវាផ្សេងៗ ដែលផ្តល់នូវសិទ្ធិផ្តាច់មុខ ប៉ុន្តែ ពុំបានផ្សាភ្ជាប់ទៅនឹងវិស័យខាងលើនេះទេ ។ បែបបទថ្មីនៃការការពារមិនទាន់ត្រូវបានចែងក្នុងបទដ្ឋានក្នុងស្រុកនៅកម្ពុជានោះទេ តែ បែបបទនេះស្ថិតនៅក្នុងផ្នែកមួយនៃអត្ថបទអន្តរជាតិដែលត្រូវបានផ្តល់សច្ចាប័នយ៉ាងត្រឹមត្រូវដោយប្រទេសកម្ពុជា ។ ក្នុងន័យនេះ យើងអាចលើកឡើងបង្ហាញក្នុងការសិក្សាខាងក្រោមនេះ ។

១. មូលដ្ឋានអនិច្ចន័យ :

គឺជាការការពារនូវស្ថាបត្យកម្ម និងការរៀបចំទិន្នន័យដើម្បីអនុញ្ញាតដល់តក្កវរអាចរកឃើញនូវការវិនិយោគធន់ធ្ងន់ចាំបាច់ក្នុងការបង្កើតនូវឧបករណ៍ផ្សេងៗ ។ ការការពារនេះស្ថិតនៅជាផ្នែកមួយនៃកម្មសិទ្ធិបញ្ញា តែ គោរពនូវវិធានផ្ទាល់ខ្លួន ។

២. នាមវិស័យ[១៦១] នានា :

គេឃើញមាន "*នាមវិស័យ*" ជាច្រើនដែលប្រើសម្រាប់សម្គាល់គេហទំព័រដែលប្រកាសផ្សាយលើទំព័រអ៊ុនធឺណេត ហើយអនុញ្ញាតឱ្យយើងអាចទទួលបាននូវព័ត៌មានជាច្រើនស្តីពីទំនិញ សេវាផ្សេងៗ ។ តែទោះបីជាយ៉ាងនេះក៏ដោយ ក៏វាហាក់បីដូចជាមានសារសំខាន់ និងលើកយកមកធ្វើការសិក្សាដោយសង្ខេបនៅទីនេះផងដែរ ដោយហេតុថា មិនយូរមិនឆាប់ បញ្ហានេះនិងកើតមានដោយខានមិនបាននៅកម្ពុជាយើងផងដែរ ។ នាពេលបច្ចុប្បន្ន "*នាមវិស័យ*" នីមួយៗនេះគ្រប់គ្រងដោយអ៊ីកាន[១៦២] ដោយឈរលើគោលការណ៍ "*អ្នកណាល្បឿន អ្នកនោះជាអ្នកប្រើ*[១៦៣]" ។ ប៉ុន្តែ រាល់វិវាទដែលកើតមានលើវិស័យនេះ ត្រូវបានដោះស្រាយដោយអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ។ តាមពិតទៅវាមិនមែនជាផ្នែកមួយនៃកម្មសិទ្ធិបញ្ញា ដែលគេធ្លាប់ស្គាល់នោះទេ តែដោយសារតែផលប្រយោជន៍របស់វាប្រហាក់ប្រហែលគ្នានឹងម៉ាកដែរ ទើបវាក្លាយជារឿងដ៏មានគុណប្រយោជន៍ ដែលវិវាទរបស់វាត្រូវបានដោះស្រាយដោយអង្គការល្បីៗលើពិភពលោកខាងកម្មសិទ្ធិបញ្ញា ។

---

[១៥៩] សូមអានមាត្រា ៤៩ នៃច្បាប់ដដែល ។

[១៦០] Propriétés *sui generis*

[161] Noms de domaines

[១៦២] Icann

[១៦៣] premier arrivé, premier servi

Scanned with CamScanner

II. រូបភាពនានានៃការយកធ្វើជាកម្មសិទ្ធិសមូហភាពក្នុងនិស័យកម្មសិទ្ធិបញ្ញា

នីតិកម្មសិទ្ធិបញ្ញាក៏ដូចជានីតិមួយចំនួនទៀតដែរ បានរៀបចំគ្រប់គ្រងនូវការប្រើប្រាស់សិទ្ធិផ្តាច់មុខជាលក្ខណៈសមូហភាពជាអាទិ៍ មានបញ្ហានានាដែលពាក់ពន្ធ័ជាមួយនឹងសញ្ញាសម្គាល់ទាំងឡាយដែលចង្អុលបង្ហាញភូមិសាស្ត្រចំណេះដឹង ចំណេះធ្វើដែលមានលក្ខណៈពិសេសតាមតំបន់ ព្រមទាំងយន្តការមួយចំនួនទៀតដែលគ្រាន់តែជាការកែច្នៃ រប្បៀបការពារដែលយើងបានសិក្សាពីខាងដើមរួចហើយ ។

ក. សិទ្ធិនានាដែលអាចប្រើប្រាស់ជាសមូហភាព :

ថ្វីដ្បិតតែគេពុំឃើញមានបញ្ញត្តិណាមួយនៃច្បាប់ជាតិ ចែងពីបញ្ហាទាំងអស់នេះក៏ពិតមែន តែយើងអាចរកបាននៅក្នុងអនុសញ្ញា ឬវិធានដទៃទៀតដែលតាក់តែងឡើងក្នុងក្របខណ្ឌអង្គការពាណិជ្ជកម្មពិភពលោក ។ ការសិក្សាវិស័យទាំងនេះមានលក្ខណៈចាំបាច់ ដោយហេតុថា វិធានអន្តរជាតិទាំងនេះ ត្រូវបានធ្វើសច្ចាប័ន និងរៀបចំក្រោមទម្រង់ជាសេចក្តីព្រាងច្បាប់ជាតិមួយ ។

១. ការចង្អុលបង្ហាញភូមិសាស្ត្រ :

បញ្ហានេះ ត្រូវបានចែងនៅក្នុងកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញាដែលត្រូវបានតាក់តែងឡើងក្នុងក្របខណ្ឌអង្គការពាណិជ្ជកម្មពិភពលោក ពិសេសនៅក្នុងមាត្រា ២៣ ដែលស្ថិតក្នុងផ្នែក២ នៃភាគទី ២ ។ គួរកត់សម្គាល់ផងដែរថា ព្រះរាជាណាចក្រកម្ពុជាក៏បានរៀបចំរួចជាស្រេចហើយដែរនូវសេចក្តីព្រាងច្បាប់ស្តីពីការចង្អុលបង្ហាញលក្ខណៈភូមិសាស្ត្រ ដើម្បីនឹងដាក់ជូនសភាធ្វើការពិនិត្យ ពិភាក្សា និងអនុម័ត[១៦៤] ។ ហើយបើយើងក្រឡេកមើលប្រវត្តិកំណកំណើតលើពិភពលោករបស់វា ការចង្អុលបង្ហាញភូមិសាស្ត្រនេះ ត្រូវបានប្រើដំបូងក្នុងវិស័យសុរា និងភេសជ្ជៈប្រហាក់ប្រហែលដទៃទៀតក្រោមឈ្មោះថា ការដាក់នាមប្រភពភូមិសាស្ត្រដែលមានការត្រួតពិនិត្យ[១៦៥] ជាឧទាហរណ៍ ស្រាកូញាក់ ស្រាសំប៉ាញ ។ល។ បន្ទាប់មកការប្រើប្រាស់វាបានរីកសាយភាយទៅដល់វិស័យដទៃទៀតរួមមានទាំងការអនុវត្តចំណេះធ្វើផងដែរ ។

តាមការពិត ការចង្អុលបង្ហាញលក្ខណៈភូមិសាស្ត្រ គឺជាការការពារដែនដី ឬតំបន់មួយដែលផលិតផលិតផលពិសេសអ្វីម្យ៉ាង ទោះបីជាលក្ខណពិសេសខាងរសជាតិនោះ បានដោយសារចំណេះធ្វើក្តី ឬដោយសារគុណភាពរបស់ដីក្តី ។ ដូចនេះ ការផ្តល់សិទ្ធិផ្តាច់មុខធ្វើឡើងដោយឈរលើប្រភពភូមិសាស្ត្រពិសេសរបស់ទំនិញ ផលិតផលដែលខុសស្រឡះពីម៉ាកដែលគ្រាន់តែជាសញ្ញាសម្គាល់ដែលគេប្រើសម្រាប់ជាការចង្អុលបង្ហាញសហគ្រាស ឬប្រភេទផលិតផល ។ ដើម្បីឱ្យកាន់តែយល់ច្បាស់ យើងសូមជូនឧទាហរណ៍មួយចំនួនដែលមាននៅលើពិភពលោក ជាអាទិ៍ អង្ករបាសម៉ាឌីរបស់ឥណ្ឌា ទឹកត្រីភូរកករបស់វៀតណាម, ម្រេចកំពតរបស់ខ្មែរ ។ល។

---

[១៦៤] សូមអាន សេចក្តីព្រាងច្បាប់ស្តីពីការចង្អុលបង្ហាញលក្ខណភូមិសាស្ត្រ រៀបរៀងនៅថ្ងៃ ១៨-០៩-២០០៣ ។

[១៦៥] L'appellation d'origine contrôlée.

Scanned with CamScanner

ការការពារតាមផ្លូវច្បាប់ដែលត្រូវផ្តល់ជូនដល់តំបន់ភូមិសាស្ត្រណាមួយនោះអាចនឹងធ្វើបាន លុះណាតែផលិតកម្ម នោះគោរពតាមទាំងរបៀបផលិត ក៏ដូចជារបៀបគាំពារ ។ ក្រោយពេលប្រគល់ជូនរួចហើយ ការចង្អុលបង្ហាញភូមិសាស្ត្រ នេះនឹងអនុញ្ញាតឱ្យអ្នកប្រើប្រាស់ស្គាល់លក្ខណៈពិសេសរបស់ទំនិញ ព្រមទាំងផ្តល់ជូនដល់ម្ចាស់របស់វានូវសិទ្ធិផ្តាច់មុខក្នុង ការប្រើប្រាស់សញ្ញាសម្គាល់ ដើម្បីការពារកេរ្តិ៍ឈ្មោះភូមិរបស់ខ្លួន ។

អត្ថិភាពនៃសិទ្ធិនេះទាមទារឱ្យមានការទទួលស្គាល់ដោយច្បាប់ជាតិពិសេស ដើម្បីកំណត់អំពីនីតិវិធីក្នុងការចុះ បញ្ជី និងការផ្តល់សិទ្ធិផ្សេងៗ ។ ការទទួលស្គាល់នេះអនុញ្ញាតឱ្យគេផ្តន្ទា ឬអាចផ្តន្ទាទោសរាល់ការរំលោភបំពាន ស្រប តាមបទចំបាត្តិជានីត្យានុកូល ។

២. ចំណេះដែលមានលក្ខណៈប្រពៃណី ទំនៀមទម្លាប់របស់អ្នកស្រុក ឬភូមិ :

មាត្រា ៨-ឈ នៃអនុសញ្ញាស្តីពីជីវចម្រុះឆ្នាំ ១៩៩២ ដែលបានតាក់តែងឡើងបន្ទាប់ពីកិច្ចប្រជុំនៅទីក្រុងរីយ៉ូ បានបង្កើតគោលការណ៍នៃការគោរពចំណេះផ្ទៃដែលមានលក្ខណៈជាប្រពៃណីទំនៀមទម្លាប់ ។ អនុសញ្ញានេះត្រូវបាន ទទួលយកដោយកម្ពុជាកាលពីថ្ងៃទី ០៥-០២-១៩៩៥ ។

"ភាគីហត្ថលេខីនីមួយៗ ត្រូវអនុវត្ត ស្របតាមកិច្ចព្រមព្រៀង និងបទបញ្ជត្តិជាតិរបស់ខ្លួន ដោយធ្វើការគោរព គាំពារ ថែរក្សា ចំណេះដឹង ការច្នៃប្រឌិត ព្រមទាំងទម្លាប់អនុវត្តរបស់សហគមជនជាតិ ក៏ដូចជារបស់ប្រជាជនក្នុងស្រុក ដែលសឱ្យឃើញនូវរបៀបរស់នៅមួយតាមលក្ខណៈប្រពៃណីមួយ ដែលតម្រូវឱ្យមានការអភិរក្ស និងប្រើប្រាស់ជាយូរ អង្វែងនូវជីវសាស្ត្រចម្រុះ ព្រមជាមួយនិងការជម្រុញឱ្យមានការពង្រីក ដោយមានការយល់ព្រមពីសំណាក់អ្នកដែលមាន ចំណេះ មានការច្នៃប្រឌិត ការអនុវត្ត ព្រមទាំងការលើកទឹកចិត្តឱ្យមានការបែងចែកដ៏មានសមធម៌នូវផលប្រយោជន៍នា នាដែលបានមកពីការប្រើប្រាស់ចំណេះដឹង ការច្នៃប្រឌិត និងការអនុវត្តអស់ទាំងនោះ ។

គឺក្នុងន័យនេះហើយដែលគេទទួលស្គាល់នូវការបែងចែកក្នុងលក្ខណៈសមធម៌នូវផលប្រយោជន៍ ដែលបានមកពី ការប្រើប្រាស់ចំណេះផ្ទៃដែលបានបន្សល់ទុកតៗគ្នាក្រោមរូបភាពជាប្រពៃណីទំនៀមទម្លាប់ ដូចមានចែងបញ្ជាក់ក្នុងបញ្ញត្តិ នៃមាត្រា ២៧-៣-ខ នៃកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា ។ បើទោះបីជាបញ្ហាស្តីពីការ ចង្អុលបង្ហាញលក្ខណៈភូមិសាស្ត្រនេះ មិនស្ថិតក្នុងវិស័យកម្មសិទ្ធិបញ្ញាក៏ដោយ ក៏វាត្រូវបានចែងទុក និងរៀបចំឡើងដើម្បី ជាប្រយោជន៍ក្នុងការប្រើប្រាស់របស់សាធារណៈជន ពិសេសគឺ របស់សហគម ម្ចាស់ស្រុក ឬប្រជាជនក្នុងនិគមណាមួយ ។ តាមរយៈការការពារបែបនេះ សហគមម្ចាស់ស្រុកទាំងនោះ អាចនឹងស្វែងរកផលចំណេញខាងសេដ្ឋកិច្ចបានតាមរយៈការ លក់ផលិតផលដើមរបស់ដែនដីខ្លួន ។

កម្ពុជា[១៦៦] ក៏មិនខុសពីសមាជិកដទៃទៀតរបស់អង្គការពាណិជ្ជកម្មពិភពលោកដែរ ត្រូវរួមចំណែកអនុវត្តវិធាន គតិយុត្តនានាដែលមានក្នុងក្របខណ្ឌនៃអង្គការនេះ ។ ក្រុមប្រឹក្សាទទួលបន្ទុកកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្ម ទាក់ទងនឹងកម្មសិទ្ធិបញ្ញា បានសហការជាមួយនិងគណកម្មការអន្តររដ្ឋាភិបាលរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ដើម្បីរៀបចំបង្កើតនូវប្រព័ន្ធការពារខាងគតិយុត្ត និងសេដ្ឋកិច្ចពិសេសមួយក្នុងវិស័យនេះ ។

[១៦៦] ក្លាយជាសមាជិកចាប់តាំងពី ខែ សីហា ២០០៤

Scanned with CamScanner

ក្នុងន័យនេះ ច្បាប់ដែលនឹងត្រូវបង្កើតឡើងត្រូវតែពិចារណាអំពីបញ្ហាសមូហភាព ព្រមទាំងអនុញ្ញាតឱ្យប្រទេសកំពុងអភិវឌ្ឍ ហើយដែលសុទ្ធសឹងជាម្ចាស់នៃប្រភពធនធានសេនេទីក ឬពន្ធុនានាជាង ៨០ % អាចការពារបេតិកភណ្ឌផង និងអាចធ្វើអាជីវកម្មលើវាផង ។

ខ. ឧបករណ៍គតិយុត្តបុរាណក្នុងកម្មសិទ្ធិបញ្ញាដែលយកទៅប្រើជាលក្ខណសមូហភាព :

អ្វីដែលយើងសិក្សាពីខាងដើម ក៏អាចនឹងយកមកប្រើប្រាស់ផងដែរ ក្នុងលក្ខណៈបម្រើឱ្យប្រយោជន៍សមូហភាព ជាអាទិ៍ ករណីម៉ាកសមូហភាព ដែលត្រូវបានប្រើប្រាស់ដោយម្ចាស់ច្រើនរូប ស្របតាមបទបញ្ញត្តិនៃជំពូក ៤ នៃច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងការប្រកួតប្រជែងមិនស្មោះត្រង់ ។ ក្នុងករណីដូចពោលខាងលើនេះ គឺយើងត្រូវវិភាគ និងដោះស្រាយស្របតាមរបបគតិយុត្តនៃសហកម្មសិទ្ធិករ ។

ដូចគ្នានេះដែរ ប្រកាសនីយបត្រតក្កកម្ម ក៏អាចមានម្ចាស់ច្រើនដែរ ប្រសិនបើក្នុងពាក្យសុំប្រកាសនីយបត្រនោះមានចែងបញ្ជាក់យ៉ាងច្បាស់ដោយមានការចង្អុលបង្ហាញអំពីអត្តសញ្ញាណរបស់អ្នកស្នើសុំផង ស្របតាមមាត្រា ១១ នៃច្បាប់ខាងលើ ។ ក្នុងករណីនេះ របបគតិយុត្តនៃសហកម្មសិទ្ធិនៃនីតិរូម អាចត្រូវបានអនុវត្តទៅក្នុងនីតិកម្មសិទ្ធបញ្ញាផងដែរ ។

សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល អាចជាសិទ្ធិសមូហភាព ។ តែ របបគតិយុត្តពិសេសនៅតែបន្តអនុវត្តចំពោះប្រភេទស្នាដៃនីមួយៗដដែល ។ លើសពីនេះទៀត គេនៅឃើញមានស្នាដៃថ្មីៗមួយចំនួនទៀតដែលមានលក្ខណៈសមូហភាពតាំងតែពីធម្មជាតិរបស់វា ។ ឧទាហរណ៍ ខ្សែភាពយន្ត ស្នាដៃពហុព័តិមាន ស្នាដៃខាងសូរសំឡេង ។ល។ ដូចនេះ ដើម្បីរកឱ្យឃើញនូវរបបគតិយុត្តសម្រាប់ការពារស្នាដៃអស់ទាំងនោះ គេត្រូវតែពិនិត្យពិចយ៉ារកវិធានពិសេសរបស់វា ។ បើពុំមានវិធានពិសេសនោះទេ គេត្រូវយកវិធានទូទៅស្តីពីរបបគតិយុត្តនៃសហកម្មសិទ្ធិមកអនុវត្ត ។

ដូចនេះការសិក្សាអំពីវិធានដែលមានស្រាប់ ដើម្បីការពារផលិតផល និងសេវាផ្សេងៗ អនុញ្ញាតឱ្យយើងបានសិក្សាដោយសង្ខេបពីអ្វីទៅដែលហៅថា នីតិកម្មសិទ្ធិបញ្ញា ព្រមទាំងវិធីសាស្ត្រគតិយុត្តផ្សេងៗទៀតដែលបង្កើតឡើងជាប្រយោជន៍ឯកជនក្តី ឬសមូហភាពក្តី ក្នុងន័យជម្រុញឱ្យមានការការពារវាល់ការច្នៃប្រឌិត និងការបង្កើតថ្មីនានាដែលជាកម្លាំងចលករនៃការអភិវឌ្ឍប្រទេសជាតិ ។

តថាខណ្ឌទី ៤ : នីតិការខារ

ក. ប្រធានបទ

"ប្រាក់ឈ្នួលស្មើគ្នា សម្រាប់ការងារដូចគ្នា"

ខ. តំណែ : (លីម ស៊ុយហុង)

"គ្រប់កំហុសទាំងអស់មានសិទ្ធិទទួលបានប្រាក់ឈ្នួល" និងនីតិការងារត្រូវបានបង្កើតឡើងជាពិសេសនៅជុំវិញសញ្ញាណនៃប្រាក់ឈ្នួលនេះ ។ សម្រាប់និយោជិត ប្រាក់ឈ្នួលតំណាងយ៉ាងជាក់ច្បាស់នូវចរិតលក្ខណៈជាអាហារ ។ យើង

Scanned with CamScanner

គួរកត់សម្គាល់ថា កិច្ចសន្យាការងារ អនុលោមតាមមាត្រា ៦៤ វាក្យខណ្ឌទី ១ នៃច្បាប់ការងារកម្ពុជា ស្ថិតនៅក្រោមវិធាននៃនីតិរូមនៃកិច្ចសន្យា ជាអាទិ៍ ដោយប្រគល់ឱ្យទៅគូភាគីនូវសេរីភាពកំណត់តម្លៃ ដែលគូភាគីយល់ថាត្រឹមត្រូវ ដោយគោរពនូវដែនកំណត់មួយចំនួនរបស់ច្បាប់ : និយោជិតម្នាក់ៗ ពុំអាចទទួលបានប្រាក់ឈ្នួលដែលតិចជាងប្រាក់ឈ្នួលអប្បបរិមានោះទេ (មាត្រា ១០៤ នៃច្បាប់ការងារកម្ពុជា) ។ ក្រៅពីលក្ខខណ្ឌនេះ ប្រាក់ឈ្នួលអាចត្រូវបានកំណត់ដោយនិយោជក និងនិយោជិត ដែលចុះកិច្ចសន្យាការងារជាឯកត្តជន ។ ការអនុវត្តច្រើស្តីនៃសេរីភាពក្នុងការចុះកិច្ចសន្យាអាចបង្កឱ្យមានការរើសអើង រវាងនិយោជិតដែលស្ថិតនៅក្រោមចំណងទាក់ទងជាមួយនឹងនិយោជក និងស្ថិតនៅក្រោមការដឹកនាំនិយោជកតែម្នាក់ នៅពេលដែលនិយោជិតទាំងអស់នោះមានបទពិសោធន៍ការងារ និងសមត្ថភាពបំពេញការងារដូចគ្នា ។ ដោយគិតទៅដល់ការរើសអើង ធ្វើឡើងដោយនិយោជកយ៉ាងដូច្នេះ អ្នកតាក់តែងច្បាប់បានចាត់វិធានការមួយចំនួន ក្នុងគោលដៅជំទាស់ប្រឆាំងនឹងការអនុវត្តខុសច្បាប់ ដោយដាក់បង្ខំនូវគោលការណ៍សមភាពខាងប្រាក់ឈ្នួល សម្រាប់ការងារដូចគ្នា (មាត្រា ១០៦ នៃច្បាប់ការងារ) បើពុំដូច្នោះទេ ការរើសអើងដែលមានចែងក្នុងមាត្រា ១២ នៃច្បាប់ការងារនោះ នឹងត្រូវបានលើកឡើង ។

មុននឹងធ្វើការពន្យល់ថា តើមានអានុភាពអ្វីខ្លះដែលអាចត្រូវបានធ្វើឡើង ក្នុងករណីគោលការណ៍ខាងលើនេះពុំត្រូវបានអនុវត្ត (II) យើងត្រូវស្គាល់ជាបឋមអំពីធាតុផ្សំសំខាន់ៗនៃគោលការណ៍នេះ និងខ្លឹមសាររបស់វា (I) ។

I. តារផ្តល់និយមន័យ និងខ្លឹមសារនៃគោលការណ៍ :

ការកំណត់ចរិតលក្ខណៈនៃប្រាក់ប្រៃវត្យ និងការងារដូចគ្នា មានលក្ខណៈចាំបាច់ ដើម្បីកំណត់អំពីអត្ថិភាពនៃការរើសអើងនេះ ។ ហេតុដូច្នេះ ជាដំបូងយើងត្រូវកំណត់និយមន័យនៃគោលការណ៍នេះ (A) បន្ទាប់មកយើងស្វែងរកថា តើ អត្ថន័យ ឬខ្លឹមសារនៃគោលការណ៍នេះសំដៅទៅលើអ្វី ? (B)

A. តារផ្តល់និយន័យប្រាក់ប្រៃវត្យ និងតារងារដូចគ្នា :

១. ប្រាក់ឈ្នួលស្មើគ្នា :

យោងតាមមាត្រា ១០២ នៃច្បាប់ការងារ ពាក្យប្រាក់ឈ្នួលសំដៅទៅលើប្រាក់រង្វាន់[១៦៧] ឬប្រាក់លាភទាំងឡាយណាដែលអាចវាយតម្លៃជាសាច់ប្រាក់ ដែលត្រូវបង់ក្នុងករណីមានកិច្ចសន្យាជួលសេវា ដោយមានទម្រង់ជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ ដោយនិយោជក ឱ្យទៅនិយោជិតម្នាក់ ឬមួយសម្រាប់ការងារដែលត្រូវបានបំពេញ ឬមួយសម្រាប់ការងារដែលនឹងត្រូវបំពេញ ឬមួយសម្រាប់ការបំពេញសេវាណាមួយ ឬមួយសម្រាប់សេវាដែលនឹងត្រូវតែបំពេញ ។

---

[១៦៧] ប្រសិនបើយើងមើលនីយមន័យនៃមាត្រាខាងលើនេះ ពាក្យប្រាក់ឈ្នួល និងប្រាក់រង្វាន់ហាក់ដូចជាត្រូវបានប្រើប្រាស់ដូចជាសទិសន័យ ។ ម៉្យាងវិញទៀត យើងឃើញថា ពាក្យទាំងពីរនេះ "Salaire et remuneration" ត្រូវបានបកប្រែនៅក្នុងវចនានុក្រមបារាំង-ខ្មែររបស់លោក សម ថង ដោយមានសញ្ញាណដូចគ្នា ។ ប៉ុន្តែ យោងតាមមាត្រា ១០៣ នៃច្បាប់ការងារ អ្នកតាក់តែងបានធ្វើការបែងចែកភាពខុសគ្នារវាងពាក្យទាំងពីរនេះ ។ តាមពិត ប្រាក់រង្វាន់ "remuneration" ក្រៅពីប្រាក់ឈ្នួល ក៏មានផលប្រយោជន៍សង្គមផ្សេងៗទៀត ជាពិសេស ប្រាក់កម្រៃជើងសារ សោហ៊ុយ ប្រាក់ឈប់សម្រាក ...។ល។ ហេតុដូច្នេះ សញ្ញាណនៃពាក្យប្រាក់រង្វាន់នេះ មានន័យទូលំទូលាយជាងប្រាក់ឈ្នួល ។ ប៉ុន្តែ ពាក្យប្រាក់ឈ្នួល ដែលយើងប្រើប្រាស់ក្នុងអត្ថបទនេះ ទទួលបានន័យការឯកភាពយ៉ាងទូលាយជាងប្រាក់ឈ្នួលធម្មតា "*ប្រាក់ប្រៃវត្យ*" ដែលវាក៏ស្ថិតនៅក្នុងន័យនៃប្រាក់រង្វាន់ផងដែរ ។

Scanned with CamScanner

អនុលោមតាមមាត្រា ១ នៃអនុសញ្ញា ១០០ នៃអង្គការការងារអន្តរជាតិ ប្រាក់រង្វាន់ មានប្រាក់ឈ្នួល ឬការបំពេញការងារជាមូលដ្ឋាន ព្រមទាំងរាល់ផលប្រយោជន៍ផ្សេងទៀតដែលត្រូវបានបង់ដោយផ្ទាល់ ឬមិនផ្ទាល់ ជាសាច់ប្រាក់ ឬជាវត្ថុ ដោយនិយោជក ទៅនិយោជិត យោងទៅលើការងាររបស់និយោជិត ។ ដោយឈរលើមូលដ្ឋាននៃមាត្រានេះ ប្រាក់ឈ្នួលគឺជាតម្លៃតបស្នងពីការងារ ឬពីសេវាដែលត្រូវបានបំពេញ ។ ការអះអាងដូច្នេះ ឈរលើមូលដ្ឋាននៅក្នុងទ្រឹស្តីនៃកិច្ចសន្យាទ្វេភាគី ដោយហេតុថា កាតព្វកិច្ចរបស់គូភាគីកិច្ចសន្យាការងារមានភាពឯករាជ្យរវាងគ្នា មានន័យថា កាតព្វកិច្ចរបស់និយោជិតដែលត្រូវបំពេញនូវតាវកាលិកការងារ រកឃើញនូវមូលដ្ឋានរបស់ខ្លួននៅក្នុងការបង់ប្រាក់ឈ្នួលដោយនិយោជក ។ ហេតុដូច្នេះ និយោជិតនឹងពុំអាចទទួលបាននូវប្រាក់ឈ្នួលនោះទេ បើសិនជាគាត់មិនទាន់បានបំពេញការងាររបស់គាត់ ។ ម៉្យាងវិញទៀត បើសិនជានិយោជិតបំពេញការងារលើសម៉ោងធ្វើការដែលមានចែងក្នុងច្បាប់ អនុសញ្ញា ឬកិច្ចសន្យាការងារ គាត់ក៏មានសិទ្ធិទទួលបាននូវប្រាក់ឈ្នួលបន្ថែមផងដែរ ។ យើងសង្កេតឃើញថា ប្រាក់ឈ្នួល និងការងារ មានចំណងទាក់ទងគ្នាដោយផ្ទាល់ : និយោជក ពុំអាចបង់ប្រាក់ឈ្នួលបាននោះទេ បើសិនជានិយោជិតបញ្ឈប់កិច្ចសន្យាការងារ ។

ប៉ុន្តែ និយមន័យនៃប្រាក់ឈ្នួលដែលត្រូវបានចាត់ទុកដូចជាតម្លៃតបស្នងពីការបំពេញការងារ ពុំអាចត្រូវបានអនុវត្តគ្រប់ករណីនោះទេ ។ និយោជិតទទួលមិនត្រឹមតែប្រាក់ឈ្នួល យោងតាមការបំពេញការងាររបស់ខ្លួននោះទេ តែគាត់ក៏អាចទទួលបាននូវប្រាក់មួយចំនួនដែលត្រូវបង់ដោយនិយោជក ដោយមូលហេតុនៃបទពិសោធន៍ការងារ សោហ៊ុយឈប់សម្រាក សោហ៊ុយជម្ងឺចិត្ត ប្រាក់រង្វាន់ឈប់សម្រាក ព្រមទាំងផលប្រយោជន៍សង្គមផ្សេងទៀត ។ ក្នុងរឿងវិវាទរវាងសណ្ឋាគារកាំបូឌីយ៉ាណា និងនិយោជិត[១៦៨] ទាក់ទងនឹងការបែងចែកប្រាក់រង្វាន់ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីសម្រេចលេខ ១១/០៣ ចុះថ្ងៃទី ២៩-០៨-២០០៣ ដោយកំណត់ថា យោងតាមមាត្រា ១០២ និង១០៣ នៃច្បាប់ការងារ ប្រាក់ទាំងអស់នេះត្រូវបានចាត់ទុកដូចជាប្រាក់ឈ្នួល ហើយនិយោជកត្រូវបង់ប្រាក់ទាំងអស់នេះឱ្យទៅនិយោជិតដែលមានទំនាក់ទំនងជាមួយនឹងអតិថិជន ។ ប៉ុន្តែ ក៏មានប្រាក់មួយចំនួនពុំត្រូវបានចាត់ទុកដូចជាប្រាក់ឈ្នួលនោះទេ ដូចជា ការព្យាបាលសុខភាព វិភាជន៍គ្រួសារតាមច្បាប់ សោហ៊ុយធ្វើដំណើរ ឬ អត្ថប្រយោជន៍ដែលផ្តល់អោយជាពិសេសចំពោះកម្មករនិយោជិតដើម្បីសម្រួលការបំពេញមុខងារ (មាត្រា ១០៣ វាក្យខណ្ឌទី ២ នៃច្បាប់ការងារ) ។ ឧទាហរណ៍ និយោជកបានប្រគល់សំបុត្រយន្តហោះនៅក្នុងក្របខណ្ឌណាមួយក្នុងចំណោមក្របខណ្ឌខាងលើនេះ សម្រាប់ចូលរួមប្រជុំនៅក្រៅប្រទេស និយោជកពុំមានការរើសអើងចំពោះក្របខណ្ឌផ្សេងទៀតនោះទេ ។

២. ការទាមទារដូចគ្នា

មាត្រា ១០៦ នៃច្បាប់ការងារចែងថា ចំពោះការងារដែលមានលក្ខខណ្ឌស្មើគ្នា ភាពប៉ិនប្រសប់ខាងវិជ្ជាជីវៈ និងផលដែលធ្វើបានស្មើគ្នា ប្រាក់ឈ្នួលត្រូវអោយស្មើគ្នាដល់កម្មករនិយោជិតទាំងអស់ដែលស្ថិតនៅក្រោមឱវាទច្បាប់នេះ ទោះមានដើមកំណើត ភេទ ឬអាយុយ៉ាងណាក៏ដោយ ។ ការបកស្រាយនៃមាត្រានាំឱ្យយើងគិតថា និយោជិតចំនួនពីរនាក់ត្រូវតែទទួលបាននូវប្រាក់ឈ្នួលស្មើគ្នា នៅក្នុងករណីដែលពួកគាត់បំពេញការងារក្នុងលក្ខខណ្ឌដូចគ្នា ដោយមានការ

[168] ក្រុមប្រឹក្សាអាជ្ញាកណ្តាល, សហគមន៍និយោជិតកម្ពុជា ប្តឹងជាមួយនឹងសណ្ឋាគារកាំបូឌីយ៉ាណា, ចុះថ្ងៃទី ២៩-០៨-២០០៣, លេខ ១១/០៣ ។

Scanned with CamScanner

ទទួលខុសត្រូវដូចគ្នា បទពិសោធន៍វិជ្ជាជីវៈដូចគ្នា ឬសញ្ញាប័ត្រដូចគ្នា ហើយគុណភាពនៃការងារដែលត្រូវបានបំពេញគឺដូចគ្នា ។ អត្ថន័យនៃមាត្រានេះមិនបានចាប់បង្ខំថា ការងារដែលត្រូវបានបំពេញដោយនិយោជិតត្រូវតែមានអត្ថសញ្ញាណដូចគ្នានោះទេ ។ អ្វីដែលសំខាន់គឺ សកម្មភាពការងារត្រូវមានលក្ខណៈប្រហាក់ប្រហែលគ្នា បង្ហាញនូវចរិតលក្ខណៈ និងគុណភាពអាចធ្វើការប្រៀបធៀបបាន ។ ប៉ុន្តែ វាជាការលំបាកក្នុងករណីដែលយើងចង់សន្និដ្ឋានចំពោះការងារខុសគ្នាអាចនាំឱ្យមានតម្លៃស្មើគ្នា ។ ហេតុដូច្នេះ កាលណាមាននិយោជិតចំនួន ២ នាក់ ប្រុស និងស្រី បំពេញការងារខុសគ្នា រួមជាមួយការបញ្ចេញខាងកម្លាំងកាយ និងស្មារតីប្រហាក់ប្រហែលគ្នា ហើយគុណភាពនៃការងារដែលពួកគាត់បំពេញមានលក្ខណៈប្រហាក់ប្រហែលគ្នា សំណួរសួរថា តើការងារដែលត្រូវបានសម្រេចនោះមានតម្លៃដូចគ្នាដែរឬទេ ? ហើយថា តើប្រាក់ឈ្នួលដែលត្រូវបង់ឱ្យទៅពួកគាត់ស្មើគ្នាដែរឬទេ ? តាមមាត្រា ១០៦ នៃច្បាប់ការងារ បង្កើតនូវលក្ខខណ្ឌសំខាន់ៗ បីយ៉ាងគឺ : លក្ខខណ្ឌការងារស្មើគ្នា, ភាពប៉ិនប្រសប់ខាងវិជ្ជាជីវៈ និងផលដែលធ្វើបានស្មើគ្នា ។ ហេតុដូច្នេះ ការប្រៀបធៀបរវាងការងារពីរខុសគ្នាអាចត្រូវបានឯកភាពតាមន័យគតិយុត្ត ។ ម៉្យាងវិញទៀត ដើម្បីឱ្យការវាយតម្លៃការងារត្រូវបានធ្វើឡើងដោយគ្មានការរើសអើង វាជាការចាំបាច់ដែលលក្ខណៈវិជ្ជាជីវៈ, លក្ខណៈនៃការចាត់ថ្នាក់ និងលក្ខណៈនៃការបង្ហាញវិជ្ជាជីវៈ ត្រូវបានធ្វើឡើងរួមគ្នា ចំពោះគ្រប់និយោជិតទាំងអស់ ដោយហេតុថា ប្រាក់ឈ្នួលត្រូវបានកំណត់ដោយយោងតាមលក្ខណៈវិជ្ជាជីវៈ ។ ប៉ុន្តែ លក្ខណៈវិជ្ជាជីវៈ នេះត្រូវបានកំណត់អាស្រ័យតាមភាពប៉ិនប្រសប់ខាងវិជ្ជាជីវៈរបស់និយោជិតទាំងអស់ ។ តាមពិត អនុសញ្ញារួម ឬបើពុំមានទេនោះ និយោជកដែលជាអ្នកកំណត់អំពីមេគុណតាមឋានានុក្រមរវាងនិយោជិត និងធាតុផ្សំនៃប្រាក់ឈ្នួលដែលត្រូវបានអនុវត្តនៅក្នុងលក្ខណៈខាងវិជ្ជាជីវៈ ។ ដើម្បីចៀសវាងការរើសអើង យើងពុំត្រូវបែងចែងរវាងបុរស និងនារីនោះទេ ។ ម៉្យាងវិញទៀត ទាក់ទងនឹងវិវាទស្តីពីការវាយតម្លៃការងារ ដើម្បីដឹងថា តើមានតម្លៃស្មើគ្នា ឬគ្មាន ចៅក្រមជាអ្នកមានអំណាចឆន្ទានុសិទ្ធិ ។ នៅក្នុងករណីនេះ បញ្ហាទាក់ទងនឹងអង្គហេតុ មានន័យថា ចៅក្រម ឬអាជ្ញាកណ្តាលត្រូវធ្វើការប្រៀបធៀបការងារទាំងនោះ ដោយយោងតាមសមត្ថភាពខាងរូបកាយ ខាងស្មារតី បទពិសោធន៍វិជ្ជាជីវៈ កម្រិតនៃការទទួលខុសត្រូវ ។ល។ ក្នុងករណីនេះ យើងមានការខ្វះខាតនូវលទ្ធិ យុត្តសាស្ត្រ[១៦៩] និងតុលាការមានជំនាញសមត្ថកិច្ចក្នុងវិស័យនេះ ។ បែបបទ និងវិធីសាស្ត្រនៃការវាយតម្លៃការងារ គឺជាមុខងារមួយដ៏លំបាកដែលត្រូវបានប្រគល់ឱ្យទៅតុលាការនីតិរួម (មាត្រា ៣៨៥ នៃច្បាប់ការងារ) ឬឱ្យទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងករណីដែលការសម្រុះសម្រួលគ្នារវាងគូភាគីត្រូវទទួលបរាជ័យ (មាត្រា ៣០៩ នៃច្បាប់ការងារ) ។

B. *អត្ថន័យនៃគោលការណ៍*

កម្មវត្ថុចុងក្រោយនៃគោលការណ៍ដែលត្រូវបានលើកឡើង គឺការហាមឃាត់ការរើសអើងលើប្រាក់ឈ្នួលរវាងនិយោជិតដែលបំពេញការងារដូចគ្នា ឬការងារដែលមានតម្លៃស្មើគ្នា ឬប្រហាក់ប្រហែលគ្នា ។ យើងគួរកត់សំគាល់ថា

---

[១៦៩] ក្នុងចំណុចនេះសូមមើល : "*សេចក្តីផ្តើមនៃនីតិកម្ពុជា*" ដោយអ្នកស្រី ចាំង ស៊ីណាត, លោក កាន ច័ន្ទមេត្តា, លោក កើត រិទ្ធ, លោក តេង-ច័ន្ទ សង្ហារ, លោក ឡូអ៊ីក អាវីឡាលីដា, កញ្ញា បេអាទ្រីស បាលីវ៉ែ ក្រោមការដឹកនាំការិយាល័យស្រាវជ្រាវនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងលោក ដេនី សាំម៉ារី ព្រមទាំងលោក ម៉ូរីស ហ្គាយ៉ា, ប្រទេសកម្ពុជា, ២០០៥, ទំព័រ ៥៧ និងបន្តបន្ទាប់ ។

Scanned with CamScanner

ការរើសអើងត្រូវបានកំណត់និយមន័យនៅក្នុងនីតិអន្តរជាតិ ដោយអនុសញ្ញា ១១១ នៃអង្គការពលកម្មអន្តរជាតិ ទាក់ទងនឹងការងារ និងវិជ្ជាជីវៈ ដែលត្រូវបានផ្តល់សច្ចាប័នដោយកម្ពុជានៅឆ្នាំ ១៩៩៩ ។ មាត្រា ១២ នៃច្បាប់ការងារ ចែងជានិយមន័យដូចគ្នានឹងអនុសញ្ញាខាងលើដែរ ដោយហាមឃាត់ចំពោះនិយោជកក្នុងការប្រកាន់យកនូវពូជសាសន៍ ពណ៌-សម្បុរ ភេទ មតិនយោបាយ ដើមកំណើតសង្គម ការចូលជាសមាជិកសហជីពកម្មករនិយោជិត ឬការធ្វើសកម្មភាពក្នុងសហជីព (...) ដើម្បីចេញសេចក្តីសម្រេចទាក់ទងនឹងការទទួលចូលបម្រើការងារ ប្រាក់រង្វាន់ ឬផលប្រយោជន៍សង្គមផ្សេងៗទៀត ។ លើសពីនេះទៀត ចំពោះកម្មករនិយោជិតម្តងម្កាល យោងតាមមាត្រា ១០ នៃច្បាប់ការងារខាងលើ ពួកគាត់ស្ថិតនៅក្រោមវិធាន មានកាតព្វកិច្ច និងមានសិទ្ធិដូចគ្នានឹងកម្មករនិយោជិតជាប់លាប់ លើកលែងតែមានខ សន្យាដោយឡែកពីនេះ ។ ហេតុដូច្នេះ យើងអាចលើកឡើងនូវករណីធំៗ បីយ៉ាងនៃការមិនរើសអើងនេះ គឺទាក់ទងនឹងនិយោជិត, ការអនុវត្តសកម្មភាពមួយចំនួនដោយនិយោជិត និងប្រភេទកិច្ចសន្យាដែលត្រូវបានចុះដោយនិយោជិត ។

ករណីទី ១ និងទី ២ ទាក់ទងជាអាទិ៍ ពូជសាសន៍ ភេទ សាសនា មតិនយោបាយ ដើមកំណើតសង្គម ការចូលជាសមាជិកសហជីពកម្មករនិយោជិត ឬការធ្វើសកម្មភាពក្នុងសហជីព ។ ហេតុដូច្នេះ និយោជកពុំអាចផ្តល់ប្រាក់រង្វាន់ ឬផ្តល់នូវផលប្រយោជន៍សង្គមមួយចំនួនឱ្យទៅនិយោជិតខុសៗគ្នា អាស្រ័យថា តើគាត់គឺជាបុរស ឬស្ត្រី ជនជាតិបរទេស ឬខ្មែរ ក្នុងករណីដែលការងារបំពេញនោះមានលក្ខណៈប្រហាក់ប្រហែលគ្នា ឬដូចគ្នា យោងតាមភាពប៉ិនប្រសប់ ។ ម៉្យាងទៀត ក្រៅពីការហាមឃាត់ដែលមានចែងក្នុងមាត្រា ១២, មាត្រា ២៧៩ នៃច្បាប់ដដែល ក៏បានហាមឃាត់ផងដែរចំពោះនិយោជកទាំងអស់ពុំត្រូវប្រកាន់យកការចូលជាសមាជិកសហជីពកម្មករនិយោជិត ឬការធ្វើសកម្មភាព ក្នុងសហជីព ដើម្បីចេញសេចក្តីសម្រេចទាក់ទងនឹងការទទួលបម្រើការងារ ឬប្រាក់រង្វាន់នោះទេ ។ ករណីដែលទាក់ទងនឹងការរើសអើងចំពោះសកម្មភាពសហជីព ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយយោងតាមមាត្រា ២៩៣ នៃច្បាប់ការងារ បានសម្រេចថា ការព្យួរកិច្ចសន្យាការងាររបស់តំណាងនិយោជិត និងសហជីព ដោយគ្មានកំណត់រយៈពេលត្រូវតែមានការឯកភាពពីអធិការកិច្ចការងារ[១៧០] ។ គ្រប់វិធានការទាំងអស់ដែលត្រូវបានធ្វើឡើងដោយនិយោជក ដោយផ្ទុយនឹងបទប្បញ្ញត្តិនេះ ត្រូវបានចាត់ទុកដូចជាការរំលោភបំពាន ហើយនាំឱ្យមានការសងសោហ៊ុយការខូចខាត ព្រមទាំងអាចធ្វើជាកម្មវត្ថុនៃការដាក់ទណ្ឌកម្មខាងផ្នែកព្រហ្មទណ្ឌ ។

ចំពោះករណីទី ៣ ទាក់ទងនឹងប្រភេទកិច្ចសន្យាការងារដែលត្រូវបានបំពេញដោយនិយោជិត ច្បាប់ការងារកម្ពុជាពុំបានចែងឱ្យបានច្បាស់អំពីការផ្តល់ប្រាក់រង្វាន់ស្មើគ្នារវាងនិយោជិត ដែលភ្ជាប់ដោយកិច្ចសន្យាការងារមានរយៈពេលកំណត់ ឬមានរយៈពេលមិនកំណត់នោះទេ ឬការងារពេញម៉ោង ឬការងារដោយផ្នែក ។ ប៉ុន្តែ សមភាពរវាងនិយោជិត

---

[១៧០] ក្រុមប្រឹក្សាអាជ្ញាកណ្តាល, Cambodian Labor Union Federation (CLUF) et Free Union of Khmers workers c/ Ho Hing Garment ចុះថ្ងៃទី ១១-១១-២០០៣ លេខ ១៧/០៣ និង ១៨/០៣ ។ ក្នុងរឿងវិវាទនេះ និយោជកបានព្យួរការងាររបស់តំណាងនិយោជិតចំនួន ពីរូប ដោយគ្មានការអនុញ្ញាតពីអធិការកិច្ច និងគ្មានរយៈពេលកំណត់ ។ ប៉ុន្តែ មាត្រា ២៩៣ នៃច្បាប់ការងារ ពុំមានលក្ខណៈច្បាស់លាស់ស្តីពីចំណុចនេះទេ ដោយហេតុថា មាត្រានេះបានហាមឃាត់ចំពោះតែនិយោជកក្នុងការបញ្ឈប់ ឬផ្ទាស់ប្តូរនិយោជិតទាំងនេះដោយគ្មានការអនុញ្ញាតពីអធិការកិច្ចការងារប៉ុណ្ណោះ ប៉ុន្តែ គ្មានចែងអ្វីទាំងអស់ ចំពោះសម្មតិកម្មនៃការព្យួរការងារនេះ ។ ប៉ុន្តែ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពុំបានរារែកក្នុងការចាត់ទុកទង្វើនេះ ដូចជាការផ្ទេរ ឬការផ្ទាស់ប្តូរការងារ ដែលត្រូវតែមានការអនុញ្ញាតពីអធិការកិច្ចការងារនោះទេ ។

Scanned with CamScanner

អាចត្រូវបានរកឃើញតាមរយៈការអនុវត្តជារួមនូវមាត្រា ១០ និងមាត្រា ៩ នៃច្បាប់ដដែល ទោះបីជាមាត្រាទាំងនោះប្រើពាក្យ "*កម្មករនិយោជិតម្តងម្កាល និងកម្មករនិយោជិតជាប់លាប់*" ក៏ដោយ ។

ហេតុដូច្នេះ នៅពេលណាដែលការងារមានតម្លៃស្មើគ្នា ប្រាក់ឈ្នួលក៏ត្រូវតែស្មើគ្នាផងដែរ បើពុំនោះសោត វានឹងត្រូវបានចាត់ទុកជាការរើសអើង ។

II. ការអនុវត្តគោលការណ៍

គោលការណ៍សមភាពក្នុងការបានទទួលប្រាក់រង្វាន់រវាងនិយោជិតត្រូវបានធានាកាន់តែច្បាស់បន្តិចម្តងៗ ។ ដើម្បីឱ្យគោលការណ៍នេះទទួលបានទូវការធានាដោយមានប្រសិទ្ធិភាព ការមិនគោរពទូវគោលការណ៍នេះ នាំឱ្យមានការដាក់ទណ្ឌកម្មយ៉ាងតឹងរឹង (A) ។ ប៉ុន្តែ គោលការណ៍នេះ ពុំមានកម្មវត្ថុធ្វើឱ្យមានសមភាព និងពុំបានហាមឃាត់ទូវភាពខុសៗគ្នានោះដែរ ។ ការលើកលែងចំពោះគោលការណ៍នេះត្រូវបានធ្វើឡើងយោងទៅលើយុត្តិកម្មវត្ថុវិស័យ (B) ។

A. ទណ្ឌកម្ម និងសកម្មភាពរើសអើង :

មានករណីមួយចំនួន ការរើសអើងទៅលើប្រាក់ឈ្នួលកើតចេញមកពីសេចក្តីចែងក្នុងកិច្ចសន្យាការងារ អនុ-សញ្ញារួម បទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស ដោយយោងទៅលើមូលហេតុខុសច្បាស់មួយចំនួន ។ ក្នុងករណីនេះ សេចក្តីចែងនេះត្រូវបានចាត់ទុកជាមោឃៈ ។ យើងគួរកត់សម្គាល់ថា អ្នកតាក់តែងច្បាប់ការងារ ពុំបានចែងដោយផ្តាល់ទៅលើរាល់លទ្ធផលដែលអាចកើតចេញពីសេចក្តីចែងដែលមានការរើសអើងដែលមានក្នុងអនុសញ្ញា កិច្ចសន្យាការងារ សេចក្តីសម្រេចជាឯកតោភាគីរបស់និយោជកនោះទេ ។ល។ មាត្រា ១៣ នៃច្បាប់ការងារ ដែលទាក់ទងនឹងសេចក្តីបង្គាប់បញ្ជាចែងថា បទប្បញ្ញត្តិទាំងឡាយនៃច្បាប់ការងារនេះ មានលក្ខណៈជាសេចក្តីបង្គាប់ជាសាធារណៈ វ៉ើរលែងតែមានបដិប-ញ្ញត្តិបញ្ជាក់ច្បាស់ ។ ដូច្នេះ វិធានទាំងអស់ដែលកើតឡើងដោយការសម្រេចចិត្តជាឯកតោភាគីក្តី ដោយកិច្ចសន្យា ឬអនុសញ្ញាណាមួយក្តី ដែលមិនគោរពបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ ឬដែលមិនគោរពអត្ថបទទាំងឡាយដែលណែនាំអនុវត្តច្បាប់នេះ ត្រូវទុកជាមោឃៈដោយពេញច្បាប់ ។ មាត្រានេះអាចប្រើប្រាស់ដើម្បីធ្វើជាមូលដ្ឋាននៃការប្រកាសមោឃភាពទូវាល់ខសន្យាដែលមានការរើសអើង ។ ប៉ុន្តែ ច្បាប់ការងារពុំបានចែងអំពីអានុភាពនៃការប្រកាសមោឃភាពកិច្ចនេះនៅចំពោះមុខជនរងគ្រោះពីការរើសអើង ដែលជានិយោជិតនោះទេ ។ ឧទាហរណ៍ នៅក្នុងករណីដែលសេចក្តីសម្រេចរបស់និយោជក ដែលយល់ព្រមប្រគល់ការងារស្មើគ្នា ប្រាក់រង្វាន់ស្មើគ្នា ឱ្យទៅនិយោជិតម្នាក់ ឬក្រុមនិយោជិតមួយក្រុម មានផលប្រយោជន៍តិចជាងនិយោជិតម្នាក់ទៀត ឬក្រុមនិយោជិតផ្សេងទៀត សំណួរសួរថា តើប្រាក់រង្វាន់ដែលមានតម្លៃលើសនោះ ត្រូវបានជំនួសដោយពេញលេញទៅនឹងប្រាក់រង្វាន់ដែលធ្វើជាកម្មវត្ថុនៃការប្រកាសមោឃភាពដែរឬទេ ? ចម្លើយទៅនឹងសំណួរនេះ ហាក់បីដូចជាពុំសូវច្បាស់លាស់នោះទេ ដោយហេតុថា មាត្រា ៩៨ វាក្យខណ្ឌ ២ នៃច្បាប់ការងារឯកភាពតែក្នុងករណីមានការជំនួសដោយឯកឯងសម្រាប់សេចក្តីចែងនៃកិច្ចសន្យាការងារ ដែលផ្តល់ភាពពេញចិត្តតិចជាងអ្វីដែលមានចែងក្នុងអនុសញ្ញារួមប៉ុណ្ណោះ ។

Scanned with CamScanner

ការប្រកាសមោឃភាពនូវសេចក្តីចែងដែលមានការរើសអើងពុំមានលក្ខណៈគ្រប់គ្រាន់នោះទេ ចារីប្រព្រឹត្តនូវការរើសអើងនោះត្រូវតែផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌថែមទៀត ។ ដើម្បីឱ្យមានទណ្ឌកម្មនេះ យើងត្រូវបានដាក់ពាក្យបណ្តឹងទៅតុលាការ និងត្រូវបង្ហាញភស្តុតាងអំពីការរើសអើងនេះ ។ ពាក្យបណ្តឹងទៅតុលាការអាចត្រូវបានធ្វើឡើងដោយនិយោជិតម្នាក់ ឬច្រើននាក់ ឬសហជីពជាតំណាងនៅក្នុងសហគ្រាស ។ និយោជិតជនរងគ្រោះជួបប្រទះនូវផលវិបាកទាក់ទងនឹងការបង្ហាញភស្តុតាង ។ ក្នុងករណីដែលកិច្ចសន្យាការងារស្ថិតនៅក្រោមវិធាននៃនីតិរូម (មាត្រា ៦៤ នៃច្បាប់ការងារ) ភស្តុតាងជាគោលការណ៍ធ្លាក់បន្ទុកទៅលើដើមបណ្តឹង[១៧១] មានន័យថា និយោជិតត្រូវបង្ហាញភស្តុតាងថាកាត់ទទួលបានប្រាក់ឈ្នួលទាបជាងសម្រាប់ការងារដូចគ្នា ឬមានតម្លៃដូចគ្នា ។ ប៉ុន្តែ តួនាទីនេះមានលក្ខណៈសុក្រស្មាញក្នុងបរិបទនៅប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ លើកលែងតែមានការចូលរួមយ៉ាងសកម្មពីអធិការកិច្ចការងារ តំណាងនិយោជិត សហជីព សហការីរបស់និយោជិត ឬចៅក្រម ។ ម៉្យាងវិញទៀត វាអាចកើតឡើងថា ភាពសង្ស័យទៅលើអសមភាពនោះត្រូវបានកើតឡើង ។ យោងតាមសេចក្តីសម្រេចរបស់តុលាការកំពូលកម្ពុជា ភស្តុតាងនេះអាចទទួលយកបាន ដើម្បីជំទាស់ប្រឆាំងទៅនឹងបុគ្គលដែលមានបន្ទុកក្នុងការបង្ហាញភស្តុតាង[១៧២] ។ បើសិនជាភស្តុតាងត្រូវបានបង្ហាញឡើង ទណ្ឌកម្មរដ្ឋប្បវេណី និងព្រហ្មទណ្ឌអាចត្រូវបានធ្វើឡើងចំពោះចារីនៃការរើសអើងនេះ ។ ដូចមានការបញ្ជាក់ក្នុងមាត្រា ៣៦៣ នៃច្បាប់ការងារ ដែលបានដាក់ទណ្ឌកម្ម ដោយត្រូវពិន័យជាប្រាក់ស្មើរនឹងសាមសិបមួយថ្ងៃ ទៅហុកសិបថ្ងៃ នៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃ គ្រប់ចារីនៃបទល្មើសដែលមានចែងក្នុងមាត្រា ១០៦ នៃច្បាប់ដដែលនេះ ។

B. បដិបញ្ញត្តិចំពោះគោលការណ៍

គោលការណ៍សមភាពនេះពុំបានលុបចោលនូវគុណភាពរបស់បុគ្គលនៅក្នុងកិច្ចសន្យាការងារនោះទេ ។ និយោជក ក្នុងនាមជាប្រធានសហគ្រាស អាចកំណត់ដោយសេរីនូវប្រភេទនៃប្រាក់រង្វាន់ខុសៗគ្នា ដោយយោងទៅលើសមត្ថភាពខុសៗគ្នានៃនិយោជិតម្នាក់ៗ ។ ប៉ុន្តែ សេរីភាពនេះអាចនាំឱ្យមានការប៉ះពាល់ទៅដល់គោលការណ៍គ្មានភាពរើសអើង នៅពេលដែលយើងអាចរកបាននូវភាពខុសគ្នានៃសមត្ថភាពរវាងនិយោជិត ។ បញ្ហានេះមានលក្ខណៈសុក្រស្មាញដោយហេតុថា ការវាយតម្លៃទៅលើតម្លៃនៃនិយោជិតជាធម្មតា គឺជាសិទ្ធិអំណាចរបស់និយោជក ។ ក្នុងករណីមានវិវាទចៅក្រមអាចអនុវត្តនូវសញ្ញាណនៃការរំលោភអំណាច និងការរើសអើងខុសច្បាប់ បន្ទាប់ពីមានការវិភាគមានលក្ខណៈវត្ថុវិស័យទៅលើស្ថានភាព ។ ហេតុដូច្នេះ កំណត់ហេតុសាមញ្ញាមួយទៅលើភាពខុសគ្នានៃប្រាក់រង្វាន់រវាងនិយោជិតពីរនាក់ ឬនិយោជិតពីរក្រុម បុរស និងស្ត្រី ពុំបានអនុញ្ញាតជានិច្ចជាកាលឱ្យយើងអាចធ្វើការសន្និដ្ឋានឱ្យមានការរើសអើងនោះទេ ។ កត្តាវត្ថុវិស័យ និងខាងក្រៅ ចំពោះរាល់ការរើសអើងទាំងនេះ ឬរាល់ការប្រកាន់យកដោយយោងទៅលើភេទអាចត្រូវបានលើកឡើងដោយនិយោជក ដើម្បីកែតម្រូវទៅលើការប្រឆាំងដែលត្រូវបានធ្វើឡើង ។ ដូចជាករណីដែល

---

[១៧១] *Op.cite.* "*សេចក្តីផ្តើមនៃនីតិកម្ពុជា*", ទំព័រ ១០១ និងបន្តបន្ទាប់ ។

[១៧២] សេចក្តីសម្រេចរបស់តុលាការកំពូលលេខ ៥៧ ចុះថ្ងៃទី ០៣-០៤-១៩៩៧, ព្រឹត្តិប័ត្រសាលដីការបស់តុលាការកំពូល លេខ ១០ ឆមាសទី ២ ទំព័រ ១៦ នៅក្នុង "សេចក្តីផ្តើមនៃនីតិកម្ពុជា" *Op.cite.* ទំព័រ ១០២ ។

Scanned with CamScanner

និយោជិតទទួលប្រាក់រង្វាន់ដោយយោងតាមចំនួនផលិត ភាពខុសគ្នានៃប្រាក់រង្វាន់អាចត្រូវបានពន្យល់បកស្រាយតាមរយៈភាពខុសគ្នារវាងលទ្ធផលឯកត្តជនរបស់និយោជិតម្នាក់ៗ ។ ម៉្យាងវិញទៀត សហគ្រាសអាចមានគ្រឹះស្ថានជាច្រើនដែលលាតសន្ធឹងនៅលើភូមិសាស្ត្រខុសៗគ្នា ។ ច្បាប់ការងារពុំបានហាមឃាត់ការចរចា និងការចុះអនុសញ្ញា ឬកិច្ចព្រមព្រៀងរួមនៅក្នុងសហគ្រាសនោះទេ ។ ហេតុដូច្នេះ កាលណាសហគ្រាស "ក" មានគ្រឹះស្ថានចំនួនពីរ មួយនៅភ្នំពេញ និងមួយទៀតនៅស្ទឹមរាប ភាពខុសគ្នានៃប្រាក់ឈ្នួល និងផលប្រយោជន៍សង្គមផ្សេងទៀត ពុំបានលេចឡើងនូវការប្រឆាំងទៅនឹងគោលការណ៍សមភាពនៃប្រាក់រង្វាន់នោះទេ ប្រសិនបើគ្រឹះស្ថានទាំងពីរនេះស្ថិតនៅក្រោមអនុសញ្ញា ឬកិច្ចព្រមព្រៀងរួមខុសគ្នា ។ ដូចគ្នាដែរ និយោជិតដែលបំពេញការងារនៅប្រទេសកម្ពុជា សម្រាប់សហគ្រាសអាមេរិកមួយ ពុំអាចទាមទារថា ប្រាក់ឈ្នួលរបស់ពួកគាត់ត្រូវមានសមភាព សម្រាប់ការងារដូចគ្នា ជាមួយនឹងនិយោជិតដែលបំពេញការងារនៅក្នុងសហគ្រាសដូចគ្នានៅសហរដ្ឋអាមេរិក ។ ការបកស្រាយពន្យល់មានលក្ខណៈសាមញ្ញ : គោលការណ៍សមភាពហាក់បីដូចជាពុំបានរាំងស្ទះ ហើយពុំបានដាក់ទណ្ឌកម្មរាល់ការប្រឆាំង ដោយគ្មានចេតនារើសអើងនោះទេ ។ ហេតុដូច្នេះ ភាពខុសគ្នានៃប្រាក់រង្វាន់រវាងសហគ្រាសពីរ ឬច្រើន ឬសាខាកូននៃសហគ្រាសតែមួយអាចបញ្ជាក់ថា ភាពខុសគ្នានៃកម្រិតជីវភាពរវាងខេត្តនីមួយៗ និងប្រទេសនីមួយៗ ។ ការប្រកាន់យកដូច្នេះ លេចឡើងនូវការឯកភាពជាមួយនឹងមាត្រា ១០៧ នៃច្បាប់ការងារកម្ពុជាឆ្នាំ ១៩៩៧[១៧៣] ។

អសមភាពនៃប្រាក់ឈ្នួល នៅតែស្ថិតនៅជាបញ្ហាចម្បង នៅក្នុងចំនាក់ចំនងការងារ ជាពិសេសនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ ដូចជាប្រទេសកម្ពុជាដែលត្រូវប្រឈមមុខនឹងបញ្ហាភាពក្រីក្រ អយុត្តិធម៌ក្នុងសង្គម ។ល។ ការជំទាស់ប្រឆាំងទៅនឹងគ្រប់រូបភាពនៃការរើសអើង អាចបង្កបង្កើតជាផល នៅពេលដែលរាជរដ្ឋាភិបាល អង្គនីតិបញ្ញត្តិ ចៅក្រម អ្នកជំនាញវិជ្ជាជីវៈច្បាប់ និងដៃគូអភិវឌ្ឍសង្គម ចូលរួមយ៉ាងសកម្ម និងម៉ឺងម៉ាត់ចំពោះបញ្ហានេះ ។

តថាខណ្ឌទី ៥ : និតិសាធារណៈ

ក. ប្រធានបទ

"ស្នើឱក្តីឆ្ងាសាទច្ឆ្ងេះឥហារ និងការឥតត្តន៍នៃនីតិអន្តរជាតិសាធារណៈ"

ខ. តំណែ : (អាន-ធីតា នភោត្តម)

បើសិនជាភាពជាក់ស្តែងដែលនិយាយថា យុត្តិសាស្ត្រជាអ្នកធ្វើឱ្យមានការវិវត្តន៍ទូទៅនៃច្បាប់ ប៉ុន្តែ យើងក៏ត្រូវតែទទួលស្គាល់ផងដែរថា ប្រព័ន្ធច្បាប់ធំៗពុំបានផ្តល់សារៈសំខាន់នៃយុត្តិសាស្ត្រដូចគ្នានោះទេ ។ នីតិអន្តរជាតិសាធារណៈជាញឹកញាប់ត្រូវបានចាត់ទុកជាសមទ្ធិផលមួយនៃការរួមបញ្ចូលគ្នានៃប្រព័ន្ធច្បាប់ខុសៗគ្នាជាច្រើន។ ហេតុដូច្នេះ យុត្តិសាស្ត្រអន្តរជាតិអាចមានឥទ្ធិពលក្នុងបណ្តាករណីខ្លះ ជាពិសេសលើការវិវត្តន៍នៃនីតិអន្តរជាតិដែលវាមានលក្ខណៈមួយជិត

[១៧៣] មាត្រា ១០៧ នៃច្បាប់ការងារចែងថា "ប្រាក់ឈ្នួលអប្បបរមាដែលត្រូវធានា ត្រូវរៀបចំឡើងដោយមិនគិតថាវិជ្ជាជីវៈណា ឬមុខរបរណាឡើយ ។ ប្រាក់ឈ្នួលអប្បបរមាដែលត្រូវធានានោះអាចប្រែប្រួលទៅតាមភូមិភាគ តាមលក្ខណៈសេដ្ឋកិច្ច ដែលសម្រាប់កំណត់លក្ខខណ្ឌជីវភាព .... ។"

Scanned with CamScanner

ស្ថិតជាមួយប្រព័ន្ធ Common law ជាងប្រព័ន្ធច្បាប់ស៊ីវិល បើទោះបីជាវាត្រូវបានបង្ហាញជាញឹកញាប់ថា តាមការពិត ការបែងចែកដូច្នេះ ពុំមានលក្ខណៈណាមួយគួរឱ្យចាប់អារម្មណ៍ដូចយើងគិត និងជឿជាក់នោះទេ ។

ហេតុដូច្នេះ ទោះបីជាសាលដីកានៃតុលាការយុត្តិធម៌អន្តរជាតិស្តីពីរឿងក្តីប្រាសាទព្រះវិហារ[174] ដែលចុះកាលបរិច្ឆេទនៅដើមទសវត្សទី ៦០ បង្ហាញនូវផលប្រយោជន៍ជាប្រវត្តិសាស្ត្រនាពេលបច្ចុប្បន្ននេះក៏ដោយ វាមានការគួរឱ្យចាប់អារម្មណ៍ដែរក្នុងការពិនិត្យទៅលើការចូលរួមរបស់វាទៅក្នុងការវិវត្តន៍នៃនីតិអន្តរជាតិសាធារណៈ បន្ទាប់ពី ៤០ ឆ្នាំក្រោយមក ។ កម្មវត្ថុនៃការសិក្សានេះពុំមែនធ្វើអត្ថាធិប្បាយលើរឿងក្តីនេះទេ អ្វីដែលត្រូវបានកើតឡើងនាអតីតកាលប៉ុន្តែ ធ្វើឱ្យយើងស្គាល់តាមរយៈការត្រលប់ពេលវេលាថយក្រោយ ប្រសិនបើសាលដីកាទាំងនេះមានលក្ខណៈគួរឱ្យកត់សម្គាល់នៅក្នុងនីតិអន្តរជាតិសាធារណៈ និងនៅក្នុងទម្រង់នៃការតាក់តែងវា ។ ហេតុដូច្នេះ ដំណាក់កាលដំបូង យើងត្រូវស្គាល់ជាបឋមអំពីប្រវត្តិនៃរឿងក្តីនេះ ។

ព្រំដែនរវាងប្រទេសថៃ និងប្រទេសកម្ពុជា ត្រូវបានកំណត់ដោយកិច្ចព្រមព្រៀងជាច្រើនដែលត្រូវបានធ្វើឡើងចាប់តាំងពីឆ្នាំ ១៨៩៣ ។ ចាប់ពីឆ្នាំ ១៩៥៤ ប្រទេសថៃ បានកាន់កាប់ប្រាសាទព្រះវិហារដោយប្រើប្រាស់នូវកងកម្លាំងទាហាន បើទោះបីជាការជំទាស់ប្រឆាំងពីភាគីកម្ពុជាក៏ដោយ ។ ប្រទេសកម្ពុជាបានស្នើសុំឱ្យមានការដកថយកងទ័ព និងទទួលស្គាល់នូវអធិបតេយ្យភាពរបស់ខ្មែរនៅក្នុងតំបន់នោះ ។ ប្រទេសថៃបានបដិសេធពុំព្រមគោរពតាមនោះទេ ប្រទេសកម្ពុជាបានដាក់ជូនរឿងវិវាទនៅចំពោះមុខតុលាការយុត្តិធម៌អន្តរជាតិ តាមរយៈពាក្យបណ្តឹងចុះថ្ងៃទី ៣០-០៩-១៩៥៩ ។ រដ្ឋាភិបាលរបស់ថៃ បានដាក់ជូននូវករណីលើកលែងជាបឋមនៃសមត្ថកិច្ចរបស់តុលាការយុត្តិធម៌អន្តរជាតិ ហើយនីតិវិធីលើអង្គសេចក្តីត្រូវបានព្យួរដោយដីកាចុះថ្ងៃទី ១០-០៦-១៩៦០ ។ វិវាទដែលទាក់ទងនឹងអធិបតេយ្យភាពតាមដែនដីបង្ហាញភ្លាមនូវដើមកំណើតពីរយ៉ាង គឺម៉្យាង នេះគឺជាលើកទី ១ ដែលរឿងក្តីរវាងបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍បានដាក់ពាក្យបណ្តឹងនៅចំពោះតុលាការយុត្តិធម៌អន្តរជាតិ និងម៉្យាងវិញទៀត គូភាគីទាំងសងខាងពុំបានឯកភាពក្នុងការតែងតាំងចៅក្រម អាដហុក ដូចដែលមាត្រា ៣១ នៃលក្ខខន្តិកៈរបស់តុលាការអន្តរជាតិ បានផ្តល់លទ្ធភាពនោះទេ ។

ក្រៅពីលក្ខណៈពិសេសទាំងពីរនេះ យើងអាចចោទជាសំណួរចំពោះឥទ្ធិពលជាក់ស្តែងនៃរឿងក្តីនេះនៅក្នុងនីតិអន្តរជាតិសាធារណៈ តើមានអ្វីសេសសល់ខ្លះ បន្ទាប់ពីការបញ្ចប់សាលដីកាទាំងពីរនេះ ? វាជាជម្លោះរវាងរដ្ឋនិងរដ្ឋដែលក្នុងនោះផលប្រយោជន៍នៅលើឆាកអន្តរជាតិពុំសូវមានសារៈសំខាន់នោះទេ បើសិនជាយើងពិនិត្យទៅលើនីតិអន្តរជាតិវិជ្ជមាន ។ តើរឿងក្តីបែបបុរាណទាក់ទងនឹងការកំណត់ព្រំដែនដីគោកនេះ ចូលរួមក្នុងការវិវត្តនីតិអន្តរជាតិសាធារណៈយ៉ាងដូចម្តេចខ្លះ ?

នីតិអន្តរជាតិមានគោលដៅគ្រប់គ្រងទៅលើទំនាក់ទំនងរវាងរដ្ឋអធិបតេយ្យ ហេតុដូច្នេះ វាគឺជាសមត្ថកិច្ចរបស់តុលាការយុត្តិធម៌អន្តរជាតិដែលត្រូវការពារគោលការណ៍ត្រឹមដែលទាក់ទងនឹងអធិបតេយ្យភាពនេះ ។ ប៉ុន្តែ គ្មានវិស័យណាមួយសំដែងនូវសារៈសំខាន់នៃគោលការណ៍ខាងលើនេះប្រសើរជាងសារៈសំខាន់នៃការកំណត់ព្រំដែននោះទេ ជាពិ

[174] C.I.J., *Affaire du temple Préah Vihéar (Cambodge c. Thaïlande)*, Exceptions préliminaires, Arrêt du 26 mai 1961, Recueil 1961, p. 17. Fond, Arrêt du 15 juin 1962, Recueil 1962, p. 6.

Scanned with CamScanner

សេសដែនគោក ។ ចុងបញ្ចប់ រឿងក្តីប្រាសាទព្រះវិហារបង្ហាញនូវរូបភាពតាមបែបបុរាណនូវអ្វីដែលនីតិអន្តរជាតិសាធារណៈត្រូវបានបង្កើតឡើង ដោយចូលរួមម៉្យាងទៅក្នុងការការពារអធិបតេយ្យភាពរបស់រដ្ឋ និងម៉្យាងទៀតទៅក្នុងការចង់ដឹងអំពីលទ្ធភាពក្នុងការបង្ហាញឆន្ទៈ ។

ការចោទជាសំណួរចំពោះអានុភាពនៃយុត្តិសាស្ត្រទៅលើនីតិអន្តរជាតិសាធារណៈ ណែនាំយើងជាចាំបាច់ទៅក្នុងការសិក្សានូវអ្វីដែលលទ្ធិត្រូវបានទទួលយកនៅក្នុងសាលដីកាទាំងពីរនេះ ស្តីពីផ្នែកដែលមានលក្ខណៈបុរាណនៃនីតិអន្តរជាតិសាធារណៈ ។ រឿងក្តីប្រាសាទព្រះវិហារបានបញ្ជាក់ថា តើនីតិវិធីនៃការកំណត់ព្រំដែនតាមផ្លូវតុលាការមានអ្វីខ្លះ ? ដែលត្រូវបានរអុមត័តដោយតុលាការអចិន្ត្រៃយ៍នៃយុត្តធម៌អន្តរជាតិ និងការដោះស្រាយតាមផ្លូវអាជ្ញាកណ្តាល ។ ប៉ុន្តែដោយប្រគល់នូវឧត្តមានុភាពក្នុងន័យគតិយុត្ត រឿងក្តីនេះបង្ហាញនូវការកំណត់របស់វាចំពោះការការពារឆន្ទៈអធិបតេយ្យភាព និងស្ថេរភាពខាងព្រំដែន ។

ក៏ប៉ុន្តែ បើសិនជារឿងក្តីនេះលើកឡើងភ្លាមៗនូវភាពគ្មានមនសិកាជារួមទៅលើបញ្ហានៃការកំណត់ព្រំដែនដីគោក ទិដ្ឋភាពនៃការបង្កើតថ្មីរបស់វាត្រូវបានស្តែងឡើងជាមួយនឹងភាពធ្ងន់ធ្ងរនៅក្នុងវិស័យនៃការការពារឆន្ទៈ ។ តាមអង្គហេតុ តាមរយៈយន្តការដែលត្រូវបានទទួលស្គាល់ និងឯកភាពក្នុងការកំណត់ព្រំដែនតាមផ្លូវតុលាការ រឿងក្តីនេះនឹងមានការកត់ចំណាំជាពិសេសទៅក្នុងការវិវត្តន៍នៃនីតិ តាមរយៈការចូលរួមក្នុងការបង្កើតទ្រឹស្តីនៃការភ័ន្តច្រឡំដែលជាអធមិនៃការបង្ហាញឆន្ទៈ នៅក្នុងនីតិអន្តរជាតិសាធារណៈ ។ យើងធ្វើការបង្រួមការសិក្សារបស់យើងត្រឹមតែទិដ្ឋភាពនេះប៉ុណ្ណោះ[១៨៥] ។

ទ្រឹស្តីនៃអធមិនៃការបង្ហាញឆន្ទៈ ដែលមានលក្ខណៈចាំបាច់ក្នុងនីតិជាតិ ត្រូវបានឯកភាពបន្តិចម្តងៗនៅក្នុងនីតិអន្តរជាតិ និងនៅក្នុងការផ្តល់តម្លៃនៃការរៀបចំ ។ ខ្លឹមសារនៃរឿងក្តីប្រាសាទព្រះវិហារមានគោលដៅក្នុងការពង្រឹងបទពិសោធន៍ខាងផ្នែកទ្រឹស្តី និងយុត្តិសាស្ត្រក្នុងមុខវិជ្ជានេះ (I) និងម៉្យាងវិញទៀត ចូលរួមក្នុងការកំណត់អំពីរបបគតិយុត្តនៃការភ័ន្តច្រឡំនៅក្នុងនីតិអន្តរជាតិជំនាន (II) ។

I. ការភ័ន្តច្រឡំ : ទ្រឹស្តីដែលបានទទួលស្គាល់ដោយនីតិអន្តរជាតិ

ទ្រឹស្តីនៃអធមិនៃការបង្ហាញឆន្ទៈ បានលើកឡើងជាបឋមនូវផលវិបាកខាងផ្នែកលទ្ធិជាច្រើន (A) មុននឹងឈានចូលទៅដល់បញ្ហាមួយចំនួននៅក្នុងយុត្តិសាស្ត្រអន្តរជាតិ (B) ។

A. ការភ័ន្តច្រឡំនៅក្នុងនីតិអន្តរជាតិសាធារណៈ: ទ្រឹស្តីដែលត្រូវបានទទួលស្គាល់បន្តិចម្តងៗដោយលទ្ធិ :

ជាយូរលង់មកហើយ លទ្ធិត្រូវបានខ្វែងគំនិតគ្នាចំពោះការទទួលស្គាល់ទ្រឹស្តីនៃអធមិនៃការបង្ហាញឆន្ទៈនៅក្នុងនីតិអន្តរជាតិសាធារណៈ ។ ប៉ុន្តែ ទ្រឹស្តីនៃអធមិនៃការបង្ហាញឆន្ទៈមានលក្ខណៈមួយចាំបាច់នៅក្នុងនីតិឯកជន ។ ការ

---

[១៨៥] ប្រធានបទខាងលើនេះ អាចត្រូវបានបង្ហាញឡើងមានលក្ខណៈត្រប់ត្រាន់ជាងនេះ ប្រសិនបើយើងលើកឡើងនៅក្នុងផ្នែកទី ១ អំពីការចូលរួមនៃរឿងវិវាទនេះទៅក្នុងទ្រឹស្តីនៃការភ័ន្តច្រឡំនៅក្នុងនីតិអន្តរជាតិ និងនៅក្នុងផ្នែកទី ២ ការបានាអះអាងនូវភាពជាច់ខាងនៃស្ថេរភាពខាងព្រំដែនក្នុងរឿងវិវាទនៃការកំណត់ព្រំដែន ។ ក្នុងក្របខណ្ឌនៃស្បៃវែកា ដែលមានគោលដៅបង្ហាញទៅដល់និស្សិត ដើម្បីស្គាល់អំពីវិធីសាស្ត្រ យ៉ាងដូច្នេះ វាជាការចាប់អារម្មណ៍ដែលយើងគួរគោរពតាមទំរង់នៃប្រធានបទបរិមាធិប្បាយគតិយុត្ត ។

Scanned with CamScanner

ទទួលស្គាល់ទ្រឹស្តីនេះនៅក្នុងនីតិអន្តរជាតិមានលក្ខណៈមួយឃ្លាតឆ្ងាយពីធម្មជាតិរបស់វា ។ ផលវិបាកចំបងសំដៅជាពិសេសទៅក្នុងការបញ្ចូលទ្រឹស្តីបុរាណនៃនីតិឯកជន នៅក្នុងប្រព័ន្ធនីតិដោយឡែកនៃនីតិអន្តរជាតិ ។ មានចរន្ត បីបែប ត្រូវបានប្រឆាំងគ្នានៅក្នុងវិស័យនេះ ។ មានអក្ខនិពន្ធមួយចំនួន ដូចជាលោក Lauterpacht (1927) ឬសាស្ត្រចារ្យ Le fur (1934) បានបង្ហាញនូវភាពចាំបាច់នៃការបញ្ចូលដោយផ្ទាល់នូវទ្រឹស្តីនៃនីតិជាតិក្នុងបទដ្ឋាននៃនីតិអន្តរជាតិ ។ ពួកគាត់ពុំបានបដិសេធនូវបណ្តាចរិតលក្ខណៈដោយឡែកនៃនីតិអន្តរជាតិ បើធ្យេបទៅនឹងនីតិជាតិនោះទេ ។ ផ្ទុយពីគំនិតទាំងនេះ លោក Charles Rousseau បានចាត់ទុកការបញ្ចូលដ៏គ្រោះថ្នាក់នេះ ចំពោះស្ថេរភាពនៃសន្ធិសញ្ញា ដោយហេតុថាអវត្តមាននៃស្ថាប័នជាន់ខ្ពស់ក្នុងនីតិអន្តរជាតិសាធារណៈ ។ ម៉្យាងវិញទៀត ភាពស្មុគ្រស្មាញនៃនីតិវិធីនៃការចុះសន្ធិ-សញ្ញា អាចច្បៀសផុតពីរាល់គ្រោះថ្នាក់ទាំងឡាយស្តីពីអធមិនៃការបង្ហាញឆន្ទៈនេះ ។ ដូច្នេះ ករណីភ័ន្តច្រឡំ ឬការបន្លំបង្កើតបានជាសម្មតិកម្មនៅតាមសាលា ប៉ុន្តែ ការបង្ខិតបង្ខំអាចត្រូវបានដោះស្រាយតែតាមរយៈការព្រមព្រៀងរបស់ភាគីតែប៉ុណ្ណោះ យោងតាមគំនិតរបស់លោកខាងលើ ។

ក្រៅពីគំនិតប្រឆាំងខាងលើនេះ មតិយោបល់ទី ៣ បានលើកឡើងនូវភាពចាំបាច់ក្នុងការគិតគូដល់លក្ខណៈដោយឡែកនៃប្រព័ន្ធគតិយុត្តអន្តរជាតិ ចំពោះការបញ្ចូលទ្រឹស្តីអធមិនៃការបង្ហាញឆន្ទៈ ។ មានអំណះអំណាងពីរ ធ្វើជាមូលដ្ឋាននៃសារណានេះ ។ ទី ១ សន្ធិសញ្ញា ពុំអាចប្រដូចទៅនឹងកិច្ចសន្យាដ៏សាមញ្ញមួយ យោងតាមនីតិជាតិនោះទេ ដូច្នេះ ការបញ្ចូលដ៏សាមញ្ញនៃទ្រឹស្តីអធមិនៃការបង្ហាញឆន្ទៈពុំអាចត្រូវបានធ្វើឡើងនោះទេ ។ ទី ២ ប្រព័ន្ធនីតិអន្តរជាតិពុំអាចអនុវត្តបណ្តឹងនិយ័តភាពនៃអាជ្ញាធរយុត្តាធិការដ៏ត្រឹមត្រូវនោះទេ ។ ការបញ្ចូលទ្រឹស្តីអធមិនៃការបង្ហាញឆន្ទៈអាចនាំឱ្យមានការរំលោភបំពាន និងមានអសន្តិសុខគតិយុត្តសម្រាប់បណ្តារដ្ឋនានា ។ ទោះបីជាមានការទទួលស្គាល់នូវផលប្រយោជន៍នៃទ្រឹស្តីអធមិនៃការបង្ហាញឆន្ទៈនៅក្នុងនីតិអន្តរជាតិក៏ដោយ ចរន្តគំនិតនេះចង់សម្របសម្រួលទ្រឹស្តីនៃនីតិឯកជនទៅក្នុងចរិតលក្ខណៈនៃប្រព័ន្ធនីតិអន្តរជាតិ ។

សេចក្តីខាងលើនេះ វាហាក់បីដូចជា ជំហរកណ្តាលមួយត្រូវបានផ្តល់ឧត្តមានុភាពដោយនីតិវិជ្ជមាន ។ ដោយពុំចាំបាច់អនុម័តយកទ្រឹស្តីនៃនីតិឯកជន យើងទទួលស្គាល់ថា លើកលែងតែការភ័ន្តច្រឡំមួយចំនួន ទាំងការបន្លំ និងប្រើអំពើហិង្សា ទាំងនេះអាចនាំឱ្យមានអធមិនៃការបង្ហាញឆន្ទៈ និងបណ្តាលឱ្យមានការប្រកាសមោឃភាពសន្ធិសញ្ញា ។

B. ការភ័ន្តច្រឡំនៅក្នុងនីតិអន្តរជាតិ គោលការណ៍ត្រូវបានទទួលស្គាល់ជារលីតដិបូចដោយយុត្តិសាស្ត្រ :

យុត្តិសាស្ត្រអន្តរជាតិបានគោរពតាមគោលជំហរនៃលទ្ធិកណ្តាល ។ រឿងក្តីប្រាសាទព្រះវិហារត្រូវបានចុះបញ្ជីនៅក្នុងដំណើរនេះ ។ យើងមានការចាប់អារម្មណ៍នៅក្នុងកថាខណ្ឌនេះនៃសាលដីកាទី ១ ទាក់ទងនឹងបដិបញ្ញត្តិជាដំបូងដែលបង្ហាញនូវការទទួលយកយុត្តិសាស្ត្រក្នុងមុខវិជ្ជានេះ ដោយមានលក្ខណៈគួរឱ្យប្រុងប្រយ័ត្ន ។

សាលដីកាឆ្នាំ ១៩៦១ របស់តុលាការយុត្តិធម៌អន្តរជាតិទាក់ទងនឹងប្រាសាទព្រះវិហារ ចូលរួមក្នុងការបង្កើតយុត្តិសាស្ត្រដែលត្រូវបានផ្តួចផ្តើមដោយរឿងក្តី *ម៉ាវ្រូម៉ាទីស* របស់តុលាការអចិន្ត្រៃយ៍យុត្តិធម៌អន្តរជាតិនៅឆ្នាំ ១៩២៥[១៧៦] ។ រដ្ឋាភិបាលថៃ បានលើកអំណះអំណាងអំពីការភ័ន្តច្រឡំ នៅក្នុងសេចក្តីប្រកាសរបស់ខ្លួនដោយទទួលស្គាល់

[១៧៦] C.P.J.I., *Affaire Mavrommatis*, arrêt du 26 mars 1925, série A/B, n°13, p. 31.

Scanned with CamScanner

តុលាការចុះថ្ងៃទី ២០-០៥-១៩៥០ ។ គួររំលឹកថា ប្រទេសថៃបានទទួលស្គាល់នូវសមត្ថកិច្ចយ៉ាងដាច់ខាតរបស់តុលាការអចិន្ត្រៃយ៍អន្តរជាតិ ចុះថ្ងៃទី ២០-០៩-១៩២៩ និងបន្តការយល់ព្រមរបស់ខ្លួនសាជាថ្មីនៅថ្ងៃទី ០៣-០៥-១៩៤០ សម្រាប់រយៈពេល ១០ ឆ្នាំ ។ ប៉ុន្តែ នៅឆ្នាំ ១៩៤៦ តុលាការអចិន្ត្រៃយ៍ត្រូវបានរលាយបាត់ មាត្រា ៣៦ កថាខណ្ឌ ៥ នៃលក្ខខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិបានចែងអំពីការផ្ទេរសេចក្តីប្រកាស ដែលត្រូវបានធ្វើឡើងក្រោមអានុភាពនៃលក្ខខន្តិកៈចាស់ ។ នៅថ្ងៃទី ២០-០៥-១៩៥០ ប្រទេសថៃ បានដាក់ជូនទៅអគ្គលេខាធិការដ្ឋានរបស់អង្គការសហប្រជាជាតិ នូវសេចក្តីប្រកាសទទួលស្គាល់សមត្ថកិច្ចជាថ្មីម្តងទៀត ។ ខ្លឹមសារទាំងអស់ធ្វើឱ្យគេជឿជាក់ថា ប្រទេសថៃស្ថិតនៅក្រោមសមត្ថកិច្ចយ៉ាងដាច់ខាតរបស់តុលាការយុត្តិធម៌អន្តរជាតិ ។

តុលាការយុត្តិធម៌អន្តរជាតិ ពុំបានចាកចេញពីដំណោះស្រាយដែលតុលាការនេះបានលើកឡើងនៅក្នុងរឿងក្តីស្តីពីគ្រោះថ្នាក់នៅផ្លូវអាកាស ចុះថ្ងៃទី ២៧-០៧-១៩៥៥ រវាងប្រទេសប៊ុលហ្គារី និងអ៊ីស្រាអែល ហើយតុលាការយុត្តិធម៌អន្តរជាតិបានរំលឹកសាជាថ្មីទៀត អំពីយន្តការនៃការទទួលស្គាល់សមត្ថកិច្ចយ៉ាងដាច់ខាតរបស់តុលាការនេះ ។ ការផ្ទេរសេចក្តីប្រកាសរបស់តុលាការអចិន្ត្រៃយ៍យុត្តិធម៌អន្តរជាតិ ត្រូវបានកំណត់ត្រឹមតែសេចក្តីប្រកាសរបស់បណ្តាប្រទេសជាសមាជិកដើមរបស់អង្គការសហប្រជាជាតិប៉ុណ្ណោះ ហើយមាត្រា ៣៦ កថាខណ្ឌទី ២ នៃលក្ខខន្តិកៈ មានដើមកំណើតគ្រាន់តែអនុវត្តនាសម័យអន្តរកាល ។ លោកសាស្ត្រាចារ្យ J.P. Cot បានវិភាគក្នុងផ្នែកនេះថា ដំណោះស្រាយរបស់តុលាការយុត្តិធម៌អន្តរជាតិ គឺត្រូវបញ្ចូលគោលការណ៍សមភាពនៃបណ្តាប្រទេសសមាជិករបស់អង្គការសហប្រជាជាតិ ដោយផ្តល់នូវការការពារការបង្ហាញឆន្ទៈរបស់បណ្តារដ្ឋទាំងនោះ[177] ។

ក្នុងករណីការភ័ន្តច្រឡំនេះ តុលាការឆ្លើយតបដោយអវិជ្ជមាននៅក្នុងសារណារបស់ប្រទេសថៃ ។ តុលាការបានគូសបញ្ជាក់សាជាថ្មីឡើងវិញនូវថ្ម្រីស្តី ដែលក្នុងនោះ ការភ័ន្តច្រឡំត្រូវតែមានការទាក់ទងជាមួយនឹងមូលដ្ឋានសំខាន់នៃការភ្ជាប់កាតព្វកិច្ច ដូចជា រដ្ឋមួយពុំអាចបង្ហាញឆន្ទៈរបស់ខ្លួននោះទេ បើសិនជារដ្ឋនេះ ពុំបានប្រព្រឹត្តនូវការបង្ហាញនេះទេ ។ ប្រទេសថៃពុំបានបដិសេធចេតនារបស់ខ្លួនក្នុងការទទួលយកតុលាការនោះទេ តែប្រទេសថៃលើកឡើងនូវបែបបទដែលប្រទេសនេះបានធ្វើសេចក្តីប្រកាស ពុំអនុញ្ញាតឱ្យខ្លួនទទួលបាននូវលទ្ធផលដែលខ្លួនចង់បាននោះទេ ។ តុលាការចាត់ទុកថា ជម្រើសនៃមធ្យោបាយពុំច្បាស់លាស់ បង្កើតបានជាការភ័ន្តច្រឡំនៃសិទ្ធិ ប៉ុន្តែ ក្នុងរឿងប្រាសាទព្រះវិហារ ការភ័ន្តច្រឡំរបស់ប្រទេសថៃពុំមានអានុភាពយ៉ាងដូច្នោះទេ ។ សេចក្តីប្រកាសឆ្លើយតបទៅនឹងតម្រូវការខាងផ្នែកទម្រង់ ដោយត្រូវដឹងអំពីការតម្កល់សេចក្តីប្រកាសនេះនៅអគ្គលេខាធិការដ្ឋានរបស់អង្គការសហប្រជាជាតិ ។ ហេតុដូច្នេះ ប្រសិនបើការភ័ន្តច្រឡំអាចធ្វើឱ្យមានប៉ះពាល់ដល់ការបង្ហាញឆន្ទៈរបស់ប្រទេសថៃ ការភ័ន្តច្រឡំនេះ ពុំបានរារាំងឱ្យប្រទេសថៃអាចបំពេញនូវទម្រង់លិខិតដោយមានសុពលភាពនោះទេ ។

តុលាការពិនិត្យនាដំណាក់កាលទី ២ ភាពសារៈសំខាន់នៃការបង្ហាញឆន្ទៈ ។ សេចក្តីប្រកាសនៅឆ្នាំ ១៩៥០ បានធ្វើការកត់ចំណាំនូវការសម្តែងឆន្ទៈ និងតម្រេកក្នុងការទទួលយកកាតព្វកិច្ចអន្តរជាតិ ។ តុលាការបានសន្និដ្ឋានថា ឆន្ទៈពិតប្រាកដរបស់ប្រទេសថៃពុំត្រូវបានទទួលរងនូវការខូចខាតនោះទេ ។

[177] Cot (J.P.), *A.F.D.I.*, 1961, p. 241.

Scanned with CamScanner

យើងកត់សម្គាល់ឃើញថា សាលដីកាចុះថ្ងៃទី ២៦-០៥-១៩៦១ បានឯកភាពយ៉ាងច្បាស់លាស់អំពីគោលការណ៍នៃការភ័ន្តច្រឡំក្នុងនីតិអន្តរជាតិ ប៉ុន្តែ សាលដីកានេះទទួលរងនូវភាពអន់ខ្សោយ ក្នុងវិធានដែលសាលដីកាពុំបានបញ្ជាក់ឱ្យបានស៊ីជម្រៅ ។ សាលាដីកានេះពុំបានបង្ហាញអំពីកម្រិតនៃភាពធ្ងន់ធ្ងរដែលទាញចេញពីកម្រិតនេះ អចមិអាចជាមូលហេតុនៃការប្រកាសមោឃភាពលិខិតនោះទេ ហើយក៏ពុំបានលើកឡើងថា តើការភ័ន្តច្រឡំនៃអង្គច្បាប់ត្រូវតែគិតគូក្នុងលក្ខណៈដូចគ្នាទៅនឹងការភ័ន្តច្រឡំនៃអង្គហេតុដែរ ឬទេ ? ទីបញ្ចប់ តុលាការពុំបានពិនិត្យអំពីអានុភាពនៃការភ័ន្តច្រឡំនោះទេ ។

ទម្រង់ដំបូងនៃយុត្តិសាស្ត្រដែលត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៦១ មានលក្ខណៈខ្លះចន្លោះច្រើន ដើម្បីអនុញ្ញាតឱ្យបង្កើតបានជាទ្រឹស្តីនៃការភ័ន្តច្រឡំគ្រប់គ្រាន់ ហើយពេញលេញ សម្រាប់ធានាសន្តិសុខគតិយុត្តរបស់បណ្តារដ្ឋទាំងឡាយ ។ ប៉ុន្តែ ក្រៅពីការពង្រឹងនៃការទទួលយកយុត្តិសាស្ត្រដែលបង្ហាញនូវការប្រុងប្រយ័ត្តមួយចំនួនរបស់តុលាការ យើងអាចឃើញដូចគ្នាដែរនូវឆន្ទៈរបស់តុលាការនេះ ក្នុងការទទួលស្គាល់យ៉ាងពិតប្រាកដនូវអត្ថិភាពនៃការភ័ន្តច្រឡំនៅក្នុងនីតិអន្តរជាតិសាធារណៈ ។ ប៉ុន្តែ យើងត្រូវរង់ចាំសាលដីកាឆ្នាំ ១៩៦២ ដើម្បីទទួលបាននូវចម្លើយថ្មី ដែលឆ្លើយតបទៅនឹងសំណួរទាំងឡាយដែលត្រូវបានលើកឡើងនៅក្នុងសេចក្តីសម្រេចឆ្នាំ ១៩៦១ ។

II. ការភ័ន្តច្រឡំ : របបគតិយុត្តមួយដែលត្រូវបានទទួលយកនៅក្នុងនីតិអន្តរជាតិថ្ងៃមាន

សាលដីកាឆ្នាំ ១៩៦២ អនុញ្ញាតឱ្យបំពេញបន្ថែមនូវរបបគតិយុត្តនៃការភ័ន្តច្រឡំដោយបង្កើត ម៉្យាងនូវបដិបញ្ញត្តចំពោះគោលការណ៍ (A) និងម៉្យាងទៀត នូវជំហានចុងក្រោយនៃយុត្តិសាស្ត្រ មុននឹងបញ្ចូលវាទៅក្នុងនីតិអនុសញ្ញា (A) ។

A. ការបង្កើតជាយុត្តិសាស្ត្រនូវរបបគតិយុត្តនៃការភ័ន្តច្រឡំឱ្យមានលក្ខណៈការពារលេចធ្លោ :

ដោយប្រើប្រាស់នូវការភ័ន្តច្រឡំដើម្បីធ្វើជាមូលដ្ឋាននៃការការពារ ប្រទេសថៃបានផ្តល់ឱកាសទៅដល់តុលាការយុត្តិធម៌អន្តរជាតិដើម្បីបញ្ជាក់អំពីរបបគតិយុត្តនៃការភ័ន្តច្រឡំដែលបានផ្តល់ជាទម្រង់ជាលើកដំបូងនៅពីខាងលើ ។

ក្នុងដំណាក់កាលទី ២ នៃរឿងក្តីប្រាសាទព្រះវិហារ ទាក់ទងនឹងអង្គសេចក្តី ប្រទេសថៃ បានលើកឡើងសាជាថ្មីនូវការភ័ន្តច្រឡំទាក់ទងនឹងការឯកភាពអំពីខ្សែបន្ទាត់ព្រំដែនដែលត្រូវបានធ្វើឡើងនៅលើផែនទី ដែលនេះគឺជាការភ័ន្តច្រឡំមួយផ្តល់នូវអានុភាពកាត់បន្ថយអធិបតេយ្យភាពរបស់ប្រទេសកម្ពុជា ។ ផែនទីនៃឧបសម្ព័ន្ធទី ១ បានដាក់ស្ទឹងអូរតាសែមដែលនៅព័ទ្ធជុំវិញភ្នំទ្រព្យ នៅភាគខាងជើងឆ្សៀងខាងលិចនៃប្រាសាទព្រះវិហារ បន្ទាប់មកចាក់ចូលទៅក្នុងបាសាំងណាមសែន និងបាសាំងមេគង្គនៅភាគខាងត្បូង ។ ដូច្នេះ ប្រទេសថៃបានរត់ខ្សែបន្ទាត់នៃការបែងចែកផ្លូវទឹកស្ថិតនៅជិតភាគខាងជើងនៃខ្សែបន្ទាត់ចំណោទទេ ហើយប្រាសាទព្រះវិហារស្ថិតនៅក្នុងដែនដីនៃប្រទេសកម្ពុជា។ ប៉ុន្តែ រវាងឆ្នាំ ១៩៣៤-៣៥ ឯកសាររបស់ថៃបានកត់សំគាល់ឃើញថា តាមការពិត ស្ទឹងអូរតាសាមមានប្រភពមកពីភាគខាងត្បូងនៃភ្នំទ្រព្យ ហើយថា ទឹកនៅភាគខាងជើងឆ្សៀងខាងលិចនៃប្រាសាទព្រះវិហារបានហូរចាក់ទៅក្នុងបាសាំងណាមមុននេះ

Scanned with CamScanner

ប្រទេសថៃ ។ បញ្ហាក្នុងន័យនេះគឺត្រូវដឹងថា តើបន្ទាត់បែងចែកទឹកពិតប្រាកដនៅត្រង់កន្លែងណា ? ហើយថា តើការភ័ន្តច្រឡំលើស្ថិងអូរតាសាមមានលក្ខណៈសំខាន់ដែរឬទេ ?

ប្រទេសថៃបានចាត់ទុកថា គំនូសនៅលើផែនទីនៃឧបសម្ព័ន្ធ ១ ងាកចេញជូនកាលច្រើនជាង ២ គីឡូម៉ែត្រពីបន្ទាប់បែងចែកទឹក ។ ប្រទេសកម្ពុជាបានឆ្លើយវិញថា សញ្ញាណនៃចម្ងាយមានលក្ខណៈបន្ទាប់បន្សំ ហើយថា ផ្ទៃដីប្រវែង ២ គីឡូម៉ែត្រ ដែលពុំអាចរស់នៅបាន ត្រូវបានឈ្លានពានដោយព្រៃធម្មជាតិ ពុំអាចកំណត់អំពីមូលហេតុដែលនាំឱ្យមានបញ្ហាចំពោះបន្ទាត់ព្រំដែនបាននោះទេ ។ ម៉្យាងវិញទៀត រាជរដ្ឋាភិបាលខ្មែរបានលើកបង្ហាញថា លក្ខណៈសំខាន់នៃការភ័ន្តច្រឡំត្រូវតែវាយតម្លៃធ្យៀបពីភាពខុសគ្នា ទៅនឹងកម្មវត្ថុ មានន័យថា ជាប្រាសាទព្រះវិហារ ។ ប៉ុន្តែ អ្នកជំនាញការនៅប្រទេសកម្ពុជាបានបញ្ជាក់ថា បន្ទាត់បែងចែងទឹកបន្សល់ទុកប្រាសាទព្រះវិហារមកឱ្យកម្ពុជា ។ តុលាការយុត្តិធម៌អន្តរជាតិពុំបានសម្រេចនៅលើចំណុចនេះទេ ហើយតុលាការមានភាពពេញចិត្តផ្លាស់ប្តូរកន្លែងរបស់ខ្លួនទៅក្នុងការទទួលយកអំណះអំណាងទៅវិញ ។

តុលាការកំណត់ករណីបីយ៉ាង ដែលយោងតាមបដិប្បញ្ញត្តិ ការភ័ន្តច្រឡំសំខាន់ពុំមានការប៉ះពាល់ទៅដល់សុពលភាពនៃឆន្ទៈនោះទេ ។ ហេតុដូច្នេះ *" ភាគីម្ខាងពុំអាចលើកឡើងនៃការភ័ន្តច្រឡំដូចជាអធិមនៃការបង្ហាញឆន្ទៈនោះទេ បើសិនភាគីនោះបានចូលរួមក្នុងការប្រព្រឹត្តន្ទវការភ័ន្តច្រឡំដោយទង្វើផ្ទាល់ខ្លួន. បើសិនជាគាត់ស្ថិតនៅក្នុងស្ថានភាពដែលអាចធ្យើសវាងការភ័ន្តច្រឡំបាន ឬប្រសិនបើបណ្តាស្ថានភាពជាច្រើនត្រូវបានចាត់ទុកជាស្ថានភាពដែលគាត់បានដឹងអំពីភាពដែលអាចនាំឱ្យមានការភ័ន្តច្រឡំ* " ។ តុលាការយុត្តិធម៌អន្តរជាតិប្រកាន់យកនូវជំហរដ៏តឹងរឹងមួយ ក្នុងករណីដែលតុលាការនេះយល់ឃើញថា គុណភាព និងសមត្ថកិច្ចរបស់បុគ្គល ដែលបានឃើញផែនទីខាងភាគីប្រទេសថៃ ធ្វើឱ្យពួកគេមានការលំបាក នូវទង្វើដែលប្រទេសថៃអាចលើកឡើងការភ័ន្តច្រឡំតាមច្បាប់ ។

បដិបញ្ញត្តិទាំងបីយ៉ាងដែលត្រូវបានកំណត់ដោយតុលាការយុត្តិធម៌អន្តរជាតិបានកាត់បន្ថយនូវលក្ខណៈសំខាន់នូវលទ្ធភាពក្នុងការបង្ហាញការភ័ន្តច្រឡំ ។ វាជាការកំរៃដែលថា ភាគីម្ខាងពុំសហប្រតិបត្តិការទៅក្នុងការបង្កើតព្រំដែន និងចូលរួមទៅក្នុងការភ័ន្តច្រឡំតាមរយៈទង្វើរបស់ខ្លួន ។ ការកាត់បន្ថយដ៏មានសារៈសំខាន់នេះ នាំឱ្យលោកសាស្ត្រាចារ្យ Jean Combacau ចាត់ទុកថា ក្នុងលក្ខខណ្ឌទាំងនេះ វាគឺជាករណីប្រធានស័ក្តជាជាងការភ័ន្តច្រឡំ ។ សាលដីកានេះធ្វើឱ្យមានការកត់សំគាល់ផ្ទុយក្នុងការបង្កើតទ្រឹស្តីនៃការភ័ន្តច្រឡំនៅក្នុងនីតិអន្តរជាតិ ដោយបន្ថែមនូវធាតុផ្សំចាំបាច់ទៅដល់ភាពមានជីវិតអាចរស់បាននៃនីតិអន្តរជាតិ ។

ការវិវត្តន៍នៃនីតិអន្តរជាតិថ្មីមានត្រូវបានធ្វើឡើងដូចដែលយើងបានឃើញ តាមរយៈយុត្តិសាស្ត្របន្ថែម និងការបញ្ជាក់អះអាងសាជាថ្មី ។ ប៉ុន្តែ ផលប្រយោជន៍គតិយុត្តនៃរឿងក្តីប្រាសាទព្រះវិហារ ត្រូវបានបង្កើតកាន់តែមានលក្ខណៈជាទម្រង់ថែមទៀត តាមរយៈនីតិវិធីមានដែលត្រូវបានធ្វើឡើងបន្ទាប់ពីសេចក្តីសម្រេចនេះ ។

B. ការចិត្តង្ហន់ជាបន្តបន្ទាប់នៃនីតិអន្តរជាតិអាស្រ័យនឹងរបបគតិយុត្តនៃការភ័ន្តច្រឡំ :

សាលដីកាឆ្នាំ ១៩៦២ បានបង្កើតជាការចូលរួមយ៉ាងពិតប្រាកដនៃលទ្ធិ ហើយធ្វើឡើងតាមរបៀបពីរយ៉ាង : ជាដំបូង សាលដីកាបានបញ្ជាក់អំពីចរិតលក្ខណៈពិសេសនៃអានុភាពនៃការភ័ន្តច្រឡំនៅក្នុងវិវាទនៃការកំណត់ព្រំដែនដី

Scanned with CamScanner

គោក ។ បន្ទាប់មក របបគតិយុត្តនៃការភ័ន្តច្រឡំត្រូវបានចាត់ទុកជាផ្នែកមួយដែលត្រូវបានបញ្ចូលសាជាថ្មីឡើងវិញដោយនីតិអនុសញ្ញា ។

យើងអាចបង្ហាញជាដំបូងអំពីភាពចាំបាច់នៃការរៀបចំទ្រឹស្តីអធមិនៃការបង្ហាញឆន្ទៈ ដូចជាសញ្ញាណរបស់វានៅក្នុងនីតិឯកជន ដើម្បីយកចិត្តទុកដាក់ទៅលើលក្ខណៈពិសេសនៃនីតិអន្តរជាតិ ។ នៅក្នុងការអនុវត្តអន្តរជាតិ ការភ័ន្តច្រឡំនាំឱ្យមានការកែប្រែសទ្ធិសញ្ញាជាជាងការលុបចោលការបង្ហាញឆន្ទៈ ។ ដំណោះស្រាយនេះត្រូវបានពន្យល់ជាពិសេសតាមរយៈទង្វើដែលថា សម្មតិកម្មជាច្រើនក្នុងការលើកឡើងនៃការភ័ន្តច្រឡំទាក់ទងនឹងបញ្ហាការភ័ន្តច្រឡំ ជាពិសេសភាពពុំច្បាស់លាស់នៃផែនទី ។

ក្នុងរឿងក្តីប្រាសាទព្រះវិហារ ចរិតលក្ខណៈពិសេសមួយទៀត អាចត្រូវបានធ្វើការកត់សម្គាល់ ដោយហេតុថាការដកពាក្យបណ្តឹងអនុញ្ញាតឱ្យមានការលុបចោលការភ័ន្តច្រឡំ ។ វាគឺជាបច្ចេកទេសនៃការចរចាភ្លាម។ ។ វាពុំផ្តល់អានុភាពនៃនីតិឯករាជ្យអ្វីទាំងអស់ ។ វាគ្រាន់តែជាមធ្យោបាយដែលតាមរយៈនោះ រដ្ឋទាំងឡាយបង្ហាញឆន្ទៈរបស់ខ្លួនប៉ុណ្ណោះ ។ តាំងពីឆ្នាំ ១៩០៨-១៩០៩ ប្រទេសថៃ យល់ព្រមទទួលយកផែនទីដែលមានភ្ជាប់នៅឧបសម្ព័ន្ធទី ១ ។ ការដកពាក្យបណ្តឹងផ្តល់នូវប្រសិទ្ធិភាពដាច់ខាតទៅផែនទីដែលខ្វះខាត ។ គោលបំណងនៃការដកពាក្យបណ្តឹង គឺធានានូវស្ថេរភាពគតិយុត្ត ដោយបញ្ចូលវាទៅក្នុងអង្គហេតុ ។ ភាពវត្ថុវិស័យតែមួយនេះ ចូលរួមពន្យល់នូវភាពបន្ទាប់បន្សំនៃការភ័ន្តច្រឡំក្នុងរឿងកំណត់ព្រំដែនដីគោក ។ តុលាការយុត្តិធម៌អន្តរជាតិ សុខចិត្តផ្តល់ភាពពេញចិត្តទៅដល់ស្ថេរភាពខាងព្រំដែន ជាជាងការប្រកាសមោឃភាពនៃសទ្ធិសញ្ញា ឬការចាប់បង្ខំទទួលយកនូវគំនូសយ៉ាងដាច់ខាតមួយដែលផ្តាច់ចេញពីការពិត ។

ក្រៅពីការចូលរួមក្នុងយុត្តិសាស្ត្រនៃឧបសម្ព័ន្ធ ដែលត្រូវបានលើកឡើងសាជាថ្មីដោយយុត្តិសាស្ត្រផ្សេងទៀតជាបន្តបន្ទាប់ រឿងក្តីប្រាសាទព្រះវិហារ ត្រូវបានបញ្ចូលមួយផ្នែកធំមួយ ដោយនីតិអនុសញ្ញា ។

អនុសញ្ញាទីក្រុងវ៉ែន ស្តីពីសិទ្ធិនៃសទ្ធិសញ្ញាចុះថ្ងៃទី ២៣-០៥-១៩៦៩ បានចងក្រងវិធាននៃការភ័ន្តច្រឡំសំខាន់ក្នុងមាត្រា ៤៨ កថាខណ្ឌទី ១ ។ ប៉ុន្តែ យោងតាមចំនួនភាគច្រើននៃលទ្ធិ បទប្បញ្ញត្តិនេះទទួលស្គាល់តែការភ័ន្តច្រឡំអង្គហេតុប៉ុណ្ណោះ ប៉ុន្តែ សាលដីកាឆ្នាំ ១៩៦១ បានលើកឡើងជាឥណ្ឌីភាពនូវការភ័ន្តច្រឡំលើអង្គច្បាប់ ។ យើងគួរកត់សម្គាល់ថា ការភ័ន្តច្រឡំលើអង្គច្បាប់ និងអង្គហេតុអាចនាំឱ្យមានភាពលំបាកក្នុងការបែងចែកការភ័ន្តច្រឡំទាំងពីរនេះ ជាពិសេសនៅពេលដែលវាជាបញ្ហានៃការកំណត់ឈ្មោះគតិយុត្ត។ ដំណោះស្រាយដែលត្រូវបានទទួលស្គាល់ដោយអនុសញ្ញា ត្រូវបានពន្យល់យ៉ាងច្បាស់ តាមរយៈការបំភ្លឺតាមន័យគតិយុត្ត ហើយជាលទ្ធផល បញ្ហាសន្តិសុខសម្រាប់បណ្តារប្រទេសជាភាគី ។

លើសពីនេះទៀត កថាខណ្ឌទី ២ នៃបទប្បញ្ញត្តិខាងលើទទួលយកនូវបដិបញ្ញត្តិពីរ ក្នុងចំណោមបដិបញ្ញត្តិទាំងបីដែលលើកឡើងដោយតុលាការយុត្តិធម៌អន្តរជាតិក្នុងរឿងក្តីប្រាសាទព្រះវិហារ ដែលក្នុងនោះចែងថា " *កថាខណ្ឌទី ១ ពុំត្រូវបានអនុវត្តទេ នៅពេលដែលរដ្ឋនោះចូលរួមចំណែកទៅក្នុងការភ័ន្តច្រឡំនោះតាមរយៈឆន្ទៈរបស់ខ្លួន ឬនៅពេលដែលស្ថានភាពទាំងឡាយជាស្ថានភាពដែលរដ្ឋនោះត្រូវតែត្រូវបានជូនដំណឹងនូវលទ្ធភាពនាំឱ្យមានការភ័ន្តច្រឡំ* " ។

Scanned with CamScanner

យោងតាមបទបញ្ញត្តិទាំងពីរ ខាងលើនេះ យើងអាចទទួលស្គាល់ថា សាលដីកាទាំងនេះទាក់ទងនឹងរឿងវិវាទ រវាងប្រទេសកម្ពុជា និងប្រទេសថៃ ដែលប្រភពដើមនៃរឿងវិវាទមានលក្ខណៈបែបបុរាណ បានជះឥទ្ធិពលយ៉ាងសំខាន់ ទៅដល់នីតិអន្តរជាតិសាធារណៈទាំងនៅក្នុងទិដ្ឋភាពយុត្តិសាស្ត្រ និងអនុសញ្ញារបស់វា ។

ទោះបីជាមានភាពសាមញ្ញ វិវាទនេះនៅតែផ្តល់នូវផលប្រយោជន៍ដល់លទ្ធិ នាពេលបច្ចុប្បន្ននេះ ។ សាលដីកា ទាំងពីររបស់តុលាការយុត្តិធម៌អន្តរជាតិ បានចូលរួម តាមរយៈការបំពេញបន្ថែម ទៅក្នុងការបង្កើតនូវទ្រឹស្តីនៃការភ័ន្ត ច្រឡំនៅក្នុងនីតិអន្តរជាតិសាធារណៈវិជ្ជមាន ។ ប៉ុន្តែ តុលាការក៏មានឱកាសដូចគ្នាដែរ ក្នុងការបញ្ជាក់អំពីយន្តការនៃការ យល់ព្រមទទួលយកសមត្ថកិច្ចយ៉ាងដាច់ខាត ឬបែបបទនៃការដកពាក្យបណ្តឹង ។ រឿងក្តីប្រាសាទព្រះវិហារ នឹងធ្វើឱ្យ មានកត់សម្គាល់ចំពោះការវិវត្តន៍នៃនីតិអន្តរជាតិ តាមរយៈលក្ខណៈនៃការបង្កើតថ្មី នាសម័យនោះ ក្នុងគោលដៅការពារ ដល់ឆន្ទៈលើកឡើងដោយរដ្ឋទាំងឡាយ ។

វិវាទនេះគឺជាវិវាទដែនដី ប៉ុន្តែ តុលាការយុត្តិធម៌អន្តរជាតិ បានលើកឡើងនូវភស្តុតាងតាមបែបបុរាណ ហេតុ ដូច្នេះហើយ យើងបានជ្រើសរើសពុំបកស្រាយទិដ្ឋភាពនេះក្នុងការការសិក្សានេះ ។ ប៉ុន្តែ តុលាការបានចូលរួមបង្កើតវិធី សាស្ត្រនៃការកំណត់ព្រំដែនដែនដីតាមយុត្តិសាស្ត្រ ហើយតាមរយៈនេះ តុលាការបានកំណត់សម្គាល់ថា នៅក្នុងមុខវិជ្ជា នេះ ជាដំបូងបំផុត គឺសំដៅទៅលើការការពារអធិបតេយ្យភាពរបស់រដ្ឋទាំងឡាយ និងធានានូវស្ថេរភាពតាមព្រំដែន ។

Scanned with CamScanner

បញ្ជីរាយឈ្មោះចំណងជើង

សេចក្តីផ្តើម..... ១

តាគធី ១ : សណាគបំត្រសេចក្តីសម្រេចរបស់តុលាការ..... ៥

ផ្នែកធី ១ : ចំណេះដឹងផ្សេងៗចាំបាច់ត្រូវមានដើម្បីឱ្យយល់បានល្អពីសេចក្តីសម្រេចរបស់តុលាការ ៧

តថាខណ្ឌធី១ : ចំណេះដឹងពីការរៀបចំផ្នែកយុត្តាធិការ..... ៧

ក. គណយុត្តាធិការឯកនិយម..... ៧

ខ. ការរៀបចំជាឯកសារីជ្រុងនៃសាលាជម្រះក្តី..... ៧

១. សាលាជំរុះក្តីថ្នាក់ធីមួយ..... ៨

២. សាលាជម្រះក្តីថ្នាក់ធីពីរ..... ៩

២. សាលាជម្រះក្តីកំពូល..... ៩

៣. តថាខណ្ឌធី ២ : ការយល់ដឹងអំពីនីតិវិធី..... ០៩

ក. នីតិវិធីរដ្ឋប្បវេណី ១០

ខ- នីតិវិធីព្រហ្មទណ្ឌ ១៥

១_ ដំណាក់កាលនៃការស្វែងរកបទល្មើស និងការធ្វើបណ្តឹងរាជ្ជា.....១៦

១.១. ឧតរចាលយុត្តិធម៌..... ១៦

២.២. ព្រះរាជអាជ្ញា.....១៧

២_ ដំណាក់កាលស៊ើបអង្កេត..... ១៨

៣_ ដំណាក់កាលជំនុំជម្រះ.....២៣

តថាខណ្ឌធី៣. ការយល់ដឹងពីភាក្យស័ព្ទគតិយុត្តរបស់សេចក្តីសម្រេចតុលាការ..... ២៥

ក. សង្ខារន្តុក្រមពាក្យច្បាប់ ២៥

ខ. ការផ្សំចង្អាក់លើការយល់ដឹងពីភាក្យស័ព្ទគតិយុត្ត..... ៣១

១_លំបាក់..... ៣១

២_កិរិណា..... ៣៣

តថាខណ្ឌធី ៤ : ការសិក្សាពីវចនាសម្ព័ន្ធនៃសេចក្តីសម្រេចរបស់តុលាការ ៣៤

ក. នៅក្នុងនីតិតម្កូជាចាប់ពីពេលទទួលបានឯកភាវតាព..... ៣៣

១_សាលដីកាសាលាឥន្ទីយ..... ៣៣

Scanned with CamScanner

២-សាលដីកាសាលាឧទ្ធរណ៍..... ៣៨

ខ. នៅក្នុងនីតិវិធីមានរបស់តម្កល់ជាបច្ចុប្បន្ន..... ៤២

១-សាលដីកាតុលាការកំពូល..... ៤២

២-សាលដីកាសាលាឧទ្ធរណ៍..... ៥០

ផ្នែកទី ២ : និតិសាស្ត្រនៃការធ្វើសេចក្តីសម្រេចរបស់តុលាការ :..... ៥៩

អនុខណ្ឌទី ១ : និតិសាស្ត្រនៃការគាំទ្រសេចក្តីសម្រេចរបស់តុលាការ .. ៥៩

ក. ការរៀបចំនិតិវិធីជាបឋម..... ៥៩

ខ. ការគាំទ្រសេចក្តីសម្រេចរបស់តុលាការ..... ៦៨

១. អត្ថហេតុ..... ៦៨

២. នីតិវិធី ៦៨

៣. បញ្ហាគតិយុត្ត "អាចមានមួយ ឬច្រើន"..... ៦៨

៤. សេចក្តីសម្រេចរបស់ឃុំក្តាធិការដែលឧទ្ធរណ៍ពាក្យបណ្តឹង..... ៧០

អនុខណ្ឌទី ២ : លំហាត់អនុវត្តធ្វើសេចក្តីសម្រេច..... ៧០

ក. នីតិរដ្ឋប្បវេណី..... ៧0

១. សាលដីកា..... ៧០

២. កំណែ ៧០

ខ. នីតិព្រហ្មទណ្ឌ..... ៧៦

១. សាលដីកា..... ៧៨

២. កំណែ ៧៨

គ. នីតិពាណិជ្ជកម្ម..... ៧៨

១. សាលដីកា ៨០

២. កំណែ ៨០

ឃ. នីតិការងារ..... ៨៦

១. សាលដីកា..... ៨៧

២. កំណែ ៩៧

ផ្នែកទី ៣ : សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ..... ៩៩

Scanned with CamScanner

តថាខណ្ឌទី ១: មុខងារនៃក្រុមប្រឹក្សាធម្មនុញ្ញ..... ៩៩

តថាខណ្ឌទី ២ : រចនាសម្ព័ន្ធនៃសេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ..... ៩៩

១. សេចក្តីសង្ខេបអំពីធម្មនុញ្ញតាគា..... ១០០

២. សេចក្តីសង្ខេបអំពីការបកស្រាយអត្ថបទច្បាប់..... ១០០

៣. សេចក្តីសង្ខេបអំពីវិធានបោះឆ្នោត..... ១០២

តថាខណ្ឌទី ៣ : វិធីសាស្ត្រក្នុងការធ្វើសលាកប័ត្រសេចក្តីសំរេចក្រុមប្រឹក្សាធម្មនុញ្ញ ១០៩

ក-អង្គហេតុ..... ១០៩

ខ-នីតិវិធី..... ១០៩

គ-បញ្ហាគតិយុត្ត..... ១១០

ឃ-ដំណោះស្រាយ..... ១១០

ង-អនុភាព..... ១១០

តថាខណ្ឌទី ៤ : សំហាត់អនុវត្ត..... ១១១

ក-ប្រធាន..... ១១១

ខ-តំណែ..... ១១១

ភាគទី ២ : អត្ថាធិប្បាយអត្ថបទតាមន័យទូលាយ..... ១១៧

ផ្នែកទី ១ : បរិមាណាធិប្បាយអត្ថបទ និងអត្ថបទរបស់អ្នកនិពន្ធ..... ១១៧

តថាខណ្ឌទី ១ : ការបច្ចាញ្ញាពីរបៀបអត្ថាធិប្បាយអត្ថបទ និងអត្ថបទរបស់អ្នកនិពន្ធ ១១៧

តថាខណ្ឌទី ២ : សំហាត់អនុវត្តសម្រាប់ស្រង់ចេញនូវគំនិតសំខាន់ៗពីអត្ថបទ និងរៀបចំគំនិតទាំងនេះ ១២១

១. ផ្ទៃខសេចក្តី..... ១២១

២. តំណែ..... ១២៣

តថាខណ្ឌទី ៣ : សំហាត់អនុវត្តវិធីសាស្ត្រតាមដំណាក់កាលនីមួយៗ ១២៦

ក. ការអធិប្បាយលើមាត្រា ៨ នៃក្រឹត្យ-ច្បាប់លេខ ៣៨ ចុះថ្ងៃទី ២៨-១០-១៩៨៨ ស្តីពីតុលាការ និងការទទួលខុសត្រូវក្រៅតុលាការ..... ១២៦

ខ- .តំណែសំហាត់ ១២៧

តថាខណ្ឌទី ៤ : សំហាត់អនុវត្តវិធីសាស្ត្រ..... ១៣០

Scanned with CamScanner

ក. និតិពាណិជ្ជកម្ម..... ១៣០
១. ប្រធានបទ..... ១៣០
២. សេចក្តីអត្ថាធិប្បាយ ១៣០
ខ. និតិការងារ..... ១៣៧
១. ប្រធានបទ..... ១៣៧
២. កំណែ ១៣៨
គ. និតិសាធារណៈ..... ១៤៣
១. ប្រធានបទ..... ១៤៣
២. កំណែ ១៤៣
ផ្នែកទី ២ : វិធីសាស្ត្រអត្ថាធិប្បាយសេចក្តីសម្រេចរបស់តុលាការ..... ១៤៩
កថាខណ្ឌទី ១ : ការបង្ហាញវិធីសាស្ត្រ ១៤៩
ក. យល់ប្រធានបទ..... ១៤៩
ខ. ការស្រាវជ្រាវរកហេតុផ្សំនៃចម្លើយ..... ១៤៩
១. ជំរឿនឆ្ងាយរាល់ហេតុផ្សំនៅក្នុងសេចក្តីសម្រេច ១៥០
២. ការស្វែងរកហេតុផ្សំនៅក្នុងបរិបទ..... ១៥០
២.១. អត្ថន័យនៃសេចក្តីសម្រេច..... ១៥០
២.២. តំម្លៃនៃសេចក្តីសម្រេច..... ១៥០
២.៣. ខ្លឹមសារនៃដំណោះស្រាយ..... ១៥១
គ. តាក់តែងបន្ថែ ១៥២
១. រៀបចំសេចក្តីអត្ថាធិប្បាយរបស់អ្នក តាមរបៀបតក្កវិជ្ជា.....១៥២
២. ទម្រង់នៃបន្ថែរបស់អ្នក ១៥២
ឃ. សរសេរសេចក្តីអត្ថាធិប្បាយសាលដីកា ១៥២
១. សេចក្តីផ្តើម..... ១៥២
២. ការសរសេរ..... ១៥៣
កថាខណ្ឌទី ២ : លំហាត់អនុវត្តលើនិតិរដ្ឋប្បវេណី..... ១៥៣
ក. សេចក្តីថ្លែង..... ១៥៣
ខ. កំណែ..... ១៥៧

Scanned with CamScanner

ភាគទី ៣ : លំហាត់អនុវត្ត.....១៦២

ផ្នែកទី ១ : ចំណេះដឹងចាំបាច់នូវធាតុផ្សំចាំបាច់ក្បាយដើមបីយល់ឱ្យបានល្អអំពីលំហាត់អនុវត្ត..... ១៦២

កថាខណ្ឌទី ១ : ការយល់ដឹងអំពីវិចារណកិច្ចគតិយុត្ត.....
១៦២

ក. ការបង្ហាញអំពីវិចារណកិច្ចគតិយុត្ត ១៦២

ខ. លំហាត់អនុវត្ត ១៦៤

១. លំហាត់..... ១៦៤

១.១. លំហាត់ទី ១..... ១៦៤

១.២. លំហាត់ទី ២ ..... ១៦៤

២. កំណែ..... ១៦៤

២.១. កំណែលំហាត់ទី ១..... ១៦៤

២.២. កំណែលំហាត់ទី ២ ..... ១៦៥

កថាខណ្ឌទី ២ : ការឆ្លងផ្តើមក្នុងការកំណត់ចរិតលក្ខណៈគតិយុត្តនៃអន្តហេតុ... ១៦៥

ក. លំហាត់ ១៦៥

ខ. កំណែលំហាត់ដាក់ឆន្ទនិយការកំណត់ចរិតលក្ខណៈគតិយុត្ត..... ១៦៦

ផ្នែកទី ២ : វិធីសាស្ត្រលំហាត់អនុវត្ត..... ១៦៨

កថាខណ្ឌទី ១ : ការបង្ហាញអំពីវិធីសាស្ត្រ ១៦៨

ក. វិធីសាស្ត្រ..... ១៦៨

ខ. ការប្រតិបត្តិភ្ជាប់ជាមួយនឹងវិធីសាស្ត្រនៃលំហាត់អនុវត្ត ១៧០

១. ការយល់ដឹងអំពីលំហាត់អនុវត្ត ១៧១

២. ការស្វែងរកសំណួរគតិយុត្ត ១៧៣

៣. ការស្វែងរកគោលការណ៍អនុវត្តចំពោះបញ្ហាគតិយុត្ត ១៧៣

៤. ការអនុវត្តគោលការណ៍ ឬវិធានទៅនឹងចំពោះអន្តហេតុ ១៧៣

៥. ការតាក់តែងលំហាត់អនុវត្ត ១៧៤

កថាខណ្ឌទី ២ : លំហាត់អនុវត្តវិធីសាស្ត្រ ១៧៩

ក. និតិរដ្ឋប្បវេណី ១៨០

១. អន្តហេតុ ១៨០

Scanned with CamScanner

២. កំណែលំហាត់ ១៨១

ខ. និតិពាណិជ្ជកម្ម..... ១៨៥

១. អត្ថហេតុ ១៨៥

២. កំណែ ១៩១

គ. និតិព្រហ្មទណ្ឌ ១៩១

១. អត្ថហេតុ..... ១៩២

២. កំណែ ១៩៦

ឃ. និតិការងារ ១៩៦

១. អត្ថហេតុ ១៩៧

២. កំណែ..... ២០២

ង. និតិរដ្ឋបាល ២០២

១. អត្ថហេតុ ២០២

២. កំណែ ២០២

ភាគទី ៤ : ប្រធានបែបបរិហារាធិប្បាយគតិយុត្ត..... ២០៦

ផ្នែកទី ១ : វិធីសាស្ត្រដោះស្រាយប្រធានបែបបរិហារាធិប្បាយ..... ២០៦

កថាខណ្ឌទី ១ : ការបង្ហាញវិធីសាស្ត្រ..... ២០៦

កថាខណ្ឌទី ២ : លំហាត់ទាក់ទងនឹងការរៀបចំបង្កើតល្អចំ..... ២១១

ក. លំហាត់..... ២១១

ខ. តំណែ..... ២១១

កថាខណ្ឌទី ៣ : ការអនុវត្តវិធីសាស្ត្រតាមដំណាក់កាលនីមួយៗរហូតដល់ដំណាក់កាលនៃការរៀបចំល្អចំ..... ២១៣

ក. ប្រធានបទ ២១៣

ខ. តំណែប្រធានបទ ២១៣

ផ្នែកទី ២ : លំហាត់អនុវត្តវិធីសាស្ត្រ..... ២២០

កថាខណ្ឌទី ១ : និតិរដ្ឋប្បវេណី..... ២២០

ក. ប្រធានបទ..... ២២0

ខ. តំណែ..... ២២0

Scanned with CamScanner

កថាខណ្ឌទី ២ : នីតិព្រហ្មទណ្ឌ..... ២២៥

ក. ប្រធានបទ..... ២២៥

ខ. កំណែ..... ២២៥

កថាខណ្ឌទី ៣ : នីតិពាណិជ្ជកម្ម..... ២៣១

ក. ប្រធានបទ..... ២៣១

ខ. កំណែ ២៣១

កថាខណ្ឌទី ៤ : នីតិការងារ..... ២៣៨

ក. ប្រធានបទ..... ២៣៨

ខ. កំណែ :..... ២៣៨

កថាខណ្ឌទី ៥ : នីតិសាធារណៈ..... ២៤០

ក. ប្រធានបទ..... ២៤០

ខ. កំណែ..... ២៤០

Scanned with CamScanner